

# មិលិន្ទបញ្ហា

## ភាគ ១

### កណ្ឌ ១ និង កណ្ឌ ២

ប្រវត្តិនិងសំណួរចម្លើយ របស់ព្រះចៅមិលិន្ទ និងព្រះនាគសេនត្ថេរ

បកប្រែពីភាសាភូមាដោយ ឧបាសក ឆែវឡ្សន៍ កបិលកាញ្ចន៍

បកប្រែជាខេមរភាសាដោយ ឧបាសិកា វណ្ណារី ទេពប្រណម្យ

# អនុមោទនាកថា

*ខ្ញុំព្រះករុណា អាត្មាភាព បានអានពិនិត្យពិច័យនូវខ្លឹមសារ និងអត្ថន័យ នៅក្នុងសៀវភៅ* **មិលិន្ទបញ្ហា** *នេះ យល់ឃើញថា គួរជាទីជ្រះថ្លា នឹងបានជាទិដ្ឋានុគតិ ដល់ព្រះភិក្ខុសង្ឃ និងពុទ្ធមាមកជនទូទៅ ។*

*លើសពីនេះទៅទៀត ខ្ញុំព្រះករុណា អាត្មាភាព ក៏សូមកោតសរសើរ និងអនុមោទនា ចំពោះស្នាដៃរបស់ឧបាសិកា* **ចណ្ណារី ចេតប្រណាម្យ** *ដែលខិតខំបកប្រែរៀបរៀងមិលិន្ទបញ្ហារបស់ប្រទេសភូមានេះ ឲ្យលេចចេញជារូបរាងឡើង ដើម្បីឲ្យពុទ្ធសាសនិកជន ងាយស្រួលក្នុងការសិក្សារៀនសូត្រ ស្វែងយល់ និងបំបាត់នូវចម្ងល់នានា នៅក្នុងព្រះពុទ្ធសាសនា ដ៏បវរនៃយើង ។*

*ក្នុងនាម ខ្ញុំព្រះករុណា អាត្មាភាព និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ នៅក្នុងបន្ទប់សន្ទនាព្រះធម៌* ( Buddhism Knowledge For All Khmer, Cambodian Buddhist Philosophy 2555, Khmer Abhidhamma and Tipitaka Teaching & Khmer Theravada Buddhism ) *តាមប្រព័ន្ធអ៊ីនធឺណេត* ( Paltalk Messenger ) *ទាំងអស់ បានមូលមតិគ្នាជាឯកច្ឆន្ទ សហការជាមួយនឹងនាទី* **ពន្លឺពុទ្ធឱវាទ នៃសហញាតព្រះធម៌** ( ***វត្តអង្គពោធិញាណ*** ) *បោះពុម្ពនូវសៀវភៅមិលិន្ទបញ្ហា ភាគ ១ ( កណ្ឌទី ១ និង កណ្ឌទី ២ ) នេះ លើកដំបូងចំនួន* **១.០០០***ច្បាប់ ក្នុងគោលបំណងជួយទ្រទ្រង់ព្រះសទ្ធម្ម ផ្សព្វផ្សាយចែកជាធម្មទាន ដែលជាមរតកដ៏មានតម្លៃ មិនអាចកាត់ថ្លៃបាន សម្រាប់ព្រះពុទ្ធសាសនាតរៀងទៅ ។*

*សូមឱ្យព្រះសទ្ធម្មរបស់ព្រះបរមគ្រូជាអម្ចាស់ផ្សាយជ្រួតជ្រាបពេញសកលលោក !*

*សូមឲ្យសព្វសត្វទាំងអស់ទទួលបាននូវសេចក្តីស្ងប់តរៀងទៅ !*

***សូមអនុមោទនា...!***

*វត្តវេឡុវនារាម ( ព្រៃឫស្សី ) , ថ្ងៃ ៣ កើត ខែ ពិសាខ ព.ស. ២៥៥៥*

*ត្រូវនឹងថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១២*

*ភិក្ខុ នន្ទញាណោ រិន សំណាង*

# ទស្សនកថា

សៀវភៅមិលិន្ទប្បញ្ហា មានលក្ខណៈដូចជាគម្ពីរ ដែលនាងខ្ញុំបានសិក្សាមកនេះ ពិតជាមានអត្ថរស ដ៏ពិសិដ្ឋទុកជាគតិ អោយកុលបុត្រត្រកូលនាគ និងត្រកូលមន ជាពិសេសសម្រាប់ពុទ្ធសាសនិកជនគ្រប់វ័យ យកទៅសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹង ក្នុងសម័យពុទ្ធកាល ឲ្យបានយល់ដឹង ព្រមទាំងកាត់បន្ថយនូវវិចិកិច្ឆា លាងជម្រះអវិជ្ជា តាមរយៈខ្លឹមសារសៀវភៅ ដែលបែងចែកជាកណ្ឌ ៗ ងាយស្រួលយល់ ។ ជាពិសេស ធ្វើឲ្យអ្នកសិក្សាឃើញនូវភាពប្រណីតសុខុមនៃធម៌ តាមរយៈបុច្ឆាវិសជ្ជនា ក្នុងជំពូកធម៌ផ្សេង ៗ រវាងព្រះថៅមិលិន្ទ និងព្រះនាគសេនត្ថេរ ដោយជាក់លាក់ និង ក្បោះក្បាយផង ។

ដោយយោងទៅលើខ្លឹមសារ ប្រកបដោយអត្ថរស នៃសៀវភៅនេះ ទើបនាទី **ពន្លឺពុទ្ធឱវាទ នៃសហញ្ញាតិព្រះធម៌** ( **វត្តអង្គពោធិញាណ** ) ក្រោមការដឹកនាំដោយព្រះគ្រូរតននាទោ **អ៊ួន សំណាង** ឧបាសក **ម៉ាន់ យ៉ាន** នាងខ្ញុំផ្ទាល់ ព្រមទាំងព្រះសង្ឃ និងពុទ្ធបរិស័ទនៅក្នុង និងក្រៅប្រទេស បានដុះចេញនូវសទ្ធា លះបង់នូវមច្ឆរិយៈ ទាំងទ្រព្យ ទាំងចិត្ត ត្រេកអរអនុមោទនា ដោយបីតិសោមនស្សរីករាយបំផុត ក្នុងការចូលរួមបោះពុម្ពផ្សាយសៀវភៅនេះ ដើម្បីទុកជាគុណប្រយោជន៍សម្រាប់ពុទ្ធសាសនិកជនទូទៅផង ។

នាងខ្ញុំសូមកោតសសើរ ចំពោះឧត្តមគតិដ៏ខ្ពង់ខ្ពស់ របស់ឧបាសិកា **វណ្ណារី ទេពប្រណម្យ** ដែលបានខិតខំផ្ចិតផ្ចង់ ចងក្រងកើតបានជាសៀវភៅមួយច្បាប់នេះ ដោយសេចក្តីព្យាយាមយ៉ាងមោះមុតបំផុត។

នាងខ្ញុំសង្ឃឹមថា សៀវភៅមួយច្បាប់នេះ ពិតជាមានប្រយោជន៍ដ៏ធំធេងចំពោះព្រះពុទ្ធសាសនា ដោយគុណានុភាពនៃព្រះរតនត្រ័យ សូមឲ្យព្រះគុណម្ចាស់គ្រប់ ៗ ព្រះអង្គ ឧបាសិកា **វណ្ណារី** ព្រមទាំងពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេសទាំងអស់ បានជួបប្រសព្វនូវសុខុមាលភាពមាំមួន និងមានសម្មាទិដ្ឋិគ្រប់ៗជាតិ តរៀងទៅ ដើម្បីទ្រទ្រង់កងចក្រនៃព្រះធម៌ ឲ្យប្រព្រឹត្តទៅជានិច្ចនិរន្តរ៍ បានគ្រប់ ៥.០០០ ព្រះវស្សា បរិបូរណ៍ទៅហោង ។

សូមព្រះធម៌របស់ព្រះសម្ពុទ្ធ ជ្រួតជ្រាបដល់មនុស្សទូទៅ ...!!!

**ថ្ងៃ ៣ កើត ខែពិសាខ ព.ស ២៥៥៥**

ឧបាសិកា **កែវ សុខហៃ**

នាទីពន្លឺពុទ្ធឱវាទ នៃសហញ្ញាតិព្រះធម៌



នាទីពន្លឺពុទ្ធឱវាទ នៃសហញ្ញាតព្រះធម៌ ( វត្តអង្គពោធិញ្ញាណ )



# អារម្ភបទអ្នករៀបរៀងជាខេមរភាសា

*ដោយបានដឹងថា មិលិន្ទបញ្ហារបស់ខ្មែរ ស្រដៀងគ្នានឹងមិលិន្ទបញ្ហារបស់ថៃ ដែលកំពុងមាននៅពេលនេះ ហើយថែមទាំងមិនទាន់ចប់សព្វគ្រប់ផងនោះ ដោយមិលិន្ទបញ្ហារបស់ខ្មែរ ដែលបោះពុម្ពលើកទី ៤ កាលពីឆ្នាំ ១៩៦៣ របស់ព្រះគ្រូវិមលបុបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា មានខ្លឹមសារត្រឹមតែ* **២ កណ្ឌ** *គឺ* **កណ្ឌទី ១ - បុព្វយោគកណ្ឌ** ( *ប្រវត្តិកន្លងមករបស់ព្រះចៅមិលិន្ទនិងព្រះនាគសេនត្ថេរ* ) និង **កណ្ឌទី ២ - មិលិន្ទបញ្ហាកណ្ឌ** ( *ជាកណ្ឌដែលព្រះចៅមិលិន្ទលើកជាបញ្ហាចម្ងល់នានា ឡើងមកដោយអង្គឯង ដោយមិនបានប្រារព្ធពាក្យក្នុងព្រះសាសនា សួរទៅព្រះនាគសេនត្ថេរ បន្ទាប់ពីបានជួបមុខគ្នា និងចាប់ផ្ដើមសន្ទនានៅថ្ងៃដំបូង មានទាំងអស់ ៧ វគ្គ* ) *ដែលមានសៀវភៅត្រឹមតែ ២ ក្បាល ប៉ុណ្ណោះគឺ ៖*

- *ខ្សែទី ១ ឬ ភាគទី ១ ជាសៀវភៅក្របស្ដើងពណ៌ស៊ីជម្ពូ កម្រាស់ ២៥៩ ទំព័រ មានខ្លឹមសារទាំងអស់ត្រឹមបុព្វយោគកណ្ឌ និង បីវគ្គនៃមិលិន្ទបញ្ហាកណ្ឌ គឺ បឋមវគ្គ ទុតិយវគ្គ និងផ្នែកខ្លះនៃតតិយវគ្គ ។*
- *ភាគទី ២ ជាសៀវភៅក្របស្ដើងពណ៌សាច់ កម្រាស់ ២១៦ ទំព័រ មានខ្លឹមសារបួនវគ្គ នៃមិលិន្ទបញ្ហាកណ្ឌ គឺ តតិយវគ្គ ចតុត្ថវគ្គ បញ្ចមវគ្គ ឆដ្ឋវគ្គ និង សត្តមវគ្គ ។*

*ចំណែក* **៤ កណ្ឌ** *ទៀត គឺ* ***លក្ខណបញ្ហាកណ្ឌ មេណ្ឌកបញ្ហាកណ្ឌ អនុមាណបញ្ហាកណ្ឌ និង ឧបមកថាកណ្ឌ*** *ពុំទាន់មានបោះពុម្ពផ្សាយនៅឡើយ តាំងពីឆ្នាំ ១៩៦៤ រហូតមកដល់ពេលនេះ ។*

ហេតុនេះ បន្ទាប់ពីបានអានមិលិន្ទបញ្ហារបស់ភូមា តាមរយៈស្នាដៃបកប្រែរបស់លោកគ្រូ ផៃវឌ្ឍន៍ កបិលកាញ្ចន៍ (ជនជាតិថៃ) ដែលជាអ្នកជំនាញនូវព្រះត្រៃបិដក ជាអ្នកមានការយល់ដឹងច្រើន ទាំងផ្នែកបរិយត្តិនិងប្រតិបត្តិ ទើបនាងខ្ញុំក្នុងនាមជាកុលធីតាខ្មែរមួយរូប ដែលជ្រះថ្លាពេញចិត្តនឹងការស្រាវជ្រាវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ **ឃើញភាពចាំបាច់ក្នុងការបកប្រែមិលិន្ទបញ្ហារបស់ភូមា** តាមរយៈស្នាដៃរបស់លោកគ្រូផៃវឌ្ឍន៍ ដោយរៀបរៀងជាខេមរភាសា ដើម្បីប្រិយមិត្តអ្នកអានខ្មែរ បានទទួលអត្ថរស និង អត្ថន័យនៃមិលិន្ទបញ្ហារបស់បរទេសម្តង ( របស់ភូមា គឺ ដូចគ្នាទៅនឹងរបស់ស្រីលង្កានិងរបស់អឺរ៉ុប ដូចលោកគ្រូ ផៃវឌ្ឍន៍ បានបញ្ជាក់នៅក្នុងសេចក្តីអត្ថាធិប្បាយ ដែលជាការផ្តើមសេចក្តីរបស់ខ្លួន ) ព្រោះមិលិន្ទបញ្ហារបស់ភូមា មានដល់ទៅ **៦ កណ្ឌ** និងមាន **អដ្ឋកថា** ជាសេចក្តីអធិប្បាយភ្ជាប់ទៅនឹងបញ្ហានីមួយ ៗ ដើម្បីងាយស្រួលក្នុងការយល់ខ្លឹមសារសេចក្តី ឱ្យបានត្រឹមត្រូវ ដែលពុំមានក្នុងមិលិន្ទបញ្ហារបស់ខ្មែរ និងថៃ ។

ដោយសារមានកម្រាស់ក្រាស់ពេក សៀវភៅមិលិន្ទបញ្ហាត្រូវបានបែងរំលែកជា ៣ ភាគ សម្រាប់ ៦ កណ្ឌនោះ ដើម្បីងាយស្រួលចាប់កាន់អាន គឺមួយភាគមានខ្លឹមសារចំនួន ២ កណ្ឌ ៖

**ភាគ ១** ៖ កណ្ឌទី ១ - បុព្វយោគកណ្ឌ និង
កណ្ឌទី ២ - មិលិន្ទបញ្ហាកណ្ឌ

**ភាគ ២** ៖ កណ្ឌទី ៣ - លក្ខណបញ្ហាកណ្ឌ និង
កណ្ឌទី ៤ - មេណ្ឌកបញ្ហាកណ្ឌ

**ភាគ ៣** ៖ កណ្ឌទី ៥ - អនុមាណបញ្ហាកណ្ឌ និង
កណ្ឌទី ៦ - ឧបមកថាកណ្ឌ ។

*ដូច្នេះ សូមអ្នកសិក្សាធម៌រង់ចាំអានជាបន្តទៀតកុំបីខាន ដើម្បីបណ្តុះនូវពន្លឺនៃបញ្ញារបស់ខ្លួន ទាក់ទងនឹងបញ្ហាចម្ងល់ផ្សេង ៗ ក្នុងព្រះពុទ្ធសាសនា ដែលកំពូលអ្នកប្រាជ្ញទាំងពីរ បានបុច្ឆាវិសជ្ជនាសួរឆ្លើយគ្នា ដើម្បីស្រាយបំភ្លឺនូវចម្ងល់ទាំងនោះទុកជាមាគ៌ាដោះស្រាយបញ្ហា សម្រាប់ពុទ្ធសាសនិកជនជំនាន់ក្រោយ បានជម្រះនូវមន្ទិលទាំងឡាយ ពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា សាងនូវភាពភ្លឺថ្លានៃព្រះសាសនាដ៏ឧត្តម ដើម្បីជាហេតុជាបច្ច័យ ធ្វើទីពឹងសម្រាប់ខ្លួន ក្នុងព្រះសាសនានេះ តទៅថ្ងៃអនាគត កុំបីខាន ។*

*ទន្ទឹមនឹងនោះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ* **ឧបាសក ជាំ កុយ** *សមាជិកគណៈកម្មការសមាគមអក្សរសាស្ត្រនិងវប្បធម៌ខ្មែរ ដែលបានជួយកែសម្រួលអក្ខរាវិរុទ្ធ នៅក្នុងសៀវភៅនេះ ។*

*ទោះបីជាយ៉ាងណាក្តី សៀវភៅនេះ ប្រាកដជានៅមានចំណុចខ្វះខាតខ្លះ ៗ ជាក់ជាមិនខាន ដែលនាងខ្ញុំសូមលំឱនកាយ សូមការអធ្យាស្រ័យពីចម្ងាយ និង រីករាយទទួលយកការរិះគន់ផ្សេង ៗ ពីសម្នាក់មិត្តអ្នកអានទូទៅ និងសង្ឃឹមយ៉ាងមុតមាំថា សៀវភៅមិលិន្ទបញ្ហានេះ នឹងនាំមកនូវ* ***ប្រយោជន៍ជាមហិមា*** *ចំពោះអ្នកសិក្សាធម៌ ដើម្បីបានស្វែងយល់អំពីព្រះពុទ្ធសាសនា ឲ្យបានច្រើនថែមទៀត និងជា****មរតក****សម្រាប់កូនខ្មែរជំនាន់ក្រោយ ឲ្យងាយស្រួលសិក្សាស្រាវជ្រាវផងដែរ ។*

*សូមអានិសង្សនៃការបកប្រែរៀបរៀងសៀវភៅនេះ ជួយឱ្យប្រិយមិត្តអ្នកអាន និង អ្នកសិក្សាធម៌ ជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនាតរៀងទៅ រហូតបានជាក់ច្បាស់នូវព្រះនិព្វាន ដោយបញ្ញារបស់ខ្លួន គ្រប់ ៗ រូប កុំបីខាន ៕*

រាជធានីភ្នំពេញ ថ្ងៃ ១១ រោច ខែមិគសិរ ឆ្នាំខាល ព.ស. ២៥៥៤
ត្រូវនឹងថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១១




**ឧបាសិកា វណ្ណារី ទេពប្រណម្យ**
vannary_t@yahoo.com

អតីតដូនជីសិក្សាព្រះអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ វិសុទ្ធិមគ្គ ធម្មសង្គណី មហាបដ្ឋាន និងព្រះសូត្រ នៅព្រះរាជាណាចក្រថៃ ។

## សមាសភាពចូលរួម ៖

| | | |
|---|---|---|
| **រៀបរៀងជាខេមរភាសា** | ៖ | - ឧបាសិកា វណ្ណារី ទេពប្រណម្យ |
| **វាយអត្ថបទ** | ៖ | - ឧបាសិកា វណ្ណារី ទេពប្រណម្យ |
| **រចនាក្រប** | ៖ | - ប្អូន ៗ បច្ចេកទេសកុំព្យូទ័រ |
| **រចនាទំព័រ** | ៖ | - ភិក្ខុ អគ្គធីរោ គង់ សុមិត្ត |
| **កែអក្ខរាវិរុទ្ធ** | ៖ | - ឧបាសក ដាំ កុយ |
| **ទីប្រឹក្សា** | ៖ | - ភិក្ខុ ព្រះមហា សុវិទ្ធ រតិន្នយោ |
| | | - ភិក្ខុ វជិរជោតោ ទូ សុជាតិ |
| | | - ភិក្ខុ ជោតិនន្ទ |
| | | - ភិក្ខុ នន្ទញ្ញាណោ រិន សំណាង |
| | | - ដូនជីប៊ុនផា និង ដូនជីសុទិសា |
| | | - ឧបាសក ឃៀក វ៉ា |

# អារម្ភកថា

*សៀវភៅមិលិន្ទបញ្ហា បានបោះពុម្ពមកជូនមិត្តអ្នកមានចិត្តសទ្ធាជ្រះថ្លានឹងធម៌ ដើម្បីបានធ្វើការសិក្សាក្នុងពេលនេះហើយ ។*

*រឿងមិលិន្ទបញ្ហានេះ លោកគ្រូឆៃវឌ្ឍន៍ កបិលកាញ្ចន៍ បានបង្រៀនអ្នកសិក្សាធម៌ជាប្រចាំ នៅសមាគមមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាវត្តស្រះកេត ។ លោកគ្រូឆៃវឌ្ឍន៍ និងអ្នកសិក្សាទាំងអស់ យល់ឃើញថា* ***គួរតែរៀបចំបោះពុម្ពជាសៀវភៅ*** *ដើម្បីជាប្រយោជន៍ដល់អ្នកគ្មានឱកាសបានទៅសិក្សានៅវត្តស្រះកេត ។*

*ខ្លឹមសារនៅក្នុងព្រះគម្ពីរនេះ* ***គួរឱ្យចង់សិក្សាជាទីបំផុត*** *លោកអ្នកប្រាជ្ញទាំងពីរសន្ទនាឆ្លើយឆ្លងគ្នា នូវបញ្ហានីមួយ ៗ សុទ្ធតែជារឿងធ្វើឱ្យដុះបញ្ញា គួរឱ្យចាប់អារម្មណ៍ គួរឱ្យចង់ដឹង។*

*សៀវភៅនេះ សម្រេចបានដោយសារសេចក្តីប្រឹងប្រែងព្យាយាមរបស់លោកគ្រូ ឆៃវឌ្ឍន៍ និងអ្នកជួយទំនុកបម្រុងជាច្រើននាក់ រួមទាំងអ្នកចូលរួមវិភាគទានជាថវិកាយ៉ាងច្រើន ដែលជួយគ្នាលះបង់ទ្រព្យ ទើបធ្វើឱ្យសៀវភៅមិលិន្ទបញ្ហានេះ អាចសម្រេចជារូបរាងមកបាន ។*

*ដោយអានិសង្សនៃកុសលនេះ សូមហុចផលដល់អ្នកបកប្រែ អ្នកជួយទំនុកបម្រុងរៀបចំបោះពុម្ព អ្នកបរិច្ចាគជនជាន ព្រមទាំងប្រិយមិត្តអ្នកអានគ្រប់គ្នា បានសម្រេចនូវធម៌ផុតទុក្ខ ក្នុងពេលឆាប់ ៗ នេះផងចុះ ។*

***ឧបាសិកា ប្រានី សំរើងរាជ្យ***

*សម្នាក់វិវដ្ដ: វត្តខោស្នាមជ័យ*

# អត្ថាធិប្បាយ

*នៅពេលព្រះចៅអាឡេចសង់ឌ្រេមហារាជ យាងលើកទ័ពមកវាយឈ្នះនគរបញ្ជាបរបស់ឥណ្ឌារួចមក ក៏មានស្តេចក្រិកគ្រប់គ្រងនគរនេះ ជាបន្តបន្ទាប់ជាច្រើនអង្គ រហូតដល់រាជសម័យរបស់ស្តេចក្រិកមួយអង្គ ទ្រង់ព្រះនាមជាភាសាមគធៈថា "* **មិលិន្ទ** *" ។ ព្រះអង្គទ្រង់មានព្រះទ័យធ្វើការឈ្វេងយល់ពីវិជ្ជាទាំងឡាយ ជាពិសេសទស្សនបញ្ញា ក្នុងលទ្ធិសាសនាផ្សេង ៗ ទ្រង់រីករាយនឹងយាងទៅជួបសន្ទនាជាមួយអ្នកមានចំណេះដឹងក្នុងលទ្ធិសាសនាទាំងនោះ ។ ក្រោយមក ទ្រង់បានជួបសន្ទនាឆ្លើយឆ្លងគ្នាជាមួយព្រះថេរៈដ៏ល្បីឈ្មោះបំផុត ក្នុងពុទ្ធសាសនា មួយអង្គ គឺ "* **ព្រះនាគ-សេនត្ថេរ** *" ។*

*ក្នុងបញ្ហាដ៏ស៊ីជម្រៅ ពាក្យពេចន៍សន្ទនាឆ្លើយឆ្លងគ្នារវាងលោកទាំងពីរ បានក្លាយជាទីចាប់អារម្មណ៍ពេញចិត្តក្រៃលែង របស់បណ្ឌិតទាំងឡាយជាច្រើន ។ នាពេលក្រោយមក ប្រមាណជាពុទ្ធសករាជ ៥០០* **ព្រះតបិដក-ចុឡាភយត្ថេរ** *ដែលជំនាញនូវព្រះត្រៃបិដក បានដល់ធម៌នៃបដិវេធ មានបញ្ញាមោះមុតជ្រាលជ្រៅ មានសម្តីដែលគ្រូបាអាចារ្យទាំងឡាយត្រូវរិះគិត បានឃើញនូវគុណតម្លៃក្នុងពាក្យសន្ទនាឆ្លើយឆ្លងគ្នារវាងលោកទាំងពីរ ជាហេតុជួយទ្រទ្រង់ព្រះសទ្ធម្ម របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឱ្យគង់វង្សបាន ទើបព្យាយាមប្រមែប្រមូលពាក្យសម្តីសន្ទនាទាំងអស់នោះ ចងក្រងរៀបរៀងឡើង ជាគម្ពីរមួយរបស់សាសនា ដាក់ឈ្មោះថា "* **មិលិន្ទបញ្ហា** *"។ កុលបុត្រ*

*ដែលចង់បានទីពឹងក្នុងព្រះសាសនាទាំងឡាយ ក៏បានជួយគ្នាថែរក្សាដោយការរៀន ការទន្ទេញចាំជាដើម ជាបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្ននេះ ។*

*មិលិន្ទប្បញ្ហាជាគម្ពីរមួយ ដែលគ្រូបាអាចារ្យទាំងឡាយ **យល់ឃើញថាសំខាន់ជាខ្លាំង** ។ ព្រះអដ្ឋកថាចារ្យទាំងឡាយ ដែលធ្វើការតែងគម្ពីរផ្សេងៗ **រមែងតែលើកសម្ដីក្នុងគម្ពីរនេះ មកជាសម្អាងក្នុងការផ្សារនិពន្ធរបស់ខ្លួនជានិច្ច** ក្នុងពេលមានការវិភាគប្រធានបទណា ដែលមានភាពស៊ីជម្រៅនោះ ។ ក្នុងសម័យបច្ចុប្បន្ននេះ អ្នកសិក្សាស្រាវជ្រាវពីទស្សនវិជ្ជានិងសាសនា របស់ប្រទេសលោកខាងកើត នៅបណ្ដាប្រទេសលោកខាងលិច យល់ឃើញស្រប គ្នាថា មិលិន្ទប្បញ្ហាជាគម្ពីរមួយ ដែលជួយផ្ដល់នូវទស្សនបុបញ្ញា ក្នុងពុទ្ធសាសនានិកាយថេរវាទ បានយ៉ាងច្បាស់ ។*

*ក្នុងសម័យបច្ចុប្បន្ន គម្ពីរមិលិន្ទប្បញ្ហានេះ ចំពោះគម្ពីរដែលជា**ភាសាមគធៈ** ទោះជាភាសាតែមួយក្ដី ក៏មានបែកចេញជាច្រើនច្បាប់ គឺ របស់ថៃប្រើអក្សរថៃកត់ត្រា របស់ភូមាប្រើអក្សរភូមា របស់ស្រីលង្កាប្រើអក្សរស្រីលង្កា របស់អឺរ៉ុបប្រើអក្សររ៉ូម៉ាំង ។*

*សម្រាប់មិលិន្ទរបស់ថៃ ដែលប្រើសិក្សាក្នុងប្រទេសថៃនោះ មានអ្នកបកប្រែ ធ្វើការបកប្រែមកជាភាសាថៃជាច្រើនលើក ជាច្រើនសំនួន មានទាំងប្រភេទបកប្រែពេញឃ្លា និងប្រភេទដកស្រង់យកតែខ្លឹមសារ មករៀបរៀង ក៏មាន ។ **ចំណែកមិលិន្ទប្បញ្ហារបស់បរទេស ដែលគេកំពុងប្រើនោះ នៅមិនទាន់មានអ្នកណាបកប្រែមកជាភាសាថៃនៅឡើយ** ។ ខ្ញុំបាទនៅពេលបានអានទាំងរបស់ថៃ និង របស់បរទេស ជាពិសេសរបស់ភូមា យកមកប្រៀបធៀបគ្នា រួមទាំងពាក្យអធិប្បាយដែលហៅថា អដ្ឋកថានោះ ក្នុងនាមជាអ្នក*

*អត្ថាធិប្បាយគម្ពីរនេះ នៅសមាគមមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាវត្តស្រះកេត ទើបខ្ញុំបាទសម្រេចចិត្តមិនធ្វើការបកប្រែមិលិន្ទប្បញ្ហារបស់ថៃ ហើយធ្វើការបកប្រែតែមិលិន្ទប្បញ្ហារបស់ភូមា ជំនួសវិញ ។*

*ក្នុងការរៀបចំជាសៀវភៅលើកនេះ ដោយមានហេតុផល ៥ ប្រការ ដូចតទៅនេះ ៖*

*១- **មិលិន្ទប្បញ្ហាភាសាមគធៈរបស់ថៃ មានអ្នកបកប្រែជាភាសាថៃជាច្រើនលើក ជាច្រើនសំនួនរួចមកហើយ** បើខ្ញុំបាទនៅតែប្រើរបស់ថៃជាច្បាប់ដើម ក្នុងការបកប្រែទៀតនោះ ទោះជាសំនួនបកប្រែមានការខុសប្លែកគ្នាខ្លះៗ ក្តី ប្រហែលជាមិនបានជួយឱ្យអ្នកអានបានទទួលនូវអត្ថរស ឬ ចំណេះដឹងអ្វីបន្ថែមទៀតឡើយ ហេតុនេះ ទើបខ្ញុំបាទមិនគិតបកប្រែមិលិន្ទប្បញ្ហារបស់ថៃទៀតទេ ។*

*២- **មិលិន្ទប្បញ្ហារបស់បរទេស នៅមិនទាន់មានអ្នកណាបកប្រែចេញមកនៅឡើយ គួរតែក្រឡេកមើលទៅរបស់គេខ្លះ** ។ ទោះជាយ៉ាងណាក៏ជាគម្ពីរខាងសាសនា ដែលយើងទាំងអស់គ្នា មានការគោរពដូចគ្នា ។*

*៣- **បើប្រៀបធៀបជាមួយព្រះត្រៃបិដក ព្រះត្រៃបិដករបស់ថៃក្តី របស់ភូមាក្តី មានការខុសគ្នាតិចតួចណាស់** ស្តីអំពីប្រយោគខ្លះ ពាក្យខ្លះ ឬក៏ការប្រើប្រាស់ តួអក្សរ ក៏អត្ថន័យមិនខុសប្លែកគ្នាដែរ ។ ប៉ុន្តែចំពោះមិលិន្ទប្បញ្ហាវិញមិនមែនដូចនេះ **គឺមានការខុសប្លែកគ្នាជាច្រើនវគ្គ** គួរឱ្យភ្ញាក់ផ្អើលថា ម្ខាង ៗ បានទទួលគម្ពីរនេះមកពីណា ? នាំគ្នាថែរក្សាយ៉ាងដូចម្តេច ? ខ្លឹមសារខ្លះ ប្រៀបដូចជានិយាយផ្សេងគ្នា ។*

## *សរុបភាពខុសគ្នា មានដូចតទៅ ៖*

*- ខ្លឹមសារខ្លះមាននៅក្នុងមិលិន្ទប្បញ្ហារបស់ថៃ តែបែរជាមិនមាននៅក្នុងមិលិន្ទប្បញ្ហារបស់ភូមា ដូចជា ខ្លឹមសារទាក់ទងទៅនឹងពុទ្ធទំនាយដំណើរកកើតនៃព្រះថៅមិលិន្ទ និង ព្រះនាគសេន ជាដើម ។*

*- ទាក់ទងនឹងឈ្មោះរបស់បុគ្គល ក៏មានចំណែកខុសគ្នាដែរ ដូចជា ឈ្មោះរបស់អាមាត្យម្នាក់ មិលិន្ទប្បញ្ហារបស់ថៃឈ្មោះ អន្តកាយអាមាត្យ ចំណែកមិលិន្ទប្បញ្ហារបស់ភូមាជា អនន្តកាយអាមាត្យ ជាដើម។*

*- ទាក់ទងនឹងឈ្មោះចំណងជើងបញ្ហា មានច្រើនបញ្ហាណាស់ ដែលមានខ្លឹមសារ បញ្ជាក់ឱ្យដឹងថាជាបញ្ហាតែមួយ ទាំងរបស់ថៃ ទាំងរបស់ភូមា ប៉ុន្តែបែរជាមានឈ្មោះបញ្ហាមិនដូចគ្នា ដូចជា របស់ថៃមានបញ្ហាមួយឈ្មោះថា សីលប្រតិស្ឋានលក្ខណបញ្ហា ។ ចំណែករបស់ភូមា បែរជាមានចំណងជើងបញ្ហាថា សីលលក្ខណបញ្ហា ទៅវិញ ជាដើម ។*

*- ទាក់ទងនឹងចំនួនឧបមាក្នុងបញ្ហានីមួយ ៗ បញ្ហាខ្លះ មិលិន្ទប្បញ្ហារបស់ថៃ មានខ្លឹមសារដែលជាការឧបមាច្រើនជាង មិលិន្ទប្បញ្ហារបស់ភូមា ។*

*- សូម្បីតែទាក់ទងនឹងការកំណត់ខ្លឹមសារក្នុងបញ្ហាខ្លះ ក៏មានការខុសប្លែកគ្នាដែរ ដូចជា បញ្ហាមានការសួរអំពីលក្ខណៈរបស់សទ្ធា ដែលព្រះនាគសេនបានឆ្លើយវិសជ្ជនាថា មានលក្ខណៈ ២ យ៉ាងនោះ ក្នុងមិលិន្ទប្បញ្ហារបស់ភូមា បានញែកលក្ខណៈម្យ៉ាង ៗ ជាបញ្ហាផ្សេងគ្នា ។ ចំណែកក្នុងមិលិន្ទប្បញ្ហារបស់ថៃ បានប្រមូលខ្លឹមសារ ដែលទាក់ទងនឹងលក្ខណៈទាំងពីរ ជាបញ្ហាតែមួយ ជាហេតុឱ្យមានចំនួនបញ្ហា មិនស្មើគ្នា ។*

- បញ្ហាជាច្រើន ដែលមានពាក្យក្នុងសំណួរ ឬ ចម្លើយ មានលក្ខណៈខុសគ្នា ដូចជារបស់ថៃ មានឃ្លាសួរថា " ព្រះគុណម្ចាស់នាគសេន បុគ្គលណាមានញាណកើតឡើងហើយ បុគ្គលនោះឈ្មោះថា មានញាណកើតឡើងហើយមែនទេ ? " ។ ចំណែករបស់ភូមា មានឃ្លាថា " ព្រះគុណម្ចាស់នាគសេន បុគ្គលណាមានញាណកើតឡើងហើយ បុគ្គលនោះឈ្មោះថា មានបញ្ញាកើតឡើងហើយមែនទេ ? " របស់ភូមាគួរតែត្រឹមត្រូវជាង ព្រោះថាព្រះចៅមិលិន្ទទ្រង់មានបំណងចង់ជ្រាបថា ញាណ និង បញ្ញា ជាធម្មជាតិតែមួយ ឬ ក៏ផ្សេងគ្នា ។

- បញ្ហាខ្លះ ដូចជា បញ្ហាមានការសួរអំពីការបួសរបស់ព្រះពុទ្ធអង្គ ។ របស់ភូមា មានត្រឹមតែខ្លឹមសារខ្លី ៗ ដែលជាការសួរ និង ឆ្លើយគ្នា ប៉ុណ្ណោះ ។ ចំណែកខាងថៃវិញ នៅមានខ្លឹមសារផ្សេងៗទៀត គឺនៅពេលព្រះថេរៈឆ្លើយវិសជ្ជនាហើយ ព្រះរាជាទ្រង់មិនព្រមទទួលយកចម្លើយ ។ ក្រោពីទ្រង់មិនទទួលយកហើយ ទ្រង់នៅបានត្រាស់និយាយចំអកឡកឡាយព្រះថេរៈជាមួយនឹងពួកបម្រើរាជការ ដែលនៅហែហមជុំវិញនោះទៀតផង យ៉ាងនេះជាដើម ។

- ទាក់ទងនឹងការលើកយកពាក្យ ក្នុងព្រះត្រៃបិដក មកអះអាងក្នុងបញ្ហានីមួយ ៗ មិលិន្ទប្បញ្ហារបស់ភូមា បានលើកយកមកត្រូវនឹងការមានពិត ក្នុងព្រះត្រៃបិដកជានិច្ច ។ ចំណែកមិលិន្ទប្បញ្ហារបស់ថៃ រមែងតែលើកយកមក មិនត្រូវ មិនចំ ។ មួយយ៉ាងវិញទៀត ពាក្យដែលលើកមកនោះក្នុងមិលិន្ទប្បញ្ហារបស់ភូមា មានកត់ត្រាទុកនៅចុងទំព័រនីមួយ ៗ នោះថាលើកយកមកពីព្រះត្រៃបិដក សៀវភៅទីប៉ុន្មាន និកាយអី ទំព័រទីប៉ុន្មាន ជួយឱ្យស្រាវជ្រាវដល់ដើមទីបានលឿន ចំណែករបស់ថៃ ពុំមានបញ្ជាក់នោះទេ ។

*- ទាក់ទងនឹងសញ្ញាផ្សេង ៗ ដែលមានជាសញ្ញាកំណត់ប្រយោគ ឬកំណត់ ខ្លឹមសារគឺ វគ្គធំ វគ្គតូច សញ្ញាពាក្យ សញ្ញាសំណួរ ជាដើម ។ មិលិន្ទបញ្ហារបស់ភូមា មានដាក់ច្បាស់លាស់ ជួយឱ្យអ្នកបកប្រែ កំណត់ប្រយោគនីមួយ ៗ បានដោយងាយ បកប្រែបានស្រួល ។ មិលិន្ទបញ្ហារបស់ថៃ មិនបានយកចិត្តទុកដាក់ក្នុងរឿងនេះ ជាហេតុឱ្យអ្នកបកប្រែ ពេលខ្លះមិនពិចារណា ក៏កាត់រំលែកញែកប្រយោគដោយខ្លួនឯង ដែលពេលខ្លះធ្វើឱ្យច្របូកច្របល់ ធ្វើឱ្យមិនប្រាកដថាត្រឹមត្រូវ ។ ជាពិសេស ពាក្យពេចន៍ក្នុងព្រះត្រៃបិដក ដែលលើកយកមកជាសម្អាងក្នុងបញ្ហានីមួយ ៗ នោះ ត្រូវមានការប្រយ័ត្នប្រយែងឱ្យមែនទែនថា ពាក្យពេចន៍ក្នុងព្រះត្រៃបិដក ដែលលើកយកមកសម្អាងនោះមានត្រឹមណា ? ហើយពាក្យណាដែលមិនមែននៅក្នុងព្រះត្រៃបិដក ? ដោយស្រាវជ្រាវឱ្យដល់ដើមទីឱ្យច្បាស់លាស់សិន មុននឹងសម្រេចចិត្តបកប្រែ ដើម្បីការពារខ្លឹមសារចូលគ្នា ដែលអាចធ្វើឱ្យការបកប្រែទៅជាខុសខ្លឹមសារបាន ។*

*- ការចាត់បញ្ហាចូលក្នុងវគ្គនីមួយ ៗ មិនត្រូវគ្នាក៏មាន ដូចជា គោតមិវត្ថទានបញ្ហា មិលិន្ទបញ្ហារបស់ភូមាចាត់ចូលក្នុងពុទ្ធវគ្គ ចំណែកមិលិន្ទបញ្ហារបស់ថៃ ចាត់ចូលក្នុង វិសេសបញ្ហា ជាដើម ។ ល។*

*អាស្រ័យហេតុនេះ ប្រសិនបើបានបកប្រែមិលិន្ទបញ្ហារបស់ភូមាក៏ជាការបើកឱកាស ឱ្យប្រិយមិត្តអ្នកអានបានទទួលអត្ថរសផ្សេង ៗ ប្លែក ដែលពុំមាននៅក្នុងមិលិន្ទបញ្ហារបស់ថៃ ។*

***៤- មិលិន្ទបញ្ហារបស់ស្រីលង្កាក្តី របស់ប្រទេសខាងអឺរ៉ុបក្តី ដូចគ្នានឹងមិលិន្ទបញ្ហារបស់ភូមា** ច្រើនជាងមិលិន្ទបញ្ហារបស់ថៃ ប្រៀបបីដូចជា គម្ពីរ*

តែមួយជាមួយនឹងរបស់ភូមា ព្រោះហេតុនេះ ប្រសិនជាបានបកប្រែមិលិន្ទ-បញ្ហារបស់ភូមាប៉ុណ្ណោះ ប្រៀបបីដូចជា បានបកប្រែមិលិន្ទបញ្ហារបស់ស្រីលង្កា ជាដើម ទាំងអស់នោះផងដែរ ។

**៥**- ការបកប្រែគម្ពីរមិលិន្ទបញ្ហា ដែលមានឋានៈស្មើនឹងថ្នាក់ព្រះបាលីដូចព្រះត្រៃបិដកឱ្យបានត្រឹមត្រូវ មានខ្លឹមសារពេញលេញល្អនោះ **ចាំបាច់ត្រូវមើលពាក្យអធិប្បាយ ក្នុងអដ្ឋកថា** ។

អដ្ឋកថាដែលអធិប្បាយពាក្យនោះ មិលិន្ទបញ្ហារបស់ថៃពុំមាននោះទេ **មានតែរបស់ភូមាប៉ុណ្ណោះ** អាស្រ័យហេតុនេះ ចាំបាច់ត្រូវតែបកប្រែ មិលិន្ទបញ្ហារបស់ភូមា ប្រសិនបើចង់បានពាក្យអត្ថាធិប្បាយនោះ ។

ដោយហេតុថា មិលិន្ទបញ្ហាទាំងពីរនេះ មានលក្ខណៈខុសប្លែកគ្នាច្រើនប្រការ ដូចបានរៀបរាប់ខាងលើនោះ ការដែលត្រូវធ្វើកំណត់ហេតុប្រៀបធៀបអំពីប្រការខុសប្លែកគ្នា រវាងមិលិន្ទបញ្ហាទាំងពីរនេះ នៅចុងទំព័រសៀវភៅ ដើម្បីឱ្យឃើញថា ខាងភូមាថាយ៉ាងម៉េច ? ខាងថៃថាយ៉ាងម៉េច ? នោះជារឿងហួសវិស័យនឹងធ្វើបាន ទោះបីរឿងនេះគួរតែធ្វើក្តី ព្រោះពេលខ្លះពាក្យក្នុងមិលិន្ទបញ្ហារបស់ថៃ គួរជាទីសណ្តាប់ជាង យ៉ាងណាក្តី ។

មិលិន្ទបញ្ហា ដែលខ្ញុំបាទបកប្រែពីច្បាប់ដើមរបស់ភូមានេះ ខ្ញុំបាទបាន **ភ្ជាប់ពាក្យអធិប្បាយទៅក្នុងបញ្ហានីមួយ ៗ** ផងដែរ ។ ចំពោះពាក្យក្នុងគម្ពីរ ខ្ញុំបាទបានបកប្រែ **ដោយរក្សាវាក្យសព្ទទុក** គឺ ថាទៅតាមវាក្យសព្ទដែលមានប៉ុណ្ណោះ មិនមែនគ្រាន់តែដកស្រង់យកតែខ្លឹមសារនោះទេ ។ ទាំងនេះ គឺដើម្បីអនុគ្រោះដល់អ្នកសិក្សាភាសាបាលី ដែលត្រូវការចង់នាំគម្ពីរបកប្រែជាភាសាថៃនេះ ទៅប្រៀបធៀបនឹងច្បាប់ដើមភាសាបាលី ( របស់ភូមា ) ឱ្យ

អាចធ្វើបានដោយស្រួល ចំណែកពាក្យអធិប្បាយទាំងប៉ុន្មាន ខ្ញុំបាទបកប្រែ **ដោយគ្រាន់តែដកស្រង់យកខ្លឹមសារ** មករៀបរៀងជាពាក្យឃ្លាប្រយោគរបស់ខ្លួនជាសំខាន់ ។ ដោយដកស្រង់ ពីអដ្ឋកថាគម្ពីរនេះខ្លះ ពីទីផ្សេងខ្លះ ដែលយល់ឃើញថា អាចជួយឲ្យប្រិយមិត្តអ្នកអាន បានយល់ខ្លឹមសារនៃបញ្ហានីមួយ ៗ នោះបានច្បាស់ជាងមុនប៉ុណ្ណោះ មិនបានដកស្រង់យកមកទាំងអស់ទេ ។ ទោះជាយ៉ាងនេះក្តី នៅពេលបញ្ចូលពាក្យអធិប្បាយចូលជាមួយក្នុងបញ្ហានីមួយ ៗ យ៉ាងនេះ បើចង់បោះពុម្ពជាសៀវភៅមួយក្បាលចប់ នឹងធ្វើឱ្យសៀវភៅមានកម្រាស់ក្រាស់ពេក ពិបាកក្នុងការចាប់បើកអាន ថែមទាំងត្រូវបង់ចំណាយលើការបោះពុម្ពបែបនេះខ្ពស់ទៀតផង ហេតុនេះចាំបាច់ត្រូវបែងរំលែកជា **សៀវភៅ ៣ ក្បាល** ។

ទាក់ទងនឹងពាក្យក្នុងគម្ពីរផ្សេង ៗ មានព្រះត្រៃបិដកជាដើម ដែលលើកមក សម្គាល់ជាអក្សរខ្មៅក្នុងទំព័រនោះ ខ្ញុំបាទបានដាក់លេខយោង ហើយបានបញ្ជាក់ពីប្រភព ដែលបានដកស្រង់យកមកទុក ក្នុងបន្ទាត់ចុងក្រោយ ។ បើជាពាក្យក្នុងព្រះត្រៃបិដក ក៏ជាព្រះត្រៃបិដកច្បាប់ភាសាបាលី ដែលបានធ្វើការសង្គាយនាលើកចុងក្រោយ នៅក្នុងប្រទេសថៃកាលពីឆ្នាំ ១៩៨៧ ។ ប្រសិនជាពាក្យក្នុងគម្ពីរផ្សេង ភាគច្រើនជាគម្ពីរភាសាបាលី របស់មហាមកុដរាជវិទ្យាល័យ ក្រៅពីនោះគឺបានបញ្ជាក់ច្បាស់ស្រាប់ហើយ ។

ប្រិយមិត្តអ្នកអានទាំងឡាយជាទីមេត្រី កំហុសខុសឆ្គងអំពីការបកប្រែក្តី ពាក្យអធិប្បាយក្តី បញ្ជីរាយនាមអ្នកបរិច្ចាគថវិកាក្តី ឬក៏រឿងផ្សេង ៗ ទៀតក្តី ប្រាកដជានៅមានជាពុំខាន ។ ខ្ញុំបាទនិងខាងមូលនិធិ សូមអភ័យទោសប្រិយមិត្តអ្នកអានទាំងឡាយ ក្នុងឱកាសនេះផងចុះ និង រីករាយទទួលយកនូវការតវ៉ាដាស់តឿនរបស់លោកអ្នក ដើម្បីនាំយកទៅកែលម្អ ឱ្យត្រឹមត្រូវ

ក្នុងការបោះពុម្ពលើកក្រោយទៀត ។ សង្ឃឹមថា សៀវភៅនេះនឹងមានចំណែកជួយឱ្យប្រិយមិត្តអ្នកអាន មានសេចក្តីរីករាយក្នុងធម៌របស់ព្រះសម្មា-សម្ពុទ្ធជាម្ចាស់ យល់ដល់ពាក្យទូន្មានក្នុងព្រះសាសនាបានមួយផ្លូវទៀត បើមិនច្រើនក៏តិចដែរ ។

ជាទីបញ្ចប់នេះ ខ្ញុំបាទ និងខាងមូលនិធិ សូមអនុមោទនាក្នុងកុសល-ចិត្តរបស់លោកអ្នក ដែលបានចូលរួមចំណែកជួយ ក្នុងការបោះពុម្ពជាសៀវភៅលើកនេះ ឱ្យបានសម្រេច ។ សូមឱ្យបុណ្យកុសលលើកនេះ មានអានុភាពការពារលោកអ្នកទាំងអស់គ្នា រួមទាំងប្រិយមិត្តអ្នកអានផងដែរ ឱ្យរួចផុតពីគ្រោះភ័យគ្រោះចង្រៃទាំងពួង ជួបប្រទះតែនឹងសេចក្តីសុខ សិរី-សួស្តី ចម្រុងចម្រើន នៅក្រោមម្លប់នៃព្រះពុទ្ធសាសនារហូតតរៀងទៅ អស់កាលជាអង្វែងទៅហោង ។



បំណាងល្អ ដោយចិត្តស្មោះ

**ឆៃខឡ្យន៍ កបិលភាញ្ញន៍**

# មូលនិធិ ប្រានី សំរើចរាជ្យ

*ការិយាល័យមានទីតាំងនៅសម្នាក់ប្រតិបត្តិធម៌វិវដ្ដៈ វត្តខៅស្នាមជ័យ ឃុំណាងយៃ ស្រុកហួហ៊ីន ខេត្តប្រចួបគីរីខន្ធ ទូរស័ព្ទ ០៣២ - ៥១២៥៨៧ ។*

*គោលបំណងរបស់មូលនិធិ ៖*

*១ - ដើម្បីជំរុញការប្រតិបត្តិធម៌ ក្នុងផ្នែកវិបស្សនាធុរៈ និងជួសជុលសម្នាក់ប្រតិបត្តិធម៌វិវដ្ដៈ ។*

*២ - ដើម្បីជំរុញការសិក្សាផ្នែកបរិយត្តិ ដែលទាក់ទងនឹងការប្រតិបត្តិវិបស្សនាធុរៈ ។*

*៣ - ដើម្បីសហការជាមួយមូលនិធិនៃបមហានីពនន្ទ ក្នុងការថែរក្សា និងផ្សព្វផ្សាយពុទ្ធសាសនា ។*

*៤ - មិនធ្វើអ្វីទាក់ទងនឹងនយោបាយជាដាច់ខាត ។*

# មាតិការឿង

**ទំព័រ**

*កថាស្តីអំពីនគរប្រភពនៃបញ្ហា* ១

**កណ្ឌទី ១** - *ពាហិរកថា បុព្វយោគៈ ជាដើម* ៥

**កណ្ឌទី ២** - *មិលិន្ទប្បញ្ហាកណ្ឌ* ៤៦

**វគ្គទី ១ - មហាវគ្គ**

*បញ្ហាទី ១ - បញ្ញត្តិប្បញ្ហា* ៤៦

*បញ្ហាទី ២ - វស្សគណនប្បញ្ហា* ៥៦

*បញ្ហាទី ៣ - វិមំសនប្បញ្ហា* ៦២

*បញ្ហាទី ៤ - អនន្តកាយប្បញ្ហា* ៦៥

*បញ្ហាទី ៥ - បព្វជ្ជាបញ្ហា* ៧១

*បញ្ហាទី ៦ - បដិសន្ធិប្បញ្ហា* ៧៩

*បញ្ហាទី ៧ - យោនិសោមនសិការប្បញ្ហា* ៨០

*បញ្ហាទី ៨ - មនសិការលក្ខណប្បញ្ហា* ៨៣

*បញ្ហាទី ៩ - សីលលក្ខណប្បញ្ហា* ៨៥

*បញ្ហាទី ១០ - សម្បសាទនលក្ខណសទ្ធាបញ្ហា* ៩៥

*បញ្ហាទី ១១ - សម្បក្ខន្ទនលក្ខណសទ្ធាបញ្ហា* ៩៨

*បញ្ហាទី ១២ - វីរិយលក្ខណប្បញ្ហា* ១០១

*បញ្ហាទី ១៣ - សតិលក្ខណប្បញ្ហា* ១០៣

*បញ្ហាទី ១៤ - សមាធិប្បញ្ហា* ១០៩

*បញ្ហាទី ១៥ - បញ្ញាលក្ខណប្បញ្ហា* ១១១

*បញ្ហាទី ១៦ - នានាធម្មានំ ឯកកិច្ចអភិនិប្ផាទនប្បញ្ហា* ១១៤

## វគ្គទី ២ - អទ្ធានវគ្គ

បញ្ហាទី ១ - ធម្មសន្តតិបញ្ហា ១១៧
បញ្ហាទី ២ - បដិសន្ធហានបញ្ហា ១២៤
បញ្ហាទី ៣ - ញាណបញ្ញាបញ្ហា ១២៦
បញ្ហាទី ៤ - បដិសន្ធហានបុគ្គលវេទិយនបញ្ហា ១៣៤
បញ្ហាទី ៥ - វេទនាបញ្ហា ១៣៧
បញ្ហាទី ៦ - នាមរូបឯកត្តនានត្តបញ្ហា ១៤៣
បញ្ហាទី ៧ - ថេរបដិសន្ធហានាបដិសន្ធហានបញ្ហា ១៥៤
បញ្ហាទី ៨ - នាមរូបបដិសន្ធហានបញ្ហា ១៥៦
បញ្ហាទី ៩ - អទ្ធានបញ្ហា ១៥៨

## វគ្គទី ៣ - វិចារវគ្គ

បញ្ហាទី ១ - អទ្ធានមូលបញ្ហា ១៦២
បញ្ហាទី ២ - បុរិមកោដិបញ្ហា ១៦៥
បញ្ហាទី ៣ - កោដិបញ្ញាយនបញ្ហា ១៦៩
បញ្ហាទី ៤ - សង្ខារជាយមានបញ្ហា ១៧៣
បញ្ហាទី ៥ - ភវន្តសង្ខារជាយមានបញ្ហា ១៧៦
បញ្ហាទី ៦ - វេទគូបញ្ហា ១៨១
បញ្ហាទី ៧ - ចក្ខុវិញ្ញាណាទិបញ្ហា ១៨៧
បញ្ហាទី ៨ - ផស្សលក្ខណបញ្ហា ១៩៥
បញ្ហាទី ៩ - វេទនាលក្ខណបញ្ហា ១៩៧
បញ្ហាទី ១០ - សញ្ញាលក្ខណបញ្ហា ១៩៩
បញ្ហាទី ១១ - ចេតនាលក្ខណបញ្ហា ២០១

បញ្ហាទី ១២ - វិញ្ញាណលក្ខណបញ្ហា ២០៣

បញ្ហាទី ១៣ - វិតក្កលក្ខណបញ្ហា ២០៥

បញ្ហាទី ១៤ - វិចារលក្ខណបញ្ហា ២០៦

**វគ្គទី ៤ - និព្វានវគ្គ**

បញ្ហាទី ១ - ផស្សាទិវិនិព្ភុជនបញ្ហា ២០៨

បញ្ហាទី ២ - នាគសេនបញ្ហា ២១១

បញ្ហាទី ៣ - បញ្ចាយតនកម្មនិព្វត្តបញ្ហា ២១៣

បញ្ហាទី ៤ - កម្មនានាករណបញ្ហា ២១៦

បញ្ហាទី ៥ - វាយាមករណបញ្ហា ២១៩

បញ្ហាទី ៦ - នេរយិកគ្គិឧណ្ហភាវបញ្ហា ២២២

បញ្ហាទី ៧ - បឋវិសណ្ឋារកបញ្ហា ២២៦

បញ្ហាទី ៨ - និរោធនិព្វានបញ្ហា ២២៧

បញ្ហាទី ៩ - និព្វានលភនបញ្ហា ២៣០

បញ្ហាទី ១០ - និព្វានសុខជាននបញ្ហា ២៣៣

**វគ្គទី ៥ - ពុទ្ធវគ្គ**

បញ្ហាទី ១ - ពុទ្ធស្ស អត្ថិនត្ថិភាវបញ្ហា ២៣៥

បញ្ហាទី ២ - ពុទ្ធស្ស អនុត្តរភាវបញ្ហា ២៣៦

បញ្ហាទី ៣ - ពុទ្ធស្ស អនុត្តរភាវជាននបញ្ហា ២៣៨

បញ្ហាទី ៤ - ធម្មទិដ្ឋបញ្ហា ២៤០

បញ្ហាទី ៥ - អសង្កមនបដិសន្ធហនបញ្ហា ២៤០

បញ្ហាទី ៦ - វេទគូបញ្ហា ២៤៣

បញ្ហាទី ៧ - អញ្ញកាយសង្កមនបញ្ហា ២៤៣

*បញ្ហាទី ៨ - កម្មផលអត្ថិភាវបញ្ហា* ២៤៥
*បញ្ហាទី ៩ - ឧប្បជ្ជតិជាននបញ្ហា* ២៤៨
*បញ្ហាទី ១០ - ពុទ្ធនិទស្សនបញ្ហា* ២៥០

**វគ្គទី ៦ - សតវគ្គ**

*បញ្ហាទី ១ - កាយបិយាយនបញ្ហា* ២៥៣
*បញ្ហាទី ២ - សព្វញ្ញុភាវបញ្ហា* ២៥៥
*បញ្ហាទី ៣ - មហាបុរិសលក្ខណបញ្ហា* ២៥៨
*បញ្ហាទី ៤ - ភគវតោ ព្រហ្មចារិបញ្ហា* ២៦១
*បញ្ហាទី ៥ - ភគវតោ ឧបសម្បទាបញ្ហា* ២៦៣
*បញ្ហាទី ៦ - អស្សុភេសជ្ជាភេសជ្ជបញ្ហា* ២៦៥
*បញ្ហាទី ៧ - សរាគវីតរាគនានាករណបញ្ហា* ២៦៦
*បញ្ហាទី ៨ - បញ្ញាបតិដ្ឋានបញ្ហា* ២៦៧
*បញ្ហាទី ៩ - សង្សារបញ្ហា* ២៦៩
*បញ្ហាទី ១០ - ចិរកតសរណបញ្ហា* ២៧១
*បញ្ហាទី ១១ - អភិជានន្តសតិបញ្ហា* ២៧២

**វគ្គទី ៧ - អរូបធម្មវវត្ថានវគ្គ**

*បញ្ហាទី ១ - សតិឧប្បជ្ជនបញ្ហា* ២៧៦
*បញ្ហាទី ២ - ពុទ្ធគុណសតិបដិលាភបញ្ហា* ២៨២
*បញ្ហាទី ៣ - ទុក្ខប្បហានវាយាមបញ្ហា* ២៨៤
*បញ្ហាទី ៤ - ព្រហ្មលោកបញ្ហា* ២៨៩
*បញ្ហាទី ៥ - ទ្វិន្នំលោកុប្បន្នានំសមកភាវបញ្ហា* ២៩០
*បញ្ហាទី ៦ - ពោជ្ឈង្គបញ្ហា* ២៩៣

*បញ្ហាទី ៧ - បាបបុញ្ញានំ អប្បានប្បភាវប្បញ្ហា* ២៩៥
*បញ្ហាទី ៨ - ជានន្តាជានន្តបាបករណបញ្ហា* ២៩៦
*បញ្ហាទី ៩ - ឧត្តរកុរុកាទិគមនប្បញ្ហា* ២៩៨
*បញ្ហាទី ១០ - ទីឃដ្ឋិប្បញ្ហា* ៣០០
*បញ្ហាទី ១១ - អស្សាសបស្សាសនិរោធប្បញ្ហា* ៣០១
*បញ្ហាទី ១២ - សមុទ្ទប្បញ្ហា* ៣០៤
*បញ្ហាទី ១៣ - សមុទ្ទឯករសប្បញ្ហា* ៣០៥
*បញ្ហាទី ១៤ - សុខុមប្បញ្ហា* ៣០៥
*បញ្ហាទី ១៥ - វិញ្ញាណនានត្តប្បញ្ហា* ៣០៦
*បញ្ហាទី ១៦ - អរូបធម្មវវត្ថានទុក្ករប្បញ្ហា* ៣០៨
**មិលិន្ទប្បញ្ហាបុច្ឆាវិសជ្ជនា** ៣១១

★★★★★★★ ★★★★★★★

# ខុទ្ទកនិកាយ

## មិលិន្ទប្បញ្ហាបាលី

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

### កថាស្តីអំពីនគរប្រភពនៃបញ្ហា

**១** - *នៅសាគលនគរដ៏ឧត្តម ព្រះរាជាទ្រង់ព្រះនាមថា "* **មិលិន្ទ** *" ព្រះអង្គនោះ បានស្តេចយាងទៅរកព្រះនាគសេន ដូចទន្លេគង្គាហូរចុះទៅរកមហាសមុទ្រដូចនោះ ។ ព្រះរាជាទ្រង់មានពាក្យពេចន៍វិចិត្រ ទ្រង់ប្រថាប់អង្គុយសួរបញ្ហាដ៏ជ្រាលជ្រៅ ដែលទៅតាមឋានៈ (ហេតុ) និងមិនមែនឋានៈ (មិនមែនហេតុ) ជាច្រើនបញ្ហា ជាមួយព្រះនាគសេនត្ថេរ អ្នកដែលប្រៀបដូចគប់ភ្លើងបន្លុយភាពងងឹត ។ បុច្ឆា និង វិសជ្ជនា សុទ្ធតែមានអត្ថន័យជ្រាលជ្រៅគួរឱ្យចាប់ចិត្ត ពីរោះស្តាប់ គួរឱ្យភ្ញាក់ផ្អើល ធ្វើឱ្យព្រឺសម្បុរ ។ ពាក្យពេចន៍របស់ព្រះនាគសេន ចូលជ្រៅក្នុងព្រះអភិធម្ម និងព្រះវិន័យ បរិបូរដោយព្រះសូត្រយ៉ាងប្រទាក់ក្រឡា វិចិត្រដោយឧបមា និងន័យជាច្រើន ។*

*សូមលោកអ្នកទាំងឡាយ ផ្ចង់បញ្ញាស្មារតី ធ្វើចិត្តឱ្យរីករាយ ស្តាប់បញ្ហាដ៏ល្អិតល្អន់ជ្រាលជ្រៅ ជាគ្រឿងបំផ្លាញហេតុ ដែលគួរឱ្យសង្ស័យក្នុងមិលិន្ទប្បញ្ហានេះ ផងចុះ ។*

**២** - *តាមដែលបានស្តាប់តៗគ្នាមក មានរឿងតំណាលថា ៖ មាននគរមួយឈ្មោះ* **សាគល** *របស់ពួកយោនក ជាទីកន្លែងផ្លាស់ប្តូរទំនិញផ្សេង ៗ ស្រស់ត្រកាល ដោយដងទន្លេនិងភ្នំ មានទេសភាពគួរឱ្យត្រជាក់ត្រជំមនោរម្យយ៉ាងក្រៃលែង ព្រោះសម្បូរដោយ អារាម ឧទ្យាន ជាយព្រៃ ត្រពាំងទឹក ស្រះបោក្ខរណី មានដងទន្លេ ដងភ្នំ និង ជួរព្រៃ គួរឱ្យមនោរម្យ ។ មានតែអ្វីដែលអ្នកមានចំណេះដឹងកសាងទុក គ្មានសត្រូវយាយី សត្រូវមិនចូលទៅឈ្លានពានរុករាន ។ មានប៉មសង្កេតការណ៍ ស៊ុមទ្វារដ៏វិចិត្រត្រកាលជាច្រើន មានប៉មការពារដ៏ស្អាតវិចិត្រ មានកំពែងជញ្ជាំងសស្អាត តាំងនៅជុំវិញរាជធានី មានផ្លូវធំ ផ្លូវតូច ផ្លូវបំបែក ដែលកាត់គ្នាយ៉ាងមានរបៀប ។ នៅក្នុងទីផ្សារមានទំនិញល្អ ៗ ជាច្រើនមុខ ដាក់តាំងលក់យ៉ាងមានរបៀប ស្រស់ស្អាតដោយរោងទានជាច្រើនរយកន្លែង លម្អទៅដោយផ្ទះសម្បែង ស្នាក់អាស្រ័យយ៉ាងស្អាត ៗ រាប់សែនកន្លែង មើលទៅដូចកំពូលភ្នំហិមៈ ។ កុះករទៅដោយ ដំរី សេះ រទេះ អ្នកថ្មើរជើង មានក្រុមមនុស្សស្រីប្រុសធ្វើដំណើរចុះឡើង មានមនុស្សម្នានៅគ្រប់ទីកន្លែង ។ មានទាំងពួកក្សត្រ ពួកព្រាហ្មណ៍ ពួកវេស្សៈ និងពួកសូទ្រៈជាច្រើន ជាកន្លែងដែលអ្នកមានចំណេះដឹងរស់នៅ ។ បរិបូរដោយផ្សារក្រណាត់ជាច្រើនប្រភេទ មានក្រណាត់តម្បាញពីនគរកោដុម្ពរ ជាដើម ។ មានទីផ្សារលក់ផ្កា លក់គ្រឿងក្រអូបជាច្រើនមុខគួរឱ្យចាប់ចិត្ត ដាក់តាំងលក់យ៉ាងស្អាតជះក្លិនក្រអូបភាយ បរិបូរដោយរតនជាតិជាច្រើនយ៉ាង គួរឱ្យប្រាថ្នា ។ មានទីផ្សារដាក់តាំងទំនិញលក់បែរមុខទៅទិសទាំងឡាយ ជាទីដែលអ្នកជំនួញស្លៀកពាក់ស្អាតបាតចេញចូល ។ បរិបូរសព្វមុខទៅដោយកាក់ប្រាក់ កាក់មាស និងភាជនៈ ។ មានទង់*

ផ្កាលាបក់រវិច មានទ្រព្យសម្បត្តិ ធញ្ញាហារ និងឧបករណ៍ដែលធ្វើឱ្យសប្បាយចិត្តគ្រប់គ្រាន់ ។ មានជង្រុកស្រូវ មានឃ្លាំងទំនិញពេញបរិបូរ មានចំណីគ្រប់យ៉ាង ដែលជាអាហារទំពា អាហារហូប អាហារលិទ្ធ អាហារក្ញក់ និងភេសជ្ជៈ របស់ផឹកជាច្រើនមុខ ។ មានអង្ករបាយបរិបូរ ដូចឧត្តរកុរុទ្វីប (ឬ) ដូចនគរទេវតា ឈ្មោះថា អាឡកមន្ទា ។

# ពាក្យអធិប្បាយ ៖

ពាក្យថា **ពួកយោនក** ក្នុងទីនេះគឺពួកក្រិកដែលចូលមកតាំងទីលំនៅនៅនគរបញ្ចាបរបស់ប្រទេសឥណ្ឌា តាំងពីស្ដេចអាឡេចសង់ដ្រេមហារាជយកឈ្នះនគរនេះបានមក មិនមែនសំដៅទៅលើជនជាតិថៃម៉ុឡានណានោះទេ ដែលបណ្ឌិតស្នាក់នៅក្នុងនគរនេះហើយ គួរតែថ្លែងដល់បុព្វកម្ម (កម្មដែលធ្វើ នៅក្នុងជាតិមុន ) របស់លោកទាំងនោះ ។ មុននឹងថ្លែងដល់បុព្វកម្មក៏គួរតែថ្លែង បែងចែកជា ៦ កណ្ឌ សិន ។ **៦ កណ្ឌ** នោះមានអ្វីខ្លះ ? គឺមាន ១-បុព្វយោគកណ្ឌ ២-មិលិន្ទប្បញ្ហាកណ្ឌ ៣-លក្ខណប្បញ្ហាកណ្ឌ ៤-មេណ្ឌកប្បញ្ហាកណ្ឌ ៥-អនុមាណប្បញ្ហាកណ្ឌ ៦-ឧបមកថាបញ្ហាកណ្ឌ ។

ក្នុង ៦ កណ្ឌនោះ មិលិន្ទប្បញ្ហាកណ្ឌបែងចេញជា ២ គឺ ១-លក្ខណប្បញ្ហា ២-វិមតិច្ឆេទនប្បញ្ហា ។ សូម្បីតែមេណ្ឌកប្បញ្ហាកណ្ឌ ក៏បែងចេញជា ២ ដែរគឺ ១-មហាវគ្គ ២-យោគិកថាបញ្ហា ១ ។

ក្នុង ៦ កណ្ឌនេះ កម្មដែលបុគ្គលទាំង ២ គឺ ព្រះចៅមិលិន្ទ និងព្រះនាគសេនត្ថេរ បានធ្វើកាលពីជាតិមុន ហៅថា " **បុព្វយោគកណ្ឌ** " ។

បញ្ហាដែលព្រះចៅមិលិន្ទ ទ្រង់ដាក់សំណួរដោយអង្គឯង មិនបានប្រារព្ធពាក្យនៅក្នុងព្រះសាសនា ហៅថា " **មិលិន្ទប្បញ្ហាកណ្ឌ** " ។

បញ្ហាដែលព្រះថេរមិលិន្ទ ទ្រង់ប្រារព្វទាក់ទងនឹងលក្ខណៈរបស់បុគ្គលជាដើម ហៅថា " **លក្ខណបញ្ហាកណ្ឌ** " ។

បញ្ហាដែលព្រះថេរមិលិន្ទ ត្រាស់សួរទាក់ទងនឹងពុទ្ធដីការបស់ព្រះពុទ្ធជាម្ចាស់ ដែលមានអត្ថន័យជា ២ យ៉ាងផ្សេងគ្នា មិនស្របគ្នា ហៅថា " **មេណ្ឌកបញ្ហាកណ្ឌ** " ។

បញ្ហាដែលព្រះថេរមិលិន្ទ ត្រាស់សួរទាក់ទងនឹងរឿងអនុមាណ ( មានរឿងឱ្យប៉ាន់ស្មានថា ប្រាកដជាយ៉ាងនេះ ប្រាកដជាយ៉ាងនោះ ) ហៅថា " **អនុមាណបញ្ហាកណ្ឌ** " ។

បញ្ហាដែលព្រះថេរមិលិន្ទ ត្រាស់សួរអំពីឧបមាប្រៀបធៀបអង្គគុណខ្លះរបស់ព្រះអរហន្តជាមួយ និងកិរិយាមួយចំនួនរបស់សត្វផ្សេង ៗ ហៅថា "**ឧបមកថាបញ្ហាកណ្ឌ** " ។

ចំណែកមិលិន្ទបញ្ហាកណ្ឌ ទោះជាមានដល់ ៧ វគ្គ ក៏ចាត់ទុកថា មាន ២ ផ្នែកដែរ ដោយទាក់ទងទៅនឹងរឿងដែលសួរដល់ គឺ មួយចំណែក ជាបញ្ហាសួរអំពីលក្ខណៈនៃធម៌មួយចំនួន ហៅថា " លក្ខណបញ្ហា " មួយចំណែកទៀត ជាបញ្ហាសួរអំពីធម៌ទាំងឡាយ ដើម្បីកាត់ការសង្ស័យដែលមានក្នុងធម៌ទាំងនោះ ហៅថា " វិមតិច្ឆេទនបញ្ហា " ។

មេណ្ឌកបញ្ហាកណ្ឌ ទោះជាមានដល់ ៨ វគ្គ ក៏បែងចែកជា ២ ចំណែក ដូចគ្នាដែរ គឺ មួយចំណែកជាបញ្ហាសួរអំពីវិសាលភាពនៃក្រុមធម៌មួយចំនួន ហៅថា " មហាវគ្គ " ។ មួយចំណែកទៀត ជាបញ្ហាសួរទាក់ទងអំពីបដិបទាមួយចំនួនរបស់ព្រះយោគី ហៅថា " យោគិកថាបញ្ហា " ៕

# កណ្ឌទី ១
# ពាហិរកថា

*បុព្វយោគៈ ជាដើម*

**៣** - *ពាក្យថា " **បុព្វយោគៈ** " គឺជាបុព្វកម្មរបស់បុគ្គលទាំង ២ នោះ ។ មានរឿងតំណាលថា ក្នុងអតីតកាល ពេលព្រះសាសនារបស់ព្រះដ៏មានព្រះភាគកស្សបសម្មាសម្ពុទ្ធប្រតិស្ឋាននៅឡើយនោះ មានព្រះភិក្ខុសង្ឃមួយចំនួនធំ អាស្រ័យនៅតាមទីអាវាសមួយកន្លែង ជិតទន្លេគង្គា ។ ក្នុងបណ្ដាភិក្ខុទាំងអស់នោះ ភិក្ខុដែលបរិបូរដោយចរិយវត្ត និងសីល នឹងក្រោកពីព្រលឹម កាន់អំបោសដងវែង នឹកដល់ព្រះពុទ្ធគុណ បោសសម្អាតទីធ្លា រួចប្រមូលសំរាមទុកជាគំនរម្ដុំ ៗ ។ ភិក្ខុមួយអង្គពោលទៅកាន់សាមណេរថា " ម្នាល ! សាមណេរ ចូរយកសំរាមនេះទៅបោះចោល " សាមណេរនោះក៏ដើរដូចមិនបានឮ ។ ទោះជាភិក្ខុហៅជាលើកទី ២ ជាលើកទី ៣ សាមណេរនោះ ក៏នៅតែដើរធ្វើព្រងើយ ដូចមិនបានឮដដែល ។ ព្រោះហេតុនោះ ភិក្ខុអង្គនោះ ក៏គិតថា " សាមណេរនេះក្បាលរឹងមែន " ក៏ខឹង រួចប្រើដងអំបោសវាយសាមណេរ ។ ពេលសាមណេរកំពុងយំ ព្រោះត្រូវវាយនោះ ក៏កើបសំរាមយកទៅបោះចោល បានតាំងសេចក្ដីប្រាថ្នាជាលើកដំបូងថា " **ដោយកម្មដែលជាបុណ្យ គឺការចោលសំរាមនេះ អំណឹះកាលតទៅ** (កន្លងផុតទៅ) **រហូតដល់យើងសម្រេចនិព្វាន សូមឱ្យយើងជាមនុស្សមានយសសក្តិខ្ពង់ខ្ពស់ មាន***

***តេជះខ្លាំងដូចព្រះអាទិត្យពេលថ្ងៃត្រង់ នៅគ្រប់កន្លែងដែលយើងកើតនោះផងចុះ*** ” ។ លុះបោលសំរាមហើយ ក៏ទៅកាន់ទន្លេគង្គា ដើម្បីស្រង់ទឹកក្នុងទន្លេគង្គា ដែលមានរលកប្រដេញគ្នាជាបន្តបន្ទាប់ ក៏តាំងសេចក្តីប្រាថ្នាជាលើកទី ២ ថា “ ***ក្នុងរវាងពេលរហូតតទៅ ទម្រាំយើងបានសម្រេចព្រះនិព្វាននេះ សូមឱ្យយើងជាមនុស្សមានបដិភាណកើតមានភ្លាម មានបដិភាណមិនចេះចប់ដូចទឹករលក នៅគ្រប់ទីកន្លែង ដែលយើងកើតផងចុះ*** ” ។

ចំណែកភិក្ខុអង្គនោះ លុះដាក់អំបោសរួចហើយ ក៏ទៅកាន់ទន្លេគង្គាដើម្បីស្រង់ទឹក បានឮសម្តីប្រាថ្នារបស់សាមណេរ ក៏គិតថា “ សាមណេរនេះទោះជាត្រូវយើងប្រើក្តី ក៏តាំងសេចក្តីប្រាថ្នាដូចនេះមុនយើង តើសេចក្តីប្រាថ្នានេះនឹងមិនសម្រេច ចំពោះយើងឬអី ? ” ទើបតាំងសេចក្តីប្រាថ្នាថា “ ***ក្នុងរវាងពេលរហូតដល់យើងសម្រេចព្រះនិព្វាននេះ សូមឱ្យយើងជាមនុស្សមានបដិភាណមិនចេះចប់ ដូចទឹករលកក្នុងទន្លេគង្គានេះផងចុះ សូមឱ្យយើងជាអ្នក ដែលអាចដោះស្រាយបញ្ហាបដិភាណ ដែលសាមណេរនេះ ចោទសួរគ្រប់យ៉ាង ផងចុះ*** ” ។

បុគ្គលទាំង ២ នោះ កើតវិលវល់នៅក្នុងទេវតានិងមនុស្សទាំងឡាយអស់រយៈពេលមួយពុទ្ធន្តរ ។ បន្ទាប់មក សូម្បីតែព្រះដ៏មានព្រះភាគរបស់ពួកយើងទាំងឡាយ ក៏បានសម្តែងទុកថា “ បុគ្គលទាំង ២ នេះ នឹងឧប្បត្តិឡើងដូចព្រះមោគ្គល្លីបុត្តត្ថេរ ឧប្បត្តិឡើងដូចនោះដែរ ។ នៅពេលកន្លងទៅអស់ ៥០០ ឆ្នាំ ចាប់ពីពេលបរិនិព្វានរបស់តថាគត បុគ្គលទាំង ២ នេះ នឹងឧប្បត្តិឡើង ។ បុគ្គលទាំង ២ នេះ នឹងបែងចែកធម៌និងវិន័យ ដែលតថាគតសម្តែងទុកយ៉ាងសុខុម ឱ្យអស់ភាពស្មុគស្មាញ ឱ្យអស់ចំណុចមន្ទិល ដោយអំណាចនៃសំណួរ ឧបមា និង យុត្តិ ក្នុងបញ្ហា ។

**៤** - ក្នុងបុគ្គលទាំង ២ នោះ សាមណេរ បានកើតជាព្រះរាជា ទ្រង់ព្រះនាមថា " **មិលិន្ទ** " នៅសាគលនគរក្នុងជម្ពូទ្វីប ទ្រង់ជាបណ្ឌិតដ៏វៃឆ្លាត មានបញ្ញា មានសមត្ថភាព មានធម្មតាត្រិះរិះសិន សឹមធ្វើ ។ រាល់លើក ទ្រង់ធ្វើតែអ្វីដែលគួរធ្វើ គឺ វិធីប្រកបការងារទាំងឡាយ ទាំងអតីត អនាគត និងបច្ចុប្បន្ន ។ ទ្រង់ថែមទាំងបានរៀនវិជ្ជាជាច្រើន វិជ្ជាទាំងនោះមានអ្វីខ្លះ ? ដូចជា សូតិ សម្មតិ សំខ្យា យោគៈ នីតិ វិសេសិកា គណិកា គន្ធព្វា តិកិច្ឆា ចតុព្វេទៈ បុរាណៈ ឥតិហាសៈ ជោតិសា មាយា ហេតុ មន្តនា យុទ្ធៈ ឆន្ទសៈ សរុប ១៩ វិជ្ជា ដោយរួមទាំងព្រះពុទ្ធវចនៈផងដែរ ។ ទ្រង់ជាវិតណ្ឌវាទី ( មានវាទៈធ្វើឱ្យចិត្តអ្នកដទៃញាប់ញ័របាន ) ជាមនុស្សដែលគេគ្រប់គ្នាពិបាកចូលជិត ( មិនហ៊ានប្រឈមមុខ ) ជាមនុស្សដែលគ្មានអ្នកណាអាចគ្របសង្កត់បាន អាចចាត់ទុកថាទ្រង់ជាកំពូល ក្នុងបណ្តាមេលទ្ធិទាំងឡាយក្នុងជម្ពូទ្វីប នឹងរកបុគ្គលណាប្រៀបស្មើនឹងព្រះចៅមិលិន្ទមិនបាន មិនថាដោយកម្លាំង ដោយភាពរាងវៃ ដោយភាពក្លាហាន ឬ ដោយបញ្ញា ។ ទ្រង់ជាមនុស្សដ៏ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគសម្បត្តិច្រើន មានពលសេនា និង ពាហនៈច្រើន រកទីបំផុតគ្មាន ។

## ពាក្យអធិប្បាយ ៖

ពាក្យថា " **សូតិ** " គឺ សព្ទសាស្ត្រ អក្សរសាស្ត្រ ស្តីពីភាសាផ្សេងៗ ។

ពាក្យថា " **សម្មតិ** " គឺ ធម្មសាស្ត្រ ស្តីអំពី គោលការណ៍ វិនិច្ឆ័យក្តីរបស់ព្រះរាជា ឬរបស់ហ្លួង ។

ពាក្យថា " **សំខ្យា** " គឺ សំខ្យាសាស្ត្រ ស្តីពីគោលការណ៍រាប់ចំនួន ។

ពាក្យថា " **យោគៈ**" គឺ យោគសាស្ត្រ ស្តីពីការប្រើវត្ថុមន្តអាគម ជាការធានាថា នឹងមិនកើតមានគ្រោះភ័យផ្សេងៗ នាពេលអនាគត ។

ពាក្យថា "**នីតិ**" គឺ នីតិសាស្ត្រ ស្តីអំពីប្រការដែលព្រះរាជានិងប្រជារាស្ត្រនៅលើលោកគួរប្រព្រឹត្ត ។

ពាក្យថា " **វិសេសិកា** " គឺ សាស្ត្រដែលស្តីអំពីការប្រើឧបករណ៍ មានឧបករណ៍ថ្វីង ... ធ្នូសសរ ... ជាដើម វិជ្ជាសំណាង ។

ពាក្យថា " **គណិកា** " គឺ គណិតសាស្ត្រ ។

ពាក្យថា " **គន្ធព្វា** " គឺ វិជ្ជារាំរបាំ ច្រៀង ប្រគំតន្ត្រី ។

ពាក្យថា " **តិកិច្ឆា** " គឺ វេជ្ជសាស្ត្រ ។

ពាក្យថា " **ចតុព្វេទា** " គឺ វេទទាំង ៤ គឺ ឥរុវេទ សាមវេទ យជុវេទ អាថព្វវេទ ។

ពាក្យថា " **ឥតិហាសៈ** " គឺ ប្រវត្តិវិជ្ជា ។

ពាក្យថា " **ជោតិសោ** " គឺ ព្យាករណសាស្ត្រ ។

ពាក្យថា " **មាយា** " គឺ មាយាសាស្ត្រ ។

ពាក្យថា " **ហេតុ** " គឺ វិជ្ជាស្តីអំពី និមិត្តហេតុល្អ និមិត្តហេតុអាក្រក់ ។

ពាក្យថា "**មន្តនា** " គឺ វិជ្ជាទស្សន៍ទាយពីអ្វីដែលចង់ដឹង ជាសាស្ត្ររបស់ពួកពិទ្យាធរ ។

ពាក្យថា " **យុទ្ធៈ** " គឺ យុទ្ធសាស្ត្រ ឬវិជ្ជាស្តីអំពីការរៀបចំក្បួនទ័ព ។

ពាក្យថា " **ឆន្ទសៈ** " គឺ ឆន្ទសាស្ត្រ ស្តីអំពីកិច្ច ដែលត្រូវធ្វើសម្រាប់ស្ត្រីមានការរៃអំបោះ ជាដើម ឬ កិច្ចដែលត្រូវធ្វើសម្រាប់បុរស មានការត្បូរស្រែ ... ជាដើម ដែលអាចធ្វើបានតាមឆន្ទៈពេញចិត្តរបស់ខ្លួន ។

**៥** - ថ្ងៃមួយ ព្រះថៅមិលិន្ទ ទ្រង់មានបំណងចង់ត្រួតពលសេនា ព្រមទាំងពាហនៈ ដ៏ច្រើនលើសលប់ រកទីបំផុតគ្មាន ដែលរៀបចំជាក្បួនទ័ពប្រកបដោយពលសេនាទាំង ៤ ក្រុមទ័ព ទើបស្ដេចយាងចេញពីរាជធានីទៅលុះរួចរាល់ ពីការត្រួតពិនិត្យសេនាក្រុមទ័ពខាងក្រៅរាជធានីហើយ ព្រះរាជាដែលទ្រង់ចូលចិត្តការសន្ទនាឆ្លើយឆ្លង (មានវាទៈ) មុតស្រួច ស្ទាត់ជំនាញ មានព្រះទ័យខ្វល់ខ្វាយតែនឹងការសន្ទនាជាមួយពួកវិតណ្ឌជនអំពីរឿងរ៉ាវក្នុងលោក ទ្រង់ងើយព្រះភក្ត្រទតមើលព្រះអាទិត្យ ត្រាស់ហៅអាមាត្យទាំងឡាយមក ទ្រង់មានបន្ទូលថា " ម្នាល ! នាយទាំងឡាយ មិនទាន់ល្ងាចទេ នៅសល់ពេលច្រើនទៀត យើងត្រឡប់ចូលរាជធានីវិញពេលនេះទៅធ្វើអ្វី ? សមណៈ ឬ ព្រាហ្មណ៍ ដែលជាមេក្រុម មេគណៈ ជាគ្រូបា-អាចារ្យប្រចាំគណៈ ឬ អ្នកដែលអះអាងខ្លួនថា ជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់អ្នកដែលអាចសន្ទនាជាមួយយើង ដើម្បីកម្ចាត់ការសង្ស័យរបស់យើង នៅមាន យើងនឹងចូលទៅសួរបញ្ហាជាមួយនឹងសមណៈ ឬព្រាហ្មណ៍នោះ យើងចង់បន្ថយការសង្ស័យរបស់យើង " ។

បន្ទាប់ពីមានបន្ទូលរួចហើយ ពួកបម្រើរាជការយោនកចំនួន ៥០០ បានក្រាបបង្គំ ទូលថ្វាយសេចក្ដីនោះចំពោះព្រះថៅមិលិន្ទថា " បពិត្រព្រះមហារាជ ! សាស្ដា ទាំង ៦ គឺ លោកបូរណកស្សបៈ លោកមក្ខលិគោសាល លោកនិគ្រន្ថនាថបុត្រ លោកសញ្ជយវេលដ្ឋបុត្រ លោកអជិតកេសកម្ពល លោកបកុទ្ធកច្ចាយនៈ ក៏មាន ។ គ្រូបាអាចារ្យទាំង ៦ នោះ សុទ្ធតែជាមេក្រុម មេគណៈ ជាគ្រូបាអាចារ្យប្រចាំគណៈ ជាមនុស្សមានចំណេះដឹង មនុស្សជាច្រើនគោរពគេថាជាមនុស្សល្អ ។ បពិត្រព្រះមហារាជ ! សូមព្រះអង្គទ្រង់

*ស្ដេចយាងទៅសួរបញ្ហាជាមួយនឹងសាស្ដាទាំង ៦ នោះ សូមព្រះអង្គទ្រង់កម្ចាត់ការសង្ស័យចុះ ក្រាបទូល ” ។*

# ពាក្យអធិប្បាយ ៖

*ពាក្យថា “ **សាស្ដាទាំង ៦** ” គឺ សាស្ដា ៦ នាក់ ដែលមានឈ្មោះដូចសាស្ដា ៦ នាក់កាលពីសម័យពុទ្ធកាល ពោលគឺ លោកបូរណកស្សបៈ ជាអ្នកដែលមានឈ្មោះ ដូចលោកបូរណកស្សបៈ សម័យពុទ្ធកាល ។ លោកមក្ខលិគោសាល ជាអ្នកមានឈ្មោះដូចលោកមក្ខលិគោសាល សម័យពុទ្ធកាល ... ដូចនេះ ជាដើម ( អដ្ឋកថាអធិប្បាយដូចនេះ ពិតមែន ប៉ុន្តែមានពាក្យអធិប្បាយក្នុងន័យម្យ៉ាងទៀត ក៏គួរឱ្យត្រងត្រាប់ដែរគឺ សាស្ដាម្នាក់នេះ ពីមុនទោះជាមានឈ្មោះមានត្រកូលថា យ៉ាងដូចម្ដេចក្ដី ប៉ុន្តែដោយសារតែជាសិស្សរបស់លោកបូរណកស្សបៈ ប្រកាសលទ្ធិរបស់លោកបូរណកស្សបៈ ទើបមានឈ្មោះថា បូរណកស្សបៈ មនុស្សទាំងឡាយហៅថា បូរណកស្សបៈ ។ លោកម្នាក់ទៀត ព្រោះជាសិស្សរបស់លោកមក្ខលិគោសាល ប្រកាសលទ្ធិរបស់លោកមក្ខលិគោសាល ទើបមានឈ្មោះថាជា មក្ខលិគោសាល មនុស្សទាំងឡាយ ហៅថា មក្ខលិគោសាល យ៉ាងនេះជាដើម ) ។*

**៦** - *ពេលនោះ ព្រះចៅមិលិន្ទ និងពួកបម្រើរាជការយោនក ៥០០ នាក់ ស្ដេចយាងឡើងរទេះព្រះទីនាំងដ៏ល្អវិចិត្រ ចូលទៅរកលោកបូរណកស្សបៈដល់កន្លែងស្នាក់នៅ ។ លុះយាងដល់ហើយ ក៏ទ្រង់រីករាយជាមួយលោកបូរណកស្សបៈ ត្រាស់សម្មោទនីយកថា ដែលជាទីរឭកដល់គ្នា រួចពល់*

ហើយ ក៏ទ្រង់ប្រថាប់អង្គុយនៅកន្ទែងសមរម្យម្ខាង ។ លុះព្រះចៅមិលិន្ទ ទ្រង់ប្រថាប់អង្គុយកន្ទែងសមរម្យហើយ ក៏បានត្រាស់សួរសេចក្ដីនោះ ចំពោះលោកបូរណកស្សបៈថា " លោកកស្សបៈដ៏ចម្រើន អ្វីទៅដែលរក្សាលោកនេះ ? " ។ " សូមថ្វាយព្រះពរ មហាបពិត្រ គឺផែនដីដែលរក្សាលោកនេះ " ព្រះរាជា " លោកកស្សបៈដ៏ចម្រើន ប្រសិនបើផែនដីរក្សាលោកនេះ ពិតជាដូចនេះមែន ហេតុអ្វីបានជាសត្វដែលទៅនរកអវិចី ទើបច្នងកាត់ផែនដីនេះទៅបាន ? " ពេលត្រាស់ដូចនេះហើយ លោកបូរណកស្សបៈ មិនអាចលេប មិនអាចខ្ជាក់ អង្គុយឱនមុខ ឱន-ក នៅស្ងៀមឈឹង គ្មានយោបល់ ។

**៧** - បន្ទាប់ពីនោះ ព្រះចៅមិលិន្ទទើប ( ស្ដេចយាងឡើងរទេះព្រះទីនាំងទៅ ) ត្រាស់សួរសេចក្ដីនេះ ទៅកាន់លោកមក្ខលិគោសាលថា " លោកគោសាលដ៏ចម្រើន កម្មដែលជាកុសល ដែលជាអកុសល មានដែរឬទេ ? វិបាកផលនៃកម្មដែលធ្វើល្អ ធ្វើអាក្រក់ មានដែរឬទេ ? " " សូមថ្វាយព្រះពរ មហាបពិត្រ កម្មដែលជាអកុសលគ្មានទេ វិបាកផលនៃកម្មដែលធ្វើល្អធ្វើអាក្រក់ក៏គ្មានដែរ ។ សូមថ្វាយព្រះពរ ពួកជាក្សត្រនៅលោកនេះ ទោះជាទៅលោកខាងមុខ ក៏នៅតែជាក្សត្រដដែល ។ ពួកជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាចណ្ឌាល ជាអ្នកចាក់សំរាម ទោះជាទៅលោកខាងមុខ ក៏នៅតែជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាចណ្ឌាល ជាអ្នកចាក់សំរាមទៀតដដែល ។ ប្រយោជន៍អ្វីដោយកុសលកម្ម អកុសលកម្មទាំងអស់នោះ ? " ព្រះរាជា "លោកគោសាលដ៏ចម្រើន ប្រសិនបើអ្នកជាក្សត្រ ជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាចណ្ឌាល ជាអ្នកចាក់សំរាមនៅលើលោកនេះ ទោះជាទៅកាន់លោកខាងមុខ ក៏នៅតែជាក្សត្រ ជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជា

ចណ្ឌាល ជាអ្នកចាក់សំរាមទៀតដដែលនោះ អ្វីដែលសត្វធ្វើដោយជាកុសលកម្ម អកុសលកម្ម ក៏គ្មាន បើអ៊ីចឹងលោកគោសាល អ្នកដែលកំបុតដៃនៅលើលោកនេះ ទោះជាទៅលោកខាងមុខហើយ ក៏នៅតែជាមនុស្សកំបុតដៃអ៊ីចឹង ។ អ្នកដែលកំបុតជើង ក៏នៅតែជាមនុស្សកំបុតជើងដដែល ។ អ្នកដែលកំបុតទាំងដៃទាំងជើង ក៏នៅតែជាមនុស្សកំបុតទាំងដៃទាំងជើងអ៊ីចឹងដដែល ។ មនុស្សឆែបត្រចៀក ក៏នៅតែឆែបត្រចៀកដដែល ។ មនុស្សឆែបមាត់ ឆែបច្រមុះ ក៏នៅតែជាមនុស្សឆែបមាត់ ឆែបច្រមុះដដែលអ៊ីចឹង ” ពេលត្រាស់ដូចនេះហើយ លោកគោសាលក៏នៅស្ងៀម ។

បន្ទាប់ពីនោះ ព្រះចៅមិលិន្ទទ្រង់មានព្រះតម្រិះដូច្នេះថា ៖

“ ***អស់លោកដ៏ចម្រើនទាំងឡាយអើយ ! ជម្ពូទ្វីបទទេស្អាតទៅហើយ***
***អស់លោកដ៏ចម្រើនទាំងឡាយអើយ ! ជម្ពូទ្វីបមានតែអង្កាម***
***គ្មានអ្នកណាម្នាក់អាចសន្ទនាជាមួយយើង ដើម្បីបន្ទយការសង្ស័យរបស់យើងទេ*** ” ។

ពេលនោះ ព្រះចៅមិលិន្ទត្រាស់ហៅអាមាត្យទាំងឡាយ រួចមានបន្ទូលថា “ អស់លោកដ៏ចម្រើនទាំងឡាយ រាត្រីខែខ្មើតគួរឱ្យសុខដុមណាស់ហ្ន៎ ធ្វើម្តេចទៅ ថ្ងៃនេះ យើងគួរតែចូលទៅរកសមណៈ ឬ ព្រាហ្មណ៍ ដើម្បីសួរបញ្ហា ។ អ្នកណាទៅហ្ន៎ ! អាចសន្ទនាជាមួយយើង ដើម្បីបន្ទយការសង្ស័យបាន ” ។ នៅពេលមានបន្ទូលដូចនេះហើយ ពួកអាមាត្យទាំងឡាយ បានតែឈរនៅស្ងៀម សម្លឹងព្រះភក្ត្រព្រះរាជា ។

នៅសម័យនោះ សាគលនគរ ក្លាយជានគរដែលទំនេរប្រាសចាកពីសមណៈ ព្រាហ្មណ៍ គហបតី ដែលជាបណ្ឌិតដល់ទៅ ១២ ឆ្នាំ ។ ព្រះរាជាទ្រង់ស្តាប់ឮថា សមណៈ ព្រាហ្មណ៍ គហបតី ដែលជាបណ្ឌិតអាស្រ័យនៅទី

ណា ទ្រង់នឹងយាងទៅកាន់ទីនោះ ត្រាស់សួរបញ្ហាជាមួយបណ្ឌិតទាំងនោះ ពួកបណ្ឌិតគ្រប់រូប មិនអាចធ្វើឱ្យព្រះរាជា ទ្រង់រីករាយនឹងពាក្យឆ្លើយ វិសជ្ជនាបញ្ហាបាន ទើបគេចចេញទៅតាមផ្លូវផ្សេង ៗ ។ ពួកដែលមិនព្រម ទៅទិសផ្សេង (គឺនៅប្រចាំកន្លែងដើម) បានតែនៅស្ងៀមទាំងអស់គ្នា ។ ចំណែកព្រះភិក្ខុទាំងឡាយ ភាគច្រើននាំគ្នាទៅកាន់ភ្នំហិមពាន្ត ។

# ពាក្យអធិប្បាយ ៖

ពាក្យថា " **ចំណែកព្រះភិក្ខុទាំងឡាយ ភាគច្រើននាំគ្នាទៅកាន់ភ្នំហិមពាន្ត** " នោះ គឺ មានតែព្រះភិក្ខុដែលមានឫទ្ធិប៉ុណ្ណោះ ។ ព្រះភិក្ខុដែលគ្មានឫទ្ធិមិនអាចទៅកាន់ភ្នំហិមពាន្តបានទេ ជាព្រះភិក្ខុដែលរាប់ចូលក្នុងពាក្យថា " **ពួកដែលមិនព្រមទៅទិសផ្សេង បានតែនៅស្ងៀមទាំងអស់គ្នា** " ។

**៨** - នៅសម័យនោះ មានព្រះអរហន្ត ១០០ កោដិ អាស្រ័យនៅរក្ខិត្តលវិហារ លើភ្នំហិមពាន្ត ។ ពេលនោះ ព្រះអស្សគុត្តបានស្ដាប់ឮពាក្យតម្រាស់របស់ព្រះចៅមិលិន្ទដោយទិព្វសោតធាតុញ្ញាណ (ញាណគឺត្រចៀកទិព្វ ) រួចក៏បានកោះប្រជុំព្រះភិក្ខុសង្ឃ នៅលើកំពូលភ្នំយុគន្ធរ សួរទៅភិក្ខុទាំងឡាយថា " ព្រះគុណម្ចាស់ដ៏មានអាយុទាំងឡាយ តើមានភិក្ខុណាអាចសន្ទនាជាមួយព្រះចៅមិលិន្ទ ដើម្បីបន្ថយការសង្ស័យខ្លះដែរឬទេ? " ។

នៅពេលព្រះអស្សគុត្តពោលដូចនេះហើយ ព្រះអរហន្ត ១០០ កោដិ បានតែនៅស្ងៀម ប៉ុណ្ណោះ ។ ព្រះអស្សគុត្តសួរជាលើកទី ២ ទោះជាសួរជាលើកទី ៣ ក៏នៅតែនៅស្ងៀម ។ ដូចនោះហើយ ទើបព្រះអស្សគុត្តពោល សេចក្ដីនោះ ទៅកាន់ព្រះភិក្ខុសង្ឃថា " ព្រះគុណម្ចាស់ដ៏មានអាយុទាំងឡាយ

នៅឋានតាវត្តិង្ស មានវិមានមួយ ឈ្មោះថា កេតុមតី នៅទិសបូព៌ានៃវេជយន្តប្រាសាទ ។ ទេវបុត្រមួយអង្គ ឈ្មោះថា **មហាសេន** អាស្រ័យនៅក្នុងវិមាននោះ ទេវបុត្រអង្គនោះ អាចសន្ទនាជាមួយព្រះចៅមិលិន្ទព្រះអង្គនោះ ដើម្បីបន្ថយការសង្ស័យបាន ” ។

បន្ទាប់ពីនោះ ព្រះអរហន្ត ១០០ កោដិ ក៏បានអន្តរធានបាត់អង្គពីភ្នំយុគន្ធរ ទៅបង្ហាញអង្គនៅឋានតាវត្តិង្ស ។ ស្តេចសក្កៈកំពូលនៃទេព ( សក្កទេវរាជ ) បានទតព្រះនេត្រឃើញព្រះភិក្ខុមក អំពីចម្ងាយទាំងអស់នោះ ឃើញហើយក៏យាងចេញ ទៅរកព្រះអស្សគុត្ត ។ លុះចូលទៅដល់ហើយ ទ្រង់ក្រាបសំពះព្រះអស្សគុត្ត រួចឈរនៅកន្លែងសមរម្យម្ខាង ។ សក្កទេវរាជ ពេលឈរនៅកន្លែងសមរម្យម្ខាងហើយ ក៏បានត្រាស់សេចក្តីនោះទៅកាន់ព្រះអស្សគុត្តថា “ ព្រះគុណម្ចាស់ ! ព្រះភិក្ខុសង្ឃមួយក្រុមធំ បាននិមន្តមកដល់ ញោមជាកូនសិស្សវត្តរបស់សង្ឃ ព្រះសង្ឃមានសេចក្តីត្រូវការដោយរឿងអ្វី ? មានអ្វីឱ្យញោមត្រូវធ្វើឬ ព្រះគុណម្ចាស់ ? ”

លំដាប់នោះ ព្រះអស្សគុត្តបានថ្វាយព្រះពរ ជម្រាបសេចក្តីនោះចំពោះសក្កទេវរាជថា “ សូមថ្វាយព្រះពរ មហាបពិត្រ នៅសាគលនគរក្នុងជម្ពូទ្វីប មានព្រះរាជាព្រះនាមថា **មិលិន្ទ** ទ្រង់ជាអ្នកមានវាទៈ ធ្វើឱ្យចិត្តអ្នកដទៃញាប់ញ័របាន ជាមនុស្សដែលគេគ្រប់គ្នាពិបាកចូលជិត ពិបាកនឹងគ្របសង្កត់បាន ពោលបានថា ទ្រង់ជាកំពូលនៃបណ្ដាមេលទ្ធិផ្សេងៗ ។ ព្រះចៅមិលិន្ទនោះ បានយាងទៅរកព្រះភិក្ខុសង្ឃ ប្រើទិដ្ឋិវាទៈ សួរបញ្ហាកំហែងដល់ព្រះភិក្ខុសង្ឃ ” ។

ពេលនោះ សក្កទេវរាជបានមានបន្ទូលពីសេចក្តីនោះ ទៅកាន់ព្រះ

អស្សគុត្តថា " ព្រះគុណម្ចាស់ ! ព្រះចៅមិលិន្ទព្រះអង្គនោះ ទ្រង់ជាអ្នកដែលផ្លាស់អំពីឋាននេះ ទៅឧប្បត្តិនៅឋានមនុស្ស ព្រះគុណម្ចាស់ នៅកេតុមតីវិមាន មានទេវបុត្រឈ្មោះថា **មហាសេន** អាស្រ័យនៅវិមាននោះ ទេវបុត្រមួយអង្គនោះ អាចសន្ទនាជាមួយព្រះចៅមិលិន្ទព្រះអង្គនោះ ដើម្បីបន្ថយការសង្ស័យបាន ញោមនឹងសំណូមពរទេវបុត្រមួយអង្គនោះ ដើម្បីឱ្យទៅឧប្បត្តិក្នុងលោកមនុស្ស " ។

បន្ទាប់ពីនោះ សក្កទេវរាជទ្រង់ឱ្យព្រះភិក្ខុសង្ឃនាំមុខ ស្តេចយាងទៅកាន់កេតុមតីវិមាន ។ ទ្រង់ចូលទៅឱបមហាសេនទេវបុត្រ ត្រាស់សួរសេចក្តីនោះថា " ម្នាល ! លោកនិរទុក្ខ ព្រះភិក្ខុសង្ឃមកសំណូមពរលោកដើម្បីឱ្យទៅឧប្បត្តិក្នុងលោកមនុស្ស " មហាសេនទេវបុត្រ ក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន ! ប្រយោជន៍អ្វីដោយលោកមនុស្ស ដែលមានការងារច្រើនស្មុគស្មាញ ក្រាបទូល ? លោកមនុស្សអន់ថយ បពិត្រព្រះអង្គដ៏ចម្រើន ! ទូលបង្គំសូមឧប្បត្តិនៅក្នុងទេវលោកនេះតទៅទៀត រហូតដល់បរិនិព្វាន ក្រាបទូល " ។ សក្កទេវរាជទ្រង់សំណូមពរជាលើកទី ២ សំណូមពរជាលើកទី ៣ ទោះជាយ៉ាងនោះក្តី មហាសេនទេវបុត្រក៏នៅតែថ្លែងថា " បពិត្រព្រះអង្គដ៏ចម្រើន ! ប្រយោជន៍អ្វីដោយលោកមនុស្ស ដែលមានការងារច្រើនស្មុគស្មាញ ក្រាបទូល ? លោកមនុស្សអន់ថយ បពិត្រព្រះអង្គដ៏ចម្រើន ! ទូលបង្គំសូមឧប្បត្តិនៅក្នុងទេវលោកនេះតទៅទៀត រហូតដល់បរិនិព្វាន ក្រាបទូល " ។

បន្ទាប់ពីនោះ ព្រះអស្សគុត្តទើបថ្លែងសេចក្តីនោះ ទៅកាន់មហាសេនទេវបុត្រ ថា " **លោកនិរទុក្ខ អាត្មាភាពគ្រប់អង្គ បានត្រួតពិនិត្យមើលលោកទាំងមូល ព្រមទាំងទេវតាផង មើលមិនឃើញថាមានអ្នកណាផ្សេង ដែលអាច**

*បំផ្លាញវាទៈរបស់ព្រះថេរមិលិន្ទ ទ្រទ្រង់ព្រះសាសនាបាន លើកលែងតែលោកម្នាក់គត់ ។ លោកជាសប្បុរស សូមលោកទៅកើត នៅក្នុងលោកមនុស្ស ទ្រទ្រង់ព្រះសាសនា របស់ព្រះទសពលផងចុះ "* ។ នៅពេលព្រះអស្សគុត្តថ្លែងសំណូមពរដូចនេះហើយ មហាសេនទេវបុត្រគិតថា " ***ទើបតែដឹងថា គឺមានតែយើងជាអ្នកអាចបំផ្លាញវាទៈព្រះថេរមិលិន្ទ ទ្រទ្រង់ព្រះសាសនាបាន*** " ក៏រីករាយសប្បាយចិត្តជាខ្លាំង ទើបសន្យាថា " ***ល្អណាស់ ព្រះគុណម្ចាស់ ខ្ញុំព្រះករុណានឹងទៅឧប្បត្តិនៅក្នុងលោកមនុស្ស*** " ។

**៩** - *គ្រានោះ ព្រះភិក្ខុទាំងនោះ លុះសម្រេចករណីយកិច្ចនោះក្នុងទេវលោក ហើយក៏អន្តរធានបាត់អង្គពីទេវលោកឋានតាវត្តិង្ស ទៅបង្ហាញអង្គនៅរក្ខិតតលវិហារ ជិតភ្នំហិមពាន្ត ។*

*គ្រានោះ* **ព្រះអស្សគុត្ត** *បានពោលសេចក្តីនោះ ចំពោះព្រះភិក្ខុសង្ឃថា " ព្រះគុណម្ចាស់ដ៏មានអាយុទាំងឡាយ ក្នុងបណ្តាភិក្ខុទាំងឡាយនេះ តើមានភិក្ខុអង្គណា មិនបានមកប្រជុំខ្លះដែរទេ ? " ។ នៅពេលព្រះថេរៈពោលសួរដូចនេះ ភិក្ខុមួយអង្គបានប្រាប់សេចក្តីនោះ ដល់ព្រះអស្សគុត្តថា "មាន ... ព្រះគុណម្ចាស់ដ៏ចម្រើន កាលពី ៧ ថ្ងៃមុននេះ ព្រះគុណម្ចាស់រោហណៈ បានចូលទៅភ្នំហិមពាន្តចូលនិរោធ សូមព្រះគុណម្ចាស់បញ្ជូនតំណាងទៅកាន់សម្នាក់របស់ព្រះគុណម្ចាស់រោហណៈនោះចុះ " ។ ចំណែកខាងលោករោហណៈ បានចេញពីនិរោធក្នុងខណៈនោះឯង គិតថា " ព្រះសង្ឃកំពុងរកយើង " ទើបអន្តរធានបាត់អង្គពីភ្នំហិមពាន្ត ទៅបង្ហាញអង្គនៅរក្ខិតតលវិហារ នៅចំពោះមុខព្រះអរហន្ត ១០០ កោដិ ។*

*លំដាប់នោះ* **ព្រះអស្សគុត្ត** *បានពោលសេចក្តីនោះ ទៅកាន់ព្រះ*

រោហណៈថា " ព្រះគុណម្ចាស់រោហណៈ ពេលព្រះពុទ្ធសាសនាបម្រុងនឹងត្រូវបំផ្លាញ ហេតុអ្វីទើបព្រះគុណម្ចាស់មិនក្រឡេកមើលករណីយកិច្ចរបស់ព្រះសង្ឃ ? " **ព្រះរោហណៈ** " ខ្ញុំព្រះករុណា មិនទាន់បានផ្តោតចិត្តទុកដាក់ព្រះគុណម្ចាស់ដ៏ចម្រើន " ។

**ព្រះអស្សគុត្ត** " បើអ៊ីចឹង ព្រះគុណម្ចាស់រោហណៈ សូមព្រះគុណម្ចាស់ធ្វើទណ្ឌកម្ម " ព្រះរោហណៈ " តើខ្ញុំព្រះករុណាត្រូវធ្វើអ្វី ឬ ព្រះគុណម្ចាស់ដ៏ចម្រើន ? " ( មិលិន្ទបញ្ហារបស់ថៃ ព្រះអស្សគុត្តពោល " ម្នាល ! ព្រះគុណម្ចាស់រោហណៈ ព្រោះព្រះគុណម្ចាស់មិនបានផ្តោតចិត្តទុកដាក់ ពួកយើងសូមដាក់ទោសព្រះគុណម្ចាស់ ដោយការដាក់ព្រហ្មទណ្ឌ" ព្រះរោហណៈ " ព្រហ្មទណ្ឌនោះគឺអ្វីទៅព្រះគុណម្ចាស់ដ៏ចម្រើន ? " ) " ម្នាល ! ព្រះគុណម្ចាស់រោហណៈ នៅក្បែរភ្នំហិមពាន្ត មានភូមិមួយរបស់ពួកព្រាហ្មណ៍ឈ្មោះថា " **គជង្គលៈ** " មានព្រាហ្មណ៍ម្នាក់ឈ្មោះ "**សោណុត្តរៈ**" អាស្រ័យនៅទីនោះ កុមារឈ្មោះ " **នាគសេន** " កូនរបស់គេនឹងកើតឡើង ព្រោះហេតុនោះ ព្រះគុណម្ចាស់រោហណៈ ចូរព្រះគុណម្ចាស់ទៅកាន់ផ្ទះត្រកូលនោះ ដើម្បីបិណ្ឌបាតរយៈពេល ៧ ឆ្នាំ ១០ ខែ រួចទាក់ទាញកុមារនាគសេនឱ្យបួស នៅពេលគេបួសរួចហើយនោះ ទើបព្រះគុណម្ចាស់រួចផុតពីទណ្ឌកម្ម"

បំណែក **ព្រះរោហណៈ** សុខចិត្តទទួលដោយស្រួលថា " សាធុ " ។

## ពាក្យអធិប្បាយ ៖

ពាក្យថា " **ចូលនិរោធ** " គឺ ចូលនិរោធសមាបត្តិ ជាការធ្វើចិត្តឱ្យរលត់

ទៅ មិនកើតបន្តបន្ទាប់គ្នាមួយរយៈពេល ដែលមានបំណងចូល គឺ ១ ថ្ងៃ ២ ថ្ងៃ រហូតដល់ ៧ ថ្ងៃ ។ ក្នុងពេលចូលនិរោធនេះ រាងកាយប៉ុណ្ណោះ ដែលនៅដំណើរការទៅមុខ ប៉ុន្តែចិត្តឬនាមធម៌ទាំងអស់ គឺឈប់ដំណើរការ ។

ពាក្យថា " **ខ្ញុំព្រះករុណាមិនទាន់បានផ្តោតចិត្តទុកដាក់** " លោកពោលបានន័យថា លោកចូលនិរោធនៅឡើយ មិនមានចិត្ត ទើបមិនអាចផ្តោតចិត្ត គឺ ទទួលដឹងរឿងរ៉ាវផ្សេង ៗ បាន ។

**១០** - ចំណែកខាងមហាសេនទេវបុត្រ បានផ្លាស់ពីទេវលោកមកចាប់បដិសន្ធិក្នុងផ្ទៃរបស់ភរិយាសោណុត្តរព្រាហ្មណ៍ ។ អ្វីដែលគួរឱ្យអស្ចារ្យ គួរឱ្យចម្លែកចិត្ត បានបង្ហាញឡើងជាមួយនឹងការចាប់បដិសន្ធិ គឺ អាវុធយុទ្ធ-កណ្ឌទាំងឡាយ បញ្ចេញពន្លឺឡើង ត្រួយសំណាបលាស់ឡើង មេឃដ៏ធំ (ភ្លៀង) ធ្លាក់ភ្លៀងយ៉ាងខ្លាំង ។

ចំណែកព្រះរោហណៈ តាំងពីមហាសេនទេវបុត្រនោះ ចាប់បដិសន្ធិហើយ ក៏ចូលទៅកាន់ត្រកូលនោះ ដើម្បីបិណ្ឌបាត អស់រយៈពេល ៧ ឆ្នាំ ១០ ខែ ។ សូម្បីបាយមួយវែក មួយថ្ងៃ ក៏មិនដែលបាន យាគូមួយបោយក៏មិនដែលបាន ឬការស្វាគមន៍ក៏មិនដែលបាន ទទួលបានតែការជេរជៀលត្មះប៉ុណ្ណោះ គ្មានអ្នកមកនិយាយជាមួយ សូម្បីតែពាក្យថា " និមន្តប្រោសសត្វខាងមុខចុះ " ក៏គ្មានដែរ ។

លុះ ៧ ឆ្នាំ ១០ ខែ កន្លងផុតទៅ ថ្ងៃមួយក៏បានត្រាន់តែពាក្យថា " និមន្តប្រោសសត្វខាងមុខចុះ " នៅថ្ងៃនោះ ជួនជា **ព្រាហ្មណ៍** ត្រឡប់ពីការងារខាងក្រៅផ្ទះ ជួបព្រះថេរៈពេលដើរជ្រួសផ្លូវគ្នា ក៏សួរថា "ព្រះគុណ-ម្ចាស់ដ៏ចម្រើន ព្រះគុណម្ចាស់បានទៅកាន់ផ្ទះរបស់ពួកយើងឬ ? " **ព្រះថេរៈ**

" មែនហើយព្រាហ្មណ៍ អាត្មាភាពបានទៅ " "ព្រះគុណម្ចាស់បានអ្វីៗខ្លះឬ ? " " អឺ ព្រាហ្មណ៍ អាត្មាបាន " ។

**ព្រាហ្មណ៍** នោះ មិនសប្បាយចិត្ត លុះទៅដល់ផ្ទះ ក៏សួរថា " ពួកឯង បានឱ្យអ្វី ៗ ដល់អ្នកបួសនោះឬ ? " **អ្នកផ្ទះ** ឆ្លើយថា " មិនបានឱ្យអ្វី ៗ នោះទេ " ។ នៅថ្ងៃទី ២ (ថ្ងៃបន្ទាប់) ព្រាហ្មណ៍អង្គុយនៅមាត់ទ្វារផ្ទះនោះ គិតថា "ថ្ងៃនេះ យើងនឹងចោទអ្នកបួសនោះ ពីរឿងនិយាយមិនពិត " នៅថ្ងៃទី ២ ព្រះថេរៈក៏ទៅដល់មាត់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ។

**ព្រាហ្មណ៍** លុះឃើញព្រះថេរៈ ក៏ពោលដូចនេះថា " ពីម្សិលមិញ ព្រះគុណម្ចាស់មិនបានទទួលអ្វីៗ ពីផ្ទះរបស់ខ្ញុំព្រះករុណាទេ ប៉ុន្តែប្រាប់ថា អាត្មាបាន ចំពោះព្រះគុណម្ចាស់ ការនិយាយមិនពិត វាគួរដែរឬអ្វី ? "

**ព្រះថេរៈ** ថ្លែងថា " ម្នាល ! ព្រាហ្មណ៍ អស់រយៈពេល ៧ ឆ្នាំ ១០ ខែ[១] ដែលអាត្មាចូលទៅផ្ទះរបស់ញោម អាត្មាមិនដែលបានសូម្បីតែពាក្យថា " និមន្តប្រោសសត្វខាងមុខចុះ " ពីម្សិលមិញទោះជាបានត្រឹមពាក្យថា " និមន្តប្រោសសត្វខាងមុខចុះ " ក៏អាត្មាសំដៅយកវាចាបដិសណ្ឋារកិច្ច ហើយពោលថា " អឺ ព្រាហ្មណ៍ អាត្មាបាន " ដូចនោះ " ។

**ព្រាហ្មណ៍** គិតថា " លោកមួយអង្គនេះ សូម្បីតែបានត្រឹមតែវាចាបដិសណ្ឋារកិច្ចប៉ុណ្ណោះ ក៏ពោលសរសើរក្នុងបណ្ដាជនទាំងឡាយថា " អាត្មាបាន " ប្រសិនបើលោកបានទទួលអាហារទំពា អាហារឆាន់អ្វីខ្លះផ្សេងទៀតនោះ មានហេតុអ្វីថា លោកមិនសរសើរនោះ " ដូចនេះហើយ ក៏មានសទ្ធាជ្រះថ្លា ប្រាប់ឱ្យគេរំលែកបាយមួយវែក និង ម្ហូបមួយមុខបន្តិច ៗ ពីអាហារដែលគេត្រៀមទុក ដើម្បីប្រយោជន៍ឱ្យខ្លួន ប្រគេនដល់ព្រះថេរៈ រួចពោល

[១] មិលិន្ទប្បញ្ហារបស់ថៃ ថ្លែងថា " អស់រយៈពេល ៧ ឆ្នាំ " ប៉ុណ្ណោះ ។

ទៅកាន់លោកថា " ព្រះគុណម្ចាស់នឹងបានភិក្សាហារនេះ រហូតតទៅអស់កាលទាំងពួង " ។

ព្រាហ្មណ៍នោះ ចាប់តាំងពីថ្ងៃបន្ទាប់មក ពេលបានឃើញភាពស្ងប់ស្ងៀមរបស់ព្រះថេរៈ ដែលចូលទៅ (ក្នុងផ្ទះ) ក៏រឹតតែមានសទ្ធាជ្រះថ្លាកាន់តែច្រើនឡើងទៀត ។ ទើបសំណូមពរព្រះថេរៈឱ្យខ្លួនមានឱកាសប្រគេនភត្តាហារក្នុងផ្ទះរហូតតទៅជានិច្ចកាល ព្រះថេរៈទទួលពាក្យនិមន្តដោយអាការស្ងប់ស្ងៀម ។ នៅពេលលោកទៅធ្វើភត្តកិច្ច ជារៀងរាល់ថ្ងៃ លោកបានថ្លែងព្រះពុទ្ធវចនៈ (ឱ្យព្រាហ្មណ៍ស្តាប់) មួយថ្ងៃបន្តិច ៗ ។ ចំណែកនាងព្រាហ្មណីនោះ វេលាកន្លងផុតទៅ ១០ ខែ ក៏ប្រសូតបុត្របានដាក់ឈ្មោះបុត្រនោះថា " **នាគសេន** " ចម្រើនធំធាត់ទៅតាមលំដាប់ រហូតដល់មាន អាយុ ៧ ខួប ។

**១១** - គ្រានោះ **បិតា** របស់កុមារនាគសេន បានពោលទៅកាន់បុត្រថា " ម្នាល ! នាគសេន ក្នុងត្រកូលព្រាហ្មណ៍នេះ ឯងត្រូវសិក្សាសិល្បសាស្ត្រដែលគប្បីសិក្សាទាំងឡាយណា " " បិតា ! ឈ្មោះថាសិល្បសាស្ត្រ ដែលគប្បីសិក្សាក្នុងត្រកូលព្រាហ្មណ៍នោះ គឺអ្វី ? " " នាគសេន ! ត្រៃវេទ ឈ្មោះថាសិល្បសាស្ត្រដែលគប្បីសិក្សា វិជ្ជាសិល្បៈដទៃផ្សេង ៗ ទៀត ក៏ឈ្មោះថា ជាសិល្បសាស្ត្រដែលគប្បីសិក្សាដែរ " " បើអ៊ីចឹងបិតា ! កូននឹងសិក្សា " ។

លំដាប់នោះ **សោណុត្តរព្រាហ្មណ៍** បានប្រគល់ប្រាក់ ១.០០០ កហាបណៈ ដែលជាចំណែករបស់គ្រូបាអាចារ្យ (ជាថ្លៃជួលគ្រូបាអាចារ្យ) ដល់ព្រាហ្មណ៍ជាគ្រូ ។ រួចឱ្យគេដាក់គ្រែនៅផ្នែកម្ខាងនៃបន្ទប់ក្នុងប្រាសាទ ពោលទៅកាន់ព្រាហ្មណ៍ជាគ្រូថា " ម្នាលលោកព្រាហ្មណ៍ សូមលោកបង្រៀនកុមារ

នេះឱ្យស្វាធ្យាយមន្តទាំងឡាយផងចុះ ” ។ **ព្រាហ្មណ៍ជាគ្រូ** បានពោលទៅកាន់កុមារនាគសេនថា “ បើអ៊ីចឹង កុមារតូច ចូរឯងរៀនមន្តទាំងឡាយចុះ ” ព្រាហ្មណ៍ជាគ្រូបានស្វាធ្យាយមន្ត ដោយលើកយកមកសម្តែងតែមួយដងប៉ុណ្ណោះ ។ កុមារនាគសេនក៏បានយល់ពីត្រៃវេទ ទន្ទេញចាំមាត់ ចាំទុកបានច្បាស់ កំណត់ទុកបានល្អ ធ្វើទុកក្នុងចិត្តបានល្អ ។ គ្រាន់តែមួយដងប៉ុណ្ណោះ ក៏កើតកែវភ្នែកឃើញត្រៃវេទ ជាអ្នកចេះដឹង ជំនាញខាងអធិប្បាយក្នុងគម្ពីរសណិខណ្ឌុ និង កេដុភៈ ក្នុងគម្ពីរសាក្ខរប្បភេទៈ ក្នុងសាស្ត្រទាំងឡាយដែលមានឥតិហាសៈជាគម្រប់ ៥ មិនមានខ្វះចន្លោះ ក្នុងគម្ពីរលោកាយតៈ និងមហាបុរិសលក្ខណៈ ។

ក្រោយមក **កុមារនាគសេន**បានពោលសេចក្តីនោះទៅកាន់បិតាថា ៖

“ បិតា ! សិល្បសាស្ត្រ ដែលគប្បីសិក្សា ក្នុងត្រកូលព្រាហ្មណ៍ ដែលប្រសើរជាងនេះ តើមានដែរទេ ? ឬក៏មានត្រឹមប៉ុណ្ណេះ ? ” ។

“ នាគសេន ! សិល្បសាស្ត្រ ដែលគប្បីសិក្សា ក្នុងត្រកូលព្រាហ្មណ៍ ដែលប្រសើរជាងនេះ គ្មានទេ ! សិល្បសាស្ត្រ ដែលគប្បីសិក្សា មានត្រឹមប៉ុណ្ណឹង ”

គ្រានោះ កុមារនាគសេន ដែលវាសនា (ការអប់រំចិត្ត) ក្នុងភពមុន ៗ ដាស់តឿនជំរុញចិត្តហើយ បានសាកសួរដេញដោលគ្រូបង្រៀន រួចក៏ចុះពីប្រាសាទទៅ ។ ពេលបានស្ងប់ស្ងាត់នៅកន្លែងកំបាំង ពិនិត្យមើលខាងដើម កណ្តាល ខាងចុង នៃវិជ្ជាសិល្បៈរបស់ខ្លួន មើលមិនឃើញមានសារសំខាន់សូម្បីតែបន្តិច ទោះជាខាងដើមក្តី កណ្តាលក្តី ចុងបំផុតក្តី ។ ទើបធ្វើឱ្យមិនសប្បាយចិត្ត មិនពេញចិត្ត គិតក្នុងចិត្តថា “លោកដ៏ចម្រើនទាំងឡាយអើយ ! ព្រះវេទទាំងអស់នេះ គ្មានបានការទេ លោកដ៏ចម្រើនទាំងឡាយអើយ ! ព្រះវេទទាំងអស់នេះ ផ្តេសផ្តាស គ្មានប្រយោជន៍ ប្រាសចាកសារប្រយោជន៍ ” ។

**១២** - ក្នុងគ្រានោះដែរ ព្រះរោហណៈកំពុងគង់នៅសេនាសនវត្តនិយៈ ដឹងនូវកង្វល់ក្នុងចិត្តរបស់កុមារនាគសេន ដោយចិត្តរបស់លោក ក៏គ្រងសំពត់ កាន់បាត្រ និង ចីពរ អន្តរធានបាត់អង្គពីសេនាសនវត្តនិយៈ ទៅបង្ហាញអង្គនៅភូមិគជង្គលព្រាហ្មណ៍ ។ កុមារនាគសេន ឈរនៅនឹងស៊ុមមាត់ទ្វាររបស់ខ្លួន ក៏បានឃើញព្រះរោហណៈ និមន្តដើរមកអំពីចម្ងាយ ។

បន្ទាប់ពីឃើញហើយ ក៏ពេញចិត្ត សប្បាយចិត្ត រីករាយក្នុងចិត្ត កើតបីតិសោមនស្សថា " លោកមួយអង្គនេះជាបព្វជិត អាចដឹងនូវអ្វី ដែលជាសារប្រយោជន៍ខ្លះជាពុំខាន " គិតដូចនេះហើយ ក៏ចូលទៅរកព្រះរោហណៈ រហូតដល់កន្លែង ។ លុះចូលទៅហើយ ក៏បានពោលសេចក្តីនោះទៅកាន់ព្រះរោហណៈថា " លោកនិរទុក្ខ បុគ្គលដែលមានសិរសាត្រងោល គ្រងសំពត់កាសាវពស្ត្រដូចលោកម្ចាស់នេះ ឈ្មោះថាជាអ្នកណា ? " " ម្នាល ! កុមារតូច អាត្មាឈ្មោះថា ជាបព្វជិត " ។ **នាគសេន** " លោកនិរទុក្ខ ព្រោះហេតុអ្វីទើបលោកម្ចាស់ឈ្មោះថា ជាបព្វជិត ? " **ព្រះថេរៈ** " ព្រោះបានបណ្តេញមន្ទិលអាក្រក់ទាំងឡាយ ព្រោះហេតុនោះណ៎ាកុមារតូច ទើបអាត្មាឈ្មោះថា ជាបព្វជិត " ។ **នាគសេន** " លោកនិរទុក្ខ ហេតុអ្វីសក់ (និងពុកមាត់) របស់លោកម្ចាស់ ទើបមិនដូចអ្នកដទៃអ៊ីចឹង ? " **ព្រះថេរៈ** " ម្នាល ! កុមារតូច បព្វជិតឃើញបលិពោធ (ហេតុធ្វើឱ្យមានកង្វល់ចិត្ត) ១៦ យ៉ាង ទើបកោរសក់ និងពុកមាត់ចេញ ។ បលិពោធ ១៦ យ៉ាង គឺអ្វីខ្លះ ? អលង្ការបលិពោធ (បលិពោធគឺ គ្រឿងអលង្ការលម្អ)១, មណ្ឌនបលិពោធ (បលិពោធគឺ ការតែងម៉ូដ)១, តេលមក្ខនបលិពោធ (បលិពោធគឺ ប្រេងលាបសក់)១, ធោវនបលិពោធ (បលិពោធ គឺការកក់លាងជម្រះ)១, មាលាបលិពោធ (បលិពោធ

គឺ ក្លួងកម្រងផ្កា)១, គន្ធបលិពោធ (បលិពោធ គឺគ្រឿងក្រអូប)១, វាសនបលិ-ពោធ (បលិពោធគឺ ការអប់សក់)១, ហរីតកបលិពោធ (បលិពោធគឺ ផ្លែសម៉)១, អាមលកបលិពោធ (បលិពោធគឺ ផ្លែកន្ទួតព្រៃ)១, រង្គបលិពោធ (បលិ-ពោធគឺ ថ្នាំលាបពណ៌សក់)១, ពន្ធនបលិពោធ (បលិពោធគឺ ក្រណាត់ចង )១, កោច្ឆបលិពោធ (បលិពោធគឺ ក្រាសសិត)១, កប្បកបលិពោធ (បលិ-ពោធគឺ ជាងកាត់សក់ ជាងកក់សម្អាតសក់)១, វិជ្ជនបលិពោធ (បលិពោធគឺ ការសិត)១, ឩកាបលិពោធ (បលិពោធគឺ ចៃ)១, ពេលសក់បាត់បង់ទៅ មនុស្សទាំងឡាយក៏សោកសៅ ក្តៅក្រហាយក្នុងចិត្ត យំបូរបាច់ ទះទ្រូង ដល់ថ្នាក់វង្វេងឈ្លក់នឹងសម្រស់សក់ ១ , ម្នាល ! កុមារតូច មនុស្សទាំងឡាយខ្វល់ខ្វាយចិត្ត ក៏ព្រោះតែបលិពោធ ១៦ យ៉ាងនេះ រមែងធ្វើឱ្យវិជ្ជាសិល្បៈទាំងឡាយទាំងពួង ខូចបង់ទៅ ” ។ **នាគសេន** “ មើលចុះ លោកនិរទុក្ខ ព្រោះហេតុអ្វី បានជាសូម្បីតែសំពត់សម្លៀកបំពាក់របស់លោកម្ចាស់ ក៏មិនដូចនឹងអ្នកដទៃទាំងឡាយអ៊ីចឹង ? ” **ព្រះថេរៈ** “ កុមារតូច សម្លៀកបំពាក់ទាំងឡាយ កាមអាស្រ័យបាន របស់ប្រើប្រាស់របស់ពួកគ្រហស្ថ កាមអាស្រ័យបាន គ្រោះភ័យទាំងឡាយគ្រោះណាមួយនឹងកើតចេញពីសំពត់សម្លៀកបំពាក់ គ្រោះទាំងនោះរមែងមិនកើតមាន ចំពោះអ្នកគ្រងសំពត់កាសាវពស្ត្រទេ ព្រោះហេតុនោះ សូម្បីតែសំពត់សម្លៀកបំពាក់របស់អាត្មា ក៏មិនដូចនឹងអ្នកដទៃ ” **នាគសេន** “ លោកនិរទុក្ខ លោកម្ចាស់ចេះវិជ្ជាសិល្បៈឬ ? ” **ព្រះថេរៈ** “ អឺ កុមារតូច អាត្មាចេះវិជ្ជាសិល្បៈ ក្នុងលោកនេះមានមន្តដ៏ខ្ពង់ខ្ពស់បំផុត ទោះជាមន្តនោះក៏អាត្មាចេះដែរ ” **នាគសេន** “លោកនិរទុក្ខ លោកម្ចាស់អាចប្រគល់មន្តនោះឱ្យខ្ញុំព្រះករុណាបានដែរឬទេ? **ព្រះថេរៈ** “ អឺ ... កុមារតូច អាត្មាអាចប្រគល់ឱ្យឯងបាន ” ។ **នាគសេន** “ បើអ៊ីចឹង សូម

ប្រគល់មកឱ្យខ្ញុំព្រះករុណាចុះ ” ។ **ព្រះថេរៈ** “ ពេលនេះជាពេលមិនសមគួរណ៎ាកុមារតូច អាត្មាកំពុងតែចូលទៅតាមលំដាប់ផ្ទះ ដើម្បីបិណ្ឌបាត ” ។

លំដាប់នោះ កុមារនាគសេនក៏ទទួលបាត្រពីដៃ របស់លោករោហណៈមក និមន្តលោកឱ្យចូលទៅក្នុងផ្ទះ ប្រគេនម្ហូបចង្ហាន់ដល់លោក ដរាបឆ្អែតឱ្យគ្រប់គ្រាន់ ដោយអាហារទំពា អាហារឆាន់ដ៏ប្រណីត ដោយដៃរបស់ខ្លួនរួចពោលទៅកាន់ព្រះរោហណៈ ដែលឆាន់រួចរាល់ ហើយដកដៃចេញពីបាត្រថា “ លោកនិរទុក្ខ ពេលនេះ សូមលោកម្ចាស់ប្រគល់មន្តដល់ខ្ញុំព្រះករុណាផងចុះ ” **ព្រះថេរៈ** “ អាត្មានឹងប្រគល់ឱ្យ ពេលដែលឯងជាមនុស្សគ្មានបលិពោធ មាតាបិតាអនុញ្ញាតឱ្យកាន់ភេទបព្វជិត ដូចអាត្មា ” ។

គ្រានោះ **កុមារនាគសេន** បានចូលទៅរកមាតាបិតា ពោលថា “មាតា ! បិតា ! អ្នកបួសមួយអង្គនេះពោលថា “ ក្នុងលោកនេះមានមន្តដ៏ខ្ពង់ខ្ពស់បំផុត ទោះជាមន្តនោះ ក៏អាត្មាដឹង ប៉ុន្តែលោកនឹងមិនឱ្យមន្តនោះដល់អ្នក ដែលមិនមែនជាអ្នកបួស ក្នុងសម្នាក់របស់លោកទេ ខ្ញុំនឹងបួសក្នុងសម្នាក់របស់លោកមួយអង្គនេះ ដើម្បីរៀនមន្តដ៏ខ្ពង់ខ្ពស់បំផុតនោះ ” ។ លំដាប់នោះ **មាតាបិតា** របស់គេគិតក្នុងចិត្តថា “ កូនរបស់យើង ទោះជាបួសហើយ រៀនបានមន្តហើយ ក៏អាចត្រឡប់មកវិញបាន ” ដូចនេះហើយ ទើបអនុញ្ញាតថា “ ចូរកាន់ភេទបព្វជិតចុះ ” ។

**១៣** - គ្រានោះ ព្រះរោហណៈបាននាំកុមារតូចនាគសេន ចូលទៅកាន់សេនាសនវត្តនិយៈ (សេនាសនៈជិតផ្លូវដើរ ? ) ចូលទៅកាន់វិជម្ភវត្ថុវិហារ ។ លុះចូលទៅហើយ ក៏ស្នាក់នៅវិជម្ភវត្ថុវិហារបានមួយយប់ ក៏ចូលទៅរក្ខិតតលវិហារ លុះចូលទៅដល់ហើយ ក៏ឱ្យកុមារនាគសេនបានបួសក្នុង

*សម្នាក់ព្រះអរហន្ត ១០០ កោដិ ។* **ព្រះនាគសេន** *បានបួសហើយ ក៏បានពោលទៅកាន់ព្រះរោហណៈថា “ ព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាបានកាន់ភេទបព្វជិតរបស់លោកម្ចាស់ហើយ ឥឡូវនេះ សូមលោកម្ចាស់ប្រគល់មន្តដល់ខ្ញុំព្រះករុណាផងចុះ ” ។ លំដាប់នោះ* **ព្រះរោហណៈ** *គិតថា “ យើងគួរណែនាំព្រះនាគសេនអ្វីមុនទើបល្អ ក្នុងព្រះវិន័យ ឬ ព្រះសូត្រ ឬក៏ព្រះអភិធម្ម ? ” ដូចនេះហើយ លុះឃើញថាព្រះនាគសេនជាបណ្ឌិត អាចរៀនអភិធម្មបាន ដោយងាយស្រួល ទើបណែនាំក្នុងព្រះអភិធម្មជាមុន ។*

*អភិធម្មបិដកទាំងអស់ គឺ* **ធម្មសង្គណីបករណ៍** *ដែលលម្អទៅដោយតិកៈ និង ទុកៈ យ៉ាងនេះថា “ កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ” ជាដើម ។* **វិភង្គប្បករណ៍** *ដែលលម្អដោយវិភង្គ ១៨ មានខន្ធវិភង្គ ជាដើម ។* **ធាតុកថាបករណ៍** *ដែលបែងចែកជា ១៤ ប្រការមាន “ សង្គហោ អសង្គហោ ” ជាដើម ។* **បុគ្គលបុបញ្ញត្តប្បករណ៍** *ដែលបែងចែកជា ៦ ប្រការ មាន “ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ” ជាដើម ។* **កថាវត្ថុប្បករណ៍** *ដែលប្រមូលផ្តុំបែងចែកជា ១.០០០ សូត្រ គឺ សកវាទៈ(វាទៈភាគីខ្លួន) ៥០០ សូត្រ បរវាទៈ (វាទៈភាគីផ្សេង) ៥០០ សូត្រ ។* **យមកប្បករណ៍** *បែងចែកជា ១០ ប្រការ គឺ “ មូលយមកៈ ខន្ធយមកៈ ” ជាដើម ។* **បដ្ឋានប្បករណ៍** *បែងចែកជា ២៤ ប្រការ គឺ “ ហេតុប្បច្ច័យ, អារម្មណប្បច្ច័យ ” ជាដើម ដូចនេះ ។*

**ព្រះនាគសេន** *បានធ្វើឱ្យស្ទាត់ជំនាញ ដោយការស្វាធ្យាយតែមួយដងប៉ុណ្ណោះ រួចពោលថា “ ព្រះគុណម្ចាស់ដ៏ចម្រើន សូមឈប់ត្រឹមហ្នឹងសិន កុំអាលពោលតទៅទៀត ខ្ញុំព្រះករុណាសូមស្វាធ្យាយ ត្រឹមប៉ុណ្ណោះសិន ” ។*

**១៤** - *គ្រានោះ* **ព្រះនាគសេន** *បានចូលទៅរកព្រះអរហន្ត ១០០*

*កោដិ នៅកន្លែងដែលលោកស្នាក់នៅ ។ លុះចូលទៅហើយ ក៏បានពោលទៅកាន់ព្រះអរហន្ត ១០០ កោដិ ថា " ព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ ខ្ញុំព្រះករុណាសូមបកស្រាយព្រះអភិធម្មបិដកទាំងពួង ចូលក្នុងបទ ទាំង ៣ នេះដែលថា " កុសលាធម្មា អកុសលាធម្មា អព្យាកតាធម្មា " នោះ ដោយពិស្តារ "* **ព្រះអរហន្ត ១០០ កោដិ** *ពោលថា " សូមបកស្រាយទៅចុះ នាគសេន " ។*

*បន្តពីនោះ ព្រះនាគសេន បានបកស្រាយ ៧ បករណ៍ ដោយពិស្តារអស់ពេល ៧ ខែ (ទើបចប់) ។ ផែនដីបន្ទឺលាន់រំពង ទេវតាទាំងឡាយផ្តល់សាធុការ ព្រហ្មទាំងឡាយក៏ទះដៃ លម្អងចន្ទន៍និងផ្កាមណ្ឌារវៈ ដែលជារបស់ទិព្វ ក៏ពោយរាយបាចសាចចុះមក ។*

**១៥** - *នាពេលក្រោយមក ព្រះអរហន្ត ១០០ កោដិ ក៏ឱ្យព្រះនាគសេនដែលមានអាយុគ្រប់ ២០ ឆ្នាំបរិបូរ បានឧបសម្បទាជាភិក្ខុនៅរក្ខិតតលវិហារ ។ ក្នុងរាត្រីនោះ កន្លងផុតទៅ នាពេលព្រលឹមស្រាង ៗ* **ព្រះនាគសេន** *ដែលបានឧបសម្បទាហើយ គ្រងសំពត់ កាន់បាត្រ និងចីវរ ចូលទៅកាន់ភូមិដើម្បីបិណ្ឌបាតជាមួយនឹងព្រះឧបជ្ឈាយ៍ បានកើតមានគំនិតយ៉ាងនេះថា "ព្រះឧបជ្ឈាយ៍របស់យើង ជាមនុស្សអត់បានការឬអ្វីហ្ន៎ ? ព្រះឧបជ្ឈាយ៍របស់យើងជាមនុស្សល្ងង់ឬអ្វីហ្ន៎ ? ការដែលលោកណែនាំយើងមុន ចំពោះតែព្រះអភិធម្ម លើកលែងព្រះពុទ្ធវចនៈដែលនៅសល់ ( គឺ ព្រះវិន័យ និងព្រះសូត្រ ) " ។*

*គ្រានោះ* **ព្រះរោហណៈ** *បានដឹងនូវគំនិតក្នុងចិត្ត របស់ព្រះនាគសេនដោយចិត្ត ទើបពោលទៅកាន់ព្រះនាគសេនថា " ម្នាល ! នាគសេន ឯងគិតដល់រឿង ដែលមិនគួរគិត គំនិតរបស់ឯងមិនសមរម្យទេណ៎ា នាគសេន " ។*

លំដាប់នោះ ព្រះនាគសេន បានមានគំនិតដូចនេះថា " គួរឱ្យអស្ចារ្យមែនហ្ន៎ លោកដ៏ចម្រើនអើយ គួរឱ្យចម្លែកមែនហ្ន៎ លោកដ៏ចម្រើនអើយ ព្រះឧបជ្ឈាយ៍របស់យើង បានដឹងនូវគំនិតរបស់យើងក្នុងចិត្ត ដោយចិត្តបាន ព្រះឧបជ្ឈាយ៍របស់យើងជាបណ្ឌិតហ្ន៎ ធ្វើដូចម្ដេចទៅ ទើបយើងអាចសុំឱ្យព្រះឧបជ្ឈាយ៍អត់ទោសឱ្យបានទៅហ្ន៎ ? " ។ គ្រានោះ **ព្រះនាគសេន** បានពោលទៅកាន់ព្រះរោហណៈថា " ព្រះគុណម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់ទោសចុះ ខ្ញុំព្រះករុណានឹងមិនគិតរឿងអ៊ីចឹងទៀតទេ " ។

គ្រានោះ **ព្រះរោហណៈ** បានពោលទៅកាន់ព្រះនាគសេនថា " ម្នាល ! នាគសេន ខ្ញុំមិនអត់ទោសឱ្យឯង ដោយហេតុត្រឹមតែឯងមកសុំខមាទោសនោះទេ ។ ម្នាល ! នាគសេន មាននគរមួយឈ្មោះថា សាគល ព្រះរាជាព្រះនាមថា មិលិន្ទ ទ្រង់គ្រងរាជសម្បត្តិនៅនគរនោះ ។ ព្រះរាជាព្រះអង្គនោះទ្រង់ប្រើទិដ្ឋិវាទៈ សួរបញ្ហាកំហែង ដល់ព្រះភិក្ខុសង្ឃ ។ ប្រសិនបើឯងទៅកាន់នគរនោះ បំបាក់ស្បាតព្រះរាជាព្រះអង្គនោះ ធ្វើឱ្យទ្រង់មានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនាបានហើយ យើងនឹងអត់ទោសឱ្យឯង " ។

**ព្រះនាគសេន** ពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ព្រះរាជាតែមួយអង្គសូមលើកទុកសិនចុះ ព្រះគុណម្ចាស់ដ៏ចម្រើន ប្រសិនបើព្រះរាជាគ្រប់ព្រះអង្គក្នុងជម្ពូទ្វីបទាំងអស់ ស្ដេចយាងមកសួរបញ្ហាដល់ខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងថ្វាយវិសជ្ជនាបំផ្លាញបញ្ហានោះឱ្យអស់ បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់អត់ទោសឱ្យខ្ញុំព្រះករុណាផងចុះ " ដូចនេះហើយ នៅពេល **ព្រះរោហណៈ** នៅតែពោលថា " យើងមិនអត់ទោសឱ្យទេ " ដូចនេះ ទើបពោលថា " បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន បើអ៊ីចឹងរហូតមួយត្រីមាសនេះ ខ្ញុំព្រះករុណានឹងនៅក្នុងសម្នាក់របស់អ្នកណា ? " ។ "

ម្នាល ! នាគសេន ព្រះអស្សគុត្តនៅឯសេនាសនវត្តនិយៈ ចូរឯងទៅរកព្រះអស្សគុត្ត នៅកន្លែងលោកស្នាក់អាស្រ័យទៅចុះ ។ លុះចូលទៅហើយ ចូរក្រាបសំពះព្រះបាទារបស់ព្រះអស្សគុត្តក្បាលដល់ដី រួចពោលទៅកាន់លោក តាមពាក្យរបស់ខ្ញុំ យ៉ាងនេះថា " បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា សូមក្រាបសំពះព្រះបាទា របស់ព្រះគុណ-ម្ចាស់ដោយព្រះសិរសា សូមសួរដល់ភាពមានអាពាធតិច មានជំងឺតិច រាងកាយរហ័សរហួនល្អមានកម្លាំង និងការរស់នៅសុខសប្បាយរបស់ព្រះគុណម្ចាស់ផង ។ ព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា បញ្ជូនខ្ញុំព្រះករុណាមក ឲ្យនៅក្នុងសម្នាក់របស់ព្រះគុណម្ចាស់ រហូតមួយត្រីមាសនេះ " ដូចនេះចុះ រួចបើលោកសួរថា " ព្រះឧបជ្ឈាយ៍របស់ឯងឈ្មោះអី ? " ចូរតបទៅលោកថា " ឈ្មោះថា ព្រះរោហណៈ ព្រះគុណម្ចាស់ដ៏ចម្រើន " នៅពេលលោកសួរថា " ចុះខ្ញុំឈ្មោះអី ? " គួរតបទៅកាន់លោកយ៉ាងនេះថា " ព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណារមែងស្គាល់ឈ្មោះរបស់ព្រះគុណម្ចាស់ " ដូចនេះចុះ " ។

**ព្រះនាគសេន** ទទួលពាក្យរបស់ព្រះឧបជ្ឈាយ៍ថា " **ឯវំ ភន្តេ** " ដូចនេះហើយ ក៏ក្រាបសំពះព្រះរោហណៈធ្វើប្រទក្សិណ កាន់បាត្រនិងចីវរ និមន្តដើរចារិកទៅតាមលំដាប់ បានទៅកាន់កន្លែងដែលសេនាសនវត្តនិយៈតាំងនៅ ចូលទៅរកព្រះអស្សគុត្ត រួចឈរនៅកន្លែងសមរម្យម្ខាង ។ ព្រះនាគ-សេនខណៈឈរនៅកន្លែងសមរម្យម្ខាងនោះ បានពោលទៅកាន់ព្រះអស្ស-គុត្តថា " ព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា សូមក្រាបសំពះព្រះបាទារបស់ព្រះគុណម្ចាស់ដោយព្រះសិរសា សូមសួរដល់ភាពមានអាពាធតិច មានជំងឺតិច រាងកាយរហ័សរហួនល្អ មានកម្លាំង និង

ការរស់នៅសុខសប្បាយរបស់ព្រះគុណម្ចាស់ផងដែរ [១] ។ បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា បញ្ជូនខ្ញុំព្រះករុណាមក ឲ្យនៅក្នុងសម្នាក់របស់ព្រះគុណម្ចាស់ រហូតមួយត្រីមាសនេះ " ។

លំដាប់នោះ **ព្រះអស្សគុត្ត** បានពោលទៅកាន់ព្រះនាគសេនថា " ឯងឈ្មោះអី ? " " ព្រះគុណម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឈ្មោះនាគសេន " "ឧបជ្ឈាយ៍របស់ឯង ឈ្មោះអី ? " " ព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណាឈ្មោះ រោហណៈ " " ចុះខ្ញុំឈ្មោះអី ? " " ព្រះគុណម្ចាស់ដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះករុណា រមែងស្គាល់ឈ្មោះរបស់ព្រះគុណម្ចាស់ " ។

**ព្រះអស្សគុត្ត** "ល្អហើយ នាគសេន ចូរទុកដាក់បាត្រនិងចីពរ ចុះទៅ " " ករុណាព្រះគុណម្ចាស់ " ។ ព្រះនាគសេន ទុកបាត្រនិងចីពររួចហើយ ក៏ទៅបោសសម្អាតបរិវេណ ត្រៀមទឹកសម្រាប់លុបលាងមុខ និងឈើសម្អាតធ្មេញទុក។ ចំណែកព្រះថេរៈក៏នៅតែបោសសម្អាតបរិវេណ ដែលព្រះនាគសេនបោសសម្អាតរួចហើយ ចាក់ទឹកនោះចោល យកទឹកថ្មីមក យកឈើសម្អាតធ្មេញនោះចេញ យកឈើសម្អាតធ្មេញផ្សេងមក ។ មិនបានសន្ទនាជាមួយព្រះថេរៈ ធ្វើដូចនេះ អស់ពេល ៧ ថ្ងៃ នៅថ្ងៃទី ៧ ទើបសួរទៀត ។ នៅពេលព្រះនាគសេន នៅតែឆ្លើយដូចនោះទៀត ទើបលោកអនុញ្ញាតឱ្យនៅចាំវស្សាបាន ។

**១៦** - នាសម័យនោះ មានឧបាសិកាម្នាក់ចាំឧបត្ថម្ភទំនុកបម្រុងព្រះអស្សគុត្តកន្លងមក រហូត ៣០ ឆ្នាំមកហើយ ។ គ្រានោះ **មហាឧបាសិកា**

[១] បាលីថា ឯវញ្ច វទេតិ អប្បពាធំ អប្បាតង្កំ បុច្ឆតិ ។ ពាក្យថា ឯវញ្ច វទេតិ គិតថា ជាពាក្យលើស ព្រោះមិនស៊ីគ្នានឹងប្រយោគ ឬឃ្លាណាទាំងអស់ ។

ហើយ ក៏បានពោលទៅកាន់ព្រះអស្សគុត្តថា " ព្រះគុណម្ចាស់ ក្នុងសម្នាក់របស់ព្រះគុណម្ចាស់នេះ មានព្រះភិក្ខុអង្គផ្សេងទៀតដែរឬទេ ? " " មាន ! មហាឧបាសិកា ក្នុងសម្នាក់របស់អាត្មាមានភិក្ខុមួយអង្គឈ្មោះថា ព្រះនាគសេន " " ព្រះគុណម្ចាស់អស្សគុត្ត បើដូចនេះ សូមនិមន្តព្រះគុណម្ចាស់ ព្រមទាំងព្រះនាគសេន ទទួលភត្តាហារនៅថ្ងៃស្អែកនេះផងចុះ " **ព្រះអស្សគុត្ត** ទទួលនិមន្ត ដោយអាការស្ងប់ស្ងៀម ។

បន្ទាប់ពីនោះមក ពេលរាត្រីនោះកន្លងផុតទៅ នាពេលព្រលឹមស្រាងៗ ព្រះអស្សគុត្តកាន់បាត្រនិងចីពរ ចូលទៅកាន់កន្លែងរស់នៅរបស់មហាឧបាសិកា ព្រមជាមួយព្រះនាគសេនដែលជាបច្ឆាសមណៈ (លោកដើរតាម, លោកដើរតាមក្រោយ )។ លុះចូលទៅដល់ហើយ ក៏គង់ចុះលើអាសនៈដែលគេត្រៀមទុក ។ លំដាប់នោះ មហាឧបាសិកា បានប្រគេនម្ហូបចង្ហាន់ដល់ព្រះអស្សគុត្ត និងព្រះនាគសេន ឆាន់ឱ្យឆ្អែត ឱ្យគ្រប់គ្រាន់ ដោយខាទនីយៈ (អាហារទំពា) និងភោជនីយាហារដ៏ប្រណីត ដោយដៃរបស់ខ្លួន ។ បន្ទាប់ពីនោះ **ព្រះអស្សគុត្ត** បានពោលទៅកាន់ព្រះនាគសេនដែលឆាន់រួចរាល់ ដកដៃចេញពីបាត្រថា "នាគសេន សូមធ្វើការអនុមោទនាដល់មហាឧបាសិកាចុះ " ពោលពាក្យនេះហើយ ក៏ក្រោកចេញពីអាសនៈទៅ ។

លំដាប់នោះ **មហាឧបាសិកា** បានពោលទៅកាន់ព្រះនាគសេនថា "ព្រះគុណម្ចាស់នាគសេន ញោមចាស់ហើយ សូមមេត្តាធ្វើការអនុមោទនាដល់ញោម ដោយធម្មកថាដ៏ជ្រាលជ្រៅផងចុះ " ។ បន្ទាប់មក ព្រះនាគសេន បានធ្វើការអនុមោទនា ដល់មហាឧបាសិកានោះ ដោយធម្មកថាដ៏ជ្រាលជ្រៅជាលោកុត្តរៈ ទាក់ទងនឹងសុញ្ញតា ។

*គ្រានោះ ធម្មចក្ខុ (កែវភ្នែកឃើញធម៌ គឺ សោតាបត្តិមគ្គញ្ញាណ) ដែលប្រាសចាកមន្ទិល បានកើតឡើងចំពោះមហាឧបាសិកានោះ នៅលើអាសនៈនោះតែម្តងថា " អ្វី ៗ មានការកើតឡើងជាធម្មតា អ្វី ៗ ទាំងអស់នោះ សុទ្ធតែមានការរលត់ទៅវិញជាធម្មតា " សូម្បីព្រះនាគសេន លុះធ្វើការអនុមោទនាដល់មហាឧបាសិកានោះ ក៏ពិចារណាធម៌ដែលខ្លួនកំពុងសម្តែង ចម្រើនវិបស្សនាបានហើយ កំពុងគង់នៅលើអាសនៈនោះតែម្តង ក៏បានទទួលព្រះសោតាបត្តិផល ។*

*គ្រានោះ ព្រះអស្សគុត្តគង់នៅរោងមូល ដឹងថា បុគ្គលទាំងពីរបានធម្មចក្ខុហើយ ក៏បានពោលពាក្យសាធុការថា " ល្អមែន ល្អមែន នាគសេន ដោយការប្រើព្រួញតែមួយ ឯងអាចបំផ្លាញកិលេសក្រុមធំទាំង ២ បាន " ទាំងទេវតាចំនួនជាច្រើនពាន់ ក៏បានពោលពាក្យសាធុការ ។*

**១៧** - *បន្ទាប់ពីនោះ ព្រះនាគសេន ក្រោកចេញពីអាសនៈ ដើរទៅរកព្រះអស្សគុត្ត ដល់កន្លែងរបស់លោក ។ លុះចូលទៅដល់ហើយ ក៏ក្រាប សំពះព្រះអស្សគុត្ត រួចគង់ចុះនៅកន្លែងសមរម្យម្ខាង ។* **ព្រះអស្សគុត្ត** *បានពោលទៅកាន់ព្រះនាគសេន ដែលគង់នៅកន្លែងសមរម្យម្ខាង ថា " ម្នាល ! នាគសេន សូមឯងទៅកាន់ក្រុងបាតលីបុត្ត ព្រះធម្មរក្ខិតអាស្រ័យនៅវត្ត អសោការាម ជិតក្រុងបាតលីបុត្ត ចូរឯងរៀនព្រះពុទ្ធវចនៈ ក្នុងសម្នាក់របស់ព្រះធម្មរក្ខិតនោះចុះ " ។*

**ព្រះនាគសេន** *សួរថា " ព្រះគុណម្ចាស់ដ៏ចម្រើន ក្រុងបាតលីបុត្តនៅឆ្ងាយពីទីនេះប៉ុន្មានដែរព្រះគុណម្ចាស់ ? " " ជាច្រើនរយយោជន៍ឯណោះ នាគសេន " "ព្រះគុណម្ចាស់ដ៏ចម្រើន ផ្លូវក៏ឆ្ងាយ នៅតាមផ្លូវភិក្សាហារក៏*

ពិបាករក ខ្ញុំព្រះករុណានឹងអាចទៅបានយ៉ាងដូចម្ដេច ?" "ឯងទៅចុះ នាគ-សេន នៅតាមផ្លូវឯងនឹងបានបិណ្ឌបាត បាយស្រូវសាលីឆ្អិន ដែលគ្មានកាក សម្ងជាច្រើន និងម្ហូបចង្ហាន់ជាច្រើន" ។

**ព្រះនាគសេន** ទទួលពាក្យថា "ករុណាព្រះគុណម្ចាស់" រួចក៏ក្រាប សំពះលាព្រះអស្សគុត្ត ធ្វើប្រទក្សិណកាន់បាត្រនិងចីពរ ដើរចារិកសំដៅទៅ កាន់ក្រុងបាតលីបុត្ត ។

**១៨** - ក្នុងគ្រានោះ សេដ្ឋីក្រុងបាតលីបុត្តម្នាក់ កំពុងធ្វើដំណើរត្រឡប់ ទៅកាន់ក្រុងបាតលីបុត្តវិញ ជាមួយនឹងរទេះគោចំនួន ៥០០ ។ **សេដ្ឋីក្រុង បាតលីបុត្ត** បានឃើញព្រះនាគសេនកំពុងនិមន្តដើរមកអំពីចម្ងាយ ។ លុះ ឃើញហើយ ក៏ដើរទៅកាន់ព្រះនាគសេន ទៅដល់ហើយក៏ក្រាបសំពះព្រះ នាគសេន សួរថា "ព្រះគុណម្ចាស់បម្រុងនឹងទៅទីណា ?" **ព្រះនាគសេន** "លោកគហបតី អាត្មាភាពបម្រុងនឹងទៅកាន់ក្រុងបាតលីបុត្ត" "ល្អមែន ព្រះ គុណម្ចាស់ សូម្បីតែពួកយើងក៏ទៅកាន់ក្រុងបាតលីបុត្ត សូមព្រះគុណម្ចាស់ និមន្តទៅជាមួយពួកយើងចុះ" ។

គ្រានោះ សេដ្ឋីក្រុងបាតលីបុត្តបានជ្រះថ្លានឹងឥរិយាបថ របស់ព្រះ នាគសេន ទើបប្រគេនម្ហូបចង្ហាន់ដល់ព្រះនាគសេនដរាបឆ្អែត ឱ្យគ្រប់គ្រាន់ ដោយអាហារទំពា អាហារឆាន់ដ៏ប្រណីត ដោយដៃរបស់ខ្លួន ។ អង្គុយនៅ អាសនៈដែលទាបជាង នៅកន្លែងសមរម្យមួយ ។ សេដ្ឋីក្រុងបាតលីបុត្តដែល អង្គុយនៅកន្លែងសមរម្យហើយ បានសួរទៅកាន់ព្រះនាគសេន ដែលឆាន់រួច ហើយ ដកដៃចេញពីបាត្រថា "ព្រះគុណម្ចាស់ ព្រះនាមអ្វីដែរ ?" "លោក

គហបតី អាត្មាភាពឈ្មោះ នាគសេន ” “ ព្រះគុណម្ចាស់ លោកម្ចាស់ដឹងពីព្រះពុទ្ធវចនៈឬទេ ? ” “ អាត្មាភាពដឹងពីព្រះអភិធម្ម លោកគហបតី ” “ ព្រះគុណម្ចាស់ ជាលាភរបស់ពួកយើងហើយ ពួកយើងបានល្អហើយ ព្រោះថាញោមជាអ្នករៀនព្រះអភិធម្ម លោកម្ចាស់ក៏ជាអ្នករៀនព្រះអភិធម្ម ព្រះគុណម្ចាស់ សូមលោកម្ចាស់និយាយពីព្រះអភិធម្មចុះ ” ។

គ្រានោះ ព្រះនាគសេនបានសម្តែងព្រះអភិធម្ម ដល់សេដ្ឋីក្រុងបាតលីបុត្ត ក្នុងខណៈលោកកំពុងសម្តែងនោះតែម្តង សេដ្ឋីក្រុងបាតលីបុត្តក៏បានកើតធម្មចក្ខុដែលប្រាសចាកធូលីប្រាសចាកមន្ទិលថា “អ្វីៗមានការកើតឡើងជាធម្មតា អ្វីៗទាំងអស់នោះសុទ្ធតែមានការរលត់ទៅវិញជាធម្មតា” ដូចនេះ។

លំដាប់នោះ **សេដ្ឋីក្រុងបាតលីបុត្ត** បានឱ្យរទេះគោទាំង ៥០០ ទៅខាងមុខមុន រួចខ្លួនឯងដើរទៅ ជាខាងក្រោយ ឈប់នៅផ្លូវបំបែកជាពីរ រួចពោលទៅកាន់ព្រះនាគសេនថា “ ព្រះគុណម្ចាស់ នេះជាផ្លូវទៅកាន់វត្តអសោការាម ព្រះគុណម្ចាស់ នេះជាសំពត់កម្ពលក្រហម បណ្តោយ ១៦ ហត្ថ ទទឹង ៨ ហត្ថ សូមព្រះគុណម្ចាស់ អនុគ្រោះទទួលយកសំពត់កម្ពលក្រហមនេះផងចុះ ព្រះគុណម្ចាស់ ” ព្រះនាគសេន បានអនុគ្រោះទទួលសំពត់កម្ពលក្រហមមួយផ្ទាំងនោះ ។ សេដ្ឋីក្រុងបាតលីបុត្តក៏ពេញចិត្តរីករាយក្នុងចិត្ត សប្បាយចិត្ត មានបីតិសោមនស្ស ក្រាបសំពះព្រះនាគសេនធ្វើប្រទក្សិណ រួចដើរបែកចេញទៅ ។

**១៩** - ព្រះនាគសេន បានចូលទៅរកព្រះធម្មរក្ខិត នៅវត្តអសោការាម លុះចូលទៅដល់ហើយ ក៏ក្រាបសំពះព្រះធម្មរក្ខិត ទូលថេរដីកាអំពីហេតុផលដែលខ្លួនមក រួចបានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកក្នុងសម្នាក់

*របស់ព្រះធម្មរក្ខិត ប្រើពេលវេលា ៣ ខែ រៀនចប់ដោយអក្ខរព្យញ្ជនៈ ដោយការសម្ដែងតែមួយដងប៉ុណ្ណោះ និងប្រើពេល ៣ ខែទៀត ពិចារណាអត្ថន័យក្នុងចិត្ត ( ចាប់អារម្មណ៍លើអត្ថន័យ ) ។*

*បន្ទាប់ពីនោះ* **ព្រះធម្មរក្ខិត** *បានពោលទៅកាន់ព្រះនាគសេនថា "ម្នាលនាគសេន អ្នកគង្វាលគោ ក៏បានត្រឹមតែថែរក្សាគោ ក៏ប៉ុន្តែអ្នកដទៃ (គឺម្ចាស់របស់គោ) ទើបបានបរិភោគរសជាតិគោ យ៉ាងណាមិញ នាគសេនចំពោះឯង ទោះជាចងចាំព្រះពុទ្ធវចនៈគឺព្រះត្រៃបិដកបានក្ដី ប៉ុន្តែមិនមានចំណែកនៃសាមញ្ញផលទេ " ។*

**ព្រះនាគសេន** *" ព្រះគុណម្ចាស់ដ៏ចម្រើន ប៉ុណ្ណឹងចុះ ចំពោះការរៀនព្រះត្រៃបិដកត្រឹមប៉ុណ្ណោះ " លោកប្រើពេលថ្ងៃ(ដែលនៅសល់)ថ្ងៃនោះឯង និងពេលយប់នោះ (ប្រតិបត្តិធម៌) បានសម្រេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទា ។*

*ព្រមគ្នានឹងការយល់ធ្លុះសច្ចៈ ទេវតាទាំងឡាយក៏ផ្ដល់សាធុការដល់ព្រះនាគសេន ផែនដីក៏បន្លឺលាន់រំពង ព្រហ្មទាំងឡាយក៏ទះដៃ លម្អងចន្ទន៍ និង ផ្កាមណ្ឌារវៈ ដែលជារបស់ទិព្វ ក៏រោយរាយបាចសាចចុះមក ។*

# ពាក្យអធិប្បាយ ៖

*រសជាតិ គឺ សម្បត្តិដែលកើតចេញពីគោ ដែលបានពីគោ មានទឹកដោះគោស្រស់ ជាដើម ហៅថា "* ***រសជាតិគោ*** *" ។*

*ពាក្យថា "* ***សាមញ្ញផល*** *" គឺ ផលនៃសមណភាវៈ ៤ យ៉ាង គឺ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។*

*ពាក្យថា " **បដិសម្ភិទា** " គឺបញ្ញាដែលចេះដឹង ៤ យ៉ាង ហៅថា បដិសម្ភិទា ៤ គឺ ៖*

**អត្ថប្បដិសម្ភិទា** - *បញ្ញាដែលចេះដឹងក្នុងអត្ថ គឺ ក្នុងផលដែលកើតចេញពីហេតុ ១ ។*

**ធម្មប្បដិសម្ភិទា** - *បញ្ញាដែលចេះដឹងក្នុងធម៌ គឺក្នុងហេតុដែលបណ្តាលផល ឱ្យកើតឡើង ១។*

**និរុត្តប្បដិសម្ភិទា** - *បញ្ញាដែលចេះដឹងក្នុងនិរុត្តិ គឺក្នុងភាសា ជាពិសេស គឺភាសាមគធ ដែលជាឫសគល់ភាសានៃសត្វទាំងឡាយ ១ ។*

**បដិភាណប្បដិសម្ភិទា** - *បញ្ញាដែលចេះដឹងក្នុងបដិភាណ គឺ ភាពច្បាស់លាស់អំពីអារម្មណ៍ដែលបដិសម្ភិទា ៣ យ៉ាង ខាងដើមនោះដឹង និងអំពីកិច្ចរបស់បដិសម្ភិទា ៣ យ៉ាង ខាងដើមនោះ ។*

**២០** - *នាពេលនោះ ព្រះអរហន្ត ១០០ កោដិ ប្រជុំគ្នានៅរក្ខិតតលវិហារ លើភ្នំហិមពាន្ត រួចក៏បានបញ្ជូនទូត(តំណាង)ទៅសម្នាក់របស់ព្រះនាគសេន ប្រាប់ថា " ព្រះនាគសេន ចូរមក ពួកយើងត្រូវការជួបព្រះនាគសេន " ដូចនេះ ។ លំដាប់នោះ ព្រះនាគសេនបានស្តាប់ពាក្យរបស់ទូតរួច ក៏អន្តរធានបាត់អង្គពីវត្តអសោការាម ទៅបង្ហាញអង្គនៅរក្ខិតតលវិហារ លើភ្នំហិមពាន្ត នៅចំពោះមុខព្រះអរហន្ត ១០០ កោដិ ។*

*គ្រានោះ **ព្រះអរហន្ត ១០០ កោដិ** បានថ្លែងទៅកាន់ព្រះនាគសេនថា " ព្រះនាគសេន ព្រះចៅមិលិន្ទព្រះអង្គនេះគំរាមកំហែងដល់ព្រះភិក្ខុសង្ឃ ដោយការប្រើវាទៈចោទសួរវាទៈ សួរបញ្ហា សូមមេត្តាផងចុះព្រះនាគសេន សូមព្រះគុណម្ចាស់ទៅបំបាក់ស្បាតព្រះចៅមិលិន្ទទៅណា "*

**ព្រះនាគសេន** " ព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ ព្រះចៅមិលិន្ទតែមួយអង្គ សូមលើកទុកចុះ ប្រសិនបើព្រះរាជាទាំងឡាយ ក្នុងជម្ពូទ្វីបទាំងមូល ស្តេចយាងមកសួរបញ្ហាចំពោះខ្ញុំព្រះករុណា ខ្ញុំព្រះករុណានឹងដោះស្រាយបញ្ហានោះបំផ្លាញឱ្យអស់ ព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ សូមព្រះគុណម្ចាស់ទៅកាន់សាគលនគរ កុំបីខ្លាចអ្វីឱ្យសោះ " ។

លំដាប់នោះ ព្រះភិក្ខុជាថេរៈទាំងឡាយ បានធ្វើឱ្យសាគលនគររុងរឿងដោយសំពត់កាសាវពស្ត្រ ឱ្យមានខ្យល់ឥសីបក់ផាត់ចុះឡើង ។

**២១** - នាសម័យនោះ ព្រះអាយុបាលអាស្រ័យនៅសំខេយ្យបរិវេណ ។ គ្រានោះ **ព្រះចៅមិលិន្ទ** បានត្រាស់ទៅកាន់អាមាត្យទាំងឡាយថា "លោកដ៏ចម្រើនទាំងឡាយអើយ ! រាត្រីភ្លឺស្រឡះគួរឱ្យមនោរម្យមែនហ្ន៎ ថ្ងៃនេះយើងគួរចូលទៅសន្ទនា សួរបញ្ហាចំពោះសមណៈ ឬ ព្រាហ្មណ៍ណាបានទៅហ្ន៎ ? អ្នកណាហ្ន៎ អាចសន្ទនាជាមួយយើង ដើម្បីបន្ទយការសង្ស័យបាន ? " ដូចនេះ ។ ពេលត្រាស់យ៉ាងនេះរួច **ពួកបម្រើរាជការយោនក** ប្រហែល ៥០០ ក៏បានក្រាបទូលសេចក្តីនោះ ទៅកាន់ព្រះចៅមិលិន្ទថា "បពិត្រព្រះមហារាជ ! មានព្រះថេរៈមួយអង្គ ព្រះនាមថា ព្រះអាយុបាល ទ្រង់ព្រះត្រៃបិដក ជាពហូសូត សម្រេចអាគម (ជំនាញបរិយត្តិ) ពេលនេះលោកអាស្រ័យនៅសំខេយ្យបរិវេណ, បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់យាងទៅសួរបញ្ហា ចំពោះព្រះគុណម្ចាស់ព្រះអាយុបាលចុះ ក្រាបទូល " ដូចនេះ

**ព្រះរាជា** " បើអ៊ីចឹង ! ពួកនាយ ចូរទៅទូលព្រះគុណម្ចាស់នោះចុះ " ។

ពេលនោះ **នេមិត្តអាមាត្យ** បានបញ្ជូនតំណាងទៅកាន់សម្នាក់របស់ព្រះអាយុបាល ទូលថា " ព្រះគុណម្ចាស់ដ៏ចម្រើន ! ព្រះចៅមិលិន្ទមាន

*បំណងចង់ជួបព្រះអាយុបាល " ព្រះអាយុបាលក៏បានពោលដូចនេះថា "បើអ៊ីចឹង ! សូមព្រះរាជាស្តេចយាងមកចុះ " ។*

*លំដាប់នោះព្រះចៅមិលិន្ទ ដែលមានពួករាជការយោនកប្រមាណ ៥០០ នាក់ ហែហម បានស្តេចយាងឡើងរទេះព្រះទីនាំងដ៏វិចិត្រ ចូលទៅកាន់សំខេយ្យបរិវេណ នៅកន្លែងដែលព្រះអាយុបាលគង់នៅ ។ លុះយាងទៅដល់ហើយ ក៏បានត្រាស់សម្មោទនីយកថា ចំពោះព្រះអាយុបាល ។ លុះត្រាស់សម្មោទនីយកថា ដែលជាទីរឭកដល់គ្នាចប់ហើយ ក៏ប្រថាប់នៅកន្លែងសមរម្យម្ខាង ។ ព្រះចៅមិលិន្ទ លុះប្រថាប់នៅកន្លែងសមរម្យម្ខាងរួច ក៏បានត្រាស់សេចក្តីនោះ ទៅកាន់ព្រះអាយុបាលថា " ព្រះគុណម្ចាស់អាយុបាល ! ការបួសរបស់ព្រះគុណម្ចាស់មានប្រយោជន៍អ្វី ? អ្វីជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកព្រះគុណម្ចាស់ ? "*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា " សូមថ្វាយព្រះពរ ! ការបួសមានការប្រព្រឹត្តធម៌ ការប្រព្រឹត្តស្ងប់ជាប្រយោជន៍ សាមញ្ញផល (ផលនៃភាពជា សមណៈ ៤ យ៉ាង មានសោតាបត្តិផល ជាដើម ) ជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកអាត្មា " ។*

**ព្រះរាជា** *" ព្រះគុណម្ចាស់ អ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្ងប់ខ្លះ សូម្បីតែគ្រហស្ថក៏មានដែរ មិនថាអ៊ីចឹងឬ ? "*

**ព្រះថេរៈ** *" សូមថ្វាយព្រះពរ ! មែនហើយ ! អ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្ងប់ សូម្បីតែគ្រហស្ថ ក៏មានដែរ ។ សូមថ្វាយព្រះពរ ! ពេលព្រះដ៏មានព្រះភាគទ្រង់ប្រកាសធម្មចក្រ នៅព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ពួកព្រហ្ម ១៨ កោដិ ក៏បានត្រាស់ដឹងនូវធម៌ ចំណែកការត្រាស់ដឹងនូវធម៌របស់ពួកទេវតាទាំងឡាយ ក៏មានចំនួនច្រើនមិនអាចរាប់បាន បុគ្គលទាំង*

នោះសុទ្ធតែជាគ្រហស្ថ មិនមែនជាបព្វជិតទេ ។

សូមថ្វាយព្រះពរ ! នៅមានទៀត នៅពេលព្រះដ៏មានព្រះភាគទ្រង់សម្តែងមហាសមយសូត្រ នៅពេលទ្រង់សម្តែងមហាមង្គលសូត្រ នៅពេលទ្រង់សម្តែងសមចិត្តបរិយាយសូត្រ នៅពេលទ្រង់សម្តែងរាហុលោវាទសូត្រ នៅពេលទ្រង់សម្តែងបរាភវសូត្រ ទេវតាទាំងឡាយចំនួនរាប់មិនអស់ បានត្រាស់ដឹងនូវធម៌ បុគ្គលទាំងនោះសុទ្ធតែជាគ្រហស្ថ មិនមែនជាបព្វជិតទេ ”។

**ព្រះរាជា** ត្រាស់ថា “ បើអ៊ីចឹងនោះ ! ព្រះគុណម្ចាស់អាយុបាល ការបួសរបស់លោកជាការគ្មានប្រយោជន៍ ។ ពួកសមណសក្យបុត្រទាំងឡាយតែងតែបួស និង ប្រព្រឹត្តធុតង្គ ព្រោះជាផលបានមកពីកម្ម ដែលបានធ្វើទុកកាលពីជាតិមុន ៗ ។

ព្រះគុណម្ចាស់អាយុបាល ភិក្ខុដែលប្រកាន់យកការឆាន់តែមួយពេល ភិក្ខុទាំងនោះ ក្នុងជាតិមុន ៗ ជាចោរប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃឬអ្វី ? ក្នុងពេលនេះ ទើបភិក្ខុទាំងនោះ ត្រូវឆាន់តែមួយពេល តែងតែមិនបានឆាន់តាមកាលគួរ ព្រោះជាផលនៃកម្ម ដែលបានកាត់ផ្តាច់ភោគទ្រព្យរបស់អ្នកដទៃនោះ ភិក្ខុទាំងនោះឈ្មោះថា មានសីលក៏មិនមែន ថាមានតបៈក៏មិនមែន ថាប្រព្រឹត្តព្រហ្មចរិយធម៌ក៏មិនមែន ។

ព្រះគុណម្ចាស់អាយុបាល ចំណែកភិក្ខុដែលកាន់ធុតង្គរស់នៅទីវាល ពួកភិក្ខុទាំងនោះក្នុងជាតិមុនៗ សុទ្ធតែជាចោរប្លន់ផ្ទះឬអ្វី ? ក្នុងពេលនេះ ទើបភិក្ខុទាំងនោះ ត្រូវរស់នៅទីវាល មិនបានប្រើប្រាស់សេនាសនៈ ព្រោះជាផលនៃកម្ម ដែលធ្វើឱ្យផ្ទះអ្នកដទៃ វិនាសនោះ ។ ភិក្ខុទាំងនោះឈ្មោះថាមានសីលក៏មិនមែន ថាមានតបៈក៏មិនមែន ថាប្រព្រឹត្តព្រហ្មចរិយធម៌ក៏មិនមែន។

ព្រះគុណម្ចាស់អាយុបាល ចំណែកភិក្ខុដែលកាន់ធុតង្គនេសជ្ជិកៈ

( យកការអង្គុយជាវត្ត គឺ មិនសឹងដេក ) ពួកភិក្ខុទាំងនោះក្នុងជាតិមុន ៗ សុទ្ធតែជាចោរប្លន់ អ្នកដំណើរឬអ្វី ? ក្នុងពេលនេះ ទើបត្រូវមកជានេសជ្ជិកៈ មិនអាចដេកពួនបាន ព្រោះជាផលនៃកម្ម ដែលចាប់អ្នកដំណើរមកចងឱ្យអង្គុយនោះ ។ ភិក្ខុទាំងនោះ ឈ្មោះថា មានសីលក៏មិនមែន ថាមានតបៈក៏មិនមែន ថាប្រព្រឹត្តព្រហ្មចរិយធម៌ក៏មិនមែន ” ដូចនេះ ។

នៅពេលព្រះរាជាត្រាស់ដូចនេះ ព្រះអាយុបាលក៏នៅស្ងៀម មិនឆ្លើយតបអ្វី ។ ពេលនោះ **ពួកបម្រើរាជការយោនក ៥០០** បានក្រាបទូលសេចក្តីនោះ ទៅកាន់ព្រះចៅមិលិន្ទថា “ បពិត្រព្រះមហារាជ ព្រះថេរៈក៏ជាបណ្ឌិតដែរក្រាបទូល គ្រាន់តែជាមនុស្សមិនអង់អាច ទើបមិនពោលតបអ្វី”ដូចនេះ។

គ្រានោះ **ព្រះចៅមិលិន្ទ** ទ្រង់ឃើញថា ព្រះអាយុបាលនៅស្ងៀម ក៏ទ្រង់ទះព្រះហស្តហ៊ោឡើង ត្រាស់ទៅកាន់ពួកបម្រើរាជការយោនកទាំងឡាយ ថា “ **លោកដ៏ចម្រើនទាំងឡាយអើយ ជម្ពូទ្វីបទទេស្អាតហ្ន៎ ជម្ពូទ្វីបគ្មានបានការហ្ន៎ គ្មានអ្នកណា ទោះជាសមណៈ ឬ ព្រាហ្មណ៍ អាចសន្ទនាជាមួយនឹងយើង ដើម្បីបន្ទយការសង្ស័យបានឡើយ** ” ដូចនេះ ។

**២២** - គ្រានោះ ពេលព្រះចៅមិលិន្ទទ្រង់ក្រឡេកមើលបរិស័ទទាំងពួង ខាងណេះ ខាងណោះ ទតព្រះនេត្រឃើញពួកបម្រើរាជការយោនកមិនខ្លាច មានអាការមិនកប់យោបល់ ក៏ទ្រង់ព្រះតម្រិះប្រការនោះថា “ឃើញថា មានភិក្ខុអង្គណាមួយ ដែលជាបណ្ឌិត អាចសន្ទនានឹងយើង ប្រាកដជាមានមិនខាន មិនបាច់សង្ស័យ ពួកបម្រើរាជការទាំងនេះ ទើបមិនកប់យោបល់ ” ដូចនេះ ។ លំដាប់នោះ **ព្រះចៅមិលិន្ទ** ទើបត្រាស់ទៅកាន់ពួកបម្រើរាជការយោនកថា “ ម្នាល ! ពួកនាយ មានភិក្ខុណាម្នាក់ជាបណ្ឌិតអាច

សន្ទនាជាមួយនឹងយើងបាន ដើម្បីបន្ទយការសង្ស័យ ប្រាកដជាមាន ” ។

ក្នុងសម័យនោះ ព្រះនាគសេន ហែហមទៅដោយគណៈសមណៈ ជាមេក្រុម មេគណៈ ជាគ្រូបាអាចារ្យប្រចាំគណៈ ជាអ្នកដែលមនុស្សទាំងឡាយស្គាល់ ជាអ្នកមានយសសក្តិ មនុស្សទាំងឡាយជាច្រើនគោរពរាប់អានថាល្អ ជាបណ្ឌិតដ៏វៃឆ្លាត មានបញ្ញា ជាវិញ្ញូជនដ៏ប្រសើរ ចេះច្បាស់ បានហ្វឹកហាត់រួចហើយ អង់អាច ស្តាប់ច្រើន ទ្រង់ព្រះត្រៃបិដក សម្រេចវេទ មានចំណេះដឹងជ្រៅជ្រះ សម្រេចអាគម មានបដិសម្ភិទាញាណ មានភាពវៃឆ្លាតទ្រង់បរិយត្តិក្នុងដំបូន្មានរបស់ព្រះសាស្តា ដែលមានអង្គ ៩ សម្រេចបារមីញាណ ។ មានភាពវៃឆ្លាតក្នុងការសម្តែង និងដាក់ច្បាស់នូវធម៌ ដែលជាព្រះតម្រាស់របស់ព្រះជិនវរពុទ្ធជាម្ចាស់ និង ក្នុងអត្ថន័យ ។ មានបដិភាណដ៏វិចិត្រមិនចេះចប់ មានពាក្យពេចន៍ដ៏វិចិត្រ តែងពាក្យពេចន៍បានល្អ ពិបាកនឹងវាយលុក ពិបាកនឹងជិះជាន់ ពិបាករកអ្នកដែលប្រសើរជាង ពិបាកការពារ ពិបាកប្រឆាំង ។ មិនរំជួលដូចសមុទ្រ មិនរង្គោះរង្គើដូចភ្នំដ៏ធំ ជាអ្នកលះសត្រូវ បានបន្ទយភាពងងឹត បង្កើតភាពភ្លឺ ថ្លៃងវាចាបានច្រើន កម្ទេចគណៈនៃមេគណៈផ្សេងបាន ជាន់ឈ្លីវាទៈលទ្ធិផ្សេងបាន ។ ជាអ្នកដែលក្រុមភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា និងរាជមហាអាមាត្យទាំងឡាយ សក្ការៈគោរពបូជា ឱនលំទោន ។ ជាអ្នកសម្តែងនូវពាក្យដំបូន្មានរបស់ព្រះជិនវរពុទ្ធជាម្ចាស់ ដែលប្រកបដោយអង្គ ៩ ដល់វិញ្ញូជន អ្នកមានចំណេះដឹងអ្នកដែលត្រៀមលក្ខណៈផ្ទៀងត្រចៀកស្តាប់ ។ ជាអ្នកត្រួសត្រាយផ្លូវធម៌ ជាអ្នកបំភ្លឺពន្លឺគឺព្រះធម៌ បូជាយញ្ញគឺព្រះធម៌ បក់ទង់គឺព្រះធម៌ លើកទង់ជ័យគឺព្រះធម៌ ផ្លុំសង្ខគឺព្រះធម៌ វាយស្គរគឺព្រះធម៌ បន្លឺសំឡេងសីហនាទគឺព្រះធម៌បន្លឺសំឡេងដូចសំឡេងព្រះឥន្ទ ជាអ្នកធ្វើឱ្យលោកទាំងមូលបរិបូរដោយ

ពពកភ្លៀងអមតៈមួយមេធំគឺព្រះធម៌ ដែលបញ្ចេញសំឡេងលាន់ពីរោះ មានផ្ទេកបន្ទោរ គឺ ញាណដ៏ប្រសើរបង្កប់នៅ ពោរពេញទៅដោយតំណក់ទឹកភ្លៀង គឺ ករុណា ។ ដើរចារិកទៅតាមភូមិ ជនបទ ទីក្រុងទាំងឡាយ រហូតដល់ក្រុងសាគលរាជធានី តាមលំដាប់ ។ តាមដំណឹងថា ពេលនោះ ព្រះនាគសេន អាស្រ័យនៅឯអសំខេយ្យបរិវេណ ព្រមជាមួយនឹងព្រះភិក្ខុសង្ឃ ៨០.០០០អង្គ ។

ព្រោះហេតុនោះ ទើប **បុរាណាចារ្យ** ពោលថា ៖

" ព្រះនាគសេនជាពហូសូត មានពាក្យពេចន៍ដ៏វិចិត្រ ជ្រាលជ្រៅអង់អាច ឆ្លាតដឹងសម័យ(លទ្ធិ) និងវាងវៃក្នុងបដិភាណ ។ ភិក្ខុទាំងឡាយដែលទ្រង់ព្រះត្រៃបិដក ជំនាញក្នុងនិកាយ ៥ និងនិកាយ ៤ ទាំងនោះ បានលើកព្រះនាគសេនឱ្យជាប្រធាន។ ព្រះនាគសេនមានបញ្ញាជ្រាលជ្រៅ ជាអ្នកប្រាជ្ញវៃឆ្លាតនូវអ្វី ដែលជាផ្លូវ និងមិនមែនផ្លូវ ជាអ្នកដែលបានសម្រេចប្រយោជន៍ខ្ពស់បំផុត ជាមនុស្សអង់អាច ។ ជាអ្នកដែលបណ្ដាភិក្ខុ ដ៏មានបញ្ញាជ្រាលជ្រៅ ជាសច្ចវាទីទាំងឡាយ ហែហមជាមួយ បានចារិកទៅគ្រប់ភូមិ និងនិគម ចូលទៅរហូតដល់ក្រុងសាគលរាជធានី ។ គ្រានោះ ព្រះនាគសេន ស្នាក់អាស្រ័យនៅឯអសំខេយ្យបរិវេណ ។ ព្រះនាគសេននោះ បានថ្លែងទៅកាន់មនុស្សទាំងឡាយ ដូចស្ដេចកេសររាជសីហ៍ បន្លឺសំឡេងនៅលើភ្នំ ដូចនោះ " ដូចនេះ ។

**២៣**- គ្រានោះ **ទេវមន្តិយអាមាត្យ** បានក្រាបទូលព្រះចៅមិលិន្ទថា " បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់រង់ចាំបន្តិចសិនចុះក្រាបទូលបពិត្រព្រះមហារាជ នៅមានព្រះថេរៈមួយអង្គឈ្មោះថា ព្រះនាគសេន

លោកជាបណ្ឌិតវៃឆ្លាត មានបញ្ញា ហ្វឹកហាត់បានល្អ អង់អាច ជាពហូសូត មានពាក្យពេចន៍ដ៏វិចិត្រ មានបដិភាណល្អ ដល់ច្រាំង(ដល់ទីបញ្ចប់)នៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និង បដិភាណប្បដិសម្ភិទា ។ ឥឡូវនេះ ព្រះថេរៈអង្គនោះស្នាក់អាស្រ័យនៅឯអសំខេយ្យបរិវេណ ក្រាបទូល, បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់យាងទៅសួរបញ្ហា ជាមួយព្រះនាគសេនចុះ ក្រាបទូល ព្រះនាគសេននោះអាចសន្ទនាជាមួយព្រះអង្គ បន្ទយការសង្ស័យបាន ក្រាបទូល ” ដូចនេះ ។

លំដាប់នោះ ព្រះចៅមិលិន្ទបន្ទាប់ពីបានស្តាប់សំឡេង(ដែលបន្លឺ)ភ្លាមថា “ ព្រះនាគសេន ” ដូចនេះប៉ុណ្ណោះ ក៏ទ្រង់កើតមានការភ័យខ្លាចភ្លាម កើតមានការញាប់ញ័រភ្លាម ព្រះលោមជាតិក៏ព្រឺឡើងភ្លាមតែម្តង ។

លំដាប់នោះ **ព្រះចៅមិលិន្ទ** ក៏បានត្រាស់ទៅកាន់ទេវមន្តិយអាមាត្យថា “ នាយដ៏ចម្រើនអើយ ! ព្រះនាគសេនអាចសន្ទនាជាមួយយើងបានឬ ? ” “ បពិត្រព្រះមហារាជ ! ព្រះនាគសេនអាចសន្ទនាជាមួយនឹងស្តេចលោកបាលទាំងឡាយ គឺ ព្រះឥន្ទ្រ ព្រះយមបាល ស្តេចវរុណ ស្តេចកុវេរៈ ស្តេចបជាបតី ស្តេចសុយាមៈ ស្តេចសន្តុសិត ទោះជាស្តេចមហាព្រហ្មដែលជាជីតា ( ជាបុព្វបុរស ) ទៅថ្ងៃអ្វីនឹងការសន្ទនាជាមួយអ្នក ដែលជាមនុស្សទាំងឡាយនោះ ក្រាបទូល ” ។

លំដាប់នោះ **ព្រះចៅមិលិន្ទ** បានត្រាស់ទៅកាន់ទេវមន្តិយអាមាត្យថា “បើអ៊ីចឹង ទេវមន្តិយអាមាត្យ ! ចូរឯងបញ្ជូនតំណាងទៅកាន់សម្នាក់ព្រះគុណម្ចាស់ចុះ ” **ទេវមន្តិយអាមាត្យ** ក៏បានក្រាបទូលតបថា “ ក្រាបទូល ! ” ដូចនេះហើយ ក៏បានបញ្ជូនតំណាងទៅកាន់សម្នាក់របស់ព្រះនាគសេនថា “ព្រះចៅមិលិន្ទទ្រង់មានបំណងនឹងជួបព្រះគុណម្ចាស់នាគសេន ”ដូចនេះ ។

ចំណែកខាងព្រះនាគសេន យល់ព្រមទទួលនិមន្តថា " បើដូចនេះ ! សូមស្តេចយាងមកចុះ " ដូចនេះ ។

គ្រានោះ ព្រះចៅមិលិន្ទ ដែលមានពួកបម្រើរាជការយោនកប្រមាណ ៥០០ ហែហម ស្តេចយាងឡើងរទេះព្រះទីនាំងដ៏ប្រសើរ ចូលទៅកាន់អសំខេយ្យបរិវេណ ជាទីកន្លែងដែលព្រះនាគសេនស្នាក់នៅ មួយអន្លើដោយពលសេនាមួយក្រុមធំ ។ នាពេលនោះ ព្រះនាគសេនកំពុងគង់នៅរោងជំនុំជាមួយនឹងភិក្ខុសង្ឃ ៨០.០០០អង្គ ។

ព្រះចៅមិលិន្ទបានទតព្រះនេត្រ ឃើញបរិស័ទរបស់ព្រះនាគសេនពីចម្ងាយ ។ លុះទតឃើញហើយ ក៏បានត្រាស់សេចក្តីទៅកាន់ទេវមន្តិយអាមាត្យថា " បរិស័ទមួយក្រុមធំនេះ ជារបស់អ្នកណា ? " " បពិត្រព្រះមហារាជ ! ជាបរិស័ទរបស់ព្រះនាគសេន ក្រាបទូល " ។

គ្រានោះ ព្រះចៅមិលិន្ទទតឃើញបរិស័ទរបស់ព្រះនាគសេនហើយ ក៏មានការភ័យខ្លាចភ្លាម កើតមានការញាប់ញ័រភ្លាម ព្រះលោមជាតិព្រឺឡើងភ្លាម តែម្តង ។ គ្រានោះ **ព្រះចៅមិលិន្ទ** ទ្រង់ភ័យខ្លាច ញាប់ញ័រ ប្រហោងពោះ តក់ស្លុត មានព្រះលោមជាតិព្រឺឡើង មានព្រះទ័យវិបរិត មានព្រះទ័យស្លុត មានព្រះទ័យជ្រួលច្រាល មានព្រះទ័យប្រែប្រួល ដូចដំរីដែលត្រូវកង្វេរសាប់ជុំវិញខ្លួន ដូចនាគដែលត្រូវគ្រុឌព័ទ្ធជុំវិញ ដូចឆ្កែចចកដែលត្រូវពស់ថ្លាន់រឹតរួត ដូចខ្លាឃ្មុំត្រូវហ្វូងក្របីព័ទ្ធជុំជិត ដូចកង្កែបដែលត្រូវពស់វារដេញតាម ដូចប្រើសដែលត្រូវខ្លាដេញតាម ដូចពស់ដែលជួបនឹងគ្រូចាប់ពស់ ដូចកណ្តុរដែលជួបនឹងឆ្មា ដូចបិសាចដែលជួបនឹងគ្រូចាប់បិសាច ដូចព្រះចន្ទនៅក្នុងមាត់រាហូ ដូចពស់ដែលជាប់ក្នុងសំណាញ់អន្ទាក់ ដូចបក្សីជាប់ក្នុងទ្រុង ដូចត្រីដែលជាប់សំណាញ់ ដូចមនុស្សវង្វេងផ្លូវដែលចូលទៅ

ក្នុងព្រៃសត្វសាហាវ ដូចយក្សដែលមានកំហុសចំពោះស្ដេចវេស្សវ័ណ ដូចទេវបុត្រដែលកំពុងអស់អាយុ ទ្រង់ព្រះតម្រិះថា " **សូមបរិស័ទនេះ កុំមើលងាយយើងបានឱ្យសោះ** " ដូចនេះហើយ ក៏ទ្រង់តាំងស្មារតី (ពង្រឹងស្មារតី)ត្រាស់ទៅកាន់ទេវមន្ដិយអាមាត្យថា " ម្នាល ! ទេវមន្ដិយ ឯងកុំអាលប្រាប់យើងថា ព្រះគុណម្ចាស់អង្គណាជាព្រះនាគសេន យើងនឹងសូមដឹងថាព្រះគុណម្ចាស់អង្គណា ជាព្រះនាគសេនដោយខ្លួនឯង មិនបាច់ប្រាប់ទេ " ដូចនេះ ។ " ល្អហើយ ក្រាបទូល ព្រះអង្គនឹងទ្រង់ជ្រាប ដោយព្រះអង្គឯងតែម្ដង ក្រាបទូល " ។

នាពេលនោះ ព្រះនាគសេនគង់នៅក្នុងចំណោមភិក្ខុបរិស័ទទាំងនោះ ខាងមុខ ភិក្ខុ ៤០.០០០ អង្គ ដែលមានវស្សាតិចជាង ខាងក្រោយភិក្ខុ ៤០.០០០ អង្គ ដែលមានវស្សាច្រើនជាង ។

គ្រានោះ ព្រះចៅមិលិន្ទទ្រង់ក្រឡេកមើលភិក្ខុសង្ឃទាំងពួងនោះ ទាំងខាងមុខ ទាំងខាងក្រោយ ទាំងប៉ែកកណ្ដាល បានទតព្រះនេត្រឃើញព្រះនាគសេន ដែលគង់នៅកណ្ដាលក្នុងចំណោមភិក្ខុទាំងឡាយពីចម្ងាយតែម្ដង លុះទតព្រះនេត្រឃើញព្រះនាគសេន ដែលប្រាសចាកការភ័យខ្លាច ការញាប់ញ័រ លោមជាតិមិនមានព្រឺសម្បុរ ប្រាសចាកភាពកំសាករួច ទើបដឹងដោយអាការនោះតែម្ដងថា " **ក្នុងបណ្ដាភិក្ខុសង្ឃទាំងអស់នោះ លោកអង្គនេះឯងជា ព្រះនាគសេន** " ។

ពេលទ្រង់ជ្រាបដូចនេះហើយ **ព្រះចៅមិលិន្ទ** ត្រាស់ទៅកាន់ទេវមន្ដិយអាមាត្យ ថា " ម្នាល ! ទេវមន្ដិយ ព្រះគុណម្ចាស់អង្គនោះ គឺ ព្រះនាគសេន " " ត្រឹមត្រូវហើយ ក្រាបទូល ព្រះគុណម្ចាស់អង្គនោះឯង គឺជា ព្រះនាគសេន ព្រះអង្គទ្រង់ស្គាល់ព្រះនាគសេនច្បាស់ហើយ ក្រាបទូល " ។

*ព្រោះហេតុនោះ ព្រះរាជាក៏ទ្រង់រីករាយថា “ **មិនបាច់នរណាមកប្រាប់ ក៏យើងអាចស្គាល់ព្រះនាគសេនបានដែរ** ” ។*

*គ្រានោះ ព្រះចៅមិលិន្ទបានទតព្រះនេត្រឃើញព្រះនាគសេន ហើយក៏ទ្រង់មានការភ័យខ្លាចភ្លាម ព្រោះហេតុនោះ* **លោកបុរាណាចារ្យ** *ទើបពោលថា ៖*

*“ ព្រោះបានទតព្រះនេត្រឃើញព្រះនាគសេន ដែលបរិបូរដោយចរណៈ អ្នកដែលបានហ្វឹកហាត់រួចហើយ ក្នុងការសង្រួមឥន្ទ្រិយ ដែលជាគ្រឿងហ្វឹកហាត់ដ៏ខ្ពង់ខ្ពស់ ។ ព្រះរាជាទើបត្រាស់ពាក្យនេះថា យើងធ្លាប់ឃើញសមណៈ ព្រាហ្មណ៍ ដែលយើងនិយាយជាមួយ ជាច្រើននាក់មកហើយ សមណៈ ព្រាហ្មណ៍ ដែលយើងធ្លាប់សន្ទនាជាមួយ ក៏មានច្រើននាក់មកហើយ យើងមិនបានកើតមានការភ័យខ្លាចដូចនេះទេ ដូចដែលកើតមានការញាប់ញ័រភ្លាម ៗ ដូចក្នុងថ្ងៃនេះឡើយ ។ ថ្ងៃនេះយើងប្រាកដជាចាញ់ជាមិនខាន មិនចាំបាច់សង្ស័យឡើយ ។ ចំណែក ព្រះនាគសេននឹងមានជ័យជម្នះ ព្រោះថាចិត្តរបស់យើង មិននៅឈប់ស្ងៀមសោះ” ដូចនេះ ។*

*ចប់ពាហិរកថា*

# ចប់បុព្វយោគកណ្ឌទី ១

# កណ្ឌទី ២
# មិលិន្ទបញ្ហាកណ្ឌ
## វគ្គទី ១ - មហាវគ្គ
### បញ្ហាទី ១ - បញ្ញត្តិបញ្ហា

*គ្រានោះ ព្រះចៅមិលិន្ទបានស្ដេចយាងទៅកាន់ព្រះនាគសេន ដល់ទីកន្លែង ។ លុះចូលទៅដល់ហើយ ក៏បានត្រាស់សម្មោទនីយកថាទៅកាន់ព្រះនាគសេន ។ ត្រាស់សម្មោទនីយកថា ជាទីរឭកដល់គ្នារួចហើយ ក៏ទ្រង់ប្រថាប់អង្គុយចុះ នៅកន្លែងសមរម្យម្ខាង ។ ទោះជាព្រះនាគសេន ក៏បានធ្វើឱ្យព្រះទ័យរបស់ព្រះចៅមិលិន្ទរីករាយ ដោយពាក្យសម្មោទនីយកថា តបវិញដែរ ។*

*លំដាប់នោះ* **ព្រះចៅមិលិន្ទ** *បានត្រាស់ទៅកាន់ព្រះនាគសេនថា "ព្រះគុណម្ចាស់ ! អ្នកទាំងឡាយស្គាល់ព្រះគុណម្ចាស់ថាយ៉ាងដូចម្ដេច ? ព្រះគុណម្ចាស់ ព្រះនាមអ្វី ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ! មហាបពិត្រ ! អ្នកទាំងឡាយស្គាល់អាត្មាភាពថា "ព្រះនាគសេន" មិត្តភក្តិដែលប្រព្រឹត្តព្រហ្មចរិយធម៌ជាមួយគ្នា ហៅ អាត្មាភាពថា "នាគសេន" ចំណែកមាតាបិតាបានដាក់ឈ្មោះហៅអាត្មាភាពថា "នាគសេន" ផង ថា "សូរសេន"ផង ថា "វីរសេន" ផង ថា "សីហសេន" ផង ។ សូមថ្វាយព្រះពរ ប៉ុន្តែពាក្យថា "នាគសេន" នេះ គ្រាន់តែ*

*ជាពាក្យហៅ គ្រាន់តែជាសមញ្ញា (ឈ្មោះដែលអ្នកដទៃស្គាល់) គ្រាន់តែជាបញ្ញត្តិ(ឈ្មោះដែលដាក់ឱ្យ) គ្រាន់តែជាវោហារ (ឈ្មោះហៅ) គ្រាន់តែជានាម (ឈ្មោះម៉្យាង)ប៉ុណ្ណោះ ការពិតឈ្មោះថា នាគសេន នេះ មិនមានបុគ្គលនោះទេ ”*

*លំដាប់នោះ* **ព្រះចៅមិលិន្ទ** *បានត្រាស់យ៉ាងនេះថា “ លោកដ៏ចម្រើនទាំងឡាយ ! ទាំងពួកបម្រើរាជការយោនក ៥០០ នាក់ ទាំងព្រះភិក្ខុ ៨០.០០០ អង្គ សូមស្តាប់ខ្ញុំព្រះករុណា ព្រះនាគសេននេះបានពោលយ៉ាងនេះថា “ ការពិតក្នុងឈ្មោះនាគសេននេះ មិនមានបុគ្គលនោះទេ ” តើគួរដែរឬទេ ដែលព្រះនាគសេនថ្លែងពាក្យនោះចេញមក ? ” ដូចនេះ ។*

*បន្ទាប់ពីនោះ ព្រះចៅមិលិន្ទក៏បានត្រាស់សេចក្តីនោះទៅកាន់ព្រះនាគសេនថា “ ព្រះគុណម្ចាស់នាគសេន ! ប្រសិនបើគ្មានបុគ្គលទេនោះ តើអ្នកណាទៅប្រគេនចីពរ បិណ្ឌបាត សេនាសនៈ និង គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺដល់ពួកព្រះគុណម្ចាស់ ? ។ តើនរណាទទួលចីពរជាដើមនោះ ? នរណារក្សាសីល ? នរណាបំពេញភាវនា ? នរណាធ្វើឱ្យដល់ព្រះនិព្វាន ? នរណាសម្លាប់សត្វ ? នរណាលួចយករបស់ដែលគេមិនបានឱ្យ ? នរណាប្រព្រឹត្តខុសក្នុងកាម ? នរណាពោលពាក្យមិនពិត ? នរណាផឹកគ្រឿងស្រវឹង ? នរណាធ្វើអនន្តរិយកម្ម ៥ ? ព្រោះហេតុនោះ កុសលក៏គ្មាន អកុសលក៏គ្មាន អ្នកធ្វើកុសលកម្មក្តី អកុសលកម្មក្តី អ្នកប្រើឱ្យធ្វើក្តី ក៏គ្មាន ។ វិបាកនៃកម្មល្អ កម្មអាក្រក់ ក៏គ្មាន ។ ព្រះគុណម្ចាស់នាគសេន ! អ្នកណាសម្លាប់ព្រះគុណម្ចាស់ អ្នកនោះមិនឈ្មោះថា មានការធ្វើបាណាតិបាត ។ ព្រះគុណម្ចាស់នាគសេន ! សូម្បីតែខ្លួនព្រះគុណម្ចាស់ក៏គ្មានគ្រូបាអាចារ្យដែរ គ្មានឧបជ្ឈាយ៍ គ្មានការឧបសម្បទា ។ ពាក្យដែលព្រះគុណម្ចាស់*

*ពោលថា " សូមថ្វាយព្រះពរ មហាបពិត្រ ! មិត្តភក្តិដែលប្រព្រឹត្តព្រហ្មចរិយធម៌ជាមួយគ្នា ក៏ហៅអាត្មាភាព ថានាគសេន " នោះ ក្នុងពាក្យនេះ តើអ្វីទៅគឺជានាគសេន ? សរសៃសក់ឬ ជានាគសេន ?"*

**ព្រះនាគសេន ៖** *" មិនមែនដូចនេះទេ មហាបពិត្រ "*

**ព្រះចៅមិលិន្ទ ៖** *" រោម ឬ ជានាគសេន ? "*

**ព្រះនាគសេន ៖** *" មិនមែនទេ មហាបពិត្រ "*

**ព្រះចៅមិលិន្ទ ៖** *" ក្រចកឬ... ? ធ្មេញឬ...? ស្បែកឬ ...? សាច់ឬ ...? ឆ្អឹងឬ ...? ខួរក្នុងឆ្អឹងឬ ...? តម្រងនោមឬ ...? បេះដូងឬ ...? ថ្លើមឬ ...? វៀវឬ ...? ផាលឬ ...? សួតឬ ...? ពោះវៀនធំឬ ...? ពោះវៀនតូចឬ ...? អាហារថ្មីឬ ...? អាហារចាស់ឬ ...? ប្រមាត់ឬ ...? ស្លេស្មឬ ...? ទឹកខ្ទុះឬ ...? ឈាមឬ ...? ញើសឬ ...? ខ្លាញ់ខាប់ឬ ...? ទឹកភ្នែកឬ ...? ខ្លាញ់រាវឬ ...? ទឹកមាត់ឬ ...? ទឹកសំបោរឬ ...? ទឹករំអិលឬ ...? ទឹកនោមឬ .... ។ ល។ ខួរក្បាលឬ ជានាគសេន ?"*

**ព្រះនាគសេន ៖** *" មិនមែនទេ មហាបពិត្រ "*

**ព្រះចៅមិលិន្ទ ៖** *" រូប ឬ ជានាគសេន ? "*

**ព្រះនាគសេន ៖** *" មិនមែនទេ មហាបពិត្រ "*

**ព្រះចៅមិលិន្ទ ៖** *"វេទនាឬជានាគសេន ?" " មិនមែនទេ មហាបពិត្រ " " សញ្ញា ឬជានាគសេន ? " " មិនមែនទេ មហាបពិត្រ " " សង្ខារឬជានាគសេន ? " " មិនមែនទេ មហាបពិត្រ " " វិញ្ញាណឬជានាគសេន ? " " មិនមែនទេ មហាបពិត្រ " " ព្រះគុណម្ចាស់ តើផ្សេងក្រៅអំពី រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ឬ ជានាគសេន ?" " មិនមែនទេ មហាបពិត្រ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាសួរហើយសួរទៀត ក៏នៅតែមិនជួប មិនឃើញជានាគសេនសោះ តើសំឡេងដែលបញ្ចេញមកថា*

"នាគសេន" ឬ ជានាគសេន ព្រះគុណម្ចាស់?"

**ព្រះនាគសេន ៖** " មិនមែនទេ មហាបពិត្រ"

**ព្រះចៅមិលិន្ទ ៖** " ក្នុងពាក្យថានាគសេននេះ តើអ្វីទៅជានាគសេន? ព្រះគុណម្ចាស់និយាយស្ដីវៀចវេរ ជាមុសាវាទ ព្រះគុណម្ចាស់! នាគសេនគ្មានទេ!"

លំដាប់នោះ ព្រះនាគសេនបានថ្វាយព្រះពរព្រះចៅមិលិន្ទថា " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់ជាក្សត្រសុខុមាលជាតិដ៏ខ្ពង់ខ្ពស់ នៅពេលព្រះអង្គស្ដេចយាងព្រះដំណើរមក ដោយព្រះបាទក្នុងវេលាថ្ងៃត្រង់ ទ្រង់ជាន់លើផ្ទៃដី ដែលក្ដៅថ្ងៃ លើខ្សាច់ក្ដៅ លើផ្ទាំងក្រួសរឹង ព្រះបាទទាំងពីរក៏ឈឺ ធ្វើឱ្យព្រះវរកាយ ក៏ពិបាក ព្រះទ័យក៏រសាប់រសល់ ព្រះកាយវិញ្ញាណដែលសហគតដោយទុក្ខ រមែងកើតមាន ។ តើព្រះអង្គស្ដេចយាងព្រះដំណើរមកដោយព្រះបាទឬ? ឬក៏មកដោយយានជំនិះ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាមិនបានប្រើជើងដើរមកទេ ខ្ញុំព្រះករុណាមកដោយរទេះ"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរមហាបពិត្រ ប្រសិនបើព្រះអង្គស្ដេចយាងមកដោយរទេះនោះ សូមទ្រង់ប្រាប់រទេះឱ្យអាត្មាភាពបានដឹង សូមថ្វាយព្រះពរ ចន្ទោល ឬ ជារទេះ?"

**ព្រះចៅមិលិន្ទ ៖** " មិនមែនទេ ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " ភ្លៅឬជារទេះ?" " មិនមែនទេ ព្រះគុណម្ចាស់" "កង់ទាំងឡាយឬជារទេះ?" " មិនមែនទេ ព្រះគុណម្ចាស់" " ដំបូលឬជារទេះ?" " មិនមែនទេ ព្រះគុណម្ចាស់" "ទូករទេះឬជារទេះ?" " មិនមែនទេ ព្រះគុណម្ចាស់" " នឹមឬជារទេះ?" " មិនមែនទេ ព្រះគុណម្ចាស់" " ខ្សែ

បង្អៀរឬជារទេះ ? ” “ មិនមែនទេ ព្រះគុណម្ចាស់ ” “ ជន្ទួញឬជារទេះ ? ” “មិនមែនទេ ព្រះគុណម្ចាស់ ” “ សូមថ្វាយ ព្រះពរ ចន្ទោល ភ្លៅ កង់ ដំបូល ទូក នឹម ខ្សែបង្អៀរ ជន្ទួញ ឬ ជារទេះ ? ” “ មិនមែនទេ ព្រះគុណម្ចាស់ ” “ផ្សេងក្រៅអំពី ចន្ទោល ភ្លៅ កង់ ដំបូល ទូក នឹម ខ្សែបង្អៀរ ជន្ទួញ ឬ ជារទេះ ? ” “ មិនមែនទេ ព្រះគុណម្ចាស់ ”

**ព្រះនាគសេន ៖** “ សូមថ្វាយព្រះពរ មហាបពិត្រ អាត្មាភាពសួរហើយសួរទៀត ក៏នៅតែមិនទាន់ឃើញរទេះនៅឡើយ សំឡេងដែលបញ្ចេញមកថា “រទេះ” ឬ ដែលជារទេះនោះ មហាបពិត្រ ”

**ព្រះចៅមិលិន្ទ ៖** “ មិនមែនទេ ព្រះគុណម្ចាស់ ”

**ព្រះនាគសេន ៖** “ ក្នុងពាក្យថារទេះនេះ តើអ្វីទៅដែលជារទេះនោះ ? សូមថ្វាយព្រះពរ ព្រះអង្គត្រាស់ពាក្យវៀចវេរ ជាមុសាវាទ រទេះគ្មានទេ ។ សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គចាត់ទុកថា ជាព្រះរាជាដ៏កំពូលក្នុងជម្ពូទ្វីបទាំងមូល តើទ្រង់ខ្លាចអ្នកណាទៅ ? ទើបទ្រង់ត្រាស់មុសាវាទ ។ លោកដ៏ចម្រើនទាំងឡាយ ទាំងពួកបម្រើរាជការយោនក ៥០០ នាក់ ទាំងភិក្ខុ ៨០.០០០ អង្គ សូមស្តាប់អាត្មាភាព ព្រះចៅមិលិន្ទព្រះអង្គនេះ ត្រាស់យ៉ាងនេះថា “ ខ្ញុំព្រះករុណាមកដោយរទេះ ” នៅពេលអាត្មាភាពពោលថា “សូមថ្វាយព្រះពរ មហាបពិត្រ ប្រសិនបើព្រះអង្គស្តេចយាងមកដោយរទេះនោះ សូមទ្រង់ប្រាប់រទេះឱ្យអាត្មាភាពបានដឹង ” ដូចនេះហើយ ព្រះរាជាទ្រង់មិនអាចអះអាងនូវអ្វីដែលហៅថា រទេះ នោះបាន តើគួរដែរទេ ? ដែលព្រះអង្គទ្រង់បញ្ចេញព្រះបន្ទូលដូចនេះ ចេញមកនោះ ”

នៅពេលព្រះនាគសេនពោលដូចនេះហើយ ពួកបម្រើរាជការយោនក ៥០០ នាក់ ក៏បានផ្តល់សាធុការដល់ព្រះនាគសេន រួចក្រាបទូលសេចក្តីនោះ

*ទៅកាន់ព្រះចៅមិលិន្ទថា " បពិត្រព្រះមហារាជ ឥឡូវនេះបើព្រះអង្គទ្រង់មានសមត្ថភាព សូមមានព្រះបន្ទូលទៅចុះ ក្រាបទូល "*

*លំដាប់នោះ* **ព្រះចៅមិលិន្ទ** *បានត្រាស់សេចក្ដីនោះទៅកាន់ព្រះនាគសេនថា ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាមិនបានពោលពាក្យមុសាទេ អាស្រ័យចន្ទោលផង អាស្រ័យភ្លៅផង អាស្រ័យកង់ផង អាស្រ័យដំបូលផង អាស្រ័យទូករទេះផង ទើបមានពាក្យហៅ មានសមញ្ញា មានបញ្ញត្តិ មានវោហារ មានគ្រាន់តែឈ្មោះ ដែលហៅថា " រទេះ " នោះឯង "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រសើរមែន ដែលព្រះអង្គទ្រង់ស្គាល់រទេះ សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ទោះជាអាត្មាភាពក្ដី ក៏អាស្រ័យសរសៃសក់ផង អាស្រ័យរោមផង... ។ល។ អាស្រ័យខួរក្បាលផង អាស្រ័យរូបផង អាស្រ័យវេទនាផង អាស្រ័យសញ្ញាផង អាស្រ័យសង្ខារផង អាស្រ័យវិញ្ញាណផង ទើបមានពាក្យហៅ មានសមញ្ញា មានបញ្ញាត្តិ មានវោហារ មានគ្រាន់តែឈ្មោះ ដែលហៅថា " នាគសេន " ក្នុងឈ្មោះនាគសេននេះ រកបុគ្គលដែលជាបរមត្ថគ្មានទេ ។*

*សូមថ្វាយព្រះពរ ព្រះវជិរាភិក្ខុនី បានពោលពាក្យនេះ នៅចំពោះមុខព្រះដ៏មានព្រះភាគថា ៖*

**" យថា ហិ អង្គសម្ភារា ហោតិ សទ្ទោ " រថោ " ឥតិ**

**ឯវំ ខន្ធេសុ សន្តេសុ ហោតិ " សត្តោ " តិ សម្មតិ "** (១)

*ប្រែថា " សព្ទ (វោហារ)ថា " រថ " រមែងមាន ព្រោះមានគ្រឿងប្រកបយ៉ាងណាមិញ នៅពេលខន្ធទាំងឡាយនៅមាន ក៏រមែងតែមានការអបលោកថា "* ***សត្វ*** *" ដូចនោះដែរ "*

**ព្រះចៅមិលិន្ទ ៖** *" គួរឱ្យអស្ចារ្យមែន ព្រះគុណម្ចាស់នាគសេន ! គួរ*

---

(១) *សំយុត្តនិកាយ សគាថវគ្គ ។*

ឱ្យចម្លែកមែន ព្រះគុណម្ចាស់នាគសេន ប្រការដែលលោកម្ចាស់វិសជ្ជនាបញ្ហាបដិភាណដ៏វិចិត្របំផុតបាន, ប្រសិនបើព្រះពុទ្ធអង្គទ្រង់គង់ព្រះជន្មនៅឡើយ ប្រាកដជាព្រះអង្គផ្តល់សាធុការថា " ប្រសើរមែន ប្រសើរមែននាគសេន អ្នកដោះស្រាយបញ្ហាបដិភាណដ៏វិចិត្របំផុតបាន " ដូចនេះ ជាពុំខាន " ៕

ចប់បញ្ញត្តិប្បញ្ហាទី ១

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

ក្នុងកណ្ឌទី ២ គឺ មិលិន្ទប្បញ្ហាកណ្ឌនេះ មាន ៧ វគ្គ គឺ **វគ្គទី ១** ឈ្មោះថា មហាវគ្គ មាន ១៦ បញ្ហា, **វគ្គទី ២** ឈ្មោះថា អទ្ធានវគ្គ មាន ៩ បញ្ហា , **វគ្គទី ៣** ដែលគ្មានឈ្មោះ មាន ១៤ បញ្ហា , **វគ្គទី ៤** ឈ្មោះថា និព្វានវគ្គ មាន ១០ បញ្ហា , **វគ្គទី ៥** ឈ្មោះថា ពុទ្ធវគ្គ មាន ១០ បញ្ហា , **វគ្គទី ៦** ឈ្មោះថា សតិវគ្គ មាន ១១ បញ្ហា និង **វគ្គទី ៧** ឈ្មោះថា អរូបធម្មវវត្ថានវគ្គ មាន ១៦ បញ្ហា ទើបសរុបបញ្ហាទាំងឡាយ ក្នុងមិលិន្ទប្បញ្ហាកណ្ឌនេះ បាន ៨៦ បញ្ហា ។

បញ្ហាទី ១ ក្នុងមហាវគ្គនេះឈ្មោះថា បញ្ញត្តិប្បញ្ហា ជាបញ្ហាសួរអំពីបញ្ញត្តិគឺ ឈ្មោះថា នាគសេន របស់ព្រះថេរៈ ។

ក្នុងមិលិន្ទប្បញ្ហារបស់ថៃ ពេលដើមដំបូងនៃបញ្ហា មានខ្លឹមសារបង្ហាញដូចនេះជាមុនថា "...បន្ទាប់ពីនោះ **ព្រះចៅមិលិន្ទ** បានត្រាស់សួរបញ្ហាប្រការដំបូងទៅកាន់ព្រះនាគសេនថា " ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាចង់សន្ទនាជាមួយ "

**ព្រះនាគសេន** " *សូមថ្វាយព្រះពរ មហាបពិត្រ សូមទ្រង់ចាប់ផ្ដើមសន្ទនាទៅចុះ អាត្មាភាពក៏ត្រូវការចង់ស្ដាប់ដែរ* "

**ព្រះចៅមិលិន្ទ** " *ខ្ញុំព្រះករុណានឹងនិយាយហើយ សូមព្រះគុណម្ចាស់ចាំស្ដាប់* "

**ព្រះនាគសេន** " *សូមថ្វាយព្រះពរ អាត្មាភាពក៏កំពុងស្ដាប់ សូមមានបន្ទូលមកចុះ* "

**ព្រះចៅមិលិន្ទ** " *ព្រះគុណម្ចាស់ស្ដាប់បានថាយ៉ាងដូចម្ដេច ?* "

**ព្រះនាគសេន** " *មហាបពិត្រ មានបន្ទូលថាយ៉ាងដូចម្ដេច ?* "

**ព្រះចៅមិលិន្ទ** " *ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាបានសួរហើយ* "

**ព្រះនាគសេន** "*សូមថ្វាយព្រះពរ អាត្មាភាពបានថ្វាយវិសជ្ជនាហើយ* "

**ព្រះចៅមិលិន្ទ** " *ព្រះគុណម្ចាស់ បានវិសជ្ជនាថាយ៉ាងដូចម្ដេច ?* "

**ព្រះនាគសេន** " *សូមថ្វាយព្រះពរ ព្រះអង្គត្រាស់សួរថាយ៉ាងដូចម្ដេច ?* " ។

*នៅពេលព្រះនាគសេន ពោលយ៉ាងនេះហើយ ពួកបម្រើរាជការយោនកបានថ្វាយសំឡេងសាធុការដល់ព្រះនាគសេន ...* " *ដូចនេះ ។*

*ខ្លឹមសារពោលមកខាងលើនេះ មិនមានបង្ហាញនៅក្នុងមិលិន្ទប្បញ្ហារបស់ភូមាទេ ។*

*ពាក្យថា* " ***អ្នកទាំងឡាយស្គាល់ព្រះគុណម្ចាស់ថាយ៉ាងដូចម្ដេច ? ព្រះគុណម្ចាស់ព្រះនាមអ្វី ?*** " *ជាទិដ្ឋិសំសន្ទនាបុច្ឆា ។*

*ក្នុងបណ្ដាបុច្ឆា ឬ សំណួរ ៥ យ៉ាង គឺ ៖*

**អទិដ្ឋជោតនាបុច្ឆា** - *សួរដើម្បីឱ្យភ្លឺជាក់ច្បាស់ នូវអ្វីដែលខ្លួនមិនទាន់ឃើញមិនទាន់ដឹង ។*

**ទិដ្ឋសំសន្ទនាបុច្ឆា** - *សួរដើម្បីប្រៀបធៀប នូវអ្វីដែលខ្លួនឃើញហើយ ដឹងហើយ ជាមួយនឹងអ្នកដទៃ ។ បានសេចក្ដីថា ដើម្បីប្រៀបធៀបចំណេះដឹងក្នុងរឿងនោះរបស់ខ្លួន ទៅនឹងចំណេះដឹងរបស់អ្នកដទៃ ។*

**វិមតិឆេទនាបុច្ឆា** - *សួរដើម្បីកាត់សេចក្ដីសង្ស័យនូវអ្វី ដែលនៅមានភាពស្ទាក់ស្ទើរ សម្រេចចិត្តមិនបាន ។*

**អនុមតិបុច្ឆា** - *សួរដើម្បីឱ្យអ្នកដទៃប្រកាន់គំនិតយល់ស្របតាម ដូចជា " ម្នាលភិក្ខុទាំងឡាយរូបទៀងឬមិនទៀង ? មិនទៀង ក្រាបទូល " ជាដើម ។*

**កថេតុកម្យតាបុច្ឆា** - *សួរដើម្បីពោល គឺ ដើម្បីឆ្លើយនឹងបញ្ហាដែលបានលើកឡើងដោយខ្លួនឯង ដូចជា " ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានមាន ៤ យ៉ាងនោះ, ៤ យ៉ាងនេះ គឺអ្វីខ្លះ ? " ដូចនេះ ជាដើម ។*

*បណ្ដាបុច្ឆាទាំង ៥ យ៉ាង ដូចខាងលើ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបុច្ឆា ២ យ៉ាង គឺ "**អនុមតិបុច្ឆា**" និង "**កថេតុកម្យតាបុច្ឆា**" ប៉ុណ្ណោះ ព្រោះទ្រង់ជាព្រះសព្វញ្ញុតញ្ញាណ ទ្រង់មិនមានអ្វីដែលទ្រង់មិនបានដឹងនោះទេ ។*

*ព្រោះទ្រង់មានព្រះបញ្ញាដ៏កំពូលលើបណ្ឌិតទាំងឡាយ ទើបទ្រង់មិនមានចំណេះដឹង ដែលគួរនឹងប្រៀបធៀប ជាមួយចំណេះដឹងរបស់បណ្ឌិតទាំងឡាយដទៃទៀត ដើម្បីនឹងបានដឹងថា របស់នរណាល្អជាង ត្រឹមត្រូវជាងនោះទេ ។*

*ម្យ៉ាងទៀត ព្រោះទ្រង់ប្រាសចាកវិចិកិច្ឆា ការសង្ស័យ នូវអ្វីដែលបានយល់ជាក់ច្បាស់ ដោយព្រះញាណរួចហើយ ដោយប្រការទាំងពួង ។*

សួរថា ព្រោះហេតុអ្វីពាក្យថា " អ្នកទាំងឡាយស្គាល់ព្រះគុណម្ចាស់យ៉ាងដូចម្ដេច ? ព្រះគុណម្ចាស់ព្រះនាមអ្វី ? " នេះទើបពោលថាជា ទិដ្ឋសំសន្ទនាបុច្ឆា ? ឆ្លើយថា " ព្រោះព្រះចៅមិលិន្ទទ្រង់ជ្រាបជាមុនថា ព្រះថេរៈដែលព្រះអង្គនឹងយាងទៅសន្ទនាជាមួយនេះ ព្រះនាមថានាគសេន នៅពេលជួបហើយក៏គ្រាន់តែសួរ ដើម្បីប្រៀបធៀប គឺដើម្បីពិនិត្យមើលថា មានឈ្មោះត្រូវគ្នានឹងអ្វីដែលទ្រង់ដឹងពីមុននោះ ដែរឬទេ ប៉ុណ្ណោះ "

**នាមឈ្មោះ** មាន៤ យ៉ាងគឺ ១-សាមញ្ញនាម ២-គុណនាម ៣-កិត្តិនាម ៤-ឧប្បត្តិកនាម ។ ក្នុងនាមទាំង ៤ យ៉ាងនោះ ៖

ព្រះនាមរបស់ព្រះរាជា ជា " មហាសម្មតិ " ចាត់ទុកជា **សាមញ្ញនាម** ព្រោះមហាជន តាំងពីបុរាណកាលយូរលង់ណាស់មកហើយ បានព្រមព្រៀងគ្នាហៅ ដាក់ឈ្មោះ ដូចនេះ ជាដើម ។

នាមរបស់អ្នកដែលមានគុណសម្បត្តិឬគុណវិសេស បានមកតាមគុណសម្បត្តិ ឬគុណវិសេសនោះ ដូចជា ភិក្ខុទ្រង់សំពត់បង្សុកូល ព្រះវិនយធរ ភិក្ខុទ្រង់ព្រះត្រៃបិដក បុគ្គលមានចិត្តសទ្ធា បុគ្គលដែលជ្រះថ្លា ជាដើម ហៅថា **គុណនាម** ។ ទោះបីជាព្រះនាមរបស់ព្រះតថាគតជាច្រើនរាប់រយ ដូចជា ព្រះភគវា ព្រះអរហន្ត ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជាដើម ក៏ចាត់ទុកថាជាគុណនាម ដែរ ។

នាមដែលពួកញាតិសន្ដាន ចាត់ចែងគ្រឿងសក្ការបូជា ដល់លោកដែលជាទក្ខិណេយ្យបុគ្គល ដើម្បីជាសិរីមង្គលក្នុងថ្ងៃដាក់ឈ្មោះឱ្យទារកទើបនឹងកើត រួចនាំគ្នាគិតដាក់ឈ្មោះឱ្យជាកិត្តិយស ឬជាការលើកតម្កើងថាឈ្មោះនេះ ឈ្មោះនោះ ហៅថា **កិត្តិនាម** ។

នាមពីបុរាណ វោហារជាយូរមកហើយ ប្រើហៅវត្ថុនេះ វត្ថុនោះ តាំងពី

*អតីតកាល ទោះជាតាំងពីកាលមុននេះទៅទៀត រហូតដល់បច្ចុប្បន្នក្តី ដូចជា ព្រះចន្ទ ព្រះអាទិត្យ សមុទ្រ ផែនដី ភ្នំ ជាដើម ហៅថា* ***ឧប្បត្តិកនាម*** *ព្រោះដូចជានាម កើតឡើងដោយខ្លួនឯង គ្មានអ្នកតែងតាំងដាក់ឈ្មោះ ។*

*ក្នុងនាមទាំង ៤ យ៉ាងនោះ នាមថា " នាគសេន " នេះជា "កិត្តិនាម" ព្រោះហេតុនោះ ទើបលោកពោលថា* ***ចំណែកមាតាបិតាបានដាក់ឈ្មោះ ហៅអាត្មាភាពថា នាគសេន*** *ជាដើម ។*

*ពាក្យថា* ***តាមពិត ក្នុងឈ្មោះថា " នាគសេន " នេះ មិនមានបុគ្គលនោះទេ*** *បានសេចក្តីថា ការពិតពាក្យថានាគសេននេះ គ្រាន់តែជាឈ្មោះប៉ុណ្ណោះ ពុំមានបុគ្គល ដែលឈ្មោះថាជានាគសេននោះ ពិតដោយបរមត្ថនោះទេ ។ ព្រោះបុគ្គល ទោះឈ្មោះអ្វីក៏ដោយ ក៏មិនមានសភាវៈជារូប មិនមានសភាវៈជាវេទនា ...ជាសញ្ញា ...ជាសង្ខារ ...ជាវិញ្ញាណ មិនមានសភាវៈជាអាយតនៈ មិនមានសភាវៈជាធាតុ ដែលជាអ្វីមានពិតដោយបរមត្ថ ទើបជាអ្វីដែលមិនមានពិតដោយបរមត្ថ គ្រាន់តែអាស្រ័យការប្រជុំគ្នា ដំណើរបន្តគ្នាជាប់មិនដាច់នៃខន្ធ អាយតនៈ ធាតុ ទាំងនោះ ប៉ុណ្ណោះ ។ សម្មតិ វោហារ បញ្ញត្តិ ថាជាបុគ្គល ជាសត្វ ជាស្រី ជាប្រុស ជានាគសេន ជាដើម ទើបកើតមាន ។ ព្រោះហេតុនោះ ព្រះវជិរាភិក្ខុនី ទើបពោលថា "* **យថា ហិ អង្គសម្ភារា** *... " ជាដើម ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១*

# បញ្ហាទី ២- វស្សគណនបញ្ហា

**ព្រះចៅមិលិន្ទ ៖** *"ព្រះគុណម្ចាស់ ខ្លួនលោកម្ចាស់ប៉ុន្មានវស្សាហើយ ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ អាត្មាភាព ៧ វស្សាហើយ* "

**ព្រះចៅមិលិន្ទ ៖** " *អ្វីរបស់ព្រះគុណម្ចាស់ដែលថា ៧ វស្សានោះ ខ្លួនលោកម្ចាស់ផ្ទាល់ឬ ឈ្មោះថា ៧ វស្សា? ឬក៏ការរាប់ឈ្មោះថា ៧ វស្សា?* "

*នាពេលនោះ ព្រះឆាយា (ស្រមោល) របស់ព្រះចៅមិលិន្ទទ្រង់លម្អដោយសម្លៀកបំពាក់ និង គ្រឿងលម្អទាំងពួងពេញយសសក្តិ បានចាំងស្រមោលនៅលើផ្ទៃដី ព្រះឆាយាក៏ប្រាកដនៅក្នុងផើងទឹកផងដែរ ។*

*គ្រានោះ* **ព្រះនាគសេន** *បានថ្វាយព្រះពរសួរសេចក្តីនោះ ទៅកាន់ព្រះចៅមិលិន្ទថា* " *សូមថ្វាយព្រះពរ មហាបពិត្រ ព្រះឆាយារបស់ព្រះអង្គនេះ បានចាំងនៅលើផ្ទៃដី នៅលើផើងទឹកផងដែរ ។ សូមថ្វាយព្រះពរ ព្រះអង្គខ្លួនឯងឈ្មោះថាជាព្រះរាជា ឬក៏ព្រះឆាយាឈ្មោះថាជា ព្រះរាជា?* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាឈ្មោះថាជាព្រះរាជា ស្រមោលនេះមិនមានឈ្មោះថា ជាព្រះរាជានោះទេ ប៉ុន្តែស្រមោលនោះកើតឡើង ព្រោះអាស្រ័យខ្ញុំព្រះករុណា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ឧបមាយ៉ាងណាឧបមេយ្យក៏យ៉ាងនោះ ការរាប់ឈ្មោះថា ៧ វស្សា ខ្លួនអាត្មាភាពខ្លួនឯង មិនមែន ឈ្មោះថា ៧ វស្សានោះទេ តែការរាប់ថា ៧ វស្សានេះ រមែងកើតឡើងព្រោះអាស្រ័យអាត្មាភាព ទើបមានឧបមាដូចស្រមោល សូមថ្វាយព្រះពរ* "

**ព្រះចៅមិលិន្ទ ៖** " *គួរឱ្យអស្ចារ្យមែន ព្រះគុណម្ចាស់នាគសេន គួរឱ្យចម្លែកមែន ព្រះគុណម្ចាស់នាគសេន ប្រការដែលលោកម្ចាស់វិសជ្ជនាបញ្ហាបដិភាណដ៏វិចិត្របំផុតបាន* " ៕

ចប់វស្សគណនបញ្ហាទី ២

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*ពាក្យថា " **វស្សគណនបញ្ហា** " ប្រែថា បញ្ហាស្ដីអំពីការរាប់វស្សា ។*

*ខ្លឹមសារសួរឆ្លើយក្នុងបញ្ហានេះ ងាយនឹងយល់ស្រាប់ហើយ ។ ទោះជាក្នុងបញ្ហាដំបូង ព្រះនាគសេនបានឆ្លើយឱ្យយល់ថា សត្វ បុគ្គល ប្រុស ស្រី គ្មានពិត ដោយបរមត្ថហើយក៏ដោយ ទោះជាយ៉ាងនោះក្ដី ប្រការដែលក្នុងបញ្ហាទី ២ ឬ សូម្បីបញ្ហាតទៅមុខទៀតគ្រប់បញ្ហា លោកទាំងពីរនៅតែមានការហៅគ្នាជាបុគ្គលកថាថា " **ព្រះគុណម្ចាស់នាគសេន... , សូមថ្វាយព្រះពរមហាបពិត្រ...** " ដូចនេះទៀត ក៏ដោយសារគោលបំណងមួយចំនួន ។*

*ជាការពិតថា ទោះជាសត្វ បុគ្គល គ្មានពិតដោយបរមត្ថ ទោះជាយ៉ាងនោះក្ដី ព្រះពុទ្ធអង្គក៏ត្រាស់ជាបុគ្គលកថា ថា " **ម្នាលភិក្ខុទាំងឡាយ... នែ៎ ! អានន្ទ... ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ជំពូក ទាំងនេះ ជាអ្នកប្រព្រឹត្តដើម្បីជាប្រយោជន៍...** " ជាដើម ។ ដោយទ្រង់មានព្រះបំណង ៨ ប្រការ ។*

*៨ ប្រការ គឺ អ្វីខ្លះ ? នោះគឺ ៖*

*- ដើម្បីសម្ដែងហិរោត្តប្បៈ ។*

*- ដើម្បីសម្ដែងនូវសេចក្ដីដែលសត្វទាំងឡាយមានកម្មជារបស់ខ្លួន ។*

*- ដើម្បីសម្ដែងពីអំពើរបស់មនុស្សម្នាក់ ៗ ដោយឡែក ៗ ។*

*- ដើម្បីសម្ដែងអនន្តរិយកម្ម ។*

*- ដើម្បីសម្ដែងព្រហ្មវិហារធម៌ ។*

*- ដើម្បីសម្ដែងបុព្វេនិវាសញ្ញាណ ។*

*- ដើម្បីសម្ដែងទក្ខិណាវិសុទ្ធិ ។*

- ដើម្បីការមិនបោះបង់ចោលនូវសម្មតិ ( ការសន្មត ) របស់មនុស្សលោក ។

បានសេចក្ដីថា នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ មានហិរិការខ្មាសអៀនបាប មានឱត្តប្បៈការខ្លាចក្រែងបាប មនុស្សទាំងឡាយរមែងមិនយល់ មិនជាក់ច្បាស់ មិនជឿ ។ ព្រោះហេតុនោះ ដើម្បីសម្ដែងហិរោត្តប្បៈ ឱ្យមនុស្សទាំងឡាយបានយល់ ទើបត្រាស់ជាបុគ្គលកថាថា អ្នកនោះគ្មានហិរោត្តប្បៈ ចំណែកអ្នកនោះ ជាមនុស្សបរិបូរដោយហិរោត្តប្បៈ ដូចជា **"ម្នាល ភិក្ខុទាំងឡាយ អ្នកចូរជាមនុស្សបរិបូរដោយហិរោត្តប្បៈទៅចុះ ព្រះឧទាយីជាមនុស្សដែលគ្មានការខ្មាសអៀន មិនខ្លាចក្រែងបាប"** ជាដើម ។

ម្យ៉ាងវិញទៀត នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ មានកម្មជារបស់ខ្លួន ក៏ដូចនោះដែរ គឺ មនុស្សទាំងឡាយរមែងស្ដាប់មិនយល់ មិនជាក់ច្បាស់ ។ ព្រោះហេតុនោះ ដើម្បីសម្ដែងនូវសេចក្ដីដែលសត្វទាំងឡាយមានកម្មជារបស់ខ្លួន ឱ្យអ្នកទាំងឡាយបានយល់ច្បាស់រឿងកម្ម ក្នុងន័យថា អ្នកណាធ្វើ អ្នកនោះតែងតែទទួលផលនៃអំពើរបស់ខ្លួន ទើបព្រះអង្គត្រាស់ជាបុគ្គលកថាថា **" សត្វទាំងឡាយមានកម្ម ជារបស់ខ្លួន ជាទាយាទទទួលយកកម្ម"** ជាដើម ។

ម្យ៉ាងទៀត នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ ឱ្យសាងព្រះវេឡុវ័នវិហារជាដើម មនុស្សទាំងឡាយរមែងស្ដាប់មិនយល់ មិនជាក់ច្បាស់។ ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់បុគ្គលកថា ដើម្បីសម្ដែងនូវអំពើរបស់មនុស្សម្នាក់ ៗ ដោយឡែក ៗ ឱ្យឃើញថា អ្នកនោះធ្វើអ្វី នោះជាអ្វីដែលអ្នកនោះធ្វើ នេះជាអ្វីដែលអ្នកនេះធ្វើ ។

*ម្យ៉ាងទៀត ពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ ផ្តាច់ជីវិតរបស់ខន្ធ ធាតុ អាយតនៈ ជាដើម ក៏ដូចនោះដែរ មនុស្សទាំងឡាយស្តាប់ហើយ មិនអាចយល់ មិនអាចជាក់ច្បាស់ក្នុងរឿងអនន្តរិយកម្មបាន ។ ព្រោះហេតុនោះ ដើម្បីសម្តែងអនន្តរិយកម្មឱ្យអ្នកស្តាប់បានយល់ ទើបព្រះអង្គត្រាស់ជាបុគ្គលកថា ពោលដល់បុគ្គលធ្វើអនន្តរិយកម្ម និង បែងចែកប្រភេទបុគ្គលដែលត្រូវគេធ្វើអំពើបាប ឬ បានទទួលការខូចខាតដោយសារតែអំពើនោះ អ្នកដែលជាហេតុឱ្យកម្មនោះបានដល់ថ្នាក់អនន្តរិយកម្មនោះ ដូចជា មាតា បិតា ជាដើម នៅពេលពោលដូចនេះ អ្នកស្តាប់រមែងយល់ពីអនន្តរិយកម្មបានច្បាស់ ។*

*ម្យ៉ាងទៀត នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ ចម្រើនមេត្តា ចម្រើន ករុណា មុទិតា ឧបេក្ខា ក៏ដូចនោះដែរ ។ មនុស្សទាំងឡាយស្តាប់ហើយរមែងមិនយល់ មិនជាក់ច្បាស់ ក្នុងការចម្រើនព្រហ្មវិហារ មិនអាចចម្រើនព្រហ្មវិហារធម៌បាន ។ ព្រោះហេតុនោះ ដើម្បីសម្តែងព្រហ្មវិហារធម៌ឱ្យមនុស្សទាំងឡាយស្តាប់យល់បានច្បាស់ ថែមទាំងអាចចម្រើនព្រហ្មវិហារ-ធម៌បាន ទើបព្រះអង្គត្រាស់ជាបុគ្គលកថាថា បុគ្គលម្នាក់នោះចម្រើនមេត្តា បុគ្គលម្នាក់នេះចម្រើនករុណា មុទិតា ឧបេក្ខា ។ បុគ្គលណាមានចិត្តលំឱនទៅកាន់សត្វទាំងឡាយដោយមេត្តា រមែងទទួលបានអានិសង្ស ១១ ប្រការ ។ ទោះជាអារម្មណ៍របស់ព្រហ្មវិហារធម៌ទាំងនេះ ក៏ត្រាស់ជាបុគ្គលកថា ដូចជា " **សព្វេ សត្តា...- សត្វទាំងឡាយទាំងពួង... សព្វេ បុគ្គលា... - បុគ្គលទាំងឡាយទាំងពួង... យ៉ាងនេះ** " ជាដើម ។ នៅពេលត្រាស់ដូចនេះហើយ អ្នកស្តាប់ទាំងឡាយ ក៏រមែងយល់ពីព្រហ្មវិហារធម៌បានច្បាស់ ។*

*ម្យ៉ាងទៀត នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ រឭកដល់ ខន្ធ ធាតុ អាយតនៈ ដែលធ្លាប់រស់នៅក្នុងភពជាតិមុន ក៏ដូចនេះដែរ គឺ មនុស្ស ទាំងឡាយស្តាប់ហើយ រមែងតែងតែមិនយល់មិនជាក់ច្បាស់ ក្នុងបុព្វេនិវាស-ញ្ញាណ ។ ព្រោះហេតុនោះ ដើម្បីសម្តែងបុព្វេនិវាសញ្ញាណ ឱ្យមនុស្ស ទាំងឡាយស្តាប់យល់ច្បាស់ ទើបព្រះអង្គត្រាស់ជាបុគ្គលកថាថា* ***" ភិក្ខុនោះ នៅពេលចិត្តតាំងមាំបរិសុទ្ធ... ។ល។ រមែងតែលំឱនចិត្តទៅ ដើម្បីបុព្វេនិវាសា-នុស្សតិញ្ញាណ រឭកដល់ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងភពមុន ៗ ដ៏ច្រើន គឺ មួយជាតិ ពីរជាតិ ... ។ ល។ "*** *ជាដើម ។*

*ម្យ៉ាងទៀត នៅពេលត្រាស់ថា ខន្ធ ធាតុ អាយតនៈ ឱ្យទាន ខន្ធ ធាតុ អាយតនៈ ទទួលយកទានទៅក៏ដូចនេះដែរ ។ អ្នកទាំងឡាយស្តាប់ហើយមិន យល់ មិនជាក់ច្បាស់ ព្រោះហេតុនោះ ដើម្បីសម្តែងទក្ខិណាវិសុទ្ធិ ភាព បរិសុទ្ធនៃទក្ខិណាទាន ពោលគឺទានដែលគេឱ្យ គេប្រគេន ព្រោះជឿថាមាន ជាតិក្រោយ ឱ្យមនុស្សទាំងឡាយយល់ជាក់ច្បាស់ក្នុងរឿងទាន ថែមទាំង អាចប្រព្រឹត្តតាមបាន ។ ទើបព្រះអង្គត្រាស់ជាបុគ្គលកថាថា មានបុគ្គលអ្នក ឱ្យ មានបុគ្គលអ្នកទទួល ។ ម្យ៉ាងវិញទៀត អ្នកឱ្យរមែងសង្ឃឹមថា បានទទួល អានិសង្ស ឬ ផលតបស្នងច្រើន ។ ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ជា បុគ្គលកថា សម្តែងដល់បុគ្គលអ្នកទទួលយកទាន ដែលជាអ្នកធ្វើឱ្យ ទក្ខិណាទានបរិសុទ្ធទៅតាមលំដាប់ ដែលអាចសង្ឃឹមអានិសង្ស កាន់តែ ច្រើន ទៅតាមលំដាប់បាន ដូចជាត្រាស់ថា ឱ្យដល់បុថុជ្ជនអ្នកទ្រុស្តសីល បានទទួលអានិសង្សតិច ឱ្យដល់បុថុជ្ជនអ្នកមានសីល បានទទួលអានិសង្ស ច្រើន ឱ្យដល់បុថុជ្ជនអ្នកមានសីល បានទទួលអានិសង្សតិច ឱ្យដល់ព្រះ សោតាបន្ន បានទទួលអានិសង្សច្រើន ជាដើម ។*

*មុយ៉ាងទៀត ព្រះពុទ្ធជាម្ចាស់ទាំងឡាយគ្រប់ព្រះអង្គ ទ្រង់មិនលះបង់សម្មតិ (ការសន្មត) ទ្រង់រក្សាសម្មតិរបស់មនុស្សលោក ។ ពោលគឺ អ្វីដែលមនុស្សលោក សន្មតហៅតៗគ្នា ដោយឈ្មោះ ដោយបញ្ញត្តិ ដោយវោហារ ដោយភាសា ដោយសមញ្ញាអ្វី ក៏ត្រាស់ហៅប្រការនោះ ដោយបញ្ញត្តិ ដោយវោហារ ដោយភាសា ដោយសមញ្ញានោះដែរ ។ ព្រោះហេតុនោះ ទើបពោលបានថា ព្រះអង្គត្រាស់ជាបុគ្គលកថា ដើម្បីការមិនលះបង់ចោលនូវសម្មតិរបស់មនុស្សលោក ។*

*បានសេចក្ដីថា ទោះជាសត្វឬបុគ្គលគ្មានពិតដោយបរមត្ថ ទោះជាយ៉ាងនោះក្ដី ព្រះពុទ្ធអង្គគ្រប់ព្រះអង្គ ក៏បានត្រាស់ព្រះធម៌ទេសនាជាបុគ្គលកថា ព្រោះទ្រង់មានព្រះបំណង ៨ ប្រការ ដូចបានពោលខាងលើមកនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - វីមំសនបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់អាចសន្ទនាជាមួយខ្ញុំព្រះករុណាបានដែរឬទេ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រសិនបើព្រះអង្គនឹងត្រាស់ពាក្យជាបណ្ឌិតវាទៈ (ពាក្យដែលបណ្ឌិតទាំងឡាយប្រើសន្ទនាគ្នា ) អាត្មាភាព ក៏នឹងសន្ទនាជាមួយ ។ ប៉ុន្តែ ប្រសិនបើព្រះអង្គត្រាស់ជាពាក្យរាជវាទៈ (ពាក្យដែលព្រះរាជាទាំងឡាយមានបន្ទូល ) អាត្មាភាពសូមមិនសន្ទនាជាមួយ "*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន ពួកបណ្ឌិតសន្ទនាគ្នាយ៉ាងដូចម្តេច ?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ នៅពេលមានការសន្ទនាគ្នា ពួកបណ្ឌិតទាំងឡាយរមែងតែចង(បញ្ហា)ខ្លះ ស្រាយ(ពាក្យគេ)ខ្លះ តបតខ្លះ ធ្វើជាពាក្យដែលពោលច្បាស់ល្អខ្លះ ធ្វើជាពាក្យដែលពោលច្បាស់ល្អជាងខ្លះ ។ ពួកបណ្ឌិតទាំងឡាយរមែងមិនល្អក់កករគ្នាព្រោះវាទៈនោះ ។ សូមថ្វាយព្រះពរ ពួកបណ្ឌិតសន្ទនាគ្នាយ៉ាងនេះ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ ពួកព្រះរាជាសន្ទនាគ្នាយ៉ាងម៉េច?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ នៅពេលមានការសន្ទនាគ្នា ( ឬនិយាយស្តីគ្នា ) ព្រះរាជាទ្រង់អះអាងរឿងមួយ អ្នកណាមិនយល់ស្របតាមរឿង ដែលទ្រង់អះអាងនោះ ទ្រង់ក៏មានបន្ទូលឱ្យដាក់ទោសអ្នកនោះថា " ចូរដាក់ទោស ម្នាក់នេះ " សូមថ្វាយព្រះពរ ព្រះរាជាទាំងឡាយទ្រង់សន្ទនាគ្នាយ៉ាងនេះ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ ខ្ញុំព្រះករុណានឹងនិយាយស្តីតែពាក្យដែលជាបណ្ឌិតវាទៈ មិនមែនរាជវាទៈទេ សូមព្រះគុណម្ចាស់ទុកចិត្តលើការនិយាយស្តី ជាមួយខ្ញុំព្រះករុណា ដូចព្រះគុណម្ចាស់និយាយស្តីទៅកាន់ភិក្ខុ ឬសាមណេរ ឬជាមួយឧបាសក ឬញោមវត្តទៅចុះ សូមកុំខ្លាចអី "*

**ព្រះថេរៈ** *អនុមោទនាថា* ៖ " *សាធុ សូមថ្វាយព្រះពរ "*

**ព្រះរាជា** *ត្រាស់ថា " ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាសូមសួរបញ្ហាហើយណ៎ា "*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ សូមត្រាស់សួរមកចុះ "*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាបានសួរហើយ "*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ អាត្មាភាពក៏បានថ្វាយវិសជ្ជនាហើយ "*

**ព្រះចៅមិលិន្ទ ៖** "*ព្រះគុណម្ចាស់ លោកម្ចាស់វិសជ្ជនាថាយ៉ាងម៉េច ?"*

**ព្រះនាគសេន ៖** " *ក៏មហាបពិត្រ ត្រាស់សួរថាយ៉ាងម៉េច ? " ។*

*ចប់វីមំសនបញ្ហាទី ៣*

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

*ពាក្យថា* ***វីមំសនបញ្ហា*** *ប្រែថា បញ្ហាទាក់ទងនឹងការត្រិះរិះពិចារណា ឬ សាកសួរ ។ ក្នុងទីនេះ សំដៅដល់ការត្រិះរិះ ឬ ពិចារណាគ្នាជាមុនថា នឹងសន្ទនាគ្នាដោយពាក្យសម្ដីយ៉ាងដូចម្ដេច ? បណ្ឌិតវាទៈ ឬរាជ-វាទៈ ? បណ្ឌិតវាទៈ យ៉ាងដូចម្ដេច ? រាជវាទៈ យ៉ាងដូចម្ដេច ?*

*ពាក្យថា* ***បណ្ឌិតវាទៈ*** *ព្រោះជាពាក្យសម្ដី ដែលបណ្ឌិតទាំងឡាយនិយាយគ្នា ។*

*ពាក្យថា* ***រាជវាទៈ*** *ព្រោះជាពាក្យដែលព្រះរាជាទាំងឡាយមានបន្ទូល។*

*ក្នុងពាក្យដែលហៅថា* ***វាទៈ*** *ក្នុងទីនេះ សំដៅយកពាក្យដែលមនុស្សពួកផ្សេងគ្នា សន្ទនាគ្នា ដែលមានគំនិតយោបល់ក្នុងរឿងតែមួយ អាចមានគំនិតដូចគ្នា លើកឡើងមក អះអាង ឬ បដិសេធរឿងនោះ ។*

*ពាក្យថា* ***ចង(បញ្ហា)*** *គឺ ចង(បញ្ហា)មុន គឺដាក់បញ្ហាទុកឱ្យម្នាក់ទៀតដោះស្រាយ ។ ទោះជាមិនពោលថា យើងខ្ញុំបានដាក់បញ្ហានេះហើយ ជាឱកាស ដែលលោកត្រូវពោលដោះស្រាយ ដូចនេះក៏ដោយ ។ ទោះជាយ៉ាង*

នោះក្តី គ្រាន់តែនិយាយដល់ប៉ុណ្ណោះ ម្នាក់ទៀតស្តាប់ហើយក៏ដឹងថា ជាពាក្យដែលយើងត្រូវដោះស្រាយ ត្រូវបកស្រាយ ។

ពាក្យថា **ស្រាយ(សម្តីគេ)** បានន័យថា ជាដំបូងគឺ លើកយកទោស គឺបង្ហាញឱ្យគេឃើញកំហុស ឬ ប្រការខុសឆ្គងក្នុងបញ្ហា ឬ ពាក្យដែលគេនិយាយ រួចហើយស្រាយឬជម្រះ បកស្រាយពាក្យដែលគេចងមកនោះ ។

ពាក្យថា **សង្កត់** គឺ សង្កត់គេ ទំនងថា គេនិយាយខុសឆ្គង ដូចជា ពាក្យមុន ពាក្យក្រោយដែលលោកនិយាយចេញមកនោះ មិនសមគ្នា ។ ពាក្យដែលគួរពោលមុន លោកបែរជាពោលក្រោយ ។ ពាក្យដែលគួរពោលក្រោយ លោកបែរជាពោលមុន ពាក្យនេះរបស់លោកមិនត្រឹមត្រូវ តែពាក្យសម្តីរបស់យើងខ្ញុំទើបត្រឹមត្រូវ ដូចនេះ ជាដើម ។

ពាក្យថា **តបត** គឺ ចេះធ្វើការតបទៅវិញថា ពាក្យរបស់យើងខ្ញុំនេះត្រឹមត្រូវហើយ មិនខុសទេ ។ តែទោះជាត្រឹមត្រូវមិនខុសក្តី លោកមានបំណងលើកយកជាកំហុស ទើបលោកពោលយកសម្តីដែលមិនខុសនោះ ថាជាសម្តីមានកំហុស ដូចនេះ ។ ដូចនេះ ជាដើម ។

ពាក្យថា **ទ្រង់អះអាងរឿងមួយ** គឺទ្រង់អះអាងរឿងដែលមានបន្ទូលរឿងមួយ ។ ពាក្យថា **មិនយល់ស្របតាម** គឺក្រាបទូលឱ្យទ្រង់ជ្រាបថា ជាបន្ទូលដែលមិនត្រឹមត្រូវ ។

ពាក្យថា **ចូរទុកចិត្ត** គឺ ចូរធ្វើចិត្តឱ្យស្និទ្ធស្នាល ដូចពេលសន្ទនាជាមួយអ្នកស្គាល់គ្នាទាំងឡាយមានភិក្ខុ សាមណេរ ឧបាសក ឬ ញោមវត្តជាដើម ៗ

ចប់ពាក្យអធិប្បាយបញ្ហាទី ៣

# បញ្ហាទី ៤ - អនន្តកាយប្បញ្ហា

*គ្រានោះ ព្រះចៅមិលិន្ទទ្រង់កើតព្រះតម្រិះ ប្រការនេះឡើងមកថា " ព្រះភិក្ខុអង្គនេះ ជាបណ្ឌិតមានសមត្ថភាពគ្រប់គ្រាន់ នឹងសន្ទនាជាមួយយើងបាន ឯរឿងដែលយើងត្រូវសួរមានច្រើន រឿងទាំងនោះយើងមិនទាន់បានសួរសោះ ប៉ុន្តែព្រះអាទិត្យកំពុងអស្តង្គតទៅហើយ បើដូចនេះ យើងអាចសន្ទនាគ្នាក្នុងរាជធានីបាន " ដូចនេះ ។*

*លំដាប់នោះ ព្រះរាជាទើបមានបន្ទូលសេចក្តីនោះ ទៅកាន់ទេវមន្តិយ-អាមាត្យថា " ម្នាល ! ទេវមន្តិយ បើដូចនេះ ចូរឯងទៅទូលចំពោះព្រះគុណ-ម្ចាស់ចុះថា " ស្អែកនេះ ព្រះគុណម្ចាស់នឹងមានការសន្ទនាជាមួយព្រះរាជាក្នុងរាជធានី " ដូចនេះ ចុះ " ។ ព្រះចៅមិលិន្ទមានបន្ទូលសេចក្តីនោះរួចហើយ ក៏បានក្រោកឡើងចេញពីអាសនៈ ត្រាស់លាព្រះនាគសេនត្ថេរ ស្តេចយាងឡើងរទេះព្រះទីនាំងចេញទៅ ទ្រង់ពោលយ៉ាងនេះថា " នាគសេន, នាគសេន " ។*

*បន្ទាប់ពីនោះ ទេវមន្តិយអាមាត្យក៏បានទៅទូលសេចក្តីនោះ ចំពោះព្រះនាគសេនថា " ព្រះគុណម្ចាស់ ព្រះចៅមិលិន្ទមានបន្ទូលយ៉ាងនេះថា ស្អែកនេះនឹងមានការសន្ទនាជាមួយព្រះរាជាក្នុងរាជធានី ព្រះគុណម្ចាស់ " ព្រះថេរៈពោលយល់ស្របថា " ល្អហើយ " ។*

*គ្រានោះ ពេលរាត្រីកន្លងផុតទៅ ទេវមន្តិយអាមាត្យ អនន្តកាយអាមាត្យ មង្គុរអាមាត្យ និង សព្វទិន្នអាមាត្យ បាននាំគ្នាទៅចូលគាល់ព្រះចៅមិលិន្ទដល់ទីប្រថាប់ ។ លុះចូលទៅដល់ហើយ ក៏ក្រាបទូលសួរសេចក្តីនោះទៅកាន់ព្រះចៅមិលិន្ទថា " បពិត្រព្រះមហារាជ ព្រះអង្គទ្រង់ប្រោសឱ្យព្រះ*

គុណម្ចាស់នាគសេននិមន្តមកបានហើយឬនៅ ក្រាបទូល ? ” ព្រះរាជា “ អឺ... សូមឱ្យព្រះគុណម្ចាស់និមន្តមកចុះ ” “ ទ្រង់ប្រោសឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយព្រះភិក្ខុចំនួនប៉ុន្មាន ក្រាបទូល ? ” “ សូមឱ្យព្រះគុណម្ចាស់និមន្តមក ព្រមទាំងព្រះភិក្ខុ ចំនួនតាមដែលព្រះគុណម្ចាស់ត្រូវការចុះ ” ។

ឃើញដូចនេះសព្វទិន្នអាមាត្យទើបក្រាបទូលថា “ បពិត្រព្រះមហារាជ សូមទ្រង់ប្រោសឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយនឹងព្រះភិក្ខុ ចំនួនត្រឹមតែ ១០ អង្គ ប៉ុណ្ណោះចុះ ក្រាបទូល ” ព្រះរាជាទើបត្រាស់ជាលើកទី ២ ថា “សូមឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយព្រះភិក្ខុ ចំនួនតាមដែលព្រះគុណម្ចាស់ត្រូវការចុះ ” សព្វទិន្នអាមាត្យក៏នៅតែក្រាបទូលជាលើកទី ២ ថា “បពិត្រព្រះមហារាជ សូមទ្រង់ប្រោសឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយនឹងព្រះភិក្ខុចំនួនត្រឹមតែ ១០ អង្គប៉ុណ្ណោះចុះ ក្រាបទូល ” ។ ទោះជាព្រះរាជាមានបន្ទូលជាលើកទី ៣ ថា “ សូមឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយព្រះភិក្ខុចំនួន តាមដែលព្រះគុណម្ចាស់ត្រូវការចុះ ” ។ សព្វទិន្នអាមាត្យនៅតែក្រាបទូលជាលើកទី ៣ ថា “ បពិត្រព្រះមហារាជ សូមទ្រង់ប្រោសឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយនឹងព្រះភិក្ខុចំនួន ត្រឹមតែ ១០ អង្គ ប៉ុណ្ណោះចុះ ក្រាបទូល ” ។

**ព្រះរាជា ៖** “ គឺគ្រឿងសក្ការៈគ្រប់យ៉ាងនេះ យើងបានត្រៀមរួចរាល់ហើយ ទាំងយើងក៏បានពោលថា “ សូមឱ្យព្រះគុណម្ចាស់និមន្តមក ជាមួយព្រះភិក្ខុចំនួន តាមដែលព្រះគុណម្ចាស់ត្រូវការចុះ ” ។ ម្នាល ! នាយសព្វទិន្នអាមាត្យម្នាក់នេះ បែរជាពោលដោយប្រការផ្សេង យើងគ្មានសមត្ថភាពគ្រប់គ្រាន់នឹងប្រគេនម្ហូបចង្ហាន់ ដល់ព្រះភិក្ខុទាំងឡាយ ឬយ៉ាងណា ? ” នៅពេលមានបន្ទូលដូចនេះហើយ សព្វទិន្នអាមាត្យក៏បានតែនៅស្ងៀម ។

*បន្ទាប់ពីនោះ ទេវមន្តិយអាមាត្យ អនន្តកាយអាមាត្យ និង មង្កុរអាមាត្យ បានចូលទៅរកព្រះនាគសេនដល់កន្លែង ។ លុះចូលទៅហើយ ក៏បានទូលសេចក្តីនោះ ទៅកាន់ព្រះនាគសេនថា " ព្រះគុណម្ចាស់ ព្រះចៅមិលិន្ទបានមានបន្ទូលយ៉ាងនេះថា សូមឱ្យព្រះគុណម្ចាស់និមន្តមក ព្រមជាមួយព្រះភិក្ខុ ចំនួនតាមដែលព្រះគុណម្ចាស់ត្រូវការចុះ " ។ លំដាប់នោះ នាពេលព្រលឹមស្រាង ៗ ព្រះនាគសេន ស្លៀកស្បង់ ប្រដាប់បាត្រនិងចីពរ ចូលទៅកាន់សាគលរាជធានីព្រមជាមួយព្រះភិក្ខុសង្ឃចំនួន ៨០.០០០អង្គ ។*

*គ្រានោះ* **អនន្តកាយអាមាត្យ** *ដើរជិតព្រះនាគសេន បានសួរសេចក្តីនោះ ទៅកាន់ព្រះនាគសេនថា " ព្រះគុណម្ចាស់នាគសេន ពាក្យដែលព្រះគុណម្ចាស់ពោលថា " នាគសេន " នេះ ក្នុងពាក្យនេះមានអ្វី ដែលជានាគសេននៅក្នុងនោះឬ ? "*

**ព្រះថេរៈ** *ពោលសួរទៅវិញថា "ក្នុងពាក្យថា " នាគសេន " នេះ តើអ្នកសំដៅយកអ្វី ជានាគសេន ? "*

**អនន្តកាយអាមាត្យ** *តបថា " ព្រះគុណម្ចាស់ ជីវៈ គឺ ខ្យល់ខាងក្នុង រមែងចូល និងចេញនោះតែម្តង ថាជានាគសេន "*

**ព្រះនាគសេន ៖** *" ប្រសិនបើខ្យល់នោះចេញទៅហើយ មិនត្រឡប់ចូលមក ចូលទៅហើយមិនចេញមក មនុស្សយើងអាចនៅកើតដែរទេ ? "*

**អនន្តកាយអាមាត្យ ៖** *" មិនបានទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" អ្នកផ្លុំខ្យងស័ង្ខ រមែងផ្លុំខ្យងស័ង្ខ ខ្យល់ផ្លុំរបស់អ្នកទាំងនោះ នឹងត្រឡប់ចូលទៅវិញឬ ? "*

**អនន្តកាយអាមាត្យ ៖** *" មិនត្រឡប់ចូលទៅទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** " *ពួកអ្នកផ្លុំខ្លុយ រមែងផ្លុំខ្លុយ ខ្យល់ផ្លុំរបស់អ្នកទាំងនោះ នឹងត្រឡប់ចូលទៅទៀតឬ?*"

**អនន្តកាយអាមាត្យ ៖** " *មិនត្រឡប់ចូលទៅទៀតទេ ព្រះគុណម្ចាស់*"

**ព្រះនាគសេន ៖** " *ពួកអ្នកផ្លុំស្នែងសត្វ ក៏រមែងផ្លុំស្នែងសត្វ ខ្យល់ផ្លុំរបស់អ្នកទាំងនោះ នឹងត្រឡប់ចូលទៅទៀតឬ?*"

**អនន្តកាយអាមាត្យ ៖** " *មិនត្រឡប់ចូលទៅទៀតទេ ព្រះគុណម្ចាស់*"

**ព្រះនាគសេន ៖** " *បើដូចនេះ ព្រោះហេតុអ្វីបានជាអ្នកទាំងនោះមិនស្លាប់?*"

**អនន្តកាយអាមាត្យ ៖** " *ខ្ញុំព្រះករុណាមិនមានសមត្ថភាព នឹងសន្ទនាជាមួយព្រះគុណម្ចាស់ដែលជាកំពូលវាទៈបានទេ សូមព្រះគុណម្ចាស់មេត្តាអធិប្បាយសេចក្ដីនោះផងចុះ*"

*ព្រះថេរៈបានពោលអភិធម្មកថា ថា " ហៅថា ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញនេះ មិនមែនជីវៈទេ នេះហៅថា កាយសង្ខារ " ដូចនេះជាដើម លំដាប់នោះ អនន្តកាយអាមាត្យក៏បានប្រកាសភាពជាឧបាសក ៕*

*ចប់អនន្តកាយប្បញ្ហាទី ៤*

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

*ពាក្យថា* ***អនន្តកាយប្បញ្ហា*** *ប្រែថា បញ្ហារបស់អនន្តកាយអាមាត្យ ។*

*ពាក្យថា* ***ខ្យល់ខាងក្នុង*** *គឺ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញខាងក្នុងខ្លួនរបស់លោក ។*

*អ្វីដែលអ្នកសួរពោលដល់ថា* ***ជីវៈ*** *ដោយវោហារ គឺ សត្វ ដែលពាក្យ*

*វិសជ្ជនាតទៅមុខ ព្រះថេរៈនឹងបដិសេធថា "ឈ្មោះថាជីវៈនេះមិនមានពិត"។*

*ពាក្យថា* ***សង្ខ*** *គឺ ខ្យងស័ង្ខមួយគូដែលគេផ្លុំ ២-៣ ដង ក្នុងពេលព្រះរាជាស្ដេចយាងចេញ ។*

*ពាក្យថា* ***ខ្មុយ*** *គឺ គ្រឿងតន្ត្រីម៉្យាង ដែលមានរាងមូលជាបំពង់ ។*

*ពាក្យថា* ***ស្នែងសត្វ*** *គឺ ស្នែងក្របី ស្នែងគោ ជាដើម ។*

*ក្នុងពាក្យថា* ***កាយសង្ខារ*** *នេះ ជាបឋមសង្ខារមាន ៣ យ៉ាង ដូចដែលវិសាខឧបាសកនិងព្រះធម្មទិន្នាភិក្ខុនីសួរឆ្លើយគ្នា ក្នុងចុល្លវេទល្លសូត្រ យ៉ាងនេះថា ៖*

**វិសាខឧបាសក ៖** *" ព្រះមេម្ចាស់ សង្ខារមានប៉ុន្មាន ?"*

**ព្រះធម្មទិន្នាថេរី ៖** *" លោកវិសាខ សង្ខារមាន ៣ យ៉ាងទាំងនេះ គឺ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ "*

**វិសាខឧបាសក ៖** *" ព្រះមេម្ចាស់ កាយសង្ខារគឺអ្វី ? វចីសង្ខារគឺអ្វី ? ចិត្តសង្ខារ គឺអ្វី ?"*

**ព្រះធម្មទិន្នាថេរី ៖** *" លោកវិសាខ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ឈ្មោះថា កាយសង្ខារ ។ វិតក្ក (គំនិត) វិចារ(ការពិចារណា) ឈ្មោះថា វចីសង្ខារ ។ សញ្ញា (ការចងចាំ) និង វេទនា (ការសោយអារម្មណ៍) ឈ្មោះថា ចិត្តសង្ខារ " ។*

**វិសាខឧបាសក ៖** *" ព្រះមេម្ចាស់ ព្រោះហេតុអ្វីបានជាខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ទើបឈ្មោះថាកាយសង្ខារ ?*

*ព្រោះហេតុអ្វីបានជា វិតក្ក និងវិចារ ទើបឈ្មោះថា វចីសង្ខារ ?*

*ព្រោះហេតុអ្វី សញ្ញា និងវេទនា ទើបឈ្មោះថា ចិត្តសង្ខារនោះ ?"*

**ព្រះធម្មទិន្នាថេរី ៖** " *លោកវិសាខ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ជារបស់មានក្នុងកាយ ។ ធម៌ទាំងនេះទាក់ទងនឹងកាយ ( ទាក់ទងថា ជារបស់ដែលកាយផ្សំតាក់តែងឡើង គឺសាងឡើង ) ។ ព្រោះហេតុនោះ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ទើបឈ្មោះថាជា កាយសង្ខារ ( អ្វីដែលកាយផ្សំតែងឡើង ) ។*

*លោកវិសាខ បុគ្គលរមែងគិតពិចារណា ( ទាក់ទងនឹងសម្ដីដែលនឹងបញ្ចេញមក និងរឿងដែលនឹងនិយាយ ) ជាមុន ទើបបញ្ចេញវាចាជាក្រោយ ព្រោះហេតុនោះ វិតក្ក និង វិចារ ទើបឈ្មោះថា វចីសង្ខារ ( អ្វីដែលផ្សំតែងវាចា ) ។*

*សញ្ញា និងវេទនា ជារបស់មាននៅក្នុងចិត្ត ធម៌ទាំងនេះទាក់ទងនឹងចិត្ត ។ ព្រោះហេតុនោះ សញ្ញា និងវេទនា ទើបឈ្មោះថា ចិត្តសង្ខារ ( អ្វីដែលចិត្តតាក់តែង ឬតាក់តែងចិត្ត ) " ដូចនេះ ។*

*ព្រះនាគសេនត្ថេរ ពោលអភិធម្មកថា ស្ដីអំពីភាពជាកាយសង្ខារនៃខ្យល់ដង្ហើមចូលនិងចេញ ដោយប្រការជាអ្វីទាក់ទងនឹងកាយ បានសេចក្ដីថា ជារបស់ដែលកាយផ្សំតែង គឺ សាងឡើង ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - បព្វជ្ជាបញ្ហា

*គ្រានោះ ព្រះនាគសេនបានចូលទៅកាន់ព្រះរាជនិវេសន៍របស់ព្រះចៅមិលិន្ទ ។ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានរៀបចំត្រៀមទុក ។ លំដាប់នោះ ព្រះចៅមិលិន្ទក៏បានប្រគេនម្ហូបចង្ហាន់ដល់ព្រះនាគ-*

សេន ព្រមទាំងបរិស័ទ ឱ្យឆ្អែត ឱ្យគ្រប់គ្រាន់ ដោយអាហារទំពា អាហារឆាន់ ដ៏ប្រណីត ដោយព្រហស្តរបស់ព្រះអង្គផ្ទាល់ ។ រួចទ្រង់ឱ្យភិក្ខុមួយអង្គ ៗ បានគ្រង់សំពត់មួយគូ ៗ និងឱ្យព្រះនាគសេនបានគ្រងត្រៃចីពរ ។ រួចត្រាស់សេចក្តីនោះ ទៅកាន់ព្រះនាគសេន ដែលបានគ្រងត្រៃចីពររួចហើយថា "ព្រះគុណម្ចាស់នាគសេន សូមនិមន្តព្រះគុណម្ចាស់ ព្រមជាមួយព្រះភិក្ខុ ១០ អង្គ គង់នៅទីនេះចុះ ភិក្ខុដែលនៅសល់ សូមនិមន្តត្រឡប់ទៅវិញសិនចុះ ព្រះគុណម្ចាស់" ដូចនេះ ។

លំដាប់នោះ ព្រះចៅមិលិន្ទ លុះទ្រង់ជ្រាបថា ព្រះនាគសេនឆាន់រួចហើយ មានដៃដកចេញពីបាត្ររួចហើយ ទ្រង់យកអាសនៈដែលទាបជាងមួយកន្លែង រួចប្រថាប់អង្គុយចុះ នៅកន្លែងសមរម្យម្ខាងរួចហើយ ក៏បានមានបន្ទូលសួរសេចក្តីនោះ ទៅកាន់ព្រះនាគសេនថា "ព្រះគុណម្ចាស់នាគសេន យើងនឹងមានការសន្ទនាគ្នា ក្នុងរឿងអ្វីខ្លះ?"

**ព្រះនាគសេន ៖** "សូមថ្វាយព្រះពរ មហាបពិត្រ ពួកយើងត្រូវការប្រយោជន៍ សូមឱ្យមានការសន្ទនាគ្នា ក្នុងរឿងដែលមានប្រយោជន៍ទៅចុះ"

**ព្រះរាជា** ត្រាស់សួរថា "ព្រះគុណម្ចាស់នាគសេន ការបួសមានប្រយោជន៍អ្វី? ហើយប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកព្រះគុណម្ចាស់ គឺអ្វី?"

**ព្រះថេរៈ** ថ្វាយវិសជ្ជនាថា "ប្រយោជន៍អ្វីឬ? សូមថ្វាយព្រះពរ ពួកអាត្មាភាព បួសដើម្បីប្រយោជន៍ប្រការនេះ គឺ ទុក្ខនេះរលត់ទៅ ទុក្ខផ្សេងមិនកើតមានទៀត, សូមថ្វាយព្រះពរ ការបួសរបស់ពួកអាត្មាភាពក៏មានប្រការដែលពោលមកនេះ ជាប្រយោជន៍ អនុបាទាបរិនិព្វានជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកអាត្មាភាព"

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ពួកព្រះគុណម្ចាស់គ្រប់អង្គ សុទ្ធតែបួសដើម្បីប្រយោជន៍ប្រការនេះឬ?"*

**ព្រះនាគសេន ៖** " *មិនមែនដូចនេះទេ សូមថ្វាយព្រះពរ អង្គខ្លះក៏បួសដើម្បីប្រយោជន៍ប្រការនេះ អង្គខ្លះជាអ្នកដែលព្រះរាជាមានបន្ទូលឱ្យចាប់ខ្លួន ក៏មកបួស (បួសគេចព្រះរាជា) អង្គខ្លះជាអ្នកដែលពួកចោរប៉ងចាប់ខ្លួនក៏មកបួស (បួសគេចចោរ) អង្គខ្លះបួសគេចបំណុល អង្គខ្លះបួសដើម្បីប្រយោជន៍ក្នុងការចិញ្ចឹមជីវិត, ចំណែកភិក្ខុក្រុមណាបួសត្រឹមត្រូវ ភិក្ខុក្រុមនោះរមែងបួស ដើម្បីប្រយោជន៍ប្រការនេះ"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ ខ្លួនព្រះគុណម្ចាស់បួសដើម្បីប្រការនេះឬ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ អាត្មាភាពបួសតាំងពីនៅក្មេង មិនទាន់បានដឹងថាដើម្បីប្រយោជន៍អ្វីនោះទេ ប៉ុន្តែអាត្មាភាពមានគំនិតយ៉ាងនេះថា " ពួកសមណសក្យបុត្រទាំងនេះជាបណ្ឌិត ព្រះគុណម្ចាស់ទាំងនោះនឹងទូន្មានយើង " អាត្មាភាពលុះព្រះគុណម្ចាស់ទាំងនោះទូន្មានហើយ ទើបដឹង ទើបយល់ថា " ការបួសរមែងមាន ដើម្បីប្រយោជន៍នេះ" ដូចនេះ"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់បព្វជ្ជាបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*ពាក្យថា **បព្វជ្ជាបញ្ហា** ប្រែថា បញ្ហាទាក់ទងនឹងការបួស ។*

*ឈ្មោះថា **បព្វជ្ជា** (ការបួស) មានន័យថា បព្វជ្ជាដោយវិធីពោលពាក្យដល់ត្រៃសរណៈ ជាការបព្វជ្ជារបស់សាមណេរ ចំណែកបព្វជ្ជាទាំង ៨ វិធី មានឯហិភិក្ខុវិធី(ចូរមកជាភិក្ខុចុះ)ជាដើម ឈ្មោះថាជាឧបសម្បទារបស់ភិក្ខុ។*

*ព្រះរាជាត្រាស់សួរប្រយោជន៍របស់ការបួស ដោយទ្រង់មានភាពស្ទាក់ស្ទើរក្នុងព្រះទ័យ ទ្រង់មិនអាចសម្រេចព្រះទ័យបានថា អ្វីជាប្រយោជន៍ផ្ទាល់របស់ការបួស ? ព្រោះព្រះពុទ្ធអង្គ បានត្រាស់ទុកជាច្រើនកន្លែងផ្សេងៗគ្នា មិនដូចគ្នា ។ គឺ កន្លែងមួយ ទ្រង់ទទួលស្គាល់ថា ការបួសនេះចាត់ទុកថាជាមរតកមួយយ៉ាងរបស់ព្រះអង្គ ទើបទ្រង់អនុញ្ញាតឱ្យកុលបុត្រ ដែលត្រូវការបួសបានបួស ដើម្បីទទួលមរតកនេះ ។*

*ដូចគ្រាព្រះរាហុលកុមារត្រូវព្រះជននី ណែនាំឱ្យទៅទទួលមរតកពីព្រះដ៏មានព្រះភាគ រួចក៏ដើរតាមព្រះដ៏មានព្រះភាគ ព្រមទាំងពោលវាចាសូមមរតកថា* **" ទាយជ្ជំ មេ សមណ ទេហិ, ទាយជ្ជំ មេ សមណ ទេហិ - *បពិត្រសមណៈ សូមទ្រង់ប្រគល់មរតកឱ្យខ្ញុំព្រះករុណាផងចុះ , បពិត្រសមណៈ សូមទ្រង់ប្រគល់មរតកឱ្យខ្ញុំព្រះករុណាផងចុះ*"** *ដូចនេះ ។*

*ព្រះអង្គស្តាប់ហើយក៏ទ្រង់ប្រគល់មរតកគឺការបំបួស មានបន្ទូលទៅកាន់ព្រះសារីបុត្រថា* **" តេនហិ ត្វំ សារិបុត្ត រាហុលំ បព្វាជេថ - *ម្នាលសារីបុត្រ បើដូចនេះ ចូរអ្នកឱ្យរាហុលបានបួសចុះ*"** *ដូចនេះ ជាដើម ។*

*ម៉្យាងវិញទៀត ត្រាស់ថាធម៌ គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ ជាមរតករបស់ព្រះអង្គ ។ បុគ្គលណាបួសដើម្បីប្រយោជន៍ពោធិបក្ខិយធម៌ ឈ្មោះថាជាធម្មទាយាទ (អ្នកទទួលមរតកធម៌) ។ ទ្រង់ណែនាំឱ្យបួសដើម្បីប្រយោជន៍ពោធិបក្ខិយធម៌នេះ ដូចដែលបានត្រាស់ក្នុងធម្មទាយាទសូត្រថា ៖*

" **ធម្មទាយាទា ភិក្ខវេ ភវថ, មា អាមិសទាយាទា** - *ម្នាលភិក្ខុទាំងឡាយ ចូរប្រព្រឹត្តខ្លួនជាធម្មទាយាទចុះ កុំបីជាអាមិសទាយាទឡើយ* " *ដូចនេះ ជាដើម ។*

*ចំណែកនៅក្នុង រថវិនីតសូត្រ ព្រះបុណ្ណមន្តានិត្ថេរ ត្រូវព្រះសារីបុត្តត្ថេរ សួរដល់គោលបំណង ក្នុងការបួសប្រព្រឹត្តព្រហ្មចរិយធម៌របស់លោក ក៏បានឆ្លើយថា* " **អនុបាទា បរិនិព្វានត្ថំ ខោ អាវុសោ ភគវតិ ព្រហ្មចរិយំ វុស្សតិ** - *លោកដ៏មានអាយុ ខ្ញុំព្រះករុណាបានអប់រំព្រហ្មចរិយធម៌ក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ ដើម្បីដល់អនុបាទាបរិនិព្វាន* " *ដូចនេះ ។ ចម្លើយនេះ បង្ហាញឱ្យឃើញថា អនុបាទាបរិនិព្វានជាប្រយោជន៍នៃការបួស ។*

*ព្រោះមានការពោលដល់ប្រយោជន៍ នៃការបួសខុសប្លែកគ្នាយ៉ាងនេះ ព្រះរាជា ទ្រង់មានភាពមន្ទិលសង្ស័យព្រះទ័យក្នុងរឿងនេះ ទើបបានត្រាស់សួរថា* " ***ការបួសមានប្រយោជន៍អ្វី? ហើយប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកព្រះគុណម្ចាស់គឺអ្វី?*** " *ដូចនេះ ។*

*គួរជ្រាបថា ពាក្យដែលនិយាយដល់ប្រយោជន៍នៃការបួស មានប្រការផ្សេងៗ គ្នាទាំងនេះ គ្រាន់តែជាទេសនាវោហារ ដែលសម្តែងឱ្យសមរម្យនឹងឧបនិស្ស័យនៃវេនេយ្យសត្វអ្នកត្រូវការបួស ។ ការពិតប្រយោជន៍ទាំងនោះ សុទ្ធតែរួមបញ្ចូលទៅក្នុងប្រយោជន៍តែមួយ គឺ អនុបាទាបរិនិព្វាន ។*

*ពោលគឺ ជាដំបូង ការដែលមានឱកាសបានទទួលប្រយោជន៍ប្រការនេះដោយស្រួល មានឧបសគ្គតិច កុលបុត្រគួរតែនៅក្នុងភេទជាអ្នកបួសសិន ព្រោះហេតុនោះ ទើបទ្រង់ចាត់ទុកការបួសនេះ ថាជាមរតកម៉្យាងរបស់ព្រះអង្គ ។ មុយ៉ាងវិញទៀត នៅពេលបួសរួចហើយ ក៏មិនគួរពេញចិត្តតែ*

ភាពជាអ្នកបួសប៉ុណ្ណោះ ។ នៅមានកិច្ចការដែលអ្នកបួសត្រូវធ្វើគឺ ប្រព្រឹត្ត តាមធម៌ និងវិន័យ ។

សួរថា ដើម្បីប្រយោជន៍អ្វី ? ឆ្លើយថា ដើម្បីភាពជាទាយាទទទួល មរតកដ៏ខ្ពង់ខ្ពស់បំផុត ជាងការបួសនោះ គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ ។ ពោធិបក្ខិយធម៌ ដែលបានទទួលនោះមានប្រយោជន៍អ្វី ? ឆ្លើយថា មាន ប្រយោជន៍ គឺជាហេតុធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន គឺ អនុបាទាបរិនិព្វាន នេះ ដែលមានការរំលត់ទុក្ខ ជាអានិសង្ស ។

ព្រោះហេតុនោះ ទើបព្រះថេរៈថ្វាយវិសជ្ជនា ប្រយោជន៍នៃការបួស ដល់កំពូល តែម្តងថា " **ទុក្ខនេះរលត់ទៅ ទុក្ខផ្សេងមិនកើតមាន គឺ អនុបាទា-បរិនិព្វាន ជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ពួកអាត្មាភាព** " ដូចនេះ ។

ពាក្យថា **ទុក្ខនេះរលត់ទៅ** បានសេចក្តីថា ទុក្ខនេះ គឺឧបាទានក្ខន្ធ ដែលមានក្នុងអត្តភាពបច្ចុប្បន្ននេះ សម្រាប់ព្រះអរហន្តប្រាសចាកតណ្ហា ដោយប្រការទាំងពួង គឺគ្រាន់តែជាខន្ធនៅសល់រលត់ទៅ គឺចប់ផុតទៅ វេលា ដល់គ្រាចុតិ ដោយប្រការដែលអស់ភាពជាបច្ច័យ ដល់បដិសន្ធិក្នុងភពថ្មី ។

ពាក្យថា **ទុក្ខផ្សេងមិនកើតមាន** បានសេចក្តីថា ទុក្ខផ្សេង គឺឧបាទាន-ក្ខន្ធ ដែលនឹងមានតទៅលោកខាងមុខ ក៏មិនកើតមាន ព្រោះអស់ហេតុ ។

ពាក្យថា **អនុបាទាបរិនិព្វាន** ជាដំបូងគួរជ្រាបថា ព្រះដ៏មានព្រះភាគ បានត្រាស់ហៅព្រះនិព្វានដោយវោហារ ដោយឈ្មោះផ្សេង ៗ គ្នា ដោយ សេចក្តីផ្សេង ៗ គ្នា ដូចជា មកជាគូនឹងគ្នាថា សឧបាទិសេសនិព្វាន និង អនុបាទិសេសនិព្វាន ជាដើម ។

ក្នុងបណ្តាឈ្មោះទាំងនោះ មានអត្ថាធិប្បាយថា ឧបាទានក្ខន្ធ ៥ ឈ្មោះថា ឧបាទិ ព្រោះជាអ្វីដែលតណ្ហាប្រកាន់យក ដោយភាពជាផលរបស់

ខ្ជួន ។ ឧបាទានក្ខន្ធ ៥ ដែលឈ្មោះថាឧបាទិនោះឯង ជាចំណែកនៅសល់ (ពីតណ្ហាលះបាន) ព្រោះហេតុនោះ ទើបឈ្មោះថា ឧបាទិសេស ។ ព្រះនិព្វានឈ្មោះថា សឧបាទិសេសនិព្វាន ព្រោះជាភាពរលត់ទៅ គឺ ការមិនអាចកើតឡើងទៀតបាននៃតណ្ហានោះ ដោយប្រការដែលនៅមានឧបាទិ គឺ ឧបាទានក្ខន្ធ ៥ នោះ ជាចំណែកនៅសល់ នៅឡើយ បានសេចក្តីថា ការរលត់តណ្ហារបស់ព្រះអរហន្ត ដែលនៅមានជីវិត ក្នុងអត្តភាពបច្ចុប្បន្ននេះនៅឡើយ ។

តណ្ហានោះ បើកើតឡើងរមែងកើតឡើងក្នុងឧបាទានក្ខន្ធ ៥ នោះ ដោយអំណាចនៃវិបល្លាស ថាស្អាត ថាទៀង ថាជាសុខ និងថាជាអត្តា នៅពេលរលត់អស់ទៅ ក៏រមែងតែរលត់អស់ទៅក្នុងឧបាទានក្ខន្ធ ៥ នោះឯង ដោយអំណាច នៃមគ្គភាវនា បានសេចក្តីថា ឧបាទានក្ខន្ធ ៥ ជាទីកើត និងជាទីរលត់ទៅនៃតណ្ហា ។

ប្រការនេះពិតដូចបានត្រាស់ទុកក្នុងមហាសតិប្បដ្ឋានសូត្រថា ៖

" **យំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ** –– *សភាវៈដ៏គួរឱ្យស្រឡាញ់ សភាវៈដ៏គួរឱ្យរីករាយបំផុតក្នុងលោក ( គឺក្នុងឧបាទានខន្ធ ៥ ) ណា តណ្ហានេះ នៅពេលកើតឡើង រមែងកើតឡើងក្នុងសភាវៈដ៏គួរឱ្យស្រឡាញ់ សភាវៈដ៏គួរឱ្យរីករាយនេះ* " ដូចនេះ និងថា ៖

" **យំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ** - *សភាវៈដ៏គួរឱ្យស្រឡាញ់ សភាវៈដ៏គួរឱ្យរីករាយក្នុងលោកណា តណ្ហានេះនៅពេលត្រូវលះទៅ រមែងត្រូវលះទៅ ក្នុង*

***សភាវៈដ៏គួរឱ្យស្រឡាញ់ ដ៏គួរឱ្យរីករាយនេះ, នៅពេលរលត់ទៅ រមែងត្រូវរលត់ទៅ ក្នុងសភាវៈដ៏គួរឱ្យស្រឡាញ់ ដ៏គួរឱ្យរីករាយនេះ*** ” ដូចនេះ ។ នៅពេលជាទីរលត់ទៅនៃតណ្ហា ជាទីលះឱ្យអស់ទៅ ក៏ឈ្មោះថាជា និព្វាន ។

*ចំណែកពាក្យថា **សឧបាទិសេសនិព្វាន** បានសេចក្តីថា ព្រះនិព្វានដែលប្រព្រឹត្តទៅជាមួយឧបាទិ គឺ ឧបាទានក្ខន្ធ ៥ នៅសល់ ដែលនឹងអស់ទៅពេលព្រះអរហន្តដល់គ្រាចុតិ ដោយប្រការដែលឧបាទិនោះ ជាទីរំលត់តណ្ហា ។ បើដូចនេះ សឧបាទិសេសនិព្វាននោះ ទើបមានទាក់ទងនឹងឧបាទានក្ខន្ធ ៥ ជាឧបាទានក្ខន្ធ ៥ មានក្នុងភពនេះ ដែលនៅប្រើប្រាស់វានោះ និងបើរាប់បញ្ចូលក្នុងឧបាទានក្ខន្ធ ក៏រមែងចាត់ចូលក្នុងទុក្ខសច្ចៈ ។*

*ចំណែក **អនុបាទិសេសនិព្វាន** ប្រែថា ព្រះនិព្វានដែលគ្មានឧបាទិនៅសល់ បានសេចក្តីថា នៅពេលព្រះអរហន្តចុតិក៏គ្មានឧបាទិ គឺឧបាទានក្ខន្ធ ៥ នោះនៅសល់ទៀតឡើយ ពោលគឺ មិនមាននៅសល់បន្តទៅភពខាងមុខទៀត ។ ព្រោះហេតុនោះ អនុបាទិសេសនិព្វាន ទើបសំដៅយកឧបាទានក្ខន្ធ ៥ ដែលនឹងមានតទៅក្នុងអនាគត គឺក្នុងភពខាងមុខ ប៉ុន្តែមិនអាចកើតមានបាន ព្រោះមគ្គភាវនាបានដល់នូវសេចក្តីបរិបូរពេញលេញហើយ ដោយប្រការទាំងពួង ។ ដូចនេះ ព្រះនិព្វាននឹងបានឈ្មោះ បានបញ្ញត្តិ បានសមញ្ញា បានវោហារថា អនុបាទិសេសនិព្វាន ក៏នៅពេលមានការសម្ងំទៅខន្ធក្នុងភពខាងមុខនោះឯង ។ បើដូចនេះ សូម្បីតែអនុបាទិសេសនិព្វាននេះ ក៏មានការរាប់បញ្ចូលទៅក្នុងឧបាទានក្ខន្ធ ៥ នោះដែរ ។ នៅពេលរាប់ចូលក្នុងឧបាទានក្ខន្ធ ៥ ក៏រមែងចាត់ចូលក្នុងទុក្ខសច្ចៈនោះដែរ ។*

*ឧបាទិសេសនិព្វាន និង អនុបាទិសេសនិព្វាន ដែលមកជាគូនឹងគ្នានេះ ជាការចែកព្រះនិព្វានដោយបរិយាយ គឺដោយហេតុ នោះគឺតណ្ហានិង*

*ឧបាទានក្ខន្ធនោះឯង ទើបមិនមែនជា អសង្ខតធម៌ (ធម៌ដែលមិនមានបច្ច័យផ្គុំគ្នាសាងឡើង) មិនមែនជា អមតធាតុ (ធាតុដែលមិនស្លាប់ មិនដល់ភាពរលត់ទៅ) មិនអាចចាត់ចូលក្នុងនិរោធសច្ចៈបានទេ ។*

*ចំណែកពាក្យថា **អនុបាទាបរិនិព្វាន** ដែលមានក្នុងបញ្ហានេះ និងក្នុងរថវិនីតសូត្រ ជាដើម មានអត្ថាធិប្បាយថា ព្រះនិព្វានដែលជាអសង្ខតធម៌ ដែលមិនរាប់បញ្ចូលក្នុងខន្ធ ៥ នេះ (ដែលជាសង្ខតធម៌) ជាអមតធាតុ (មិនរាប់បញ្ចូលក្នុងធាតុទាំងឡាយដែលកើតឡើង រួចក៏ដល់ទីរលត់ទៅ) និងជាអារម្មណ៍នៃមគ្គនិងផល ។*

*ឈ្មោះថា **អនុបាទា** ព្រោះសេចក្តីថា រកបច្ច័យធ្វើឱ្យកើតឡើងមិនបាន និងឈ្មោះថា **បរិនិព្វាន** ព្រោះសេចក្តីថា អ្នកណាបានសម្រេចដល់និព្វាន កិលេសរបស់អ្នកនោះ ក៏ដល់ទីរលត់ទៅ ។ ព្រោះហេតុនោះ ទើបបានឈ្មោះរួមបញ្ចូលគ្នាថា អនុបាទាបរិនិព្វាន ។ អនុបាទាបរិនិព្វាននេះ ចាត់ចូលក្នុងនិរោធសច្ចៈ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៥*

# បញ្ហាទី ៦ - បដិសន្ធិប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន អ្នកខ្លះស្លាប់ហើយមិនបដិសន្ធិ (មិនកើតទៀត) មានដែរឬទេ ? "*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា " អ្នកខ្លះបដិសន្ធិ អ្នកខ្លះមិនបដិសន្ធិ "*

**ព្រះចៅមិលិន្ទ ៖** *" នរណាបដិសន្ធិ ? នរណាមិនបដិសន្ធិ ? "*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ អ្នកមានកិលេសបដិសន្ធិ អ្នកគ្មានកិលេសមិនបដិសន្ធិ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន ខ្លួនលោកម្ចាស់នឹងបដិសន្ធិដែរឬទេ?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ប្រសិនបើអាត្មាភាពជាមនុស្សមានឧបាទាន អាត្មាភាពក៏នឹងបដិសន្ធិ ប្រសិនបើអាត្មាភាពជាមនុស្សគ្មានឧបាទាន អាត្មាភាពក៏នឹងមិនបដិសន្ធិ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ"* ៕

*ចប់បដិសន្ធិប្បញ្ហាទី ៦*

## ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*ពាក្យថា* ***បដិសន្ធិប្បញ្ហា*** *គឺ បញ្ហាដែលទាក់ទងនឹងបដិសន្ធិ ។*

*ពាក្យថា* ***អ្នកមានឧបាទាន*** *គឺ អ្នកមានបច្ច័យ (បានដល់កិលេសនោះឯង) ។ ពាក្យថា* ***អ្នកគ្មានឧបាទាន*** *គឺ អ្នកគ្មានបច្ច័យ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៦*

# បញ្ហាទី ៧ - យោនិសោមនសិការប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា* ៖ " *ព្រះគុណម្ចាស់នាគសេន បុគ្គលណាមិនបដិសន្ធិ បុគ្គលនោះរមែងមិនបដិសន្ធិ ព្រោះមានយោនិសោមនសិការមែនឬទេ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរមហាបពិត្រ បុគ្គលរមែងមិនបដិសន្ធិ ព្រោះមានយោនិសោមនសិការ ព្រោះមានបញ្ញា និង ព្រោះមានកុសលធម៌ទាំងឡាយផ្សេងទៀត* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ យោនិសោមនសិការនោះ ជាបញ្ញាមិនជាអ៊ីចឹង ឬ?* "

**ព្រះនាគសេន ៖** " *មិនមែនទេ សូមថ្វាយព្រះពរ (យោនិសោ)មនសិការផ្សេង បញ្ញាផ្សេង ។ សូមថ្វាយព្រះពរ សូម្បីពួកសត្វទាំងនេះ គឺ ពពែ ចៀម គោ ក្របី អូដ្ឋ លា ក៏មាន (យោនិសោ)មនសិការដែរ ប៉ុន្តែសត្វទាំងនោះ ពុំមានបញ្ញាទេ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ។

*ចប់យោនិសោមនសិការបញ្ហាទី ៧*

# ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*ពាក្យថា* ***យោនិសោមនសិការបញ្ហា*** *ប្រែថា បញ្ហាទាក់ទងនឹងយោនិសោមនសិការ ។*

*ពាក្យថា* ***យោនិសោមនសិការ*** *ប្រាកដមាននៅច្រើនកន្លែង ដូចជាក្នុងបេដកោបទេសប្បករណ៍ ដែលថា* " **បរតោ ច ឃោសោ សច្ចានុសន្ធិ, អជ្ឈត្តញ្ច យោនិសោមនសិការោ** [១]- *បរតោឃោសៈ ( ពាក្យពោលប្រាប់ពីអ្នកដទៃ ) ដែលអនុលោមចំពោះសច្ចៈ និង យោនិសោមនសិការក្នុងខ្លួន* " *ដូចនេះ ជាដើម ។*

*ពាក្យថា **យោនិសោ** ប្រែថា ដោយត្រូវឧបាយ គឺ ត្រូវផ្លូវ ត្រូវឱកាស ។*

*ពាក្យថា **មនសិការ** ប្រែថា ការធ្វើទុកក្នុងចិត្ត ។*

*ការធ្វើទុក្ខក្នុងចិត្តដោយត្រូវឧបាយ ហៅថា យោនិសោមនសិការ បានសេចក្ដីថា គឺ ផ្ដោតចិត្តទៅកាន់អារម្មណ៍ ចំពោះកន្លែងដែលគួរចាប់អារម្មណ៍ ជាអារម្មណ៍ ដែលផ្ដោតចិត្តហើយ ជាហេតុឱ្យកើតចំណេះដឹងបានក្នុងពេលនោះ ដោយមិនបណ្ដោយចិត្តឱ្យផ្សាកទៅរកអារម្មណ៍ផ្សេង ៗ ជាច្រើន នៅខាងក្រៅ ។*

*យោនិសោមនសិការនេះ មិនមែនជាវិបស្សនាបញ្ញា ហើយក៏មិនមែនមគ្គបញ្ញា ព្រោះហេតុនោះ ព្រះថេរៈគ្រាបដិសេធថា " មិនមែនទេ សូមថ្វាយព្រះពរ " ដូចនេះហើយ ទើបថ្វាយវិសជ្ជនាបន្តថា " យោនិសោមនសិការ ថ្វាយព្រះពរ សូម្បីពួកសត្វទាំងនេះ ... ប៉ុន្តែសត្វទាំងនោះ ពុំមានបញ្ញាទេ " ដូចនេះ ។ ដើម្បីភាពជាក់ច្បាស់ នៃសេចក្ដីដែលថា សត្វតិរច្ឆានក៏មានយោនិសោមនសិការបាន តែមិនអាចមានបញ្ញា (គឺ វិបស្សនាបញ្ញានិងមគ្គបញ្ញា ) បាននេះ បណ្ឌិតគួរពិចារណាពីរឿងសត្វសេកដែលភិក្ខុនីបានចិញ្ចឹម និងបង្រៀនឱ្យមនសិការកម្មដ្ឋាន ថា " **អដ្ឋិ អដ្ឋិ** " - "ឆ្អឹង ឆ្អឹង" ជារៀងរាល់ថ្ងៃ ។*

*ថ្ងៃមួយត្រូវខ្លែងប្រើក្រញាំជើងចាប់យកទៅ ទោះជាមនសិការថាឆ្អឹងៗ កើតចំណេះដឹងការយល់ឃើញថា " មានតែគំនរឆ្អឹង គំនរឆ្អឹងត្រូវគំនរឆ្អឹងចាប់យកទៅ " ដូចនេះ ក៏មិនអាចបន្តចំណេះដឹងការយល់ឃើញនោះ រហូតជាបច្ច័យដល់វិបស្សនាបញ្ញានិងមគ្គបញ្ញាបាន តាមដែលលោកបានពោលទុកក្នុងអដ្ឋកថាមហាសតិប្បដ្ឋានសូត្រទៅចុះ ។*

---

(១) *បេដកោបទេស ១ ។*

*គួរជ្រាបថា សម្រាប់សត្វតិរច្ឆានទាំងឡាយនោះ ទោះជាលោកពោលថា គ្មានបញ្ញា មិនមែនសំដៅលើបញ្ញាគ្រប់យ៉ាងនោះទេ ។ សំដៅតែចំពោះវិបស្សនាបញ្ញា និងមគ្គបញ្ញា ( រួមទាំងបញ្ញាផ្សេងទៀតដែលជាផល ជាអានិសង្សនៃវិបស្សនាបញ្ញា ឬមគ្គបញ្ញា ) ប៉ុណ្ណោះ ។ ព្រោះថា បញ្ញាដែលទាបជាងនោះ សត្វតិរច្ឆានក៏អាចធ្វើឱ្យកើតឡើងបាន ដោយអាស្រ័យយោនិសោមនសិការ ដែលអាចមានទៅបាននោះជាបច្ច័យ ។ យោនិសោ-មនសិការមិនមែនជាបញ្ញា ជាសភាវធម៌ផ្សេងគ្នាពីបញ្ញា គ្រាន់តែជាហេតុគ្រាន់តែជាបច្ច័យនៃបញ្ញា ប៉ុណ្ណោះ ។*

*ប្រការនេះ ពិតដូចដែលត្រាស់ទុកថា "* **នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ, យេន អនុប្បន្នា វា សម្មាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា វា សម្មាទិដ្ឋិ បវឌ្ឍតិ យថយិទំ ភិក្ខវេ យោនិសោមនសិការោ** [១] *- ម្នាល ... មិនឃើញធម៌ណាផ្សេងសូម្បីតែម៉្យាង ដែលជាហេតុឱ្យសម្មាទិដ្ឋិមិនទាន់កើត ឱ្យកើតឡើង ឬសម្មាទិដ្ឋិដែលកើតឡើងហើយបានចម្រើនឡើង ដូចយោនិសោមនសិការនេះណា ភិក្ខុទាំងឡាយ " ដូចនេះ ។ ពាក្យថា " សម្មាទិដ្ឋិ " ដែលបានត្រាស់ទុកក្នុងសូត្រនេះ គឺវិបស្សនាសម្មាទិដ្ឋិ ( សម្មាទិដ្ឋិដែលជាវិបស្សនាបញ្ញា ) និង មគ្គសម្មាទិដ្ឋិ ( សម្មាទិដ្ឋិដែលជាមគ្គបញ្ញា ) នោះឯង ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - មនសិការលក្ខណបញ្ហា

[១] *អង្គុត្តរនិកាយ ឯកនិបាត ។*

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន មនសិការមានអ្វីជាលក្ខណៈ? បញ្ញាមានអ្វីជាលក្ខណៈ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ មនសិការមានការចាប់ទុកជាលក្ខណៈ បញ្ញាមានការកាត់ជាលក្ខណៈ"

**ព្រះចៅមិលិន្ទ ៖** " មនសិការមានការចាប់ទុកជាលក្ខណៈយ៉ាងដូចម្ដេច? បញ្ញាមានការកាត់ជាលក្ខណៈយ៉ាងដូចម្ដេច? សូមព្រះគុណម្ចាស់ធ្វើការឧបមា"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់ស្គាល់អ្នកច្រូតស្រូវដែរឬទេ?"

**ព្រះចៅមិលិន្ទ ៖** " មែនហើយ ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាស្គាល់"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ពួកអ្នកច្រូតស្រូវ គេច្រូតស្រូវយ៉ាងដូចម្ដេច?"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ពួកគេប្រើដៃឆ្វេងចាប់ក្ដាប់ដើមស្រូវ ប្រើដៃស្ដាំកាន់កណ្ដៀវ កាត់ដើមស្រូវដោយកណ្ដៀវ"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ពួកអ្នកច្រូតស្រូវប្រើដៃឆ្វេងចាប់ក្ដាប់ដើមស្រូវ ប្រើដៃស្ដាំកាន់កណ្ដៀវកាត់ដើមស្រូវយ៉ាងណា សូមថ្វាយព្រះពរ ព្រះយោគាវចររមែងប្រើមនសិការចាប់ចិត្តទុក រួចប្រើបញ្ញាកាត់កិលេសទាំងឡាយដូចនេះ សូមថ្វាយព្រះពរ មនសិការមានការចាប់ទុកជាលក្ខណៈ បញ្ញាមានការកាត់ជាលក្ខណៈ តាមប្រការដូចបានពោលមកនេះ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។

ចប់មនសិការលក្ខណបញ្ហាទី ៨

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*ពាក្យថា **មនសិការលក្ខណាបញ្ហា** ប្រែថា បញ្ហាទាក់ទងនឹងលក្ខណៈរបស់មនសិការ ។*

*នៅពេលព្រះថេរមិលិន្ទ ទ្រង់ទទួលស្គាល់ថា យោនិសោមនសិការជាសភាវធម៌ផ្សេងគ្នាពីបញ្ញា ទ្រង់ក៏មានបំណងចង់ជ្រាបតទៅទៀតថា ធម៌ទាំងពីរនេះ មានលក្ខណៈដោយឡែកផ្សេងគ្នាយ៉ាងដូចម្ដេច ទើបត្រាស់សួរថា " **ព្រះគុណម្ចាស់នាគសេន មនសិការមានអ្វីជាលក្ខណៈ** " ដូចនេះ ជាដើម ។*

*ក្នុងពាក្យវិសជ្ជនានោះ ពាក្យថា **ឩហនលក្ខណោ** ប្រែថាមានការចាប់ទុកជាលក្ខណៈ ។ អធិប្បាយថា លក្ខណៈចាប់កាន់របស់មនសិការ នឹងថាដូចលក្ខណៈចាប់កាន់អារម្មណ៍របស់វិតក្ក គឺលើកចិត្តឡើងទៅកាន់អារម្មណ៍ក៏មិនមែន ។*

*ប៉ុន្តែ ព្រះយោគាវចរប្រើមនសិការ ចាប់កាន់ចិត្តទុកឱ្យនៅដឹងអារម្មណ៍ (អារម្មណ៍កម្មដ្ឋាន) ។ នៅពេលចិត្តនោះនៅតាមដឹងអារម្មណ៍នៅឡើយ ក៏រមែងកាត់កិលេសទាំងឡាយ បានដោយវិបស្សនាបញ្ញា និង មគ្គបញ្ញាតាមលំដាប់ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - សីលលក្ខណាបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន ប៉ុន្តែលោកម្ចាស់ពោលពាក្យនេះថា "និងព្រោះមានកុសលធម៌ទាំងឡាយផ្សេងទៀត" កុសលធម៌ទាំងនោះ មានអ្វីខ្លះ ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ សីល សទ្ធា វីរិយៈ សតិ សមាធិ ធម៌ទាំងនេះហៅថា កុសលធម៌ទាំងនោះ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ សីលមានអ្វីជាលក្ខណៈ ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ សីលមានភាពជាទីតាំងជាលក្ខណៈ គឺសីលជាទីតាំងនៃកុសលធម៌ទាំងឡាយទាំងពួង នោះគឺ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អង្គមគ្គ សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឈាន វិមោក្ខ សមាធិ សមាបត្តិ ។ សូមថ្វាយព្រះពរ ព្រះយោគាវចរ ដែលតាំងក្នុងសីល អាស្រ័យសីល តាំងស៊ប់ក្នុងសីលហើយ រមែងចម្រើនឥន្ទ្រិយទាំង ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយបាន កុសលធម៌ទាំងឡាយទាំងពួង រមែងមិនចុះខ្សោយនោះទេ"

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ ធ្វើការឧបមា"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរមហាបពិត្រ ប្រៀបដូចជា រុក្ខជាតិដើមឈើណាមួយ រមែងដុះរីកលូតលាស់បរិបូរ រុក្ខជាតិដើមឈើទាំងនោះសុទ្ធតែអាស្រ័យផែនដីតាំងនៅលើផែនដីហើយ ក៏រមែងដល់នូវភាពរីកលូតលាស់បរិបូរបាន យ៉ាងណា ។ សូមថ្វាយព្រះពរ ព្រះយោគាវចរអាស្រ័យសីល តាំងក្នុងសីលហើយ រមែងចម្រើនឥន្ទ្រិយទាំង ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយបាន យ៉ាងនោះដែរ"

**ព្រះចៅមិលិន្ទ ៖** "សូមព្រះគុណម្ចាស់ធ្វើការឧបមាបន្តិចទៀតផងចុះ"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា អ្នកទាំងឡាយ ដែលត្រូវធ្វើការងារដោយកម្លាំង អ្នកទាំងនោះអាស្រ័យផែនដី តាំងនៅលើផែនដីហើយ រមែងធ្វើការងារទាំងនោះបានយ៉ាងណា ។ សូមថ្វាយព្រះពរ ព្រះយោគាវចរ អាស្រ័យសីលតាំងក្នុងសីលហើយ រមែងចម្រើនឥន្ទ្រិយទាំង ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិ-ន្ទ្រិយបាន យ៉ាងនោះដែរ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមាឱ្យកាន់តែច្រើនបន្តិចទៀត* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា ជាងសំណង់ក្រុង ត្រូវការសាងសង់ទីក្រុង ដំបូងឱ្យគេជម្រះសម្អាតទីតាំងក្រុង ជម្រះកាប់គាស់ គល់ឈើនិងបន្លាចេញ ពង្រាបដីឱ្យរាបស្មើ បន្ទាប់ពីនោះក៏កាត់ចំណែកបែងចែក ជាផ្លូវថ្នល់ ផ្លូវបំបែកជាបួន ជាដើម សាងចេញជាក្រុងយ៉ាងណា ។ សូមថ្វាយព្រះពរ ព្រះយោគាវចរអាស្រ័យសីល តាំងក្នុងសីលហើយ រមែងចម្រើនឥន្ទ្រិយទាំង ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយបាន យ៉ាងនោះដែរ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ឧបមាឱ្យច្បាស់ថែមទៀត* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាអ្នកសម្តែងសិល្បៈកាយ ត្រូវការសម្តែងសិល្បៈ ក៏រមែងឱ្យគេជម្រះផ្ទៃដី កម្ចាត់ដុំក្រួស ដុំឥដ្ឋ ចេញយ៉ាងណា ។ សូមថ្វាយព្រះពរ ព្រះយោគាវចរអាស្រ័យសីល តាំងក្នុងសីលហើយ រមែងចម្រើនឥន្ទ្រិយទាំង ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិ-យ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយបាន យ៉ាងនោះដែរ ។*

*សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្តីនេះថា ៖*

**សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបិ និបកោ ភិក្ខុ សោ ឥមំ វិជ្ជយេ ជដំ** [១]

*ប្រែថា ៖ នរៈអ្នកមានបញ្ញា តាំងក្នុងសីលហើយ ចម្រើនចិត្ត និង បញ្ញា ជាអ្នកមានសេចក្តីព្យាយាម មានភាពវៃឆ្លាត ជាភិក្ខុ អ្នកនោះនឹងអាចជម្រះបណ្តាញចាក់ស្រេះ (គឺតណ្ហា) នេះបាន ។*

*ដូចនេះ ។*

*ម្យ៉ាងទៀត សីល គឺជាឫសគល់នៃសេចក្តីចម្រើនបំផុតរបស់កុសលធម៌ទាំងឡាយ ។ ប្រៀបដូចធរណីនេះ គឺជាទីតាំងនៃសត្វទាំងឡាយ ។ ដូចនេះ ក្នុងព្រះសាសនារបស់ព្រះជិនវរពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ក៏មានសីលនេះជាប្រធាន គឺ កងសីលដែលមានព្រះបាដិមោក្ខ ដ៏ប្រសើរ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់សីលលក្ខណប្បញ្ហាទី ៩*

---

[១] *សំយុត្តនិកាយ សគាថវគ្គ ។*

**ទ ៖**

*បញ្ហាទាក់ទងនឹងលក្ខណៈរបស់សីល ឈ្មោះថា* ***សីលលក្ខណប្បញ្ហា*** *( មិលិន្ទប្បញ្ហារបស់ថៃជា សីលបតិដ្ឋានលក្ខណប្បញ្ហា ) ។*

*សីលសំវរៈ ៤ យ៉ាង គឺ បាដិមោក្ខសំវរសីល ( សីលដែលជាសេចក្តីសង្រួមក្នុងបាដិមោក្ខ) មានដូចជា សីលក្នុងសិក្ខាបទទាំងឡាយ ១ ឥន្ទ្រិយសំវរសីល ( សីលដែលជាសេចក្តីសង្រួមឥន្ទ្រិយ ៦ មានភ្នែក... ជាដើម ) ១ ,*

*អាជីវបរិសុទ្ធសីល ( សីលដែលជាភាពបរិសុទ្ធក្នុងអាជីព ) ១ , បច្ចយសន្និស្សិតសីល ( សីលអាស្រ័យបច្ច័យ គឺការពិចារណាបច្ច័យមុនប្រើប្រាស់ ) ១ ឈ្មោះថា **សីល** ដែលសំដៅយកក្នុងបញ្ហានេះ ។*

*តទៅនេះ ជាអត្ថាធិប្បាយស្ដីអំពីពាក្យថា " **ឥន្ទ្រិយ** " ជាដើម ។*

**ធម៌ ៥ យ៉ាង** *មានសទ្ធា ជាដើម ឈ្មោះថា* **ឥន្ទ្រិយ** *ដោយសេចក្ដីថា ជាធំ ពោលគឺញ៉ាំងឱ្យធម៌ទាំងឡាយឱ្យដំណើរទៅ ស្របតាមអំណាចរបស់ខ្លួន នៅពេលខ្លួន ចាស់ក្លាក៏ឱ្យចាស់ក្លាតាម នៅពេលខ្លួនមិនទាន់ចាស់ក្លាក៏ឱ្យមិនទាន់ចាស់ក្លាតាម ។*

***សទ្ធា*** *(ការជឿ ជំនឿ ភាពជ្រះថ្លា) នៅពេលកើតឡើង រមែងមានភាពជាធំក្នុង លក្ខណៈលំឱនចិត្តជឿរបស់ខ្លួន ទាក់ទងនឹងធម៌ទាំងឡាយ ដែលកើតរួមគ្នាជាមួយខ្លួនមាន ផស្សៈ វិតក្ក វិចារ មនសិការ ជាដើម រួមទាំងឥន្ទ្រិយដែលនៅសល់ ឱ្យលំឱនទៅតាមដោយស្រួល ឈោងទៅតាមដោយស្រួលទៅកាន់អារម្មណ៍ដែលខ្លួនលំឱនចិត្តជឿ បីដូចជារួមលំឱនចិត្តជឿទៅជាមួយខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថាជាឥន្ទ្រិយ ហៅថា* ***សទ្ធិន្ទ្រិយ*** *។*

*ចំណែក* ***វិរិយៈ*** *(សេចក្ដីព្យាយាម) នៅពេលកើតឡើង រមែងមានភាពជាធំក្នុង លក្ខណៈត្រកង គឺ ទ្រទ្រង់ធម៌ទាំងឡាយ ដែលកើតរួមជាមួយខ្លួនឱ្យប្រព្រឹត្តទៅ ក្នុងអារម្មណ៍នោះជាញឹកញយបន្តបន្ទាប់មិនបោះបង់ចោល។ ធម៌ទាំងឡាយ ដែលវិរិយៈចាំត្រកងទុកយ៉ាងនេះ ក៏រមែងស្ទុះស្ទាក្នុងកិច្ចរបស់ខ្លួន ក្នុងអារម្មណ៍នោះ មិនរួញរា មិនបោះបង់ចោល តាមអំណាចនៃវិរិយៈ ព្រោះហេតុនោះទើបឈ្មោះថា ជាឥន្ទ្រិយ ហៅថា* ***វិរិយិន្ទ្រិយ*** *។*

***សតិ*** *(ការរឭកបាន) នៅពេលកើតឡើង រមែងមានភាពជាធំក្នុងលក្ខណៈ ដែលចូលទៅតាំងក្នុងអារម្មណ៍ ។ ធម៌ទាំងឡាយដែលកើតរួម*

*ជាមួយសតិ រមែងស្របទៅតាមអំណាចរបស់សតិ គឺ រមែងត្រូវសតិធ្វើឱ្យចូលទៅតាំងក្នុងអារម្មណ៍ ដែលសតិចូលទៅតាំងនោះ ។ ព្រោះហេតុនោះ ទើបឈ្មោះថាជាឥន្ទ្រិយ ហៅថា* ***សតិន្ទ្រិយ*** *។*

***សមាធិ*** *(ការតាំងមាំជានិច្ចក្នុងអារម្មណ៍តែមួយនៃចិត្ត ) នៅពេលកើតឡើង រមែងមានភាពជាធំក្នុងលក្ខណៈមិនស្រមើស្រមៃរាយមាយ ។ ធម៌ទាំងឡាយ ដែលកើតរួមជាមួយសមាធិ រមែងស្របទៅតាមអំណាចនៃសមាធិ គឺរមែងតាំងមាំក្នុងអារម្មណ៍តែមួយជាមួយសមាធិ ដែលតាំងមាំនៅក្នុងអារម្មណ៍នោះ មិនស្រមើស្រមៃរាយមាយ គឺមិនងាករេទៅរកអារម្មណ៍ផ្សេង ព្រោះហេតុនោះ ទើបឈ្មោះ ថាជាឥន្ទ្រិយ ហៅថា* ***សមាធិន្ទ្រិយ*** *។*

*បើលើកលែង* ***បញ្ញា*** *ចេញ ការបានចាក់ធ្លុះសច្ចធម៌ តាមសភាវៈពិតមិនអាចកើតឡើងឡើយ ។ នៅពេលបញ្ញាកើតឡើង មកចាក់ធ្លុះសច្ចធម៌តាមសភាវៈពិតនោះ ធម៌ទាំងឡាយដែលកើតជាមួយគ្នា រមែងដំណើរទៅដោយស្រួល ក្នុងអារម្មណ៍ដោយឡែក ដែលមានប្រយោជន៍ចំពោះបញ្ញានឹងបានកើតឡើងមក ឃើញតាមសភាវៈពិត ប៉ុណ្ណោះ ។ ពោល គឺ ផស្សៈចាំទង្គិចអារម្មណ៍នោះ មិនទង្គិចអារម្មណ៍ផ្សេង ដែលមិនមានប្រយោជន៍ដល់បញ្ញា ។ វិតក្ក ក៏ចាំលើកចិត្តឡើងទៅកាន់អារម្មណ៍នោះ វិចារ ក៏ចាំតែតាមត្រកងអារម្មណ៍នោះ សទ្ធាក៏លំឱនចិត្តជឿចំពោះអារម្មណ៍នោះ យ៉ាងនេះជាដើម ។ ធម៌ដែលកើតរួមជាមួយបញ្ញាទាំងនោះ នៅពេលមានដំណើរទៅយ៉ាងនេះ ក៏ឈ្មោះថា ដំណើរទៅតាមអំណាចនៃបញ្ញា ដូចអ្នកបម្រើចាំបង្កលក្ខណៈងាយស្រួល ចាំស្នងប្រយោជន៍ដល់ចៅហ្វាយនាយដូចនេះ ដែរ ព្រោះហេតុនោះ ទើបបញ្ញាឈ្មោះថាជា ឥន្ទ្រិយ ហៅថា* ***បញ្ញិន្ទ្រិយ*** *។ ធម៌ទាំង ៥ យ៉ាងនេះ មានសទ្ធាជាដើម ឈ្មោះថា ជាឥន្ទ្រិយ តាមអត្ថន័យដូច*

ប្រការខាងលើ ។

***ធម៌ទាំង ៥ យ៉ាង*** មានសទ្ធាជាដើម ទាំងនោះ ពេលមានកម្លាំងឡើងមក ធម៌ទាំងឡាយដែលជាបដិបក្ខ ក៏មិនអាចធ្វើឱ្យរំជួលបាន គឺ មិនអាចធ្វើឱ្យវិនាស ឬ ប្រែប្រួលបាន លោកហៅថា **ពលះ** សេចក្ដីថា ៖

***សទ្ធា*** ពេលមានកម្លាំងក៏រមែងជាធម្មជាតិដែលអស្សទ្ធិយៈ ( ភាពជាអ្នកគ្មានសទ្ធា គឺ អកុសលធម៌ទាំងឡាយដែលជាបដិបក្ខចំពោះសទ្ធា ) មិនអាចធ្វើឱ្យរង្គោះរង្គើបាន ព្រោះហេតុនោះ ទើបហៅថា ***សទ្ធាពលៈ*** ។

***វីរិយៈ*** ពេលមានកម្លាំងក៏រមែងជាធម្មជាតិដែលកោសជ្ជៈ ( ភាពខ្ជិលច្រអូស ) មិនអាចធ្វើឱ្យរង្គោះរង្គើបាន ព្រោះហេតុនោះទើបហៅថា ***វីរិយ-ពលៈ*** ។

***សតិ*** ពេលមានកម្លាំង រមែងជាធម្មជាតិដែលមុដ្ឋសច្ចៈ (ភាពវង្វេងភ្លេចស្មារតី គឺ អកុសលធម៌ទាំងឡាយ កើតឡើងគ្របដណ្ដប់ចិត្តហើយ ក៏ធ្វើឱ្យមានភាពវង្វេង ភ្លេចភ្លាំង ) មិនអាចធ្វើឱ្យរង្គោះរង្គើបាន ព្រោះហេតុនោះទើបហៅថា ***សតិពលៈ*** ។

***សមាធិ*** ពេលមានកម្លាំង ក៏រមែងជាធម្មជាតិដែលការស្រមើស្រមៃរាយមាយ មិនអាចធ្វើឱ្យរង្គោះរង្គើបាន ព្រោះហេតុនោះ ទើបហៅថា ***សមាធិពលៈ*** ។

***បញ្ញា*** ពេលមានកម្លាំង ក៏រមែងជាធម្មជាតិ ដែលអវិជ្ជា (ការមិនដឹង ) មិនអាចធ្វើឱ្យរង្គោះរង្គើបាន ព្រោះហេតុនោះទើបហៅថា ***បញ្ញាពលៈ*** ។

ធម្មជាតិ ៥ យ៉ាង មានសទ្ធា ជាដើម ឈ្មោះថា ពលៈ តាមអត្ថន័យដូចប្រការខាងលើ ។

**ធម៌ ៧ យ៉ាង** ពោល គឺ សតិ ១, ធម្មវិចយៈ ( បញ្ញាដែលវិភាគធម៌ គឺ

វិបស្សនាបញ្ញា ) ១ , វិរិយៈ ១ , បីតិ ( ភាពស្រស់បស់នៃចិត្តដែលកើតរួមជាមួយវិបស្សនាចិត្ត ) ១, បស្សទ្ធិ (ភាពស្ងប់ពីនីវរណៈនៃចិត្ត ) ១, សមាធិ ១, ឧបេក្ខា ( ការដាក់ចិត្តជាព្រងើយ គឺ ភាពជាកណ្តាល មិនរីករាយ ឬ ខឹង-សម្បាក្នុងអារម្មណ៍ ) ១, ឈ្មោះថា **ពោជ្ឈង្គ** ។ ព្រោះជាអង្គ គឺជាអង្គប្រកបជាសម្ភារៈនៃពោធិ (ការត្រាស់ដឹង ) នោះគឺ ព្រះអរិយមគ្គមានអង្គ ៨ ជាដំពូកធម៌ដែលព្រះយោគាវចរ ត្រូវធ្វើឱ្យពេញ ឱ្យបរិបូរ ដើម្បីការកើតឡើងនៃព្រះអរិយមគ្គមានអង្គ ៨ ព្រោះហេតុនោះ ទើបហៅថា សតិសម្ពោជ្ឈង្គៈ វិរិយសម្ពោជ្ឈង្គៈ ជាដើម ។

ចំណែក **ធម៌ ៨ យ៉ាង** គឺ សម្មាទិដ្ឋិ ។ល។ សម្មាសមាធិ ឈ្មោះថា **អដ្ឋមគ្គ** ព្រោះមានអត្ថន័យថា អង្គប្រកបដែលជាផ្លូវ គឺជាឧបាយសម្រេចព្រះនិព្វាន ។

ចំណែក **សតិ** ដែលព្រះយោគាវចរ ធ្វើឱ្យចូលទៅតាំងនៅនឹងធម៌ ៤ យ៉ាង គឺ កាយ វេទនា ចិត្ត និង ធម៌ ដែលប្រព្រឹត្តទៅ ដើម្បីលះវិបល្លាស (ការយល់ឃើញច្រឡំខុសពីការពិត) ៤ យ៉ាង គឺ សុភវិបល្លាស (ការយល់ច្រឡំថាស្អាត), សុខវិបល្លាស (ការយល់ច្រឡំថា សុខ), និច្ចវិបល្លាស (ការយល់ច្រឡំថា ទៀងបិតថេរ), អត្តវិបល្លាស (ការយល់ច្រឡំថា ជាអត្តាខ្លួន) ក្នុងកាយដែលមិនស្អាតជាដើម ហៅថា សតិប្បដ្ឋាន ។ រាប់ថាមាន ៤ យ៉ាង មានកាយានុបស្សនាសតិប្បដ្ឋាន ជាដើម ក៏ព្រោះហេតុចូលទៅតាំងនៅក្នុងអារម្មណ៍ ៤ យ៉ាងគឺ កាយ វេទនា ចិត្ត និងធម៌នោះឯង ។

**វិរិយៈ** ដែលប្រព្រឹត្ត ទៅក្នុងកិច្ច ៤ យ៉ាង ពោលគឺ ៖

- ព្យាយាមលះអកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ។
- ព្យាយាមការពារអកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើងមិន

ឱ្យកើតឡើង។

- ព្យាយាមធ្វើកុសលធម៌ទាំងឡាយ ដែលមិនទាន់កើត ឱ្យកើតឡើង ។

- ព្យាយាមធ្វើកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឱ្យតាំងនៅបាន ឱ្យរឹតតែចម្រើនឡើង ៗ ។

លោកហៅថា សម្មប្បធាន ដែលហៅថា សម្មប្បធាន ៤ ក៏ព្រោះមានកិច្ច ៤ យ៉ាង តាមដែលពោលមកខាងលើនោះហើយ ។

**ធម៌ ៤ យ៉ាង** គឺ ឆន្ទៈ (ការពេញចិត្ត គឺការប្រាថ្នានឹងធ្វើឱ្យសម្រេច) ១, វិរិយៈ ១, ចិត្តៈ (ដែលផ្ចង់ក្នុងអារម្មណ៍នោះជាពិសេស) ១, វីមំសា (បញ្ញាត្រិះរិះ) ១ ដែលកើតឡើង ចំពោះព្រះយោគាវចរគិតថា " ការសម្រេចជោគជ័យនឹងមានចំពោះអ្នកដែលប្រកបដោយឆន្ទៈយ៉ាងដូចម្តេច ទោះជាយើងក៏មានឆន្ទៈយ៉ាងដូចនោះដែរ " ដូចនេះ ជាដើម រួចធ្វើឆន្ទៈ ជាដើមនោះ ឱ្យចម្រើនឡើង ឱ្យជាធំ ឱ្យចេញមុខ ប្រកបការងាររបស់ខ្លួនទៅ រហូតដល់សម្រេចជោគជ័យ ឈ្មោះថា **ឥទ្ធិបាទ** មាន ៤ យ៉ាងមានឆន្ទិទ្ធិបាទ ជាដើម ។

ពាក្យថា **ឈាន** គឺ ឈាន ៤ មានបឋមជ្ឈាន ជាដើម ដែលបានឈ្មោះថា ឈាន ដោយអត្ថន័យថា ផ្ចង់អារម្មណ៍ និងដោយអត្ថន័យថា ដុតបំផ្លាញធម៌ដែលជាសត្រូវ ។ នោះគឺ លោកិយឈាន ដែលព្រះយោគាវចរប្រើជាបាទនៃវិបស្សនា ដែលផ្ចង់អារម្មណ៍ មានកសិណជាដើម ដុតបំផ្លាញធម៌ដែលជាសត្រូវគឺ នីវរណធម៌ ទាំងឡាយ ដោយការសង្កត់ទុក និង លោកុត្តរឈាន ដែលកើតព្រមជាមួយព្រះអរិយមគ្គ ៤ មានសោតាបត្តិមគ្គ ជាដើម ដើម្បីផ្ចង់អារម្មណ៍ គឺ ព្រះនិព្វាន និង ដុតបំផ្លាញធម៌ដែលជាសត្រូវ គឺ នីវរណធម៌ទាំងឡាយ ដោយការកាត់ផ្តាច់បាន ។

ពាក្យថា **វិមោក្ខ** គឺវិមោក្ខ ៣ គឺអនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ និង

*សុញ្ញតវិមោក្ខ បានសេចក្ដីថា ព្រះនិព្វាន ឈ្មោះថា " អនិមិត្ត: " ព្រោះជាទីប្រាសចាកនិមិត្ត គឺ សង្ខារទាំងឡាយ ។ ព្រះអរិយមគ្គទាំងឡាយ មានសោតាបត្តិមគ្គ ជាដើម ឈ្មោះថា " វិមោក្ខ " ព្រោះជាហេតុចេញផុតពីកិលេសទាំងឡាយ ។ ព្រះអរិយមគ្គនោះឯង កាលបើប្រព្រឹត្តទៅ ដោយធ្វើព្រះនិព្វានដែលឈ្មោះថាអនិមិត្ត:នោះមកជាអារម្មណ៍ ជាហេតុចេញផុតពីកិលេសទាំងឡាយបាន ព្រោះហេតុនោះទើបឈ្មោះថា* ***អនិមិត្តវិមោក្ខ*** *។ ព្រះនិព្វានបានឈ្មោះថា " អប្បណិហិត: " ព្រោះមិនជាទីប្រាថ្នានៃរាគ: ។ ឈ្មោះថា " សុញ្ញត: " ព្រោះប្រាសចាកសង្ខារទាំងឡាយ ។ ព្រះអរិយមគ្គបានឈ្មោះថា* ***អប្បណិហិតវិមោក្ខ*** *បានឈ្មោះថា* ***សុញ្ញតវិមោក្ខ*** *ដោយន័យដូចខាងលើ ។*

*ពាក្យថា* ***សមាធិ*** *គឺអនិមិត្តសមាធិ អប្បណិហិតសមាធិ និងសុញ្ញតសមាធិ ។ ក្នុងទីនេះ បំណងយកសមាធិ ដែលកើតរួមជាមួយព្រះអរិយមគ្គទាំងឡាយ បានឈ្មោះថា អនិមិត្តសមាធិ ជាដើម ក៏ព្រោះការតាំងមាំក្នុងអារម្មណ៍តែមួយ គឺ ព្រះនិព្វានដែលឈ្មោះថា អនិមិត្ត: ជាដើមនោះ ។*

*ពាក្យថា* ***សមាបត្តិ*** *គឺ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ និងសុញ្ញតសមាបត្តិ ។ ព្រះអរិយផលទាំងឡាយ ឈ្មោះថា " សមាបត្តិ " ព្រោះសេចក្ដីថា ព្រះអរិយបុគ្គលរមែងចូល គឺធ្វើឱ្យប្រព្រឹត្តទៅ បន្តរហូតអស់រយៈពេលដែលត្រូវការ ។ សមាបត្តិទាំងនោះ ឈ្មោះថា* ***អនិមិត្តសមាបត្តិ*** *ជាដើម ក៏ព្រោះសេចក្ដី ដែលមានព្រះនិព្វានឈ្មោះថា អនិមិត្ត: ជាដើម ជាអារម្មណ៍នោះឯង ។*

*ក្នុងគាថា ពាក្យថា* ***នរ:*** *ប្រែថា សត្វ ។ ពាក្យថា* ***អ្នកមានបញ្ញា*** *គឺ អ្នកមានបញ្ញា ដែលកើតពីកម្ម ដែលជាបញ្ញាបានមកព្រមជាមួយបដិសន្ធិ ។*

ពាក្យថា **តាំងក្នុងសីល** បានសេចក្ដីថា ជាអ្នកធ្វើសីលឱ្យពេញឱ្យបរិបូរក៏បាន ឈ្មោះថា តាំងក្នុងសីល ។ ក្នុងទីនេះ ពាក្យថា **ចម្រើនចិត្តនិងបញ្ញា** គឺ ចម្រើនសមាធិ និង វិបស្សនាបញ្ញា ។ សមាធិ ក្នុងទីនេះ ត្រាស់ហៅថា ចិត្ត ក៏ព្រោះជាភាពតាំងមាំនៃចិត្ត ។ ពាក្យថា ជាអ្នកមានសេចក្ដីព្យាយាម គឺជាអ្នកមានសេចក្ដីព្យាយាម ដែលដល់ភាពជាតបៈ ដុតបំផ្លាញកិលេសបាន ដោយអំណាចនៃការធ្វើឱ្យមាន ជាបន្តបន្ទាប់គ្នា ។ ពាក្យថា **មានភាពវៃឆ្លាត** គឺជាអ្នកមានបរិហារិកបញ្ញា ដែលជាអ្នកដឹកនាំក្នុងកិច្ចផងទាំងពួង ។ ពាក្យថា **ជាភិក្ខុ** គឺជាអ្នកមានធម្មតាមើលឃើញគ្រោះភ័យក្នុងសង្សារវដ្ដ ។ ពាក្យថា **នឹងអាចជម្រះបណ្ដាញចាក់ស្រេះនេះបាន** គឺ នឹងអាចជម្រះភាពចាក់ស្រេះនៃបណ្ដាញ គឺតណ្ហានេះបាន ។ តណ្ហា លោកហៅថា "**បណ្ដាញចាក់ស្រេះ**" ក៏ព្រោះទាក់រួបរឹតសត្វទាំងឡាយ ឱ្យជាប់នៅនឹងភពតូចភពធំ ។

ប្រៀបដូចជា បុរសឈរនៅលើផែនដី យារកាំបិតដែលសំលៀងបានល្អហើយ លើថ្មសំនៀង ជម្រះគុម្ពឫស្សីធំបានយ៉ាងណា ។ ព្រះយោគាវចរតាំងក្នុងសីល ហើយក៏បានប្រើដៃ គឺ បរិហារិកបញ្ញា ដែលកម្លាំងនៃសេចក្ដីព្យាយាម ក្ដាប់ទ្រ យារកាំបិត គឺ វិបស្សនាបញ្ញា ដែលសំលៀងល្អហើយលើថ្ម គឺសមាធិ ជម្រះគឺកាត់បំផ្លាញភាពចាក់ស្រេះនៃបណ្ដាញ គឺតណ្ហាបាន ដូចនេះ ។

ប្រៀបដូចជា ធរណីនេះជាទីតាំងនៃសត្វទាំងឡាយ យ៉ាងណា ។ សីលនេះ ក៏ជាឫសគល់ គឺជាទីតាំងដើម្បីភាពចម្រើនឡើងនៃកុសលធម៌ទាំងឡាយ យ៉ាងនេះដែរ ។ ក្នុងព្រះសាសនារបស់ព្រះជិនវរពុទ្ធជាម្ចាស់ ក៏មានកងសីល ដែលមានក្នុងព្រះបាដិមោក្ខ គឺមានក្នុងពាក្យទូន្មានជាហេតុឱ្យសត្វ ដែលមានធម្មតាធ្លាក់ទៅក្នុងអបាយនិងក្នុងវដ្ដទុក្ខ ឱ្យរួចផុតពីគ្រោះ

ភ័យក្នុងអបាយ និងគ្រោះភ័យក្នុងវដ្តទុក្ខ ដែលជាសីលដ៏ប្រសើរនេះឯង ជាប្រធាន ជាអ្នកនាំមុខ ជាផ្នែកដំបូង ដូចនេះដែរ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៩

# បញ្ហាទី ១០ - សម្បសាទនលក្ខណសទ្ធាបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន សទ្ធាមានអ្វីជាលក្ខណៈ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ សទ្ធាមានភាពធ្វើឱ្យជ្រះថ្លា ដោយស្រួល ជាលក្ខណៈ និងមានភាពទោរទៅ ដោយស្រួល ជាលក្ខណៈ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ សទ្ធាឈ្មោះថា មានភាពធ្វើឱ្យជ្រះថ្លា ដោយស្រួល ជាលក្ខណៈ យ៉ាងដូចម្ដេច?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ សទ្ធាពេលកើតឡើងរមែងសង្កត់នីវរណៈទាំងឡាយបាន ចិត្តដែលប្រាសចាកនីវរណៈ រមែងជាចិត្តដែលថ្លាជ្រះថ្លា មិនល្អក់កករ សូមថ្វាយព្រះពរ សទ្ធាមានសេចក្ដីធ្វើឱ្យជ្រះថ្លា ដោយស្រួល ជាលក្ខណៈ យ៉ាងនេះ"

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមាផងចុះ"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា ព្រះចៅចក្រពត្តិ ស្ដេចយាងដំណើរផ្លូវឆ្ងាយ ព្រមទាំងកងទ័ព ៤ ពលរេហ៍ ត្រូវយាងឆ្លងកាត់ថ្លុកទឹកទៅ ។ ថ្លុកទឹកនោះក៏ល្អក់ឡើង កករឡើង ក្លាយជាទឹកភក់ ព្រោះពលដំរី ពលសេះ ពលរទេះ និង ពលថ្មើរជើងទាំងឡាយ ។ ព្រះ

ចៅចក្រពត្តិ ដែលយាងផុតទៅហើយនោះ ក៏ត្រាស់ទៅកាន់មនុស្សទាំងឡាយថា " ម្នាល ! នាយទាំងឡាយ ចូរយកទឹកមក យើងនឹងសោយទឹក " ដូចនេះ ។

ព្រះរាជាទ្រង់មានកែវមណីដែលប្រើធ្វើទឹកឱ្យថ្លាបាន ។ មនុស្សទាំងឡាយក្រាបទូលទទួលព្រះរាជបញ្ជារបស់ព្រះចៅចក្រពត្តិថា " ក្រាបទូល " ដូចនេះហើយ ក៏ ( ដួសទឹកដាក់ភាជនៈមក ) ដាក់កែវមណីដែលប្រើធ្វើទឹកឱ្យថ្លានោះ ចូលទៅក្នុងទឹក ។

គ្រាន់តែដាក់កែវមណីចូលទៅក្នុងទឹកប៉ុណ្ណោះ បណ្ដាសារាយ ចកទាំង ឡាយ ក៏ប្រាសចាកទៅ កករទាំងឡាយក៏ស្ងប់ចុះតែម្ដង ទឹកក៏ក្លាយជាទឹកថ្លា ជ្រះថ្លា មិនល្អក់កករ ។ រួចក៏នាំយកមកថ្វាយជាទឹកសោយចំពោះព្រះចៅចក្រពត្តិ ក្រាបទូលថា " បពិត្រព្រះអង្គ ទ្រង់ជាសម្មតិទេព សូមទ្រង់សោយ

ចុះក្រាបទូល " ដូចនេះ ។

សូមថ្វាយព្រះពរ អ្នកជាបណ្ឌិតគួរឃើញចិត្តថាដូចជាទឹក គួរឃើញព្រះយោគាវចរថា ដូចមនុស្សទាំងនោះ គួរឃើញកិលេសទាំងឡាយថា ដូចសារាយ ចក និងកករ គួរឃើញសទ្ធា ថាជាកែវមណីដែលប្រើធ្វើទឹកឱ្យថ្លា ប្រៀបដូចថា ពេលគ្រាន់តែដាក់កែវមណីចូលទៅក្នុងទឹកប៉ុណ្ណោះ សារាយ ចក ក៏ប្រាសចាកទៅ និងកករក៏ស្ងប់ចុះទៅ ទឹកក៏ក្លាយជាទឹកថ្លា ជ្រះថ្លា មិនល្អក់កករ យ៉ាងណា ។

សូមថ្វាយព្រះពរ សទ្ធាពេលកើតឡើង រមែងសង្កត់នីវរណៈ ទាំងឡាយបាន, ចិត្តដែលប្រាសចាកនីវរណៈ រមែងជាចិត្តដែលថ្លា ជ្រះថ្លា មិន

*ល្អក់កករ យ៉ាងនោះ ដែរ, សូមថ្វាយព្រះពរ សទ្ធាឈ្មោះថា មានសេចក្តីធ្វើឱ្យជ្រះថ្លា ដោយស្រួល ជាលក្ខណៈ តាមប្រការដូចពោលខាងលើមកនេះ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ"* ៕

*ចប់សម្បសាទនលក្ខណសទ្ធាបញ្ហាទី ១០*

# ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*ពាក្យថា* ***សម្បសាទនលក្ខណសទ្ធាបញ្ហា*** *ប្រែថា បញ្ហាស្តីអំពីសទ្ធាដែលមាន ភាពធ្វើឱ្យជ្រះថ្លា ដោយស្រួល ជាលក្ខណៈ ។*

*ពាក្យថា* ***នីវរណៈទាំងឡាយ*** *បានសេចក្តីថា ធម៌ទាំងឡាយឈ្មោះថា នីវរណៈ ព្រោះមានសេចក្តីថា រាំងកុសលចិត្ត ។ មាន ៥ យ៉ាង គឺ កាមច្ឆន្ទ-នីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆា-នីវរណៈ ។*

*ឆន្ទៈ គឺ ការពេញចិត្ត ដែលជាការប៉ងក្នុងកាមគុណ ៥ នោះឯងជានីវរណៈ ឈ្មោះថា* ***កាមច្ឆន្ទនីវរណៈ*** *។ សេចក្តីក្រោធ ឈ្មោះថា ព្យាបាទ ព្រោះជាហេតុ ឱ្យចិត្តដល់សេចក្តីវិនាស ព្យាបាទនោះឯងជានីវរណៈ ឈ្មោះថា* ***ព្យាបាទនីវរណៈ*** *។ ថីនៈ គឺ ភាពរួញថយនៃចិត្ត និង មិទ្ធៈ គឺភាពងោក-ងុយនោះឯងជានីវរណៈ ឈ្មោះថា* ***ថីនមិទ្ធនីវរណៈ*** *។ ឧទ្ធច្ចៈ គឺការស្រមើ-ស្រមៃរាយមាយ និង កុក្កុច្ចៈ គឺការមិនសប្បាយចិត្តនោះឯងជានីវរណៈ ឈ្មោះថា* ***ឧទ្ធច្ចកុក្កុច្ចនីវរណៈ*** *។ វិចិកិច្ឆា គឺ ភាពស្ទាក់ស្ទើរសង្ស័យនោះឯងជានីវរណៈ ឈ្មោះថា* ***វិចិកិច្ឆានីវរណៈ*** *៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១០*

# បញ្ហាទី ១១ - សម្បក្ខន្ទនលក្ខណសទ្ធាបញ្ហា

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ សទ្ធា ឈ្មោះថា មានភាពទោរទៅដោយស្រួល ជាលក្ខណៈ យ៉ាងដូចម្ដេច?* "

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ ដូចដែលព្រះយោគាវចរ លុះឃើញចិត្តរួចផុតរបស់អ្នកដទៃហើយ ក៏រមែងទោរទៅ ដោយស្រួល ក្នុងព្រះសោតាបត្តិផល ក្នុងព្រះសកទាគាមិផល ក្នុងព្រះអនាគាមិផល ក្នុងព្រះអរហត្តផល, រមែងធ្វើសេចក្ដីព្យាយាម ដើម្បីដល់នូវធម៌ ដែលមិនទាន់ដល់ ដើម្បីសម្រេចនូវធម៌ ដែលមិនទាន់សម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវធម៌ ដែលមិនទាន់ជាក់ច្បាស់, សូមថ្វាយព្រះពរ សទ្ធា ឈ្មោះថា មានភាពទោរទៅ ដោយស្រួល ជាលក្ខណៈ យ៉ាងដូចនេះ ។* "

**ព្រះចៅមិលិន្ទ** ៖ " *សូមព្រះគុណម្ចាស់ធ្វើការឧបមាផងចុះ* "

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា ភ្លៀងមួយមេធំ ធ្លាក់ពីលើភ្នំ ទឹកភ្លៀងនោះក៏ហូរចុះទៅតាមទីទំនាប ធ្វើឱ្យច្រកភ្នំ អូរ ស្ទឹង ទាំងឡាយ មានទឹកពេញ រួចក៏ទៅធ្វើឱ្យទន្លេមានទឹកពេញដែរ, ទន្លេនោះឯង (ពេញប្រៀបហើយ) ក៏ហូរកាត់ច្រាំងទាំងសងខាងទៅ, ក្រោយមក មហាជនមកដល់ ពេលមិនដឹងថា ទន្លេនោះរាក់ឬជ្រៅក៏ខ្លាច ទើបឈរ (អោរ) នៅប្របច្រាំងដ៏ល្វឹងល្វើយនោះ ។*

*លំដាប់នោះ មានបុរសម្នាក់មកដល់ ពេលឃើញភាពរឹងប៉ឹង និង កម្លាំងរបស់ខ្លួនរួច ក៏ចងជាយសំពត់ឱ្យណែន ធ្វើដំណើរឆ្លងកាត់ទៅដោយ ស្រួល មហាជនទាំងឡាយ លុះឃើញគេឆ្លងបាន ក៏ឆ្លងទៅដែរ យ៉ាងណា ។*

*សូមថ្វាយព្រះពរ ព្រះយោគាវចរ លុះឃើញចិត្ត ដែលរួចផុតរបស់ អ្នកដទៃហើយ ក៏រមែងទោរទៅ ដោយស្រួល ក្នុងព្រះសោតាបត្តិផល ក្នុង ព្រះសកទាគាមិផល ក្នុងព្រះអនាគាមិផល ក្នុងព្រះអរហត្តផល រមែងធ្វើសេ ចក្តីព្យាយាម ដើម្បីដល់នូវធម៌ ដែលមិនទាន់ដល់ ដើម្បីសម្រេចនូវធម៌ ដែល មិនទាន់សម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវធម៌ ដែលមិនទាន់ជាក់ច្បាស់ ដូច នោះដែរ, សូមថ្វាយព្រះពរ សទ្ធា ឈ្មោះថា មានភាពទោរទៅ ដោយស្រួល ជាលក្ខណៈ ដូចនេះ ។*

*សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្តីនេះ ទុកក្នុង សំយុត្តនិកាយថា ៖*

**សទ្ធាយ តរតិ ឱឃំ អប្បមាទេន អណ្ណវំ**
**វីរិយេន ទុក្ខមច្ចេតិ បញ្ញាយ វិសុជ្ឈតិ** [១]

*ប្រែថា ៖ បុគ្គលរមែងឆ្លងអន្លង់ទឹកបានដោយសទ្ធា*
*រមែងឆ្លងសមុទ្របានដោយសេចក្តីមិនប្រមាទ*
*រមែងឆ្លងផុតទុក្ខបានដោយសេចក្តីព្យាយាម*
*រមែងបរិសុទ្ធបានដោយបញ្ញា "*

**ព្រះចៅមិលិន្ទ** ៖ *"ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរ ហើយ" ៕*

*ចប់សម្បក្ខន្ទនលក្ខណសទ្ធាបញ្ហាទី ១១*

# ពាក្យអធិប្បាយបញ្ហាទី ១១ ៖

*បញ្ហាមានការសួរ ដល់លក្ខណៈធ្វើឱ្យទោរទៅ ដោយស្រួល នៃសទ្ធា ឈ្មោះថា **សម្បក្ខន្ទនលក្ខណសទ្ធាបញ្ហា** ។*

*ពាក្យថា **រមែងទោរទៅ ដោយស្រួល ក្នុងព្រះសោតាបត្តិផល** ជាដើម បានសេចក្ដីថា លុះឃើញចិត្តដែលរួចផុតរបស់អ្នកដទៃ គឺដឹងថា បុគ្គលម្នាក់នេះជាអ្នកដែលមានចិត្តរួចផុតហើយ ក៏កើតមានសទ្ធាជ្រះថ្លាថា " បដិបទានេះ មិនមែនអត់ប្រយោជន៍ឡើយ " ដូចនេះ រួចក៏បញ្ជូនចិត្តទៅក្នុងព្រះសោតាបត្តិផលជាដើម គឺ កើតគំនិតក្នុងការប្រតិបត្តិធម៌ ដើម្បីឱ្យដល់ព្រះសោតាបត្តិផល ជាដើមនោះ ។*

*ពាក្យថា **ដើម្បីដល់នូវធម៌ ដែលមិនទាន់ដល់** គឺ ដើម្បីដល់នូវផលដែលខ្លួនមិនទាន់ដល់ ។*

*...**លមិនទាន់សម្រេច** គឺ ដើម្បីសម្រេចនូវមគ្គ ដែលខ្លួនមិនទាន់បានសម្រេច ។*

*ពាក្យថា **ដើម្បីធ្វើឱ្យជាក់ច្បាស់នូវធម៌ ដែលមិនទាន់ជាក់ច្បាស់** គឺដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ឬ ផលនោះឯង ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១១*

# បញ្ហាទី ១២ - វីរិយលក្ខណបញ្ហា

---
(១) *សំយុត្តនិកាយ សគាថវគ្គ ។*

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន វីរិយៈមានអ្វីជាលក្ខណៈ ?"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ វីរិយៈមានការទ្រទ្រង់ទុកជាលក្ខណៈ កុសលធម៌ទាំងឡាយទាំងពួង ដែលវីរិយៈទ្រទ្រង់ហើយ រមែងមិនថយចុះឡើយ"*

**ព្រះចៅមិលិន្ទ** ៖ *" សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ ប្រៀបដូចជា ផ្ទះដែលបម្រុងនឹងរលំដួល បុរស (ជាម្ចាស់ផ្ទះ) ប្រើឈើមួយទប់ ផ្ទះនោះត្រូវឈើទ្រទ្រង់ទប់ដូចនេះ ក៏មិនអាចរលំដួលបានឡើយ យ៉ាងណានោះ សូមថ្វាយព្រះពរ វីរិយៈមានការទ្រទ្រង់ទុកជាលក្ខណៈ កុសលធម៌ទាំងឡាយទាំងពួង ដែលវីរិយៈទ្រទ្រង់ហើយ រមែងមិនថយចុះ យ៉ាងនោះដែរ"*

**ព្រះចៅមិលិន្ទ** ៖ *" សូមព្រះគុណម្ចាស់ឧបមាបន្ថែមទៀតផងចុះ"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា កងទ័ពធំ អាចវាយកងទ័ពតូចជាងបាន ព្រោះហេតុនោះ ទើបព្រះរាជាទ្រង់បន្ថែម ទ្រង់ជំនួយទ័ព ទ្រង់ប្រទានកម្លាំងពលឱ្យដល់កងទ័ពតូចរបស់ព្រះអង្គបន្ថែមជារឿយ ៗ កងទ័ពតូច ព្រមទាំងកងទ័ពបន្ថែម និងកងទ័ពជំនួយនោះ នឹងអាចវាយកងទ័ពធំ បានយ៉ាងណានោះ ។ សូមថ្វាយព្រះពរ វីរិយៈមានការទ្រទ្រង់ទុកជាលក្ខណៈ កុសលធម៌ទាំងឡាយទាំងពួង ដែលវីរិយៈទ្រទ្រង់ហើយ រមែងមិនថយចុះ យ៉ាងនោះដែរ ។*

*សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះភាសិតទុកថា ៖*

**វីរិយវា ខោ ភិក្ខវេ អរិយសាវកោ អកុសលំ បជហតិ, កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធមត្តានំ បរិហរតិ** (១)

*- ម្នាលភិក្ខុទាំងឡាយ ព្រះអរិយសាវកដែលមានសេចក្ដីព្យាយាម រមែងលះអកុសលបាន រមែងចម្រើនកុសលបាន រមែងលះធម៌ដែលមានទោសបាន រមែងចម្រើនធម៌ដែលគ្មានទោសបាន រមែងចាត់ចែងខ្លួនឱ្យបរិសុទ្ធបាន ។*

*ដូចនេះ ”*

**ព្រះចៅមិលិន្ទ ៖** *“ ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ ” ៕*

*ចប់វីរិយលក្ខណបញ្ហាទី ១២*

# ពាក្យអធិប្បាយបញ្ហាទី ១២ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់វីរិយៈ ឈ្មោះថា* ***វីរិយលក្ខណបញ្ហា*** *។*

*ក្នុងឧបមាដំបូង កុសលធម៌ទាំងឡាយប្រៀបដូចផ្ទះ វីរិយៈប្រៀបដូច ...ះមានឈើទប់យ៉ាងណានោះ កុសលធម៌ទាំងឡាយ មិនថយចុះ ព្រោះមានវីរិយៈចាំទ្រទ្រង់ទុក យ៉ាងនោះដែរ ។*

*ក្នុងឧបមាទី ២ ពាក្យថា* ***ទ្រង់បន្ថែម*** *គឺ ទ្រង់បញ្ជូនកងទ័ពតូចផ្សេងៗចូលទៅក្នុងកងទ័ពតូចនោះរឿយៗ ។*

*ពាក្យថា* ***ទ្រង់ជំនួយ*** *គឺ ទ្រង់ត្រាស់បង្គាប់ឱ្យកងទ័ពតូចផ្សេងទៀត តាមទៅជួយរក្សាកងទ័ពតូចទាំងពីរនោះ ។ កុសលធម៌ទាំងឡាយ ប្រៀបដូចជាកងទ័ពតូច វីរិយៈប្រៀបដូចជាកងទ័ពបន្ថែម និងកងទ័ពជំនួយ ។ កងទ័ពតូច មិនចាញ់ មិនបាក់ទ័ព ព្រោះមានកងទ័ពបន្ថែម និងកងទ័ពជំនួយ ចាំ*

(១) អង្គុត្តរនិកាយ សត្តកនិបាត ។

*ជួយទ្រទ្រង់ យ៉ាងណានោះ កុសលធម៌ទាំងឡាយមិនខូចបង់ ព្រោះមានវិរិយៈចាំទ្រទ្រង់ទុក យ៉ាងនោះដែរ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១២*

# បញ្ហាទី ១៣ - សតិលក្ខណបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា ៖ " ព្រះគុណម្ចាស់នាគសេន សតិមានអ្វី ជាលក្ខណៈ?"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ សតិមានភាពមិនវង្វេង (មិនច្របូកច្របល់) ជាលក្ខណៈ និងមានការចូលទៅប្រកាន់យក ជាលក្ខណៈ"*

**ព្រះចៅមិលិន្ទ** ៖ *" ព្រះគុណម្ចាស់ សតិឈ្មោះថា មានភាពមិនវង្វេងជាលក្ខណៈ យ៉ាងដូចម្ដេច ?"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ សតិ ពេលកើតឡើងរមែង មិនវង្វេង(មិនច្របូកច្របល់) នូវធម៌ជាកុសល ធម៌ជាអកុសល, ធម៌មានទោស ធម៌មិនមានទោស, ធម៌អន់ ធម៌ប្រណីត, ធម៌ខ្មៅ ធម៌ស, ធម៌សមរម្យ ធម៌មិនសមរម្យ, រមែងមិនវង្វេងក្នុងធម៌ទាំងឡាយថា នេះគឺសតិប្បដ្ឋាន ៤, នេះគឺសម្មប្បធាន ៤, នេះគឺឥទ្ធិបាទ ៤, នេះគឺឥន្ទ្រិយ ៥, នេះគឺពលៈ ៥, នេះគឺពោជ្ឈង្គៈ ៧, នេះគឺព្រះអរិយមគ្គមានអង្គ ៨, នេះគឺសមថៈ, នេះគឺវិបស្សនា, នេះគឺវិជ្ជា, នេះគឺវិមុត្តិ ដូចនេះ ។*

ព្រោះលក្ខណៈដែលមិនវង្វេងនោះ ទើបព្រះយោគាវចរសេពតែធម៌គួរសេព មិនសេពនូវធម៌មិនគួរសេព រាប់រកធម៌ដែលគួររាប់រក មិនរាប់រកធម៌ដែលមិនគួររាប់រក ។

សូមថ្វាយព្រះពរ សតិ ឈ្មោះថា មានភាពមិនវង្វេង ជាលក្ខណៈយ៉ាងដូចនេះ "

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា មន្ត្រីឃ្លាំងរបស់ព្រះចៅចក្រពត្តិរមែងមិនវង្វេង (មិនច្របូកច្របល់) រមែងក្រាបទូលព្រះចៅចក្រពត្តិ ឱ្យទ្រង់រឭកដល់ព្រះរាជឥស្សរិយយស ក្នុងវេលាល្ងាច ក្នុងវេលាព្រឹកថា " ក្រាបទូលព្រះអង្គទ្រង់ជាសម្មតិទេព ព្រះអង្គទ្រង់មានដំរីប៉ុននេះ មានសេះប៉ុននេះ មានរថប៉ុននេះ មានពលថ្មើរជើងប៉ុននេះ មានប្រាក់ប៉ុននេះ មានមាសប៉ុននេះ មានវត្ថុរបស់របររបស់ព្រះអង្គប៉ុននេះ " ដូចនេះ រមែងមិនវង្វេងព្រះរាជទ្រព្យ យ៉ាងណានោះ។

សូមថ្វាយព្រះពរ សតិ ពេលកើតឡើងរមែងមិនវង្វេង (មិនច្របូកច្របល់ ) នូវធម៌ជាកុសល ធម៌ជាអកុសល, ធម៌មានទោស ធម៌មិនមានទោស , ធម៌អន់ ធម៌ប្រណីត, ធម៌ខ្មៅ ធម៌ស, ធម៌សមរម្យ ធម៌មិនសមរម្យ, រមែងមិនវង្វេងក្នុងធម៌ទាំងឡាយថា នេះគឺសតិប្បដ្ឋាន ៤, នេះគឺសម្មប្បធាន ៤, នេះគឺឥទ្ធិបាទ ៤, នេះគឺឥន្ទ្រិយ ៥, នេះគឺពលៈ ៥, នេះគឺពោជ្ឈង្គៈ ៧, នេះគឺព្រះអរិយមគ្គមានអង្គ ៨, នេះគឺសមថៈ, នេះគឺវិបស្សនា, នេះគឺវិជ្ជា, នេះគឺវិមុត្តិ ដូចនេះ ។

*ព្រោះលក្ខណៈដែលមិនវង្វេងនោះ ទើបព្រះយោគាវចរសេពតែធម៌គួរសេព មិនសេពនូវធម៌មិនគួរសេព រាប់រកធម៌ដែលគួររាប់រក មិនរាប់រកធម៌ដែលមិនគួររាប់រក ។*

*សូមថ្វាយព្រះពរ សតិ ឈ្មោះថា មានភាពមិនវង្វេងជាលក្ខណៈយ៉ាងដូចនេះ ”*

**ព្រះចៅមិលិន្ទ ៖** *“ ព្រះគុណម្ចាស់ សតិមានការចូលទៅប្រកាន់យកជាលក្ខណៈ យ៉ាងដូចម្តេច ? ”*

**ព្រះនាគសេន ៖** *“ សូមថ្វាយព្រះពរ មហាបពិត្រ សតិ ពេលកើតឡើងរមែងទទួលដឹងយ៉ាងត្រឹមត្រូវ នូវគតិនៃធម៌ទាំងឡាយ ដែលផ្តល់ប្រយោជន៍និងមិនផ្តល់ប្រយោជន៍ថា “ ធម៌ទាំងនេះផ្តល់ប្រយោជន៍ ធម៌ទាំងនេះមិនផ្តល់ប្រយោជន៍ ធម៌ទាំងនេះមានឧបការៈ ធម៌ទាំងនេះមិនមានឧបការៈ ” ដូចនេះ ។*

*ព្រោះលក្ខណៈនោះ ព្រះយោគាវចររមែងកម្ចាត់នូវធម៌ដែលមិនផ្តល់ប្រយោជន៍ ចូលទៅប្រកាន់យកនូវធម៌ដែលផ្តល់តែប្រយោជន៍ កម្ចាត់នូវធម៌ដែលមិនមានឧបការៈ ចូលទៅប្រកាន់យកតែធម៌ដែលមានឧបការៈ ។*

*សូមថ្វាយព្រះពរ សតិ ឈ្មោះថា មានការចូលទៅប្រកាន់យក ជាលក្ខណៈ យ៉ាងដូចនេះ ”*

**ព្រះចៅមិលិន្ទ ៖** *“ សូមព្រះគុណម្ចាស់ ធ្វើការឧបមា ”*

**ព្រះនាគសេន ៖** *“ សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា មហាអាមាត្យកែវរបស់ព្រះចៅចក្រពត្តិ រមែងដឹងនូវបុគ្គលដែលផ្តល់ប្រយោជន៍និងមិនផ្តល់ប្រយោជន៍ដល់ព្រះរាជាថា “ បុគ្គលទាំងនេះផ្តល់ប្រយោជន៍*

បុគ្គលទាំងនេះ មិនផ្តល់ប្រយោជន៍ បុគ្គលទាំងនេះមានឧបការៈ បុគ្គលទាំងនេះមិនមានឧបការៈ ដូចនេះ ។

ព្រោះហេតុនោះ ក៏រមែងកម្ចាត់មនុស្សដែលមិនផ្តល់ប្រយោជន៍ ចូលទៅប្រកាន់យកតែមនុស្សដែលផ្តល់ប្រយោជន៍ កម្ចាត់មនុស្សដែលគ្មានឧបការៈ ចូលទៅប្រកាន់យកតែមនុស្សដែលមានឧបការៈ យ៉ាងណានោះ ។

សូមថ្វាយព្រះពរ សតិពេលកើតឡើង រមែងទទួលដឹងយ៉ាងត្រឹមត្រូវនូវគតិនៃធម៌ទាំងឡាយ ដែលផ្តល់ប្រយោជន៍ និងមិនផ្តល់ប្រយោជន៍ថា "ធម៌ទាំងនេះ ផ្តល់ប្រយោជន៍ ធម៌ទាំងនេះមិនផ្តល់ប្រយោជន៍ ធម៌ទាំងនេះមានឧបការៈ ធម៌ទាំងនេះមិនមានឧបការៈ" ដូចនេះ ។

ព្រោះលក្ខណៈចូលទៅប្រកាន់យកនោះ ព្រះយោគាវចររមែងកម្ចាត់នូវធម៌ ដែលមិនផ្តល់ប្រយោជន៍ចេញ ចូលទៅប្រកាន់យកនូវធម៌ដែលផ្តល់តែប្រយោជន៍, កម្ចាត់ធម៌ដែលមិនមានឧបការៈ ចូលទៅប្រកាន់យកតែធម៌ដែលមានឧបការៈ ដូចនោះដែរ ។

សូមថ្វាយព្រះពរ សតិ ឈ្មោះថា មានការចូលទៅប្រកាន់យក ជាលក្ខណៈ យ៉ាងដូចនេះ ។

សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះភាសិតទុកថា ៖

**" សតិញ្ច ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ** [១]

**ម្នាលភិក្ខុទាំងឡាយ តថាគតពោលដល់សតិថាជាធម៌ចាំបាច់ក្នុងកិច្ចទាំងពួង"** ដូចនេះ"

[១] សំយុត្តនិកាយ. មហាវគ្គ ។

ណាម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។៕

ចប់សតិលក្ខណបញ្ហាទី ១៣

# ពាក្យអធិប្បាយបញ្ហាទី ១៣ ៖

*ពាក្យថា **សតិមានភាពមិនវង្វេងជាលក្ខណៈ** បានសេចក្តីថា សតិឈ្មោះថា មានភាពមិនវង្វេងជាលក្ខណៈ ព្រោះមានសភាវៈមិនវង្វេង គឺមានសភាវៈចុះទៅចាប់យកអារម្មណ៍ តាមដែលបានឃើញហើយ តាមដែលបានប្រកាន់យកហើយ។*

*ពាក្យថា **សតិពេលកើតឡើង រមែងមិនវង្វេងនូវធម៌ជាកុសល ធម៌ជាអកុសល** ជាដើម បានសេចក្តីថា សតិ ពេលកើតឡើងរមែងមិនវង្វេងយ៉ាងនេះថា " នេះជាកុសលគួរសេព នេះជាអកុសលមិនគួរសេព, នេះមានទោសជាអកុសលមិនគួរសេព នេះគ្មានទោសជាកុសលគួរសេព, នេះអន់អាក្រក់ជាអកុសលមិនគួរសេព នេះប្រណីតជាកុសលគួរសេព, នេះខ្មៅជាអកុសលមិនគួរសេព នេះសជាកុសលគួរសេព, នេះសមរម្យជាកុសលគួរសេព នេះមិនសមរម្យជាអកុសលមិនគួរសេព " ដូចនេះ ។*

*ពាក្យថា **រមែងមិនវង្វេងនូវធម៌ទាំងឡាយថា នេះគឺសតិប្បដ្ឋាន ៤** ជាដើម បានសេចក្តីថា រមែងមិនវង្វេងនូវធម៌ទាំងឡាយ យ៉ាងនេះថា " នេះគឺសតិប្បដ្ឋាន ៤ ជាកុសលដែលគួរសេព " ដូចនេះ ជាដើម ។*

*ក្នុងបណ្តាខន្ធ ៣ គឺ សីលក្ខន្ធ (កងសីល) សមាធិក្ខន្ធ(កងសមាធិ) និងបញ្ញាខន្ធ(កងបញ្ញា) **សមថៈ** ចាត់ចូលក្នុងខន្ធ ២ គឺ សីលក្ខន្ធ និង សមាធិក្ខន្ធ ចំណែក **វិបស្សនា** ចាត់ចូលក្នុងខន្ធតែមួយ គឺ បញ្ញាខន្ធ ។*

*ពាក្យថា **វិជ្ជា** គឺ ផលញ្ញាណ ( ញាណដែលប្រកបរួមគ្នាជាមួយព្រះអរិយផល ) ។*

ពាក្យថា **វិមុត្តិ** គឺ ព្រះនិព្វាន ដោយជានិស្សរណវិមុត្តិ ( ធម៌ដែលរួចផុត គឺ រលាស់ចេញពីសង្ខារទាំងពួង )។

ន័យម្យ៉ាងវិញទៀត ពាក្យថា វិជ្ជា គឺ សម្មាញាណ ( ញាណដែលដឹងត្រឹមត្រូវ ) ដោយភាពជាញាណដែលលះមិច្ឆាញាណ ( មោហៈដែលដឹងនូវអ្វីមិនត្រឹមត្រូវ ) ។ ពាក្យថា វិមុត្តិ គឺ សម្មាវិមុត្តិ ( សេចក្ដីរួចផុតត្រឹមត្រូវ ) ដោយភាពជាវិមុត្តិ ដែលជាបដិបក្ខចំពោះមិច្ឆាវិមុត្តិ ( សេចក្ដីរួចផុតដោយមិនត្រឹមត្រូវ គឺ មិនបានល្អ )។

ព្រោះហេតុនោះ ទើបលោកពោលអំពី សម្មត្តធម៌ ( ធម៌ដែលមានសភាវៈដ៏ត្រឹមត្រូវ) ១០ ប្រការ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ។ល។ សម្មាសមាធិ សម្មាញាណ សម្មាវិមុត្តិ និងពោលដោយពាក្យថា " អរិយមគ្គមានអង្គ ៨ " ដោយពាក្យថា " វិជ្ជា " និងដោយពាក្យថា " វិមុត្តិ " នេះ ។

ពាក្យថា **សតិមានការចូលទៅប្រកាន់យក ជាលក្ខណៈ** បានសេចក្ដីថា សតិ ឈ្មោះថា មានការចូលទៅប្រកាន់យក ជាលក្ខណៈ ព្រោះមានសភាវៈដែលចូលទៅត្រិះរិះ រួចប្រកាន់យកអារម្មណ៍ តាមដែលឃើញរួចហើយ តាមដែលចិត្តប្រកាន់យក រួចហើយ ។

ពាក្យថា **សតិពេលកើតឡើង រមែងទទួលដឹងគតិនៃធម៌ទាំងឡាយដែលផ្ដល់ ប្រយោជន៍និងមិនផ្ដល់ប្រយោជន៍** បានសេចក្ដីថា សតិពេលកើតឡើង រមែងទទួលដឹងគតិ គឺ ដំណើរនៃធម៌ទាំងឡាយថា ៖

" នេះផ្ដល់ប្រយោជន៍ នេះជាកុសលគួរប្រកាន់យក, នេះមិនផ្ដល់ប្រយោជន៍ គឺជាអកុសលមិនគួរប្រកាន់យក គួរកម្ចាត់ចេញ, នេះមានឧបការៈគឺជាកុសល គួរប្រកាន់យក, នេះមិនមានឧបការៈ គឺជាអកុសលមិនគួរប្រកាន់យក គួរកម្ចាត់ចេញ " ។

*ពាក្យថា **បុគ្គលដែលផ្តល់ប្រយោជន៍ និងបុគ្គលដែលមិនផ្តល់ប្រយោជន៍ដល់ព្រះរាជា** គឺ បុគ្គលដែលជាហេតុចម្រើន និងបុគ្គលដែលជាហេតុអន់ថយ ។ ទោះជាពាក្យថា អ្នកមានឧបការៈ អ្នកមិនមានឧបការៈ គឺជាសទិសន័យនៃពាក្យថា អ្នកដែលផ្តល់ប្រយោជន៍ អ្នកដែលមិនផ្តល់ប្រយោជន៍ នោះឯង ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៣*

# បញ្ហាទី ១៤ - សមាធិបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន សមាធិមានអ្វី ជាលក្ខណៈ ? "*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ សមាធិមានភាពជាប្រមុខ ជាលក្ខណៈ កុសលធម៌ទាំងឡាយណាមួយ កុសលធម៌ទាំងនោះ សុទ្ធតែមានសមាធិ ជាប្រមុខ លំឱនទៅរកសមាធិ ទេរទៅរកសមាធិ ឈមទៅរកសមាធិ "*

**ព្រះចៅមិលិន្ទ** ៖ *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន** ៖ *"សូមថ្វាយព្រះពរ ប្រៀបដូចជា ផ្ទោងទាំងឡាយនៃផ្ទះ មានកំពូលដំបូល ឈើផ្ទោងទាំងនោះ សុទ្ធតែសំដៅទៅកាន់កំពូល លំឱនទៅកាន់កំពូល ទៅរួមគ្នានៅឯកំពូល ។ បណ្តាឈើផ្ទោងទាំងនោះ ដំបូលផ្ទះចាត់ទុកថា ជាកំពូលខ្ពស់បំផុត យ៉ាងណា ។*

*សូមថ្វាយព្រះពរ កុសលធម៌ទាំងឡាយណាមួយ កុសលធម៌ទាំងនោះ សុទ្ធតែមានសមាធិជាប្រមុខ លំឱនទៅរកសមាធិ ទេរទៅរកសមាធិ ឈមទៅរកសមាធិ ដូចនោះដែរ"*

**ព្រះចៅមិលិន្ទ** ៖ " *សូមព្រះគុណម្ចាស់ឧបមាបន្ថែមទៀតផងចុះ"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ប្រៀបដូចជា ព្រះរាជាមួយព្រះអង្គ ទ្រង់យាងទៅកាន់សមរភូមិ ព្រមទាំងកងទ័ពមានអង្គទាំង ៤ កងទ័ពទាំងពួងនោះ គឺ ពលដំរីក្តី ពលសេះក្តី ពលរថក្តី ពលថ្មើរជើងក្តី សុទ្ធតែមានព្រះរាជាព្រះអង្គនោះជាប្រមុខ លំឱនទៅកាន់ព្រះរាជាព្រះអង្គនោះ ទេរទៅរកព្រះរាជាព្រះអង្គនោះ ឈមទៅរកព្រះរាជាព្រះអង្គនោះ នឹងស្រុបទៅតាមព្រះរាជាព្រះអង្គនោះប៉ុណ្ណោះ យ៉ាងណានោះ ។*

*សូមថ្វាយព្រះពរ កុសលធម៌ទាំងឡាយណាមួយ កុសលធម៌ទាំងនោះ សុទ្ធតែមានសមាធិជាប្រមុខ លំឱនទៅរកសមាធិ ទេរទៅរកសមាធិ ឈមទៅរកសមាធិ ដូចនោះដែរ ។ សូមថ្វាយព្រះពរ សមាធិឈ្មោះថា មានភាពជាប្រមុខជាលក្ខណៈ តាមប្រការដូចខាងលើ ។*

*សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់បានត្រាស់ព្រះភាសិតថា ៖*

**" សមាធឹ ភិក្ខវេ ភាវេថ សមាហិតោ ភិក្ខុ យថាភូតំ បជានាតិ** [១]

***- ម្នាលភិក្ខុទាំងឡាយ ចូរចម្រើនសមាធិទៅចុះ ភិក្ខុដែលមានចិត្តតាំងមាំ រមែងដឹងច្បាស់តាមសភាវៈពិត"*** *ដូចនេះ "*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់សមាធិប្បញ្ហាទី ១៤*

---

[១] *សំយុត្តនិកាយ មហាវារវគ្គ ។*

# ពាក្យអធិប្បាយបញ្ហាទី ១៤ ៖

*បញ្ហាស្ដីអំពីសមាធិឈ្មោះថា សមាធិប្បញ្ហា ( មិលិន្ទរបស់ថៃជាសមាធិលក្ខណាប្បញ្ហា ) ។*

*ពាក្យថា **កុសលធម៌ទាំងអស់នោះ សុទ្ធតែមានសមាធិជាប្រមុខ** បានសេចក្ដីថា កុសលធម៌ទាំងឡាយ មានសទ្ធា ជាដើម ទាំងនោះ សុទ្ធតែមានសមាធិជាប្រធាន គឺ ដល់ដំណើររួមគ្នា ក្នុងអារម្មណ៍តែមួយ ដោយអំណាចសមាធិ សំដៅទៅចូលជាមួយសមាធិ ដើម្បីធ្វើកិច្ចរបស់ខ្លួន ក្នុងអារម្មណ៍តែមួយ ដែលសមាធិតាំងនៅនោះ ព្រោះហេតុនោះ ទើបលោកពោលថា "**លំឱនទៅរកសមាធិ**" ជាដើម ។*

*ពាក្យថា **ឈើផ្ទោង** គឺ ឈើដែលតម្រង់ទៅមេដំបូល ។*

*ពាក្យថា **សុទ្ធតែសំដៅទៅរកកំពូល** បានសេចក្ដីថា សុទ្ធតែទៅទល់គ្នានៅឯកំពូល ។*

*ពាក្យថា **រួមគ្នានៅឯកំពូល** គឺ ប្រជុំគ្នានៅឯកំពូល ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៤*

# បញ្ហាទី ១៥ - បញ្ញាលក្ខណាប្បញ្ហា

**ព្រះរាជា** *ត្រាស់ថា " ព្រះគុណម្ចាស់ បញ្ញាមានអ្វី ជាលក្ខណៈ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ អាត្មាភាពបានពោលនៅគ្រាមុនហើយថា " បញ្ញាមានការកាត់ ជាលក្ខណៈ " មួយ៉ាងវិញ*

ទៀត បញ្ញាមានការបំភ្លឺឱ្យភ្លឺ ជាលក្ខណៈ"

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់ បញ្ញាឈ្មោះថា មានការបំភ្លឺឱ្យភ្លឺ ជាលក្ខណៈ យ៉ាងដូចម្ដេច ?"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ បញ្ញាពេលកើតឡើង រមែងកម្ចាត់ ភាពងងឹត គឺ អវិជ្ជា រមែងធ្វើភាពភ្លឺ គឺវិជ្ជាឱ្យកើតឡើង រមែងបំភ្លឺនូវពន្លឺ គឺញាណ រមែងធ្វើអរិយសច្ចៈទាំងឡាយ ឱ្យប្រាកដឡើង ។ ព្រោះលក្ខណៈដែលបំភ្លឺនូវពន្លឺនោះ ទើបព្រះយោគាវចរឃើញ ដោយបញ្ញាត្រឹមត្រូវថា " មិនទៀង " " ជាសេចក្ដីទុក្ខ " " ជាអនត្តា "

**ព្រះចៅមិលិន្ទ** ៖ " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាថា បុរសគួរនាំយកប្រទីបចូលទៅក្នុងផ្ទះ ដែលមានតែភាពងងឹត ប្រទីបដែលនាំចូលទៅនោះ រមែងកម្ចាត់ភាពងងឹត រមែងធ្វើភាពភ្លឺឱ្យកើតឡើង រមែងបំភ្លឺនូវពន្លឺឱ្យភ្លឺ រមែងធ្វើរូប(រូបភាព)ទាំងឡាយឱ្យប្រាកដឡើង យ៉ាងណា ។

សូមថ្វាយព្រះពរ បញ្ញាពេលកើតឡើង រមែងកម្ចាត់ភាពងងឹត គឺ អវិជ្ជា រមែងធ្វើភាពភ្លឺ គឺវិជ្ជាឱ្យកើតឡើង រមែងបំភ្លឺនូវពន្លឺ គឺញាណ រមែងធ្វើអរិយសច្ចៈទាំងឡាយឱ្យប្រាកដឡើងយ៉ាងនោះដែរ, ព្រោះលក្ខណៈដែលបំភ្លឺនូវពន្លឺនោះ ទើបព្រះយោគាវចរ ឃើញដោយបញ្ញាត្រឹមត្រូវ ថា " មិនទៀង " " ជាសេចក្ដីទុក្ខ " " ជាអនត្តា " ។

សូមថ្វាយព្រះពរ បញ្ញាឈ្មោះថា មានការបំភ្លឺឱ្យភ្លឺ ជាលក្ខណៈ តាមប្រការដូចពោលខាងលើ មកនេះ "

**ព្រះចៅមិលិន្ទ** ៖ "ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

*ចប់បញ្ញាលក្ខណបញ្ហាទី ១៤*

# ពាក្យអធិប្បាយបញ្ហាទី ១៥ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់បញ្ញា ឈ្មោះថា* ***បញ្ញាលក្ខណ-បញ្ហា*** *។ អវិជ្ជា ឈ្មោះថា " ភាពងងឹត " ក៏ព្រោះមានអាការបិទបាំងសច្ចៈ មិនឱ្យសច្ចៈទាំងឡាយ ប្រាកដឡើងតាមសភាវៈពិត ។ បញ្ញាពេលកើតឡើង រមែងកម្ចាត់ភាពងងឹត គឺ អវិជ្ជា នោះបាន ក៏ព្រោះមានការបង្កើតពន្លឺភ្លឺ គឺ វិជ្ជា បំភ្លឺនូវពន្លឺ គឺ ញាណ ។ ពេលភាពងងឹត គឺ អវិជ្ជា អស់ទៅ សច្ចៈទាំងឡាយ ក៏ប្រាកដឡើង ។ ព្រោះហេតុនោះ ទើបលោកពោលថា " រមែងធ្វើអរិយសច្ចៈទាំងឡាយ ឱ្យប្រាកដឡើង " ដូចនេះ ។*

*ក្នុងឧបមាឧបមេយ្យនោះ ប្រទីបកម្ចាត់ភាពងងឹតបាន ធ្វើរូបទាំងឡាយឱ្យប្រាកដដល់ក្រសែភ្នែករបស់បុរសបានពិតមែនក្តី ។ ទោះជាយ៉ាងនោះក៏មានកំណត់ព្រំដែនថា អាចកម្ចាត់ភាពងងឹតបានក្នុងបរិវេណប៉ុននេះ ប៉ុននោះ មិនហួសពីនោះ មិនឆ្ងាយជាងនេះ ។ អាចបញ្ចាំងរូប(ភាព) ឱ្យប្រាកដដល់ក្រសែភ្នែកបាន ក្នុងបរិវេណប៉ុននេះ ប៉ុននោះ មិនហួសពីនោះ មិនឆ្ងាយជាងនេះ ។ ម្យ៉ាងវិញទៀត មិនអាចបញ្ចាំងឱ្យឃើញរូប ដែលត្រូវវត្ថុផ្សេង មានជញ្ជាំងផ្ទះ ជាដើម បិទបាំងនោះ បានទេ ។ ចំណែកបញ្ញាមានសមត្ថភាពក្នុងការកម្ចាត់ភាពងងឹតគឺ អវិជ្ជា ញុំាងពន្លឺ គឺ វិជ្ជាឱ្យកើតឡើង បំភ្លឺនូវពន្លឺ គឺញាណ ដោយកំណត់ព្រំដែនមិនបាន ។*

*ធម៌ទាំងឡាយ ទោះជាបិតនៅក្នុងភាពងងឹតយ៉ាងណាក្តី មានវត្ថុអ្វីផ្សេង ៗ មកបិទបាំងក្តី បញ្ញាពេលកើតឡើង រមែងដឹងតាមការពិតថា " មិនទៀង"ផង "ជាសេចក្តីទុក្ខ"ផង "ជាអនត្តា"ផង បានទាំងអស់ មិនមានអ្វីជា*

ឧបសគ្គក្នុងការដឹងនោះទេ ។ ព្រោះហេតុនោះ ទើបត្រាស់ថា " **នត្ថិ បញ្ញាសមា អាភា** (១) – ពុំមានពន្លឺណា ស្មើនឹងពន្លឺ គឺ បញ្ញា " ដូចនេះ ។

ពាក្យថា **អរិយសច្ចៈ** ប្រែថា សច្ចៈរបស់ព្រះអរិយបុគ្គល ឬ សច្ចៈដែលសាងភាពជាព្រះអរិយបុគ្គលមាន ៤ យ៉ាង មានទុក្ខអរិយសច្ចៈ ជាដើម ។ ជាការពិតណាស់ ធម៌ ៤ យ៉ាង មានទុក្ខជាដើម ចាត់ទុកជាសច្ចៈ(របស់ពិត) ក៏ព្រោះភាពមិនវិបរិតប្រែប្រួល ធម៌ ៤ យ៉ាង នោះឯង នរណាបានឃើញដោយបញ្ញាត្រឹមត្រូវហើយ អ្នកនោះនឹងបានសម្រេចជាព្រះអរិយបុគ្គល ព្រោះហេតុនោះ ទើបហៅថា អរិយសច្ចៈ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១៥

# បញ្ហាទី ១៦- នានាធម្មានំ ឯកកិច្ចអភិនិប្ផាទនបញ្ហា

**ព្រះរាជា** ត្រាស់សួរថា ៖ " ព្រះគុណម្ចាស់នាគសេន ធម៌ទាំងឡាយមានផ្សេង ៗ គ្នាទាំងនេះ រមែងធ្វើឱ្យសម្រេចប្រយោជន៍តែមួយឬ ? "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ មហាបពិត្រ ធម៌ទាំងឡាយមានផ្សេង ៗ គ្នាទាំងនេះ រមែងធ្វើឱ្យសម្រេចប្រយោជន៍តែមួយ គឺ កម្ចាត់កិលេសទាំងឡាយបាន "

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់ ធម៌ទាំងឡាយមានផ្សេង ៗ គ្នាទាំងនេះ រមែងធ្វើឱ្យសម្រេចប្រយោជន៍តែមួយ គឺ កម្ចាត់កិលេសទាំងឡាយបានយ៉ាងដូចម្ដេច ? សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន** ៖ " ប្រៀបដូចជា កងទ័ពទាំងឡាយមានផ្សេង ៗ គ្នា គឺ កងទ័ពដំរី កងទ័ពសេះ កងទ័ពរថ និងកងទ័ពពលថ្មើរជើង រមែងសម្រេច

(១) សំយុត្តនិកាយ. សគាថវគ្គ ។

*ទ័ពភាគីផ្សេងក្នុងការធ្វើសង្គ្រាមបាន យ៉ាងណា ។*

*សូមថ្វាយព្រះពរ ធម៌ទាំងឡាយមានផ្សេងៗ គ្នាទាំងនេះ រមែងធ្វើឱ្យសម្រេចប្រយោជន៍តែមួយគឺ កម្ចាត់កិលេសទាំងឡាយបាន យ៉ាងនោះដែរ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់នានាធម្មានំ ឯកកិច្ចអភិនិប្ផាទនបញ្ហាទី ១៦*

# ពាក្យអធិប្បាយបញ្ហាទី ១៦ ៖

*ពាក្យថា **នានាធម្មានំ ឯកកិច្ចអភិនិប្ផាទនបញ្ហា** ប្រែថា បញ្ហាទាក់ទងពីប្រការ ដែលធម៌ទាំងឡាយមានផ្សេង ៗ គ្នា ឱ្យសម្រេចកិច្ចតែមួយ ។*

*ពាក្យថា **ធម៌ទាំងឡាយមានផ្សេង ៗ គ្នាទាំងនេះ** គឺ ធម៌ ៧ យ៉ាងទាំងនេះ គឺ យោនិសោមនសិការ សីល សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា ។*

*ពាក្យថា **មានផ្សេង ៗ គ្នា** គឺ មិនដូចគ្នា ។*

*ពាក្យថា **ឱ្យសម្រេចប្រយោជន៍តែមួយ** គឺ ឱ្យសម្រេចកិច្ចតែមួយ ។*

*ប្រៀបដូចជា កងទ័ពទាំងឡាយ ទោះជាមានភាពខុសប្លែកគ្នា ជាកងទ័ព ប្រភេទផ្សេង ៗ គ្នា ដូចជា កងទ័ពនេះជាកងទ័ពដំរី កងទ័ពនោះជាកងទ័ពសេះ ជាដើម ទោះជាយ៉ាងនោះ ក៏ធ្វើកិច្ចតែមួយ គឺ រួមគ្នាប្រយុទ្ធឱ្យឈ្នះកងទ័ពភាគីផ្សេង យ៉ាងណា ។*

ធម៌ទាំងនេះ ទោះជាមានភាពខុសប្លែកគ្នា ជាធម៌ផ្សេង ៗ គ្នា ដូចជា យោនិសោមនសិការ សីល ជាដើម ។ ទោះជាយ៉ាងនោះ ក៏ធ្វើកិច្ចតែមួយ គឺ រួមគ្នាលះកិលេស យ៉ាងនោះដែរ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១៦

# ចប់មហាវគ្គទី ១

ក្នុងវគ្គនេះមាន ១៦ បញ្ហា

❖❖❖❖❖❖❖ 🕮 ❖❖❖❖❖❖❖

# វគ្គទី ២ - អទ្ធានវគ្គ

## បញ្ហាទី ១ - ធម្មសន្តតិប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន អ្នកណាម្នាក់នឹងកើត គេនោះឯងជាអ្នកកើត ឬ ក៏អ្នកផ្សេងជាអ្នកកើត ?"*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា " អ្នកនោះកើតក៏មិនមែន អ្នកផ្សេងកើតក៏មិនមែន "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់យល់ឃើញសេចក្តីនោះយ៉ាងដូចម្តេច ប្រៀបដូចជា ព្រះអង្គទ្រង់ធ្លាប់ជាទារកតូចមកហើយ រហូតមកដល់ពេលនេះ ព្រះអង្គដែលធ្លាប់ជាទារកតូចនោះឯងក្លាយមកជាមនុស្សធំ ឬយ៉ាងណា ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនមែនទេ ព្រះគុណម្ចាស់ ទារកតូចនោះក៏ជាមនុស្សម្នាក់ ខ្ញុំព្រះករុណាជាមនុស្សធំពេលនេះ ក៏ជាមនុស្សម្នាក់ទៀត "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ បើដូចនេះ សូម្បីអ្នកដែលបុត្រហៅថា "មាតា" ក៏គ្មាន សូម្បីអ្នកដែលបុត្រហៅថា "បិតា" ក៏គ្មាន សូម្បីអ្នកដែលសិស្ស ហៅថា "គ្រូ" ក៏គ្មាន សូម្បីអ្នកដែលគេហៅថា "អ្នកមានសិល្បៈ" ក៏គ្មាន សូម្បីអ្នកដែលគេហៅថា "អ្នកមានសីល" ក៏គ្មាន សូម្បីអ្នកដែលគេហៅថា "អ្នកមានបញ្ញា" ក៏គ្មាន ។ សូមថ្វាយព្រះពរ មាតារបស់អ្នកដែលនៅជាកលលៈនៅឡើយនោះ ក៏ជាមនុស្សម្នាក់ផ្សេង មាតារបស់អ្នកដែលជាអព្វុទៈក៏ជាមនុស្សម្នាក់ មាតារបស់អ្នកដែលជាបេសិក៏ជាមនុស្សម្នាក់ មាតា*

របស់អ្នកដែលជាយនៈក៏ជាមនុស្សម្នាក់ផ្សេង មាតារបស់អ្នកដែលជាកុមារតូចក៏ជាមនុស្សម្នាក់ទៀត មាតារបស់កុមារធំក៏ជាមនុស្សម្នាក់ទៀត មនុស្សម្នាក់រៀនវិជ្ជាសិល្បៈ តែអ្នកដែលរៀនចប់វិជ្ជាសិល្បៈជាមនុស្សម្នាក់ផ្សេងទៀត មនុស្សម្នាក់ធ្វើកម្មអាក្រក់ ប៉ុន្តែមនុស្សម្នាក់ផ្សេងទៀត ត្រូវគេកាត់ដៃកាត់ជើង ឬ យ៉ាងណា?"

**ព្រះចៅមិលិន្ទ ៖** " មិនមែនទេ ព្រះគុណម្ចាស់ ពេលខ្ញុំព្រះករុណាពោលទៅហើយយ៉ាងនេះ ( ថា " ទារកតូចនោះក៏ជាមនុស្សម្នាក់ ខ្ញុំព្រះករុណាជាមនុស្សធំនៅពេលនេះក៏ជាមនុស្សម្នាក់ទៀត " ) ខ្លួនព្រះគុណម្ចាស់ផ្ទាល់នឹងពោលថាយ៉ាងដូចម្តេច?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ អាត្មាភាពសូមពោលថា អាត្មាភាព នោះឯងធ្លាប់ជាទារកតូច អាត្មាភាពមនុស្សតែម្នាក់នោះឯង ជាមនុស្សធំនៅពេលនេះ អ្នកទាំងនោះរួមបញ្ចូលគ្នាជាមនុស្សតែមួយបាន ដោយអាស្រ័យកាយតែមួយនេះ"

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ ឧបមាបន្ថែមទៀតផងចុះ"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសខ្វះតាមមើលប្រទីប ប្រទីបនោះនឹងភ្លឺរហូតតទៅ អស់មួយយប់ឬទេ?"

**ព្រះចៅមិលិន្ទ៖** " មែនហើយព្រះគុណម្ចាស់ ប្រទីបអាចភ្លឺរហូតអស់មួយយប់"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ អណ្តាតភ្លើងនៅយាមដំបូងមកជាអណ្តាតភ្លើង ក្នុងយាមកណ្តាលឬ ?"

**ព្រះចៅមិលិន្ទ ៖** " មិនមែនទេ ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " អណ្តាតភ្លើងនៅយាមកណ្តាល មកជាអណ្តាត

*ភ្លើង ក្នុងយាមចុងក្រោយឬ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនមែនទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រទីបក្នុងយាមដំបូង ជាភ្លើងមួយដួងប្រទីបក្នុងយាមកណ្ដាលជាមួយដួងទៀត ប្រទីបក្នុងយាមចុងក្រោយជា មួយដួងទៀត ឬយ៉ាងណា ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនមែនទេ ព្រះគុណម្ចាស់ ពន្លឺប្រទីបដែលភ្លឺរហូតពេញមួយយប់បាន ដោយអាស្រ័យដួងប្រទីបតែមួយនោះឯង "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ធម្មសន្តតិ (ធម៌ដែលបន្តគ្នា) រមែងបន្តគ្នាទៅ មនុស្សម្នាក់កើតឡើង មនុស្សម្នាក់ទៀតរលត់ទៅ បន្តគ្នាទៅ ហាក់ដូចជាមិនមុនមិនក្រោយ ព្រោះហេតុនោះ នឹងជាមនុស្សតែម្នាក់ក៏មិនមែន នឹងជាមនុស្សផ្សេងគ្នាក៏មិនមែន អ្នកមានវិញ្ញាណដួងក្រោយ [១] រមែងដល់សេចក្ដីរួមគ្នា ជាមួយអ្នកមានវិញ្ញាណដួងមុន "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ ឧបមាបន្ថែមទៀតផងចុះ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា ទឹកដោះគោស្រស់ដែលគេច្របាច់ទុក ក្នុងកាលបន្ទាប់មកក៏ក្លាយជាទឹកដោះគោជូរ ពីទឹកដោះគោជូរក៏ក្លាយជាទឹកដោះខាប់ ពីទឹកដោះខាប់ក៏ក្លាយជាទឹកដោះថ្លា ។ មហាបពិត្រ នរណាពោលយ៉ាងនេះថា " ទឹកដោះគោស្រស់មួយណា ទឹកដោះគោជូរគឺមួយនោះ ទឹកដោះគោជូរមួយណា ទឹកដោះខាប់ក៏មួយនោះ ទឹកដោះខាប់មួយណា ទឹកដោះថ្លាក៏មួយនោះ " ដូចនេះ អ្នកដែលពោលយ៉ាងនោះ ហៅថា ពោលត្រឹមត្រូវឬ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនហៅថាពោលត្រឹមត្រូវទេ ព្រះគុណម្ចាស់ គឺ វា*

---

*(១) បាថជា បច្ឆិមវិញ្ញាណំ អដ្ឋកថាជា បច្ឆិមវិញ្ញាណោ*
*បានប្រែតាមអដ្ឋកថា ព្រោះអត្ថន័យត្រូវគ្នាជាង ។*

*ជាអ្វីដែលកើតឡើង ដោយអាស្រ័យទឹកដោះគោស្រស់តែមួយនោះឯង"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ធម្មសន្តតិរមែងបន្តគ្នាទៅ មនុស្សម្នាក់កើតឡើង មនុស្សម្នាក់ទៀតរលត់ទៅបន្តគ្នាទៅ ហាក់ដូចជាមិនមុនមិនក្រោយ ព្រោះហេតុនោះនឹងថាជាមនុស្សតែម្នាក់ក៏មិនមែន នឹងជាមនុស្សផ្សេងគ្នាក៏មិនមែន អ្នកមានវិញ្ញាណដួងក្រោយ រមែងដល់សេចក្ដីរួមគ្នា ជាមួយអ្នកមានវិញ្ញាណដួងមុន "*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់ធម្មសន្តតិបញ្ហាទី ១*

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

*បញ្ហាអំពីធម៌ទាំងឡាយដែលដំណើរទៅបន្តគ្នា ឈ្មោះថា **ធម្មសន្តតិ-បញ្ហា** ។*

*ពាក្យថា **មិនមែនទេ ព្រះគុណម្ចាស់ ទារកតូចនោះក៏ជាមនុស្សម្នាក់ ខ្ញុំព្រះករុណាជាមនុស្សធំពេលនេះ ក៏ជាមនុស្សម្នាក់ទៀត** បានសេចក្ដីថា ក្នុងគ្រាដែលខ្ញុំព្រះករុណានៅជាទារកតូច គ្រានោះរកភាពជាមនុស្សធំដូចពេលនេះ មិនមានឡើយ ។ ក្នុងពេលនេះ ខ្ញុំព្រះករុណាជាមនុស្សធំ ក្នុងពេលនេះ ខ្ញុំព្រះករុណាក៏រកភាពជាទារកតូច មិនមានដែរ ។ ព្រោះហេតុនោះ ទារកតូចនៅគ្រានោះ ក៏ជាមនុស្សម្នាក់ ខ្ញុំព្រះករុណាជាមនុស្សធំ ក្នុងពេលនេះ ក៏ជាមនុស្សម្នាក់ទៀត ។*

ពាក្យថា **សូមថ្វាយព្រះពរ បើដូចនេះ សូម្បីអ្នកដែលបុត្រហៅថា "មាតា" ក៏នឹងគ្មាន ។ល។ សូម្បីអ្នកដែលគេហៅថា "អ្នកមានបញ្ញា" ក៏គ្មាន** បានសេចក្តីថា បើជាមនុស្សផ្សេងគ្នាដូចនេះ សូម្បីអ្នកដែលបុត្រគួរហៅថា មាតាក៏គ្មាន ។ ព្រោះហេតុអ្វី ? ព្រោះក្នុងភពតែមួយ ក្នុងគ្រាដែលនៅជា កលលៈក៏មានមាតាម្នាក់ ពេលភាពជាកលលៈអស់ទៅ ដល់ភាពជាអព្វុទៈក៏ មានមាតាម្នាក់ទៀត ។ ព្រោះក្នុងគ្រានេះ ពេលជាអព្វុទៈក៏មិនមែនបុត្រ របស់អ្នកដែលគ្រាន់តែជា កលលៈ ។ បើដូចនេះ សត្វដែលកើតក្នុងគភ៌គួរ ចាត់ទុកអ្នកណាថា ជាមាតារបស់ខ្លួនទៅ ? ក៏ក្លាយជាថា សូម្បីមាតាក៏គ្មាន ពាក្យដទៃទៀត ក៏គួរជ្រាបក្នុងន័យដូចនេះ ។ ព្រោះហេតុនោះ ទើបលោក ពោលថា **មាតារបស់អ្នកដែលនៅជាកលលៈនៅឡើយនោះ ក៏ជាមនុស្សម្នាក់ ផ្សេង** ដូចនេះ ជាដើម ។

ក្នុងពាក្យថា **មាតារបស់អ្នកដែលនៅជាកលលៈនៅឡើយ** ជាពាក្យ ដែលពោលដល់លំដាប់នៃដំណាក់កាលកកើតនៃអត្តភាពរបស់សត្វ ដោយ យោងទៅតាមភាពរីកលូតលាស់ទៅតាមវ័យ ចាប់ពីបដិសន្ធិរហូតទាល់តែ កើតអវយវៈ មានដៃមានជើង ជាដើមពេញលេញល្អ តាមដែលបានត្រាស់ ទុកថា ៖

បឋមំ កលលំ ហោតិ    កលលា ហោតិ អព្ពុទំ
អព្ពុទា ជាយតេ បេសិ    បេសិ និព្វត្តតី ឃនោ
ឃនា បសាខា ជាយន្តិ    កេសា លោមា នខាបិ ច
យញ្ចស្ស ភុញ្ជតិ មាតា    អន្នំ បានញ្ច ភោជនំ
តេន សោ តត្ថ យាបេតិ    មាតុកុច្ឆិគតោ នរោ [១]

ប្រែថា ៖ ដំបូងកើតជាកលលៈ បន្តពីកលលៈជាអព្វុទៈ បន្តពីអព្វុទៈក៏

---

(១) សំយុត្តនិកាយ សគាថវគ្គ ។

*កើតជាបេសិ បន្តពីបេសិក៏កើតជាឃនៈ បន្តពីឃនៈ ក៏កើតជាបញ្ចសាខា ទាំង សក់ រោម និង ក្រចក ។ ម្យ៉ាងវិញទៀត មាតារបស់សត្វនោះបរិភោគអាហារ គឺ បាយនិងទឹក យ៉ាងណា សត្វដែលនៅក្នុងពោះមាតានោះ រមែងដំណើរទៅក្នុងពោះមាតាដោយអាហារ ដែលមាតាបានបរិភោគនោះ ។*

ក្នុងព្រះគាថានេះ ពាក្យថា ***កលលៈ*** គឺ រូបដែលគ្រាន់តែជាទឹកថ្លា ៗ មាន បរិមាណស្មើនឹងប្រេងល្ងថ្លា ៗ ដែលប្រឡាក់នៅចុងរោមចៀម ។ បន្ទាប់មក ក៏មានបរិមាណច្រើនឡើង និងល្អក់ជាងមុន មានពណ៌ដូចទឹកលាងសាច់ ហៅថា ***អព្វុទៈ*** ។ ចំណែកបេសិ គឺ រូបដែលមានកំណកឡើងជាអន្ទិលជាដុំ ច្រើនហៅថា ដុំឈាម ។ បន្ទាប់ពី ***បេសិ*** នោះ មានវ៉យវឌ្ឍនាការ លូតលាស់តទៅទៀត រហូតក្លាយជាដុំសាច់ ហៅថា ***ឃនៈ*** ។ បន្ទាប់មក ***បញ្ចសាខា*** (សាខា ៥) គឺ ដៃ ២ ជើង ២ ក្បាល ១ ក៏បង្ហាញឡើង រស់នៅដោយអាហារដែលមាតាបរិភោគ ជ្រាបក្នុងខ្លួនមាតា និង អាហារដែលត្រូវបញ្ជូនទៅតាមខ្សែទងផ្ចិត រហូតទាល់តែសម្រាលចេញពីគភ៌មាតា ។

ពាក្យថា ***មនុស្សម្នាក់រៀនវិជ្ជាសិល្បៈ ប៉ុន្តែអ្នកដែលរៀនចប់វិជ្ជាសិល្បៈជាមនុស្សម្នាក់ផ្សេងទៀត*** ជាដើម បានសេចក្តីថា ក្នុងភពតែមួយ អ្នកដែលរៀនសិល្បៈនោះ នៅរៀនមិនទាន់ចប់ ជាមនុស្សម្នាក់ ។ ចំណែកថាពេលណារៀនចប់ហើយ រាប់ចាប់តាំងពីពេលនោះទៅ ក៏មិនត្រូវរៀនទៀត ទើបជាមនុស្សម្នាក់ផ្សេងពីអ្នកដែលរៀនមិនទាន់ចប់ ដោយសារដំណាក់កាលផ្សេងគ្នា ។ ក្នុងភពតែមួយ មនុស្សម្នាក់បានធ្វើកម្មអាក្រក់ទុក អ្នកដែលត្រូវដាក់ទោសកាត់ដៃ កាត់ជើង ព្រោះការធ្វើកម្មអាក្រក់នោះជាបច្ច័យ មិនមែនមនុស្សអ្នកធ្វើកម្មអាក្រក់នោះទេ ព្រោះជាដំណាក់កាលផ្សេងគ្នា

*គឺ ពេលធ្វើមិនត្រូវបានដាក់ទោស ពេលដាក់ទោសមិនបានធ្វើ ។*

*ពាក្យថា **អ្នកទាំងនោះរួមបញ្ចូលគ្នាជាមនុស្សតែមួយបាន ដោយអាស្រ័យកាយតែមួយនេះ** បានសេចក្តីថា ក្មេងនិងមនុស្សធំមានភាពជាមនុស្សតែមួយ ដោយអាស្រ័យការបន្តគ្នានៃធម៌ ( ធម៌សន្តតិ ) ដែលជាប់ទៅបន្តគ្នា នៅក្នុងកាយតែមួយនេះ ។ ពាក្យថា **ដោយអាស្រ័យប្រទីបដួងតែមួយនោះ** គឺ ដោយអាស្រ័យចានក្បៀង ប្រឆេះ ប្រេង ដែលរួមផ្សំគ្នាជាប្រទីបដួងតែមួយនោះ ។*

*ពាក្យថា **មនុស្សម្នាក់កើតឡើង ម្នាក់ទៀតរលត់ទៅ** គឺ ក្នុងធម៌សន្តតិដែលបន្តគ្នា ដោយវោហារហៅថា វ័យ នោះ ។ មនុស្សម្នាក់ គឺ មនុស្សធំ កើតឡើង មនុស្សម្នាក់ទៀត គឺ ក្មេង រលត់ទៅ ។*

*ពាក្យថា **អ្នកមានវិញ្ញាណដួងមុន** លោកពោលសំដៅយកមនុស្សធំ ។*

*ពាក្យថា **អ្នកមានវិញ្ញាណដួងក្រោយ** លោកពោលសំដៅយកមនុស្សក្មេង ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១*

# បញ្ហាទី ២ - បដិសន្ធិហានប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន អ្នកដែលមិនបដិសន្ធិ រមែងដឹងឬថា យើងនឹងមិនបដិសន្ធិ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ពិតមែន អ្នកដែលមិនបដិសន្ធិ រមែងដឹងថា យើងនឹងមិនបដិសន្ធិ "*

**ព្រះចៅមិលិន្ទ ៖** *" ដឹងយ៉ាងដូចម្តេចទៅ ព្រះគុណម្ចាស់ ? "*

**ព្រះនាគសេន ៖** " *ហេតុណា បច្ច័យណា ដែលមានដើម្បីបដិសន្ធិ ព្រោះរម្ងាប់ហេតុនោះ បច្ច័យនោះ ទើបលោកដឹងថា យើងនឹងមិនបដិសន្ធិ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាគហបតី អ្នកស្រែ ភ្ជួរនិងសាបព្រោះរួចហើយ ក៏ធ្វើឱ្យស្រូវពេញជង្រុកបាន សម័យក្រោយមក គេមិនបានភ្ជួរ មិនបានសាបព្រោះ គិតតែពីបរិភោគស្រូវដែលមានខ្លះ ចាយវាយស្រូវខ្លះ ធ្វើឱ្យសមរម្យតាមបច្ច័យខ្លះ ។ សូមថ្វាយព្រះពរ គហបតីអ្នកស្រែម្នាក់នោះ អាចដឹងដែរឬទេថា ជង្រុកស្រូវរបស់យើងនឹងមិនពេញទៀតទេ* "

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន អាចដឹងបាន ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *គេអាចដឹងបានយ៉ាងដូចម្ដេច ?* "

**ព្រះចៅមិលិន្ទ ៖** " *ហេតុណា បច្ច័យណា ដែលមានដើម្បីធ្វើឱ្យជង្រុកស្រូវពេញ ព្រោះបានរម្ងាប់ហេតុនោះបច្ច័យនោះ ទើបដឹងថាជង្រុកស្រូវរបស់ខ្លួន នឹងមិនពេញទៀតទេ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ហេតុណា បច្ច័យណា ដែលមានដើម្បីបដិសន្ធិ ព្រោះបានរម្ងាប់ហេតុនោះ បច្ច័យនោះ ទើបលោកដឹងថា យើងនឹងមិនបដិសន្ធិ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៚

ចប់បដិសន្ធហានបញ្ហាទី ២

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហាស្តីអំពីបដិសន្ធិឈ្មោះថា* ***បដិសន្ធហានបញ្ហា*** *( មិលិន្ទបញ្ហារបស់ថៃជា នបដិសន្ធិគហណជានបញ្ហា - បញ្ហាស្តីអំពីការដឹងថា គ្មានការកាន់យកបដិសន្ធិ ) ។*

*ពាក្យថា* ***ហេតុណា*** *គឺ បច្ច័យមានអវិជ្ជាជាដើម ( អវិជ្ជា តណ្ហា ឧបាទានកម្ម ) ណា ដែលបានឈ្មោះថា ហេតុ(នៃបដិសន្ធិ) ក៏ព្រោះជាអ្នកធ្វើឱ្យកើត ។*

*ពាក្យថា* ***បច្ច័យណា*** *គឺ បច្ច័យផ្សេង ៗ មានផស្សៈ វេទនា សញ្ញា ជាដើម ដែលកើតរួមជាមួយអវិជ្ជាជាដើមនោះ ដែលបានឈ្មោះថា បច្ច័យ (នៃបដិសន្ធិ) ព្រោះជាអ្នកឧបត្ថម្ភ ។*

*ពាក្យថា* ***រមែងមានដើម្បីបដិសន្ធិ*** *គឺ រមែងមានដើម្បីការធ្វើបដិសន្ធិឱ្យកើតឡើងក្នុងភពបន្ទាប់ បន្ទាប់ពីចុតិចិត្តក្នុងវារៈដែលភពនេះបានបញ្ចប់ ។*

*ពាក្យថា* ***ព្រោះបានរម្ងាប់ហេតុនោះ បច្ច័យនោះ*** *បានសេចក្តីថា ព្រោះបានរំលត់ គឺ បញ្ចេញអស់គ្មានសល់នូវហេតុនោះ បច្ច័យនោះដោយអរហត្តមគ្គ ។*

*ពាក្យថា* ***ទើបលោកដឹងថា យើងនឹងមិនបដិសន្ធិ*** *បានសេចក្តីថា ពេលដឹងថា យើងផុតពីការកើតហើយ កិច្ចអ្វីៗដែលយើងត្រូវធ្វើដើម្បីផុតពីការកើតនេះ មិនមានទៀតឡើយ ដូចនេះ ក៏ឈ្មោះថា ដឹងថា យើងនឹងមិនបដិសន្ធិ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - ញាណបញ្ញាបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន អ្នកណាមានញាណកើតឡើងហើយ អ្នកនោះឈ្មោះថា មានបញ្ញាកើតឡើងហើយ ឬយ៉ាងណា ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវ អ្នកណាមានញាណកើតឡើងហើយ អ្នកនោះឈ្មោះថា មានបញ្ញាកើតឡើងហើយ "*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់ ញាណមួយណា បញ្ញាក៏មួយនោះឬ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ពិតមែន ញាណមួយណា បញ្ញាក៏មួយនោះ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ប៉ុន្តែអ្នកណាមានញាណនោះ មានបញ្ញានោះកើតឡើងហើយ គេនោះនៅអាចវង្វេង(គឺមិនដឹង)បាន ឬក៏មិនអាចវង្វេងបាន ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ នៅអាចវង្វេងបានក្នុងរឿងមួយចំនួន មិនអាចវង្វេងបានក្នុងរឿងមួយចំនួន "*

**ព្រះចៅមិលិន្ទ ៖** *" នៅអាចវង្វេងបានក្នុងរឿងអ្វីខ្លះ ព្រះគុណម្ចាស់ ?"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ នៅអាចវង្វេងបានក្នុងវិជ្ជាសិល្បៈដែលមិនធ្លាប់ដឹង ក្នុងទិសដែលមិនធ្លាប់ទៅ ក្នុងឈ្មោះឬបញ្ញត្តិដែលមិនធ្លាប់ឮ "*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចវង្វេងបានក្នុងរឿងអ្វីខ្លះ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ កិច្ចដែលបញ្ញានោះ បានធ្វើរួច*

*ហើយថា មិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី មិនអាចវង្វេងបាន ក្នុងកិច្ចដែលធ្វើរួចហើយ នោះ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ តើភាពវង្វេងរបស់គេទៅណា ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ វេលាគ្រាន់តែញាណកើតឡើងប៉ុណ្ណោះ ភាពវង្វេងក៏រមែងរលត់ទៅក្នុងទីនោះ ៗ ឯង"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាថាបុរសម្នាក់ បានដាក់ប្រទីបក្នុងផ្ទះងងឹត ព្រោះហេតុនោះ ភាពងងឹតក៏រលត់ទៅ ភាពភ្លឺក៏បង្ហាញឡើងយ៉ាងណា សូមថ្វាយព្រះពរ ពេលគ្រាន់តែញាណកើតឡើងប៉ុណ្ណោះ ភាពវង្វេងក៏រមែងរលត់ទៅក្នុងទីនោះ ដូចនោះដែរ "*

**ព្រះចៅមិលិន្ទ ៖** *" ចំណែកបញ្ញានឹងទៅណាដែរ ព្រះគុណម្ចាស់ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ សូម្បីបញ្ញា លុះធ្វើកិច្ចរបស់ខ្លួនរួចហើយ ក៏រមែងរលត់ទៅក្នុងកិច្ច ដែលបានធ្វើរួចនោះឯង ប៉ុន្តែកិច្ចដែលបញ្ញានោះបានធ្វើរួចហើយ ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តីណា កិច្ចដែលបានធ្វើរួចហើយនោះ មិនរលត់ទៅទេ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន ពាក្យដែលលោកបានពោលថា បញ្ញា លុះធ្វើកិច្ចរបស់ខ្លួនរួចហើយ ក៏រមែងរលត់ទៅក្នុងកិច្ច ដែលបានធ្វើរួចនោះឯង ប៉ុន្តែកិច្ចដែលបញ្ញានោះ បានធ្វើរួចហើយ ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី ណា កិច្ចដែលបានធ្វើរួចហើយនោះ មិនរលត់ទៅទេ ដូចនេះ សូមព្រះគុណម្ចាស់ ធ្វើការឧបមាសម្រាប់ពាក្យនោះ ផងចុះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាបុរសម្នាក់ត្រូវការជួលឱ្យគេសរសេរអក្សរនៅពេលយប់ ទើបហៅអ្នកសរសេរមក*

តាំងប្រទីបទុកឱ្យគេសរសេរ ពេលគេសរសេរអក្សររួចរាល់ហើយ ក៏ពន្លត់ប្រទីបនោះ ទោះជាប្រទីបរលត់ទៅហើយក្តី តួអក្សរ (ដែលសរសេររួចហើយ) ក៏មិនវិនាសទៅដែរនោះ យ៉ាងណា ។ សូមថ្វាយព្រះពរ បញ្ញាលុះបានធ្វើកិច្ចរបស់ខ្លួនរួចហើយ ក៏រមែងរលត់ទៅ ក្នុងកិច្ចដែលបានធ្វើរួចហើយនោះឯង ។ ប៉ុន្តែ កិច្ចដែលបញ្ញានោះបានធ្វើរួចហើយ ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី កិច្ចដែលបានធ្វើរួចហើយនោះ ពុំមានរលត់យ៉ាងនោះដែរ"

**ព្រះចៅមិលិន្ទ** ៖ " សូមព្រះគុណម្ចាស់ ឧបមាបន្ថែមទៀតផងចុះ"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាមនុស្សម្នានៅជនបទទិសខាងកើត បានដាក់ពាងទឹកតាមផ្ទះ មួយផ្ទះ ៥ ពាង លើដំបូលទុកពន្លត់ភ្លើង ពេលផ្ទះណាមួយត្រូវភ្លើងឆេះ គេក៏រមែងចាក់ទឹកទាំង ៥ ពាងនោះទៅលើ ផ្ទះ ភ្លើងរមែងរលត់ទៅព្រោះហេតុនោះ ។ សូមថ្វាយព្រះពរ តើមនុស្សទាំងនោះ រមែងកើតគំនិតដូចនេះថា យើងនឹងប្រើពាងទាំង ៥ នោះ ធ្វើកិច្ចដែលគួរធ្វើដោយពាងទៀត ដូចនេះឬទេ ? "

**ព្រះចៅមិលិន្ទ** ៖ " មិនទេ ព្រះគុណម្ចាស់ គ្រប់គ្រាន់ហើយដោយពាងទាំងឡាយ ប្រយោជន៍អ្វីដោយពាងទាំងនោះទៀតទៅ ?"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ គួរឃើញឥន្ទ្រិយ ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ប្រដូចពាងទឹកទាំង ៥ ទៅចុះ ។ គួរឃើញព្រះយោគាវចរ ប្រដូចមនុស្សម្នាទាំងនោះ គួរឃើញកិលេសទាំងឡាយ ប្រដូចភ្លើង ។ មនុស្សម្នាទាំងឡាយ រមែងប្រើទឹកទាំង ៥ ពាង ពន្លត់ភ្លើងយ៉ាងណា ព្រះយោគាវចរក៏រមែងប្រើឥន្ទ្រិយ ៥ រំលត់កិលេសទាំងឡាយ សូម្បីកិលេសទាំងឡាយដែលរលត់ទៅហើយ ក៏រមែងមិន

*កើតទៀត ដូចនោះដែរ សូមថ្វាយព្រះពរ បញ្ញាឈ្មោះថា លុះធ្វើកិច្ចរបស់ខ្លួនរួចហើយ ក៏រមែងរលត់ទៅ ប៉ុន្តែកិច្ចដែលបញ្ញានោះបានធ្វើរួចហើយថា មិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី កិច្ចដែលបានធ្វើរួចហើយនោះ ពុំមានរលត់ទៅទេ តាមប្រការខាងលើមកនេះ"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមាបន្ថែមទៀតផងចុះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា គ្រូពេទ្យកាន់យកគ្រឿងថ្នាំដែលជាឫសឈើ ៥ យ៉ាង ទៅរកអ្នកជំងឺ កិនគ្រឿងថ្នាំដែលជាឫសឈើ ៥ យ៉ាងនោះឱ្យរលាយ ឱ្យអ្នកជំងឺផឹក ទោស(ជំងឺ) ទាំងឡាយនឹងបាត់ទៅ ព្រោះគ្រឿងថ្នាំទាំងនោះ ។ សូមថ្វាយព្រះពរ គ្រូពេទ្យនោះរមែងកើតគំនិតយ៉ាងនេះថា យើងនឹងប្រើគ្រឿងថ្នាំ ដែលជាឫសឈើ ៥ យ៉ាងទាំងនោះ ធ្វើកិច្ចដែលគួរធ្វើដោយថ្នាំទៀត ដូចនេះឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនទេ ព្រះគុណម្ចាស់ គ្រប់គ្រាន់ហើយដោយគ្រឿងថ្នាំ ដែលជាឫសឈើ ៥ យ៉ាងទាំងនោះ ប្រយោជន៍អ្វីដោយគ្រឿងថ្នាំដែលជាឫសឈើ ៥ យ៉ាងទាំងនោះទៀតទៅ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ គួរឃើញឥន្ទ្រិយ ៥ គឺ សទ្ធិន្ទ្រិយ វីរិ-យិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ប្រដូចគ្រឿងថ្នាំដែលជាឫសឈើ ៥ យ៉ាងនោះទៅចុះ ។ គួរឃើញព្រះយោគាវចរប្រដូចគ្រូពេទ្យ គួរឃើញកិលេសទាំងឡាយប្រដូចជំងឺឈឺថ្កាត់ គួរឃើញអ្នកដែលជាបុថុជ្ជនប្រដូចបុរសមានជំងឺ ។ ទោស(ជំងឺ)ទាំងឡាយរបស់អ្នកជំងឺបាត់ទៅ ព្រោះគ្រូពេទ្យប្រើគ្រឿងថ្នាំដែលជាឫសឈើ ៥ យ៉ាង ។ ពេលទោសទាំងឡាយរលត់បាត់ទៅ អ្នកជំងឺក៏ជាសះស្បើយពីជំងឺឈឺថ្កាត់ យ៉ាងណាមិញ ព្រះ*

យោគាវចរក៏រមែងប្រើឥន្ទ្រិយ ៥ ធ្វើកិលេសទាំងឡាយឱ្យរលត់ទៅ កិលេសទាំងឡាយដែលត្រូវរំលត់ហើយនោះ រមែងមិនកើតទៀត ដូចនោះដែរ ។ សូមថ្វាយព្រះពរ បញ្ញាឈ្មោះថា លុះបានធ្វើកិច្ចរបស់ខ្លួនរួចហើយ ក៏រមែងរលត់ទៅក្នុងកិច្ចនោះឯង ប៉ុន្តែកិច្ចដែលបញ្ញានោះបានធ្វើរួចហើយ ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី កិច្ចដែលបានធ្វើរួចហើយនោះ រមែងមិនរលត់ទៅ តាមប្រការដូចពោលខាងលើមកនេះទេ"

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមាបន្ថែមទៀតផងចុះ"

**ព្រះនាគសេនៈ** " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាអ្នកប្រយុទ្ធ ដែលស្ទាត់ជំនាញក្នុងសមរភូមិ ស្រវាយកព្រួញ ៥ ដើម រួចក៏ចុះទៅកាន់សមរភូមិ ដើម្បីយកឈ្នះលើកងទ័ពភាគីម្ខាងទៀត ។ អ្នកប្រយុទ្ធនោះទៅដល់សមរភូមិហើយ ក៏បាញ់ព្រួញ ៥ ដើមនោះ ភាគីម្ខាងទៀតក៏បែកខ្ចាត់ខ្ចាយបរាជ័យ ព្រោះព្រួញទាំងនោះ ។ សូមថ្វាយព្រះពរ អ្នកប្រយុទ្ធដែលស្ទាត់ជំនាញក្នុងសមរភូមិនោះ នឹងកើតគំនិតយ៉ាងនេះថា យើងនឹងប្រើព្រួញ ៥ ដើម ទាំងនោះ ធ្វើកិច្ចដែលគួរធ្វើដោយព្រួញទៀត ដូចនេះឬទេ?"

**ព្រះចៅមិលិន្ទ ៖** " មិនទេ ព្រះគុណម្ចាស់ គ្រប់គ្រាន់ហើយដោយព្រួញ ទាំងនោះ ប្រយោជន៍អ្វីដោយធ្នូទាំងនោះទៀតទៅ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ គួរឃើញឥន្ទ្រិយ ៥ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ប្រដូចព្រួញ ៥ ដើម ។ គួរឃើញ ព្រះយោគាវចរប្រដូចអ្នកប្រយុទ្ធដែលស្ទាត់ជំនាញក្នុងសមរភូមិ ។ គួរឃើញកិលេសទាំងឡាយ ប្រដូចកងទ័ពភាគីម្ខាងទៀត។ កងទ័ពភាគីម្ខាង

*ទៀតបែកខ្ចាត់ខ្ចាយ បរាជ័យទៅ ព្រោះព្រួញ ៥ ដើម យ៉ាងណាមិញ កិលេសទាំងឡាយរមែងបែកខ្ចាត់ខ្ចាយទៅ ព្រោះឥន្ទ្រិយ ៥ ។ កិលេសដែលបែកខ្ចាត់ខ្ចាយហើយ ក៏មិនកើតទៀត ដូចនោះ ។ សូមថ្វាយព្រះពរ បញ្ញាឈ្មោះថា លុះបានធ្វើកិច្ចរបស់ខ្លួនរួចហើយក៏រលត់ទៅក្នុងកិច្ចនោះ នោះឯង ប៉ុន្តែកិច្ចដែលបញ្ញានោះបានធ្វើរួចហើយ ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាជាអនត្តាក្តី កិច្ចដែលបានធ្វើរួចហើយនោះ រមែងមិនរលត់ទៅ តាមប្រការដូចពោលខាងលើមកនេះ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមរម្យហើយ " ៕*

*ចប់ញាណបញ្ញាបញ្ហាទី ៣*

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

*បញ្ហាសួរដល់ញាណនិងបញ្ញា ឈ្មោះថា **ញាណបញ្ញាបញ្ហា** ។*

*ពាក្យថា **អ្នកណាមានញាណកើតឡើង** បានសេចក្តីថា ព្រះយោគាវចរណាមានញាណ គឺ វិបស្សនាញាណ ឬមានមគ្គញាណ ដែលមានវិបស្សនា-ញាណ នោះជាហេតុកើតឡើងហើយ ។ ធម្មជាតិតែមួយ បញ្ញានោះឯងឈ្មោះថា **ញាណ** ដោយអត្ថន័យថា " ដឹងនូវអ្វីដែលគួរដឹង " ឈ្មោះថា **បញ្ញា** ដោយអត្ថន័យថា " ដឹងដោយប្រការទាំងឡាយ " ។*

*ពាក្យថា **អ្នកនោះឈ្មោះថាមានបញ្ញាកើតឡើងហើយ** បានសេចក្តីថា ព្រះយោគាវចរនោះ ឈ្មោះថាមានបញ្ញា គឺ វិបស្សនាបញ្ញា ឬ មានមគ្គបញ្ញា ដែលមានវិបស្សនាបញ្ញានោះ ជាហេតុកើតឡើងហើយ ។*

ពាក្យថា **ក្នុងវិជ្ជាសិល្បៈដែលមិនធ្លាប់ដឹង** បានសេចក្តីថា នៅអាចវង្វេង គឺ នៅអាចមិនដឹងក្នុងវិជ្ជាសិល្បៈទាំងឡាយ ដែលមិនធ្លាប់ដឹងពីមុន ជាការងារសិល្បៈក្នុងផ្លូវលោកក្តី ជាការងារសិល្បៈគឺធម៌និងវិន័យក្តី ព្រោះមិនធ្លាប់បានសន្សំចំណេះដឹងទុក អំពីការរៀននិងការសាកសួរបែបនេះថា "អ្វីទៅ...? យ៉ាងម៉េចទៅ...? យ៉ាងនេះឬទេ...? មិនមែនយ៉ាងនេះឬយ៉ាងណា...?" ជាដើម ក្នុងវិជ្ជាសិល្បៈទាំងនោះ ។

ពាក្យថា **ក្នុងឈ្មោះឬបញ្ញត្តិដែលមិនធ្លាប់បានឮ** បានសេចក្តីថា អ្នកមានញាណឬបញ្ញានោះ នៅជាបុថុជ្ជនក្តី ជាព្រះសេក្ខៈក្តី ឬជាព្រះអរហន្តក្តី ក៏នៅអាចវង្វេង គឺ អាចនៅមិនដឹង ក្នុងឈ្មោះ បញ្ញត្តិ សមញ្ញា វោហារ ភាសា ពាក្យហៅគ្នា ដែលមិនធ្លាប់បានឮ គឺ មិនធ្លាប់បានស្តាប់ពីមុនបែបនេះថា ឈ្មោះថាអ្វី...? ហៅថាអ្វី...? គេនាំគ្នាហៅថាយ៉ាងដូចម្តេច...? យ៉ាងនេះឬ...? មិនមែនយ៉ាងនេះឬ...? ជាដើម។

ពាក្យថា **កិច្ចដែលបញ្ញានោះបានធ្វើរួចហើយ** បានសេចក្តីថា ការដឹងឈ្មោះថា ជាកិច្ចរបស់បញ្ញា ក៏កិច្ចនោះរមែងប្រព្រឹត្តទៅ ដោយប្រការ ២ គឺ ធ្វើលក្ខណៈឱ្យបង្ហាញតាមការពិត ១ លះសេចក្តីវង្វេងដែលបិទបាំងលក្ខណៈទាំងនោះ ១ ។ ក្នុងបញ្ហានេះ ព្រះថេរៈពោលសំដៅយកវិបស្សនាបញ្ញាជាសំខាន់ ( បើជាមគ្គបញ្ញារមែងធ្វើកិច្ច ៤ យ៉ាង ក្នុងបណ្តាកិច្ចនៃអរិយសច្ចៈ ៤ មានការកំណត់ដឹងនូវទុក្ខ ជាដើម) ។

ពាក្យថា **ភាពវង្វេងរមែងរលត់ទៅនៅទីនោះនោះឯង** គឺ សេចក្តីវង្វេងរមែងរលត់ទៅ ក្នុងទីដែលខ្លួនកើត គឺ ក្នុងខ្លួនព្រះយោគាវចរនោះនោះឯង ។

ប្រៀបដូចជា ពេលតាំងប្រទីបក្នុងផ្ទះងងឹត ប្រទីបរមែងញ៉ាំងឱ្យ

ប្រាកដឡើង អ្នកដែលមានភ្នែកល្អ ទើបសម្លឹងឃើញរូបទាំងឡាយបាន ថែមទាំងរមែងកម្ចាត់ភាពងងឹតឱ្យអស់ទៅក្នុងពេលតែមួយ មិនមុនមិនក្រោយគ្នាយ៉ាងណាមិញ ពេលគ្រាន់តែញាណឬបញ្ញាកើតឡើងប៉ុណ្ណោះ ញាណឬបញ្ញាដែលកើតឡើងនោះ រមែងធ្វើលក្ខណៈ មានអនិច្ចលក្ខណៈ ( លក្ខណៈដែលមិនទៀង ) ជាដើម ឱ្យប្រាកដឡើង ។ អ្នកមានបញ្ញាទើបឃើញ ទើបដឹងតាមការពិតថា ប្រការនេះមិនទៀងជាដើម ថែមទាំងរមែងកម្ចាត់ភាពវង្វេងឱ្យអស់ទៅក្នុងពេលតែមួយ មិនមុនមិនក្រោយគ្នា ដូចនោះដែរ ។

ពាក្យថា **កិច្ចដែលបញ្ញានោះ បានធ្វើរួចហើយថា មិនទៀង។ ល។ កិច្ចដែលបានធ្វើរួចហើយនោះ ពុំមានរលត់ទៅទេ** បានសេចក្តីថា កិច្ច ២ យ៉ាង គឺការធ្វើលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ឱ្យប្រាកដឡើង គឺឱ្យឃើញជាក់ច្បាស់ថា ប្រការនេះមិនទៀង ជាដើម ក៏ដោយ ការលះភាពវង្វេងគឺភាពមិនដឹងក៏ដោយ ដែលបញ្ញាបានធ្វើរួចហើយនោះ ឈ្មោះថាពុំមានរលត់ទៅទេ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រសិនបើកិច្ចដែលធ្វើរួចហើយនោះរលត់ទៅដូចបញ្ញានោះ លក្ខណៈដែលប្រាកដរួចហើយ ក៏នឹងវិលត្រឡប់មកមិនប្រាកដឱ្យឃើញ គឺ ត្រូវបិទបាំងទុកដូចដើមទៀត ។ ភាពវង្វេងក៏នឹងវិលត្រឡប់មកទៀត ព្រះយោគាវចរក៏នឹងត្រឡប់មកជាមនុស្ស ដែលមិនដឹងថា ប្រការនេះទៀងឬមិនទៀង ជាដើម ដូចមុនទៀត ។ ប៉ុន្តែ ព្រោះពុំមានវិបរិតត្រឡប់ត្រឡិនយ៉ាងនេះ កិច្ចដែលបញ្ញាបានធ្វើរួចហើយនោះ ទើបឈ្មោះថា មិនរលត់ទៅ ។

ក្នុងឧបមាក្រោយ ៗ មានឧបមាស្តីអំពីពាងទឹក ៥ ពាង ជាដើម ព្រះនាគសេនលើកឡើងមក ជារឿងប្រៀបធៀប ឱ្យឃើញនូវការធ្វើកិច្ច របស់បញ្ញា ដែលដំណើរទៅ ព្រមជាមួយនឹងឥន្ទ្រិយ ៤ យ៉ាង ផ្សេងទៀតមាន

*សទ្ធា ជាដើម ដែលជាបរិវារ ។ ខ្ទឹមសារក្នុងឧបមាទាំងនោះ មានអត្ថន័យរាក់ស្រួលយល់ស្រាប់ហើយ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៣*

# បញ្ហាទី ៤ - បដិសន្ធហានបុគ្គលវេទិយនប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់អង្គណានឹងមិនបដិសន្ធិ ( នឹងមិនកើតក្នុងភពថ្មីតទៅទៀត ) លោកម្ចាស់អង្គនោះនឹងនៅតែសោយទុក្ខវេទនាផ្សេង ៗ ដែរឬទេ ?"*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា " លោកនៅសោយទុក្ខវេទនាខ្លះ និងមិនសោយទុក្ខវេទនាខ្លះ"*

**ព្រះចៅមិលិន្ទ ៖** *" សោយទុក្ខវេទនាអ្វី ? មិនសោយទុក្ខវេទនាអ្វី ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ សោយទុក្ខវេទនាផ្លូវកាយ មិនសោយទុក្ខវេទនាផ្លូវចិត្ត "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ លោកសោយទុក្ខវេទនាផ្លូវកាយយ៉ាងដូចម្ដេច មិនសោយទុក្ខវេទនាផ្លូវចិត្តយ៉ាងដូចម្ដេច ?"*

**ព្រះនាគសេន ៖** *" ហេតុណា បច្ច័យណា រមែងមានដើម្បីការកើតឡើងនៃទុក្ខវេទនាផ្លូវកាយ ព្រោះហេតុនោះ បច្ច័យនោះ នៅមិនទាន់រម្ងាប់ទៅ ទើបលោកនៅសោយទុក្ខវេទនាផ្លូវកាយ ។ ហេតុណា បច្ច័យណា រមែងមានដើម្បីការកើតឡើង នៃទុក្ខវេទនាផ្លូវចិត្ត ព្រោះហេតុនោះ បច្ច័យនោះរម្ងាប់ទៅ ទើបលោកមិនសោយទុក្ខវេទនាផ្លូវចិត្ត ។ សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគ ទ្រង់បានត្រាស់ព្រះភាសិតនេះថា "* **សោ ឯកំ វេទនំ វេទេតិ**

**កាយិកំ ន ចេតសិកំ** – *ភិក្ខុអង្គនោះ រមែងសោយទុក្ខវេទនាផ្លូវកាយតែមួយមុខ មិនសោយទុក្ខវេទនាផ្លូវចិត្ត" ដូចនេះ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន ព្រោះហេតុអ្វីទើបលោកនៅសោយទុក្ខវេទនា ម្ដេចមិនបរិនិព្វានទៅ (ដើម្បីឲ្យមិនបាច់នៅសោយទុក្ខវេទនាផ្លូវកាយនោះដូចនេះ)?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ លោកដែលជាព្រះអរហន្តពុំមានសេចក្ដីរីករាយឬខឹងសម្បាទេ ម៉្យាងវិញទៀត ព្រះអរហន្តទាំងឡាយជាបណ្ឌិត រមែងមិនធ្វើខន្ធ ដែលនៅមិនទាន់ទុំជោរ ឱ្យជ្រុះនោះទេ រមែងរង់ចាំភាពទុំជោរនៅឡើយ ។ សូមថ្វាយព្រះពរ ព្រះធម្មសេនាបតីសារីបុត្តត្ថេរបានភាសិតសេចក្ដីនេះទុកថា ៖*

**នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ** *។ល។*
**កាលញ្ច បដិកង្ខាមិ សម្បជានោ បតិស្សតោ** (១)

*ប្រែថា ៖ យើងមិនរីករាយសេចក្ដីស្លាប់ យើងមិនរីករាយសេចក្ដីរស់ ប៉ុន្តែយើងបានតែរង់ចាំប៉ុណ្ណោះ ដូចដែលអ្នកស៊ីឈ្នួលរង់ចាំថ្ងៃឈ្នួល ដូចនេះ ។ យើងមិនរីករាយសេចក្ដីស្លាប់ យើងមិនរីករាយសេចក្ដីរស់ ប៉ុន្តែយើងមានស្មារតីចំពោះមុខ មានសម្បជញ្ញៈ បានតែរង់ចាំវេលា ប៉ុណ្ណោះ ។*

*ដូចនេះ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់បដិសន្ធហានបុគ្គលវេទិយនបញ្ហាទី ៤*

---

(១) *ខុទ្ទកនិកាយ ថេរគាថា ជាសម្ដីរបស់ព្រះខទិរវនិយរេវតត្ថេរ មិនមែនរបស់ព្រះសារីបុត្តត្ថេរទេ ។*

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

*ឈ្មោះបញ្ហាទី ៤ នេះ ក្នុងអដ្ឋកថាជា* **នប្បដិសន្ធហនបុគ្គលវេទិយនបញ្ហា** *ប្រែថា " បញ្ហាស្តីអំពីការសោយវេទនារបស់បុគ្គលអ្នកដែលមិនបដិសន្ធិ " ដែលគួរតែត្រឹមត្រូវជាង ។*

*ពាក្យថា* **លោកម្ចាស់អង្គណានឹងមិនបដិសន្ធិ?** *បានសេចក្តីថា លោកម្ចាស់ ដែលជាព្រះអរហន្តអង្គណានឹងមិនបដិសន្ធិ? ។*

*ពាក្យថា* **ព្រោះនៅមិនទាន់រម្ងាប់ទៅ** *គឺ ព្រោះនៅមិនទាន់រលត់ទៅ បានសេចក្តីថា ពេលព្រះអរហន្តនៅមានជីវិតនៅឡើយ កាយប្រសាទក៏នៅដំណើរការ នៅមិនទាន់រលត់ទៅ ព្រោះហេតុនោះ ពេលមានផោដ្ឋព្វារម្មណ៍ដែលមិនជាទីប្រាថ្នា ដូចជា ក្តៅពេក ត្រជាក់ពេក រឹងពេក ជាដើម មកទង្គិចកាយ លោកក៏រមែងកើតមានការឈឺចាប់ ពេលមានធាតុភ្លើងមក ប៉ះនឹងផ្ទៃក្រពះក្នុងគ្រាដែលត្រូវបរិភោគអាហារ ប៉ុន្តែមិនទាន់បានបរិភោគ លោកក៏កើតមានភាពស្រេកឃ្លាន ។ នៅពេលទ្រង់កាយក្នុងឥរិយាបថនោះយូរ លោកក៏កើតមានការឈឺរួយស្រពន់យ៉ាងនេះ ជាដើម ។ ការឈឺចាប់ជាដើមដែលកើតឡើង ឈ្មោះថា ទុក្ខវេទនាផ្លូវកាយ ។ ព្រោះហេតុគឺ កាយប្រសាទនៅមិនទាន់រម្ងាប់ ទើបលោកនៅសោយទុក្ខវេទនាទាំងនោះ ។*

*ពាក្យថា* **ព្រោះរម្ងាប់ទៅ** *គឺ ព្រោះរលត់ទៅ សេចក្តីថាទុក្ខវេទនាផ្លូវចិត្តដែលហៅថា ទោមនស្ស មានទោសៈជាហេតុ ក្នុងឋានៈជាឫសកែវ មានធម្មជាតិកើតរួមជាមួយផ្សេង ៗ ទៀត មានផស្សៈ វិតក្ក វិចារ ជាដើម ជាបច្ច័យក្នុងឋានៈជាអ្នកឧបត្ថម្ភ ។ ព្រោះហេតុនិងបច្ច័យទាំងនោះរម្ងាប់រលត់ទៅ គឺត្រូវលះដោយអំណាចនៃមគ្គភាវនា ទុក្ខវេទនាគឺទោមនស្សនោះ ទើបរលត់ទៅ ព្រោះហេតុនោះ ទើបព្រះអរហន្តមិនមានការសោយទុក្ខវេទនាផ្លូវចិត្ត ។*

ក្នុងព្រះគាថា ពាក្យថា **ប៉ុន្តែយើងបានតែរង់ចាំវេលាប៉ុណ្ណោះ** បានសេចក្តីថា យើងបានតែរង់ចាំវេលាមរណៈ ដែលនឹងមកដល់ ប៉ុណ្ណោះ ។

ពាក្យថា **ដូចអ្នកស៊ីឈ្នួលរង់ចាំថ្ងៃឈ្នួល** បានសេចក្តីថា ប្រៀបដូចជាអ្នកស៊ីឈ្នួលរង់ចាំថ្ងៃឈ្នួល គឺ វេលាដែលលាភមកដល់ យ៉ាងណាមិញ យើងក៏រង់ចាំវេលាមរណៈ ដែលនឹងមកដល់ ដូចនោះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៤

# បញ្ហាទី ៥ - វេទនាបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន សុខវេទនាជាកុសល ឬជាអកុសល ឬជាអព្យាកត (មិនមែនទាំងកុសលទាំងអកុសល) ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ សុខវេទនាជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតក៏មាន "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ វេទនាប្រសិនបើជាកុសលក៏រមែងមិនជាទុក្ខ ប្រសិនបើជាទុក្ខក៏រមែងមិនជាកុសល ពាក្យថា "កុសលក៏ជាទុក្ខ" ដូចនេះ ពិបាកស្តាប់ណាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច នៅទីនេះមានបុរសម្នាក់ដាក់ដុំដែកក្តៅលើបាតដៃម្ខាង ដាក់ដុំព្រិលត្រជាក់លើបាតដៃម្ខាងទៀត សូមថ្វាយព្រះពរ បាតដៃរបស់គេត្រូវឆេះខ្លោចទាំងសងខាងឬយ៉ាងណា ? "

**ព្រះចៅមិលិន្ទ ៖** " ពិតមែន ព្រះគុណម្ចាស់ បាតដៃរបស់គេត្រូវឆេះខ្លោចទាំងសងខាង "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ បាតដៃរបស់គេក្តៅទាំងសងខាងឬ?* "

**ព្រះចៅមិលិន្ទ ៖** " *មិនមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប៉ុន្តែបាតដៃរបស់គេ ត្រជាក់ទាំងសងខាងឬ?* "

**ព្រះចៅមិលិន្ទ ៖** " *មិនមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមទ្រង់ជ្រាបផងថា បន្ទូលរបស់ព្រះអង្គត្រូវអាត្មាភាពចាប់ចំណុចខ្សោយបាន ។ ប្រសិនបើដុំដែកក្តៅប៉ុណ្ណោះ អាចដុតកម្ទេចបាន ប៉ុន្តែបាតដៃរបស់គេមិនបានក្តៅទាំងសងខាង ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះអង្គ ( ដែលថា " ពិតមែន ព្រះគុណម្ចាស់ បាតដៃរបស់គេត្រូវឆេះខ្ទេចទាំងសងខាង " ) រមែងពិបាកស្តាប់ណាស់ ។ ប្រសិនបើដុំព្រិលត្រជាក់ប៉ុណ្ណោះ អាចដុតកម្ទេចបាន ប៉ុន្តែបាតដៃរបស់គេមិនបានត្រជាក់ទាំងសងខាង ។ ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះអង្គរមែងពិបាកស្តាប់ ។ សូមថ្វាយព្រះពរ បាតដៃរបស់គេឆេះខ្ទេចទាំងសងខាងយ៉ាងដូចម្តេច ? ព្រោះថា បាតដៃរបស់គេមិនបានក្តៅទាំងសងខាង និងមិនបានត្រជាក់ទាំងសងខាងបាតដៃម្ខាងក្តៅ បាតដៃម្ខាងត្រជាក់ ក៏ប៉ុន្តែដៃទាំងពីរត្រូវឆេះខ្ទេច ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះអង្គរមែងពិបាកស្តាប់* "

**ព្រះចៅមិលិន្ទ ៖** " *ខ្ញុំព្រះករុណាមិនមានសមត្ថភាពគ្រប់គ្រាន់នឹងឆ្លងឆ្លើយជាមួយព្រះគុណម្ចាស់ ដែលជាកំពូលវាទៈបាននោះទេ សូមព្រះគុណម្ចាស់ មេត្តាអធិប្បាយផងចុះ* "

*បន្ទាប់ពីនោះ* **ព្រះថេរៈ** *ក៏បានថ្វាយវិសជ្ជនា ធ្វើឱ្យព្រះចៅមិលិន្ទឱ្យទ្រង់បានយល់ ដោយសម្ដីដែលប្រកបដោយអភិធម្ម យ៉ាងនេះថា ៖*

*" សូមថ្វាយព្រះពរ មហាបពិត្រ គេហនិស្សិតសោមនស្ស ( សោមនស្សអាស្រ័យផ្ទះ ) មាន ៦ យ៉ាងទាំងនេះ,នេក្ខម្មនិស្សិតសោមនស្ស ( សោមនស្សអាស្រ័យនេក្ខម្មៈ) ក៏មាន ៦ យ៉ាង, គេហនិស្សិតទោមនស្ស(ទោមនស្សអាស្រ័យផ្ទះ) ក៏មាន ៦ យ៉ាង, នេក្ខម្មនិស្សិតទោមនស្ស (ទោមនស្សអាស្រ័យនេក្ខម្មៈ) ក៏មាន ៦ យ៉ាង, គេហនិស្សិតឧបេក្ខា (ឧបេក្ខាអាស្រ័យផ្ទះ) ក៏មាន ៦ យ៉ាង, នេក្ខម្មនិស្សិតឧបេក្ខា(ឧបេក្ខាអាស្រ័យនេក្ខម្មៈ)ក៏មាន ៦ យ៉ាង ។ វេទនាមាន ៦ ជំពូកទាំងនេះ វេទនាជាអតីតក៏មាន ៣៦ វេទនាជាអនាគតក៏មាន ៣៦ វេទនាជាបច្ចុប្បន្នក៏មាន ៣៦ ដែរ ។ សរុបវេទនាទាំងអស់នោះចូលគ្នាមានវេទនា ១០៨ " ជាដើម ។*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់វេទនាបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាទាក់ទងនឹងវេទនា ឈ្មោះថា* ***វេទនាបញ្ហា*** *។*

*ព្រះដ៏មានព្រះភាគត្រាស់ថា "* **វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ** [១] *- វេទនា សុខក៏ដោយ ទុក្ខក៏ដោយ អទុក្ខមសុខក៏ដោយ វេទនាទាំងនោះ ក៏ជាទុក្ខ " ដូចនេះ មានសេចក្ដីថា វេទនាគ្រប់យ៉ាងជាសេចក្ដីទុក្ខ ។*

---

[១] *សំយុត្តនិកាយ. សឡាយតនវគ្គ ។*

*ពិតដូចនោះ សុខវេទនា ក៏ចាត់ថាជាទុក្ខ ព្រោះជា **វិបរិណាមទុក្ខ** (ទុក្ខ គឺ សភាពដែលប្រែប្រួលទៅ គឺ រលត់ទៅអស់ទៅ ព្រោះជារបស់មិនទៀង) ។ ទុក្ខវេទនា ក៏ចាត់ថាជាទុក្ខ ព្រោះជា **ទុក្ខទុក្ខ** (ទុក្ខ គឺ សភាវៈដែលសត្វទាំងឡាយពិបាកទ្រាំ) ។ ឧបេក្ខាវេទនាក៏ចាត់ថាជាទុក្ខ ព្រោះជា **សង្ខារទុក្ខ** (ទុក្ខ គឺ សភាពដែលសង្ខារទាំងឡាយ ត្រូវគាបសង្កត់ ដោយការកើតឡើង និងការរលត់ទៅ) ។ វេទនាទាំងឡាយផ្សេង ៗ ដែលបែកចេញដោយជាតិ ដោយភូមិ ជាដើម បានជាច្រើនទាំងអស់នោះ ចាត់ចូលក្នុងវេទនា ៣ យ៉ាងទាំងនេះ ។ ព្រោះហេតុនោះ វេទនាទាំងឡាយទាំងពួង សុទ្ធតែជាទុក្ខវេទនា ទោះជាកុសលក៏ជាទុក្ខ ពោល គឺ សុខវេទនាដែលជាកុសល រមែងជាវិបរិណាមទុក្ខ យ៉ាងនេះ ជាដើម ។*

*ព្រះចៅមិលិន្ទទ្រង់ធ្វើទុកក្នុងព្រះទ័យយ៉ាងនេះថា " វេទនា ប្រសិនបើជា អកុសល ពោលថា ជាទុក្ខ ក៏សមរម្យនឹងស្តាប់បាន ព្រោះជារបស់មិនជាទីប្រាថ្នា ។ ប៉ុន្តែវេទនាប្រសិនបើជាកុសល ដែលជាសភាពបដិបក្ខចំពោះអកុសលគ្រប់យ៉ាង ការដែលពោលថា ជាទុក្ខ ដូចគ្នានឹងអកុសលនោះទៀតនេះ មិនគួរឱ្យស្តាប់ឡើយ " ដូចនេះ ទើបត្រាស់ថា " **ពាក្យថា កុសលក៏ជាទុក្ខដូចនេះ ពិបាកស្តាប់ណាស់** " ដូចនេះ ។*

*ពាក្យថា **ប្រសិនបើដុំដែកក្តៅប៉ុណ្ណោះ អាចដុតកម្ទោចបាន ប៉ុន្តែបាតដៃរបស់គេមិនបានក្តៅទាំងសងខាង** បានសេចក្តីថាប្រសិនបើដុំដែកក្តៅប៉ុណ្ណោះ អាចមានសមត្ថភាពដុតកម្ទោចបាន ហើយដុំព្រិលមិនអាចមានសមត្ថភាពដុតកម្ទោចបាននោះ ប៉ុន្តែបាតដៃរបស់គេមិនបានក្តៅទាំងសងខាង ព្រោះម្ខាងទៀតមានដុំព្រិលដាក់នៅលើបាតដៃ ព្រោះហេតុអ្វីបានជាដៃដែលមានដុំព្រិលដាក់ពីលើនោះ ក៏ឆេះខ្លោចដូចគ្នា ? ។*

*ពាក្យថា **ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះអង្គរមែងពិបាកស្តាប់** បានសេចក្តីថា ព្រោះហេតុនោះ ព្រះតម្រាស់របស់ព្រះអង្គដែលថា " ពិតមែន ព្រះគុណម្ចាស់ បាតដៃរបស់គេ ត្រូវឆេះខ្លោចទាំងសងខាង " ដូចនេះ រមែងពិបាកស្តាប់ ព្រោះកាលណាដៃដែលមានរបស់ក្តៅដាក់ពីលើទើបត្រូវឆេះខ្លោចបាន បើដូចនេះ ដៃដែលមានរបស់ត្រជាក់ដាក់ពីលើ ក៏មិនគួរនឹងឆេះខ្លោចទៅដែរនោះទេ ។ ចំណែក ពាក្យថា ប្រសិនបើដុំព្រិលប៉ុណ្ណោះអាចដុតកម្មោចបាន ជាដើម គួរជ្រាបតាមអត្ថន័យដូចពោលខាងលើ ។*

*បណ្ឌិតគួរជ្រាបការប្រៀបធៀបដោយឧបមាយ៉ាងនេះថា ប្រៀបបីដូចដុំដែកក្តៅ និងដុំព្រិលត្រជាក់ ទោះជាមានចំណែកខុសគ្នា ដោយលក្ខណៈដែលក្តៅ និងត្រជាក់ ។ ទោះជាយ៉ាងនោះក្តី ពេលដាក់លើដៃម្ខាង ៗ វត្ថុទាំងនោះក៏ឈ្មោះថា មានចំណែកដូចគ្នា ដោយការដុតកម្មោចឱ្យឆេះខ្លោចបានដូចគ្នា ។ យ៉ាងណាមិញ កុសលវេទនា និង អកុសលវេទនា ទោះជាមានចំណែកខុសគ្នាដោយជាតិ គឺ កុសល និងអកុសល ទោះជាយ៉ាងនោះក្តីវេទនាទាំង ២ នេះ មានឈ្មោះថា មានចំណែកដូចគ្នាដែរ សុទ្ធតែជាសេចក្តីទុក្ខ រកសុខឬសារៈប្រយោជន៍អ្វីក៏មិនមាន ដូចនោះដែរ។*

*ពាក្យថា **សូមថ្វាយព្រះពរ គេហនិស្សិតសោមនស្សមាន ៦ យ៉ាង ទាំងនេះ** បានសេចក្តីថា សោមនស្សដែលកើតឡើង ចំពោះបុគ្គលដែលបានឥដ្ឋារម្មណ៍ (អារម្មណ៍ដែលគួរឱ្យប្រាថ្នា) មាន ៦ យ៉ាង គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម៌ ដែលគួរឱ្យស្រឡាញ់ គួរឱ្យពេញចិត្ត គួរឱ្យចូលចិត្ត ឬទោះជាមិនទាន់បាន ប៉ុន្តែសង្ឃឹមថានឹងបាន ឬទោះជានឹកដល់ឥដ្ឋារម្មណ៍ដែលធ្លាប់បាន ដែលរលត់ទៅហើយក្តី ឈ្មោះថា **គេហនិស្សិតសោមនស្ស** មាន ៦ យ៉ាង តាមអារម្មណ៍ទាំងនោះឯង ជាសោមនស្សអាស្រ័យកាម*

គុណកើតឡើងដោយពាក្យថា " **គេហៈ-ផ្ទះ** " នៅទីនេះ ជាឈ្មោះហៅ កាមគុណ ទាំងឡាយ ។

សោមនស្សកើតឡើងចំពោះបុគ្គល ដែលឃើញដោយបញ្ញាដ៏ត្រឹមត្រូវថា អារម្មណ៍ ៦ មានរូបជាដើមទាំងនោះ មិនទៀង មានការប្រែប្រួល មានការរសាយទៅ មានការរលត់ទៅជាធម្មតា រួចរីករាយសប្បាយចិត្តថា " យើងនឹងផុតពីជរា មរណៈ ពីទុក្ខទាំងពួង ដោយបដិបទាដែលយើងបានបំពេញនេះ យើងហ្ន៎ យើងជាអ្នកមានចំណែកដឹងនូវធម៌ ឃើញនូវធម៌ ដែលព្រះអរិយជាម្ចាស់ទាំងឡាយ ដឹងហើយ ឃើញហើយនោះហ្ន៎ " ដូចនេះ ឈ្មោះថា **នេក្ខម្មនិស្សិតសោមនស្ស** ។ ក្នុងទីនេះ លោកហៅកុសលគ្រឿងចេញពីកាម គឺ វិបស្សនាបញ្ញាថា " **នេក្ខម្មៈ** " ។

ទោមនស្សកើតឡើងចំពោះបុគ្គលជួបអនិដ្ឋារម្មណ៍ ( អារម្មណ៍ដែលមិនគួរឱ្យប្រាថ្នា ) មានរូបដែលមិនស្អាត មិនប្រណីត មិនគួរឲ្យស្រឡាញ់ មិនគួរឱ្យចូលចិត្ត ជាដើម ឈ្មោះថា **គេហនិស្សិតទោមនស្ស** ។

ទោមនស្សកើតឡើងចំពោះបុគ្គលធ្វើវិបស្សនាបញ្ញា ឱ្យកើតឡើងបានឃើញ ដោយបញ្ញាដ៏ត្រឹមត្រូវថា អារម្មណ៍ ៦ មានរូបជាដើមទាំងនោះ ជារបស់មិនទៀង ជាដើម ។ ប៉ុន្តែ ពេលមិនអាចធ្វើបញ្ញាឱ្យឈានទៅមុខរហូតសម្រេចមគ្គផលបាន ទោះជាអាស្រ័យពេលវេលាដ៏យូរលង់ទៅហើយក្តី ក៏រមែងមិនសប្បាយចិត្ត សោកសៅ កើតទុក្ខ ថា " ច្បាស់ជាយើងមិនអាចទៅកាន់អរិយភូមិក្នុងអត្តភាពនេះ ជាមិនខាន យើងត្រូវស្លាប់ទៅ ទាំងនៅជាបុថុជ្ជន " ដូចនេះ ឈ្មោះថា **នេក្ខម្មនិស្សិតទោមនស្ស** ។

គួរជ្រាប គេហនិស្សិតឧបេក្ខា និង នេក្ខម្មនិស្សិតឧបេក្ខា ក្នុងគ្រាដែលប្រារព្ធឥដ្ឋារម្មណ៍មជ្ឈិម ឬ សូម្បីអនិដ្ឋារម្មណ៍មជ្ឈិម តាមន័យដូច

ពោលខាងលើ ។ មានប្រការខុសគ្នា គ្រាន់តែនោះជាសោមនស្ស ឬទោមនស្ស ប៉ុន្តែនេះជាឧបេក្ខា ។ វេទនានេះលោកហៅថា ឧបេក្ខា ក៏ព្រោះមានភាពព្រងើយ មិនសុខ មិនទុក្ខ មិនត្រេកអរ មិនកើតទុក្ខក្នុងអារម្មណ៍ទាំងឡាយ ។ គេហនិស្សិតសោមនស្សមាន ៦ យ៉ាង តាមអារម្មណ៍ដែលមាន ៦ យ៉ាង យ៉ាងណា ទោះជាវេទនា ៥ យ៉ាងទៀត មាននេក្ខម្មនិស្សិតសោមនស្ស ជាដើម ក៏យ៉ាងនោះដែរ ។

ព្រោះហេតុនោះ ទើបសរុបជាវេទនា ៣៦ យ៉ាង ជាអតីត ៣៦ ជាអនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ ទើបសរុបជាវេទនា ១០៨ យ៉ាង ដូចនេះ" ។

ចប់ពាក្យអធិប្បាយបញ្ហាទី ៥

# បញ្ហាទី ៦ - នាមរូបឯកត្តនានត្តបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន នរណាបដិសន្ធិ ? "

**ព្រះថេរៈ** ថ្វាយវិសជ្ជនាថា " សូមថ្វាយព្រះពរ មហាបពិត្រ គឺ នាមរូបបដិសន្ធិ "

**ព្រះចៅមិលិន្ទ ៖** " នាមរូបនេះ ឬ បដិសន្ធិ ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មិនមែននាមរូបនេះទេ ដែលបដិសន្ធិ សូមថ្វាយព្រះពរ បុគ្គលរមែងធ្វើកម្មល្អខ្លះ អាក្រក់ខ្លះ ដោយសារនាមរូបនេះ ទើបនាមរូបផ្សេងបដិសន្ធិ ព្រោះកម្មនោះ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ប្រសិនបើនាមរូបនេះមិនបានបដិសន្ធិទេ បុគ្គលនោះនឹងជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន មិនថាអ៊ីចឹងឬ ? "

**ព្រះថេរៈ** ថ្វាយវិសជ្ជនាថា " ប្រសិនបើនាមរូបមិនអាចបដិសន្ធិបាន គេគួរតែជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយ ។ សូមថ្វាយព្រះពរ តែដោយហេតុថា នាមរូបរមែងបដិសន្ធិ ព្រោះហេតុនោះ គេមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបានឡើយ "

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ប្រៀបដូចជាបុរសម្នាក់លួចផ្លែស្វាយរបស់បុរសម្នាក់ទៀត បុរសជាម្ចាស់ស្វាយទើបចាប់ខ្លួនបុរសនោះ ហើយនាំចូលគាល់ព្រះរាជា ក្រាបទូលថា " ក្រាបទូល ព្រះអង្គទ្រង់ជាសម្មតិទេព នាយម្នាក់នេះលួចផ្លែស្វាយរបស់ទូលបង្គំ ក្រាបទូល " ។ បុរសអ្នកលួចផ្លែស្វាយនោះទើបក្រាបទូលថា " ក្រាបទូល ព្រះអង្គទ្រង់ជាសម្មតិទេព ទូលបង្គំមិនបានលួចផ្លែស្វាយរបស់នាយម្នាក់នេះទេ ផ្លែស្វាយដែលនាយម្នាក់នេះដាំ ( រហូតដុះឡើងមកជាដើមស្វាយ នាពេលក្រោយ ) ជាផ្លែស្វាយផ្សេង រីឯផ្លែស្វាយដែលទូលបង្គំបេះមក ជាផ្លែស្វាយផ្សេងទៀតទេតើ ទូលបង្គំមិនគួរជាអ្នកត្រូវទទួលទោសទេ ក្រាបទូល " ដូចនេះ ។ សូមថ្វាយព្រះពរ បុរសជាអ្នកលួចផ្លែស្វាយនោះ គួរជាអ្នកត្រូវទទួលទោស ឬយ៉ាងណា ? "

**ព្រះចៅមិលិន្ទ ៖** " ពិតមែន ព្រះគុណម្ចាស់ គេគួរតែជាអ្នកទទួលទោស "

**ព្រះនាគសេន ៖** " ព្រោះហេតុអ្វីឬ ? "

**ព្រះចៅមិលិន្ទ ៖** " បុរសជាអ្នកលួចផ្លែស្វាយនោះ អាចពោលយ៉ាងនេះបាន ក៏ពិតមែន ព្រះគុណម្ចាស់ បុរសនោះនិយាយទម្លាក់ទៅផ្លែស្វាយមុនមិនបានទេ គេគួរតែជាអ្នកត្រូវទទួលទោស ព្រោះផ្លែស្វាយក្រោយ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏

*យ៉ាងនោះដែរ បុគ្គលរមែងធ្វើកម្មល្អខ្លះអាក្រក់ខ្លះដោយសារនាមរូបនេះ ទើបនាមរូបផ្សេងបដិសន្ធិព្រោះកម្មនោះ ព្រោះហេតុនោះ ទើបមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន ”*

**ព្រះចៅមិលិន្ទ ៖** *“ សូមព្រះគុណម្ចាស់ ធ្វើការឧបមាបន្ថែមបន្តិចទៀតផងចុះ ”*

**ព្រះនាគសេន ៖** *“ សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា បុរសម្នាក់លួចស្រូវសាលីរបស់បុរសម្នាក់ទៀត ។ល។ លួចអំពៅរបស់បុរសម្នាក់ទៀត ។ល។*

*សូមថ្វាយព្រះពរ ប្រៀបដូចជា នារដូវរងាបុរសម្នាក់បង្កាត់ភ្លើង អាំងភ្លើង មិនទាន់បានពន្លត់ ខ្លួនក៏ដើរទៅ(កន្លែងផ្សេង)បាត់ ភ្លើងនោះបានឆេះស្រែរបស់បុរសម្នាក់ទៀត ។ បុរសអ្នកដែលជាម្ចាស់ស្រែ ទើបចាប់ខ្លួនបុរសនោះ ហើយនាំចូលគាល់ព្រះរាជា ក្រាបទូលថា “ ក្រាបទូល ព្រះអង្គទ្រង់ជាសម្មតិទេព នាយម្នាក់នេះដុតស្រែរបស់ទូលបង្គំ ក្រាបទូល ” បុរសអ្នកបង្កាត់ភ្លើងនោះ ទើបក្រាបទូលថា “ ក្រាបទូល ព្រះអង្គទ្រង់ជាសម្មតិទេព ទូលបង្គំមិនបានដុតស្រែរបស់នាយម្នាក់នេះទេ ព្រោះភ្លើងដែលទូលបង្គំមិនទាន់បានពន្លត់ជាភ្លើង មួយ រីឯភ្លើងដែលឆេះស្រែរបស់នាយម្នាក់នេះ ជាភ្លើងមួយទៀត ទូលបង្គំមិនគួរជាអ្នកត្រូវទទួលទោសទេ ក្រាបទូល ” ដូចនេះ សូមថ្វាយព្រះពរ បុរសអ្នកបង្កាត់ភ្លើងនោះ គួរជាអ្នកត្រូវទទួលទោស ឬយ៉ាងណា ? ”*

**ព្រះចៅមិលិន្ទ ៖** *“ ពិតមែន ព្រះគុណម្ចាស់ គេគួរតែជាអ្នកទទួលទោស ”*

**ព្រះនាគសេន ៖** *“ តើព្រោះហេតុអ្វី ? ”*

**ព្រះចៅមិលិន្ទ ៖** " *បុរសអ្នកដុតភ្លើងនោះអាចពោលយ៉ាងនេះបានក៏ពិតមែន ព្រះគុណម្ចាស់ បុរសនោះនិយាយទម្លាក់ទៅភ្លើងមុនមិនបានទេ បុរសនោះត្រូវជាអ្នកទទួលទោសដោយសារភ្លើងក្រោយ* "

**ព្រះនាគសេន ៖** " *ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ បុគ្គលរមែងធ្វើកម្មល្អខ្លះ កម្មអាក្រក់ខ្លះ ដោយសារនាមរូបនេះ ទើបនាមរូបផ្សេងបដិសន្ធិដោយសារកម្មនោះ ព្រោះហេតុនោះ ទើបមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ ធ្វើការឧបមាបន្ថែមបន្តិចទៀតផងចុះ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចជាបុរសម្នាក់កាន់ប្រទីបឈានឡើងលើប្រាសាទ(ផ្ទះ)រួចបរិភោគអាហារ ប្រទីបដែលឆេះនោះក៏ទៅឆាបឆេះស្បូវ ស្បូវដែលឆេះនោះ ក៏ទៅឆាបឆេះផ្ទះ ផ្ទះដែលឆេះនោះក៏ទៅឆាបឆេះផ្ទះជាច្រើន ។ ពួកអ្នកស្រុកទើបធ្វើការចាប់ខ្លួនបុរសនោះហើយពោលសួរយ៉ាងនេះថា " នាយអើយ ហេតុអ្វីទើបនាយដុតផ្ទះជាច្រើនដូចនេះ ?* " *បុរសនោះទើបពោល(តបទៅអ្នកស្រុក) យ៉ាងនេះថា* " *នាយអើយ ខ្ញុំមិនបានដុតផ្ទះទាំងនោះទេ ភ្លើងប្រទីបដែលខ្ញុំបានអាស្រ័យពន្លឺហូបបាយជាភ្លើងមួយ រីឯភ្លើងដែលឆេះផ្ទះទាំងនោះជាភ្លើងមួយទៀត* " *ដូចនេះអ្នកទាំងនោះឈ្លោះគ្នារួច ក៏នាំគ្នាមកកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ សូមថ្វាយព្រះពរ ព្រះអង្គទ្រង់នឹងចាត់ការទទួលពាក្យបណ្ដឹងរបស់អ្នកណា ?* "

**ព្រះចៅមិលិន្ទ ៖** " *របស់អ្នកស្រុក ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *ព្រោះហេតុអ្វីឬ ?* "

**ព្រះចៅមិលិន្ទ** ៖ *" បុរសនោះអាចពោលយ៉ាងនេះបានក៏ពិតមែន ប៉ុន្តែភ្លើង (ដែលឆេះផ្ទះជាច្រើន)នោះ កើតពីភ្លើងប្រទីបនោះឯង "*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាង នោះដែរ នាមរូបមុននឹងស្លាប់ (ក្នុងភពមុន) ជាចំណែកមួយ រីឯនាមរូបគ្រាបដិសន្ធិក៏ជាចំណែកមួយទៀត ។ ប៉ុន្តែនាមរូប (ក្នុងគ្រាបដិសន្ធិ) នោះ ក៏កើតពីនាមរូបមុនស្លាប់នោះឯង ។ ព្រោះហេតុនោះ ទើបមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន "*

**ព្រះចៅមិលិន្ទ** ៖ *" សូមព្រះគុណម្ចាស់ ធ្វើការឧបមាបន្ថែមបន្តិចទៀតផងចុះ "*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសម្នាក់បានស្ដីដណ្ដឹងក្មេងស្រីម្នាក់ ភ្ជាប់ពាក្យរួចហើយ ក៏ទៅបាត់ ។ សម័យបន្ទាប់មកក្មេងស្រីនោះធំពេញវ័យ បន្ទាប់មកក៏មានបុរសម្នាក់ទៀត មកស្ដីដណ្ដឹងរួចរៀបអាពាហ៍ពិពាហ៍ ។ បុរសម្នាក់មុនបានត្រឡប់មកវិញ រួចពោលយ៉ាងនេះថា " នែ៎ ! នាយអើយ ព្រោះហេតុអ្វីទើបនាយនាំកិរិយារបស់ខ្ញុំទៅ យ៉ាងនេះ ? " ដូចនេះ ។ បុរសម្នាក់ក្រោយនោះ ទើបពោលយ៉ាងនេះថា " ខ្ញុំមិនបាននាំកិរិយារបស់នាយទៅទេ ក្មេងស្រីវ័យជំទង់ ដែលនាយស្ដីដណ្ដឹង និងភ្ជាប់ពាក្យទុកនោះ ជាមនុស្សម្នាក់ ក្មេងស្រីដែលធំពេញវ័យ ហើយដែលខ្ញុំស្ដីដណ្ដឹង និងភ្ជាប់ពាក្យហើយនេះ ក៏ជាមនុស្សម្នាក់ទៀត " ដូចនេះ អ្នកទាំងពីរនោះឈ្លោះគ្នា រួចក៏នាំគ្នាមកកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ សូមថ្វាយព្រះពរ ព្រះអង្គទ្រង់នឹងទទួលពាក្យបណ្ដឹងរបស់អ្នកណា ? "*

**ព្រះចៅមិលិន្ទ** ៖ *" របស់បុរសម្នាក់មុន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន** ៖ *" ព្រោះហេតុអ្វី ? "*

**ព្រះចៅមិលិន្ទ ៖** " *បុរសទី ២ នោះ អាចពោលយ៉ាងនេះបានក៏ពិតមែន ប៉ុន្តែស្ត្រីដែលពេញវ័យនោះ ក៏កើតចេញពីក្មេងស្រីនោះឯង* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ នាមរូបមុននឹងស្លាប់ជាចំណែកមួយ រីឯនាមរូបក្នុងគ្រាបដិសន្ធិក៏ជាចំណែកមួយទៀតពិតមែន ប៉ុន្តែនាមរូបក្នុងគ្រាបដិសន្ធិនោះ ក៏កើតពីនាមរូបមុនស្លាប់នោះឯង ព្រោះហេតុនោះ ទើបមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមាបន្ថែមបន្តិចទៀតផងចុះ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា បុរសម្នាក់ ទិញទឹកដោះគោឆៅមួយឆ្នាំង ពីដៃអ្នកចិញ្ចឹមគោ ផ្ញើឆ្នាំងទឹកដោះគោនៅក្នុងដៃអ្នកចិញ្ចឹមគោនៅឡើយ ( នៅមិនទាន់ទទួលយកទៅ ) ពោលថា "ស្អែកនេះ ខ្ញុំនឹងមកទទួលយកទៅ " ដូចនេះហើយ ក៏ទៅបាត់ ។ ថ្ងៃបន្ទាប់មក ទឹកដោះគោឆៅមួយឆ្នាំងនោះ ក៏ក្លាយជាទឹកដោះគោជូរ ។ បុរសម្នាក់នោះត្រឡប់មកវិញ រួចពោលយ៉ាងនេះថា " ចូរយកឆ្នាំងទឹកដោះគោឆៅមកឱ្យយើង " ដូចនេះ អ្នកចិញ្ចឹមគោក៏ប្រគល់ទឹកដោះគោជូរឱ្យទៅ ។ បុរសម្នាក់មុននេះពោលយ៉ាងនេះថា "ខ្ញុំមិនបានទិញទឹកដោះគោជូរពីដៃរបស់នាយទេ ចូរយកឆ្នាំងទឹកដោះគោឆៅមកឱ្យខ្ញុំ " ដូចនេះ ។ នាយចិញ្ចឹមគោនោះ ទើបពោលយ៉ាងនេះថា " ទឹកដោះគោឆៅរបស់លោក មិនដឹងមកពីអ្វីក៏ក្លាយជាទឹកដោះគោជូរទៅហើយ " អ្នកទាំងពីរឈ្លោះគ្នា រួចក៏នាំគ្នាមកកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ សូមថ្វាយព្រះពរ ព្រះអង្គទ្រង់នឹងទទួលពាក្យបណ្ដឹងរបស់អ្នកណា ?* "

**ព្រះចៅមិលិន្ទ ៖** " *របស់អ្នកចិញ្ចឹមគោ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *ព្រោះហេតុអ្វីឬ?* "

**ព្រះចៅមិលិន្ទ ៖** " *បុរសនោះអាចពោលយ៉ាងនេះបានក៏ពិតមែន ប៉ុន្តែ ទឹកដោះគោជូរនោះ គឺ កើតពីទឹកដោះគោឆៅនោះឯង* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ នាមរូបមុននឹងស្លាប់ជាចំណែកមួយ រីឯនាមរូបក្នុងគ្រាបដិសន្ធិក៏ជាចំណែកមួយទៀត ។ ប៉ុន្តែនាមរូបក្នុងគ្រាបដិសន្ធិនោះ ក៏កើតពីនាមរូបមុនស្លាប់នោះឯង ។ ព្រោះហេតុនោះ ទើបមិនអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់នាមរូបឯកត្តនានត្តបញ្ហាទី ៦*

# ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*បញ្ហាស្ដីពីភាពតែមួយឬភាពផ្សេងគ្នា នៃនាមរូបឈ្មោះថា* ***នាមរូបឯកត្តនានត្តបញ្ហា*** ។

*ពេលព្រះរាជាត្រាស់សួរថា* " ***ព្រះគុណម្ចាស់នាគសេន នរណាបដិសន្ធិ ?*** " *ព្រះថេរៈថ្វាយវិសជ្ជនាធ្វើការបដិសេធសត្វបុគ្គលដែលបដិសន្ធិថា* " ***សូមថ្វាយព្រះពរមហាបពិត្រ គឺ នាមរូបបដិសន្ធិ*** " *ក្នុងពាក្យវិសជ្ជនានោះ ព្រះថេរៈគួរតែពោលថា* " ***វិញ្ញាណបដិសន្ធិ*** " *ព្រោះការបដិសន្ធិជាកិច្ចរបស់វិញ្ញាណ ដែលជាវិបាក (ផល) នៃកម្មល្អ កម្មអាក្រក់ តាមព្រះបាលី*

ដែលថា **បដិសន្ធិ វិញ្ញាណំ ឱក្កន្តិ ជាមរូបំ** [១] (បដិសន្ធិឈ្មោះថាជា វិញ្ញាណ ការឈានចុះឈ្មោះថា នាមរូប)។

ប៉ុន្តែលោកបែរជាពោលថា " **នាមរូបបដិសន្ធិ** " ព្រោះបើពោលដូចនេះ ជាការចាត់វិញ្ញាណចូលក្នុងនាមនោះដែរ ព្រោះវិញ្ញាណក៏ជានាមក្ខន្ធមួយ ក្នុង បណ្ដានាមក្ខន្ធ ៤ យ៉ាង និង ព្រោះក្នុងខណៈបដិសន្ធិ ដែលជាខណៈ ដំបូងនៃភពថ្មីនោះ វិញ្ញាណក៏ដំណើរទៅ រួមជាមួយនាមរូប ។

ទោះជាក្នុងពេលបន្ទាប់មក ក្រោយពីបដិសន្ធិហើយ ក៏ដូចនេះដែរ វិញ្ញាណ និងនាមរូបរមែងដំណើរទៅជាមួយគ្នា (ក្នុងទេសនាបដិច្ចសមុប្បាទ ថា " **វិញ្ញាណប្បច្ចយា ជាមរូបំ - ព្រោះវិញ្ញាណជាបច្ច័យទើបមាននាមរូប** " នោះ គួរជ្រាបថា លើកលែងវិញ្ញាណក្ខន្ធក្នុងឋានៈជាបច្ច័យចេញ នាមក្ខន្ធ ៣ ដែលនៅសល់ គឺ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ឈ្មោះថា នាមរូប) ពោលឱ្យងាយស្ដាប់គឺ ចិត្តគំនិតគិតនឹកទាំងពួងនោះឯង ហៅថា នាម ។

ពាក្យថា **នាម** ក្នុងទីនេះប្រែថា ធម្មជាតិដែលលំឱនទៅរកអារម្មណ៍ គឺ ដឹងអារម្មណ៍។ ធម្មជាតិនេះមិនមាននៅក្នុងមនុស្សស្លាប់ទេ ពាក្យថា នាម ក្នុងទីនេះមិនបានសំដៅដល់នាមឈ្មោះនោះដែរ ។

អត្តភាពរាងកាយ ដែលចម្រើនធំធាត់ សន្សឹមៗ ទៅតាមវ័យជា លំដាប់នោះ ហៅថា **រូប** ។ ការប្រកាន់យកថា ជាសត្វជាបុគ្គល ដែលក្រៅ អំពីនាមរូបនេះ គឺពុំមានទេ ។

ពាក្យថា **នាមរូបនេះឬបដិសន្ធិ ?** បានសេចក្ដីថា នាមរូបដែលកំពុង ដំណើរទៅ ក្នុងភពនេះ ឬបន្ទាប់ពីស្លាប់ក៏នឹងបដិសន្ធិ (បន្តភពថ្មី កើតជាថ្មី ) ក្នុងភពខាងមុខ ? ឬថា នាមរូបនេះ សាបសូន្យទៅជាមួយសេចក្ដីស្លាប់ នាមរូបផ្សេងបដិសន្ធិ ? ។

---

[១] ខុទ្ទកនិកាយ ខុទ្ទកបាឋ ។

ពាក្យថា **បុគ្គលរមែងធ្វើកម្មល្អខ្លះ អាក្រក់ខ្លះ ដោយសារនាមរូបនេះ ទើបនាមរូបផ្សេងបដិសន្ធិ** បានសេចក្តីថា អាស្រ័យធម្មសន្តតិ ( ធម៌គឺ នាមរូបដែលដំណើរទៅបន្តគ្នា ) ទើបកើតមានការសន្មតថាសត្វ ថាបុគ្គល ។ កាលណាមានការធ្វើល្អ ធ្វើអាក្រក់ក្នុងគ្រាដែលបន្តគ្នាទៅនោះ កម្មនោះរមែងជាបច្ច័យ បង្កើតនាមរូបផ្សេងឱ្យបដិសន្ធិ គឺ ឱ្យតាំងក្នុងភពថ្មី ។

ពាក្យថា " **ប្រសិនបើនាមរូបនេះ មិនបានបដិសន្ធិទេនោះ បុគ្គលនោះនឹងជា អ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបាន មិនថាអ៊ីចឹងឬ** ? " បានសេចក្តីថា បើសត្វ ឬ បុគ្គល គ្មានពិតដោយបរមត្ថ ហៅនាមរូបដែលដំណើរបន្តគ្នាទៅនោះថា ជាសត្វ ជាបុគ្គល ព្រោះហេតុនោះ ពាក្យថា បុគ្គលធ្វើកម្មល្អខ្លះ អាក្រក់ខ្លះដោយនាមរូបនេះ ទើបមានអត្ថន័យថា នាមរូបដែលដំណើរបន្តគ្នានោះឯង ជាអ្នកធ្វើកម្មល្អខ្លះ អាក្រក់ខ្លះ ។

បើនាមរូបនេះធ្វើកម្មអាក្រក់ទុក តែនាមរូបផ្សេងបែរជាបដិសន្ធិក្នុងនរក ដោយសារកម្មអាក្រក់នោះ ក៏រមែងឈ្មោះថា បុគ្គលនោះធ្វើកម្មអាក្រក់ទុក តែបុគ្គលផ្សេងជាអ្នកទទួលផលនៃកម្មអាក្រក់នោះ ។ បើដូចនេះ អ្នកណាធ្វើកម្មអាក្រក់ អ្នកនោះក៏ឈ្មោះថា រួចផុតពីកម្មអាក្រក់ គឺ មិនបាច់ទទួលផលនៃកម្មអាក្រក់ដែលខ្លួនបានធ្វើ ។

ពាក្យថា **ប្រសិនបើនាមរូបមិនអាចបដិសន្ធិបាន គេក៏គួរជាអ្នករួចផុតពីកម្ម អាក្រក់ទាំងឡាយ** ជាដើម បានសេចក្តីថា ប្រសិនបើបុគ្គលទោះជាបានធ្វើកម្មអាក្រក់ ដោយសារនាមរូបនេះទុកហើយ ក៏មិនមាននាមរូបផ្សេងបដិសន្ធិដែរ គួរពោលបានថា គេគួរជាអ្នករួចផុតពីកម្មអាក្រក់ ។

ប៉ុន្តែ ព្រោះបានធ្វើកម្មអាក្រក់ ដោយសារនាមរូបនេះទុករួចហើយតែម្តង ទើបមាននាមរូបផ្សេងទៀត ដោយអំណាចការបដិសន្ធិក្នុងភពថ្មី

ដោយសារកម្មអាក្រក់ដែលបានធ្វើទុករួចហើយនោះ ព្រោះហេតុនោះ ទើបមិនអាចរួចផុតពីកម្មអាក្រក់ទាំងឡាយបាន។

ការពិត នាមរូបកើតឡើងដោយហេតុច្រើនយ៉ាង មិនមែនចំពោះតែកម្ម ប៉ុណ្ណោះទេ ។ ហេតុទាំងនោះមាន ៤ យ៉ាង គឺ **អវិជ្ជា**-ការមិនដឹងសច្ចធម៌ ១ **តណ្ហា**-ចំណង់ ១ **ឧបាទាន**- ការប្រកាន់មាំ ១ **កម្ម**- កម្មល្អកម្មអាក្រក់ដែលសត្វបានធ្វើទុក ១។

លោកពោលថា "**អវិជ្ជា តណ្ហា ឧបាទានំ កម្មន្តិ ឥមេ ចត្តារោ ធម្មា និព្វត្តកត្តា ហេតុ**" [១] ប្រែថា "**ធម៌ ៤ យ៉ាងទាំងនេះ គឺ អវិជ្ជា តណ្ហា ឧបាទាន កម្ម ឈ្មោះថាហេតុនៃនាមរូប ព្រោះជាអ្នកធ្វើឱ្យកើតឡើង**" ដូចនេះ។

ប៉ុន្តែព្រះថេរៈពោលដល់កម្មប៉ុណ្ណោះថា ជាហេតុនៃនាមរូប ព្រោះលោកមានបំណងពោលចំពោះហេតុជាប្រធាន ព្រោះក្នុងបណ្ដាហេតុទាំងនោះ កម្មចាត់ទុកថាជាប្រធាន និង ដើម្បីឱ្យសមស្របនឹងពាក្យតវ៉ារបស់ព្រះចៅមិលិន្ទ ដែលត្រាស់ដល់កម្មថា " **ប្រសិនបើនាមរូបផ្សេងបដិសន្ធិ បុគ្គលក៏គួរជាអ្នករួចផុតពីកម្មអាក្រក់បាន**" ដូចនេះ ។

ក្នុងឧបមាទាំងឡាយនោះ ឧបមាដំបូង ចំណុចសំខាន់របស់ឧបមាមានត្រាន់តែថា ស្វាយផ្លែក្រោយ ៗ ជាស្វាយដែលបុរសជាម្ចាស់ចម្ការស្វាយមិនបានដាំដុះទុកពិតមែន ប៉ុន្តែ ព្រោះហេតុកើតចេញពីស្វាយ ដែលបុរសនេះបានដាំដុះទុក ទើបចាត់ទុកថា ជាស្វាយរបស់បុរសជាម្ចាស់ចម្ការនោះ អ្នកដទៃមិនអាចមានសិទ្ធិគ្រប់គ្រងបាន ។

យ៉ាងណាមិញ នាមរូបដែលបដិសន្ធិ រមែងកើតចេញពីកម្មដែលបុគ្គលបានធ្វើទុក ដោយនាមរូបដែលប្រព្រឹត្តទៅមុនស្លាប់ ដោយអំណាចនៃ

---

[១] វិសុទ្ធិមគ្គ ។

ការវិវឌ្ឍន៍ទៅក្នុងភាពបន្តគ្នាតែមួយ ។ ព្រោះហេតុនោះ រមែងជានាមរូបរបស់បុគ្គលតែមួយនោះឯង ពុំមែនជានាមរូបរបស់បុគ្គលផ្សេងនោះទេ ។ ពេលនាមរូបបដិសន្ធិនោះកើតឡើងក្នុងនរក ព្រោះជានាមរូបដែលកើតពីកម្មអាក្រក់ដែលបានធ្វើទុកមុនស្លាប់ ក៏ឈ្មោះថា បុគ្គលអ្នកធ្វើកម្មអាក្រក់ទុកមុនស្លាប់នោះ ជាអ្នកកើតក្នុងនរក ។ ព្រោះហេតុនោះ ទើបមិនអាចផុតពីកម្មអាក្រក់ទាំងឡាយបាន បានសេចក្តីថា ចាំបាច់ត្រូវទទួលផល នៃកម្មអាក្រក់ដែលខ្លួនបានធ្វើទុក ។

ចំណែកការដែលលោកធ្វើការឧបមាពោលដល់ពាក្យសម្អាង ដើម្បីឱ្យរួចផុតពីកំហុសរបស់បុគ្គលដែលលួចស្វាយនោះ គឺគ្រាន់តែដើម្បីបង្ហាញឱ្យឃើញថា ក្នុងភាពបន្តគ្នាតែមួយ តាមទំនាក់ទំនងនៃហេតុនិងផល បុរសអ្នកដាំផ្លែស្វាយមុននោះ រមែងជាម្ចាស់របស់ស្វាយផ្លែក្រោយ ៗ ដែរ ។

បុរសអ្នកលួចស្វាយផ្លែក្រោយ ៗ ទៅ មិនអាចអាងយកភាពជាម្ចាស់មានសិទ្ធិគ្រប់គ្រងស្វាយផ្លែក្រោយ ៗ ដែលខ្លួនលួចទៅ បាននោះទេ ។ ការដែលគេត្រូវទទួលទោស មិនរួចផុតពីទោសទៅនោះ ជាការបង្ហាញឱ្យឃើញថា ស្វាយផ្លែក្រោយ ៗ ជារបស់បុរសអ្នកដាំស្វាយផ្លែមុនយ៉ាងពិតប្រាកដ បុរសអ្នកលួចយកទៅមិនអាចជំទាស់បានយ៉ាងនេះ ប៉ុណ្ណោះ ដូចនេះ ។

ក្នុងឧបមាដែលនៅសល់ ក៏គួរជ្រាបអត្ថន័យតាមន័យ ដូចពោលខាងលើមកនេះ ផងចុះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៦

# បញ្ហាទី ៧ - ថេរបដិសន្ធហាជាបដិសន្ធហានប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់នឹងបដិសន្ធិទៀតឬទេ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ កុំអី ប្រយោជន៍អ្វីដោយពាក្យដែលព្រះអង្គត្រាស់សួរនោះ ? អាត្មាភាពបានថ្វាយវិសជ្ជនាហើយថា "* ***ប្រសិនបើអាត្មាភាពនៅជាអ្នកមានឧបាទាន អាត្មាភាពក៏នឹងបដិសន្ធិទៀត ប្រសិនបើអាត្មាភាពជាអ្នកគ្មានឧបាទាន អាត្មាភាពក៏នឹងមិនបដិសន្ធិទៀត*** *" ដូចនេះ មិនមែនទេឬ ?"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសម្នាក់បានធ្វើការទំនុកបម្រុងព្រះរាជា ព្រះរាជាទ្រង់រីករាយហើយក៏ទ្រង់ផ្តល់ការទំនុកបម្រុងដល់គេ ។ គេជាមនុស្សរីករាយ ពេញប្រៀបបរិបូរដោយកាមគុណទាំង ៥ ព្រោះការទំនុកបម្រុងនោះ ប្រសិនបើគេប្រាប់ដល់មហាជនថា "* ***ព្រះរាជាទ្រង់មិនបានធ្វើការតបស្នងអ្វីដល់គេនោះទេ*** *" ដូចនេះនោះ សូមថ្វាយព្រះពរ បុរសនោះឈ្មោះថា ជាអ្នកធ្វើត្រឹមត្រូវហើយឬ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ប្រយោជន៍អ្វីដោយពាក្យ ដែលព្រះអង្គត្រាស់សួរសេចក្តីនោះ អាត្មាភាពបានពោលចំពោះរឿងនេះរួចហើយថា "* ***ប្រសិនបើអាត្មាភាពនៅជាអ្នកមានឧបាទាន អាត្មាភាពក៏នឹងបដិសន្ធិទៀត ប្រសិនបើអាត្មាភាពជាអ្នកគ្មានឧបាទាន អាត្មាភាពក៏នឹងមិនបដិសន្ធិទៀតទេ*** *" ដូចនេះ មិនមែនទេឬ ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់ថេរបដិសន្ធហនាបដិសន្ធហនបញ្ហាទី ៧*

# ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*បញ្ហាមានការសួរដល់ការបដិសន្ធិ ឬ មិនបដិសន្ធិនៃព្រះថេរៈ ឈ្មោះថា **ថេរបដិសន្ធហនាបដិសន្ធហនបញ្ហា** ។*

*ពាក្យថា **កុំអី** គឺ មិនត្រឹមត្រូវទេ ។*

*ពាក្យថា **ការទំនុកបម្រុង** គឺឧបការៈ ។*

*ក្នុងឧបមា បុរសនោះ ពេលព្រះរាជាទ្រង់ធ្វើឧបការៈតបស្នងដល់ខ្លួនធ្វើឱ្យខ្លួនពេញចិត្តហើយ ការដែលគេបែរជាពោលទៅកាន់មនុស្សទាំងឡាយថា ព្រះរាជាទ្រង់មិនបានធ្វើការឧបការៈអ្វីដល់យើងទេ ដូចនេះនៅពេលក្រោយនោះ ឈ្មោះថា ធ្វើមិនត្រឹមត្រូវ គឺមិនសមរម្យ ។*

*យ៉ាងណាមិញ ប្រការដែលព្រះថេរៈបានថ្វាយវិសជ្ជនាបញ្ហានេះដល់ព្រះរាជា ធ្វើឱ្យព្រះរាជាទ្រង់រីករាយទទួលស្គាល់មុននេះរួចហើយ ក្នុងពេលនេះ ព្រះរាជាទ្រង់បែរជាមកត្រាស់សួរបញ្ហានេះទៀត បីដូចព្រះថេរៈមិនបានថ្វាយវិសជ្ជនាមុននោះ ក៏ឈ្មោះថាទ្រង់ធ្វើមិនត្រឹមត្រូវ គឺមិនសមគួរ ដូចនោះដែរ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - នាមរូបបដិសន្ធិបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន ក្នុងពាក្យដែលពោលថា "នាមរូប" នេះ អ្វីគឺនាម ? អ្វីគឺរូប ?"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ មហាបពិត្រ ក្នុងពាក្យថា នាមរូបនោះ ធម្មជាតិដែលគ្រោតគ្រាតគឺ **"រូប"** ក្នុងពាក្យថា នាមរូបនោះ ចិត្ត និងចេតសិកធម៌ទាំងឡាយ ដែលជាធម្មជាតិដ៏សុខុម គឺ **"នាម"** "

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់នាគសេន ព្រោះហេតុអ្វីនាមតែមួយមុខ បដិសន្ធិមិនបាន ឬរូបតែមួយមុខ ក៏បដិសន្ធិមិនបាន យ៉ាងដូចនោះ ?"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ធម៌ទាំងនេះពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក រមែងកើតឡើងដំណាលគ្នាតែម្តង"

**ព្រះចៅមិលិន្ទ** ៖ " សូមព្រះគុណម្ចាស់ធ្វើការឧបមា"

**ព្រះនាគសេន** ៖ "សូមថ្វាយព្រះពរមហាបពិត្រ ប្រៀបដូចជា បើស៊ុតថ្មី (កើតដំបូង)របស់មេមាន់គ្មាន សូម្បីក្នាសស៊ុត(ដែលជាទីតាំងអាស្រ័យ)ក៏គ្មាន ។ ក្នុងនោះ ស៊ុតថ្មីក្តី ក្នាសស៊ុតក្តី ទាំងពីរយ៉ាងនេះ ពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក ទាំងពីរយ៉ាងនេះ មានការកើតឡើងដំណាលគ្នាតែម្តង ។

យ៉ាងណាមិញ សូមថ្វាយព្រះពរ ក្នុងនាមនិងរូបនោះ បើនាមមិនមាន សូម្បីរូបក៏មិនអាចមានទៅកើតដែរ ក្នុងនាមនិងរូបនោះ នាមក្តី រូបក្តី ធម៌ទាំងពីរនេះ ពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក ។

*ធម៌ទាំងពីរនេះ មានការកើតឡើង ដំណាលគ្នាតែម្តង ដូចនេះដែរ នាមនិងរូបនេះ ដូចពោលមកខាងលើនេះ មានដំណើរទៅមុខ រហូតអស់កាលដ៏យូរអង្វែង"*

**ព្រះចៅមិលិន្ទ ៖** *"ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់នាមរូបបដិសន្ធហានបញ្ហាទី ៨*

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*បញ្ហាស្តីអំពីការបដិសន្ធិរបស់នាមរូប ឈ្មោះថា* ***នាមរូបបដិសន្ធហាន-បញ្ហា*** *។*

*ព្រះរាជាត្រាស់សួរថា "* ***ព្រោះហេតុអ្វីនាមតែមួយមុខ បដិសន្ធិមិនបាន*** *" ដូចនេះ ជាដើម ទ្រង់សំដៅយកការបដិសន្ធិរបស់មនុស្ស ជាសត្វនៅក្នុងបញ្ចវោការភូមិ ( ភូមិដែលមានខន្ធ ៥ គឺ មានទាំងរូបទាំងនាម ) ។*

*ជាការពិតថា ក្នុងចតុវោការភូមិ ( ភូមិដែលមានខន្ធ ៤ លើកលែងរូបក្ខន្ធគឺអរូបភូមិទាំងឡាយនោះ មានតែនាមមួយមុខប៉ុណ្ណោះដែលបដិសន្ធិ ពុំមានរូបបដិសន្ធិទេ ។ ក្នុងឯកវោការភូមិ ( ភូមិដែលមានខន្ធតែមួយ គឺ រូប-ក្ខន្ធ គឺអសញ្ញីសត្តភូមិ ) មានតែរូបមួយមុខប៉ុណ្ណោះដែលបដិសន្ធិ ពុំមាននាមបដិសន្ធិទេ ។*

*ក្នុងគ្រាបដិសន្ធិនៃសត្វក្នុងបញ្ចវោការភូមិទាំងឡាយ មានមនុស្សជាដើមនោះ នាមរូបរមែងពឹងពាក់អាស្រ័យគ្នា ឧប្បត្តិព្រមគ្នា ។ ទោះជានាមមានចិត្តជាប្រធាន ប៉ុណ្ណោះ ធ្វើតួនាទីបដិសន្ធិ ពុំមែនរូបក៏ដោយ ប៉ុន្តែនាម*

នោះ ក៏ត្រូវមានរូបជាទីតាំងអាស្រ័យ ហើយរូបនោះកើតឡើងក្នុងគ្រានោះបាន ក៏ព្រោះបាននាម ដែលមានបដិសន្ធិចិត្តជាប្រធាននោះជាបច្ច័យ ជាអ្នកធ្វើឱ្យកើតឡើង ដោយការកើតឡើងដំណាលគ្នា ជាមួយបដិសន្ធិចិត្តនោះ ។

ព្រោះហេតុនោះទើបព្រះថេរៈពោលថា "**នាមក្តី រូបក្តី ធម៌ទាំងពីរនេះ ពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក ធម៌ទាំង ២ នេះ មានការកើតឡើងដំណាលគ្នាតែម្តង**" ដូចនេះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៨

# បញ្ហាទី ៩ - អទ្ធានបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន ពាក្យដែលលោកពោលថា " អស់កាលដ៏យូរអង្វែង (ទីឃអទ្ធានំ) " នេះ អ្វីទៅឈ្មោះថា របស់មានកាល (អទ្ធានៈ) នេះ ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ អ្វីដែលកន្លងផុតទៅហើយ ឈ្មោះថារបស់មានកាល ដែលមិនទាន់មកដល់ក៏ឈ្មោះថា របស់មានកាល អ្វីដែលកើតឡើងចំពោះមុខក៏ឈ្មោះថា របស់មានកាល "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ របស់ដែលមានកាលសុទ្ធតែមាននៅក្នុងនោះឬ ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ របស់មានកាលខ្លះមាននៅ របស់មាន កាលខ្លះមិនមាននៅ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ អ្វីឈ្មោះថា របស់មានកាលមាននៅ ? អ្វីឈ្មោះថា របស់មានកាលមិនមាននៅ ? "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ សង្ខារទាំងឡាយដែលកន្លងផុតទៅ ហើយ ប្រាសចាកទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយទាំងនោះឈ្មោះថា របស់មានកាល មិនមាននៅ ។ វិបាកធម៌ទាំងឡាយក្តី ធម៌ដែលឱ្យវិបាកធម៌ទាំងឡាយក្តី ធម៌ដែលកំពុងឱ្យបដិសន្ធិ ក្នុងភពដទៃក្តី នោះឈ្មោះថា របស់មានកាល មាននៅ ។ មួយ៉ាងវិញទៀត សត្វទាំងឡាយដែលបានធ្វើកាលៈហើយ មិនកើតក្នុងភពដទៃនោះ ឈ្មោះថា របស់មានកាល មិនមាននៅ គឺ សត្វទាំងឡាយ ដែលបរិនិព្វានទៅហើយនោះ ឈ្មោះថារបស់មានកាលមិនមាននៅ ព្រោះរលត់អស់ហើយ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់អទ្ធានប្បញ្ហាទី ៩*

# ពាក្យអធិប្បាយបញ្ហាទី ៩ ៖

*បញ្ហាមានការសួរដល់អទ្ធានៈ (កាល,របស់មានកាល) ឈ្មោះថា* ***អទ្ធានប្បញ្ហា*** *។ ពាក្យថា* ***អទ្ធានៈ*** *(របស់មានកាល) គឺជាអ្វីដែលដំណើរទៅទាក់ទងនឹងកាល ៣ មានអតីតកាល ជាដើម ។*

*ពាក្យថា* ***របស់មានកាលខ្លះមាននៅ របស់មានកាលខ្លះមិនមាននៅ*** *បាន សេចក្តីថា របស់មានកាលខ្លះដែលជាបច្ចុប្បន្នមាននៅ របស់មានកាលខ្លះដែលជាអតីត ឬ ដែលជាអនាគត មិនមាននៅ ។*

ពាក្យថា **សង្ខារ** គឺធម៌ដែលបច្ច័យប្រជុំតាក់តែង ឬធ្វើឱ្យកើតឡើង ដំណើរទៅ ទាក់ទងនឹងបច្ច័យ កើតឡើងអំពីបច្ច័យនោះ រួចក៏ដល់នូវភាព រលត់ទៅ

ជាធម្មតា ។

ពាក្យថា **សង្ខារទាំងឡាយដែលកន្លងផុតទៅហើយ ។ ល។ របស់មាន កាល មិនមាននៅ** បានសេចក្តីថា សង្ខារទាំងឡាយដែលកន្លងផុតទៅហើយ ក្នុងភពមុន ឈ្មោះថា "របស់មានកាល" ដោយមានកាលជាអតីត និងឈ្មោះ ថា "មិនមាននៅ" ព្រោះពុំមានតួសភាវៈនៅសល់ក្នុងភពនេះ សូម្បីប៉ុនចុង សរសៃសក់ ព្រោះកន្លងផុតទៅហើយ ដោយអំណាចការរលត់អស់ទៅ ។

ពាក្យថា **វិបាកធម៌ទាំងឡាយ** គឺ ធម៌ជាវិបាក គឺធម៌ជាផលនៃកុសល កម្ម និង អកុសលកម្ម ដែលសត្វធ្វើទុកក្នុងភពមុនដែលកំពុងដំណើរទៅក្នុង ភពបច្ចុប្បន្ននេះ។ ពាក្យថា **ធម៌ដែលឱ្យវិបាកធម៌ទាំងឡាយ** គឺ ធម៌ជាកុសល និងអកុសលដែលសត្វធ្វើទុកក្នុងភពបច្ចុប្បន្ននេះ ដែលអាចធ្វើវិបាកឱ្យកើត ឡើងក្នុងភពផ្សេង ។

ពាក្យថា **ធម៌ដែលកំពុងឱ្យបដិសន្ធិ ក្នុងភពដទៃ** គឺ វិបាកធម៌ ដែល កំពុងធ្វើមុខងារបដិសន្ធិ ក្នុងភពបច្ចុប្បន្ននេះ ១ កុសលនិងអកុសល ដែល អាចធ្វើវិបាកធម៌ឱ្យកើតឡើង ធ្វើមុខងារបដិសន្ធិក្នុងភពដទៃ ១ ឈ្មោះថា របស់មានកាលមាននៅ ដោយអំណាចទំនាក់ទំនងហេតុនិងផល ពោលគឺ ជាផលក្នុងបច្ចុប្បន្ន ដោយសារហេតុពីអតីតខ្លះ ជាហេតុក្នុងបច្ចុប្បន្ន សាង ផលក្នុងអនាគតខ្លះ ។

ពាក្យថា **ធ្វើកាលៈហើយ** ( ស្លាប់ហើយ ) គឺធ្វើកាលៈហើយដោយ អំណាច នៃចុតិចិត្ត ( ចិត្តរំកិលចេញពីភព ) ដែលកើតឡើង ។

ពាក្យថា ***កើតក្នុងភពដទៃ*** បានសេចក្ដីថា កើតឡើងក្នុងភពដទៃ ដោយ អំណាចនៃការមានបដិសន្ធិចិត្ត ( ចិត្តដួងដំបូងដែលធ្វើមុខងារបន្ត ភពជាតិ ) កើតឡើង ។ សត្វនោះឈ្មោះថា របស់មានកាលមាននៅ ព្រោះទោះជាធ្វើកាលៈហើយ ក៏នៅដំណើរទៅជាប់មិនដាច់ ដោយអំណាច បដិសន្ធិចិត្តដែលកើតឡើងនោះ ។

ពាក្យថា ***ធ្វើកាលៈហើយ*** មិនកើតឡើងក្នុងភពដទៃ បានសេចក្ដីថា សត្វ គឺ លោកជាព្រះអរហន្តធ្វើកាលៈហើយ មិនកើតឡើងក្នុងភពដទៃ ដោយអំណាចនៃបដិសន្ធិនោះ ឈ្មោះថា របស់មានកាលមិនមាននៅ ព្រោះគ្មានបដិសន្ធិទៀត នោះឯង ។ ព្រោះហេតុនោះ ទើបលោកពោល ថា " គឺ សត្វទាំងឡាយដែលបរិនិព្វានហើយនោះ ឈ្មោះថារបស់មាន កាលមិនមាននៅ ព្រោះរលត់អស់ហើយ " ដូចនេះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៩

# ចប់អទ្ធានវគ្គទី ២

ក្នុងវគ្គនេះមាន ៩ បញ្ហា

ៜៜៜៜៜៜៜ 🕮 ៙៙៙៙៙៙៙

# វគ្គទី ៣ - វចារវគ្គ

## បញ្ហាទី ១ - អទ្ធានមូលប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន អ្វីជាមូលនៃអទ្ធានៈ (របស់មានកាល)ផ្នែកអតីត អ្វីជាមូលនៃអទ្ធានៈផ្នែកអនាគត អ្វីជាមូលនៃអទ្ធានៈផ្នែកបច្ចុប្បន្ន ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ អវិជ្ជាជាមូលនៃអទ្ធានៈផ្នែកអតីត នៃអទ្ធានៈផ្នែកអនាគត និង នៃអទ្ធានៈផ្នែកបច្ចុប្បន្ន គឺថា ព្រោះអវិជ្ជាជាបច្ច័យ ក៏រមែងមានសង្ខារ ។ ព្រោះសង្ខារជាបច្ច័យ រមែងមានវិញ្ញាណ ។ ព្រោះវិញ្ញាណជាបច្ច័យ រមែងមាននាមរូប ។ ព្រោះនាមរូបជាបច្ច័យ រមែងមានអាយតនៈ ៦ ។ ព្រោះអាយតនៈ ៦ ជាបច្ច័យ រមែងមានផស្សៈ ។ ព្រោះផស្សៈជាបច្ច័យ រមែងមានវេទនា ។ ព្រោះវេទនាជាបច្ច័យ រមែងមានតណ្ហា ។ ព្រោះតណ្ហាជាបច្ច័យ រមែងមានឧបាទាន ។ ព្រោះឧបាទានជាបច្ច័យ រមែងមានភព ។ ព្រោះភពជាបច្ច័យ រមែងមានជាតិ ។ ព្រោះជាតិជាបច្ច័យ រមែងមានជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ។ ចុងបំផុតខាងដើមនៃអទ្ធានៈ ដែលជាគំនរទុក្ខទាំងអស់ តាមប្រការដូចពោលខាងលើមកនេះ រមែងមិនបង្ហាញឱ្យឃើញនោះទេ ។"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់អទ្ធានមូលប្បញ្ហាទី ១*

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

*ក្នុងវគ្គទី ៣ គឺវគ្គនេះ មានបញ្ហាមកហើយចំនួន ១៤ បញ្ហា ។*

*បញ្ហាមានការសាកសួរដល់មូលនៃអទ្ធានៈ ឈ្មោះថា* ***អទ្ធានមូលបញ្ហា*** *។*

*ពាក្យថា* ***មូលនៃអទ្ធានៈ*** *ប្រែថា មូលគឺឫសគល់នៃអទ្ធានៈ សំដៅដល់ហេតុ ដែលជាប្រធាននៃអទ្ធានៈ ដែលប្រព្រឹត្តទៅទាក់ទងនឹងកាល ៣ ។*

*ព្រះនាគសេនមានបំណងបង្ហាញ ឱ្យព្រះរាជាទ្រង់មើលឃើញថា អវិជ្ជាឈ្មោះថា ជាមូលនៃអទ្ធានៈទាំង ៣ កាលនោះយ៉ាងដូចម្ដេច ដោយព្រះបាលី ទើបពោលបដិច្ចសមុប្បាទកថា ថា " ព្រោះអវិជ្ជាជាបច្ច័យ រមែងមានសង្ខារ " ដូចនេះ ជាដើម ។ បណ្ឌិតគួរជ្រាបសេចក្ដីពិស្ដារស្ដីអំពីបដិច្ចសមុប្បាទ ( បច្ច័យដែលផលអាស្រ័យកើតឡើង ) ក្នុងគម្ពីរផ្សេង ៗ មានវិសុទ្ធិមគ្គ ជាដើម ផងចុះ ។*

*នៅក្នុងបដិច្ចសមុប្បាទកថានោះ ការដែលទ្រង់សម្ដែងអង្គទាំងឡាយដោយមានអវិជ្ជាដែលជាអង្គដំបូងមុនថា " ព្រោះអវិជ្ជាជាបច្ច័យ រមែងមានសង្ខារ " នោះមិនមែនបង្ហាញថា អវិជ្ជាជាចុងបំផុតខាងដើម ( ចំណុចចាប់ផ្ដើម ) នៃអទ្ធានៈនោះទេ ។ ប៉ុន្តែជាការបង្ហាញថា អវិជ្ជាជាហេតុដែលជាប្រធាននៃអទ្ធានៈប៉ុណ្ណោះ ។ ព្រោះហេតុនោះហើយ ទើបព្រះថេរៈពោលថា " ចុងបំផុតខាងដើមនៃអទ្ធានៈ រមែងមិនបង្ហាញឱ្យឃើញ " ដូចនេះ បានសេចក្ដីថា ទោះជាអវិជ្ជានោះ ក៏ជារបស់ដែលមានបច្ច័យ គឺ មានអាសវៈដែលសត្វនៅមិនទាន់បានលះជាបច្ច័យ តាមព្រះបាលីដែលថា "* ***អាសវ***

**សមុទយា អវិជ្ជាសមុទយោ** ⁽¹⁾ ព្រោះអាសវៈកើតឡើង ទើបអវិជ្ជាកើតឡើង" ព្រោះហេតុនោះ ទើបអវិជ្ជាមិនមែនឈ្មោះថា ចុងបំផុត ខាងដើមនៃអទ្ធានៈ ។

ប្រសិនបើមានសំណួរថា " ប្រការដែលថា អវិជ្ជាជាមូលនៃអទ្ធានៈផ្នែកបច្ចុប្បន្ននេះ នឹងដឹងបានយ៉ាងដូចម្តេច ? " ។ សូមឆ្លើយថា " នឹងដឹងបានតាមព្រះសូត្រ ដែលថា **អវិជ្ជា បច្ចយោ សង្ខារា បច្ចយសមុប្បន្នា ។ ល។ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិ ញាណំ** ⁽²⁾ បញ្ញាដែលកំណត់បានថា អវិជ្ជាជាបច្ច័យ សង្ខារជាអ្វីដែលកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរ ( គឺ អវិជ្ជា និង សង្ខារ ) នេះ ជាធម៌ដែលកើតឡើងព្រោះបច្ច័យ ដូចនេះ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ( បច្ចយបរិគ្គហញ្ញាណ ) ព្រោះជាការកំណត់ដឹងអវិជ្ជាបច្ចុប្បន្ន ដែលជាបច្ច័យដល់សង្ខារបច្ចុប្បន្ន ។

ប្រសិនបើមានសំណួរទៀតថា " ប្រការដែលថាអវិជ្ជាជាមូលនៃអទ្ធានៈផ្នែកអតីត នៃអទ្ធានៈផ្នែកអនាគតនេះ នឹងដឹងបានយ៉ាងដូចម្តេច ? " ។ សូមឆ្លើយថា " នឹងដឹងបាន តាមព្រះសូត្រដដែលនោះដែលថា " **អតីតំបិ អទ្ធានំ អនាគតំបិ អទ្ធានំ, អវិជ្ជាបច្ចយោ សង្ខារា បច្ចយសមុប្បន្នា ។ល។ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ** ⁽³⁾ បញ្ញាដែលកំណត់បច្ច័យបានថា ទោះជាអតីតកាល ទោះជាអនាគតកាល អវិជ្ជាក៏ជាបច្ច័យ សង្ខារជាអ្វីដែលកើតឡើងព្រោះបច្ច័យ ធម៌ទាំង២នេះជាធម៌ដែលកើតឡើងព្រោះបច្ច័យ ដូចនេះ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ព្រោះជាការកំណត់ដឹងអវិជ្ជាអតីត ដែលជាបច្ច័យដល់សង្ខារអតីតនោះឯង និងអវិជ្ជាអនាគត ដែលជាបច្ច័យដល់សង្ខារអនាគត " ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១

---
(១) មជ្ឈិមនិកាយ មូលបណ្ណាសក ។
(២) ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ។
(៣) ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ។

# បញ្ហាទី ២ - បុរិមកោដិប្បញ្ហា

**ព្រះរាជា** ត្រាស់សួរថា "ព្រះគុណម្ចាស់នាគសេន ពាក្យដែលលោកម្ចាស់ពោលថា " ចុងបំផុតខាងដើម មិនបង្ហាញ " នេះ សូមលោកម្ចាស់ធ្វើការឧបមាសម្រាប់ពាក្យនោះផងចុះ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាបុរសម្នាក់កប់គ្រាប់រុក្ខជាតិតូច ៗ នៅក្នុងដី ។ ក្រោយមកក៏មានពន្លកដុះឡើង មានភាពរីកលូតលាស់ទៅតាមលំដាប់ រួចក៏ឱ្យផល ។ ភាពបន្តគ្នាទៅដោយអាការដូចពោលខាងលើមកនេះ មានទីបំផុតឬយ៉ាងណា ? "

**ព្រះចៅមិលិន្ទ ៖** " មិនមានទីបំផុតទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ចុងបំផុតខាងដើមនៃអទ្ធានៈ រមែងមិនបង្ហាញ ដូចនេះ "

**ព្រះចៅមិលិន្ទ ៖** "សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ប្រៀបដូចជា ចេញពីមាន់ក៏មានស៊ុត ចេញពីស៊ុតក៏មានមាន់ ចេញពីមាន់ក៏មានស៊ុត ភាពបន្តគ្នាទៅ ដោយអាការដូចពោលខាងលើមកនេះ មានទីបំផុតឬយ៉ាងណា ?

**ព្រះចៅមិលិន្ទ ៖** " គ្មានទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ចុងបំផុតខាងដើម រមែងមិនបង្ហាញដូចនេះ "

**ព្រះចៅមិលិន្ទ ៖** "សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ "

**ព្រះថេរៈ** គូររូបរង្វង់មូលទៅលើដី ថ្វាយព្រះពរសួរសេចក្ដីនោះ ទៅកាន់ព្រះរាជាថា " សូមថ្វាយព្រះពរ រូបរង្វង់មូលនេះមានទីបំផុត ឬយ៉ាង

ណា ?"

**ព្រះចៅមិលិន្ទ** ៖ " គ្មានទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់វង្វង់ទាំងនេះយ៉ាងនេះថា ចក្ខុ-វិញ្ញាណ ( ការឃើញរូបភាព ) អាស្រ័យប្រសាទភ្នែក និងរូប ( រូបភាពដែលឃើញ ) កើតឡើង ផស្សៈរមែងមាន ព្រោះការប្រជុំព្រមគ្នានៃធម៌ ៣ យ៉ាង ព្រោះផស្សៈជាបច្ច័យរមែងមានវេទនា ព្រោះវេទនាជាបច្ច័យរមែងមានតណ្ហា ព្រោះតណ្ហាជាបច្ច័យរមែងមានឧបាទាន ព្រោះឧបាទានជាបច្ច័យ ក៏រមែងមានកម្ម ប្រសាទភ្នែករមែងកើតពីកម្មទៀត " ដូចនេះ ភាពបន្តគ្នាទៅដោយអាការដូចពោលខាងលើមកនេះ ដូចនេះ មានទីបំផុតឬយ៉ាងណា ?"

**ព្រះចៅមិលិន្ទ** ៖ " មិនមានទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន** ៖ " សោតវិញ្ញាណ ( ការបានឮសូរសំឡេង ) អាស្រ័យប្រសាទ ត្រចៀកនិងសំឡេងកើតឡើង ។ល។ មនោវិញ្ញាណអាស្រ័យចិត្តនិងធម៌កើតឡើង ផស្សៈរមែងមានព្រោះការប្រជុំព្រមគ្នានៃធម៌ ៣ យ៉ាង ព្រោះផស្សៈជាបច្ច័យក៏រមែងមានវេទនា ព្រោះវេទនាជាបច្ច័យក៏រមែងមានតណ្ហា ព្រោះតណ្ហាជាបច្ច័យក៏រមែងមានឧបាទាន ព្រោះឧបាទានជាបច្ច័យក៏រមែងមានកម្ម ចិត្តរមែងកើតពីកម្មទៀត ដូចនេះ ។ ភាពបន្តគ្នាទៅដោយអាការដូចពោលខាងលើមកនេះ ដូចនេះ មានទីបំផុតឬយ៉ាងណា ?

**ព្រះចៅមិលិន្ទ** ៖ "គ្មានទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ ចុងបំផុតខាងដើមនៃអទ្ធានៈ រមែងមិនបង្ហាញ ដូចនេះ "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់បុរិមកោដ្ឋិបញ្ហាទី ២*

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហាស្តីអំពីចុងបំផុតខាងដើម ឈ្មោះថា* ***បុរិមកោដិបញ្ហា*** *។*

*ក្នុងឧបមាដំបូង មានសេចក្តីសង្ខេបតែប៉ុណ្ណេះថា ប្រៀបដូចជាដើមឈើក្រោយ ៗ រមែងកើតពីគ្រាប់រុក្ខជាតិនៃដើមមុនៗ ។ ទោះជាដើមមុន ៗ នោះ ក៏រមែងកើតពីគ្រាប់រុក្ខជាតិនៃដើមមុននោះទៀត ។ ភាពបន្តគ្នាដូចនេះ រកទីបំផុតខាងដើមមិនបាន រកចំណុចចាប់ផ្តើមមិនបាន បានសេចក្តីថា មិនអាចស្រាវជ្រាវបានថា ដើមមួយណាជាដើមដំបូង ។ ប្រការនេះមានឧបមាយ៉ាងណា ស្តីអំពីភាពបន្តគ្នាទៅនៃអទ្ធានៈ ក៏មានឧបមាដូចនោះ ទោះជាឧបមាដែលនៅសល់ ក៏មានន័យដូចគ្នានេះ ។*

*ពាក្យថា* ***ចក្ខុវិញ្ញាណ អាស្រ័យប្រសាទភ្នែក និងរូបកើតឡើង*** *បានសេចក្តីថា ចក្ខុវិញ្ញាណ គឺ វិញ្ញាណខាងភ្នែក មានមុខងារឃើញរូបភាព គឺការឃើញរូបភាពនោះឯង អាស្រ័យប្រសាទភ្នែក ព្រោះប្រសាទភ្នែកជាទីតាំងអាស្រ័យ និងជាទ្វារ និង អាស្រ័យរូប គឺរូបភាព ដែលនឹងឃើញនាគ្រានោះ រួចទើបកើតឡើងបាន ។*

*ពាក្យថា* ***ផស្សៈរមែងមានព្រោះការប្រជុំព្រមគ្នានៃធម៌ ៣ យ៉ាង*** *បានសេចក្តីថា ផស្សៈគឺការទង្គិចនឹងអារម្មណ៍ គឺរូបភាពដែលមកដល់គន្លងទ្វារចក្ខុនោះឯងរមែងមាន ព្រោះការប្រជុំព្រមគ្នានៃធម៌ ៣ យ៉ាងគឺ ប្រសាទភ្នែក*

១ រូបឬរូបភាពដែលនឹងឃើញនោះ ១ ចក្ខុវិញ្ញាណដែលកើតឡើងមក ឃើញរូបភាពនោះ ១ ។

ពាក្យថា **ព្រោះផស្សៈជាបច្ច័យក៏រមែងមានវេទនា** បានសេចក្តីថា លុះមានផស្សៈកើតឡើងទង្គិចអារម្មណ៍ គឺរូបនោះហើយ ក៏រមែងមានវេទនាកើតឡើងសោយអារម្មណ៍ ដែលផស្សៈទង្គិចនោះ ខ្លះជាសុខវេទនា ខ្លះជាទុក្ខវេទនា ខ្លះជាឧបេក្ខាវេទនា ។

ពាក្យថា **ព្រោះវេទនាជាបច្ច័យក៏រមែងមានតណ្ហា** បានសេចក្តីថា ពេលមានវេទនាកើតឡើងសោយអារម្មណ៍គឺរូបនោះហើយ តណ្ហាចំណង់ក្នុងអារម្មណ៍នោះក៏រមែងកើតឡើង ដោយអាស្រ័យវេទនាជាផ្លូវ ពោលគឺ ពេលអារម្មណ៍គឺរូបនោះ ជាឥដ្ឋារម្មណ៍គួរឱ្យប្រាថ្នា គួរឱ្យចម្រើនភ្នែក ជាទីតាំងនៃសុខវេទនា សត្វដែលឃើញតែសេចក្តីសុខ ក៏រមែងកើតតណ្ហា ប៉ងប្រាថ្នាក្នុងរូបនោះ ។

ពាក្យថា **ព្រោះតណ្ហាជាបច្ច័យក៏រមែងមានឧបាទាន** បានសេចក្តីថា តណ្ហាដែលមានកម្លាំង លោកហៅថា ឧបាទាន គឺភាពប្រកាន់មាំដំណើរទៅក្នុងអារម្មណ៍ដែលបានមកហើយ ។ សត្វទាំងឡាយពេលបានទទួលអារម្មណ៍ដ៏គួរឱ្យប្រាថ្នាមកហើយ ក៏រមែងប្រកាន់មាំថា " នេះរបស់យើង " ជាដើម ។

ពាក្យថា **ព្រោះឧបាទានជាបច្ច័យក៏រមែងមានកម្ម** បានសេចក្តីថា សត្វទាំងឡាយ ពេលកើតឧបាទានក្នុងអ្វីដែលខ្លួនប្រាថ្នាហើយ ក៏សម្ងឹងមិនឃើញទោសនៃអារម្មណ៍គឺរូបនោះ រមែងធ្វើកម្មល្អខ្លះអាក្រក់ខ្លះ ដើម្បីឱ្យបានមកនូវអ្វីដែលត្រូវការ ។

*ពាក្យថា **ប្រសាទភ្នែករមែងកើតពីកម្មទៀត** បានសេចក្តីថា កម្មដែលបុគ្គល ធ្វើដោយអំណាចនៃរូបតណ្ហា រមែងបង្កើតប្រសាទភ្នែកដល់គេទៀត រួចនៅពេលមានប្រសាទភ្នែកទៀត ក្នុងពេលដែលមានរូបមកដល់គន្លងទ្វារ ចក្ខុវិញ្ញាណក៏អាស្រ័យប្រសាទភ្នែកនិងរូបនោះកើតឡើងទៀត តាមន័យដូចខាងលើ ។ ភាពបន្តគ្នាទៅនៃអទ្ធានៈ តាមប្រការដូចខាងលើមកនេះ មិនអាចស្រាវជ្រាវរហូតដល់ចំណុចចាប់ផ្តើមបាន ហៅថា គ្មានចុងបំផុតខាងដើម ។ ទោះជាស្តីអំពីទ្វារផ្សេងដែលនៅសល់ មានខាងត្រចៀកជាដើម បណ្ឌិតក៏គួរជ្រាបតាមលំនាំ ដូចពោលខាងលើមកនេះ ផងចុះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - កោដិបញ្ញាយនបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា ៖ " ព្រះគុណម្ចាស់នាគសេន ពាក្យដែលលោកម្ចាស់ពោលថា "ចុងបំផុតខាងដើមមិនបង្ហាញ" ដូចនេះនោះ ចុងបំផុតខាងដើមនោះយ៉ាងដូចម្តេច ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ អទ្ធានៈដែលកន្លងផុតទៅហើយ ឈ្មោះថា ចុងបំផុតខាងដើម "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន ពាក្យដែលលោកម្ចាស់ពោលថា " ចុងបំផុតខាងដើមរមែងមិនបង្ហាញ " ដូចនេះនោះ ចុងបំផុតខាងដើមនោះ ទោះគ្រប់យ៉ាង ឬ ដែលមិនបង្ហាញ ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ចុងបំផុតខាងដើមខ្លះបង្ហាញ ចុងបំផុត ខាងដើមខ្លះមិនបង្ហាញ ?"*

**ព្រះចៅមិលិន្ទ** "ព្រះគុណម្ចាស់ ចុងបំផុតអ្វីបង្ហាញ ? ចុងបំផុតអ្វីមិនបង្ហាញ ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ប្រការដែលត្រាស់ទុកថា មុននេះអវិជ្ជាមិនធ្លាប់មានសោះ ដោយគ្រប់ប្រការទាំងអស់ដូចនេះ ឈ្មោះថាចុងបំផុតខាងដើម រមែងមិនបង្ហាញ ។ អ្វីដែលមិនមានក៏មកមានឡើង មានហើយ ក៏បែរជាប្រាសចាកទៅវិញ នេះចាត់ទុកថា ចុងបំផុតខាងដើម រមែងបង្ហាញ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន អ្វីដែលមិនមានក៏បែរជាមកមានឡើង មានហើយក៏បែរជាប្រាសចាកទៅវិញ ។ អ្វីនោះត្រូវកាត់ដោយខណៈទាំង ២ (ខណៈកើតឡើង និងខណៈរលត់ទៅ) រួចរមែងដល់នូវសេចក្ដីតាំងនៅមិនបាន មិនមែនដូចនេះឬ?

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ប្រសិនបើជាអ្វីដែលត្រូវកាត់ដោយខណៈទាំងពីរ ក៏រមែងដល់នូវសេចក្ដីតាំងនៅមិនបាន ចុងបំផុតដែលត្រូវកាត់ដោយខណៈទាំង ២ អាចចម្រើនបានឬ?"

**ព្រះចៅមិលិន្ទ ៖** " មែន ចុងបំផុតនោះអាចចម្រើនបាន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាមិនបានសួរថា ចុងបំផុតអាចចម្រើនបានឬទេនោះទេ សួរថា ចុងបំផុត អាចចម្រើនបានដោយចុងបំផុតឬទេ ?"

**ព្រះនាគសេន ៖** " ពិតមែន អាចចម្រើនបាន "

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះថេរៈ** បានធ្វើការឧបមារឿងដើមឈើ ដល់ព្រះចៅមិលិន្ទនោះថា ខន្ធទាំងឡាយ ជារុក្ខជាតិនៃគំនរទុក្ខទាំងអស់ ។

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់កោដិបញ្ញាយនប្បញ្ហាទី ៣*

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

*បញ្ហាស្តីអំពីការបង្ហាញឡើងនៃចុងបំផុត ឈ្មោះថា **កោដិបញ្ញាយនប្បញ្ហា** ។*

*ពាក្យថា **ចុងបំផុតខាងដើម** ទោះគ្រប់យ៉ាងឬដែលមិនបង្ហាញ ? បានសេចក្តីថា ចុងបំផុតខាងដើមនៃអទ្ធានៈ ( របស់មានកាល ) ដែលជាអតីត ចុងបំផុតខាងដើមនៃអទ្ធានៈដែលជាអនាគត ចុងបំផុតខាងដើមនៃអទ្ធានៈដែលជាបច្ចុប្បន្នទាំងអស់តែម្តងឬដែលមិនបង្ហាញ ? ។ ព្រោះហេតុនោះព្រះថេរៈទើបថ្វាយវិសជ្ជនាថា " សូមថ្វាយព្រះពរ ចុងបំផុតខាងដើមខ្លះបង្ហាញ ចុងបំផុតខាងដើមខ្លះមិនបង្ហាញ " ដូចនេះ ។*

*ពាក្យថា **មុននេះអវិជ្ជាមិនធ្លាប់មាន** បានសេចក្តីថា ចុងបំផុតខាងដើមនៃអវិជ្ជា ដែលគួរពិចារណាឱ្យឃើញថា មានឬមិនមានហ្ន៎ ? ដូចនេះ ចុងបំផុតខាងដើម នៃអវិជ្ជានោះ មិនបង្ហាញ ។ ព្រះថេរៈថ្វាយវិសជ្ជនា ដោយលើកយកចំពោះតែអវិជ្ជា មកជានិទស្សន៍ ។ គួរជ្រាបថា ចុងបំផុតខាងដើមទោះជាធម៌ផ្សេង ៗ មានសង្ខារ ជាដើម សុទ្ធតែមិនបង្ហាញ បានសេចក្តីថា ពុំមាននរណាអាចដឹងបាន ។*

*ចុងបំផុតខាងដើមខ្លះបង្ហាញយ៉ាងដូចម្តេច ? ក្នុងការកើតឡើងតាំងនៅនិងរលត់ទៅនៃខន្ធនីមួយ ៗ ដែលដល់ខណៈទាំង ៣ ការកើតឡើង*

ដែលអាចឃើញបាន ដោយឧទយព្វយញ្ញាណ ចាត់ទុកជាចុងបំផុតខាងដើម នៃការរលត់ទៅ ឈ្មោះថា រមែងបង្ហាញ ។ ទោះជាការរលត់ទៅ ក៏ចាត់ទុកជាចុងបំផុត នៃការកើតឡើង ឈ្មោះថា រមែងបង្ហាញ ។ ការកើតឡើងគឺនិព្វត្តិលក្ខណៈ ( លក្ខណៈដែលធ្វើឱ្យកើត ) លោកហៅថា **ឧទយៈ**-ការកើតឡើង ។ ការរលត់ទៅ គឺ វិបរិណាមលក្ខណៈ លោកហៅថា **វយៈ**-ការប្រាសចាកទៅ ។ សម្រាប់អទ្ធានៈ ( របស់មានកាល ) ដែលជាបច្ចុប្បន្ន ចុងបំផុតខាងដើមរមែងបង្ហាញដោយចុងបំផុតខាងចុងយ៉ាងនេះ។

ព្រះយោគាវចរនោះ រមែងពិចារណាឃើញថា ក្នុងកាលទោះជាអតីតដែលមានលំដាប់មុន ៗ នៃខន្ធ ដែលដល់ខណៈទាំង ៣ ចុងបំផុតខាងដើមក៏បានបង្ហាញហើយ ដោយចុងបំផុតខាងចុង ។ ក្នុងកាលទោះជាអនាគតដែលមានលំដាប់ក្រោយ ៗ នៃខន្ធ ដែលដល់ខណៈ ទាំង ៣ ចុងបំផុតខាងដើម ក៏រមែងបង្ហាញដោយចុងបំផុតខាងចុង ដូចជា ខន្ធដែលដល់ខណៈទាំង ៣ ក្នុងកាលបច្ចុប្បន្ននោះដែរ ។ ព្រះថេរៈសំដៅយកសេចក្តីដូចពោលខាងលើមកនេះ ពោលថា " **អ្វីដែលមិនមានក៏មកមានឡើង មានហើយក៏បែរជាប្រាសចាកទៅ** " ដូចនេះ ។

ក្នុងពាក្យនោះ ពាក្យ **អ្វី** គឺរុក្ខជាតិ គឺខន្ធ ។ ពាក្យថា **មិនមាន** គឺមិនធ្លាប់មានពីមុន ។ ពាក្យថា **ក៏មកមានឡើង** គឺ ក៏មកមានឡើងក្នុងពេលនេះ ។ ពាក្យថា **មានហើយ** គឺមានក្នុងពេលនេះហើយ ។ ពាក្យថា **បែរជាប្រាសចាកទៅ** គឺបែរជាប្រាសចាកទៅក្នុងពេលនេះ ។ ចុងបំផុតខាងដើម ដែលអាចឃើញបានយ៉ាងនេះ រមែងបង្ហាញដោយចុងបំផុតខាងចុង ។

ពាក្យថា **ចុងបំផុតដែលត្រូវកាត់ដោយខណៈទាំង ២ អាចចម្រើនបានឬ ?** គឺ អាចឃើញជាក់ច្បាស់បានដោយញាណឬ ? ព្រះថេរៈពោលសំដៅ

*យកឧទយព្វយញ្ញាណ ។ ព្រោះហេតុនោះ ទើបព្រះរាជាត្រាស់ឆ្លើយថា "ពិតមែន ចុងបំផុត នោះអាចចម្រើនបាន" គឺអាចដឹងបាន ។*

*ពាក្យថា* ***ចុងបំផុតអាចចម្រើនបាន ដោយចុងបំផុតឬ?*** *បានសេចក្តីថា ចុងបំផុតខាងដើមអាចចម្រើនបាន គឺដឹងបានមិនដាច់រយៈ ដោយចុងបំផុតខាងចុងឬទេ ? ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៣*

# បញ្ហាទី ៤ - សង្ខារដោយមានប្បញ្ហា

**ព្រះរាជា** *ត្រាស់សួរថា ៖ " ព្រះគុណម្ចាស់នាគសេន សង្ខារមួយក្រុមមាន (ពេលមានសង្ខារទាំងនោះ) សង្ខារមួយក្រុមក៏រមែងកើតឡើងឬ?*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវហើយ សង្ខារមួយក្រុមរមែងកើតឡើង"*

**ព្រះចៅមិលិន្ទ ៖** *" សង្ខារដែលមាន និងសង្ខារដែលកើតឡើងក្រុមនោះ យ៉ាងដូចម្តេច ព្រះគុណម្ចាស់?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ពេលមានចក្ខុ(ភ្នែក) និងពេលមានរូប ( រូបភាព ) ក៏រមែងមានចក្ខុវិញ្ញាណ ។ ពេលមានចក្ខុវិញ្ញាណ ក៏រមែងមានវេទនា ។ ពេលមានវេទនា ក៏រមែងមានតណ្ហា ។ ពេលមានតណ្ហា ក៏រមែងមានឧបាទាន ។ ពេលមានឧបាទាន ក៏រមែងមានភព ។ ពេលមានភព ក៏រមែងមានជាតិ ។ ពេលមានជាតិ ក៏រមែងមានជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ។ ការកើតឡើងនៃគំនរទុក្ខទាំងអស់នេះរមែងមានដោយអាការយ៉ាងនេះ។*

*សូមថ្វាយព្រះពរ ពេលគ្មានចក្ខុ និងពេលគ្មានរូប ក៏រមែងគ្មានចក្ខុវិញ្ញាណ ។*

*ពេលគ្មានចក្ខុវិញ្ញាណ ក៏រមែងគ្មានចក្ខុសម្ផស្សៈ ។*

*ពេលគ្មានចក្ខុសម្ផស្សៈ ក៏រមែងគ្មានវេទនា ។*

*ពេលគ្មានវេទនា ក៏រមែងគ្មានតណ្ហា ។*

*ពេលគ្មានតណ្ហា ក៏រមែងគ្មានឧបាទាន ។*

*ពេលគ្មានឧបាទាន ក៏រមែងគ្មានភព ។*

*ពេលគ្មានភព ក៏រមែងគ្មានជាតិ ។*

*ពេលគ្មានជាតិ ក៏រមែងគ្មានជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ។*

*ការរលត់ទៅនៃគំនរទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ" ។*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់សង្ខារដោយមានបញ្ហាទី ៤*

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

*បញ្ហាសួរដល់សង្ខារដែលកើតឡើងឈ្មោះថា* ***សង្ខារដោយមានបញ្ហា***។

*ពាក្យថា* ***សង្ខារមួយក្រុម*** *គឺសង្ខារ(អ្វីដែលបច្ច័យធ្វើឱ្យកើតឡើង) ទាំងឡាយទាំងពួង ដែលបានប្រកាន់យកដោយពាក្យថា សង្ខារ ក្នុងភស្តុតាងដែលមានថា " សង្ខារទាំងឡាយទាំងពួងមិនទៀង សង្ខារទាំងឡាយ*

*ទាំងពួងជាទុក្ខ " ដូចនេះ គឺមិនបានសំដៅយកសង្ខារដែលមាន អវិជ្ជាជាបច្ច័យនោះទេ ព្រោះថាព្រះរាជាត្រាស់សួរថា " ពេលសង្ខារមួយក្រុមមានសង្ខារមួយក្រុមរមែងកើតឡើងឬ?" ដូចនេះឯង ។*

*ពាក្យថា* **កតមេ តេ** *បានសេចក្ដីថា សង្ខារមួយក្រុមដែលមាននោះយ៉ាងដូចម្ដេច? និង សង្ខារមួយក្រុមដែលកើតឡើងនោះ យ៉ាងដូចម្ដេច?។*

*ព្រះថេរៈ ត្រូវការឆ្លើយពាក្យត្រាស់សួរនោះ ទើបពោលថា " ពេលមានចក្ខុ និង ពេលមានរូប ក៏រមែងមានចក្ខុវិញ្ញាណ " ដូចនេះជាដើម ។ ក្នុងពាក្យវិសជ្ជនានោះ ប្រសិនបើសួរបញ្ច្រាសទៅវិញថា ពេលមានអ្វីទៅទើបមានចក្ខុ? ឆ្លើយថា ពេលមាននាមរូប ទើបមានចក្ខុ ។ ពេលមានអ្វីទៅទើបមាននាមរូប? ពេលមានវិញ្ញាណ ទើបមាននាមរូប ។ ពេលមានអ្វីទៅទើបមានវិញ្ញាណ? ពេលមានសង្ខារ ទើបមានវិញ្ញាណ ។ ពេលមានអ្វីទៅទើបមានសង្ខារ? ពេលមានអវិជ្ជា ទើបមានសង្ខារ ដូចនេះ ។*

*ព្រោះហេតុនោះ ទើបគួរធ្វើការប្រកបសេចក្ដីឱ្យបរិបូរយ៉ាងនេះថា ពេលមានអវិជ្ជា ក៏រមែងមានសង្ខារ ពេលមានសង្ខារ ក៏រមែងមានវិញ្ញាណ ពេលមានវិញ្ញាណ ក៏រមែងមាននាមរូប ពេលមាននាមរូប ក៏រមែងមានចក្ខុ ពេលមានចក្ខុនិងរូប ក៏រមែងមានចក្ខុវិញ្ញាណ ។ល។ ពេលមានជាតិ ក៏រមែងមាន ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ។*

*ទោះក្នុងនិរោធវារៈ ក៏គួរធ្វើការប្រកបសេចក្ដីឱ្យបរិបូរ យ៉ាងនេះថា ពេលគ្មានអវិជ្ជា ក៏រមែងគ្មានសង្ខារ ។ល។ ពេលគ្មានចក្ខុនិងរូប ក៏រមែងគ្មានចក្ខុវិញ្ញាណ ។ ល។ ពេលគ្មានជាតិ ក៏រមែងគ្មានជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាស ។*

*ពាក្យថា* ***ការរលត់ទៅ*** *(នៃគំនរទុក្ខទាំងអស់)គឺការរលត់ គឺការមិនកើត*

ឡើង ដោយប្រការយ៉ាងនេះ គឺ ពេលវិជ្ជាកើតឡើង ក៏រមែងគ្មានអវិជ្ជា ក៏រមែងគ្មានសង្ខារ ដូចនេះ ជាដើម ។

ចប់ពាក្យអធិប្បាយបញ្ហាទី ២

# បញ្ហាទី ៤ - ភវន្តសង្ខារជាយមានប្បញ្ញា

**ព្រះរាជា** ត្រាស់សួរថា ៖ " ព្រះគុណម្ចាស់នាគសេន សង្ខារអ្វីៗដែលកើតមក ជារបស់មិនមាននៅឬ?"

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ សង្ខារអ្វីៗដែលកើតមកជារបស់មិនមាននៅ សង្ខារទាំងនោះពុំមានទេ ។ សូមថ្វាយព្រះពរ សង្ខារទាំងឡាយកើតមក សុទ្ធតែជារបស់មាននៅទាំងអស់ "

**ព្រះចៅមិលិន្ទ** ៖ " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច ? ព្រះរាជដំណាក់ដែលព្រះអង្គប្រថាប់នៅនេះ កើតមកជារបស់មិនមាននៅ ឬយ៉ាងណា ?"

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់ ក្នុងផ្ទះនេះអ្វី ៗ ដែលកើតមកជារបស់មិនមាននៅ គឺពុំមាននោះទេ អ្វី ៗ ដែលកើតមកជារបស់មាននៅទាំងអស់ ។ ព្រះគុណម្ចាស់ ដើមឈើទាំងឡាយមានស្រាប់ហើយនៅក្នុងព្រៃ ដី (ដែលយកមកធ្វើជញ្ជាំង)ក៏មានស្រាប់ហើយនៅលើផ្ទៃដី អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ចំពោះការងារនោះ របស់បុរសនិងស្ត្រីទាំងឡាយ យ៉ាងនេះហើយ ផ្ទះមួយខ្នងនេះ ទើបសម្រេចបាន "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏

*យ៉ាងនោះដែរ សង្ខារអ្វី ៗ ដែលកើតមកជារបស់មិនមាននៅ សង្ខារទាំងនោះពុំមានទេ សង្ខារទាំងនោះ កើតមកសុទ្ធតែជារបស់មាននៅទាំងអស់"*

**ព្រះចៅមិលិន្ទ ៖** *"សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជារុក្ខជាតិមួយដើម ដែលគេដាំនៅលើផ្ទៃដី ពេលដល់សេចក្ដីចម្រើន សេចក្ដីរីកលូតលាស់ទៅតាមលំដាប់ក៏បានផ្ដល់ផ្កានិងផ្លែ ដើមឈើទាំងនោះ ពុំមែនកើតមកជារបស់មិនមាននៅនោះទេ ដើមឈើទាំងនោះ កើតមានសុទ្ធតែជារបស់មាននៅទាំងអស់ ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ សង្ខារអ្វី ៗ ដែលកើតមកជារបស់មិនមាននៅ សង្ខារទាំងនោះ ពុំមានទេ សង្ខារទាំងនោះ កើតមកសុទ្ធតែជារបស់មាននៅទាំងអស់ ដូចនេះដែរ"*

**ព្រះចៅមិលិន្ទ ៖** *"សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា ពួកជាងធ្វើឆ្នាំងដី ចូកយកដី ពីផ្ទៃផែនដី មកធ្វើជាភាជនៈផ្សេង ៗ ភាជនៈទាំងនោះ ពុំមែនកើតមក ជារបស់មិនមាននៅទេ កើតមកសុទ្ធតែជារបស់មាននៅទាំងអស់ ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ សង្ខារអ្វី ៗ ដែលកើតមកជារបស់មិនមាននៅ សង្ខារទាំងនោះ ពុំមានទេ សង្ខារទាំងឡាយកើតមក សុទ្ធតែជារបស់មាននៅទាំងអស់"*

**ព្រះចៅមិលិន្ទ ៖** *"សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា តួពិណគ្មាន ស្បែកពិណក៏គ្មាន ពោះពិណក៏គ្មាន ដងពិណក៏គ្មាន ក-ពិណក៏គ្មាន ខ្សែពិណក៏*

*គ្មាន ឧបករណ៍កេះខ្សែពិណក៏គ្មាន និងសេចក្ដីព្យាយាមដ៏សមគួរចំពោះការនោះ របស់បុរសក៏គ្មាន តើសំឡេងពិណកើតឡើងបានយ៉ាងដូចម្ដេច ?*

**ព្រះចៅមិលិន្ទ ៖** *" សំឡេងពិណមិនអាចកើតឡើងបានទេ ព្រះគុណ-ម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប៉ុន្តែពេលណាដែលតួពិណមានស្បែកពិណក៏មាន ពោះពិណក៏មាន ដងពិណក៏មាន ក-ពិណក៏មាន ខ្សែពិណក៏មាន ឧបករណ៍កេះខ្សែពិណក៏មាន និងសេចក្ដីព្យាយាមដ៏សមគួរចំពោះការនោះ របស់បុរសក៏មាន សំឡេងពិណអាចកើតឡើងបាន មែនឬទេ ? "*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន អាចកើតបានព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សង្ខារអ្វី ៗ ដែលកើតមក ជារបស់មិនមាននៅ សង្ខារទាំងនោះពុំមានទេ សង្ខារទាំងនោះកើតមក សុទ្ធតែជារបស់មាននៅទាំងអស់ "*

**ព្រះចៅមិលិន្ទ ៖** *"សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាឈើមេកួតភ្លើងគ្មាន ឈើកូនកួតភ្លើងក៏គ្មាន ខ្សែចងឈើកួតភ្លើងក៏គ្មាន ឈើកួតភ្លើងកំណាត់លើក៏គ្មាន កម្ទេចកួតក៏គ្មាន និងសេចក្ដីព្យាយាមដ៏សមគួរចំពោះការនោះ របស់បុរសក៏គ្មាន ភ្លើងនោះអាចកើតបានឬទេ ? "*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចកើតបានទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប៉ុន្តែពេលណាដែលឈើមេកួតភ្លើងមាន ឈើកូនកួតភ្លើងក៏មាន ខ្សែចងឈើកួតភ្លើងក៏មាន ឈើកួតភ្លើង*

*កំណាត់លើក៏មាន កម្ទេចក្ជួតក៏មាន និង សេចក្ដីព្យាយាមដ៏សមគួរចំពោះការនោះ របស់បុរសក៏មាន ភ្លើងនោះអាចកើតបានមែនឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន អាចកើតបាន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សង្ខារអ្វី ៗ ដែលកើតមកជារបស់មិនមាននៅ សង្ខារទាំងនោះពុំមានទេ សង្ខារទាំងនោះកើតមក សុទ្ធតែជារបស់មាននៅទាំងអស់ "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀត "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជា កែវមណីក៏គ្មាន ពន្លឺថ្ងៃក៏គ្មាន គោម័យក៏គ្មាន ភ្លើងនោះអាចកើតបានឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចកើតបានទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" ប៉ុន្តែពេលណាដែលកែវមណីមាន ពន្លឺថ្ងៃក៏មាន គោម័យក៏មាន ភ្លើងនោះអាចកើតឡើងបានឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន អាចកើតបាន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សង្ខារអ្វី ៗ ដែលកើតមកជារបស់គ្មាននៅ សង្ខារទាំងនោះពុំមានទេ សង្ខារទាំងនោះកើតមក សុទ្ធតែជារបស់មាននៅទាំងអស់ "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀត "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាកញ្ចក់ឆ្លុះគ្មាន ពន្លឺភ្លឺក៏គ្មាន មុខអ្នកឆ្លុះក៏គ្មាន មនុស្ស ( រូបភាពមុខមនុស្ស ) អាចកើតឡើងបានឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចកើតបានទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប៉ុន្តែពេលណាដែលកញ្ចក់ឆ្លុះក៏*

*មាន ពន្លឺភ្លឺក៏មាន មុខអ្នកឆ្លុះក៏មាន មនុស្ស ( រូបភាពមុខមនុស្ស ) អាចកើតឡើងបានមែនឬទេ ? "*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន អាចកើតបាន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សង្ខារអ្វី ៗ ដែលកើតមកជារបស់គ្មាននៅ សង្ខារទាំងនោះពុំមាននោះទេ សង្ខារទាំងនោះ កើតមកសុទ្ធតែជារបស់មាននៅទាំងអស់ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់ភវន្តសង្ខារជាយមានបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាស្តីអំពីរបស់ដែលមាននៅ កើតជាសង្ខារទាំងឡាយឈ្មោះថា* ***ភវន្តសង្ខារជាយមានបញ្ហា*** *។*

*ពាក្យថា* ***ព្រះរាជដំណាក់ដែលព្រះអង្គប្រថាប់នៅនេះ កើតមកជារបស់គ្មាននៅឬយ៉ាងណា ?*** *បានសេចក្តីថា មិនមាននៅឬ ? ។ ប្រសិនបើ មិនមាននៅ សូមសួរថា ព្រះអង្គប្រថាប់នៅក្នុងកន្លែងណា ? ព្រះរាជាពេលនឹងទ្រង់សម្តែងថា សុទ្ធតែជារបស់មាននៅទាំងអស់ ទើបត្រាស់ថា " ព្រះគុណម្ចាស់ដើមឈើទាំងឡាយក៏មានស្រាប់ ហើយនៅក្នុងព្រៃ " ដូចនេះ ជាដើម ។*

*ពាក្យថា* ***សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ*** *បានសេចក្តីថា ព្រះថេរៈបដិសេធថា សូមថ្វាយព្រះពរ ប្រសិនបើក្នុងព្រះរាជដំណាក់របស់ព្រះអង្គនេះ ឈើ ដី អ្វី ៗ ជារបស់មិនមាននៅទេ ព្រះរាជ*

*ដំណាក់អ្វី ៗ ក៏រមែងមិនមាន ។ ប៉ុន្តែ ព្រោះហេតុតែឈើនិងដី ជារបស់មានស្រាប់នៅក្នុងព្រៃ និងនៅលើផ្ទៃដី ព្រោះហេតុនោះ ព្រះរាជដំណាក់ដែលកើតឡើងពីឈើនិងដីនេះ រមែងជារបស់មាននៅ ។*

*យ៉ាងណាមិញ ប្រសិន បើបច្ច័យនៃសង្ខារអ្វី ៗ កើតមកជារបស់មិនមាននៅ សង្ខារអ្វី ៗ ក៏រមែងមិនមានទាំងអស់ ប៉ុន្តែព្រោះហេតុតែបច្ច័យនៃសង្ខារ ជារបស់មាននៅ ព្រោះហេតុនោះ សង្ខារអ្វី ៗ ដែលកើតមក សុទ្ធតែជារបស់មាននៅទាំងអស់ ដូចនេះ ។*

*ទោះជាឧបមាផ្សេង ៗ ទៀត ក៏គួរជ្រាបអត្ថន័យតាមន័យនេះផងចុះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៥*

# បញ្ហាទី ៦ - វេទគូបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា “ ព្រះគុណម្ចាស់នាគសេន វេទគូមានឬទេ ? ”*

**ព្រះនាគសេន ៖** *“ សូមថ្វាយព្រះពរ តើនរណាទៅឈ្មោះថា វេទគូនេះ ? ”*

**ព្រះចៅមិលិន្ទ ៖** *“ ព្រះគុណម្ចាស់នាគសេន គឺ តួអព្ភន្តរជីវៈ ( ជីវៈខាងក្នុង ) ដែលសម្លឹងមើលរូបផ្លូវភ្នែក ស្តាប់សំឡេងផ្លូវត្រចៀក ហិតក្លិនផ្លូវច្រមុះ ភ្លក់រសផ្លូវអណ្តាត ត្រូវផោដ្ឋព្វៈផ្លូវកាយ ដឹងធម៌ផ្លូវចិត្ត ។*

*ប្រៀបដូចជា យើងអង្គុយនៅលើប្រាសាទ ត្រូវការសម្លឹងមើលទៅតាមបង្អួចណា យើងក៏សម្លឹងមើលទៅតាមបង្អួចនោះបាន គឺថា នឹងសម្លឹងមើលទៅតាមបង្អួចទិសខាងកើតក៏បាន នឹងសម្លឹងមើលទៅ តាមបង្អួចទិសខាងលិចក៏បាន នឹងសម្លឹងមើលទៅតាមបង្អួចទិសខាងត្បូងក៏បាន ។*

*យ៉ាងណាមិញ ព្រះគុណម្ចាស់ តួអព្ភន្តរជីវៈនេះត្រូវការនឹងសម្លឹងមើលរូបជាដើម តាមទ្វារណា ក៏រមែងសម្លឹងមើលរូបជាដើម តាមទ្វារនោះបាន ដូចនេះដែរ"*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា " សូមថ្វាយព្រះពរ អាត្មាភាពសូមថ្វាយព្រះពរ ពោលដល់ទ្វារ ៥ សូមព្រះអង្គទ្រង់សណ្ដាប់រឿងទ្វារ ៥ នោះ ។ សូមទ្រង់ធ្វើទុក ក្នុងព្រះទ័យឱ្យបានល្អ ផងចុះ ។*

*ប្រៀបដូចជា យើងអង្គុយនៅលើប្រាសាទ ត្រូវការសម្លឹងមើលរូបតាមបង្អួចមួយណា យើងក៏សម្លឹងមើលចំពោះរូបនោះតែម្ដង តាមបង្អួចមួយនោះ គឺ យើងអាចសម្លឹងមើលរូបនោះ តាមបង្អួចទិសខាងកើតក៏បាន អាចសម្លឹងមើលរូបនោះ តាមបង្អួចទិសខាងលិចក៏បាន អាចសម្លឹងមើលរូបនោះ តាមបង្អួចទិសខាងជើងក៏បាន អាចសម្លឹងមើលរូបនោះ តាមបង្អួចទិសខាងត្បូងក៏បាន ។*

*យ៉ាងណាមិញ ប្រសិនបើតួអព្ភន្តរជីវៈ អាចសម្លឹងមើលរូបផ្លូវភ្នែកបាន តួអព្ភន្តរជីវៈនោះ ក៏អាចសម្លឹងមើលរូបនោះផ្លូវត្រចៀកក៏បាន អាចសម្លឹងមើលរូបនោះផ្លូវច្រមុះក៏បាន អាចសម្លឹងមើលរូបនោះផ្លូវអណ្ដាតក៏បាន អាចសម្លឹងមើលរូបនោះផ្លូវកាយក៏បាន អាចសម្លឹងមើលរូបនោះផ្លូវចិត្តក៏បាន ។*

*អាចស្ដាប់សំឡេងនោះផ្លូវភ្នែកក៏បាន អាចស្ដាប់សំឡេងនោះផ្លូវច្រមុះក៏បាន អាចស្ដាប់សំឡេងនោះផ្លូវអណ្ដាតក៏បាន អាចស្ដាប់សំឡេងនោះផ្លូវកាយក៏បាន អាចស្ដាប់សំឡេងនោះផ្លូវចិត្តក៏បាន ។*

*អាចហិតក្លិននោះផ្លូវភ្នែកក៏បាន អាចហិតក្លិននោះផ្លូវត្រចៀកក៏បាន អាចហិតក្លិននោះផ្លូវអណ្ដាតក៏បាន អាចហិតក្លិននោះផ្លូវកាយក៏បាន អាចហិតក្លិននោះផ្លូវចិត្តក៏បាន។*

*អាចភ្លក់រសនោះផ្លូវភ្នែកក៏បាន អាចភ្លក់រសនោះផ្លូវត្រចៀកក៏បាន អាចភ្លក់រសនោះផ្លូវច្រមុះក៏បាន អាចភ្លក់រសនោះផ្លូវកាយក៏បាន អាចភ្លក់រសនោះផ្លូវចិត្តក៏បាន ។*

*អាចប៉ះពាល់ផោដ្ឋព្វៈនោះផ្លូវភ្នែកក៏បាន អាចប៉ះពាល់ផោដ្ឋព្វៈនោះផ្លូវត្រចៀកក៏បាន អាចប៉ះពាល់ផោដ្ឋព្វៈនោះផ្លូវច្រមុះក៏បាន អាចប៉ះពាល់ផោដ្ឋព្វៈនោះផ្លូវអណ្ដាតក៏បាន អាចប៉ះពាល់ផោដ្ឋព្វៈនោះផ្លូវចិត្តក៏បាន ។*

*អាចដឹងធម៌ទោះបីផ្លូវភ្នែកក៏បាន អាចដឹងធម៌ទោះបីផ្លូវត្រចៀកក៏បាន អាច ដឹងធម៌ទោះបីផ្លូវច្រមុះក៏បាន អាចដឹងធម៌ទោះបីផ្លូវអណ្ដាតក៏បាន អាចដឹងធម៌ ទោះបីផ្លូវកាយក៏បាន ដូចនេះដែរឬយ៉ាងណា ?"*

**ព្រះចៅមិលិន្ទ ៖** *" មិនមែនទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះបន្ទូលរបស់ព្រះអង្គពេលក្រោយ មិនសមនឹងពេលដំបូង ឬ ពេលមុនដំបូងមិនសមនឹងពេលក្រោយ ។ សូមថ្វាយព្រះពរ ម៉្យាងវិញទៀត ប្រៀបដូចជា យើងអង្គុយនៅលើប្រាសាទនេះ បើកបង្អួចទាំងនេះចេញបែរមុខតម្រង់ទៅ ខាងក្រៅខាងអាកាសដ៏ធំទូលាយក៏រមែងសម្លឹងមើលរូបបានច្បាស់បំផុត ។*

*យ៉ាងណាមិញ តួអព្ភន្តរជីវៈនោះ ពេលបានបើកចក្ខុទ្វារ បែរមុខតម្រង់ទៅក្រៅខាងអាកាសដ៏ធំទូលាយ ក៏រមែងមើលរូបបានច្បាស់បំផុត ពេលបានបើកសោតទ្វារ... ពេលបានបើកឃានទ្វារ... ពេលបានបើកជិវ្ហាទ្វារ ... ពេលបានបើកកាយទ្វារ បែរមុខសម្លឹងទៅខាងក្រៅខាងអាកាសដ៏ធំទូលាយ ក៏រមែងសម្លឹងមើលរូបបានច្បាស់បំផុត ។*

*ម៉្យាងទៀត ពេលបានបើកសោតទ្វារ បែរមុខតម្រង់ទៅខាងក្រៅខាងអាកាសដ៏ធំទូលាយ ក៏រមែងស្ដាប់សំឡេងបានច្បាស់បំផុត ។ ពេលបានបើក*

*ចក្ខុទ្វារ... ពេលបានបើកជិវ្ហាទ្វារ... ពេលបានបើកកាយទ្វារ... បែរមុខតម្រង់ទៅខាងក្រៅខាងអាកាសដ៏ធំទូលាយក៏រមែងស្តាប់សំឡេងបានច្បាស់បំផុត។*

*ម៉្យាងទៀត ពេលបានបើកឃានទ្វារ បែរមុខតម្រង់ទៅខាងក្រៅខាងអាកាសដ៏ធំទូលាយ ក៏រមែងហិតក្លិនបានច្បាស់បំផុត ... ។ល។ ពេលបានបើកជិវ្ហាទ្វារ ក៏រមែងបានភ្លក់រសច្បាស់បំផុត ... ។ល។ ពេលបានបើកកាយទ្វារ ក៏រមែងប៉ះពាល់ផោដ្ឋព្វៈបានច្បាស់បំផុត ... ។ល។ ដូចនេះដែរ ឬយ៉ាងណា?"*

**ព្រះចៅមិលិន្ទ ៖** " មិនមែនទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះបន្ទូលរបស់ព្រះអង្គពេលក្រោយ មិនសមនឹងពេលមុនដំបូង ឬពេលមុនដំបូងមិនសមនឹងពេលក្រោយ ។*

*សូមថ្វាយព្រះពរ ម៉្យាងវិញទៀត ប្រៀបដូចជា បុរសម្នាក់នេះបានទទួលព្រះរាជទានរួច ក៏ចេញទៅឈរនៅខ្លោងទ្វារខាងក្រៅ ។*

*សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ជ្រាបឬទេថា បុរសម្នាក់នេះបានទទួលព្រះរាជទាន រួចចេញទៅឈរនៅខ្លោងទ្វារខាងក្រៅ?"*

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន ខ្ញុំព្រះករុណាជ្រាប ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ម៉្យាងទៀត ប្រៀបដូចជា បុរសម្នាក់នេះ បានទទួលព្រះរាជទានរួច ចូលទៅឈរនៅពីមុខព្រះភក្ត្ររបស់ព្រះអង្គ ។*

*សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ជ្រាបឬទេថា បុរសម្នាក់នេះ បានទទួលព្រះរាជទានរួច ចូលទៅឈរនៅចំពោះមុខយើង?"*

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន ខ្ញុំព្រះករុណាជ្រាប ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ តួអព្ភន្តរជីវៈនោះ ពេលបានដាក់រសនៅលើអណ្ដាត អាចដឹងបាន ឬទេថាជារសជូរ ឬថាជារសល្វីង ឬថាជារសហឹរ ឬថាជារសចត់ ឬថាជារសផ្អែម?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន អាចដឹងបាន ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" ពេលមិនបានយករសដាក់ចូលទៅក្នុងមាត់ តួអព្ភន្តរជីវៈនោះ អាចដឹងបានឬទេថាជារសជូរ ឬថាជារសប្រៃ ឬថាជារសល្វីង ឬថាជារសហឹរ ឬថាជារសចត់ ឬថាជារសផ្អែម?"*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចដឹងបានទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះបន្ទូលរបស់ព្រះអង្គពេលក្រោយ មិនសមនឹងពេលមុនដំបូង ឬពេលមុនដំបូងមិនសមនឹងពេលក្រោយ ។*

*សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសម្នាក់ឱ្យយកទឹកឃ្មុំ ១០០ ផ្ទាំងមកចាក់ឱ្យពេញស្នូក ដាក់ទឹកឃ្មុំ រួចចងមាត់បុរសម្នាក់ រួចហើយចាប់ដាក់ទៅក្នុងស្នូកដាក់ទឹកឃ្មុំ ។*

*សូមថ្វាយព្រះពរ បុរសម្នាក់នោះនឹងអាចដឹងបានទេថា ជាទឹកឃ្មុំល្អ ឬជាទឹកឃ្មុំ មិនល្អ? "*

**ព្រះចៅមិលិន្ទ ៖** *" មិនអាចដឹងបានទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *"ព្រោះហេតុអ្វីឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ព្រោះថាទឹកឃ្មុំមិនបានចូលទៅក្នុងមាត់របស់គេ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះបន្ទូលរបស់ព្រះអង្គពេល*

ក្រោយ មិនសមនឹងពេលមុនដំបូង ឬពេលមុនដំបូងមិនសមនឹងពេលក្រោយ ។

**ព្រះចៅមិលិន្ទ ៖** " ខ្ញុំព្រះករុណាមិនមែនជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ នឹងឆ្លងឆ្លើយជាមួយព្រះគុណម្ចាស់ដែលជាកំពូលវាទៈបាន សូមព្រះគុណម្ចាស់ មេត្តាអធិប្បាយសេចក្តីផងចុះ " ។

**ព្រះថេរៈ** បានធ្វើឱ្យព្រះរាជាទ្រង់បានយល់ ដោយពាក្យពេចន៍ប្រកបដោយព្រះអភិធម្មថា " សូមថ្វាយព្រះពរមហាបពិត្រ ក្នុងសេចក្តីប្រការនេះ ចក្ខុវិញ្ញាណអាស្រ័យចក្ខុ ( ប្រសាទភ្នែក ) និងរូបកើតឡើង ។ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការ ជាធម៌ដែលកើតរួមជាមួយចក្ខុវិញ្ញាណនោះ ។

ធម៌ទាំងនេះ រមែងកើតពីបច្ច័យតាមប្រការដូចពោលខាងលើមកនេះដូចនេះ វេទគូពុំមាននៅក្នុងធម៌ទាំងនេះទេ ។ សោតវិញ្ញាណអាស្រ័យសោតៈ(ប្រសាទត្រចៀក) និងសទ្ទៈ (សំឡេង)កើតឡើង ។ល។ មនោវិញ្ញាណអាស្រ័យមនៈ(ចិត្ត) និងធម៌ទាំងឡាយ កើតឡើង ។ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការ ជាធម៌ដែលកើតរួមជាមួយចក្ខុវិញ្ញាណនោះ ។

ធម៌ទាំងនេះ រមែងកើតពីបច្ច័យ តាមប្រការដូចពោលខាងលើមកនេះដូចនេះ វេទគូពុំមាននៅក្នុងធម៌ទាំងនេះទេ " ដូចនេះ ។

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់វេទគូបញ្ហាទី ៦

# ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*អត្តា ( ខ្លួន ) ហៅថា **វេទគូ** ព្រោះអត្ថន័យថា មានធម្មតាដល់វេទគូ (ការដឹង) ។*

*ពាក្យថា **តួអព្ភន្តរជីវៈនោះ ពេលបានដាក់រសលើអណ្ដាត អាចដឹងបាន ឬទេថា ជារសជូរ** ជាដើម តួអព្ភន្តរជីវៈនោះពេលបានដាក់រសលើអណ្ដាត មិនបានដាក់ក្រៅមាត់ អាចដឹងតាមផ្លូវទ្វារអណ្ដាតនោះឬទេថា ជារសជូរ ជាដើម ។ ឈ្មោះថា ដាក់រសលើអណ្ដាត លោកពោលដល់បរិវេណ ចាប់តាំងពីគល់ករហូតដល់ផ្នែកក្រៅនៃមាត់ ។*

*ពាក្យថា **ពេលមិនបានយករសដាក់ចូលទៅក្នុងមាត់ តួអព្ភន្តរជីវៈនោះ អាចដឹង ឬទេថាជារសជូរ** ជាដើម បានសេចក្ដីថា ពេលមិនបានយករសដាក់ចូលទៅក្នុងមាត់ ដាក់នៅខាងក្រៅមាត់ មិនប៉ះនឹងអណ្ដាត តួអព្ភន្តរជីវៈនោះ អាចដឹងតាមផ្លូវទ្វារអណ្ដាតនោះ ឬទេថាជា រសជូរ ជាដើម ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៦*

# បញ្ហាទី ៧ - ចក្ខុវិញ្ញាណាទិបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងខាងទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងខាងទ្វារនោះឬ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវហើយ ចក្ខុវិញ្ញាណកើតឡើងខាងទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងខាងទ្វារនោះ "*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ ចក្ខុវិញ្ញាណរមែងកើតឡើងមុន មនោវិញ្ញាណរមែងកើតឡើងពេលក្រោយឬ ? ឬក៏មនោវិញ្ញាណរមែងកើតឡើងមុន ចក្ខុវិញ្ញាណរមែងកើតឡើងពេលក្រោយ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ចក្ខុវិញ្ញាណរមែងកើតឡើងមុន មនោវិញ្ញាណរមែងកើតឡើងពេលក្រោយ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណបានផ្តាំមនោវិញ្ញាណទុកថា "យើងកើតឡើងតាមទ្វារណា ទោះជាអ្នកក៏ត្រូវកើតឡើងតាមទ្វារនោះ" ដូចនេះឬយ៉ាងណា ? ឬក៏មនោវិញ្ញាណបានផ្តាំចក្ខុវិញ្ញាណថា " អ្នកនឹងកើតឡើងតាមទ្វារណា ទោះជាយើងក៏កើតឡើងតាមទ្វារនោះ" ដូចនេះឬ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ វិញ្ញាណទាំងនោះ មួយ ៗ ពុំមានការនិយាយស្តីគ្នាទេ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា មនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ យ៉ាងដូចម្តេច?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា មនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ក៏ព្រោះទ្វារនោះ ប្រៀបដូចជាទីទំនាប ប្រៀបដូចជាច្រកទ្វារ ប្រៀបដូចជាផ្លូវធ្វើដំណើរដែលធ្លាប់ស្គាល់និង ព្រោះសេចក្តីថា ទ្វារនោះជាកន្លែងដែលវិញ្ញាណទាំង ២ នោះ ដំណើរទៅជានិច្ចកាល* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា មនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះទ្វារនោះប្រៀបដូចជា ទីទំនាប យ៉ាងដូចម្តេច សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គទ្រង់យល់សេចក្តីប្រការនោះយ៉ាងដូចម្តេច ពេលភ្លៀងធ្លាក់ចុះមក ទឹកនឹងហូរទៅតាមណា ?"*

**ព្រះចៅមិលិន្ទ ៖** " *នឹងហូរទៅតាមទីទំនាប ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** " *នាសម័យក្រោយមក ភ្លៀងធ្លាក់មកទៀតទឹកនឹងហូរទៅតាមណា ?*

**ព្រះចៅមិលិន្ទ ៖** " *ទោះទឹកនោះ ក៏នឹងហូរទៅតាមកន្លែងដែលទឹកដំបូងបានហូរទៅ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ទឹកលើកដំបូងបានផ្តាំទឹកលើកក្រោយទុកថា " យើងហូរទៅតាមណា ទោះជាអ្នកក៏ត្រូវហូរទៅតាមនោះ " ដូចនេះឬយ៉ាងណា ? ឬថា ទឹកលើកក្រោយបានផ្តាំទឹកលើកដំបូងថា " អ្នកហូរទៅតាមណា យើងក៏នឹងហូរទៅតាមនោះ" ដូចនេះឬ ?"*

**ព្រះចៅមិលិន្ទ ៖** " *មិនមែនទេ ព្រះគុណម្ចាស់ ទឹកទាំងពីរលើកនោះមួយ ៗ ពុំមានការនិយាយស្តីគ្នាទេ រមែងហូរ(ទៅផ្លូវតែមួយ)ព្រោះជាផ្លូវទីទំនាប"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះទ្វារនោះប្រៀបដូចជាទីទំនាប ។ ចក្ខុវិញ្ញាណមិនបានបានផ្តាំមនោវិញ្ញាណទុកទេថា " យើងកើតឡើងតាមទ្វារណា ទោះជាអ្នកក៏ត្រូវកើតឡើងតាមទ្វារនោះ" ដូចនេះទេ ។ ទោះជាមនោ-វិញ្ញាណ ក៏មិនបានបានផ្តាំចក្ខុវិញ្ញាណ ទុកទេថា "អ្នកនឹងកើតឡើងតាមទ្វារណា ទោះជាយើងក៏នឹងកើតឡើងតាមទ្វារនោះ" ដូចនេះទេ ។ វិញ្ញាណទាំង ២ នោះ មួយ ៗ ពុំមានការនិយាយស្តីគ្នាទេ រមែងកើតឡើង ( តាមទ្វារតែ*

មួយបាន ) ព្រោះទ្វារនោះប្រៀបដូចជា ទីទំនាប "

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះសេចក្តីថា ទ្វារនោះ ប្រៀបដូចជាច្រកទ្វារយ៉ាងដូចម្តេច ? សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្តីប្រការ នោះយ៉ាងដូចម្តេច ? ក្រុងជាយដែនរបស់ព្រះរាជា ដែលមានប៉មការពារកំពែងរឹងមាំ មានច្រកទ្វារតែមួយ មាននៅ ។ បុរសដែលត្រូវការចេញពីក្រុងនោះ ត្រូវចេញទៅតាមណាបាន ? "

**ព្រះចៅមិលិន្ទ** ៖ " ត្រូវចេញទៅតាមច្រកទ្វារ ព្រះគុណម្ចាស់ "

**ព្រះនាគសេន** ៖ " បន្ទាប់មកមានបុរសម្នាក់ទៀត ត្រូវការចេញទៅគេនោះ ត្រូវចេញទៅតាមណាបាន ? "

**ព្រះចៅមិលិន្ទ** ៖ " គេត្រូវចេញទៅតាមច្រកទ្វារតែមួយ ដែលបុរសម្នាក់មុន បានចេញទៅ ព្រះគុណម្ចាស់ "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ បុរសម្នាក់មុនបានផ្តាំបុរសម្នាក់ក្រោយទុកថា " យើងទៅតាមណា ទោះជាអ្នកក៏ត្រូវទៅតាមនោះ " ដូចនេះឬយ៉ាងណា ? ឬក៏បុរសម្នាក់ក្រោយ បានផ្តាំបុរសម្នាក់មុនទុកថា " អ្នកនឹងទៅតាមណា ទោះជាយើង ក៏នឹងទៅតាមនោះ " ដូចនេះឬ ? "

**ព្រះចៅមិលិន្ទ** ៖ " មិនមែនទេ ព្រះគុណម្ចាស់ បុរសទាំង ២ នោះម្នាក់ ៗ ពុំមានការនិយាយស្តីគ្នានោះទេ ។ ពួកគេរមែងទៅ (ផ្លូវតែមួយ)ក៏ព្រោះផ្លូវនោះ ជាច្រកទ្វារ "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះទ្វារនោះប្រៀបដូចជា ច្រកទ្វារ ។ ចក្ខុវិញ្ញាណមិនបានផ្ដាំមនោវិញ្ញាណទុកទេថា " យើងកើតឡើងតាមទ្វារណា ទោះជាអ្នកក៏ត្រូវកើតឡើងតាមទ្វារនោះ " ដូចនេះទេ ។ ទោះជាមនោវិញ្ញាណ ក៏មិនបានផ្ដាំចក្ខុវិញ្ញាណទុកទេថា " អ្នកនឹងកើតឡើងតាមទ្វារណា ទោះជាយើងក៏នឹងកើតឡើងតាមទ្វារនោះ " ដូចនេះ ទេ ។ វិញ្ញាណទាំង ២ នោះ មួយ ៗ ពុំមានការនិយាយស្ដីគ្នាទេ រមែងកើតឡើង ( តាមទ្វារតែមួយបាន ) ព្រោះទ្វារនោះប្រៀបដូចជា ច្រកទ្វារ "*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណ ក៏កើតឡើងតាមទ្វារនោះ ព្រោះសេចក្ដីថា ទ្វារនោះ ប្រៀបដូចជា ផ្លូវដែលធ្លាប់ស្គាល់យ៉ាងដូចម្ដេច ? សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច រទេះគោទី ១ ត្រូវចេញមុន បន្ទាប់មករទេះគោទី ២ នឹងត្រូវចេញទៅតាមផ្លូវណា ?*

**ព្រះចៅមិលិន្ទ ៖** " *នឹងត្រូវចេញទៅតាមផ្លូវតែមួយ ដែលរទេះគោទី ១ បានទៅ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ រទេះគោដំបូងបានផ្ដាំរទេះគោក្រោយទុកថា "យើងនឹងទៅតាមផ្លូវណា ទោះជាអ្នកក៏ត្រូវទៅតាមផ្លូវនោះ" ដូចនេះឬយ៉ាងណា ? ឬក៏រទេះគោក្រោយបានផ្ដាំរទេះគោដំបូងទុកថា "អ្នកនឹងទៅតាមផ្លូវណា ទោះជាយើងក៏នឹងទៅតាមផ្លូវនោះ" ដូចនេះឬ ? "*

**ព្រះចៅមិលិន្ទ** ៖ " មិនមែនទេ ព្រះគុណម្ចាស់ វទេះគោទាំង ២ នោះ មួយ ៗ ពុំមានការនិយាយស្តីគ្នាទេ រមែងទៅ ( តាមផ្លូវតែមួយ ) ព្រោះជាផ្លូវ ដែលធ្លាប់ស្គាល់ "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះទ្វារនោះប្រៀបដូចជា ផ្លូវដែលធ្លាប់ស្គាល់ ។ ចក្ខុវិញ្ញាណមិនបានផ្តាំមនោវិញ្ញាណទុកទេ ថា " យើងកើតឡើងតាមទ្វារណា ទោះជាអ្នកក៏ត្រូវកើតឡើង តាមទ្វារនោះ " ដូចនេះទេ ។ ទោះជាមនោ-វិញ្ញាណ ក៏មិនបានផ្តាំចក្ខុវិញ្ញាណទុកទេថា " អ្នកនឹងកើតឡើងតាមទ្វារណា ទោះជាយើងក៏នឹងកើតឡើងតាមទ្វារនោះ " ដូចនេះទេ ។

វិញ្ញាណទាំង ២ នោះ មួយ ៗ ពុំមានការនិយាយស្តីគ្នាទេ រមែងកើតឡើង(តាមទ្វារតែមួយបាន)ព្រោះទ្វារនោះប្រៀបដូចជា ផ្លូវដែលធ្លាប់ស្គាល់ "

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់នាគសេន ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះទ្វារនោះជាកន្លែងដែលវិញ្ញាណទាំង២ តែងដំណើរទៅជានិច្ចកាលយ៉ាងដូចម្តេច ? សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន** ៖ " សូមថ្វាយព្រះពរ ប្រៀបដូចជា អ្នកចាប់ផ្តើមធ្វើការងារក្នុងការងារសិល្បៈទាំងឡាយ មានការរាប់ចំនួនដោយម្រាមដៃ មានការគូរ ឬសរសេរ (ជាដើម) ដំបូង ៗ នៅអែអង់ យឺតយ៉ាវ នៅឡើយ ។ នាសម័យក្រោយមក ក៏ពុំមានភាពអែអង់ យឺតយ៉ាវ ព្រោះបានដំណើរទៅជានិច្ចកាល(ធ្វើញយដង)ក្នុងការងារ ដែលត្រូវត្រិះរិះធ្វើនោះ ។ យ៉ាងណាមិញ សូមថ្វាយព្រះពរ ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោ-

*វិញ្ញាណក៏កើតឡើងតាមទ្វារនោះ ព្រោះសេចក្ដីថា ទ្វារនោះជាកន្លែងដែលវិញ្ញាណទាំង ២ នោះ តែងប្រព្រឹត្តទៅជានិច្ចកាល ដូចនោះដែរ ។ ចក្ខុវិញ្ញាណមិនបានផ្ដាំមនោវិញ្ញាណទុកទេថា " យើងកើតឡើងតាមទ្វារណា ទោះជាអ្នកក៏ត្រូវកើតឡើងតាមទ្វារនោះ " ដូចនេះទេ ។ ទោះជាមនោវិញ្ញាណ ក៏មិនបានផ្ដាំចក្ខុវិញ្ញាណទុកទេថា " អ្នកនឹងកើតឡើងតាមទ្វារណា ទោះជាយើងក៏នឹងកើតឡើងតាមទ្វារនោះ " ដូចនេះទេ ។ វិញ្ញាណទាំង ២ នោះ មួយ ៗ ពុំមានការនិយាយស្ដីគ្នាទេ រមែងកើតឡើង ( តាមទ្វារតែមួយបាន ) ព្រោះទ្វារនោះជាកន្លែងដែលវិញ្ញាណទាំង ២ នោះ តែងប្រព្រឹត្តទៅជានិច្ចកាល "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន សោតវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះឬ ? ឃានវិញ្ញាណ កើតឡើងតាមទ្វារណា ។ល។ ជិវ្ហាវិញ្ញាណកើតឡើងតាមទ្វារណា ។ល។ កាយវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះ ដែរឬ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ត្រឹមត្រូវហើយ ។ល។ កាយវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើងតាមទ្វារនោះដែរ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ កាយវិញ្ញាណរមែងកើតឡើងមុន មនោវិញ្ញាណរមែងកើតឡើងពេលក្រោយឬ ? ឬក៏មនោវិញ្ញាណរមែងកើតឡើងមុន កាយវិញ្ញាណរមែងកើតឡើងពេលក្រោយ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ កាយវិញ្ញាណរមែងកើតឡើងមុន មនោវិញ្ញាណរមែងកើតឡើងពេលក្រោយ "*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន កាយវិញ្ញាណបានផ្តាំមនោវិញ្ញាណទុកថា ។ល។ ដូចនេះឬ?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ វិញ្ញាណទាំងនោះ មួយ ៗ ពុំមានការនិយាយស្តីគ្នាទេ ។ ល ។ រមែងកើតឡើងតាមទ្វារតែមួយបាន ព្រោះសេចក្តីថា ទ្វារនោះជាកន្លែងដែលវិញ្ញាណទាំង ២ នោះ តែងប្រព្រឹត្តទៅជានិច្ចកាល"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់ចក្ខុវិញ្ញាណាទិប្បញ្ហាទី ៧*

# ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*បញ្ហាស្តីអំពីវិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម ឈ្មោះថា* ***ចក្ខុវិញ្ញាណាទិប្បញ្ហា*** *។*

*ពាក្យថា* ***ចក្ខុវិញ្ញាណកើតឡើងតាមទ្វារណា ទោះជាមនោវិញ្ញាណក៏កើតឡើង តាមទ្វារនោះឬ*** *? អធិប្បាយថា ព្រះរាជាត្រាស់សួរថា ចក្ខុវិញ្ញាណកើតឡើងតាមចក្ខុទ្វារ ទោះជាមនោវិញ្ញាណក៏កើតឡើងតាមចក្ខុទ្វារនោះឬ? ។*

*សរុបសេចក្តីថា ចក្ខុវិញ្ញាណរមែងកើតឡើងតាមចក្ខុទ្វារ ធ្វើកិច្ចរបស់ខ្លួនគឺ ឃើញរូបភាព ។ សោតវិញ្ញាណរមែងកើតឡើងតាមសោតទ្វារ ធ្វើកិច្ចរបស់ខ្លួនគឺ ឮសូរសំឡេង ។ ឃានវិញ្ញាណរមែងកើតឡើងតាមឃានទ្វារ ធ្វើកិច្ចរបស់ខ្លួនគឺ ហិតក្លិន ។ ជិវ្ហាវិញ្ញាណរមែងកើតឡើងតាមជិវ្ហាទ្វារ ធ្វើកិច្ច*

*របស់ខ្លួនគឺ ភ្លក់រស ។ កាយវិញ្ញាណរមែងកើតឡើងតាមកាយទ្វារ ធ្វើកិច្ចរបស់ខ្លួនគឺ ប៉ះអារម្មណ៍ដែលមកពាល់កាយ ។ មនោវិញ្ញាណរមែងកើតឡើង ផ្លូវទ្វារទាំង ៥ មានចក្ខុទ្វារ ជាដើមនោះ បន្តពីចក្ខុវិញ្ញាណជាដើមនោះ ដោយកិច្ចរបស់ខ្លួនគឺ តាមដឹងអារម្មណ៍ទាំង ៥ មានរូបារម្មណ៍ ( រូបភាព )ដែលចក្ខុវិញ្ញាណបានឃើញហើយនោះ ជាដើម ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - ផស្សលក្ខណបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន មនោវិញ្ញាណ*[១] *កើតឡើង នៅទីណា (ក្នុងក្រុមធម៌ណា)ទោះជាផស្សៈ ទោះជាវេទនាក៏កើតឡើងក្នុងទីនោះឬ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ មនោវិញ្ញាណកើតឡើងក្នុងទីណា ទោះជាផស្សៈក៏កើតឡើងក្នុងទីនោះ ទោះជាវេទនាក៏កើតឡើងក្នុងទីនោះ ទោះជាសញ្ញាក៏កើតឡើងក្នុងទីនោះ ទោះជាចេតនាក៏កើតឡើងក្នុងទីនោះ ទោះជាវិតក្កក៏កើតឡើងក្នុងទីនោះ ទោះជាវិចារក៏កើតឡើងក្នុងទីនោះ ទោះជាធម៌គ្រប់យ៉ាងមានផស្សៈជាប្រមុខ*[២] *រមែងកើតឡើងក្នុងទីនោះ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ផស្សៈមានអ្វីជាលក្ខណៈ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ផុស្សនលក្ខណោ ជស្សោ-ផស្សៈ មានការទង្គិចជាលក្ខណៈ "*

---

(១) *មិលិន្ទបញ្ហារបស់ថៃជា ចក្ខុវិញ្ញាណ ។*

(២) *មិលិន្ទបញ្ហារបស់ថៃជា ធម៌ទាំងឡាយមានផស្សៈជាដើម ទោះជាទាំងអស់ ។*

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចពពែ ២ ក្បាល ប្រយុទ្ធគ្នា ។ ក្នុងពពែ ២ ក្បាលនោះ គួរឃើញចក្ខុដូចពពែ ១ ក្បាល គួរឃើញរូប (ភាព)ដូចពពែទី ២ គួរឃើញផស្សៈដូចការមកដល់គ្នា(ការជល់គ្នា)នៃពពែ ២ ក្បាលនោះចុះ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចមនុស្សទះដៃទាំងសងខាង ក្នុងដៃទាំង ២ ខាងនោះ គួរឃើញចក្ខុដូចដៃម្ខាង គួរឃើញរូបដូចដៃម្ខាងទៀត គួរឃើញផស្សៈដូចការមកដល់គ្នា(ការទះគ្នា)នៃដៃទាំងសងខាងនោះចុះ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ* "

**ព្រះនាគសេន ៖** " *ប្រៀបដូចអ្នកគោះក្រាប់ ២ ខាង ក្នុងក្រាប់ទាំង ២ នោះ គួរឃើញចក្ខុដូចក្រាប់ម្ខាង គួរឃើញរូបដូចក្រាប់ម្ខាងទៀត គួរឃើញផស្សៈដូចការមកដល់គ្នា (ការគោះទង្គិចគ្នា)នៃក្រាប់ទាំង ២ ខាងនោះចុះ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់ផស្សលក្ខណបញ្ហាទី ៨*

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*បញ្ហាសួរដល់លក្ខណៈរបស់ផស្សៈ ឈ្មោះថា* ***ផស្សលក្ខណបញ្ហា*** ។

*ពាក្យថា **ការមកដល់គ្នា** (សន្និបាត- ការមកដល់គ្នា ការប្រជុំ) មិនគួរប្រកាន់ យកអត្ថន័យថា ជាការមកជុំគ្នា ប៉ុន្តែគួរប្រកាន់យកអត្ថន័យថា ជាការទង្គិចគ្នាចុះ ។ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា " **សូមថ្វាយព្រះពរ ផស្សៈមានការទង្គិច ជាលក្ខណៈ** " ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - វេទនាលក្ខណបញ្ហា

**ព្រះចៅមិលិន្ទ** *"ព្រះគុណម្ចាស់នាគសេន វេទនាមានអ្វីជាលក្ខណៈ?"*

**ព្រះនាគសេន** ៖ *" សូមថ្វាយព្រះពរ មហាបពិត្រ* **វេទយិតលក្ខណា វេទនា អនុភវនលក្ខណា ច** - *វេទនាមានការបានទទួល (**វេទយិត**- បានទទួល, ដឹង) និងមានការសោយ ( **អនុភវន**- សោយ ) ជាលក្ខណៈ "*

**ព្រះចៅមិលិន្ទ** ៖ *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន** ៖ *"សូមថ្វាយព្រះពរ ប្រៀបដូចបុរសខ្លះបានធ្វើសេចក្តីល្អចំពោះព្រះរាជា ព្រះរាជាទ្រង់រីករាយរួចក៏ឱ្យរង្វាន់ចំពោះសេចក្តីល្អដល់គេ ទើបគេជាអ្នកបរិបូរហូរហៀរដោយកាមគុណ ៥ ព្រោះរង្វាន់ចំពោះសេចក្តីល្អនោះ ។ គេនោះបានកើតគំនិតយ៉ាងនេះថា " **យើងបានធ្វើសេចក្តីល្អចំពោះព្រះរាជាមុន ព្រះរាជាទ្រង់រីករាយរួចក៏ឱ្យរង្វាន់ចំពោះសេចក្តីល្អដល់យើង ។ យើងនោះបានទទួលវេទនាយ៉ាងនេះ ក៏ព្រោះសេចក្តីល្អដែលព្រះរាជាទ្រង់ឱ្យរង្វាន់ចំពោះយើងនោះ** " ដូចនេះ ។*

*សូមថ្វាយព្រះពរ ម្យ៉ាងទៀតដូចបុរសខ្លះបានធ្វើកុសលកម្មទុក បន្ទាប់*

ពីកាយបែកធ្លាយស្លាប់ទៅ ក៏នឹងទៅកាន់សុគតិឋានសួគ៌ ហើយគេនោះក៏ជាអ្នកដែលបរិបូរហូរហៀរដោយកាមគុណទិព្វក្នុងឋានសួគ៌នោះ ។ គេនោះបានកើតគំនិតយ៉ាងនេះ ថា " **យើងនោះបានធ្វើកុសលកម្មទុកជាមុន ព្រោះហេតុថា យើងបានធ្វើកុសលកម្មទុកនោះ ទើបយើងបានទទួលវេទនាយ៉ាងដូចនេះបាន** " ដូចនេះ ។

សូមថ្វាយព្រះពរ វេទនាមានការទទួលជាលក្ខណៈ និង មានការសោយជាលក្ខណៈ តាមប្រការ ដូចពោលខាងលើមកនេះ ដូចនេះ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់វេទនាលក្ខណបញ្ហាទី ៩

# ពាក្យអធិប្បាយបញ្ហាទី ៩ ៖

ពាក្យថា **វេទយិតលក្ខណា វេទនា - វេទនាមានការបានទទួល ជាលក្ខណៈ** គឺ វេទនាមានការបានទទួលរសនៃអារម្មណ៍ ជាលក្ខណៈ ។

ពាក្យថា **អនុភវនលក្ខណា វេទនា - វេទនាមានការសោយ ជាលក្ខណៈ** គឺ វេទនាមានការសោយរសនៃអារម្មណ៍ ជាលក្ខណៈ ។

ពាក្យថា **បានទទួលវេទនាយ៉ាងដូចនេះ** គឺ បានទទួលរសនៃអារម្មណ៍យ៉ាង ដូចនេះ ។

ពាក្យថា **បានសោយវេទនាយ៉ាងដូចនេះ** គឺ បានសោយរសនៃអារម្មណ៍យ៉ាងដូចនេះ ។ ទោះជាធម្មជាតិដែលបានទទួលរសនៃអារម្មណ៍ក៏ដោយ បានសោយរសនៃអារម្មណ៍ក៏ដោយ គឺ វេទនា ជាធម្មជាតិតែមួយនោះឯង ។ ប៉ុន្តែលោកបែរជាពោលថា " **បានទទួលវេទនា បានសោយ**

*វេទនា " ជំនួសពាក្យពោលថា " **បានទទួលរសនៃអារម្មណ៍ បានសោយរសនៃអារម្មណ៍** " ក៏ដើម្បីបង្ហាញឱ្យឃើញពីសភាវៈ ដែលប្រព្រឹត្តទៅច្បាស់លាស់បំផុតនៃវេទនា ក្នុងគ្រាវេទនានោះកើតឡើងចំពោះបុគ្គល ព្រោះពេលពោលយ៉ាងនេះ ក៏រមែងធ្វើឱ្យកើតការយល់អត្ថន័យដ៏ជាក់ច្បាស់បាន ដូចពាក្យថា ភាពនៃបណៃនអារម្មណ៍ ទោះជាមានន័យតែមួយជាមួយអប្បនានោះឯង លោកបែរជាពោលដូចផ្សេងគ្នាថា " **រមែងនៃបណៃនអប្បនា** " ដូចនេះ ជាដើម ដូចនេះ ។*

*លក្ខណៈបានទទួល ( រសនៃអារម្មណ៍ ) ជាលក្ខណៈទូទៅនៃវេទនាទាំងឡាយ តាមព្រះសូត្រដែលថា "* **វេទយិតំ វេទនា - ធម្មជាតិដែលបានទទួលរសនៃអារម្មណ៍ឈ្មោះថា វេទនា** *" ដូចនេះ ។ ចំណែកលក្ខណៈដែលសោយ ( រសនៃអារម្មណ៍ ) ជាលក្ខណៈពិសេសនៃវេទនាទាំងឡាយ តាមព្រះសូត្រដែលថា "* **សុខំ វា វេទនំ វេទិយមានោ សុខំ វេទនំ វេទិយមីតិ បជានាតិ** [១] *– ពេលកំពុងសោយសុខវេទនា ក៏រមែងដឹងច្បាស់ថា កំពុងសោយសុខវេទនា " ដូចនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៩*

# បញ្ហាទី ១០ - សញ្ញាលក្ខណប្បញ្ហា

**ព្រះចៅមិលិន្ទ** *"ព្រះគុណម្ចាស់នាគសេន សញ្ញាមានអ្វីជាលក្ខណៈ?"*

**ព្រះនាគសេន ៖** *"* *សូមថ្វាយព្រះពរ មហាបពិត្រ* **សញ្ជាននលក្ខណា សញ្ញា** *- សញ្ញាមានការចងចាំជាលក្ខណៈ ។ ចងចាំអ្វីឬ? ចង*

[១] *ទីឃនិកាយ. មហាវគ្គ ។*

*ចាំពណ៌ខៀវ ចងចាំពណ៌លឿង ចងចាំពណ៌ក្រហម ចងចាំពណ៌ស ចងចាំពណ៌ទឹកក្រូច សញ្ញាមានការចងចាំជាលក្ខណៈ តាមប្រការដូចពោលខាងលើមកនេះ"*

**ព្រះចៅមិលិន្ទ ៖** "*សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន ៖** "*សូមថ្វាយព្រះពរ ប្រៀបដូចជា មន្ត្រីឃ្លាំងរបស់ព្រះរាជា ចូលទៅក្នុងរោងឃ្លាំង ឃើញរូបទាំងឡាយ ជាគ្រឿងប្រើប្រាស់របស់ព្រះរាជា ដែលមានពណ៌បៃតង មានពណ៌លឿង មានពណ៌ក្រហម មានពណ៌ស មានពណ៌ទឹកក្រូច រួចក៏រមែងចងចាំបាន ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ សញ្ញាមានការចងចាំជាលក្ខណៈដូចនេះដែរ"*

**ព្រះចៅមិលិន្ទ ៖** "*ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់សញ្ញាលក្ខណបញ្ហាទី ១០*

# ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់សញ្ញា ឈ្មោះថា* ***សញ្ញាលក្ខណ-បញ្ហា*** *។*

*សញ្ញាឈ្មោះថា* ***មានការចងចាំជាលក្ខណៈ*** *ព្រោះមានការចងចាំនូវអារម្មណ៍ មានពណ៌បៃតងជាដើម និងពេលបានធ្វើការចងចាំអាការពិសេសក្នុងអារម្មណ៍នោះ គឺ ធ្វើជាគ្រឿងសម្គាល់ទុក ជាបច្ច័យឱ្យចងចាំបានទៀតនៅពេលក្រោយ ដូចបុគ្គលចំណាំអ្នកដទៃបានថា "នេះគឺអ្នកនោះ"*

*ព្រោះបានសម្គាល់ប្រជ្រុយដែលមាននៅលើមុខទុករួចហើយ ដូចនេះ ព្រោះហេតុនោះ ទើបលោកពោលថា "***សញ្ជាននលក្ខណា សញ្ញា តទេវេតន្តិ បុន សញ្ជាននបច្ចយនិមិត្តករណរសា*** (១) - *សញ្ញាមានការចងចាំ ជាលក្ខណៈ មានការធ្វើការសម្គាល់ទុក ដើម្បីជាបច្ច័យដល់ការចងចាំបាន ទៀតថា "នេះគឺវត្ថុនោះ" ដូចនេះ ជារស(កិច្ច)" ជាដើម ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១០*

# បញ្ហាទី ១១ - ចេតនាលក្ខណាប្បញ្ហា

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ ចេតនាមានអ្វីជាលក្ខណៈ?*"

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ* **ចេតយិតលក្ខណា ចេតនា អភិសង្ខារលក្ខណា ច** - *ចេតនាមានការតាំងចិត្តជាលក្ខណៈ និងមានការតាក់តែងជាលក្ខណៈ* "

**ព្រះចៅមិលិន្ទ** ៖ " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសខ្លះផ្សំថ្នាំពុលរួចក៏ផឹកខ្លួនឯងផង ឱ្យអ្នកដទៃផឹកផង ។ ទោះជាគេនោះក៏មានទុក្ខ ទោះជាអ្នកដទៃក៏មានទុក្ខ ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ បុគ្គលខ្លះនៅលើលោកនេះ មានចេតនាតាំងចិត្តធ្វើអកុសលកម្ម បន្ទាប់ពីកាយបែកធ្លាយស្លាប់ទៅ ក៏នឹងចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ។ បុគ្គលក្រុមណាយកគំរូតាមគេ ទោះជាបុគ្គលក្រុមនោះ បន្ទាប់ពីកាយបែកធ្លាយស្លាប់ទៅ ក៏រមែងចូលដល់ អបាយ ទុគ្គតិ វិនិបាត នរក ដូចនេះដែរ ។*

---
(១) *វិសុទ្ធិមគ្គ ។*

*សូមថ្វាយព្រះពរ ឬម៉្យាងវិញទៀត ប្រៀបដូចជា បុរសខ្លះផ្សំទឹកដោះថ្វា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅ ឱ្យមានជារសតែមួយ រួចក៏ផឹកខ្លួនឯងផង ឱ្យអ្នកដទៃផឹកផង ខ្លួនគេនោះក៏បានសុខ ទោះជាអ្នកដទៃក៏បានសុខ ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ បុគ្គលខ្លះលើលោកនេះ មានចេតនាតាំងចិត្តធ្វើកុសលកម្ម បន្ទាប់ពីកាយបែកធ្លាយស្លាប់ទៅ ក៏រមែងចូលដល់សុគតិឋានសួគ៌ បុគ្គលក្រុមណាយកគំរូតាមគេ ទោះជាបុគ្គលក្រុមនោះបន្ទាប់ពីកាយបែកធ្លាយស្លាប់ទៅ ក៏រមែងចូលដល់សុគតិឋានសួគ៌ ដូចនេះដែរ ។ សូមថ្វាយព្រះពរ ចេតនាមានការតាំងចិត្តជាលក្ខណៈ និងមានការតាក់តែងជាលក្ខណៈ តាមប្រការដូចពោលខាងលើមកនេះ ” ៕*

*ចប់ចេតនាលក្ខណបញ្ហាទី ១១*

# ពាក្យអធិប្បាយបញ្ហាទី ១១ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់ចេតនា ឈ្មោះថា* ***ចេតនា-លក្ខណបញ្ហា*** *។*

*ពេលមានការតាំងចិត្ត ក្នុងការធ្វើកុសលក្តី អកុសលក្តី កើតឡើង ការតាំងចិត្ត នោះឯង ជាលក្ខណៈរបស់ចេតនាដែលជាសញ្ញាបង្ហាញថា មានចេតនាកើតឡើង ចេតនានោះហៅថា “* ***កម្ម*** *” ដូចដែលបានត្រាស់ទុកថា* **“ចេតនាហំ ភិក្ខវេ កម្មំ វទាមិ [១]- ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចេតនាថាជាកម្ម** *” ដូចនេះ ។ ប្រសិនបើតាំងចិត្តធ្វើកុសល ចេតនានោះឈ្មោះថា* ***កុសលកម្ម*** *ប្រសិនបើតាំងចិត្ត ធ្វើអកុសល ក៏ឈ្មោះថា* ***អកុសល-***

---
(១) *អង្គុត្តរនិកាយ ឆក្កនិបាត ។*

***កម្ម*** *ដល់ភាពជាកម្មយ៉ាងនេះហើយ ក៏អាចនាំវិបាកផលជាសុខ ឬជាទុក្ខ ឱ្យកើតឡើងក្នុងអនាគតបាន ។ ព្រះថេរៈសំដៅយកសមត្ថភាពក្នុងការញុំាងវិបាកផលឱ្យកើតឡើងនៃចេតនា យ៉ាងដូចនេះ ទើបពោលថា "* ***ចេតនាមានការតាំងចិត្តជាលក្ខណៈ*** *" ។*

*ម្យ៉ាងវិញទៀត ទោះជាមិនបានសំដៅដល់ភាពជាកម្ម ក្នុងការធ្វើវិបាកឱ្យកើតឡើង ចេតនានេះក៏ត្រូវកើតឡើងក្នុងចិត្តគ្រប់ដួងតែម្តង ជាសាធារ-ណៈ ចំពោះចិត្តគ្រប់ដួង គ្រប់ប្រភេទ ដូចជា នាមធម៌ទាំងឡាយ មានផស្សៈជាដើម ដែលបានថ្លែងរួចមកហើយ ។ ក្នុងខណៈកើតឡើងនោះ ទោះជាមានសមត្ថភាពធ្វើវិបាកផល ឱ្យកើតឡើងក្នុងអនាគតក៏ដោយ គ្មានសមត្ថភាពយ៉ាងនោះក៏ដោយ ក៏មានកិច្ចប្រចាំរបស់ខ្លួនម្យ៉ាងគឺ* ***តាក់តែង*** *គឺចាត់ចែងឱ្យធម៌ ដែលកើតរួមជាមួយខ្លួន បានធ្វើកិច្ចរបស់ខ្លួនទីមួយ ៗ គឺចាត់ចែងឱ្យផស្សៈទង្គិចអារម្មណ៍ ចាត់ចែងឱ្យវេទនាសោយអារម្មណ៍ ចាត់ចែងឱ្យសញ្ញាចាំអារម្មណ៍ជាដើម ។*

*ព្រះថេរៈសំដៅយកកិច្ចគឺ ការតាក់តែង តាមប្រការដូចពោលមកនេះពោលថា "**ចេតនាមានការតាក់តែងជាលក្ខណៈ**" ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១១*

# បញ្ហាទី ១២ - វិញ្ញាណលក្ខណបញ្ហា

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន វិញ្ញាណមានអ្វីជាលក្ខណៈ ?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ មហាបពិត្រ* **វិជានលក្ខណំ**

**វិញ្ញាណំ** - *វិញ្ញាណមានការដឹងផ្សេង ៗ ជាលក្ខណៈ"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ប្រៀបដូចជាបុរសអ្នករក្សាក្រុង អង្គុយនៅផ្លូវបំបែកកណ្តាលក្រុង រួចក៏អាចឃើញមនុស្សម្នាមកពីទិសខាងកើត អាចឃើញមនុស្សម្នាមកពីទិសខាងត្បូង អាចឃើញមនុស្សម្នាមកពីទិសខាងលិច អាចឃើញមនុស្សម្នាមកពីទិសខាងជើង ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ បុរសឃើញរូប(ភាព)អ្វីផ្លូវភ្នែក ឈ្មោះថា ដឹងរូបនោះដោយវិញ្ញាណ ឮសូរសំឡេងអ្វីផ្លូវត្រចៀក ឈ្មោះថាដឹងសំឡេងនោះដោយវិញ្ញាណ ហិតក្លិនអ្វីផ្លូវច្រមុះ ឈ្មោះថាដឹងក្លិននោះដោយវិញ្ញាណ ភ្លក់រសអ្វីផ្លូវអណ្តាត ឈ្មោះថា ដឹងរសនោះដោយវិញ្ញាណ ទង្គិចផោដ្ឋព្វៈ ( អារម្មណ៍ដែលមកទង្គិចកាយ ) អ្វីផ្លូវកាយ ឈ្មោះថាដឹងផោដ្ឋព្វៈនោះដោយវិញ្ញាណ ដឹងធម៌អ្វីផ្លូវចិត្តឈ្មោះថា ដឹងធម៌នោះដោយវិញ្ញាណ ដូចនេះដែរ ។ សូមថ្វាយព្រះពរ វិញ្ញាណមានការដឹងផ្សេង ៗ ជាលក្ខណៈ តាមប្រការដូចពោលខាងលើមកនេះ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់វិញ្ញាណលក្ខណបញ្ហាទី ១២*

# ពាក្យអធិប្បាយបញ្ហាទី ១២ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់វិញ្ញាណ ឈ្មោះថា* ***វិញ្ញាណលក្ខណបញ្ហា*** *។*

*ធម្មជាតិតែមួយនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅដោយឈ្មោះជាច្រើនឈ្មោះ គឺ ត្រាស់ហៅថា វិញ្ញាណផង ចិត្តផង មនោផង ។ ប្រការនោះ ពិតដូចបានថ្លែងថា "* **វិញ្ញាណំ ចិត្តំ មនោតិ អត្ថតោ ឯកំ** [១] *- ពាក្យថា វិញ្ញាណ ចិត្ត មនោ ថាដោយសភាវៈ គឺជាធម្មជាតិតែមួយ " ដូចនេះ ។*

*ពាក្យថា* **ដឹងផ្សេង ៗ** *គឺ ដឹងអារម្មណ៍ផ្សេង ៗ តាមផ្លូវទ្វារផ្សេង ៗ ពោលគឺ ក្នុងបណ្ដាអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម រមែងដឹងរូបារម្មណ៍ ( រូបភាព ) ផ្លូវភ្នែក រមែងដឹងសទ្ទារម្មណ៍ ( សំឡេង ) ផ្លូវត្រចៀក រមែងដឹងគន្ធារម្មណ៍ ( ក្លិន ) ផ្លូវច្រមុះ រមែងដឹងរសារម្មណ៍ ( រស ) ផ្លូវអណ្ដាត រមែងដឹងផោដ្ឋព្វារម្មណ៍ ( ភាពត្រជាក់ ក្ដៅ ទន់ រឹង ដែលមកប៉ះកាយ ) ផ្លូវកាយ រមែងដឹងធម្មារម្មណ៍ ( ធម្មជាតិដែលនៅសល់ពីអារម្មណ៍ ៥ ខាងដើម ) ឬសូម្បីអារម្មណ៍ទាំង ៦ នោះ ផ្លូវចិត្ត ដូចនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១២*

# បញ្ហាទី ១៣ - វិតក្កលក្ខណបញ្ហា

**ព្រះចៅមិលិន្ទ ៖** *"ព្រះគុណម្ចាស់នាគសេន វិតក្កមានអ្វីជាលក្ខណៈ ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ* **អប្បនាលក្ខណោ វិតក្កោ** *- វិតក្កមានការប្រត់ដល់អារម្មណ៍ជាលក្ខណៈ "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា ជាងឈើរមែងធ្វើកំណាត់ឈើឱ្យប្រត់ដល់គ្នាត្រង់កន្ទៀងដែលមានការតភ្ជាប់គ្នាយ៉ាងណាមិញ សូមថ្វាយព្រះពរ វិតក្កមានការប្រត់ដល់អារម្មណ៍ជាលក្ខណៈ ដូចនេះដែរ "*

---

[១] *វិសុទ្ធិមគ្គ ។*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ។

ចប់វិតក្កលក្ខណបញ្ហាទី ១៣

# ពាក្យអធិប្បាយបញ្ហាទី ១៣ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់វិតក្ក ឈ្មោះថា* ***វិតក្កលក្ខណ-បញ្ហា*** ។

*វិតក្ក ឈ្មោះថា* ***មានការប្រេតដល់អារម្មណ៍ជាលក្ខណៈ*** *ក៏ព្រោះជាសភាវៈដែលចាំលើកចិត្តព្រមទាំងធម៌ដែលកើតរួមគ្នាឡើងទៅកាន់អារម្មណ៍ ធ្វើឱ្យចិត្តនិងធម៌ដែលកើតរួមគ្នា បានដឹងអារម្មណ៍ ដែលវិតក្កលើកឡើងទៅប្រេតដល់នោះ ។ ព្រោះហេតុនោះក្នុងឧបមា ទើបព្រះថេរៈពោលថា វិតក្កប្រៀបបាននឹងការដែលជាងឈើធ្វើកំណាត់ឈើឱ្យប្រេតដល់គ្នា ត្រង់កន្លែងដែលមានការតភ្ជាប់គ្នា ដូចនេះ ។*

ចប់ពាក្យអធិប្បាយបញ្ហាទី ១៣

# បញ្ហាទី ១៤ - វិចារលក្ខណបញ្ហា

**ព្រះចៅមិលិន្ទ** "*ព្រះគុណម្ចាស់នាគសេន វិចារមានអ្វីជាលក្ខណៈ?*"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ* **អនុមជ្ជន លក្ខ-ណោ វិចារោ** - *វិចារមានការតាមត្រកងអារម្មណ៍ ជាលក្ខណៈ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចជា ជួង លុះចាប់ផ្ដើមវាយរួចហើយ ក្រោយមកក៏មានសំឡេងលាន់រងំបន្តគ្នា មានសំឡេងខ្ទរងំបន្តគ្នា យ៉ាងណាមិញ សូមថ្វាយព្រះពរ គួរឃើញវិតក្កៈ ប្រៀបដូចជាការវាយលើកដំបូង គួរឃើញវិចារថា ប្រៀបដូចជាសំឡេងរងំនោះចុះ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់វិចារលក្ខណប្បញ្ហាទី ១៤*

## ពាក្យអធិប្បាយបញ្ហាទី ១៤ ៖

*បញ្ហាមានការសួរដល់លក្ខណៈរបស់វិចារ ឈ្មោះថា* ***វិចារលក្ខណ-ប្បញ្ហា*** ។

*វិចារឈ្មោះថា មានការតាមត្រកងអារម្មណ៍ ព្រោះវិចារជាសភាវៈដែលចាំតាមបន្តចំពោះអារម្មណ៍ដល់ចិត្ត* ។

*ពាក្យថា* ***គួរឃើញវិតក្កថា ប្រៀបដូចជាការវាយលើកដំបូង*** *គឺ គួរឃើញវិតក្កថា ប្រៀបដូចសំឡេង ដែលកើតពីការវាយលើកដំបូង* ៕

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៤*

# ចប់វិចារវគ្គទី ៣

*ក្នុងវគ្គនេះមាន ១៤ បញ្ហា*

ꩡꩡꩡꩡ 📖 ꩢꩢꩢꩢ

# វគ្គទី ៤ - និព្វានវគ្គ

## បញ្ហាទី ១ - ផស្សាទិវិកុជនប្បញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន អ្នកណាក៏អាចញែកធម៌ទាំងឡាយ ដែលដល់ភាពរួមគ្នា នៅក្នុងចិត្តដួងតែមួយទាំងនេះ ដើម្បីឱ្យដឹងដល់ភាពផ្សេងគ្នាថា* "**នេះផស្សៈ នេះវេទនា នេះសញ្ញា នេះចេតនា នេះវិញ្ញាណ នេះវិតក្ក នេះវិចារ**" *ដូចនេះ បានឬទេ ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ អ្នកណាក៏មិនអាចញែកធម៌ទាំងឡាយ ដែលដល់ភាពរួមគ្នា នៅក្នុងចិត្តដួងតែមួយទាំងនេះ ដើម្បីឱ្យដឹងដល់ភាពផ្សេងគ្នាថា* "**នេះផស្សៈ នេះវេទនា នេះសញ្ញា នេះចេតនា នេះវិញ្ញាណ នេះវិតក្ក នេះវិចារ**" *ដូចនេះ បានឡើយ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចជា នាយវិសេស (ចុងភៅ) ធ្វើក្រយាស្ងោយ ដែលមានរសមិនល្អខ្លះ ដែលមានរសល្អខ្លះ ថ្វាយដល់ព្រះរាជា ។ នាយវិសេសនោះបានដាក់ទឹកដោះគោជូរ ក្នុងក្រយាស្ងោយនោះខ្លះ បានដាក់អំបិលខ្លះ បានដាក់ខ្ញីស្រស់ខ្លះ បានដាក់ប៉ូចកាក់ខ្លះ បានដាក់ម្ទេសខ្លះ បានដាក់គ្រឿងផ្សំខ្លះៗ ។*

*ព្រះរាជាមានបន្ទូលទៅកាន់នាយវិសេសនេះយ៉ាងនេះថា ចូរឯងញែកយករសទឹកដោះគោជូរមកឱ្យយើង ចូរញែកយករសអំបិលមកឱ្យយើង ចូរញែកយករសខ្ញីស្រស់មកឱ្យយើង ចូរញែកយករសប៉ូចកាក់មក*

*ឱ្យយើង ចូរញែកយករសម្ទេសមកឱ្យយើង ចូរញែកយករសគ្រឿងផ្សំគ្រប់យ៉ាងដែលដាក់ចូលទៅ មកឱ្យយើង ដូចនេះ ។*

*សូមថ្វាយព្រះពរ បណ្តារសទាំងឡាយដែលដល់ភាពរួមគ្នា នៅក្នុងក្រយាស្ងោយតែមួយទាំងនោះ នាយវិសេសអាចញែកចេញនាំមក ចំពោះតែរសជូរក៏ដោយ ប្រៃក៏ដោយ ល្វីងក៏ដោយ ស្កាតក៏ដោយ ហឹរក៏ដោយ ចត់ក៏ដោយ ផ្អែមក៏ដោយ (ថ្វាយដល់ព្រះរាជា) បានឬទេ ?"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ បណ្តារសទាំងឡាយដែលដល់ភាពរួមគ្នានៅក្នុងក្រយាស្ងោយតែមួយទាំងនោះ នាយវិសេសមិនអាចញែកចេញនាំមក ចំពោះតែរសជូរក៏ដោយ ប្រៃក៏ដោយ ល្វីងក៏ដោយ ស្កាតក៏ដោយ ហឹរក៏ដោយ ចត់ក៏ដោយ ផ្អែមក៏ដោយ(ថ្វាយដល់ព្រះរាជា)បានទេ ប៉ុន្តែរសទាំងឡាយក៏បង្ហាញ (ឱ្យដឹងបាន) ដោយលក្ខណៈដោយឡែក ៗ របស់ខ្លួននោះ "*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ អ្នកណាក៏មិនអាចញែកធម៌ទាំងឡាយ ដែលដល់ភាពរួមគ្នានៅក្នុងចិត្តដួងតែមួយទាំងនេះ ដើម្បីឱ្យដឹងដល់ភាពផ្សេងគ្នាថា* ***"នេះផស្សៈ នេះវេទនា នេះសញ្ញា នេះ ចេតនា នេះវិញ្ញាណ នេះវិតក្ក នេះវិចារ"*** *ដូចនេះបានឡើយ ប៉ុន្តែធម៌ទាំងនោះរមែងបង្ហាញ (ឱ្យដឹងបាន) ដោយលក្ខណៈដោយឡែក ៗ របស់ខ្លួននោះ "*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់ផស្សាទិវិនិព្ភុជនបញ្ហាទី ១*

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

*ក្នុងនិព្វានវគ្គនេះ មានបញ្ហាមកហើយ ១០ បញ្ហា ។*

*ក្នុងបញ្ហាមានការសួរដល់ការញែកចេញនូវធម៌ទាំងឡាយ មានផស្សៈជាដើម ឈ្មោះថា **ផស្សាទិវិនិព្ភុជនបញ្ហា** ។*

*ព្រះរាជាទ្រង់នឹកដល់ពាក្យ ដែលព្រះថេរៈបានពោលទុកមុននេះថា " **មនោវិញ្ញាណកើតឡើងនៅទីណា ទោះជាផស្សៈក៏កើតឡើងនៅទីនោះ ទោះជាវេទនាក៏កើតឡើងនៅទីនោះ ។ ល។ ធម៌គ្រប់យ៉ាងដែលមានផស្សៈជាប្រមុខ រមែងកើតឡើងនៅទីនោះ** " ដូចនេះហើយ ទើបប្រារព្វបញ្ហានេះដែលមានការសួរដល់ការញែកចេញនូវធម៌ទាំងនោះ ។*

*ពាក្យថា **ភាពផ្សេងគ្នា** គឺ ភាពជាដទៃផ្សេង ៗ គ្នា ។*

*ក្នុងឧបមា ពាក្យថា **រសទាំងឡាយក៏បង្ហាញបានដោយលក្ខណៈដោយឡែក ៗ ដែលជារបស់ខ្លួន** បានសេចក្តីថា ក្នុងពេលដែលព្រះរាជាសោយនោះឯង បណ្តារសទាំងឡាយដែលដល់នូវភាពរួមគ្នា នៅក្នុងក្រយាស្ងោយតែមួយ រសជូរនេះរមែងបង្ហាញដោយលក្ខណៈជូររបស់ខ្លួន រសប្រៃនេះក៏រមែងបង្ហាញដោយលក្ខណៈប្រៃរបស់ខ្លួន ។ រសផ្អែមនេះក៏រមែងបង្ហាញដោយលក្ខណៈផ្អែមរបស់ខ្លួន ។*

*ពាក្យថា **ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ** បានសេចក្តីថា រសនីមួយ ៗ រមែងបង្ហាញដោយលក្ខណៈរបស់ខ្លួននីមួយ ៗ មានលក្ខណៈជូរជាដើម ចំពោះព្រះរាជា ក្នុងពេលសោយ ។ យ៉ាងណាមិញ ធម៌ទាំងឡាយមាន ផស្សៈជាដើម ដែលកើតរួមគ្នា ធម៌នីមួយ ៗ រមែងបង្ហាញដោយលក្ខណៈដោយឡែករបស់ខ្លួន មានលក្ខណៈទង្គិចអារម្មណ៍*

*ជាដើម ។ ព្រះយោគាវចរ ដែលមានបំណងនឹងដឹងថាជាធម៌អ្វី ក្នុងខណៈដឹងនោះដែរ គឺ ផស្សៈនេះរមែងបង្ហាញដោយលក្ខណៈ ដែលទង្គិចអារម្មណ៍របស់ខ្លួន វេទនានេះរមែងបង្ហាញដោយលក្ខណៈ ដែលសោយអារម្មណ៍របស់ខ្លួន ។ ល។ វិចារនេះរមែងបង្ហាញដោយលក្ខណៈ ដែលតាមត្រកងអារម្មណ៍របស់ខ្លួន ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១*

# បញ្ហាទី ២ - នាគសេនប្បញ្ហា

**ព្រះថេរៈ** *ថ្វាយព្រះពរសួរថា " សូមថ្វាយព្រះពរ ភាពប្រែជាអ្វីដែលដឹងបានដោយភ្នែកឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែនព្រះគុណម្ចាស់ ជាអ្វីដែលដឹងបានដោយភ្នែក "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ដឹងត្រឹមត្រូវហើយឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ភាពប្រែជាអ្វីដែលដឹងបានដោយអណ្ដាត ឬ យ៉ាងណា?"*

**ព្រះនាគសេន ៖** *" ត្រឹមត្រូវ មហាបពិត្រ ភាពប្រែជាអ្វីដែលដឹងបានដោយអណ្ដាត "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ មនុស្សយើងដឹងប្រែបានដោយអណ្ដាតទាំងអស់ឬ?"*

**ព្រះនាគសេន ៖** " *ត្រឹមត្រូវ មហាបពិត្រ មនុស្សយើងដឹងប្រែបាន ដោយអណ្តាតទាំងអស់* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ ប្រសិនបើមនុស្សយើងដឹងប្រែបាន ដោយអណ្តាតទាំងអស់នោះ ព្រោះហេតុអ្វីទើបប្រើគោអូសយកអំបិលនោះមក ជាច្រើនរទេះទៅ គួរតែយកមកចំពោះតែភាពប្រៃប៉ុណ្ណោះ មិនមែនទេឬ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ អ្នកណាក៏មិនអាចញែកយកចំពោះតែភាពប្រៃប៉ុណ្ណោះបានទេ ធម៌ទាំងនេះរួមនៅក្នុងបណ្តុំតែមួយ ដល់ភាពជាអារម្មណ៍ដែលផ្សេងគ្នា, សូមថ្វាយព្រះពរ ភាពប្រៃមានទម្ងន់ដែរឬ? អ្នកណាក៏អាចប្រើជញ្ជីងថ្លឹងភាពប្រៃបានឬ?* "

**ព្រះចៅមិលិន្ទ ៖** " *ពិតមែនព្រះគុណម្ចាស់ អ្នកណាក៏អាចប្រើជញ្ជីងថ្លឹងភាពប្រៃបាន* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ អ្នកណាក៏មិនអាចប្រើជញ្ជីងថ្លឹងភាពប្រៃបានទេ ទម្ងន់របស់អំបិលប៉ុណ្ណោះ ដែលអ្នកណាក៏អាចប្រើជញ្ជីងថ្លឹងបាន* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់នាគសេនបញ្ហាទី ២*

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហានេះ ជាបញ្ហាដែលព្រះនាគសេនជាអ្នកចាប់ផ្តើមសួរ ទើបឈ្មោះថា* ***នាគសេនបញ្ហា*** *។*

*ពាក្យថា* ***ដល់ភាពជាអារម្មណ៍ដែលផ្សេងគ្នា*** *គឺជាអារម្មណ៍ផ្សេងគ្នា បានសេចក្ដីថា ភាពប្រែជារសារម្មណ៍ ( អារម្មណ៍គឺ រស ) ក្នុងបណ្ដាអារម្មណ៍ ៦ ។ ដុំអំបិលជាបណ្ដុំនៃធាតុ ៤ មានធាតុដីជាដើម ធាតុ ៣ គឺ ធាតុដី ធាតុភ្លើង និងធាតុខ្យល់ ជាផោដ្ឋព្វារម្មណ៍ ចំណែកធាតុទឹកជាធម្មារម្មណ៍ រូបភាពដុំអំបិលជារូបារម្មណ៍ ក្លិនជាគន្ធារម្មណ៍ ទម្ងន់( ឬភាពធ្ងន់ស្រាល ) ជាធម្មារម្មណ៍ ។ល។ ព្រះថេរៈមានបំណងនឹងបង្ហាញ នូវភាពជាអារម្មណ៍ផ្សេងគ្នា នៃធម៌ ដែលពាក់ព័ន្ធនៅក្នុងបណ្ដុំតែមួយនោះ ទើបថ្វាយព្រះពរសួរថា "* ***អ្នកណាក៏អាចប្រើជញ្ជីងថ្លឹងភាពប្រែបានឬ?*** *" ។*

*ព្រះរាជា ព្រោះទ្រង់យល់ថា ដុំអំបិលនិងភាពប្រែជាធម្មជាតិតែមួយ ទើបទ្រង់ឆ្លើយទទួលថា "* ***ពិតមែនព្រះគុណម្ចាស់ អ្នកណាក៏អាចប្រើជញ្ជីងថ្លឹងភាពប្រែបាន*** *" ដូចនេះ ។ ព្រោះហេតុនោះ ទើបព្រះថេរៈបដិសេធការយល់ ខុសរបស់ព្រះរាជា រួចថ្វាយព្រះពរឱ្យទ្រង់ជ្រាបថា ជាអារម្មណ៍ផ្សេងគ្នា ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - បញ្ហាយតនកម្មនិព្វត្តបញ្ហា

**ព្រះរាជា** *ទ្រង់មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន អាយតនៈ ៥ យ៉ាងទាំងនេះ កើតពីកម្មផ្សេង ៗ ឬក៏កើតពីកម្មតែមួយ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ អាយតនៈ ៥ យ៉ាង កើតពីកម្មផ្សេង ៗ គ្នា ពុំមែនកើតពីកម្មតែមួយនោះទេ "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ ធ្វើការឧបមា "*

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីនោះយ៉ាងដូចម្ដេច អ្នកចម្ការបានព្រោះគ្រាប់រុក្ខជាតិប្រភេទផ្សេង ៗ គ្នា ក្នុងចម្ការមួយកន្លែង គ្រាប់រុក្ខជាតិមានប្រភេទផ្សេង ៗ គ្នាទាំងនោះ នឹងហុចផលជាប្រភេទផ្សេង ៗ គ្នា មែនឬទេ ? "

**ព្រះចៅមិលិន្ទ ៖** " ពិតមែនព្រះគុណម្ចាស់ នឹងហុចផលជាប្រភេទផ្សេងៗ គ្នា "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ។ អាយតនៈ ៥ យ៉ាងក្រុមណា អាយតនៈ ៥ យ៉ាងក្រុមនោះសុទ្ធតែកើតពីកម្មផ្សេង ៗ គ្នា ពុំមែនកើតពីកម្មតែមួយនោះទេ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់បញ្ហាយតនកម្មនិពត្តបញ្ហាទី ៣

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

បញ្ហាមានការសួរដល់អាយតនៈ ៥ យ៉ាង ដែលជារបស់កើតពីកម្ម ឈ្មោះថា **បញ្ហាយតនកម្មនិពត្តបញ្ហា** ។

ពាក្យថា **អាយតនៈ ៥ យ៉ាង** គឺ អាយតនៈដែលជាទ្វារ ៥ យ៉ាង គឺ ចក្ខុវាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ និង កាយាយតនៈ ។

ពាក្យថា **កើតពីកម្មផ្សេង ៗ គ្នា** បានសេចក្ដីថា ចក្ខាយតនៈ គឺ ប្រសាទភ្នែក រមែងកើតពីកម្ម ដែលសម្រេចឡើងដោយសារ **រូបតណ្ហា** គឺ សេចក្ដីរីករាយពេញចិត្តចំពោះរូប ។ សោតាយតនៈ គឺ ប្រសាទត្រចៀក រមែងកើត

ពីកម្ម ដែលសម្រេចឡើងដោយសារ **សទ្ទតណ្ហា** គឺ សេចក្ដីរីករាយពេញចិត្ត ចំពោះសំឡេង ។ ឃានាយតនៈ គឺប្រសាទច្រមុះ រមែងកើតពីកម្ម ដែល សម្រេចឡើងដោយសារ **គន្ធតណ្ហា** គឺ ភាពរីករាយពេញចិត្តចំពោះក្លិន ។ ជិវ្ហាយតនៈរមែងកើតពីកម្ម ដែលសម្រេចឡើងដោយសារ **រសតណ្ហា** គឺ សេចក្ដីរីករាយពេញចិត្ត ចំពោះរស ។ កាយាយតនៈរមែង កើតពីកម្ម ដែល សម្រេចឡើងដោយសារ **ផោដ្ឋព្វតណ្ហា** គឺ សេចក្ដីរីករាយពេញចិត្តចំពោះ ភាពត្រជាក់ ក្ដៅ ទន់ រឹង ដែលមកប៉ះកាយ ។

ម៉្យាងវិញទៀត អាយតនៈ ទោះជាទាំង ៥ នោះ របស់សត្វដែលកើត ក្នុងទុគ្គតិ រមែងកើតពីអកុសលកម្ម ចំណែករបស់សត្វដែលកើតក្នុងសុគតិ រមែងកើតពីកុសលកម្ម ដូចនេះ។

ក្នុងអដ្ឋកថា មិលិន្ទបុប្បញ្ហា លោកនៅបានចែកទៅតាមភាពផ្សេង គ្នានៃកម្ម ២ យ៉ាង គឺ កុសលកម្ម និងអកុសលកម្ម យ៉ាងនេះទៀតថា " ក្នុង គ្រាណាដែលបុគ្គលកើតមានទស្សនកិច្ច ( កិច្ច គឺការឃើញរូប ) ឃើញរូបគួរ ឱ្យប្រាថ្នាដោយភ្នែក ក្នុងគ្រានោះ ចក្ខាយតនៈរមែងកើតពីកុសលកម្មតែមួយ មុខ ។ ល។ ក្នុងគ្រាណាដែលកើតមានទស្សនកិច្ចឃើញរូបមិនគួរឱ្យប្រាថ្នា ដោយភ្នែក ក្នុងគ្រានោះ ចក្ខាយតនៈរមែងកើតពីអកុសលកម្មតែមួយមុខ " ដូចនេះ លោកមិនគួរពោលយ៉ាងនេះទេ ព្រោះថាអត្តភាពជាមនុស្ស ដោយ រួមទាំងអាយតនៈ គឺ ប្រសាទរូប ៥ យ៉ាងនេះ កើតឡើងពីកុសលកម្ម ដែល បានធ្វើទុកក្នុងភពមុន តែមួយមុខប៉ុណ្ណោះ ។

ក្នុងពេលឃើញរូបដោយភ្នែក រូបនោះទោះជាគួរឱ្យប្រាថ្នាក៏ដោយ មិនគួរឱ្យប្រាថ្នាក៏ដោយ ពុំមានអំណាចផ្លាស់ប្ដូរប្រសាទរូប ៥ ដែលជារូប ធម៌ទាំងនេះបានទេ គឺនៅតែជារូប ដែលកើតឡើងពីកុសលកម្ម តែមួយមុខ

ព្រោះរូប ជាធម្មជាតិងងឹត មិនដឹងអារម្មណ៍ វិបាកគឺ ចក្ខុវិញ្ញាណដែលឃើញរូបប៉ុណ្ណោះ រមែងផ្លាស់ប្តូរទៅតាមអារម្មណ៍ គឺ ប្រសិនបើរូបដែលឃើញនោះ ជាឥដ្ឋារម្មណ៍គួរឱ្យប្រាថ្នា ចក្ខុវិញ្ញាណនោះគឺជាវិបាកដែលកើតពីកុសលកម្ម ប្រសិនបើរូបដែលឃើញនោះ ជាអនិដ្ឋារម្មណ៍មិនគួរឱ្យប្រាថ្នា ចក្ខុវិញ្ញាណនោះគឺជាវិបាកដែលកើតពីអកុសលកម្ម ព្រោះវិបាកជានាមធម៌ ជាធម្មជាតិដែលដឹងអារម្មណ៍ ទើបផ្លាស់ប្តូរទៅតាមអារម្មណ៍បាន ទោះជាអាយតនៈ ៥ ផ្សេងទៀត ក៏គួរជ្រាបដោយន័យនេះ ផងចុះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៣

# បញ្ហាទី ៤ - កម្មនានាការណបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា “ ព្រះគុណម្ចាស់នាគសេន ព្រោះហេតុអ្វី បានជាមនុស្សគ្រប់រូប ទើបមានភាពមិនស្មើគ្នា គឺ ពួកខ្លះមានអាយុខ្លី ពួកខ្លះមានអាយុវែង ពួកខ្លះមានជំងឺឈឺថ្កាត់ច្រើន ពួកខ្លះមានជំងឺឈឺថ្កាត់តិច ពួកខ្លះមានពណ៌សម្បុរអាក្រក់ ពួកខ្លះមានពណ៌សម្បុរល្អស្អាត ពួកខ្លះមានយសសក្តិទាប ពួកខ្លះមានយសសក្តិខ្ពស់ ពួកខ្លះមានភោគទ្រព្យច្រើន ពួកខ្លះមានភោគទ្រព្យតិច ពួកខ្លះមានត្រកូលទាប ពួកខ្លះមានត្រកូលខ្ពស់ ពួកខ្លះមានបញ្ញាទាប ពួកខ្លះមានបញ្ញាខ្ពស់ ?”

**ព្រះថេរៈ** ថ្វាយវិសជ្ជនាថា “ សូមថ្វាយព្រះពរ មហាបពិត្រ ព្រោះហេតុអ្វីដើមឈើ គ្រប់ជំពូកមានភាពមិនស្មើគ្នា គឺ ពួកខ្លះជូរ ពួកខ្លះប្រៃ ពួកខ្លះហឹរ ពួកខ្លះល្វីង ពួកខ្លះចត់ ពួកខ្លះផ្អែម ?”

**ព្រះចៅមិលិន្ទ ៖** “ ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាយល់ថា ដើមឈើ

*គ្រប់ដំពូកមានភាពមិនស្មើគ្នា ព្រោះហេតុមានភាពផ្សេងគ្នានៃពូជ(ប្រភេទ) វក្ខជាតិ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ មនុស្សគ្រប់រូបមានភាពមិនស្មើគ្នា គឺ ពួកខ្លះអាយុខ្លី ពួកខ្លះអាយុវែង ពួកខ្លះមានជំងឺឈឺថ្កាត់ច្រើន ពួកខ្លះមានជំងឺឈឺថ្កាត់តិច ពួកខ្លះមានពណ៌សម្បុរអាក្រក់ ពួកខ្លះមានពណ៌សម្បុរល្អស្អាត ពួកខ្លះមានយសសក្តិតិច ពួកខ្លះមានយសសក្តិច្រើន ពួកខ្លះមានត្រកូលទាប ពួកខ្លះមានត្រកូលខ្ពស់ ពួកខ្លះមានបញ្ញាទាប ពួកខ្លះមានបញ្ញាខ្ពស់ ព្រោះហេតុគឺ ភាពផ្សេងគ្នានៃកម្ម ។*

*សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្តីនេះទុកថា* **"កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** [១] *"* *ប្រែថា " ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន ជាទាយាទទទួលកម្ម មានកម្មជាកំណើត មានកម្មជាពូជពង្ស មានកម្មជាទីពឹងពាក់អាស្រ័យ កម្មរមែងបែងចែកសត្វ ដើម្បីឱ្យជាមនុស្សអាក្រក់និងប្រណីត " ដូចនេះ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៗ*

*ចប់កម្មនានាករណបញ្ហាទី ៨*

---

(១) *មជ្ឈិមនិកាយ ឧបរិបណ្ណាសក ។*

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

*បញ្ហាមានការពោលដល់ហេតុ គឺភាពផ្សេងគ្នានៃកម្ម ឈ្មោះថា **កម្ម-នានាករណបញ្ហា** ។*

*ពាក្យថា **កម្មស្សកា - មានកម្មជារបស់ខ្លួន** គឺ មានកម្មជាសម្បត្តិរបស់ខ្លួន ។*

*ពាក្យថា **កម្មទាយាទា - ជាទាយាទទទួលកម្ម** គឺ មានកម្មជាមរតក បានសេចក្ដីថា អ្នកណាធ្វើកម្ម ទោះជាកុសលក៏ដោយ អកុសលក៏ដោយ តទៅអនាគត អ្នកនោះឯងជាអ្នកទទួលមរតក គឺកម្មនោះនឹងប្រគល់ឱ្យអ្នកដទៃទទួលជំនួសពុំបានឡើយ ពោលគឺ ត្រូវសោយវិបាកដែលគួរឱ្យប្រាថ្នាខ្លះ មិនគួរឱ្យប្រាថ្នាខ្លះ ដែលបណ្ដាលមកពីកម្មនោះ ដោយខ្លួនឯង ។*

*ពាក្យថា **កម្មយោនី - មានកម្មជាកំណើត** គឺ មានកម្មជាហេតុ បានសេចក្ដីថា ការប្រព្រឹត្តទៅនៃសត្វទាំងឡាយ កម្មមានចំណែកជាហេតុយ៉ាងសំខាន់ ។*

*ពាក្យថា **កម្មពន្ធូ - មានកម្មជាពូជពង្ស** គឺមានកម្មជាសាច់ញាតិ បានសេចក្ដីថា សត្វទាំងឡាយមានមាតាបិតា បងប្អូនប្រុស បងប្អូនស្រី ជាដើម ជាសាច់ញាតិឧបការៈខ្លះ បៀតបៀនខ្លះ យ៉ាងណាមិញ ក៏មានកម្មរបស់ខ្លួននេះឯង ជាសាច់ញាតិដែលមានឧបការៈខ្លះ បៀតបៀនខ្លះ ដូចនេះដែរ ។*

*ពាក្យថា **កម្មប្បដិសរណា - មានកម្មជាទីពឹងពាក់អាស្រ័យ** គឺមានកម្មជាទីពឹង មានកម្មជាទីតាំងអាស្រ័យដែលល្អខ្លះ មិនល្អខ្លះ ។*

*ពាក្យថា **ដើម្បីឱ្យជាមនុស្សអាក្រក់ និងប្រណីត** បានសេចក្ដីថា ភាពជាមនុស្សមានអាយុខ្លី ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានអាយុវែង ឈ្មោះថា*

*ប្រណីត(គឺល្អ) ។ ភាពជាមនុស្សមានជំងឺឈឺថ្កាត់ច្រើន ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានជំងឺឈឺថ្កាត់តិច ឈ្មោះថាប្រណីត ។ ភាពជាមនុស្សមានពណ៌សម្បុរអាក្រក់ ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានពណ៌សម្បុរល្អស្អាត ឈ្មោះថាប្រណីត ។ ភាពជាមនុស្សមានយសសក្តិតិច ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានយសសក្តិច្រើន ឈ្មោះថាប្រណីត ។ ភាពជាមនុស្សមានភោគទ្រព្យតិច ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានភោគទ្រព្យច្រើន ឈ្មោះថាប្រណីត ។ ភាពជាមនុស្សមានត្រកូលទាប ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានត្រកូលខ្ពស់ ឈ្មោះថាប្រណីត ។ ភាពជាមនុស្សមានបញ្ញាទាប ឈ្មោះថាអាក្រក់ ភាពជាមនុស្សមានបញ្ញាច្រើន ឈ្មោះថាប្រណីត ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៤*

# បញ្ហាទី ៥ - វាយាមការណបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន ពួកលោកម្ចាស់តែងតែពោលថា " យ៉ាងដូចម្តេចទើបទុក្ខនេះរលត់ផុតទៅ ហើយទុក្ខផ្សេងក៏មិនកើតឡើង " ដូចនេះ មិនមែនទេឬ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ការបួសរបស់អាត្មាភាពមានប្រការដែលពោលមកនេះ ជាប្រយោជន៍ "*

**ព្រះចៅមិលិន្ទ ៖** " *ប្រយោជន៍អ្វីដោយការព្យាយាមពីចម្ងាយ គួរតែព្យាយាមពេលដែលវេលាមកដល់ មិនមែនទេឬ?"*

**ព្រះថេរៈ** *វិសជ្ជនាថា " សូមថ្វាយព្រះពរ សេចក្តីព្យាយាមពេលដែល*

*វេលាមកដល់ ជាសេចក្ដីព្យាយាមដែលប្រើការមិនបាន សេចក្ដីព្យាយាមពីចម្ងាយប៉ុណ្ណោះ ជាសេចក្ដីព្យាយាមដែលប្រើការបាន"*

**ព្រះចៅមិលិន្ទ៖** *"សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច ព្រះអង្គមានបន្ទូលឱ្យគេជីកអណ្ដូងទឹក មានបន្ទូលឱ្យគេជីកស្រះទឹក ក្នុងវេលាដែលព្រះអង្គទ្រង់ស្រេកទឹក រួចទ្រង់មានព្រះតម្រិះថា "**យើងនឹងសោយទឹក**" ដូចនេះ ឬយ៉ាងណា?"*

**ព្រះចៅមិលិន្ទ៖** *"មិនមែនទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សេចក្ដីព្យាយាមពេលដែលវេលាមកដល់ ជាសេចក្ដីព្យាយាមដែលប្រើការមិនបាន សេចក្ដីព្យាយាមពីចម្ងាយប៉ុណ្ណោះ ជាសេចក្ដីព្យាយាមដែលប្រើការបាន"*

**ព្រះចៅមិលិន្ទ៖** *"សូមព្រះគុណម្ចាស់ ឧបមាបន្ថែមបន្តិចទៀតផងចុះ"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច ព្រះអង្គមានបន្ទូលឱ្យគេភ្ជួរស្រែ មានបន្ទូលឱ្យគេព្រោះស្រូវសាលី មានបន្ទូលឱ្យគេប្រមូលផលស្រូវ ក្នុងវេលាដែលព្រះអង្គទ្រង់ឃ្លាន ហើយទ្រង់មានព្រះតម្រិះថា "**យើងនឹងបរិភោគបាយ**" ដូចនេះ ឬយ៉ាងណា?"*

**ព្រះចៅមិលិន្ទ៖** *"មិនមែនទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សេចក្ដីព្យាយាមពេលដែលវេលាមកដល់ ជាសេចក្ដី*

ព្យាយាម ដែលប្រើការមិនបាន សេចក្តីព្យាយាមពីចម្ងាយប៉ុណ្ណោះ ជាសេចក្តីព្យាយាម ដែលប្រើការបាន"

**ព្រះចៅមិលិន្ទ៖** " សូមព្រះគុណម្ចាស់ ឧបមាបន្ថែមបន្តិចទៀតផងចុះ"

**ព្រះនាគសេន៖** " សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្តីប្រការនោះយ៉ាងដូចម្តេច ព្រះអង្គមានបន្ទូលឱ្យគេជីកប្រឡាយជុំវិញក្រុង មានបន្ទូលឱ្យគេសាងកំពែង មានបន្ទូលឱ្យគេធ្វើខ្លោងទ្វារ មានបន្ទូលឱ្យគេសាងប៉មការពារ មានបន្ទូលឱ្យគេប្រមែប្រមូលធញ្ញាហារទុក ខ្លួនព្រះអង្គផ្ទាល់ក៏ទ្រង់នឹងសិក្សាក្នុងរឿងដំរី ទ្រង់នឹងសិក្សាក្នុងរឿងសេះ ទ្រង់នឹងសិក្សាក្នុងរឿងរថ ទ្រង់នឹងសិក្សាក្នុងរឿងធ្នូ ទ្រង់នឹងសិក្សាក្នុងរឿងដាវ ក្នុងវេលាដែលសង្គ្រាមកើតឡើង យ៉ាងនោះឬ?"

**ព្រះចៅមិលិន្ទ៖** " មិនមែនទេ ព្រះគុណម្ចាស់"

**ព្រះនាគសេន៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សេចក្តីព្យាយាមពេលដែលវេលាមកដល់ ជាសេចក្តីព្យាយាមដែលប្រើការមិនបាន សេចក្តីព្យាយាមពីចម្ងាយប៉ុណ្ណោះ ជាសេចក្តីព្យាយាមដែលប្រើការបាន ។

សូមថ្វាយព្រះពរ ប្រការនេះ សមពិតដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ៖ " **បុគ្គលដឹងថា ប្រការមួយជាប្រយោជន៍ចំពោះខ្លួន គួរធ្វើប្រការនោះពីចម្ងាយទៅចុះ បុគ្គលជាអ្នកប្រាជ្ញមិនគួរស្របតាមគំនិតរបស់ឈ្មួញរទេះ ដឹងហើយក៏ពុះពារអំពីចម្ងាយ ។ ប្រៀបដូចជាឈ្មួញរទេះលះបង់ចោលផ្លូវធំដែលរាបស្មើ រួចទៅកាន់ផ្លូវដែលរដិបរដុប ភ្លៅរទេះបែកបាក់ទៅ ក៏រមែងសោកសៅដូចនេះ"** យ៉ាងនេះ "

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

ចប់វាយាមករណបញ្ហាទី ៤

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាស្តីអំពីការធ្វើសេចក្តីព្យាយាម ឈ្មោះថា **វាយាមករណបញ្ហា** ។*

*ពាក្យថា **ពេលដែលវេលាមកដល់** ព្រះរាជាទ្រង់សំដៅយកវេលាចាស់ជិតស្លាប់ ។ ពាក្យថា **អ្វីជាប្រយោជន៍របស់ខ្លួន** គឺ កិច្ចការណាដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ជួយឧបត្ថម្ភចំពោះខ្លួន ទាំងក្នុងលោកនេះ និងលោកខាងមុខ និងដើម្បីប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺ ព្រះនិព្វាន ។*

*ពាក្យថា **គេចចេញពីធម៌** គឺ គេចចេញ គឺ លះពីការធ្វើកុសល ។*

*ពាក្យថា **ប្រព្រឹត្តតែអធម៌** គឺ ប្រព្រឹត្តជានិច្ចកាលនូវអកុសល ៕*

ចប់ពាក្យអធិប្បាយបញ្ហាទី ៤

# បញ្ហាទី ៦ - នេរយិកគ្គិឧណ្ហភាវបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *" ព្រះគុណម្ចាស់នាគសេន ពួកលោកម្ចាស់តែងតែពោលថា " **ភ្លើងនរកក្តៅខ្លាំងជាងភ្លើងធម្មតា ដុំថ្មទោះជាទំហំតូចមួយ ដាក់ចូលទៅក្នុងភ្លើងធម្មតា ត្រូវដុតពេញមួយថ្ងៃ ក៏រកភាពវិនាសគ្មាន ដុំថ្មទោះជាទំហំធំប៉ុនផ្ទះ ដាក់ចូលទៅក្នុងភ្លើងនរក តែមួយភ្លែតប៉ុណ្ណោះ ក៏ដល់ភាពវិនាសទៅ** " ដូចនេះ ។ ខ្ញុំព្រះករុណាមិនជឿពាក្យដែល*

ពោលនេះទេ ហើយទោះជាពាក្យដែលពួកលោកម្ចាស់ពោលយ៉ាងនេះថា "**ពួកសត្វនរកដែលឧប្បត្តិនៅក្នុងនរកនោះ ត្រូវភ្លើងឆេះនៅក្នុងនរក ទោះជាច្រើនពាន់ឆ្នាំ ក៏មិនដល់ភាពវិនាសឡើយ**" ដូចនេះនោះ ខ្ញុំព្រះករុណាក៏មិនជឿដែរ"

**ព្រះនាគសេន** ថ្វាយព្រះពរថា " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច សត្វពពួកនាគក្ដី ពពួកក្រពើក្ដី ពពួកអណ្ដើកក្ដី ពពួកក្ងោកក្ដី ពពួកលលកក្ដី រមែងស៊ីដុំថ្ម និងដុំក្រួសរឹង ៗ បាន មិនមែនទេឬ?"

**ព្រះចៅមិលិន្ទ ៖** " ពិតមែន រមែងស៊ីបាន ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " ដុំថ្ម ដុំក្រួសទាំងនោះ ដែលនៅក្នុងពោះរបស់សត្វទាំងនោះ ដល់ភាពវិនាសទៅ ពិតមែនឬទេ?"

**ព្រះចៅមិលិន្ទ ៖** " ពិតមែន រមែងដល់ភាពវិនាសទៅ ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " ប៉ុន្តែកូនខ្ចីក្នុងពោះរបស់សត្វទាំងនោះ ដល់ភាពវិនាសទៅដែរឬ ទេ?"

**ព្រះចៅមិលិន្ទ ៖** " មិនទេ ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " ព្រោះហេតុអ្វីឬ?"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាយល់ថា រមែងមិនដល់ភាពវិនាសទៅទេ ពីព្រោះជាអ្វីដែលកម្មចាត់ចែង"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ពួកសត្វទាំងឡាយត្រូវភ្លើងឆេះនៅក្នុងនរក ទោះជារហូតច្រើនពាន់ឆ្នាំ មិនដល់ភាពវិនាសទៅ ពីព្រោះជាអ្វីដែលកម្មចាត់ចែង ។ សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្ដីប្រការនេះទុកថា

"**សោ ន តាវ កាលំ ករោតិ, យាវ ន តំ បាបកម្មំ ពយន្តី ហោតិ** (១)-
*សត្វនរកនោះ ដរាបណាកម្មអាក្រក់នៅមិនទាន់បញ្ចប់ ដរាបនោះនឹងមិនទាន់ស្លាប់" ដូចនេះ"*

**ព្រះចៅមិលិន្ទ៖** " *សូមព្រះគុណម្ចាស់ ឧបមាបន្ថែមបន្តិចទៀតផងចុះ"*

**ព្រះនាគសេន៖** " *សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច សត្វពពួកសីហៈក្ដី ពពួកខ្លាធំក្ដី ពពួកខ្លាដំបងក្ដី ពពួកសុនខក្ដី រមែងស៊ីឆ្អឹង ឬ សាច់រឹង ៗ បាន មិនមែនទេឬ?"*

**ព្រះចៅមិលិន្ទ៖** " *ពិតមែន រមែងស៊ីបាន ព្រះគុណម្ចាស់"*

**ព្រះនាគសេន៖** " *ឆ្អឹងនិងសាច់រឹង ៗ ទាំងនោះ ដែលនៅក្នុងពោះរបស់សត្វទាំងនោះ រមែងដល់ភាពវិនាសទៅ ពិតមែនឬទេ?"*

**ព្រះចៅមិលិន្ទ៖** " *ពិតមែន រមែងដល់ភាពវិនាសទៅ ព្រះគុណម្ចាស់"*

**ព្រះនាគសេន៖** " *ប៉ុន្តែកូនខ្ចីក្នុងពោះរបស់សត្វទាំងនោះដល់ភាពវិនាសទៅដែរឬទេ?"*

**ព្រះចៅមិលិន្ទ៖** " *មិនទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន៖** " *ព្រោះហេតុអ្វីឬ?"*

**ព្រះចៅមិលិន្ទ៖** " *ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាយល់ថា រមែងមិនដល់ភាពវិនាសទៅទេ ពីព្រោះជាអ្វីដែលកម្មចាត់ចែង"*

**ព្រះនាគសេន៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ពួកសត្វទាំងឡាយត្រូវភ្លើងឆេះនៅក្នុងនរក ទោះជារហូតច្រើនពាន់ឆ្នាំ មិនដល់ភាពវិនាសទៅ ពីព្រោះជាអ្វីដែលកម្មចាត់ចែង"*

---

(១) *មជ្ឈិមនិកាយ ឧបរិបណ្ណាសក ។*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ ឧបមាបន្ថែមទៀតផងចុះ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច ពួកស្ត្រីជនជាតិយោនកដែលជាសុខុមាលជាតិក្ដី ពួកក្សត្រីដែលជាសុខុមាលជាតិក្ដី ពួកស្ត្រីព្រាហ្មណ៍ដែលជាសុខុមាលជាតិក្ដី ពួកស្ត្រីគហបតី ដែលជាសុខុមាលជាតិក្ដី រមែងបរិភោគនូវរបស់ទំពារឹង ៗ សាច់រឹង ៗ បាន មិនមែនទេឬ? "*

**ព្រះចៅមិលិន្ទ ៖** *" រមែងបរិភោគបាន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" របស់ទំពារឹង ៗ សាច់រឹង ៗ ទាំងនោះ ដែលនៅក្នុងពោះរបស់ស្ត្រីទាំងនោះ រមែងដល់ភាពវិនាសទៅមែនឬទេ? "*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន រមែងដល់ភាពវិនាសទៅ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" ប៉ុន្តែកូនខ្ចីក្នុងពោះរបស់ស្ត្រីទាំងនោះដល់ភាពវិនាសទៅដែរឬទេ? "*

**ព្រះចៅមិលិន្ទ ៖** *" មិនទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ពួកសត្វទាំងឡាយត្រូវភ្លើងឆេះនៅក្នុងនរក ទោះជារហូតច្រើនពាន់ឆ្នាំ មិនដល់ភាពវិនាសទៅ ពីព្រោះជាអ្វីដែលកម្មចាត់ចែង ។ សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្ដីប្រការនេះទុកថា "សត្វនរកនោះ ដរាបណាកម្មអាក្រក់នៅមិនទាន់បញ្ចប់ ដរាបនោះនឹងមិនទាន់ស្លាប់ " ដូចនេះ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់នេរយិកគ្គិឧណ្ហភាវបញ្ហាទី ៦*

# ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*បញ្ហាមានការសួរដល់កម្តៅនៃភ្លើងនរក ឈ្មោះថា **នេរយិកគ្គិឧណ្ហ-ភាវប្បញ្ហា** ។*

*ពាក្យថា* **កម្មាធិកតេន** *ប្រែថា ព្រោះជាអ្វីដែលកម្មចាត់ចែងក៏បាន ប្រែថា ព្រោះកម្មដែលបានចាត់ចែងទុកក៏បាន ឬ ម៉្យាងវិញទៀត ប្រែថា ព្រោះកម្មដែលខ្លួនបានចាត់ចែងធ្វើរួចរាល់ ។*

*ពាក្យថា **ដរាបណាកម្មអាក្រក់នោះនៅមិនទាន់បញ្ចប់** បានសេចក្តីថា ដរាបណា កម្មអាក្រក់ដែលបានចាត់ចែងធ្វើរួចរាល់ហើយនោះ នៅមិនទាន់បញ្ចប់ គឺ នៅហុចវិបាកមិនទាន់បញ្ចប់ នៅមិនទាន់អស់វិបាក ដរាបនោះ សត្វនរកនោះនឹងមិនទាន់ស្លាប់ គឺ នឹងមិនទាន់រំកិលចេញពីនរកនោះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៦*

# បញ្ហាទី ៧ - បឋវិសណ្ឋារកប្បញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ទាំងឡាយតែងតែពោលថា "**ផែនដីដ៏ធំនេះ តម្កល់នៅលើទឹក ទឹកតម្កល់នៅលើខ្យល់ ខ្យល់តម្កល់នៅលើអាកាស**" ដូចនេះ សូម្បីពាក្យនេះ ខ្ញុំព្រះករុណាក៏មិនជឿដែរ "*

**ព្រះថេរៈ** *ប្រើធមក្រកដួសទឹក ថ្វាយព្រះពរព្រះចៅមិលិន្ទឱ្យទ្រង់យល់ថា " សូមថ្វាយព្រះពរ ទឹកនេះជាទឹកដែលខ្យល់ទ្រទុកយ៉ាងណា ទោះជា*

*ទឹកដែលទ្រផែនដីនោះ ក៏ជាទឹកដែលខ្យល់ទ្រទុក ដូចនោះដែរ”*

**ព្រះចៅមិលិន្ទ៖** *“ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ” ៕*

*ចប់បឋវិសណ្ឋារកបញ្ហាទី ៧*

# ពាក្យអធិប្បាយបញ្ហាទី ៧៖

*បញ្ហាមានការសួរដល់ទឹកទ្រផែនដី ឈ្មោះថា* ***បឋវិសណ្ឋារកបញ្ហា*** *៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - និរោធនិព្វានបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា “ព្រះគុណម្ចាស់នាគសេន និរោធឈ្មោះថា និព្វានឬ?”*

**ព្រះនាគសេន៖** *“ សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវ និរោធឈ្មោះថា និព្វាន”*

**ព្រះចៅមិលិន្ទ ៖** *“ ព្រះគុណម្ចាស់នាគសេន និរោធឈ្មោះថា និព្វានយ៉ាងដូចម្ដេច?”*

**ព្រះនាគសេន៖** *“ សូមថ្វាយព្រះពរ ពួកពាលបុថុជ្ជនទាំងឡាយទាំងពួង រមែងត្រេកអរ រមែងត្រេកត្រអាល រមែងជាប់ចិត្តនឹងអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅទាំងឡាយ ។*

*ពួកពាលបុថុជ្ជនទាំងនោះ ទើបត្រូវចរន្ត(តណ្ហា)នោះ ផាត់នាំទៅ ទើប*

*មិនរួចផុត ពីការកើត ពីការចាស់ ពីការស្លាប់ ពីការសោកសៅ ពីការយំខ្សឹកខ្សួល ពីសេចក្តីទុក្ខនៃកាយ ពីសេចក្តីទុក្ខនៃចិត្ត ពីសេចក្តីណែនតឹងទ្រូង អាត្មាភាពសូមពោលថា រមែងមិនរួចផុតពីទុក្ខ ។*

*សូមថ្វាយព្រះពរ ព្រះអរិយសាវក អ្នកដែលមានធម៌បានស្តាប់រួចហើយ រមែងមិនភ្លើតភ្លើន មិនត្រេកត្រអាល រមែងមិនជាប់ចិត្តនឹងអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅទាំងឡាយ ។ ពេលព្រះអរិយសាវកនោះមិនភ្លើតភ្លើន មិនត្រេកត្រអាល មិនជាប់ចិត្តនឹងអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅទាំងឡាយនោះ តណ្ហាក៏រមែងរលត់ទៅ ។ ព្រោះតណ្ហារលត់ទៅ ទើបឧបាទានរលត់ទៅ ។ ព្រោះឧបាទានរលត់ទៅ ទើបភពរលត់ទៅ ទើបការកើតរលត់ទៅ ការចាស់ ការស្លាប់ ការសោកសៅ ការយំខ្សឹកខ្សួល សេចក្តីទុក្ខនៃកាយ សេចក្តីទុក្ខនៃចិត្ត សេចក្តីណែនតឹងទ្រូង ទើបរលត់ទៅ និរោធ(ការរលត់)នៃគំនរទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូចពោលមកនេះ ។*

*សូមថ្វាយព្រះពរ និរោធឈ្មោះថា និព្វាន ដូចពោលខាងលើ មកនេះ ”*

**ព្រះចៅមិលិន្ទ ៖** *“ ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ ” ៕*

*ចប់និរោធនិព្វានបញ្ហាទី ៨*

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*បញ្ហាមានការសួរដល់និរោធ និង និព្វាន ឈ្មោះថា* ***និរោធនិព្វាន-បញ្ហា*** *។*

ពាក្យថា **ព្រះគុណម្ចាស់នាគសេន និរោធឈ្មោះថា និព្វានយ៉ាងដូចម្តេច** ? មានអត្ថន័យថា " ព្រះគុណម្ចាស់នាគសេន និរោធ(ការរលត់)របស់អ្នកណា ហៅនិរោធរបស់អ្នកនោះថានិព្វាន បានយ៉ាងដូចម្តេច ? "

បទថា **សុត្វា - អ្នកដែលមានធម៌បានស្តាប់រួចហើយ** គឺ ព្រះអរិយសាវកអ្នកមានសុតៈ ដោយសុតៈ គឺព្រះអរិយមគ្គ ។ ប្រាកដណាស់ បុគ្គលជាក់ច្បាស់ធម៌ណា ធម៌នោះឈ្មោះថា សុតៈ ប្រែថា ធម៌ដែលខ្លួនបានស្តាប់ល្អហើយ ។ ព្រះអរិយមគ្គមានអង្គ ៨ ជាធម៌ដែលព្រះអរិយសាវកជាក់ច្បាស់រួចហើយ ព្រោះហេតុនោះ ទើបបានឈ្មោះថា សុតៈ - **ធម៌ដែលបានស្តាប់រួចហើយ** និង ព្រះអរិយបុគ្គលទាំងឡាយ ក៏ឈ្មោះថា **សុត្វា - អ្នកដែលមានធម៌បានស្តាប់រួចហើយ** ។

ពាក្យថា **មិនភ្លើតភ្លើន មិនត្រេកត្រអាល មិនជាប់ចិត្ត** គឺមិនភ្លើតភ្លើនថា " ល្អ " មិនត្រេកត្រអាលថា " ល្អ " មិនជាប់ចិត្តថា " ល្អ " ដោយអំណាចនៃបញ្ញា ដែលឃើញហើយថា មិនស្អាត មិនទៀង ជាទុក្ខ ជាអនត្តា ។

ដោយពាក្យថា **តណ្ហានិរោធា - ព្រោះតណ្ហារលត់ទៅ ឧបាទាននិរោធា- ព្រោះឧបាទានរលត់ទៅ ភវនិរោធា - ព្រោះភពរលត់ទៅ ជាតិនិរោធា- ព្រោះជាតិរលត់ទៅ** ដូចនេះ ជាពាក្យថ្លែងដល់ការរលត់ទៅនៃហេតុ លោកសម្តែងការរលត់ទៅនៃសមុទយសច្ចៈ ជាសច្ចៈដែលមគ្គអាចលះឱ្យអស់ទៅ ។ រីឯ ដោយពាក្យថា **ឧបាទាននិរោធោ** - ទើបឧបាទានរលត់ទៅ **ភវនិរោធោ**- ទើបភពរលត់ទៅ **ជាតិនិរោធោ**- ទើបការកើតរលត់ទៅ ជរាមរណៈ។ល។ **ឧបាយាសា និរុជ្ឈន្តិ**- ការចាស់ ការស្លាប់ ។ល។ ការណែនតឹងទ្រូងទើបរលត់ទៅ ជាពាក្យថ្លែងដល់ការរលត់ទៅនៃផល លោកសម្តែងការរលត់ទៅនៃទុក្ខសច្ចៈ ជាសច្ចៈដែលមគ្គកំណត់ដឹង ។ ការ

*រលត់ទៅនៃហេតុឈ្មោះថា និរោធ ។ ព្រោះពាក្យ ថា "**និរោធ**" ត្រាស់សំដៅយកការរលត់ទៅព្រោះត្រូវលះរហូតអស់ទៅនៃហេតុ ពោលគឺសមុទ័យ។ ការរលត់ទៅនៃផលឈ្មោះថា និព្វាន ព្រោះពាក្យថា "**និព្វាន**" ត្រាស់សំដៅយកការរលត់ទៅ គឺ ការកើតឡើងតទៅទៀត មិនបាននៃផល ពោលគឺទុក្ខ ។ ផលនឹងដល់ការរលត់ទៅ មិនកើតទៀត ព្រោះមានការរលត់ទៅនៃហេតុ ព្រោះហេតុនោះ ទើបនិរោធជាពាក្យតែមួយជាមួយនិព្វាន ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - និព្វានលភនបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *" ព្រះគុណម្ចាស់នាគសេន បុគ្គលរមែងបានព្រះនិព្វានគ្រប់គ្នា ឬ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ បុគ្គលនឹងបានព្រះនិព្វានគ្រប់គ្នា ក៏មិនមែន សូមថ្វាយព្រះពរ ប៉ុន្តែអ្នកឯណាជាអ្នកប្រតិបត្តិត្រឹមត្រូវ ដឹងប្រាកដនូវអភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ លះបហាតព្វធម៌ ចម្រើនភាវេតព្វធម៌ ធ្វើឱ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌ អ្នកនោះរមែងបានព្រះនិព្វាន "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់និព្វានលភនបញ្ហាទី ៩*

# ពាក្យអធិប្បាយបញ្ហាទី ៩ ៖

*បញ្ហាមានការសួរដល់ការបានជាក់ព្រះនិព្វាន ឈ្មោះថា **និព្វានលភនបញ្ហា** ។*

*ពាក្យថា **អភិញ្ញេយ្យធម៌** ប្រែថា ធម៌ដែលគួរដឹងជាខ្លាំង បានសេចក្ដីថា ដឹងជ្រាលជ្រៅនូវធម៌ ដែលគួរដឹងជាខ្លាំង ។ ពីព្រោះជាការដឹងដល់លក្ខណៈនីមួយ ៗ របស់ធម៌ទាំងនោះ យ៉ាងនេះថា " ធម្មជាតិដែលមានលក្ខណៈរឹង គឺ ធាតុដី ធម្មជាតិដែលមានលក្ខណៈផ្ដុំ គឺ ធាតុទឹក ។ល។ ធម្មជាតិដែលមានលក្ខណៈទង្គិចអារម្មណ៍ គឺ ផស្សៈ ធម្មជាតិដែលមានលក្ខណៈសោយអារម្មណ៍ គឺ វេទនា " ដូចនេះ ជាដើម ។*

*ពាក្យថា **បរិញ្ញេយ្យធម៌** ប្រែថា ធម៌ដែលគួរកំណត់ដឹង បានសេចក្ដីថា កំណត់ដឹង គឺ កំណត់កាន់យកដោយសតិ ហើយដឹងលក្ខណៈសាមញ្ញនៃធម៌នោះ ដោយអំណាចនៃវិបស្សនាបញ្ញា យ៉ាងនេះថា " **មិនទៀង ជាទុក្ខ ជាអនត្តា** " ដូចនេះ ។*

*ពាក្យថា **បហាតព្វធម៌** ប្រែថា ធម៌ដែលគួរលះ បានសេចក្ដីថា លះធម៌ដែលគួរលះ គឺ រាគៈ ទោសៈ មោហៈ ដោយការធ្វើឱ្យស្ងប់មិនអាចកញ្ជ្រោលឡើងបាន ដោយអំណាចនៃញាណ ដែលតាមឃើញតែការរលត់ទៅ ការប្រាសចាកទៅ ការអស់ទៅនៃធម៌ទាំងឡាយ ជាបន្តបន្ទាប់ ។*

*ពាក្យថា **ភាវេតព្វធម៌** ប្រែថា ធម៌ដែលគួរចម្រើន បានសេចក្ដីថា រមែងចម្រើនធម៌ ដែលគួរចម្រើន គឺ កុសលធម៌ដែលជាផ្នែកមួយនៃការត្រាស់ដឹង គឺ សមថៈ និង វិបស្សនា ។*

*ពាក្យថា **សច្ឆិកាតព្វធម៌** ប្រែថា ធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់*

បានសេចក្ដីថា រមែងធ្វើឱ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ គឺ ព្រះនិព្វាន ។ ន័យម៉្យាងទៀត អរិយសច្ច ៤ ឈ្មោះថា អភិញ្ញេយ្យធម៌ ព្រោះជាធម៌ដែលគួរដឹងជាខ្លាំង គឺ គួរដឹងដោយបញ្ញាដ៏ខ្ពង់ខ្ពស់ជាងបញ្ញាប្រក្រតីធម្មតា គឺ វិបស្សនាបញ្ញា និងមគ្គបញ្ញា។

**ទុក្ខអរិយសច្ច** គឺ ឧបាទានខន្ធ ៥ ឈ្មោះថា បរិញ្ញេយ្យធម៌ ព្រោះជាធម៌ដែលគួរកំណត់ដឹងដោយសតិ និងបញ្ញា ។ ពីព្រោះជាការដឹងដល់លក្ខណៈនីមួយ ៗ របស់ធម៌ទាំងនោះ យ៉ាងនេះថា “ **ធម្មជាតិដែលមានលក្ខណៈរឹង គឺ ធាតុដី ធម្មជាតិដែលមានលក្ខណៈទង្គិចអារម្មណ៍ គឺ ផស្សៈ** ” ដូចនេះ ជាដើម និងពីព្រោះជាការដឹងដល់សាមញ្ញលក្ខណៈ យ៉ាងនេះថា “ **មិនទៀង ជាទុក្ខ ជាអនត្តា** ” ។

**ទុក្ខសមុទយអរិយសច្ច** គឺ តណ្ហា ឈ្មោះថា បហាតព្វធម៌ ព្រោះជាធម៌ដែលគួរលះឱ្យអស់ទៅ ។

**ទុក្ខនិរោធអរិយសច្ច** គឺ ព្រះនិព្វាន ឈ្មោះថា សច្ឆិកាតព្វធម៌ ព្រោះជាធម៌ដែលគួរធ្វើឱ្យជាក់ច្បាស់ គឺ គួរធ្វើឱ្យជាអារម្មណ៍ដោយប្រត្យក្សផ្ទាល់ ប្រៀបដូចសម្លឹងមើលផ្លែកន្ទួតព្រៃ លើបាតដៃ យ៉ាងដូចនេះ ។

**ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** គឺ អរិយមគ្គដែលមានអង្គ ៨ ឈ្មោះថា ភាវេតព្វធម៌ ព្រោះជាធម៌ដែលគួរចម្រើន គឺ គួរធ្វើឱ្យកើតឡើង និង កើតបន្ថែម ដូចនេះ ។

ពាក្យថា **អ្នកនោះរមែងបានព្រះនិព្វាន** គឺ អ្នកនោះរមែងបានជាក់ គឺ រមែងសម្រេចព្រះនិព្វាន ដែលជាធម៌រំលត់ទុក្ខ មានការកើតជាដើម បានសេចក្ដីថា អ្នកនោះរមែងផុតពីការកើត ជាដើម ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៩

# បញ្ហាទី ១០ - និព្វានសុខជាននបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *"ព្រះគុណម្ចាស់នាគសេន អ្នកដែលមិនបានជាក់ច្បាស់ព្រះនិព្វាន នឹងបានដឹងឬទេថា ព្រះនិព្វានជាសុខ?"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ មហាបពិត្រ ពិតមែន អ្នកដែលមិនបានជាក់ច្បាស់ព្រះនិព្វាន ក៏អាចដឹងបានថា ព្រះនិព្វានជាសុខ"*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់នាគសេន ពេលមិនបានជាក់ច្បាស់ដូចនេះ នឹងដឹងថា ព្រះនិព្វានជាសុខ បានយ៉ាងដូចម្ដេច?"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច អ្នកដែលមិនធ្លាប់ត្រូវកាត់ដៃកាត់ជើងពីមុនមកអាចដឹងបានឬទេថា ការត្រូវគេកាត់ដៃកាត់ជើង ជាទុក្ខ?"*

**ព្រះចៅមិលិន្ទ៖** *" ពិតមែន អាចដឹងបាន ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" អាចដឹងបានយ៉ាងដូចម្ដេច?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ គេបានឮសូរសំឡេងថ្ងូចថ្ងូរឈឺចាប់របស់អ្នកដទៃដែលត្រូវគេកាត់ដៃឬកាត់ជើង ក៏រមែងដឹងថា ការត្រូវគេកាត់ដៃឬកាត់ជើង ជាទុក្ខ"*

**ព្រះនាគសេន៖** *"សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ អ្នកទាំងឡាយបានស្ដាប់សំឡេង(សរសើរ)របស់អ្នកដែលបានឃើញព្រះនិព្វាន ក៏រមែងដឹងថា ព្រះនិព្វានជាសុខ"*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់និព្វានសុខជាននបញ្ហាទី ១០*

# ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*បញ្ហាមានការសួរដល់ការដឹងថា ព្រះនិព្វានជាសុខ ឈ្មោះថា **និព្វានសុខជាននបញ្ហា** ។*

*ពាក្យថា **ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ** បានសេចក្តីថា អ្នកដែលមិនធ្លាប់ ត្រូវកាត់ដៃកាត់ជើងពីមុនមក បានឮសូរសំឡេងថ្ងូចថ្ងូរ ឈឺចាប់របស់អ្នកដទៃ ដែលត្រូវគេកាត់ដៃឬកាត់ជើងហើយ ក៏រមែងដឹងថា ការត្រូវគេកាត់ដៃឬកាត់ជើង ជាទុក្ខយ៉ាងណា អ្នកដែលមិនធ្លាប់ធ្វើព្រះនិព្វានឱ្យជាក់ច្បាស់ពីមុនមក បានស្តាប់សំឡេងសរសើរគុណរបស់ព្រះនិព្វាន យ៉ាងនេះថា "**ជាធម៌រំលត់ទុក្ខ ជាធម៌ស្ងប់ពីទុក្ខ ជាធម៌ដែលរំលត់ភ្លើងមានរាគៈ ជាដើម**" ដូចនេះហើយ ក៏រមែងដឹងថា ព្រះនិព្វានជាសុខ ដូចនេះដែរ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១០*

# ចប់និព្វានវគ្គទី ៤

*ក្នុងវគ្គនេះមាន ១០ បញ្ហា*

ᨀᨀᨀᨀ 📖 ᨀᨀᨀᨀ

# វគ្គទី ៥ - ពុទ្ធវគ្គ

## បញ្ហាទី ១ - ពុទ្ធស្ស អត្ថិនត្ថិភាវបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ធ្លាប់ឃើញព្រះពុទ្ធអង្គឬទេ ?*"

**ព្រះនាគសេន ៖** " *អាត្មាភាពមិនធ្លាប់ឃើញទេ មហាបពិត្រ*"

**ព្រះចៅមិលិន្ទ ៖** " *បើដូចនេះ គ្រូបាអាចារ្យទាំងឡាយរបស់ព្រះគុណ-ម្ចាស់ធ្លាប់ឃើញព្រះពុទ្ធអង្គ ឬយ៉ាងណា ?*"

**ព្រះនាគសេន ៖** " *គ្រូបាអាចារ្យទាំងឡាយរបស់អាត្មាភាព ក៏មិនធ្លាប់ឃើញដែរ មហាបពិត្រ*"

**ព្រះចៅមិលិន្ទ ៖** " *បើដូចនេះ ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធអង្គក៏ពុំមាន ពិតមែនដែរ*"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ធ្លាប់ទតព្រះនេត្រឃើញទន្លេឱហានទី នៅភ្នំហិមពាន្តឬទេ ?*"

**ព្រះចៅមិលិន្ទ ៖** " *មិនធ្លាប់ឃើញទេ ព្រះគុណម្ចាស់*"

**ព្រះនាគសេន ៖** " *បើដូចនេះ ព្រះជនករបស់ព្រះអង្គ ទ្រង់ធ្លាប់ទតព្រះនេត្រឃើញទន្លេឱហានទី ឬទេ ?*"

**ព្រះចៅមិលិន្ទ ៖** " *ទ្រង់ក៏មិនធ្លាប់ទតព្រះនេត្រឃើញដែរ ព្រះគុណ-ម្ចាស់*"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ បើដូចនេះ ទន្លេឱហានទីក៏ពុំមាន ពិតមែនដែរ*"

**ព្រះចៅមិលិន្ទ ៖** " *មានពិតមែន ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាមិនធ្លាប់ឃើញទន្លេឱហានទីទេ ទោះជាបិតារបស់ខ្ញុំព្រះករុណា ក៏*

*មិនធ្លាប់ឃើញទន្លេឱហានទីដែរ ក៏ពិតមែន ទោះជាយ៉ាងនោះក្តី ទន្លេឱហានទី គឺមានពិតមែន ”*

**ព្រះនាគសេន ៖** “ *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ អាត្មាភាពមិនធ្លាប់ឃើញព្រះដ៏មានព្រះភាគ ទោះជាគ្រូបាអាចារ្យទាំងឡាយរបស់អាត្មាភាព ក៏មិនធ្លាប់ឃើញព្រះដ៏មានព្រះភាគដែរ ក៏ពិតមែន ទោះជាយ៉ាងនោះក្តី ព្រះដ៏មានព្រះភាគ គឺមានពិតមែន ”*

**ព្រះចៅមិលិន្ទ ៖** “ *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ ”* ៕

*ចប់ពុទ្ធស្ស អត្ថិនត្ថិភាវប្បញ្ហាទី ១*

## ពាក្យអធិប្បាយបញ្ហាទី ១ ៖

*ក្នុងពុទ្ធវគ្គនេះមាន ១០ បញ្ហា ។*

*បញ្ហាមានការសួរដល់ការមាន ឬ ពុំមាននៃព្រះពុទ្ធអង្គ ឈ្មោះថា* ***ពុទ្ធស្ស អត្ថិនត្ថិភាវប្បញ្ហា*** *។*

*ពាក្យថា* ***ទន្លេឱហានទី*** *គឺ ទន្លេដែលហូរបែកចេញពីស្រះអនោតត្តលើភ្នំហិមពាន្ត ដែលមានឈ្មោះថា “ឱហា” ព្រោះហូរទៅ មានសំឡេងលាន់ឮថា “ឱហា... ឱហា...” ។ តាមការពិត ជាឈ្មោះរបស់ទន្លេគង្គា ដែលហូរមកពីស្រះអនោតត្ត ត្រង់កន្លែងទឹកក្តួចនោះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១*

# បញ្ហាទី ២ - ពុទ្ធស្ស អនុត្តរភាវប្បញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា “ ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់ទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង ពិតមែនឬ ? ”*

**ព្រះនាគសេន ៖** " *ត្រឹមត្រូវហើយ មហាបពិត្រ ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង ពិតមែន* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់មិនធ្លាប់ឃើញព្រះពុទ្ធជាម្ចាស់ តើលោកម្ចាស់នឹងដឹងបានយ៉ាងដូចម្ដេចថា ព្រះពុទ្ធជាម្ចាស់ទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច ? ពួកមនុស្សដែលមិនធ្លាប់ឃើញមហាសមុទ្រ នឹងដឹងបានយ៉ាងដូចម្ដេចថា មហាសមុទ្រធំធេង មានជម្រៅមិនអាចប៉ាន់ប្រមាណបាន ពិបាកស្ទង់ដល់ ដាកន្ទ្លេងដែលទន្លេធំ ៥ ខ្សែ ទាំងនេះ ហូរមកបញ្ចប់ជាប្រចាំជានិច្ចកាល គឺ ទន្លេគង្គា ទន្លេយមុនា ទន្លេអចិរវតី ទន្លេសរភូ ទន្លេមហី មហាសមុទ្រនោះមិនប្រាកដថា ស្រកចុះ ឬ ពេញហៀរច្រាំងឡើយ ?* "

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន ដឹងបាន ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ អាត្មាភាពបានជួបឃើញព្រះអរហន្តសាវកទាំងឡាយ ដែលបានរំលត់កិលេសហើយ ក៏ដឹងថា ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ។

*ចប់ពុទ្ធស្ស អនុត្តរភាវប្បញ្ហាទី ២*

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហាស្ដីអំពីភាពជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង នៃព្រះពុទ្ធជាម្ចាស់ ឈ្មោះថា* ***ពុទ្ធស្ស អនុត្តរភាវប្បញ្ហា*** ។

*ពាក្យថា **អនុត្តរោ - បុគ្គលដែលពុំមានអ្នកណាប្រសើរជាង** គឺ បុគ្គលដែលពុំមានអ្នកណាប្រសើរជាង គឺ វិសេសជាង ដោយគុណទាំងឡាយ ។*

*ពាក្យថា **ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ** បានសេចក្ដីថា ប្រៀបដូចជា មនុស្សដែលមិនធ្លាប់ឃើញមហាសមុទ្រ គឺមិនធ្លាប់ទៅកាន់មហាសមុទ្រ ឃើញទន្លេធំទាំង ៥ ខ្សែ ដែលហូរមកបញ្ចប់គ្នា នៅមហាសមុទ្រហើយ ក៏រមែងដឹងថាមហាសមុទ្រមានភាពធំធេង ។*

*យ៉ាងណាមិញ អាត្មាភាពបានប្រទះឃើញព្រះសាវ័កដ៏ខ្ពង់ខ្ពស់ ដែលជាភិក្ខុ ជាភិក្ខុនី ជាក្សត្រ ជាព្រាហ្មណ៍ ជាគហបតី នៅប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម៌វិន័យរបស់ព្រះដ៏មានព្រះភាគ អ្នកមានកិលេសទាំងឡាយរលត់ទាំងនេះហើយ ក៏រមែងដឹងថា ព្រះដ៏មានព្រះភាគ ទ្រង់ជានាយសារថីបង្ហាត់បុរស ដែលអាចបង្ហាត់បាន ពុំមានអ្នកណាប្រសើរជាង ដូចនេះដែរ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - ពុទ្ធស្ស អនុត្តរភាវជាននបញ្ហា

**ព្រះរាជា**មានបន្ទូលថា ៖ *"ព្រះគុណម្ចាស់នាគសេន យើងអាចដឹងបានឬទេថា ព្រះពុទ្ធជាម្ចាស់ទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង ?"*

**ព្រះនាគសេន ៖** *" **ពិតមែន** សូមថ្វាយព្រះពរ យើងអាចដឹងបានថា ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន យើងអាចដឹងបានយ៉ាងដូចម្ដេចថា ព្រះពុទ្ធជាម្ចាស់ទ្រង់ជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មុននេះក៏ធ្លាប់មានព្រះគ្រូ ជាអ្នកនិពន្ធ ឈ្មោះថា ព្រះតិស្សត្ថេរ ពេលលោកមរណភាពកន្លងទៅជាច្រើន*

*ឆ្នាំ អ្នកទាំងឡាយនៅអាចស្គាល់លោកបានយ៉ាងដូចម្ដេច ?"*

**ព្រះចៅមិលិន្ទ** ៖ " *អ្នកទាំងឡាយនៅអាចស្គាល់លោកបានដោយសារការងារនិពន្ធ"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ អ្នកឯណាឃើញព្រះធម៌ អ្នកនោះរមែងឃើញព្រះដ៏មានព្រះភាគ ព្រោះថាព្រះធម៌ ព្រះដ៏មានព្រះភាគទ្រង់បានសម្ដែងទុករួចហើយ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់ពុទ្ធស្ស អនុត្តរភាវជាននបញ្ហាទី ៣*

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

*បញ្ហាស្ដីអំពីការដឹងដល់ភាពជាបុគ្គល ដែលពុំមានអ្នកណាប្រសើរជាង នៃព្រះពុទ្ធជាម្ចាស់ ឈ្មោះថា* ***ពុទ្ធស្ស អនុត្តរភាវជាននបញ្ហា*** *។*

*ពាក្យថា* ***ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះ*** *បានសេចក្ដីថាប្រៀបដូចជា អ្នកទាំងឡាយស្គាល់ព្រះតិស្សត្ថេរ ជាគ្រូបាអាចារ្យ ជាអ្នកនិពន្ធ ដែលបានទទួលមរណភាពជាច្រើនឆ្នាំទៅហើយនោះ ដោយសារការងារនិពន្ធ គឺ ដោយការបានឃើញការងារនិពន្ធរបស់លោកយ៉ាងណា ពួកយើងក៏រមែងស្គាល់ព្រះដ៏មានព្រះភាគដោយព្រះធម៌ គឺ ដោយការឃើញធម៌ដែលព្រះដ៏មានព្រះភាគនោះ ទ្រង់បានសម្ដែងទុករួចហើយ ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៣*

# បញ្ហាទី ៤ - ធម្មទិដ្ឋបញ្ហា

**ព្រះរាជា** មានបន្ទូលថា " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់បាន ឃើញព្រះធម៌ហើយឬ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ពួកសាវ័កគួរ ប្រព្រឹត្តធម៌រហូតអស់មួយជីវិត ព្រោះជាអ្វី ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បាន ណែនាំទុក ព្រោះជាអ្វី ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បានបញ្ញត្តទុក"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរ ហើយ" ៕

ចប់ធម្មទិដ្ឋបញ្ហាទី ៤

## ពាក្យអធិប្បាយបញ្ហាទី ៤ ៖

បញ្ហាស្តីអំពីធម៌ ដែលបានឃើញហើយ ឈ្មោះថា **ធម្មទិដ្ឋបញ្ហា** ។

ពាក្យថា ***ព្រោះជាអ្វី ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បានណែនាំទុក*** ជាដើម គឺ ព្រោះជាអ្វី ដែលព្រះពុទ្ធជាម្ចាស់ ដ៏មានព្រះបញ្ញាចក្ខុ ទោះគ្រប់ព្រះអង្គ ទ្រង់បានណែនាំទុក គឺ ទ្រង់បានសម្តែងទុក និង ទ្រង់បានបញ្ញត្តទុក ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៤

# បញ្ហាទី ៥ - អសង្កមនបដិសន្ធានបញ្ហា

**ព្រះរាជា** មានបន្ទូលថា " ព្រះគុណម្ចាស់នាគសេន ចិត្តមិនរំកិលទៅ ផង ក៏បដិសន្ធិបានដែរឬ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវហើយ ចិត្ត មិនរំកិលទៅផង ក៏បដិសន្ធិបានដែរ"

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ចិត្តមិនរំកិលទៅផង ក៏បដិសន្ធិបានដែរយ៉ាងដូចម្ដេច ? សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ បុរសខ្លះអាចដុតភ្លើងចង្កៀង(ថ្មី)បានពីភ្លើងចង្កៀង(ចាស់) ភ្លើងចង្កៀងថ្មីជាភ្លើងដែលរំកិលពីចង្កៀង(ចាស់)ទៅឬ ?* "

**ព្រះចៅមិលិន្ទ ៖** " *មិនមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ចិត្តមិនរំកិលទៅផង ក៏បដិសន្ធិបានដែរ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ឧបមាបន្ថែមបន្តិចទៀតផងចុះ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ គ្រាដែលព្រះអង្គទ្រង់នៅជាព្រះរាជកុមារ ព្រះអង្គទ្រង់ចាំបានឬទេថា ទ្រង់បានទទួលកិត្តិយសខ្លះ ក្នុងសម្នាក់របស់គ្រូបាអាចារ្យដ៏មានកិត្តិយស ?* "

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណានៅចាំបាន* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ កិត្តិយសដែលព្រះអង្គទ្រង់បានទទួលនោះ រំកិលទៅពីខ្លួនគ្រូបាអាចារ្យឬ ?* "

**ព្រះចៅមិលិន្ទ ៖** " *មិនមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ចិត្តមិនរំកិលទៅផង ក៏បដិសន្ធិបានដែរ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់អសង្កមនបដិសន្ធហានបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាស្តីអំពីការមិនរំកិលចេញ ក៏បដិសន្ធិបាន ឈ្មោះថា* ***អសង្កមន-បដិសន្ធហនបញ្ហា*** *។*

*ពាក្យថា* ***ចិត្តមិនរំកិលទៅផង ក៏បដិសន្ធិបានដែរឬ ?*** *បានសេចក្តីថា ព្រះរាជាមានបន្ទូលសួរថា ចិត្តបដិសន្ធិ(កើត)ក្នុងភពថ្មីបាន ដោយមិនមានការរំកិលចេញពីភពចាស់ឬ?*

*ក្នុងពាក្យនោះ ចិត្តដួងមុន ដែលជាចិត្តដួងចុងក្រោយនៃភពមុន ឈ្មោះថា* ***ចុតិ*** *(រំកិល) ចិត្តដួងបន្ទាប់ដែលជាចិត្តដួងដំបូងនៃភពនេះ ឈ្មោះថា* ***បដិសន្ធិ*** *។ ចិត្តដួងមុនធ្វើមុខងារចុតិ គឺ រំកិលចេញពីភព ហើយក៏រលត់ទៅក្នុងខណៈនោះ ពុំមែនរំកិលទៅក្នុងភពបន្ទាប់ទៀតបានទេ ។*

*ព្រោះហេតុនោះ ទើបពោលបានថា គ្មានចិត្តអ្វីរំកិលពីភពចាស់មកកាន់ភពនេះទេ ដែលបានឈ្មោះថា ចុតិ ប្រែថា ចិត្តរំកិល ពីព្រោះមានកិច្ច ឬ មុខងារប្រៀបដូចជា រំកិលចេញពីភពប៉ុណ្ណោះ ពីព្រោះថា លុះរលត់ទៅជាហេតុឱ្យមានភពថ្មី មិនមែនរំកិលចេញទៅបាន មែននោះទេ ។*

*ម្យ៉ាងវិញទៀត លុះចិត្តដួងមុនរលត់ទៅហើយ ចិត្តដួងបន្ទាប់ក៏កើតឡើងធ្វើមុខងារបដិសន្ធិ គឺធ្វើមុខងារប្រៀបដូចជា ភ្ជាប់ភពថ្មីជាមួយនឹងភពចាស់ ធ្វើឱ្យមានភពថ្មីតទៅទៀត ។*

*បើដូចនេះអាចពោលបានថា ចិត្តដួងនេះមិនមែនជាចិត្ត ដែលរំកិលចេញពីភពមុននោះទេ ។ គឺថា ចិត្តដួងមុន និងចិត្តដួងបន្ទាប់ ជាចិត្តដួងផ្សេងគ្នា មិនឡូកឡំគ្នា ប៉ុន្តែបានប្រព្រឹត្តទៅ ដោយមានការទាក់ទងគ្នាដោយជាហេតុ ជាផលនឹងគ្នា តាមប្រការដូចពោលខាងលើ ដូចនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៥*

# បញ្ហាទី ៦ - វេទគូបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន វេទគូមានពិតឬទេ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ និយាយតាមបរមត្ថ វេទគូពុំមានពិតទេ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។

ចប់វេទគូបញ្ហាទី ៦

## ពាក្យអធិប្បាយបញ្ហាទី ៥ ៖

បញ្ហាមានការសួរដល់វេទគូ គឺ តួអត្តាជីវៈខាងក្នុង ឬបុគ្គលដែលជាអ្នកតាមដឹងអារម្មណ៍ខាងទ្វារទាំង ៦ ឈ្មោះថា **វេទគូបញ្ហា** ។

ពាក្យថា **តាមបរមត្ថ** គឺ និយាយតាមការពិតនៃបរមត្ថ ដែលប្រាសចាកសត្វបុគ្គល បានសេចក្ដីថា តាមការពិតនៃបរមត្ថ អត្តាជីវៈ ឬបុគ្គល គឺពុំមានពិតទេ ។

ចប់ពាក្យអធិប្បាយបញ្ហាទី៦

# បញ្ហាទី ៧ - អញ្ញកាយសង្កមនបញ្ហា

**ព្រះរាជា** មានបន្ទូលថា " ព្រះគុណម្ចាស់នាគសេន សត្វអ្វី ៗ ដែលរំកិលចេញពីកាយនេះ ទៅកាន់កាយផ្សេងមានដែរឬទេ?"

**ព្រះនាគសេន ៖** " ពុំមានទេ សូមថ្វាយព្រះពរ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន ប្រសិនបើសត្វដែល

*វិកិលចេញពីកាយនេះ ទៅកាន់កាយផ្សេង ពុំមានទេ ក៏នឹងជាអ្នកដែលរួចផុតពីកម្មអាក្រក់ទាំងឡាយបាន មិនមែនទេឬ?"*

**ព្រះនាគសេន៖** *" ពិតមែនហើយ សូមថ្វាយព្រះពរ ប្រសិនបើគេមិនបដិសន្ធិ គេនឹងជាអ្នកដែលរួចផុតពីកម្មអាក្រក់ទាំងឡាយបាន ។ សូមថ្វាយព្រះពរ ប៉ុន្តែព្រោះហេតុថា គេនៅមានបដិសន្ធិ ព្រោះហេតុនោះ ទើបពុំអាចរួចផុតពីកម្មអាក្រក់ទាំងឡាយបានឡើយ"*

**ព្រះចៅមិលិន្ទ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជាបុរសខ្លះបានលួចស្វាយរបស់បុរសម្នាក់ទៀតយកទៅ បុរសនោះត្រូវតែជាប់ទោស មិនមែនឬទេ?"*

**ព្រះចៅមិលិន្ទ៖** *" ពិតមែន ព្រះគុណម្ចាស់ គេត្រូវតែជាប់ទោស"*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ បុរសនោះមិនបានលួចយកស្វាយ ដែលបុរសជាម្ចាស់បានដាំនោះទេ ព្រោះហេតុអ្វីទើបគេត្រូវតែជាអ្នកជាប់ទោសទៅវិញ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ស្វាយ(ដែលត្រូវលួច)ទាំងនោះអាស្រ័យស្វាយ (ដែលបុរសជាម្ចាស់ដាំទុក)ទាំងនោះ ទើបកើតឡើងបាន ព្រោះហេតុនោះ គេត្រូវតែជាអ្នកជាប់ទោស"*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ បុគ្គលធ្វើកម្មល្អខ្លះ អាក្រក់ខ្លះ ដោយរូបនាមនេះ នាមរូបផ្សេងទើបបដិសន្ធិព្រោះកម្មនោះ ព្រោះហេតុនោះ ទើបពុំអាចជាអ្នករួចផុតពីកម្មអាក្រក់ទាំងឡាយបានទេ"*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់អញ្ញកាយសង្កមនបញ្ហាទី ៧*

## ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*បញ្ហាមានការសួរដល់ការរំកិលពីកាយនេះ ទៅកាន់កាយផ្សេង ឈ្មោះថា* ***អញ្ញកាយសង្កមនបញ្ហា*** *។*

*ពាក្យថា* ***កាយនេះ*** *គឺ កាយ(នាមរូប)នេះ ក្នុងភពបច្ចុប្បន្ននេះ ពាក្យថា* ***កាយផ្សេង*** *គឺ កាយ(នាមរូប)ផ្សេង ក្នុងភពផ្សេង ។*

*ក្នុងឧបមា និង ឧបមេយ្យ មានន័យប្រៀបធៀបគ្នា ដូចតទៅនេះ ៖*

*ស្វាយដែលត្រូវលួច អាស្រ័យស្វាយដែលអ្នកជាម្ចាស់បានដាំទុក ទើបកើតឡើងបាន ព្រោះហេតុនោះ បុរសអ្នកលួចស្វាយផ្សេងពីស្វាយដែលម្ចាស់បានដាំទុកនោះ ទើបមិនអាចរួចផុត ពីភាពជាអ្នកជាប់ទោស ។ យ៉ាងណាមិញ នាមរូបផ្សេងអាស្រ័យកម្មល្អ ឬ អាក្រក់ ដែលបានធ្វើទុកដោយនាមរូបនេះ ទើបបដិសន្ធិបាន ។ ព្រោះហេតុនោះ សត្វដែលធ្វើកម្មអាក្រក់ទុកនោះ ទោះជាប្រព្រឹត្តទៅ ដោយនាមរូបផ្សេង ពីនាមរូបនេះហើយ ក៏មិនឈ្មោះថា រួចផុតពីកម្មអាក្រក់នោះ ដូចនេះ ។*

*ពាក្យដែលនៅសល់ ក៏គួរជ្រាបតាមន័យ ដូចដែលបានពោលរួចហើយក្នុងបញ្ហាមុន ៗ ផងចុះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - កម្មផលអត្ថិភាវបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *" ព្រះគុណម្ចាស់នាគសេន កុសលកម្មក្តី អកុសលកម្មក្តី ដែលសត្វបានធ្វើទុកដោយនាមរូបនេះ កម្មទាំងនោះតាំងនៅទីណា ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ កម្មទាំងនោះនឹង*

*តាមជាប់ទៅ ដូចស្រមោលអន្ទោលតាមខ្លួន ដូចនោះ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់អាចបង្ហាញកម្មទាំងនោះបានឬទេថា កម្មទាំងនោះតាំងនៅទីត្រង់នេះ ឬ ក៏ទីត្រង់នេះ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ នរណាក៏មិនអាចបង្ហាញកម្មទាំងនោះថា កម្មទាំងនោះតាំងនៅទីត្រង់នេះ ឬ ក៏ទីត្រង់នេះទេ"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីប្រការនោះយ៉ាងដូចម្ដេច ដើមឈើដែលមិនទាន់មានផ្លែកើតឡើង តើព្រះអង្គទ្រង់អាចបង្ហាញផ្លែឈើទាំងនោះបានឬទេថា ផ្លែទាំងនោះនឹងតាំងនៅ (នឹងកើតឡើង) នៅត្រង់នេះ ឬក៏នៅត្រង់នេះ?"*

**ព្រះរាជា ៖** *" មិនអាចបង្ហាញបានទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ កាលណាភាពបន្ត(នៃនាមរូប) នៅមិនទាន់ដាច់រយៈ នរណាក៏មិនអាចបង្ហាញកម្មទាំងនោះបានថា កម្មទាំងនោះ តាំងនៅទីត្រង់នេះ ឬក៏នៅត្រង់នេះ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់កម្មផលអត្ថិភាវប្បញ្ហាទី ៨*

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*បញ្ហាស្ដីអំពីភាវៈកម្មមានផល ឈ្មោះថា* ***កម្មផលអត្ថិភាវប្បញ្ហា*** *។*

*ពាក្យថា* ***កម្មទាំងនោះនឹងជាប់តាមខ្លួនទៅ ដូចស្រមោលអន្ទោលតាមខ្លួនទៅដូចនោះ*** *ដូចនេះជាការណោវោហារ (ពាក្យនិយាយដល់ហេតុ គឺកម្ម) ។ គួរជ្រាបអត្ថន័យយ៉ាងនេះថា នាមរូបដែលជាផលនៃកម្មនោះ នឹងជាប់ទៅតាមខ្លួន ដូចស្រមោលអន្ទោលទៅតាមខ្លួន ដូចនោះដែរ ។ ជាពាក្យដែល*

*លោកពោលស្មើគ្នា ទាំងកុសលកម្ម ទាំងអកុសលកម្ម ឬជាសាធារណៈ ។*

*ប៉ុន្តែក្នុងធម្មបទ បានត្រាស់ទុកសម្រាប់អកុសលកម្មថា "* **តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ** [១] ***ព្រោះទុច្ចរិត ៣ យ៉ាងនោះ ទើបទុក្ខជាប់តាមខ្លួនគេទៅ ដូចកង់រទេះ ដែលវិលតាមស្នាមជើងគោ(អូសរទេះ)ទៅ ដូចនោះ*** *" ។*

*បានត្រាស់ទុកសម្រាប់កុសលកម្មថា "* **តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី** [២] ***ព្រោះសុចរិត ៣ យ៉ាងនោះ ទើបសុខជាប់ទៅតាមខ្លួនគេ ដូចស្រមោលអន្ទោលតាមខ្លួន ដូចនោះ*** *" ។*

*ក្នុងព្រះបន្ទូលនេះ មានអត្ថន័យថា ព្រោះទុច្ចរិត ៣ យ៉ាង ជាអកុសលកម្មដែលគេបានសាងទុកនោះ ទុក្ខ គឺនាមរូបដែលជាទីប្រជុំនៃទុក្ខ ឬនាមរូបដែលកើតឡើងនៅក្នុងទុគ្គតិ ជាផលនៃអកុសលកម្មនោះ រមែងជាប់ទៅតាមខ្លួនគេ គឺនឹងតាមកើតឡើងចំពោះគេ ក្នុងកាលទាំង ៣ ។ ប្រៀបដូចជាអ្វី ? ប្រៀបដូចជា កង់រទេះវិលតាមស្នាមជើងគោ ដែលអូសរទេះទៅខាងមុខ ដូចនោះ ។ ព្រោះសុចរិត ៣ យ៉ាង ដែលជាកុសលកម្មនោះ សុខ គឺនាមរូបដែលជាទីប្រជុំនៃសុខ ឬនាមរូបដែលកើតឡើងនៅក្នុងសុគតិ ជាផលនៃកុសលកម្មនោះ រមែងជាប់តាមខ្លួនគេទៅ គឺ នឹងតាមកើតឡើងចំពោះគេ ក្នុងកាលទាំង ៣ ។ ប្រៀបដូចជាអ្វី ? ប្រៀបដូចជាស្រមោលអន្ទោលតាមខ្លួនទៅ ដូចនេះ ។*

*ពាក្យថា "* ***ប្រៀបដូចកង់រទេះវិលតាមស្នាមជើងគោ*** *" ក្តី ពាក្យថា "* ***ដូចស្រមោលអន្ទោលតាមខ្លួនទៅ*** *" ក្តី ពោលដោយអត្ថន័យគឺ តែមួយ ។ ព្រោះហេតុនោះ ក្នុងទីនេះ ពាក្យឧបមាដែលថា " ដូចស្រមោលអន្ទោលតាមខ្លួនដូចនោះ " ព្រះថេរៈពោលជាសាធារណៈ ចំពោះទាំងកុសលកម្ម ទាំងអកុសលកម្ម ។*

---

[១] *ខុទ្ទកនិកាយ ធម្មបទ ។*

[២] *ខុទ្ទកនិកាយ ធម្មបទ ។*

*ប្រៀបដូចថា ពេលរាងកាយដើរទៅ ស្រមោលដែលជារបស់ទាក់ទង នឹងរាងកាយនេះ ក៏រមែងដើរទៅដែរ ពេលឈរក៏ឈរដែរ ពេលអង្គុយក៏អង្គុយដែរ ពេលដេកក៏ដេកដែរ ។ ស្រមោលទើបឈ្មោះថា អន្ទោលទៅតាមបុគ្គលនោះ យ៉ាងណាមិញ ពេលបានធ្វើកុសលកម្មក្ដី អកុសលកម្មក្ដី នាមរូបដែលជាផលនៃកម្មទាំងនោះ ក៏រមែងតាមទៅកើតឡើង ក្នុងកាលទាំង ៣ តាមឱកាសរបស់កម្មនោះ ទើបឈ្មោះថា អន្ទោលទៅតាមបុគ្គលនោះ ដូចនោះ ។*

*ព្រោះហេតុនោះ ទើបបានជាពុំមាននរណាអាចបង្ហាញបានថា កម្មដែលធ្វើនាមរូបឱ្យកើតឡើងនោះ តាំងនៅត្រង់នេះ ឬ ក៏ត្រង់នោះ ដូចនេះបានទេ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - ឧប្បជ្ជតិជាននបញ្ហា

**ព្រះរាជា** *ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន សត្វដែលនឹងកើត រមែងដឹងបានឬទេថា យើងនឹងកើត ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ពិតមែន សត្វនឹងកើតរមែងដឹងបានថា យើងនឹងកើត "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ គហបតីអ្នកស្រែបានកប់គ្រាប់ស្រូវទុកនៅក្នុងដី ពេលមានភ្លៀងធ្លាក់ល្អ រមែងដឹងឬទេថា ធញ្ញជាតិនឹងដុះឡើង ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន ព្រះគុណម្ចាស់នាគសេន គេរមែងដឹងបាន "*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ សត្វដែលនឹងកើត រមែងដឹងបានថា យើងនឹងកើត* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់ឧប្បជ្ជតិជាននប្បញ្ហាទី ៩*

# ពាក្យអធិប្បាយបញ្ហាទី ៩ ៖

*បញ្ហាស្តីអំពីការដឹងថានឹងកើត នៃសត្វដែលនឹងកើត ឈ្មោះថា* ***ឧប្បជ្ជតិជាននប្បញ្ហា*** ។

*គហបតី អ្នកស្រែបានកប់គ្រាប់ស្រូវទុកនៅក្នុងដី ពេលមានភ្លៀងធ្លាក់ល្អរមែងដឹង បានថាធញ្ញជាតិនឹងដុះឡើង យ៉ាងណាមិញ អ្នកជួញដូរទោះជាក្រីក្រក្តី ពេលគំនរទ្រព្យសម្បត្តិ កើនឡើងជារឿយ ៗ ព្រោះការជួញដូររបស់ខ្លួន ក៏រមែងដឹងថា យើងនឹងបានក្លាយជាសេដ្ឋី។*

*យ៉ាងណាមិញ អ្នកបម្រើរាជការ ដែលព្រះរាជាទ្រង់ចិញ្ចឹមទុក ដោយថ្លៃឈ្នួលបន្តិចបន្តួច ទោះជាមានយសសក្តិតូចតាចក្តី ពេលបានធ្វើអំពើល្អវិសេស ចំពោះព្រះរាជា មានការចាប់ខ្លួនអ្នកគិតអាក្រក់ ចំពោះព្រះរាជាជាដើម ក៏រមែងដឹងបានថា យើងនឹងបានក្លាយជាអាមាត្យ ។*

*យ៉ាងណាមិញ បុគ្គលដែលមានអវិជ្ជា តណ្ហា ឧបាទាន និង កម្ម ពេលបានស្តាប់ធម៌ របស់ព្រះតថាគត ដឹងថា អវិជ្ជា តណ្ហា ឧបាទាន និងកម្ម ជាហេតុនាំមកនូវការកើត ដូចនេះហើយ ក៏រមែងដឹងថា យើងនឹងកើតទៀតដូចនោះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី៩*

# បញ្ហាទី ១០ - ពុទ្ធនិទស្សនបញ្ហា

**ព្រះរាជា** ត្រាស់សួរថា " ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់មានពិតមែនឬ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះដ៏មានព្រះភាគមានពិតមែន "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន ក៏ប៉ុន្តែលោកម្ចាស់អាចបង្ហាញបានឬទេថា ព្រះពុទ្ធជាម្ចាស់ប្រថាប់នៅទីកន្លែងនេះ ឬក៏ទីកន្លែងនេះ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់បានបរិ-និព្វានទៅហើយ ដោយអនុបាទិសេសបរិនិព្វានធាតុ ។ នរណាក៏មិនអាចបង្ហាញបានថា ព្រះដ៏មានព្រះភាគប្រថាប់នៅទីកន្លែងនេះ ឬក៏ទីកន្លែងនេះ?"

**ព្រះចៅមិលិន្ទ ៖** " សូមព្រះគុណម្ចាស់ធ្វើការឧបមា "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ព្រះអង្គទ្រង់យល់សេចក្តីប្រការនោះយ៉ាងដូចម្តេច អណ្តាតភ្លើងនៃគំនរភ្លើងធំដ៏សន្ធោសន្ធៅបានដល់ភាពរលត់ទៅ ព្រះអង្គអាចបង្ហាញបានឬទេថា អណ្តាតភ្លើងនោះទៅនៅទីកន្លែងនេះ ឬក៏ទីកន្លែងនេះ?"

**ព្រះចៅមិលិន្ទ ៖** " មិនអាចបង្ហាញបានទេ ព្រះគុណម្ចាស់ អណ្តាតភ្លើងដែលរលត់ទៅហើយនោះ ដល់ភាពមិនបង្ហាញខ្លួនហើយ "

**ព្រះនាគសេន ៖** " ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ព្រះដ៏មានព្រះភាគទ្រង់បានបរិនិព្វានទៅហើយ ទ្រង់ដល់ភាពរលត់ទៅ ដោយអនុបាទិសេសនិព្វានធាតុ ទើបបានជានរណាក៏មិនអាចបង្ហាញបានថា ព្រះដ៏មានព្រះភាគប្រថាប់នៅទីកន្លែងនេះ ឬក៏ទីកន្លែងនេះ ។

*សូមថ្វាយព្រះពរ ប៉ុន្តែបុគ្គលអាចបង្ហាញព្រះដ៏មានព្រះភាគ(ថាមានពិតមែន)បាន ដោយព្រះធម្មកាយ ព្រោះថាព្រះធម៌ ព្រះដ៏មានព្រះភាគទ្រង់បានសម្តែងទុកហើយ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់ពុទ្ធនិទស្សនបញ្ហាទី ១០*

# ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*បញ្ហាមានការបង្ហាញថា ព្រះពុទ្ធជាម្ចាស់មានពិតមែនឬទេ ឈ្មោះថា* ***ពុទ្ធនិទស្សនបញ្ហា*** *។*

*ពាក្យថា "* ***សូមថ្វាយព្រះពរ ប៉ុន្តែបុគ្គលអាចបង្ហាញព្រះដ៏មានព្រះភាគ (ថាមានពិតមែន) បានដោយព្រះធម្មកាយ ព្រោះថាព្រះធម៌ ព្រះដ៏មានព្រះភាគទ្រង់បានសម្តែងទុកហើយ*** *" ដូចនេះ ។*

*ព្រះថេរៈពោលសំដៅយកព្រះសូត្រថា ៖ "* **សិយា ខោ បនានន្ទ តុម្ហាកំ ឯវមស្ស អតីតសត្ថុកំ ចាវចនំ ។ល។ សោ វោ មមច្ចយេន សត្ថា** [(១)] - ***ម្នាលអានន្ទ ភិក្ខុទាំងឡាយអាចមានគំនិតយ៉ាងនេះថា ព្រះតម្រាស់ដែលជាប្រធានរបស់ព្រះសាស្តាក៏កន្លងផុតទៅហើយ ពួកយើងគ្មានព្រះសាស្តាទៅហើយ ដូចនេះ ម្នាលអានន្ទ ភិក្ខុទាំងឡាយមិនគួរគិតឃើញយ៉ាងនេះ ម្នាលអានន្ទ ធម៌និងវិន័យ ដែលតថាគតបានសម្តែងទុកហើយ បញ្ញត្តទុកហើយ ធម៌វិន័យនោះ រមែងជាសាស្តារបស់ភិក្ខុទាំងឡាយ ពេលតថាគតបរិនិព្វានទៅហើយ*** *" ដូចនេះ ។*

*ធម៌និងវិន័យ ដែលបានត្រាស់ដល់នោះ ឈ្មោះថា* ***ព្រះធម៌*** *ក្នុងពាក្យថា* ***ធម្មកាយ*** *នេះ ។ ព្រះធម៌នេះ បែកជា ៣ យ៉ាងគឺ ចំណែកដែលទ្រង់*

---

(១) *ទីឃនិកាយ មហាវគ្គ ។*

ហៅថា វិន័យ ក៏ហៅថា ព្រះវិន័យ ចំណែកដែលទ្រង់ហៅថា ព្រះធម៌ បែង បែកជា ២ យ៉ាង គឺព្រះសូត្រ និង ព្រះអភិធម្ម ។ កាយ គឺក្រុមឬកងផ្តុំ នូវធម៌ ៣ យ៉ាងទាំងនេះ ហៅថា **ធម្មកាយ** ។ បុគ្គលរមែងដឹងថា ព្រះពុទ្ធជាម្ចាស់ មានពិតមែន ព្រោះបានឃើញ គឺបានដឹងធម្មកាយ ដែលទ្រង់បានសម្តែង ទុកនេះ ។

ម៉្យាងវិញទៀត ព្រះលោកុត្តរសទ្ធម្ម ៩ យ៉ាង គឺមគ្គ ៤ ផល ៤ និព្វាន ១ ត្រូវជា ១០ រួមទាំងព្រះបរិយត្តិសទ្ធម្ម ឈ្មោះថា **ព្រះធម៌** ។ ព្រះដ៏មានព្រះ ភាគទ្រង់ព្រះនាមថា **ព្រះធម្មកាយ** ព្រោះទ្រង់មានព្រះធម៌ជាព្រះសរីរ-កាយ ។ អ្នកឯណាបានឃើញព្រះធម៌ទាំងនេះ ដោយបញ្ញា អ្នកនោះឈ្មោះ ថា ឃើញព្រះសរីរកាយរបស់ព្រះអង្គ រមែងដឹងបានថា ព្រះអង្គមានពិត មែន ។

សមពិត ដូចបានត្រាស់ទុកថា " **យោ ហិ បស្សតិ សទ្ធម្មំ សោ មំ បស្សតិ បណ្ឌិតោ** [១] អ្នកឯណាឃើញព្រះសទ្ធម្ម ( ធម៌របស់សប្បុរស មាន ១០ យ៉ាង មានមគ្គ ៤ ជាដើម ទាំងនោះ ) អ្នកនោះឈ្មោះថា ជាបណ្ឌិត រមែងមើលឃើញតថាគត " ដូចនេះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១០

# ចប់ពុទ្ធវគ្គទី ៥

ក្នុងវគ្គនេះមាន ១០ បញ្ហា

[១] ខុទ្ទកនិកាយ អបទាន ។

# វគ្គទី ៦ - សតវគ្គ

## បញ្ហាទី ១ - កាយបិយាយនប្បញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន រាងកាយជាទីស្រឡាញ់របស់ពួកបព្វជិតឬ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ រាងកាយពុំមែនជាទីស្រឡាញ់របស់ពួកបព្វជិតទាំងឡាយទេ "

**ព្រះចៅមិលិន្ទ ៖** " បើដូចនេះ ព្រះគុណម្ចាស់ ព្រោះហេតុអ្វីទើបពួកបព្វជិតនៅតែប្រណិប័តន៍រាងកាយ នៅតែស្រឡាញ់រាងកាយនៅឡើយ?"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ អ្នកប្រយុទ្ធដែលទៅសង្គ្រាមរបស់ព្រះអង្គ ជួនកាលអាចត្រូវវាយប្រហារដោយធ្នូក៏មាន មិនមែនទេឬ?"

**ព្រះចៅមិលិន្ទ ៖** " ពិតមែន មាន ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មុខរបួសនោះ គេត្រូវប្រើថ្នាំលាបមុខរបួស ប្រើប្រេងលាប និងប្រើសំពត់សាច់ម៉ដ្ឋរុំរបួស មិនមែនទេឬ?"

**ព្រះចៅមិលិន្ទ ៖** " ពិតមែន ព្រះគុណម្ចាស់ គេត្រូវប្រើថ្នាំលាបមុខរបួស ប្រើប្រេងលាប និងប្រើសំពត់សាច់ម៉ដ្ឋរុំរបួសទុក "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មុខរបួសជាទីស្រឡាញ់របស់គេឬយ៉ាងណា បានជាគេត្រូវប្រើថ្នាំលាបមុខរបួស ប្រើប្រេងលាប និងប្រើសំពត់សាច់ម៉ដ្ឋរុំរបួសទុក?"

**ព្រះចៅមិលិន្ទ ៖** "មុខរបួសជាទីស្រឡាញ់ ពុំមែននោះទេ ព្រះគុណ-ម្ចាស់ ប៉ុន្តែគេត្រូវប្រើថ្នាំលាបមុខរបួស ប្រើប្រេងលាប និងប្រើសំពត់សាច់ម៉ដ្ឋរុំរបួសទុក ដើម្បីជាប្រយោជន៍ដល់ការផ្សះសាច់ (ផ្សះរបួស) "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ រាងកាយពុំមែនជាទីស្រឡាញ់របស់ពួកបព្វជិតទេ ។ ពួកបព្វជិតទាំងឡាយជាអ្នកមិនចុះញ៉ាំមរាងកាយ រមែងគ្រប់គ្រងរាងកាយដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ ។ សូមថ្វាយព្រះពរ ម៉្យាងវិញទៀត ព្រះដ៏មានព្រះភាគត្រាស់ដល់រាងកាយថា មានឧបមាដូចមុខរបួស ។ ព្រោះហេតុនោះ ពួកបព្វជិតទាំងឡាយជាអ្នកមិនចុះញ៉ាំមរាងកាយ រមែងចាត់ចែងរាងកាយដូចព្យាបាលរបួស ។ សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់ភាសិតសេចក្តីប្រការនេះ ទុកថា ៖

**" អល្លចម្មបដិច្ឆន្នោ នវទ្វារោ មហាវណោ**
**សមន្តតោ បគ្ឃរតិ អសុចិបូតិគន្ធិយោ "** [១]

ប្រែថា ៖ " **រាងកាយដែលហុំព័ទ្ធទៅដោយស្បែកស្រស់ មានទ្វារទាំង ៩**
**ជារបួសធំ វត្ថុស្មោកគ្រោក មានក្លិនស្អុយ រមែងហូរចេញពេញទាំងខ្លួន"**

ដូចនេះ។

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់កាយបិយាយនបញ្ហាទី ១

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

ក្នុងសតិវគ្គនេះ មាន ១០ បញ្ហា ។ បញ្ហាទាក់ទងនឹងការប្រព្រឹត្តប្រដូចថា រាងកាយជាទីស្រឡាញ់ ឈ្មោះថា **កាយបិយាយនបញ្ហា** ។

ពាក្យថា **រាងកាយ** ក្នុងទីនេះ គឺ សរីរកាយដែលជាទីប្រជុំនៃមហាភូតរូប ៤ ដែលប្រកបដោយកោដ្ឋាសធំតូចទាំងឡាយ ។

---

[១] វិសុទ្ធិមគ្គ ។

*ពាក្យថា* ***រាងកាយជាទីស្រឡាញ់របស់ពួកបព្វជិតឬ ?*** *បានសេចក្ដីថា ព្រះរាជាមានបន្ទូលសួរថា សរីរកាយជាទីស្រឡាញ់ គឺ ជាទីប្រព្រឹត្តដោយសេចក្ដីស្រឡាញ់របស់ពួកបព្វជិត ឬ? ។*

*ពាក្យថា* ***រាងកាយពុំមែនជាទីស្រឡាញ់របស់ពួកបព្វជិតទាំងឡាយទេ*** *បានសេចក្ដីថា ព្រះថេរៈបដិសេធថា រាងកាយពុំមែនជាទីស្រឡាញ់ គឺ ពុំមែនជាទីប្រព្រឹត្តដោយសេចក្ដីស្រឡាញ់របស់ពួកបព្វជិតទាំងឡាយទេ ។*

*ពាក្យថា* ***បើដូចនេះ*** *គឺ បើរាងកាយមិនបានជាទីស្រឡាញ់របស់ពួកបព្វជិត ។*

*ពាក្យថា* ***ព្រោះហេតុអ្វីទើបពួកបព្វជិតនៅតែប្រណិប័តន៍រាងកាយ នៅតែស្រឡាញ់រាងកាយនៅឡើយ*** *បានសេចក្ដីថា ព្រោះហេតុអ្វីទើបពួកបព្វជិតនៅតែប្រណិប័តន៍រាងកាយ គឺ នៅទំនុកបម្រុងរាងកាយ នៅស្រឡាញ់រាងកាយ គឺ នៅចូលចិត្តរាងកាយ ដោយចាត់ចែង ដោយការស្លៀក ការពាក់ ជាដើម ។*

*ពាក្យថា* ***មិនចុះញ៉ម*** *គឺ ពួកបព្វជិតមិនចុះញ៉ម គឺ មិនជាប់ជំពាក់ក្នុងរាងកាយ ដោយអំណាចនៃតណ្ហា ។ ព្រោះហេតុនោះ ទើបលោកពោលថា ពួកបព្វជិតទាំងឡាយ ទើបចាត់ចែងរាងកាយ ប្រដូចការព្យាបាលរបួស ដូចនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១*

# បញ្ហាទី ២ - សព្វញ្ញុភាវបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់ទ្រង់ជាព្រះសព្វញ្ញូ - អ្នកដឹងនូវអ្វី ៗ គ្រប់យ៉ាង ជាព្រះសព្វទស្សាវី -*

*អ្នកឃើញអ្វី ៗ គ្រប់យ៉ាងឬ?"*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ត្រឹមត្រូវហើយ ព្រះដ៏មានព្រះភាគទ្រង់ជាព្រះសព្វញ្ញូ- អ្នកដឹងនូវអ្វី ៗ គ្រប់យ៉ាង ជាព្រះសព្វទស្សាវី- អ្នកឃើញអ្វី ៗ គ្រប់យ៉ាង "*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់នាគសេន បើដូចនេះ ព្រោះហេតុអ្វីទើបទ្រង់សន្សឹម ៗ បញ្ញត្តសិក្ខាបទចំពោះសាវ័កទាំងឡាយ ទៅតាមលំដាប់ទៅវិញ?"*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ពេទ្យខ្លះស្គាល់ថ្នាំគ្រប់ប្រភេទនៅលើផែនដីនេះ មាន មិនមែនទេឬ?"*

**ព្រះចៅមិលិន្ទ៖** *" ពិតមែន មាន ព្រះគុណម្ចាស់ "*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ ពេទ្យនោះឱ្យអ្នកជំងឺផឹកថ្នាំ ក្នុងពេលដល់គ្រាមានជំងឺ ឬក៏ក្នុងពេលមិនទាន់ដល់គ្រាមានជំងឺ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ពេទ្យនោះរមែងឱ្យអ្នកជំងឺផឹកថ្នាំក្នុងពេលដល់គ្រាមានជំងឺ មិនមែនក្នុងពេលមិនទាន់ដល់គ្រាមានជំងឺទេ "*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ព្រះដ៏មានព្រះភាគ ទ្រង់ជាព្រះសព្វញ្ញូ ជាព្រះសព្វទស្សាវី ទ្រង់មិនបញ្ញត្តសិក្ខាបទ ចំពោះសាវ័កទាំងឡាយ ក្នុងពេលមិនទាន់ដល់គ្រានោះទេ ទ្រង់បញ្ញត្តសិក្ខាបទចំពោះសាវ័កទាំងឡាយ តែក្នុងពេលដល់គ្រាប៉ុណ្ណោះ ជាសិក្ខាបទដែលសាវ័កទាំងឡាយ មិនគួរប្រព្រឹត្តល្មើស រហូតអស់ជីវិត "*

**ព្រះចៅមិលិន្ទ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ "* ៕

*ចប់សព្វញ្ញុភាវប្បញ្ហាទី ២*

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហាមានការសួរដល់ភាពជាព្រះសព្វញ្ញូរបស់ព្រះពុទ្ធជាម្ចាស់ ឈ្មោះថា **សព្វញ្ញុភាវបញ្ហា** ។*

*ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា **ព្រះសព្វញ្ញូ** ព្រោះអត្ថន័យថា ទ្រង់ដឹងនូវអ្វីដែលគួរដឹងគ្រប់យ៉ាង ។ ទ្រង់ព្រះនាមថា **ព្រះសព្វទស្សាវី** ព្រោះទ្រង់មានប្រក្រតីឃើញអ្វី ៗ គ្រប់យ៉ាង ។ ពីរពាក្យនេះមានអត្ថន័យតែមួយបង្ហាញដល់ភាពជាអ្នកមានសព្វញ្ញុតញ្ញាណប៉ុណ្ណោះ ព្រោះហេតុនេះ ទើបជាពាក្យដែលប្រើជំនួសគ្នាបាន ។*

*ពាក្យថា **ព្រោះហេតុអ្វីទើបទ្រង់សន្សឹម ៗ បញ្ញត្តសិក្ខាបទ ចំពោះសាវ័កទាំងឡាយទៅតាមលំដាប់ ?** បានសេចក្តីថា ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីទើបទ្រង់បញ្ញត្តសិក្ខាបទម្តងមួយប្រការ ៗ ពេលមានរឿងកើតឡើងប៉ុណ្ណោះ ដោយមិនបញ្ញត្តទុកជាមុន ដំណាលគ្នាគ្រប់ប្រការ ក្នុងគ្រាតែមួយតែម្តង ? ។*

*ពាក្យថា **ក្នុងពេលមិនទាន់ដល់គ្រា** គឺ ក្នុងពេលនៅមិនទាន់មានរឿងកើតឡើង គឺ ជាការបន្ថយសទ្ធារបស់អ្នកមានសទ្ធា ជាការមិនធ្វើសទ្ធារបស់អ្នកមិនទាន់មានសទ្ធាឱ្យកើតឡើង ឬ ធ្វើឱ្យមានភាពអន់ថយដល់ព្រះសាសនា ។*

*ពាក្យថា **ក្នុងពេលដល់គ្រា** គឺ ក្នុងពេលមានរឿងកើតឡើង ហើយទ្រង់ក៏សម្លឹងឃើញអំណាចប្រយោជន៍ ១០ យ៉ាង មានការព្រមព្រៀងនៃសង្ឃជាដើម ទើបទ្រង់បញ្ញត្តសិក្ខាបទប្រការនីមួយ ៗ នោះឡើង ។*

*ពាក្យថា **ជាសិក្ខាបទដែលសាវ័កទាំងឡាយ មិនគួរប្រព្រឹត្តល្មើស រហូតអស់ជីវិត** អធិប្បាយថា ជាសិក្ខាបទដែលសាវ័កទាំងឡាយ មិនគួរប្រព្រឹត្ត*

*ល្មើស គឺ គួរប្រព្រឹត្តតាម ដែលទ្រង់បានបញ្ញត្តទុកយ៉ាងខ្ជាប់ខ្ជួន រហូតអស់ជីវិត ចាប់តាំងពីបានបញ្ញត្តទុករួចហើយ និងមិនគួរប្រព្រឹត្តល្មើស ទោះជាដើម្បីប្រយោជន៍ចំពោះជីវិតក្តី ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - មហាបុរិសលក្ខណបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់ទ្រង់ជាមនុស្សប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងលម្អដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការ មានពណ៌ព្រះវរកាយដូចមាស មានព្រះឆវីរុងរឿងដូចមាស មានព្រះរស្មីចេញទៅប្រមាណ ១ ព្យាម ពិតមែនឬ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ជាការពិត ព្រះដ៏មានព្រះភាគទ្រង់ ជាមនុស្សប្រកបបរិបូរទៅដោយ ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និង លម្អដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការ មានពណ៌ព្រះវរ-កាយដូចមាស មានព្រះឆវីរុងរឿងដូចមាស មានព្រះរស្មីចេញទៅ ប្រមាណ ១ ព្យាម "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ ក៏ប៉ុន្តែទោះជាព្រះជនកជននីរបស់ព្រះអង្គ ក៏ទ្រង់ជាមនុស្សប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និង លម្អដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការ មានពណ៌ព្រះវរ-កាយដូចមាស មានព្រះឆវីរុងរឿងដូចមាស មានព្រះរស្មីចេញទៅប្រមាណ ១ ព្យាម ឬយ៉ាងណា?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះជនកជននីរបស់ព្រះអង្គ មិនមែនជាមនុស្ស ប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ។ល។ មានព្រះរស្មីចេញទៅ ប្រមាណ ១ ព្យាម ទេ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ បើដូចនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ជាមនុស្ស ប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ។ ល។ មានព្រះរស្មីចេញទៅ ប្រមាណ ១ ព្យាម យ៉ាងដូចម្ដេច ? ព្រោះថា អ្នកដែលជាបុត្ររមែងជាមនុស្សដូចមាតា ឬ កាត់ទៅរកមាតា ជាមនុស្សដូចបិតា ឬកាត់ទៅរកបិតា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ផ្កាឈូកសតបត្ត (ផ្កាឈូកមួយរយស្រទាប់?) មួយប្រភេទ មាន មិនមែនទេឬ?* "

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន មាន ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *ផ្កាឈូកប្រភេទនោះ កើតបាននៅទីណា ?* "

**ព្រះចៅមិលិន្ទ ៖** " *រមែងកើតបានក្នុងភក់ជ្រាំ អាស្រ័យនៅក្នុងទឹក* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ផ្កាឈូកមានពណ៌ក្ដី ក្លិនក្ដី រសក្ដី ដូចគ្នានឹងភក់ជ្រាំ ឬយ៉ាងណា ?* "

**ព្រះចៅមិលិន្ទ ៖** " *ពុំមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *បើដូចនេះ មានពណ៌ក្ដី ក្លិនក្ដី រសក្ដី ដូចគ្នានឹងទឹក ឬ?* "

**ព្រះចៅមិលិន្ទ ៖** " *ពុំមែនទេ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ព្រះដ៏មានព្រះភាគទ្រង់ជាមនុស្សប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ។ ល។ មានព្រះរស្មីចេញទៅ ប្រមាណ ១ ព្យាម ពិតមែន ។ ប៉ុន្តែ ព្រះជនកជននីរបស់ព្រះអង្គ ទ្រង់ពុំមែនជាមនុស្ស*

*ប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ។ ល។ មានព្រះរស្មីចេញទៅ ប្រមាណ ១ ព្យាម នោះទេ "*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់មហាបុរិសលក្ខណបញ្ហាទី ៣*

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

*បញ្ហាមានសំណួរទាក់ទងនឹងលក្ខណៈរបស់បុគ្គល ដែលជាមហាបុរសឈ្មោះថា* ***មហាបុរិសលក្ខណបញ្ហា*** *។*

*ព្រះដ៏មានព្រះភាគទ្រង់បានព្រះនាមថា* ***មហាបុរស*** *ព្រោះអត្ថន័យថា ទ្រង់ជាបុរសខ្ពង់ខ្ពស់ ដោយគុណទាំងឡាយ មានសីល ជាដើម គ្របដណ្តប់លើគុណរបស់សត្វទាំងឡាយទាំងពួង ឬ ព្រោះអត្ថន័យថា ទ្រង់ជាបុរសដែលទេវតា និងមនុស្សទាំងឡាយគោរពបូជា ។*

*លក្ខណៈរបស់បុគ្គល ដែលជាមហាបុរស គឺ ជាការបង្ហាញឱ្យដឹងថាបុគ្គលនេះជាមហាបុរស ឈ្មោះថា* ***មហាបុរិសលក្ខណៈ*** មាន ៣២ ប្រការ *មានបាតព្រះបាទ ដែលឈរជាន់លើផ្ទៃដី បានរាបស្មើល្អគ្រប់ចំណែក ជាដើម ។*

*ប្រការរាយរង ដែលប្រៀបប្រដូចទៅនឹង គ្រឿងលម្អព្រះវរកាយ ចំពោះបុគ្គលដែលជាមហាបុរស ឈ្មោះថា* ***ព្រះអនុព្យញ្ជនៈ*** មាន ៨០ *ប្រការ មានក្រឡាកង់ចក្រនៅបាតព្រះបាទ ជាដើម ។*

*ពាក្យថា* ***មានព្រះឆវីរុងរឿងដូចមាស*** *គឺមានព្រះឆវីចាំងថែងស្រដៀងមាស ។*

*ពាក្យថា **កាត់ទៅរកមាតា** គឺ អ្នកជាបុត្រក៏រមែងមានរូបរាង ពណ៌សម្បុរ សណ្ឋានអវយវៈកាត់ទៅខាងមាតា ។ ទោះជាពាក្យថា **កាត់ទៅរកបិតា** ក៏មានន័យដូចនេះដែរ គឺ ព្រះរាជាត្រាស់សួរថា ពេលព្រះជនកជននី ពុំមែនជាមនុស្សប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ជាដើម ទ្រង់គួរតែដូចនឹងអ្នកដទៃ ដែលមានរូបរាង ពណ៌សម្បុរ សណ្ឋាន អវយវៈដូចមាតា ឬ បិតា ។*

*បានសេចក្ដីថា ភាពជាមនុស្សប្រកបបរិបូរដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ភាពជាមនុស្សលម្អដោយអនុព្យញ្ជនៈ ៨០ ប្រការ ព្រះអង្គទ្រង់បានមកព្រោះហេតុ គឺ ព្រះបារមីដែលទ្រង់បានសន្សំមកល្អហើយ ជាច្រើនក្នុងភពមុន ៗ ដែលជាការប្រព្រឹត្តដ៏កំពូល ពុំមានអ្នកប្រៀបប្រដូចស្មើ ពុំមែនទ្រង់បានមកតាមខ្សែព្រះលោហិតនោះទេ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៣*

# បញ្ហាទី ៤ - ភគវតោ ព្រហ្មចារិបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *" ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់ទ្រង់ជាព្រហ្មចារី (អ្នកប្រព្រឹត្តដូចព្រះព្រហ្ម) ឬ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ពិតមែន ព្រះដ៏មានព្រះភាគទ្រង់ជាព្រហ្មចារី"*

**ព្រះចៅមិលិន្ទ ៖** *" បើដូចនេះ ព្រះគុណម្ចាស់នាគសេន ព្រះពុទ្ធជាម្ចាស់ ក៏ឈ្មោះថា ទ្រង់ជាសិស្សរបស់ព្រះព្រហ្ម"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គទ្រង់មានដំរីព្រះទីនាំងជាប្រធាន មិនមែនទេឬ?"*

**ព្រះចៅមិលិន្ទ ៖** " មាន ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ដំរីនោះ ជួនកាលក៏បន្លឺកោញ្ចនាទ ( បញ្ចេញសំឡេងស្រែកដូចបក្សីក្រៀល ) មិនមែនទេឬ? "

**ព្រះចៅមិលិន្ទ ៖** " ពិតមែន ព្រះគុណម្ចាស់ វាបន្លឺកោញ្ចនាទ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ បើដូចនេះ ដំរីនោះក៏ឈ្មោះថាជាសិស្សរបស់បក្សីក្រៀល "

**ព្រះចៅមិលិន្ទ ៖** " មិនមែនទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ព្រះព្រហ្មជាអ្នកត្រូវមានព្រះពុទ្ធជាម្ចាស់ ឬ ក៏មិនបាច់មានព្រះពុទ្ធជាម្ចាស់? "

**ព្រះចៅមិលិន្ទ ៖** " ជាអ្នកត្រូវមានព្រះពុទ្ធជាម្ចាស់ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ បើដូចនេះ ព្រះព្រហ្មក៏ត្រូវជាសិស្សរបស់ព្រះពុទ្ធជាម្ចាស់ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់ភគវតោ ព្រហ្មចារិប្បញ្ហាទី ៤

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

បញ្ហាទាក់ទងនឹងភាពជាព្រហ្មចារីរបស់ព្រះដ៏មានព្រះភាគ ឈ្មោះថា ភគវតោ ព្រហ្មចារិប្បញ្ហា ។

តាមព្រះមតិរបស់ព្រះចៅមិលិន្ទ ទ្រង់កំណត់ទុកថា ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា **ព្រហ្មចារី** ព្រោះមានអត្ថន័យថា ទ្រង់ប្រព្រឹត្តដូចដែលព្រះ

*ព្រហ្មទ្រង់ប្រព្រឹត្ត ។ ព្រោះដូចនោះ ទើបត្រាស់ថា ព្រះពុទ្ធជាម្ចាស់ទ្រង់ជាសិស្សរបស់ព្រះព្រហ្ម ។*

*ចំណែក តាមមតិរបស់ព្រះថេរៈ ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា ព្រហ្មចារី ព្រោះអត្ថន័យថា ទ្រង់ប្រព្រឹត្តប្រការគួរប្រព្រឹត្ត ដែលជាព្រហ្ម គឺប្រសើរបំផុត ព្រោះពាក្យថា " **ព្រហ្ម** " មានអត្ថន័យថា ប្រសើរបំផុត ក៏បាន ។ ព្រោះហេតុនោះ ទើបបានជាលោកសួរថា " **ព្រះព្រហ្មជា សពុទ្ធិកាៈ - ត្រូវមានព្រះពុទ្ធជាម្ចាស់ ឬក៏ជា អពុទ្ធិកាៈ - មិនបាច់មានព្រះពុទ្ធជាម្ចាស់** " ដូចនេះ ។*

*ក្នុងពាក្យទាំងនោះ ពាក្យថា **សពុទ្ធិកាៈ** ប្រែថា អ្នកត្រូវមានព្រះពុទ្ធជាម្ចាស់ គឺ ដំណើរទៅអាស្រ័យព្រះពុទ្ធជាម្ចាស់ ធ្វើខ្លួនឱ្យដល់សេចក្ដីសុខសេចក្ដីសួស្ដីបាន ដោយអាស្រ័យពាក្យដំបូន្មាន របស់ព្រះពុទ្ធជាម្ចាស់ ។*

*ពាក្យថា **អពុទ្ធិកាៈ** ប្រែថា អ្នកមិនបាច់មានព្រះពុទ្ធជាម្ចាស់ គឺ មិនបានប្រព្រឹត្តទៅ ដោយអាស្រ័យព្រះពុទ្ធជាម្ចាស់ គឺ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធជាម្ចាស់ ក្នុងអត្តភាពចុងក្រោយ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៤*

# បញ្ហាទី ៥ - ភគវតោ ឧបសម្បទាបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា "ព្រះគុណម្ចាស់នាគសេន ការឧបសម្បទាជាប្រការល្អឬ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ពិតមែន មហាបពិត្រ ការបួសជាប្រការល្អ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់ ព្រះពុទ្ធជាម្ចាស់ទ្រង់មានការឧបសម្បទា ឬក៏ទ្រង់មិនមាន ?"*

**ព្រះនាគសេន** ៖ " *សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់បានឧបសម្បទាហើយ នៅគល់ពោធិ៍ព្រឹក្ស ព្រមជាមួយព្រះសព្វញ្ញុតញ្ញាណ ពុំមានអ្នកដទៃថ្វាយការឧបសម្បទា ចំពោះព្រះដ៏មានព្រះភាគ ដូចដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ចំពោះពួកសាវ័កទាំងឡាយ គឺជាសិក្ខាបទ ដែលសាវ័កទាំងឡាយ មិនគួរប្រព្រឹត្តល្មើសរហូតអស់ជីវិត ដូចនេះ"*

**ព្រះចៅមិលិន្ទ** ៖ " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់ភគវតោ ឧបសម្បទាបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាសួរដល់ការឧបសម្បទា របស់ព្រះដ៏មានព្រះភាគ ឈ្មោះថា* ***ភគវតោ ឧបសម្បទាបញ្ហា*** *។*

*ពាក្យថា* ***ឧបសម្បទា*** *- ការឧបសម្បទា សម្រាប់អ្នកជាសាវ័កទាំងឡាយ រមែងបានការឧបសម្បទាដោយប្រការដែលអ្នកផ្សេងឱ្យកាន់សិក្ខា ៣ គឺ ព្រះពុទ្ធជាម្ចាស់ ឬគណៈសង្ឃ ឱ្យកាន់សិក្ខា ៣ ពោលគឺ* **អធិសីលសិក្ខា អធិចិត្តសិក្ខា និង អធិបញ្ញាសិក្ខា** *។*

*រីឯ សម្រាប់ព្រះដ៏មានព្រះភាគ ទ្រង់បានទទួលការឧបសម្បទា ដោយទ្រង់ប្រព្រឹត្តចរិយា ៣ យ៉ាង គឺ* **លោកត្ថចរិយា** *- ប្រព្រឹត្តដើម្បីប្រយោជន៍ចំពោះមនុស្សលើលោក* **ញាតត្ថចរិយា** *- ប្រព្រឹត្តដើម្បីប្រយោជន៍ ចំពោះញាតិ និង* **ពុទ្ធត្ថចរិយា** *- ប្រព្រឹត្តដើម្បីប្រយោជន៍ ចំពោះភាពជាព្រះពុទ្ធ*

*ដែលសម្រេចបានដំណាលគ្នានឹងព្រះសព្វញ្ញុតញ្ញាណ គឺ ភ្លាម ៗ ដែលទ្រង់សម្រេចបានព្រះសព្វញ្ញុតញ្ញាណ ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៥*

# បញ្ហាទី ៦ - អស្សុភេសជ្ជាភេសជ្ជបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន មនុស្សម្នាក់យំពេលមាតាស្លាប់ មនុស្សម្នាក់ទៀតយំដោយក្តីស្រឡាញ់ធម៌ បណ្តាអ្នកដែលយំទាំង ២ នាក់នោះ ទឹកភ្នែករបស់នរណា ចាត់ទុកជាថ្នាំ របស់នរណាមិនចាត់ទុកជាថ្នាំ ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ទឹកភ្នែករបស់មនុស្សម្នាក់មានមន្ទិល ក្តៅព្រោះភ្លើង គឺ រាគៈ ទោសៈ និងមោហៈ ទឹកភ្នែករបស់មនុស្សម្នាក់ទៀតប្រាសចាកមន្ទិល ត្រជាក់ព្រោះបីតិ និងសោមនស្ស សូមថ្វាយព្រះពរ ទឹកភ្នែកដែលត្រជាក់ចាត់ទុកជាថ្នាំ ទឹកភ្នែកដែលក្តៅមិនចាត់ទុកជាថ្នាំទេ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់អស្សុភេសជ្ជាភេសជ្ជបញ្ហាទី ៦*

## ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*បញ្ហាមានការសួរអំពីទឹកភ្នែកដែលជាថ្នាំ និងមិនមែនថ្នាំ ឈ្មោះថា អស្សុភេសជ្ជាភេសជ្ជបញ្ហា ។*

ពាក្យថា ***យំដោយក្ដីស្រឡាញ់ធម៌*** គឺ យំមានទឹកភ្នែកហូរដោយក្ដីស្រឡាញ់ គឺ ដោយបីតិសោមនស្សដ៏មានកម្លាំងកើតឡើង ព្រោះការបានស្ដាប់ធម៌ ឬដឹងដល់ធម៌ ។

ឈ្មោះថា ***ទឹកភ្នែកត្រជាក់*** ព្រោះមិនបានក្ដៅដោយសារភ្លើងមានរាគៈជាដើម ។ ឈ្មោះថា ***ចាត់ទុកជាថ្នាំ*** ព្រោះភាពជាបច្ច័យកម្ចាត់ជំងឺ គឺ កិលេសទាំងឡាយបាន ។

ចប់ពាក្យអធិប្បាយបញ្ហាទី ៦

# បញ្ហាទី ៧ - សរាគវីតរាគនានាករណបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន អ្នកដែលមានរាគៈ និង អ្នកដែលប្រាសចាករាគៈ មានអ្វីជាប្រការខុសប្លែកគ្នា ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ម្នាក់ជាអ្នកចុះញ៉ម ម្នាក់ទៀតជាអ្នកមិនចុះញ៉ម "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ឈ្មោះថា ជាអ្នកចុះញ៉ម ជាអ្នកមិនចុះញ៉មនេះគឺ យ៉ាងដូចម្ដេច ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ គឺថា ម្នាក់មានសេចក្ដីត្រូវការ ម្នាក់ទៀតពុំមានសេចក្ដីត្រូវការទេ "

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាឃើញដូចតែគ្នាគឺ អ្នកមានរាគៈក្ដី អ្នកប្រាសចាករាគៈក្ដី គ្រប់ ៗ គ្នាទាំងនេះ សុទ្ធតែត្រូវការរបស់ល្អ ៗ ដូចគ្នា មិនថា ជារបស់ទំពា ឬរបស់ហូប អ្នកណាក៏មិនត្រូវការរបស់មិនល្អ "

**ព្រះនាគសេន ៖** *"សូមថ្វាយព្រះពរ អ្នកមិនទាន់ប្រាសចាករាគៈ បរិភោគអាហារ ជាអ្នកស្គាល់រសផង ចេះរីករាយក្នុងរសផង ប៉ុន្តែអ្នកដែលប្រាសចាករាគៈបរិភោគអាហារ ជាអ្នកស្គាល់រសតែមុយ៉ាង ពុំមែនជាអ្នកចេះរីករាយក្នុងរសដែរទេ"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់សរាគវីតរាគនានាករណបញ្ហាទី ៧*

# ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*បញ្ហាមានការសួរអំពីប្រការដែលខុសប្លែកគ្នានៃអ្នកមានរាគៈ និងអ្នកប្រាសចាករាគៈ ឈ្មោះថា **សរាគវីតរាគនានាករណបញ្ហា** ។*

*ពាក្យថា **បរិភោគអាហារជាអ្នកស្គាល់រស** គឺ បរិភោគអាហារជាអ្នកស្គាល់រស ដោយ វេទនា គឺ កើតពីជិវ្ហាសម្ផស្សៈ (ការប៉ះផ្លូវអណ្តាត) ។*

*ពាក្យថា **ជាអ្នកចេះរីករាយក្នុងរស** គឺជាអ្នកចេះរីករាយក្នុងរស ដោយរាគៈ ដែលកើតពីការប៉ះជិវ្ហា ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - បញ្ញាបតិដ្ឋានបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា *" ព្រះគុណម្ចាស់នាគសេន បញ្ញារមែងនៅប្រចាំទីកន្លែងណា?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ បញ្ញាពុំបាននៅ*

ប្រចាំទីណាទេ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ បើដូចនេះបញ្ញាក៏គ្មានពិត"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ខ្យល់រមែងនៅប្រចាំទីណា ?"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់ ខ្យល់ពុំបាននៅប្រចាំទីណាទេ"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ បើដូចនេះខ្យល់ក៏គ្មានពិត"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។

ចប់បញ្ញាបតិដ្ឋានបញ្ហាទី ៨

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

បញ្ហាមានការសួរអំពីទីតាំងនៃបញ្ញា ឈ្មោះថា **បញ្ញាបតិដ្ឋានបញ្ហា** ។

ព្រះរាជាទ្រង់សំដៅដល់លទ្ធិដែលថា វត្ថុដែលមាននៅពិត រមែងមានទីនៅប្រចាំ បានជាត្រាស់សួរថា " បញ្ញារមែងនៅប្រចាំទីកន្លែងណា " ដូចនេះ ។

**បញ្ញា** ពេលកើតឡើងរមែងកើតឡើងជាធម៌ ដែលសម្បយុត្តជាមួយចិត្ត កាន់យកអារម្មណ៍តែមួយជាមួយចិត្ត ដល់ខណៈទាំង ៣ គឺ កើតឡើង តាំងនៅ និងរលត់ទៅ ដំណាលគ្នានឹងចិត្ត ។ បញ្ញានោះ ពេលផុតខណៈទាំង ៣ នោះទៅហើយ ក៏ដល់ភាពជារបស់មិនទៀង ពោល គឺ ដល់ភាពរលត់ទៅ បញ្ញាដែលដល់ភាពរលត់ទៅហើយ រមែងមិនកើតទៀត ។

បើបច្ច័យនៃបញ្ញាប្រជុំគ្នាទៀត បញ្ញាផ្សេងរមែងកើតឡើង កើតឡើងហើយក៏ដល់ភាពរលត់ទៅ យ៉ាងនោះទៀត ។ ព្រោះហេតុថា ពេលមាន

*បច្ច័យក៏កើតឡើង ពេលមិនទាន់មានបច្ច័យ ក៏មិនទាន់កើតឡើងយ៉ាងនេះ ទើបព្រះថេរៈពោលថា " បញ្ញាពុំបាននៅប្រចាំទីកន្លែងណាទេ " ដូចនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៨*

# បញ្ហាទី ៩ - សង្សារបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន អ្វីដែលលោកម្ចាស់ហៅថា "សង្សារវដ្ដ" នេះ សង្សារវដ្ដនោះយ៉ាងដូចម្ដេច ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ បុគ្គលកើតក្នុងលោកនេះហើយ ក៏ស្លាប់ក្នុងលោកនេះ លុះស្លាប់ក្នុងលោកនេះហើយ ក៏កើតក្នុងលោកផ្សេង កើតក្នុងលោកនោះហើយ ក៏ស្លាប់ក្នុងលោកនោះ ៗ ឯង លុះស្លាប់ក្នុងលោកនោះហើយ ក៏កើតក្នុងលោកផ្សេងទៀត ។ សូមថ្វាយព្រះពរ សង្សារវដ្ដ គឺ យ៉ាងដូចនេះ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសម្នាក់ទំពាហូបផ្លែស្វាយទុំ រួចបណ្ដុះគ្រាប់ស្វាយនោះទុក បន្ដពីគ្រាប់ស្វាយដែលបណ្ដុះទុកនោះ បានកើតជាដើមស្វាយធំ រួចឱ្យផល ។*

*លំដាប់នោះ បុរសនោះក៏នឹងទំពាហូបផ្លែស្វាយទុំ ពីដើមស្វាយដើមទី ២ នោះ រួចក៏បណ្ដុះគ្រាប់ស្វាយទុក បន្ដពីគ្រាប់ស្វាយដែលបណ្ដុះទុកនោះ បានកើតជាដើមស្វាយធំ រួចក៏ឱ្យផលទៀត ។ បើដូចនេះ ដើមដំបូងបំផុតនៃបណ្ដាដើមស្វាយទាំងនោះ ក៏រមែងមិនបង្ហាញឱ្យឃើញ ។*

*យ៉ាងណាមិញ សូមថ្វាយព្រះពរ បុគ្គលកើតក្នុងលោកនេះហើយ ក៏កើតក្នុងលោកផ្សេង កើតក្នុងលោកនោះហើយ ក៏ស្លាប់ក្នុងលោកនោះ ៗ*

ឯង លុះស្លាប់ក្នុងលោកនោះហើយ ក៏កើតក្នុងលោកផ្សេងទៀត សូមថ្វាយព្រះពរ សង្សារវដ្តរមែងមានតាមប្រការដូចពោលមកនេះ"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕

ចប់សង្សារបញ្ហាទី ៩

## ពាក្យអធិប្បាយបញ្ហាទី ៩ ៖

បញ្ហាទាក់ទងនឹងសង្សារវដ្ត ឈ្មោះថា **សង្សារបញ្ហា** ។

គួរជ្រាបអំពីការប្រៀបធៀបសេចក្តីក្នុងឧបមា និងឧបមេយ្យ ដូចតទៅនេះ ៖

បច្ច័យនៃការកើត គឺ កិលេស និងកម្ម ដែលសត្វសន្សំទុកក្នុងជាតិមុនៗ ប្រៀបដូច គ្រាប់ស្វាយពីដើមស្វាយមុន ៗ ដែលបុរសនោះបណ្តុះទុក នាមរូបដែលសន្មតថា សត្វ បុគ្គល កើតឡើងក្នុងជាតិបន្តៗទៀត ។

ព្រោះកិលេសនិងកម្ម ដែលបានសន្សំទុក ក្នុងជាតិមុនៗនោះ ប្រៀបដូចដើមស្វាយថ្មី ដែលកើតឡើងដោយសារគ្រាប់ស្វាយនៃដើមស្វាយមុនៗ ដែលបុរសនោះបានបណ្តុះទុក សុខនិងទុក្ខ ដែលសត្វបានសោយក្នុងជាតិនោះ ៗ ប្រៀបដូច ផ្លែស្វាយទុំដែលបុរសបានទំពាហូប ដូចនេះ ។

ពាក្យថា **ដើមដំបូងបំផុតរមែងមិនបង្ហាញឱ្យឃើញ** បានសេចក្តីថា ដើមដំបូងបំផុត អ្នកណាក៏មិនអាចដឹងបាន ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៩

# បញ្ហាទី ១០ ចិរកាតសរណាបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា “ព្រះគុណម្ចាស់នាគសេន បុគ្គលរមែងរឭកដល់កិច្ច ដែលកន្លងទៅហើយ ដែលបានធ្វើយូរហើយ បានដោយសារអ្វី?”

**ព្រះនាគសេន៖** “សូមថ្វាយព្រះពរ មហាបពិត្រ គេរមែងរឭកឃើញដោយសារសតិ”

**ព្រះចៅមិលិន្ទ ៖** “ ព្រះគុណម្ចាស់នាគសេន គេរមែងរឭកឃើញដោយចិត្ត មិនមែនទេឬ? មិនមែនដោយសតិទេ”

**ព្រះនាគសេន៖** “ សូមថ្វាយព្រះពរ ព្រះអង្គក៏ទ្រង់ជ្រាបច្បាស់មិនមែនទេឬ ? ថា ព្រះរាជករណីយកិច្ចខ្លះ ដែលព្រះអង្គទ្រង់បានធ្វើ រួចភ្លេចទៅ (រឭកមិនឃើញ) ក៏មាន ?”

**ព្រះចៅមិលិន្ទ៖**“ពិតមែន ខ្ញុំព្រះករុណាជ្រាបច្បាស់ ព្រះគុណម្ចាស់”

**ព្រះនាគសេន៖** “ សូមថ្វាយព្រះពរ ក៏ក្នុងសម័យនោះ ព្រះអង្គទ្រង់ជាមនុស្សគ្មានចិត្ត ឬយ៉ាងណា ?”

**ព្រះចៅមិលិន្ទ៖** “ ពុំមែនដូចនេះទេ ក្នុងសម័យនោះគឺគ្មានសតិទេតើ”

**ព្រះនាគសេន៖** “ សូមថ្វាយព្រះពរ បើដូចនេះ ព្រោះហេតុអ្វីបានជាព្រះអង្គត្រាស់យ៉ាងនេះថា “គេរមែងរឭកឃើញដោយចិត្ត មិនមែនដោយសតិទេ” ដូចនេះទៅវិញ ?”

**ព្រះចៅមិលិន្ទ៖** “ ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ” ។

ចប់ចិរកតសរណបញ្ហាទី ១០

# ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*បញ្ហាទាក់ទងនឹងការរឭកដល់កិច្ច ដែលបានធ្វើយូរហើយ ឈ្មោះថា **ចិរកតសរណបញ្ហា** ។*

*ធម៌ដែលជាការរឭកឃើញ ឬជាហេតុឱ្យសត្វរឭកឃើញ ឈ្មោះថា **សតិ** សតិជាធម៌ ដែលកើតក្នុងចិត្ត រមែងមាន ពេលមានចិត្តក៏ពិតមែន ប៉ុន្តែ នៅពេលណាដែលមានចិត្ត ពេលនោះនឹងមានសតិកើតឡើងជាមួយពិតប្រាកដ គឺពុំមែននោះទេ ។ ចិត្តមាននៅជាប្រចាំចំពោះសត្វគ្រប់វេលាដែលមានជីវិត ប៉ុន្តែសតិពុំបានមានជាប្រចាំគ្រប់វេលាដូចនោះទេ ។*

*ក្នុងវេលាដែលបុគ្គលរឭកឃើញ ក្នុងវេលានោះពោលបានថា មានសតិកើតឡើង ។ ក្នុងវេលាណាដែលរឭកមិនឃើញ ទោះជាមានចិត្តក្នុងវេលានោះ គឺពោលបានថា ពុំមានសតិកើតឡើង។ ហេតុនោះ ទើបពោលបានថា បុគ្គលរមែងរឭកឃើញដោយសតិ មិនមែនដោយចិត្តទេ ។*

*ពាក្យថា **ភ្លេចទៅ** គឺ ភ្លេចភ្លាំងសតិ បានសេចក្តីថា រឭកមិនឃើញ ព្រោះពុំមានសតិកើតឡើង ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១០*

# បញ្ហាទី ១១ - អភិជានន្តសតិបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន សតិលុះកើតឡើងមក ក៏ដឹងភ្លាមទាំងអស់ឬ ? ឬក៏មានតែសតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ប៉ុណ្ណោះ ?* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ សូមថ្វាយព្រះពរ មហាបពិត្រ សតិទោះជាឱ្យដឹងភ្លាមក៏មាន ទោះជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយក៏មាន* "

**ព្រះចៅមិលិន្ទ ៖** *" ជាដូចនេះទេតើ ព្រះគុណម្ចាស់នាគសេន សតិសុទ្ធតែឱ្យដឹងភ្លាមៗ សតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ពុំមានទេ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រសិនបើសតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ពុំមានទេនោះ ពួកសិក្សាការងារសិល្បៈទាំងឡាយ ក៏ពុំមានកិច្ចអ្វីៗ ដែលគួរធ្វើ ដោយជាការងារដែលគួរធ្វើ ដោយជាសិល្បៈដែលគួរធ្វើ ឬដោយជាឋានៈនៃវិជ្ជា ទាំងពួកគ្រូបាអាចារ្យទាំងឡាយ ក៏រមែងជាមនុស្សឥតប្រយោជន៍ ។ សូមថ្វាយព្រះពរ ប៉ុន្តែដោយហេតុថា សតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ក៏មាន ព្រោះហេតុនោះ ទើបមានកិច្ច ដែលគួរធ្វើ ដោយជាការងារដែលគួរធ្វើ ដោយជាសិល្បៈដែលគួរធ្វើ ឬ ដោយជាឋានៈនៃវិជ្ជា និង ប្រយោជន៍ដោយគ្រូបាអាចារ្យទាំងឡាយ ក៏មាន "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់អភិជានន្តសតិបញ្ហាទី ១១*

# ពាក្យអធិប្បាយបញ្ហាទី ១១ ៖

*ពាក្យថា **សតិលុះកើតឡើងមកក៏ដឹងភ្លាម** បានសេចក្តីថា សតិពេលកើតឡើងមកភ្លាម ៗ ក៏ប្រកបជាមួយបញ្ញា ដែលជាការដឹង ។*

*ពាក្យថា **សតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ** បានសេចក្តីថា សតិលុះកើតឡើងមក មិនទាន់អាចដឹងបានភ្លាម គឺ មិនទាន់ប្រកបព្រមនឹងបញ្ញា ។ ប៉ុន្តែ លុះបានធ្វើកិច្ចទាក់ទងនឹងការសិក្សាក្នុងការងារនោះ តាមដែលអ្នកដទៃបានធ្វើទុកជាគំរូ ឬតាមដែលគ្រូបាអាចារ្យបង្រៀន ក៏ជាហេតុ*

ឱ្យកើតបញ្ញាបាននាពេលក្រោយ គឺជាធម្មជាតិ ដែលប្រកបព្រមនឹងបញ្ញា នាពេលក្រោយ ។

ពាក្យថា **ប្រសិនបើសតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ពុំមានទេនោះ ។ល។ ពួកគ្រូបាអាចារ្យទាំងឡាយ ក៏រមែងជាមនុស្សឥតប្រយោជន៍** បានសេចក្តីថា ប្រសិនបើសតិ ជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ពុំមានទេនោះ បើដូចនេះ កិច្ចដែលទាក់ទងនឹងការសិក្សាក្នុងការងារសិល្បៈទាំងឡាយ ក៏រមែងមិនមាន គឺមិនអាចប្រារព្ធបាន ។

ព្រោះការធ្វើកិច្ចទាំងនោះបាន ចាំបាច់ត្រូវអាស្រ័យភាពជាអ្នកមានសតិ ប៉ុន្តែក្នុងពេលនោះ មិនអាចធ្វើសតិឱ្យកើតឡើងបាន ព្រោះសតិសុទ្ធតែត្រូវកើតរួមជាមួយបញ្ញា ដែលក្នុងពេលនោះ មិនទាន់ជាឱកាសរបស់បញ្ញា ព្រោះនៅសិក្សានៅឡើយ មិនទាន់ចប់ការសិក្សា និង ព្រោះហេតុនោះ គ្រូបាអាចារ្យទាំងឡាយ ក៏រមែងជាមនុស្សគ្មានប្រយោជន៍ ពោលគឺ មិនអាចបង្រៀនឱ្យអ្នកដទៃធ្វើកិច្ចទាក់ទងនឹងការសិក្សាបាន ព្រោះសតិរបស់មនុស្សទាំងនោះ មិនកើតឡើង ។

ប៉ុន្តែ តាមការពិត ពួកសិក្សាការងារសិល្បៈទាំងឡាយ ទោះជាមិនទាន់មានបញ្ញា មិនទាន់ដឹងសព្វគ្រប់ក្នុងការងារសិល្បៈនោះក្តី ក៏រមែងធ្វើកិច្ចទាក់ទងនឹងការសិក្សារបស់ខ្លួនបាន ដែលជាការបង្ហាញថា អាចធ្វើសតិឱ្យកើតឡើងបាន ។

ព្រោះហេតុនោះ សតិដែលមិនប្រកបព្រមជាមួយបញ្ញា ជាសតិដើម-ហេតុឱ្យកើតបញ្ញានាពេលក្រោយ ដែលបានធ្វើកិច្ចទាក់ទង នឹងការសិក្សាបរិបូរហើយ ក៏មាន ។

ព្រោះហេតុនោះ ប្រយោជន៍ដោយគ្រូបាអាចារ្យទាំងឡាយ រមែងមានដោយហេតុថា ការពិតជាយ៉ាងនេះ បានជាព្រះថេរៈពោលថ្វាយវិសជ្ជនាថា

*"សូមថ្វាយព្រះពរ ប៉ុន្តែដោយហេតុថា សតិជាហេតុឱ្យដឹងក្រោយពេលធ្វើទៅហើយ ក៏មាន" ដូចនេះជាដើម ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១១*

# ចប់សតវគ្គទី ៦

*ក្នុងវគ្គនេះមាន ១១ បញ្ហា*

# វគ្គទី ៧ - អរូបវបគ្គានវគ្គ

## បញ្ហាទី ១ - សតិឧប្បជ្ជនបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន សតិរមែងកើតឡើងដោយអាការប៉ុន្មាន ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ សតិរមែងកើតឡើងដោយអាការ ១៧ "*

**ព្រះចៅមិលិន្ទ ៖** *" សតិរមែងកើតឡើងដោយអាការ ១៧ អ្វីខ្លះ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ សតិរមែងកើតឡើងព្រោះជាមនុស្សរៀនចេះដឹង, សតិរមែងកើតឡើងព្រោះជាមនុស្សដែលអ្នកដទៃដាស់តឿនឱ្យដឹងនូវអ្វីដែលធ្វើទៅហើយ, សតិរមែងកើតឡើងព្រោះវិញ្ញាណគ្រោតគ្រាត, សតិរមែងកើតឡើងព្រោះវិញ្ញាណអំណោយផល, សតិរមែងកើតឡើងព្រោះវិញ្ញាណមិនអំណោយផល, សតិរមែងកើតឡើងព្រោះនិមិត្តមានចំណែកដូចគ្នា, សតិរមែងកើតឡើងព្រោះនិមិត្តមានចំណែកខុសគ្នា, សតិរមែងកើតឡើងព្រោះការយល់សម្តី, សតិរមែងកើតឡើងព្រោះលក្ខណៈ, សតិរមែងកើតឡើងព្រោះបានអ្នកដទៃប្រាប់ឱ្យរឭក, សតិរមែងកើតឡើងព្រោះមានវិធីកត់ត្រា, សតិរមែងកើតឡើងព្រោះវិធីរាប់, សតិរមែងកើតឡើងព្រោះវិធីចងចាំ, សតិរមែងកើតឡើងព្រោះភាវនា, សតិរមែងកើតឡើងព្រោះពាក្យនិពន្ធក្នុងគម្ពីរ, សតិរមែងកើតឡើងព្រោះការទុកដាក់, សតិរមែងកើតឡើងព្រោះជាអារម្មណ៍ដែលធ្លាប់សោយ ដូចនេះ ។*

*សតិរមែងកើតឡើង ព្រោះជាមនុស្សរៀនចេះដឹងយ៉ាងដូចម្តេច ? សូមថ្វាយព្រះពរ សតិរមែងកើតឡើង ព្រោះជាមនុស្សរៀនចេះដឹង ប្រៀបដូចជា*

*ព្រះអានន្ទ និង នាងខុជ្ជុត្តរាឧបាសិកា ឬ អ្នកដទៃខ្លះ ដែលរឭកជាតិទាំងឡាយបាន រមែងរឭកជាតិបាន ។*

*សតិរមែងកើតឡើង ព្រោះជាមនុស្សដែលអ្នកដទៃដាស់តឿនឱ្យដឹងនូវអ្វី ដែលបានធ្វើទៅហើយយ៉ាងដូចម្តេច ? បុគ្គលរមែងភ្លេចភ្លាំងសតិ លុះអ្នកដទៃដាស់តឿនដើម្បីឱ្យរឭកដល់អ្វី ដែលបានធ្វើទៅហើយនោះ ក៏រមែងរឭកបាន ។ សតិរមែងកើតឡើងព្រោះជាមនុស្ស ដែលអ្នកដទៃដាស់តឿនឱ្យដឹងនូវអ្វី ដែលបានធ្វើទៅហើយ យ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះវិញ្ញាណគ្រោតគ្រាតយ៉ាងដូចម្តេច ? សតិរមែងកើតឡើង ព្រោះវិញ្ញាណគ្រោតគ្រាត ដូចក្នុងគ្រាដែលបុគ្គលបានអភិសេកក្នុងរាជសម្បត្តិ ឬ សម្រេចសោតាបត្តិផល យ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះវិញ្ញាណអំណោយផលយ៉ាងដូចម្តេច ? បុគ្គលជាមនុស្សពោរពេញទៅដោយសេចក្តីសុខនៅទីណា ក៏រមែងរឭកបានថា "**នៅទីនោះ យើងជាមនុស្សពោរពេញទៅដោយសេចក្តីសុខហើយយ៉ាងនេះ**" ដូចនេះ ។ សតិរមែងកើតឡើង ព្រោះវិញ្ញាណអំណោយផល យ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះវិញ្ញាណមិនអំណោយផលយ៉ាងដូចម្តេច ? បុគ្គលជាមនុស្សពោរពេញទៅដោយសេចក្តីទុក្ខនៅទីណា ក៏រមែងរឭកបានថា "**នៅទីនោះ យើងជាមនុស្សពោរពេញទៅដោយសេចក្តីទុក្ខហើយយ៉ាងនេះ**" ដូចនេះ ។ សតិរមែងកើតឡើង ព្រោះវិញ្ញាណមិនអំណោយផលយ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះនិមិត្តមានចំណែកដូចគ្នាយ៉ាងដូចម្តេច ? បុគ្គលឃើញមនុស្សដែលដូចនឹងមាតា(របស់ខ្លួន)ជាដើម ក៏រមែងរឭកដល់មាតា ឬបិតា ឬបងប្អូនប្រុស ឬបងប្អូនស្រី(របស់ខ្លួន) ឃើញអូដ្ឋ ឬគោ ឬពពែ របស់អ្នកដទៃ ដែលដូចគ្នានឹងរបស់ខ្លួននោះ ក៏រមែងរឭកដល់អូដ្ឋ*

ឬគោ ឬពពែ(របស់ខ្លួន) ។ សតិរមែងកើតឡើង ព្រោះនិមិត្តមានចំណែកដូចគ្នា យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះនិមិត្តមានចំណែកខុសគ្នាយ៉ាងដូចម្ដេច ? គឺរមែង រឭកបានថា របស់នោះមានពណ៌ដូចនេះ មានរសដូចនេះ មានផោដ្ឋព្វៈដូចនេះ ។ សតិរមែងកើតឡើង ព្រោះនិមិត្តមានចំណែកខុសគ្នា យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះការយល់សម្ដីយ៉ាងដូចម្ដេច ? អ្នកដែលរមែងភ្លេចភ្លាំងច្រើន លុះបានអ្នកដទៃប្រាប់ឱ្យរឭក ក៏រឭកបានព្រោះសម្ដីនោះ ។ សតិរមែងកើតឡើង ព្រោះការយល់សម្ដី យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះលក្ខណៈយ៉ាងដូចម្ដេច ? ធម្មតា បុគ្គលដែលសម្គាល់គោពលិព័ទ្ទ ទាំងឡាយ បានដោយអវយវៈ ឈ្មោះថាស្គាល់ព្រោះលក្ខណៈ ។ សតិរមែងកើតឡើង ព្រោះលក្ខណៈ យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះបានអ្នកដទៃប្រាប់ឱ្យរឭកយ៉ាងដូចម្ដេច ? អ្នកដែលរមែងភ្លេចភ្លាំង លុះអ្នកដទៃមកប្រាប់ឱ្យរឭកជាញយ ៗ ថា " **ចូររឭកឃើញចុះណ៎ា អ្នកមហាចម្រើន, ចូររឭកឃើញចុះណ៎ា អ្នកមហាចម្រើន**" ដូចនេះ (ក៏រមែងរឭកបាន) សតិរមែងកើតឡើង ព្រោះបានអ្នកដទៃប្រាប់ឱ្យរឭក យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះមានវិធីកត់ត្រា យ៉ាងដូចម្ដេច ? ព្រោះបានសិក្សាវិធីសរសេររួចហើយ ទើបដឹងថា " **អក្សរមួយនេះត្រូវធ្វើ(ត្រូវសរសេរ) បន្ទាប់ពីអក្សរមួយនេះ** " ជាដើម ។ សតិរមែងកើតឡើង ព្រោះមានវិធីកត់-ត្រា យ៉ាងនេះ ។

សតិរមែងកើតឡើង ព្រោះមានវិធីរាប់ យ៉ាងដូចម្ដេច ? ព្រោះបានសិក្សាវិធីរាប់រួចហើយ អ្នករាប់ទើបអាចរាប់ចំនួន ទោះជាច្រើនយ៉ាងណាបាន(មិនខុស) សតិរមែងកើតឡើង ព្រោះមានវិធីរាប់ យ៉ាងនេះ ។

*សតិរមែងកើតឡើង ព្រោះមានវិធីចងចាំ យ៉ាងដូចម្ដេច ? គឺ ព្រោះបានសិក្សាវិធីចងចាំរួចហើយ បុគ្គលអ្នកនឹងចងចាំទុកទើបអាចចាំបានទោះជាច្រើនយ៉ាងណា។ សតិរមែងកើតឡើង ព្រោះមានវិធីចងចាំ យ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះការនាយ៉ាងដូចម្ដេច ? គឺ ភិក្ខុក្នុងសាសនានេះ រមែងតាមរឭកដល់ខន្ធដែលធ្លាប់នៅ ក្នុងភពមុន ៗ បានជាច្រើន គឺរមែងរឭកទៅមួយជាតិខ្លះ ពីរជាតិខ្លះ ។ល។ រមែងតាមរឭកដល់ខន្ធដែលធ្លាប់នៅក្នុងភពមុន ៗ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ សតិរមែងកើតឡើង ព្រោះការនាយ៉ាងនេះ។*

*សតិរមែងកើតឡើង ព្រោះពាក្យនិពន្ធក្នុងគម្ពីរយ៉ាងដូចម្ដេច ? គឺ ពួកព្រះរាជាទាំងឡាយ ពេលនឹងរឭកដល់អនុសាសនី ទើបមានបន្ទូលថា ចូរយកគម្ពីរនេះមក ទ្រង់រឭកដល់អនុសាសនីបាន ព្រោះគម្ពីរនោះ ។ សតិរមែងកើតឡើង ព្រោះពាក្យនិពន្ធក្នុងគម្ពីរ យ៉ាងនេះ។*

*សតិរមែងកើតឡើង ព្រោះការទុកដាក់យ៉ាងដូចម្ដេច ? គឺ លុះឃើញរបស់ដែលបានទុកដាក់ ក៏រមែងរឭកបាន ។ សតិរមែងកើតឡើង ព្រោះការទុក ដាក់ យ៉ាងនេះ ។*

*សតិរមែងកើតឡើង ព្រោះជាអារម្មណ៍ ដែលធ្លាប់សោយយ៉ាងដូចម្ដេច ? គឺ រមែងរឭកដល់រូបបានព្រោះធ្លាប់ឃើញ រមែងរឭកដល់សំឡេងបានព្រោះធ្លាប់ឮ រមែងរឭកដល់ក្លិនបានព្រោះធ្លាប់ធុំក្លិន រមែងរឭកដល់រសបានព្រោះធ្លាប់ភ្លក់ រមែងរឭកដល់ផោដ្ឋព្វៈបានព្រោះធ្លាប់ប៉ះ រមែងរឭកដល់ធម៌បានព្រោះធ្លាប់ដឹង ។ សតិរមែងកើតឡើង ព្រោះជាអារម្មណ៍ ដែលធ្លាប់សោយយ៉ាងនេះ ។*

*សូមថ្វាយព្រះពរ សតិរមែងកើតឡើង ដោយអាការ ១៧ ទាំងនេះ"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

ចប់សតិឧប្បជ្ជនបញ្ហាទី ១

# ពាក្យអធិប្បាយបញ្ហាទី ១ ៖

*ក្នុងវគ្គទី ៧ នេះ មាន ១៦ បញ្ហា ។ បញ្ហាទាក់ទងនឹងការកើតឡើងនៃសតិ ឈ្មោះថា* ***សតិឧប្បជ្ជនបញ្ហា*** *។*

*ពាក្យថា* ***សតិរមែងកើតឡើង ព្រោះជាមនុស្សរៀនចេះដឹង*** *បានសេចក្ដីថា អ្នកដែលរៀនចេះដឹង ជាធម្មតាប្រើសតិរឭកដល់មេរៀនញឹកញាប់ ដើម្បីជាប្រយោជន៍ដល់ការចងចាំបាន ដោយអាស្រ័យទាំងភាពជាមនុស្សអស់កិលេស ឬមានកិលេសតិចទៀតផង សតិនេះរមែងមានកម្លាំង រហូតទាល់តែរឭកជាតិមុនបាន ។*

*ពាក្យថា* ***វិញ្ញាណអំណោយផល*** *គឺ វិញ្ញាណដែលប្រកបដោយសុខវេទនាដ៏ស្ងប់ ដ៏ត្រជាក់ មិនខ្វល់ខ្វាយ មិនមានសេចក្ដីព្យាបាទបៀតបៀន ។ គួរជ្រាប* ***វិញ្ញាណមិនអំណោយផល*** *ដោយប្រការផ្ទុយគ្នា ។*

*ពាក្យថា* ***និមិត្តមានចំណែកដូចគ្នា និមិត្តមានចំណែកខុសគ្នា*** *គឺប្រការដែលដូចគ្នា ប្រការដែលខុសប្លែកគ្នា ។*

*ពាក្យថា* ***រមែងរឭកបានថា របស់នោះមានពណ៌ដូចនេះ ។ល។ មានផោដ្ឋព្វៈដូចនេះ*** *គឺ លុះដឹងហើយថា របស់នោះមានពណ៌ដូចនេះ គឺ ពណ៌បៃតង ។ល។ មានផោដ្ឋព្វៈដូចនេះ គឺ គ្រោតគ្រាត ក៏រមែងរឭកដល់របស់មួយទៀត ដែលមានប្រការខុសប្លែកគ្នាបានថា រីឯរបស់នោះមានពណ៌ដូចនេះ គឺ ពណ៌ក្រហម ។ល។ មានផោដ្ឋព្វៈដូចនេះ គឺ ម៉ដ្ឋល្អិត យ៉ាងនេះ ជាដើម ។*

*ពាក្យថា* ***ព្រោះលក្ខណៈ*** *គឺ ព្រោះលក្ខណៈនៃអវយវៈ ពោលគឺ ផ្នែក*

ផ្សេង ៗ នៃរូបរាងកាយ ។

ពាក្យថា **ព្រោះបានសិក្សាវិធីសរសេររួចហើយ** គឺ ព្រោះបានសិក្សារហូតដឹងវិធីសរសេរពាក្យដែលត្រឹមត្រូវរួចហើយ ពេលនឹងសរសេរសេចក្ដីក៏រមែងរឭកបានថា បើនឹងសរសេរពាក្យនេះ ត្រូវសរសេរអក្សរមួយនេះមុន បន្ទាប់មកត្រូវសរសេរអក្សរមួយនេះ អក្សរមួយនេះត្រូវសរសេរបន្ទាប់ពីអក្សរមួយនេះ យ៉ាងនេះ ជាដើម ។

ពាក្យថា **វិធីរាប់ វិធីចងចាំ** គឺ ឧបាយរាប់ ឧបាយចងចាំ ។

ពាក្យថា **ព្រោះភាវនា** គឺ ព្រោះការចម្រើនបុព្វេនិវាសានុស្សតិញ្ញាណដែលជាញាណប្រព្រឹត្តទៅ ជាមួយសតិដ៏មានកម្លាំង ក្នុងការរឭកជាខ្លាំង ។

ចំណែកក្នុងពាក្យថា **ភិក្ខុក្នុងព្រះសាសនានេះ រមែងតាមរឭកដល់ខន្ធដែលធ្លាប់នៅ ក្នុងភពមុនបានជាច្រើន** ជាដើមនេះ មានសេចក្ដីពេញយ៉ាងនេះគឺ ៖ ភិក្ខុក្នុងព្រះសាសនានេះ រមែងតាមរឭកដល់ខន្ធ ដែលធ្លាប់នៅក្នុងភពមុន ៗ បានជាច្រើន គឺ រមែងរឭកទៅមួយជាតិខ្លះ ពីរជាតិខ្លះ ។ល។ ច្រើនសំវដ្ដកប្បខ្លះ ច្រើនវិវដ្ដកប្បខ្លះ ច្រើនសំវដ្ដវិវដ្ដកប្បខ្លះ ថា "**ក្នុងកាលនោះ យើងមានឈ្មោះយ៉ាងនេះ មានត្រកូលយ៉ាងនេះ មានពណ៌សម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខឬទុក្ខយ៉ាងនេះ មានកម្រិតអាយុយ៉ាងនេះ យើងនោះរំកិល(ស្លាប់)ចេញពីទីនោះ រួចក៏បានកើតឡើងនៅទីឯណោះ ។ នៅទីនោះ យើងមានឈ្មោះយ៉ាងនេះ មានត្រកូលយ៉ាងនេះ មានពណ៌សម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខឬទុក្ខយ៉ាងនេះ យើងនោះរំកិលពីទីនោះហើយ ក៏មកកើតឡើងនៅទីឯណោះ**" ដូចនេះ ភិក្ខុនោះ រមែងតាមរឭកដល់ខន្ធដែលធ្លាប់នៅក្នុងភពមុនៗ បានជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស។

ក្នុងពាក្យទាំងនេះ ពាក្យថា **សំវដ្ដកប្ប** គឺ កប្បដែលកំពុងត្រូវបំផ្លាញ ។ ពាក្យថា **វិវដ្ដកប្ប** គឺ កប្បដែលកំពុងចម្រើន ។ ពាក្យថា **ព្រមទាំងអាការ** គឺ

ព្រមទាំងឈ្មោះ និងត្រកូល ។ ពាក្យថា **ព្រមទាំងឧទ្ទេស** គឺ ព្រមទាំងប្រការផ្សេង ៗ នៃពណ៌សម្បុរ អាហារ សុខ និងទុក្ខ ជាដើម ។

ពាក្យថា **លុះបានឃើញរបស់ដែលទុកដាក់ក៏រមែងរឭកបាន** គឺ លុះឃើញរបស់ដែលបានទុកដាក់ក៏រមែងរឭកបានថា របស់នេះយើងបានមកដោយប្រការយ៉ាងនេះ ជាដើម ព្រមទាំងបុគ្គល ទីកន្លែង ជាដើម ទាក់ទងនឹងរបស់ដែលទុកដាក់នោះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១

# បញ្ហាទី ២ - ពុទ្ធគុណសតិបដិលាភបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ព្រះគុណម្ចាស់ទាំងឡាយ ពោលពាក្យនេះថា " **បុគ្គលឯណាធ្វើតែអកុសលរហូត ១០០ ឆ្នាំ ប៉ុន្តែនាពេលជិតស្លាប់ មានសតិរឭកដល់ព្រះពុទ្ធគុណ បុគ្គលនោះនឹងកើតក្នុងបណ្តាទេវតាទាំងឡាយ** " ខ្ញុំព្រះករុណាមិនជឿពាក្យដែលថា នេះទេ ។ ម្យ៉ាងវិញទៀត សូម្បីពាក្យដែលព្រះគុណម្ចាស់ទាំងឡាយពោលយ៉ាងនេះថា " **បុគ្គលនឹងកើតឡើងនៅនរកបាន ព្រោះបាណាតិបាតដែលបានធ្វើតែមួយដង** " នេះ ខ្ញុំព្រះករុណាក៏មិនជឿដែរ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់យល់សេចក្តីនោះ យ៉ាងដូចម្តេច ដុំថ្មទោះជាដុំតូច ៗ ក្តី លើកលែងការប្រើនាវាចេញ តើអាចអណ្តែតនៅលើទឹកបានឬយ៉ាងណា ? "

**ព្រះចៅមិលិន្ទ ៖** " មិនបានទេ ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ដុំថ្មទោះបីជាចំនួន ១០០ រទេះដែលគេផ្ទុកនៅលើនាវា តើអាចអណ្តែតនៅលើទឹកបានឬទេ ? "

**ព្រះចៅមិលិន្ទ ៖** " បាន ព្រះគុណម្ចាស់ "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ បុគ្គលគួរឃើញកុសលកម្មទាំងឡាយថា ប្រៀបដូចជានាវាផងចុះ* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់ពុទ្ធគុណាបដិលាភបញ្ហាទី ២*

# ពាក្យអធិប្បាយបញ្ហាទី ២ ៖

*បញ្ហាស្ដីអំពីការមានសតិរឭកដល់ព្រះពុទ្ធគុណ ឈ្មោះថា* ***ពុទ្ធគុណ-បដិលាភបញ្ហា*** ។

*គួរជ្រាប ការប្រៀបធៀបដោយឧបមា ដូចតទៅ ៖*

*ប្រៀបដូចជា ដុំថ្មទោះជាដុំតូច ៗ ក្ដី ដាក់នៅផ្ទៃលើទឹក ដោយមិនបានដាក់នៅលើនាវា ពុំមាននាវាទ្រទ្រង់ រមែងមិនអាចអណ្ដែតនៅលើផ្ទៃទឹកបាន រមែងតែលិចចុះទៅក្នុងទឹកតែម្ដង យ៉ាងណា ។ បុគ្គលដែលធ្វើអកុសលកម្ម សូម្បីតែមួយលើកក្ដី នៅវេលាជិតស្លាប់ នៅពេលពុំមានកុសលកើតឡើងមកទ្រទ្រង់ គឺ ការពារទុក រមែងតែលិចចុះទៅ គឺ ធ្លាក់ទៅក្នុងនរកតែម្ដង ដូចនោះ ។*

*ដុំថ្មទោះជាចំនួន ១០០ រទេះ ផ្ទុកនៅលើនាវាធំមួយគ្រឿង រមែងអណ្ដែតនៅលើផ្ទៃទឹកបាន មិនលិចចុះទៅក្នុងទឹកយ៉ាងណា ។ បុគ្គលដែលបានធ្វើអកុសលកម្មច្រើន ប៉ុន្តែ នៅពេលជិតស្លាប់ មានកុសលដ៏អស្ចារ្យមានពុទ្ធានុស្សតិ ជាដើម កើតឡើងមកតែមួយគ្រាប៉ុណ្ណោះ ក៏រមែងឈានឡើងទៅកាន់ឋានសួគ៌បាន មិនធ្លាក់ចុះទៅក្នុងនរក យ៉ាងនោះ ។*

*គួរឃើញសត្វដែលធ្វើអកុសលកម្ម ប្រៀបដូចជាដុំថ្ម គួរឃើញកុសល-កម្ម ប្រៀបដូចជានាវា ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ២*

# បញ្ហាទី ៣ - ទុក្ខប្បហានវាយាមប្បញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន ពួកលោកម្ចាស់ទាំងឡាយ រមែងព្យាយាមដើម្បីលះទុក្ខអតីត ឬយ៉ាងណា?*"

**ព្រះនាគសេន៖** " *មិនមែនទេ មហាបពិត្រ*"

**ព្រះចៅមិលិន្ទ៖** " *បើដូចនេះ រមែងព្យាយាមដើម្បីលះទុក្ខអនាគត ឬព្រះគុណម្ចាស់?*"

**ព្រះនាគសេន៖** " *មិនមែនទេ មហាបពិត្រ*"

**ព្រះចៅមិលិន្ទ៖** " *បើដូចនេះ រមែងព្យាយាមដើម្បីលះទុក្ខបច្ចុប្បន្ន ឬព្រះគុណម្ចាស់?*"

**ព្រះនាគសេន៖** " *មិនមែនទេ មហាបពិត្រ*"

**ព្រះចៅមិលិន្ទ៖** " *ប្រសិនបើ ពួកលោកម្ចាស់មិនបានព្យាយាមដើម្បីលះទុក្ខអតីត មិនបានព្យាយាមដើម្បីលះទុក្ខអនាគត មិនបានព្យាយាមដើម្បីលះទុក្ខបច្ចុប្បន្ន បើដូចនេះ ពួកលោកម្ចាស់នាំគ្នាព្យាយាម ដើម្បីប្រយោជន៍អ្វី?*"

**ព្រះថេរៈ** *ថ្វាយព្រះពរឆ្លើយថា " សូមថ្វាយព្រះពរ ដើម្បីប្រយោជន៍អ្វីទៅឬមហាបពិត្រ? ពួកអាត្មាភាពរមែងព្យាយាមដើម្បីប្រយោជន៍ប្រការនេះ គឺ ទុក្ខនេះរលត់ទៅហើយ ទុក្ខផ្សេងមិនកើតឡើង*"

**ព្រះចៅមិលិន្ទ៖** " *ព្រះគុណម្ចាស់នាគសេន ប៉ុន្តែលោកម្ចាស់នៅមានទុក្ខអនាគតនៅឡើយឬ?*"

**ព្រះនាគសេន៖** " *ពុំមានទេ សូមថ្វាយព្រះពរ*"

**ព្រះចៅមិលិន្ទ៖** " *ព្រះគុណម្ចាស់នាគសេន ពួកលោកម្ចាស់សុទ្ធតែជាអ្នកវៃឆ្លាតហួសបណ្ឌិត ដែលព្យាយាមលះទុក្ខអនាគត ដែលពុំទាន់មាន*"

**ព្រះនាគសេន៖** " *សូមថ្វាយព្រះពរ ព្រះអង្គទ្រង់មានព្រះរាជា*

*បដិបក្ខមួយចំនួន ជាសត្រូវឈ្នានពានឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** " *ពិតមែនហើយ មានសត្រូវ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យជីកគូជុំវិញនគរ ឱ្យសាងកំពែង ឱ្យសាងខ្លោងទ្វារនគរ ឱ្យសាងប៉មការពារ ឱ្យប្រមូលស្រូវអង្ករទុក ក្នុងវេលានោះ (ក្នុងវេលាដែលសត្រូវឈ្នានពាន) ឬ?"*

**ព្រះចៅមិលិន្ទ ៖** " *ពុំមែនទេ ព្រះគុណម្ចាស់ កិច្ចមានការជីកគូជុំវិញនគរទុក ជាដើមនោះ ចាំបាច់ត្រូវត្រៀមការឱ្យស្រេច តាំងពីចម្ងាយតែម្តង"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ពួកព្រះអង្គទ្រង់សិក្សាក្នុងរឿងដំរី ទ្រង់សិក្សាក្នុងរឿងសេះ ទ្រង់សិក្សាក្នុងរឿងរទេះ ទ្រង់សិក្សាក្នុងរឿងធ្នូ ទ្រង់សិក្សាក្នុងរឿងលំពែង ក្នុងវេលានោះឬ?"*

**ព្រះចៅមិលិន្ទ ៖** " *ពុំមែនទេ ព្រះគុណម្ចាស់ កិច្ចមានការសិក្សាក្នុងរឿងដំរី ជាដើមនោះ ចាំបាច់ត្រូវត្រៀមការឱ្យស្រេច តាំងពីចម្ងាយតែម្តង"*

**ព្រះនាគសេន ៖** " *ដើម្បីប្រយោជន៍អ្វីទៅឬ?"*

**ព្រះចៅមិលិន្ទ ៖** " *ដើម្បីប្រយោជន៍ គឺការការពារគ្រោះភ័យអនាគត"*

**ព្រះនាគសេន ៖** "*សូមថ្វាយព្រះពរ គ្រោះភ័យអនាគតកំពុងមានឬ?"*

**ព្រះចៅមិលិន្ទ ៖** " *ពុំទាន់មានទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ពួកព្រះអង្គសុទ្ធតែជាអ្នកវៃឆ្លាតហួសបណ្ឌិត ដែលទ្រង់ត្រៀមការ ដើម្បីការពារគ្រោះភ័យអនាគត ដែលពុំទាន់មាន"*

**ព្រះចៅមិលិន្ទ ៖** "*សូមព្រះគុណម្ចាស់ឧបមាឱ្យកាន់តែច្បាស់ថែមទៀត"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គនឹងទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច ព្រះអង្គទ្រង់ស្រេកទឹកក្នុងវេលាណា ព្រះអង្គក៏ត្រាស់ឱ្យគេជីកអណ្តូងទឹក ឱ្យជីកស្រះ ឱ្យជីកត្រពាំងទឹក ដោយ*

*កំណត់ក្នុងព្រះទ័យថា "**យើងនឹងសោយទឹក**" ក្នុងវេលានោះ ឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ពុំមែនទេ ព្រះគុណម្ចាស់ កិច្ចមានការឱ្យជីកអណ្ដូងទឹក ជាដើមនោះ ចាំបាច់ត្រូវតែត្រៀមការឱ្យហើយស្រេច តាំងពីចម្ងាយតែម្ដង"*

**ព្រះនាគសេន ៖** *" ដើម្បីប្រយោជន៍អ្វីឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ដើម្បីប្រយោជន៍ គឺការការពារការស្រេកទឹកក្នុងពេលអនាគត ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ការស្រេកទឹកក្នុងអនាគតកំពុងមានឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ពុំទាន់មានទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ពួកព្រះអង្គទ្រង់សុទ្ធតែជាអ្នកវៃឆ្លាតហួសបណ្ឌិត ដែលត្រៀមកិច្ចមានការឱ្យជីកអណ្ដូងទឹក ជាដើមនោះ ដើម្បីប្រយោជន៍ គឺ ការពារការស្រេកទឹកក្នុងអនាគត ដែលមិនទាន់មាន"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ឧបមាឱ្យកាន់តែច្បាស់បន្តិចទៀត"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គទ្រង់យល់សេចក្ដីនោះយ៉ាងដូចម្ដេច ព្រះអង្គទ្រង់ឃ្លានអាហារឡើងមកវេលាណា ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ឱ្យភ្ជួរស្រែ ឱ្យព្រោះស្រូវសាលី កំណត់ទុកក្នុងព្រះទ័យថា "**យើងនឹងសោយអាហារ**" ក្នុងវេលានោះឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ពុំមែនទេ ព្រះគុណម្ចាស់ កិច្ចមានការឱ្យភ្ជួរស្រែជាដើមនោះ ចាំបាច់ត្រូវត្រៀមការឱ្យហើយស្រេច តាំងពីចម្ងាយតែម្ដង"*

**ព្រះនាគសេន ៖** *" ដើម្បីប្រយោជន៍អ្វីឬ?"*

**ព្រះចៅមិលិន្ទ ៖** *" ដើម្បីប្រយោជន៍ គឺការពារភាពស្រេកឃ្លានក្នុងអនាគត"*

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ភាពស្រេកឃ្លានក្នុងអនាគតកំពុងមានឬ ?"

**ព្រះចៅមិលិន្ទ ៖** " ពុំទាន់មានទេ ព្រះគុណម្ចាស់"

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ ពួកព្រះអង្គទ្រង់សុទ្ធតែជាអ្នកវៃឆ្លាតហួសបណ្ឌិត ដែលត្រៀមការដើម្បីប្រយោជន៍ គឺការពារភាពស្រេកឃ្លានក្នុងអនាគត ដែលមិនទាន់មាន"

**ព្រះចៅមិលិន្ទ ៖** " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។

ចប់ទុក្ខប្បហានវាយាមបញ្ហាទី ៣

# ពាក្យអធិប្បាយបញ្ហាទី ៣ ៖

បញ្ហាស្ដីអំពីសេចក្ដីព្យាយាមដើម្បីលះទុក្ខ ឈ្មោះថា ***ទុក្ខប្បហានវាយាមបញ្ហា*** ។

នៅពេលព្រះរាជាទ្រង់ត្រាស់សួរថា " ពួកលោកម្ចាស់រមែងព្យាយាមដើម្បីលះទុក្ខអតីតឬ ? " ការដែលព្រះនាគសេនត្រូវថ្វាយព្រះពរឆ្លើយបដិសេធពាក្យត្រាស់របស់ព្រះរាជាថា " **មិនមែនទេ មហាបពិត្រ** " ដូចនេះ ក៏ព្រោះតែទុក្ខអតីតជាឧបាទានក្ខន្ធ ៥ ដែលកន្លងផុតទៅហើយ អស់ទៅហើយ បាត់បង់ទៅហើយ បើដូចនេះ ប្រយោជន៍អ្វីដោយសេចក្ដីព្យាយាម គឺដោយការប្រារព្ធសេចក្ដីព្យាយាមដើម្បីលះនូវអ្វីដែលកន្លងទៅហើយនោះទៀតទៅ ។

ចំណែកឯទុក្ខអនាគត ព្រះថេរៈគួរតែទទួលស្គាល់ថា " ***ពិតមែន មហាបពិត្រ*** " ព្រោះការប្រារព្ធសេចក្ដីព្យាយាមក្នុងពេលបច្ចុប្បន្ន គឺដើម្បីការមិនកើតឡើងនៃទុក្ខដែលនឹងកើតឡើងនាពេលអនាគត ប៉ុន្តែលោកក៏នៅតែបដិសេធថា " **មិនមែនទេ មហាបពិត្រ** " ដូចគ្នានោះដែរ ។

ព្រោះហេតុអ្វីទើបលោកនៅតែបដិសេធ ? ឆ្លើយថា ព្រោះហេតុថា សេចក្តីព្យាយាម ក្នុងពេលបច្ចុប្បន្នដំណើរទៅ ដើម្បីការមិនកើតឡើងនៃទុក្ខ ដែលនឹងកើតឡើងក្នុងអនាគតក៏ពិតមែន ប៉ុន្តែទុក្ខក្នុងអនាគតមិនបានមាន ឱ្យលះក្នុងពេលបច្ចុប្បន្ន ប្រៀបបីដូច ការត្រៀមធ្នូ លំពែង ជន្លួញ ការហ្វឹកហាត់ប្រយុទ្ធ ជាដើម រមែងមានដើម្បីកម្ចាត់សឹកសត្រូវ ដែលអាចមកទន្ទ្រានឈ្លានពានក្នុងពេលអនាគតក៏ពិតមែន ប៉ុន្តែសឹកសត្រូវក៏ពុំទាន់មាន មិនបានបង្ហាញ ឱ្យកម្ចាត់ក្នុងខណៈនោះ ដូចនេះទើបព្រះថេរៈសំដៅដល់សេចក្តីនោះ ទើបពោលបដិសេធ យ៉ាងនេះ ។

នៅពេលមានបន្ទូលសួរតទៅទៀតថា " **បើដូចនេះ រមែងព្យាយាមដើម្បីលះទុក្ខ បច្ចុប្បន្នឬ ?** " ដូចនេះ ព្រះថេរៈនៅតែបដិសេធទៀតថា " **មិនមែនទេ មហាបពិត្រ** " ព្រោះថា ទុក្ខ គឺឧបាទានក្ខន្ធ ៥ ក្នុងបច្ចុប្បន្ននេះ រមែងដល់សេចក្តីវិនាសដោយខ្លួនឯង តាមសភាពរបស់ខ្លួន ដោយមិនបាច់ប្រើសេចក្តីព្យាយាមអ្វី ដើម្បីឱ្យអស់ទៅនោះទេ ។

ក្នុងពាក្យថា **ទុក្ខនេះរលត់ទៅ ហើយទុក្ខផ្សេងមិនកើតឡើង** បានសេចក្តីថា ទុក្ខនេះ គឺ ឧបានទានក្ខន្ធ ៥ ក្នុងភពបច្ចុប្បន្ននេះ រលត់ទៅដោយអំណាចនៃចុតិ ដោយប្រការ ដែលមិនជាបច្ច័យ ចំពោះបដិសន្ធិក្នុងភពខាងមុខ ហើយទុក្ខផ្សេង គឺ ឧបាទានក្ខន្ធ ៥ ដែលនឹងកើតឡើង ក្នុងភពផ្សេងក្នុងអនាគត នឹងមិនកើតឡើងដោយអំណាចនៃមគ្គភាវនា ដែលបានអប់រំសន្សំទុកមកហើយក្នុងភពមុន ៗ ។

ពាក្យអធិប្បាយដែលនៅសល់ក្រៅពីមួយឃ្លានេះ គួរជ្រាបតាមប្រការដូចបានពោលរួចហើយ ក្នុងបញ្ហាមុននេះ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៣

# បញ្ហាទី ៤ - ព្រហ្មលោកបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន ព្រហ្មលោកនៅឆ្ងាយពីទីនេះ ទៅប៉ុនណា ?"*

**ព្រះនាគសេន ៖** *"សូមថ្វាយព្រះពរ មហាបពិត្រ ព្រហ្មលោកនៅឆ្ងាយពីទីនេះ រយៈចម្ងាយដែលដុំថ្មទំហំប៉ុនផ្ទះ ធ្លាក់ពីព្រហ្មលោកនោះ មួយយប់មួយថ្ងៃ អស់រយៈចម្ងាយ ៤៨.០០០ យោជន៍ ធ្លាក់ដល់ដី ប្រើពេល ៤ ខែ*[១] *"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន ពួកលោកម្ចាស់នាំគ្នាពោលយ៉ាងនេះថា " ភិក្ខុដ៏មានឫទ្ធិ ដែលមានចេតោវសី អាចអន្តរធានបាត់ខ្លួននៅជម្ពូទ្វីបនេះ ទៅបង្ហាញខ្លួននៅព្រហ្មលោក រយៈពេលប្រៀបដូចបុរសដ៏មានកម្លាំងសន្ធឹងដៃ ដែលបត់នោះចេញទៅ ឬ បត់ដៃ ដែលកំពុងសន្ធឹងនោះ ចូលមក " ខ្ញុំព្រះករុណាមិនជឿឡើយ ភិក្ខុនឹងទៅអស់រយៈចម្ងាយជាច្រើនរយយោជន៍ដល់ថ្នាក់នោះ បានលឿនរហ័សបែបនេះឬ ?"*

**ព្រះថេរៈ** *ពោលថ្វាយព្រះពរថា " សូមថ្វាយព្រះពរ ជាតិភូមិ(ដែនប្រសូត)របស់ព្រះអង្គនៅទីណា ?"*

**ព្រះចៅមិលិន្ទ ៖** " *មានកោះមួយឈ្មោះថា អលសន្ទ ខ្ញុំព្រះករុណាប្រសូតនៅទីនោះ "*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ កោះអលសន្ទនៅឆ្ងាយពីទីនេះប៉ុន្មាន ?"*

**ព្រះចៅមិលិន្ទ** ៖*"ឆ្ងាយពីទីនេះប្រមាណ ២០០យោជន៍ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** " *ព្រះអង្គទ្រង់ជ្រាប មិនថាអ៊ីចឹងឬ ? ថា ព្រះអង្គទ្រង់រឭកដល់ព្រះរាជករណីយកិច្ច ដែលទ្រង់បានធ្វើនៅឯកោះនោះបាន ?"*

---

[១] *ត្រូវជារយៈចម្ងាយ ៤៨.០០០ យោជន៍ x ៣០ថ្ងៃ x ៤ (ខែ) = ៥.៧៦០.០០០ យោជន៍ ។ តាមអភិ.បរិ.៥ គឺ ៤២.០០០ x ៦(ដាន់) +៥.៥០៨.០០០ = ៥.៧៦០.០០០ យោជន៍ ។*

**ព្រះចៅមិលិន្ទ ៖** " *ពិតមែន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាវឮកបាន* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ព្រះអង្គយាងទៅអស់រយៈចម្ងាយ ២០០ យោជន៍ បានលឿនមែនទែនហ្ន៎!* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់ព្រហ្មលោកប្បញ្ហាទី ៤*

# ពាក្យអធិប្បាយបញ្ហាទី ៤ ៖

*បញ្ហាស្តីអំពីរយៈចម្ងាយទៅកាន់ព្រហ្មលោក ឈ្មោះថា **ព្រហ្មលោកប្បញ្ហា** ។*

*ព្រះរាជាទ្រង់រឭកទៅកាន់កោះអលសន្ទ ដែលនៅឆ្ងាយដល់ទៅ ២០០ យោជន៍ បានលឿនមែនទែន គឺ រឭកទៅដល់បានភ្លាមតាមបំណងយ៉ាងណា ភិក្ខុដ៏មានឫទ្ធិ ធ្វើកាយឱ្យស្រុបទៅតាមអំណាចនៃចិត្ត ទៅកាន់ព្រហ្មលោក ដែលនៅឆ្ងាយប្រមាណប៉ុណ្ណោះ បានភ្លាមតាមបំណង គឺ ដំណាលគ្នានឹងចិត្ត ដែលអធិដ្ឋាន យ៉ាងនោះ ។*

*គួរជ្រាបថា ព្រហ្មលោក ដែលនៅចម្ងាយមានប្រមាណប៉ុណ្ណោះ គឺ ព្រហ្មលោកថ្នាក់បឋមជ្ឈានភូមិ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៤*

# បញ្ហាទី ៥- ទ្វិន្នំលោកុប្បន្នាជំសមកាលប្បញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន បុគ្គលដែលស្លាប់ក្នុងទីក្រុងនេះ ហើយទៅកើតនៅព្រហ្មលោក ជាមួយនឹងបុគ្គលដែល*

*ស្លាប់ក្នុងទីក្រុងនេះ ហើយទៅកើតឡើងនៅកស្មិរនគរ អ្នកណាយូរជាងអ្នកណារហ័សជាង ?"*

**ព្រះនាគសេន ៖** " *ស្មើគ្នា មហាបពិត្រ* "

**ព្រះចៅមិលិន្ទ ៖** " *សូមព្រះគុណម្ចាស់ធ្វើការឧបមា* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ នគរប្រសូតរបស់ព្រះអង្គនៅទីណា ?* "

**ព្រះចៅមិលិន្ទ ៖** " *មានទីកន្លែងមួយឈ្មោះថា កាលសិគ្រាម ខ្ញុំព្រះករុណាប្រសូតនៅទីនោះ* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ កាលសិគ្រាម នៅឆ្ងាយពីទីនេះប៉ុន្មាន ?* "

**ព្រះចៅមិលិន្ទ ៖** " *ប្រមាណ ២០០ យោជន៍ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ កស្មិរនគរនៅឆ្ងាយពីទីនេះប៉ុន្មាន ?* "

**ព្រះចៅមិលិន្ទ ៖** " *ប្រមាណ ១២ យោជន៍ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *ណ្ហើយចុះ មហាបពិត្រ សូមព្រះអង្គទ្រង់នឹកដល់កាលសិគ្រាម ទៅចុះ* "

**ព្រះចៅមិលិន្ទ ៖** " *ខ្ញុំព្រះករុណា នឹកដល់ហើយ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *ណ្ហើយចុះ មហាបពិត្រ សូមព្រះអង្គទ្រង់នឹកដល់កស្មិរនគរ ទៅចុះ* "

**ព្រះចៅមិលិន្ទ ៖** " *ខ្ញុំព្រះករុណា នឹកដល់ហើយ ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ទីណាជាទីដែលព្រះអង្គទ្រង់ប្រើពេលនឹកដល់យូរជាង ទីណានឹកដល់បានលឿនជាង ?* "

**ព្រះចៅមិលិន្ទ ៖** " *ប្រើពេលស្មើគ្នា ព្រះគុណម្ចាស់* "

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏*

*យ៉ាងនោះដែរ បុគ្គលដែលស្លាប់ក្នុងនគរនេះហើយ កើតឡើងក្នុងព្រហ្មលោក និងបុគ្គលដែលស្លាប់ក្នុងនគរនេះហើយ កើតឡើងក្នុងកស្មិរនគរ រមែងកើតឡើង ប្រើពេលស្មើគ្នាតែម្តង"*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ឧបមាឱ្យកាន់តែច្បាស់បន្តិច"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច ចាប ២ ក្បាលហើរនៅលើអាកាស ចំណោមចាប ២ ក្បាលនោះ ចាបមួយហើរទៅទំនៅលើមែកឈើខ្ពស់ ចាបមួយទៀតហើរទៅទំនៅលើមែកឈើទាប បណ្តាចាបទាំង ២ ដែលចុះទំប្រើពេលស្មើគ្នានោះ ស្រមោលរបស់ចាបមួយណា តាំងនៅលើផ្ទៃដីមុន ស្រមោលរបស់ចាបមួយណា ប្រើពេលតាំងនៅលើផ្ទៃដីយូរជាង ?"*

**ព្រះចៅមិលិន្ទ ៖** *" ប្រើពេលស្មើគ្នា ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ បុគ្គលដែលស្លាប់ក្នុងទីក្រុងនេះហើយ ទៅកើតនៅព្រហ្មលោក ជាមួយនឹងបុគ្គលដែលស្លាប់ក្នុងទីក្រុងនេះ ហើយទៅកើតឡើងនៅកស្មិរនគរ រមែងកើតឡើងប្រើពេលស្មើគ្នាតែម្តង"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់ទ្វិន្នំលោកុប្បន្នានំសមកភាវបញ្ហាទី ៥*

# ពាក្យអធិប្បាយបញ្ហាទី ៥ ៖

*បញ្ហាស្តីអំពីការៈ ដែលបុគ្គល ២ នាក់ ប្រើពេលឧប្បត្តិក្នុងលោកស្មើគ្នា ឈ្មោះថា **ទ្វិន្នំលោកុប្បន្នានំសមកភាវបញ្ហា** ។*

*ពាក្យថា **យូរជាង** គឺ យឺតជាង ។*

*ពាក្យថា **លឿនជាង** គឺ រហ័សខ្លាំង ។*

*ពាក្យថា **ស្មើគ្នា** គឺ ប្រើពេលស្មើគ្នា ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៥*

# បញ្ហាទី ៦ - ពោជ្ឈង្គប្បញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ពោជ្ឈង្គៈមានប៉ុន្មាន ? "*

**ព្រះនាគសេនៈ** *"សូមថ្វាយព្រះពរមហាបពិត្រ ពោជ្ឈង្គៈមាន៧យ៉ាង"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ បុគ្គលរមែងត្រាស់ដឹងដោយពោជ្ឈង្គៈប៉ុន្មានយ៉ាង ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ បុគ្គលរមែងត្រាស់ដឹងដោយពោជ្ឈង្គៈតែមួយគឺ ដោយធម្មវិចយសម្ពោជ្ឈង្គៈ "*

**ព្រះចៅមិលិន្ទ ៖** *" បើដូចនេះ ព្រោះហេតុដូចម្តេចទើបពោលថាពោជ្ឈង្គៈមាន ៧ យ៉ាងដូចនេះ ព្រះគុណម្ចាស់ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច ដាវដែលទុកក្នុងស្រោម ដោយមិនបានប្រើដៃទាញចេញមក អាចកាប់ដាច់ឬ ? "*

**ព្រះចៅមិលិន្ទ ៖** *" មិនទេ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ លើកលែងធម្មវិចយសម្ពោជ្ឈង្គៈចេញ បុគ្គលនឹងត្រាស់ដឹងដោយពោជ្ឈង្គៈ ៦ យ៉ាង (ដែលនៅសល់ផ្សេងទៀត) គឺ ពុំមានឡើយ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ។*

*ចប់ពោជ្ឈង្គប្បញ្ហាទី ៦*

# ពាក្យអធិប្បាយបញ្ហាទី ៦ ៖

*បុគ្គលឈ្មោះថា "ពោធិ" ព្រោះអត្ថន័យថា ត្រាស់ដឹង ។ ធម៌ ៧ យ៉ាង មានសតិ ជាដើម ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថន័យថា ជាអង្គ គឺជាសម្ភារៈ ឬជាឧបករណ៍គ្រឿងត្រាស់ដឹងនៃបុគ្គលដែលឈ្មោះថា " ពោធិ " នោះ ។ ពោជ្ឈង្គៈមាន ៧ យ៉ាង គឺ សតិសម្ពោជ្ឈង្គៈ ធម្មវិចយសម្ពោជ្ឈង្គៈ វិរិយ-សម្ពោជ្ឈង្គៈ បីតិសម្ពោជ្ឈង្គៈ បស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និង ឧបេក្ខាសម្ពោជ្ឈង្គៈ ។*

*ដោយនិប្បរិយាយ គឺបញ្ញាប៉ុណ្ណោះ ដែលត្រាស់ដឹងនូវធម៌ទាំងឡាយ ឬ ត្រាស់ដឹងនូវសច្ចៈ ៤ ឬជាហេតុឱ្យបុគ្គលត្រាស់ដឹង ព្រោះហេតុនោះ ទើប ព្រះថេរៈពោលថា " រមែងត្រាស់ដឹង ដោយពោជ្ឈង្គៈតែមួយ គឺ ដោយធម្ម-វិចយសម្ពោជ្ឈង្គៈ" គឺ ធម្មវិចយសម្ពោជ្ឈង្គៈ ជាឈ្មោះរបស់បញ្ញា ។*

*បើដូចនេះ ពោជ្ឈង្គៈគួរតែមានតែមួយ គឺ ធម្មវិចយសម្ពោជ្ឈង្គៈនោះ ប៉ុណ្ណោះ ព្រោះហេតុដូចម្ដេចធម៌ ៦ យ៉ាងផ្សេងទៀត មានសតិជាដើម ទើប បានឈ្មោះថា ជាពោជ្ឈង្គៈដែរ ? ឆ្លើយថា ធម៌ ៦ យ៉ាងផ្សេងទៀត បាន ឈ្មោះថា ជាពោជ្ឈង្គៈ ដោយបរិយាយ ដោយពាក់ព័ន្ធក្នុងឋានៈ ជាអ្នក ឧបត្ថម្ភធម្មវិចយសម្ពោជ្ឈង្គៈនោះ ។*

*ប្រៀបដូចជា ទោះជាដាវនោះដែលប្រើកាប់វត្ថុបានដាច់ល្អ ស្រោមដាវ មិនអាចប្រើកាប់វត្ថុបានដាច់ ក៏ពិតមែនហើយ ប៉ុន្តែប្រសិនបើបុគ្គលមិនទុក ដាវក្នុងស្រោម មិនរក្សាដាវ ទុកក្នុងស្រោមដោយល្អ ដាវនោះមិនបានទទួល ការរក្សាដោយល្អ នឹងកើតមន្ទិល ឡើងច្រែះ ជាដើម នឹងរឹលមុខ អស់ភាព មុត បុគ្គលនឹងមិនអាចប្រើកាប់វត្ថុនោះ ឱ្យដាច់ដោយស្រួល បានយ៉ាង ណា។ ទោះជាបញ្ញាប៉ុណ្ណោះ ដែលព្រះយោគាវចរប្រើកាប់ គឺ ត្រាស់ដឹងនូវ ធម៌ លះកិលេសបានក្ដី ធម៌ ៦ យ៉ាងផ្សេងទៀត មិនអាចប្រើត្រាស់ដឹងនូវធម៌*

*បាន ក៏ពិតមែន ទោះជាយ៉ាងនោះក្តី ប្រសិនបើធម៌ ៦ យ៉ាងផ្សេងទៀតមាន ភាពខុសឆ្គង បញ្ញាមិនបានទទួលការឧបត្ថម្ភដោយល្អពីធម៌ទាំងនោះ រមែង នឹងខ្វះភាពមុត មិនអាចត្រាស់ដឹងធម៌ មិនអាចលះកិលេសទាំងឡាយបាន ដូចនេះដែរ ។ បញ្ញាប្រៀបបាននឹងដាវ ធម៌ ៦ យ៉ាងផ្សេងទៀត ប្រៀបបាន នឹងស្រោមដាវ ព្រោះជាអ្នកឧបត្ថម្ភបញ្ញា ។ ដូចនេះ ធម៌ ៦ យ៉ាងផ្សេង ទៀត ក៏ឈ្មោះថា ពោជ្ឈង្គៈ ដោយបរិយាយនេះ ។*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៦*

# បញ្ហាទី ៧ - ចាបបុញ្ញានំ អប្បាងប្បភាវបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន មួយណាមាន ច្រើនជាងគ្នា បុណ្យឬក៏បាប ?*"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ បុណ្យមានច្រើន ជាង បាបមានបន្តិចបន្តួច* "

**ព្រះចៅមិលិន្ទ ៖** " *ព្រោះហេតុអ្វីឬ ?*"

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ បុគ្គលនៅពេលធ្វើអំពើបាប រមែងជាមនុស្សមានវិប្បដិសារៈថា " យើងបានធ្វើកម្មអាក្រក់មកហ្ន៎ " ព្រោះ ហេតុនោះ ទើបបាបមិនចម្រើន (មិនសាយភាយ) ឡើង ។*

*សូមថ្វាយព្រះពរ នៅពេលបានធ្វើអំពើបុណ្យក៏ពុំមានវិប្បដិសារៈ បុគ្គលពុំមានវិប្បដិសារៈរមែងមានសេចក្តីសប្បាយចិត្ត បុគ្គលសប្បាយចិត្ត រមែងមានភាពរីករាយចិត្ត កាយ(នាមកាយ)របស់បុគ្គលដែលមានចិត្ត រីករាយ រមែងមានភាពស្ងប់រម្ងាប់ល្អ (គឺមានភាពមិនអន្ទះអន្ទែង) បុគ្គលមាន កាយរម្ងាប់ រមែងសោយសុខ ចិត្តរបស់បុគ្គលដែលមានសុខវេទនា រមែង តាំងមាំបានល្អ បុគ្គលមានចិត្តតាំងមាំបានល្អ រមែងដឹងច្បាស់តាមសភាវៈ ពិត ព្រោះហេតុនោះ ទើបបុណ្យចម្រើនបាន ។*

*សូមថ្វាយព្រះពរ បុរសមានដៃនិងជើងកំបុត បានថ្វាយផ្កាឈូកតែមួយបាច់ដល់ព្រះដ៏មានព្រះភាគ នឹងមិនទៅវិនិបាតភូមិរហូត ៩១ កប្ប ។ សូមថ្វាយព្រះពរ អាស្រ័យដោយហេតុនេះ ទើបអាត្មាភាពពោលថា បុណ្យមានច្រើនជាង បាបមានបន្តិចបន្តួច"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់បាបបុញ្ញានំ អប្បនប្បភាវបញ្ហាទី ៧*

## ពាក្យអធិប្បាយបញ្ហាទី ៧ ៖

*បញ្ហាស្តីអំពីបាបមានតិច បុណ្យមានច្រើន ឈ្មោះថា* ***បាបបុញ្ញានំ អប្បនប្បភាវបញ្ហា*** *។*

*ពាក្យថា* ***បុណ្យ*** *គឺ កុសល ។*

*ពាក្យថា* ***បាប*** *គឺ អកុសល ។*

*ពាក្យថា* ***រមែងចម្រើនបាន*** *ដោយពាក់ព័ន្ធនឹងភាពជាបច្ច័យដល់បុណ្យដទៃ ដែលកាន់តែខ្ពស់ថែមទៀត ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៧*

# បញ្ហាទី ៨ - ជានន្តាជានន្តបាបការណបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន បុគ្គលម្នាក់បានដឹងរួចធ្វើកម្មអាក្រក់ បុគ្គលម្នាក់ទៀតមិនបានដឹងរួចធ្វើកម្មអាក្រក់ តើនរណាមានបាបច្រើនជាង ?"*

**ព្រះថេរៈ** *ថ្វាយព្រះពរឆ្លើយថា " សូមថ្វាយព្រះពរ មហាបពិត្រ អ្នក*

*ដែលមិនបានដឹង រួចធ្វើកម្មអាក្រក់ មានបាបច្រើនជាង "*

**ព្រះចៅមិលិន្ទ ៖** *" បើដូចនេះ ព្រះគុណម្ចាស់នាគសេន អ្នកដែលជារាជឱរស ឬជារាជមហាអាមាត្យរបស់ខ្ញុំព្រះករុណា មិនបានដឹងរួចធ្វើកម្មអាក្រក់ ខ្ញុំព្រះករុណាត្រូវដាក់ទោសអ្នកនោះ ទ្វេជាពីរដងហើយអ៊ីចឹង "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីនោះយ៉ាងដូចម្ដេច ដុំដែកដែលត្រូវដុតភ្លើងរហូតឡើងក្រហមឆេះ ម្នាក់បានដឹងរួចចាប់ដែក ម្នាក់ទៀតមិនបានដឹងរួចចាប់ដែក តើនរណាចាប់ណែនជាង ? "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន អ្នកដែលមិនបានដឹងចាប់ណែនជាង "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ បុគ្គលដែលមិនបានដឹង រួចធ្វើកម្មអាក្រក់ រមែងមានបាបច្រើនជាង "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់ជានន្តាជានន្តបាបករណបញ្ហាទី ៨*

# ពាក្យអធិប្បាយបញ្ហាទី ៨ ៖

*បញ្ហាស្ដីអំពីការធ្វើកម្មអាក្រក់ នៃអ្នកបានដឹង និងអ្នកមិនបានដឹង ឈ្មោះថា* ***ជានន្តាជានន្តបាបករណបញ្ហា*** *។*

*ក្នុងការចាប់ដុំដែកក្ដៅរបស់បុគ្គលទាំង ២ អ្នកដែលមិនបានដឹងថា "**នេះជាដុំដែកក្ដៅខ្លាំង** " ដូចនេះ ក៏នឹងចាប់យ៉ាងណែន បាតដៃរបស់គេនឹងរលាក ឡើងពងដៃយ៉ាងណា អ្នកមិនបានដឹងថា " **ការធ្វើបែបនេះជាបាណាតិបាត ជាកម្មអាក្រក់មានផលជាសេចក្ដីទុក្ខ** " ដូចនេះ ជាដើម រមែង*

ធ្វើកម្មអាក្រក់នោះយ៉ាងធ្ងន់ គឺ ចេតនាក្នុងការធ្វើមានកម្លាំង ព្រោះពុំមានភាពខ្លាចក្រែងផលនៃអំពើបាប ។ បើដូចនេះ នឹងរមែងបានសោយទុក្ខដែលជាផល នៃកម្មអាក្រក់នោះដ៏ធ្ងន់ធ្ងរ មានការត្រូវភ្លើងឆេះនៅក្នុងនរកជាដើម ដូចនេះ ។

ចំណែក អ្នកដែលបានដឹងថា " **នេះជាដុំដែកក្តៅខ្លាំង** " ដូចនេះ ទោះជា ចាំបាច់ត្រូវចាប់ដែក ក៏រមែងនឹងចាប់ដោយអាការស្រាល មិនចាប់ណែន ព្រោះខ្លាចរលាកបាតដៃ បាតដៃរបស់គេ ទោះជាក្តៅ ក៏មិនដល់ថ្នាក់រលាកពងដៃយ៉ាងណា ។

អ្នកដែលបានដឹងថា " **ការធ្វើបែបនេះជាបាណាតិបាត ជាកម្មអាក្រក់មានផលជាសេចក្តីទុក្ខ** " ដូចនេះ ជាដើម ទោះជាចាំបាច់ត្រូវធ្វើកម្មអាក្រក់នោះ ព្រោះមិនអាចអត់ទ្រាំកិលេស ដែលកើតឡើងគ្របដណ្តប់ចិត្ត ក្នុងវេលានោះបានក្តី នឹងរមែងធ្វើអំពើបាបយ៉ាងស្រាល មិនធ្ងន់ធ្ងរ គឺចេតនាក្នុងការធ្វើ មិនមានកម្លាំង ដោយបង្ខំចិត្តធ្វើ ព្រោះខ្លាចផលនៃអំពើបាប ។

បើដូចនេះ ទោះជាត្រូវសោយទុក្ខ ដែលជាផលនៃកម្មអាក្រក់នោះ ក៏មិនធ្ងន់ធ្ងរ ទោះជាត្រូវធ្លាក់នរកអបាយភូមិ ព្រោះកម្មអាក្រក់ ដែលបានធ្វើនោះ ក៏ក្នុងរយៈពេលដ៏ខ្លី មិនយូរប៉ុន្មាននឹងរួចផុតពីនរក ដូចនេះដែរ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ៨

# បញ្ហាទី ៩ - ឧត្តរកុរុកាទិគមនបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន បុគ្គលខ្លះទៅឧត្តរកុរុទ្វីប ឬព្រហ្មលោក ឬទ្វីបផ្សេងបានដោយសរីរៈនេះ (រាងកាយនេះ) តើមានដែរឬទេ ? "

**ព្រះនាគសេន ៖** " សូមថ្វាយព្រះពរ មហាបពិត្រ បុគ្គលដែលទៅឧត្តរ-

*កុរុទ្វីប ឬព្រហ្មលោក ឬទ្វីបផ្សេង ដោយកាយដែលប្រកបដោយមហាភូតរូប ៤ នេះ គឺមាន"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ គេទៅឧត្តរកុរុទ្វីប ឬព្រហ្មលោក ឬទ្វីបផ្សេង ដោយកាយដែលប្រកបដោយមហាភូតរូប៤នេះ បានយ៉ាងដូចម្តេច ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គទ្រង់ជ្រាបទេថា ព្រះអង្គក៏ទ្រង់លោតនៅលើផ្ទៃដីនេះ ខ្ពស់ឡើងមួយចំអាមក៏បាន មួយហត្ថក៏បាន"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាជ្រាបច្បាស់ ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាលោតបានខ្ពស់ដល់ទៅ ៨ ហត្ថឯណោះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គលោតបានខ្ពស់ដល់ទៅ ៨ ហត្ថ យ៉ាងដូចម្តេច ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់ លុះខ្ញុំព្រះករុណាកើតមានគំនិតថា "**យើងនឹងលោតនៅទីនេះ** " ដូចនេះ រាងកាយរបស់ខ្ញុំព្រះករុណា ក៏ស្រាលភ្លាម ស្របគ្នានឹងគំនិតដែលកើតឡើង"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ឧបមាយ៉ាងណា ឧបមេយ្យក៏យ៉ាងនោះដែរ ភិក្ខុដ៏មានឫទ្ធិដែលមានចេតោវសី ( មានភាពជំនាញក្នុងសមាធិចិត្ត ) រមែងលើកកាយចូលទុកក្នុងចិត្ត ហើយទៅកាន់វេហា ដោយអំណាចនៃចិត្ត"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ។*

*ចប់ឧត្តរកុរុកាទិគមនបញ្ហាទី ៩*

## ពាក្យអធិប្បាយបញ្ហាទី ៩ ៖

*បញ្ហាស្តីអំពីការទៅកាន់ឧត្តរកុរុទ្វីបជាដើម ឈ្មោះថា **ឧត្តរកុរុកាទិគមនបញ្ហា** ។*

*ពាក្យថា **រមែងលើកកាយចូលទុកក្នុងចិត្ត** គឺ ធ្វើសរីរកាយឱ្យសម្រេចទៅតាមអំណាចចិត្ត ដែលអធិដ្ឋាន ព្រោះហេតុនោះ ទើបកាយជាធម្មជាតិ ដែលស្រាល អាចទៅបានលឿន ដូចចិត្តប៉ងប្រាថ្នា ។*

*ពាក្យថា **ដោយអំណាចនៃចិត្ត** គឺ ដោយអំណាចនៃអភិញ្ញាចិត្ត ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ៩*

# បញ្ហាទី ១០ - ទីឃដ្ឋិបញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ព្រះគុណម្ចាស់ទាំងឡាយនាំគ្នាពោលយ៉ាងនេះ ថា " គ្រោងឆ្អឹង សូម្បីមានប្រវែងដល់ទៅ ១០០ យោជន៍ ក៏មាន " សូម្បីដើមឈើមានកម្ពស់ដល់ទៅ ១០០ យោជន៍ មិនទាន់មានផង គ្រោងឆ្អឹងដែលមានប្រវែងដល់ទៅ ១០០ យោជន៍ នឹងមានមកពីណា ?"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់យល់សេចក្តីនោះយ៉ាងដូចម្តេច ព្រះអង្គទ្រង់បានស្តាប់មកខ្លះឬទេថា ក្នុងមហាសមុទ្រ ត្រីសូម្បីមានប្រវែងដល់ទៅ ៥០០ យោជន៍ ក៏មាន ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាធ្លាប់ឮសួរ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ត្រីដែលមានដងខ្លួនប្រវែងដល់ទៅ ៥០០ យោជន៍ក៏នៅមាន គ្រោងឆ្អឹងសូម្បីមានប្រវែងត្រឹមតែ ១០០ យោជន៍ ក៏មានដែរ មិនថាអ៊ីចឹងឬ ?"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ* " ៕

*ចប់ទីឃដ្ឋិបញ្ហាទី ១០*

## ពាក្យអធិប្បាយបញ្ហាទី ១០ ៖

*បញ្ហាមានការសួរដល់គ្រោងឆ្អឹងដ៏វែង ឈ្មោះថា* ***ទីឃដ្ឋិបញ្ហា*** *។*

*ពាក្យថា* ***យោជន៍*** *ឈ្មោះថា "យោជន៍" មានការរាប់យ៉ាងនេះ គឺ ២ វិទត្ថិ (២ ចំអាម) ស្មើនឹង ១ រតនៈ(១ ហត្ថ), ៧ រតនៈ ស្មើនឹង ១ យដ្ឋិ, ២០ យដ្ឋិ ស្មើនឹង ១ ឧសភៈ, ២០ ឧសភៈ ស្មើនឹង ១ គោសៈ, ៤ គោសៈ ស្មើនឹង ១ គាវុត, ៤ គាវុត ស្មើនឹង ១ យោជន៍ ដូចនេះ ។*

*ពាក្យថា* ***ត្រីដែលមានប្រវែងដល់ទៅ ៥០០ យោជន៍*** *គឺ ត្រីដែលមានឈ្មោះថា តិមិតិមិង្គលៈ នៅក្នុងមហាសមុទ្រ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១០*

# បញ្ហាទី ១១ - អស្សាសបស្សាសនិរោធបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន ព្រះគុណម្ចាស់ទាំងឡាយនាំគ្នាពោលយ៉ាងនេះថា* " ***បុគ្គលអាចរំលត់ខ្យល់អស្សាសៈនិងបស្សាសៈបាន*** " *ពិតមែនឬ?* "

**ព្រះនាគសេន ៖** " *ពិតមែន មហាបពិត្រ បុគ្គលអាចរំលត់ខ្យល់អស្សាសៈនិងបស្សាសៈបាន* "

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន បុគ្គលអាចរំលត់ខ្យល់អស្សាសៈ និងបស្សាសៈបានយ៉ាងដូចម្តេច?* "

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះអង្គនឹងទ្រង់យល់សេចក្ដីនោះយ៉ាងដូចម្ដេច ព្រះអង្គទ្រង់ធ្លាប់ឮដែរឬទេថា អ្នកខ្លះគេងស្រមុក ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន ព្រះគុណម្ចាស់ ខ្ញុំព្រះករុណាធ្លាប់ឮ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ នៅពេលគេផ្អៀងកាយ សំឡេងស្រមុកនោះនឹងរម្ងាប់ទៅ មែនឬទេ ?"*

**ព្រះចៅមិលិន្ទ ៖** *" ពិតមែន នឹងរម្ងាប់ទៅ ព្រះគុណម្ចាស់ "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ចំពោះអ្នកដែលមិនទាន់បានអប់រំកាយ មិនបានអប់រំសីល មិនបានអប់រំចិត្ត មិនបានអប់រំបញ្ញា នៅពេលគ្រាន់តែផ្អៀងកាយ សំឡេងស្រមុកនៅអាចរម្ងាប់ទៅបាន បើដូចនេះ នឹងនិយាយអ្វីចំពោះភិក្ខុ ដែលបានអប់រំកាយហើយ បានអប់រំសីលហើយ បានអប់រំចិត្តហើយ បានអប់រំបញ្ញាហើយ កំពុងចូលនៅក្នុងឈានទី ៤ ថា ខ្យល់អស្សាសៈ និងបស្សាសៈ នឹងមិនរលត់ទៅបាននោះ ?"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕*

*ចប់អស្សាសបស្សាសបញ្ហាទី ១១*

# ពាក្យអធិប្បាយបញ្ហាទី ១១ ៖

*ក្នុងព្រះវិន័យ ឈ្មោះថា **ខ្យល់អស្សាសៈ** គឺខ្យល់ដកដង្ហើមចេញ ឈ្មោះថា **ខ្យល់បស្សាសៈ** គឺខ្យល់ដកដង្ហើមចូល ។ ចំណែកក្នុងព្រះសូត្រ ឈ្មោះថា **ខ្យល់អស្សាសៈ** គឺខ្យល់ដកដង្ហើមចូល ឈ្មោះថា **ខ្យល់បស្សាសៈ** គឺខ្យល់ដកដង្ហើមចេញ ។ គួរប្រកាន់យកតាមព្រះសូត្រ ព្រោះជារឿងទាក់ទងនឹងការប្រតិបត្តិកម្មដ្ឋាន ។*

*ពាក្យថា **អប់រំកាយ** គឺ មានខន្តីអត់ធ្មត់ ចំពោះសុខវេទនា និង ទុក្ខវេទនាដែលកើតឡើងក្នុងកាយ ។*

*ពាក្យថា **អប់រំសីល** គឺ ចម្រើនសីលបរិសុទ្ធ ៤ យ៉ាង មានបាដិមោក្ខ-សំវរសីល ជាដើម ។*

*ពាក្យថា **អប់រំចិត្ត** គឺចម្រើនសមាធិ ខុសគ្នាដោយឧបចារៈ និងអប្បនា។*

*ពាក្យថា **អប់រំបញ្ញា** គឺ ចម្រើនវិបស្សនាបញ្ញា និងមគ្គបញ្ញា ។ បុថុជ្ជន ទោះជាពួកអន្យតិរ្ថិយក្រៅសាសនា គ្រាន់តែជាអ្នកបានឈាន ៤ ហើយចូល ចតុត្ថជ្ឈាន (ឈានទី ៤) ប៉ុណ្ណោះ ខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ រមែងរលត់ទៅបានពិតមែន ។ ប៉ុន្តែព្រះថេរៈ មានបំណងនឹងពោលដល់ ភាពរលត់ទៅតាមលំដាប់នៃសង្ខារ ៣ គឺ កាយសង្ខារ វចីសង្ខារ និង ចិត្ត សង្ខារ នៃភិក្ខុដែលចូលនិរោធសមាបត្តិ ទើបពោលថា " ចំពោះភិក្ខុដែល បានអប់រំកាយហើយ បានអប់រំសីលហើយ " ដូចនេះ ជាដើម ។*

*ជាការពិតថា ភិក្ខុចូលនិរោធសមាបត្តិ រមែងអាស្រ័យកម្លាំង ២ យ៉ាង ដើម្បីធ្វើចិត្តឱ្យដល់ភាពរលត់ទៅ គឺ កម្លាំងសមថៈ ដោយការចូលលោកិយ ឈានទៅតាមលំដាប់ ចាប់តាំងពីបឋមជ្ឈាន(ឈានទី១)ទៅ រហូតដល់នេវ-សញ្ញានាសញ្ញាយតនជ្ឈាន និងកម្លាំងវិបស្សនា ដោយការចេញពីឈាន នីមួយ ៗ ដែលចូលនោះ រួចក៏ពិចារណាត្រៃលក្ខណ៍ ធ្វើសង្ខារ ៣ ឱ្យរលត់ ទៅតាមលំដាប់យ៉ាងនេះគឺ នៅពេលចូលឈានទៅតាមលំដាប់រហូតដល់ ទុតិយជ្ឈាន (ឈានទី២) ដែលពុំមានវិតក្កនិងវិចារ វចីសង្ខារគឺវិតក្កនិងវិចារ ក៏រមែងរលត់ទៅ នៅពេលដល់ចតុត្ថជ្ឈាន(ឈានទី ៤) ឈានចិត្តនោះជា ធម្មជាតិដែលស្ងប់ជាខ្លាំង រហូតមិនអាចជាសមុដ្ឋាននៃខ្យល់ដកដង្ហើមបាន កាយសង្ខារគឺខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ ក៏រមែងនឹងរម្ងាប់រលត់ ទៅ ។ នៅពេលដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញា-យតនចិត្ត ដំណើរទៅ ២ ខណៈ រលត់ទៅហើយ ចិត្តសង្ខារ គឺ សញ្ញានិង វេទនា ឬ សូម្បីតែនាមធម៌ទាំងអស់ រមែងរម្ងាប់រលត់ទៅ ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១១*

# បញ្ហាទី ១២ - សមុទ្ទបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ហៅទឹកថា សមុទ្រ សមុទ្រ ព្រោះហេតុអ្វីទើបហៅទឹកថា សមុទ្រ ?"

**ព្រះថេរៈ** ថ្វាយព្រះពរវិសជ្ជនាថា " សូមថ្វាយព្រះពរ មហាបពិត្រ ក្នុងទីមានទឹក ក៏ជាទីដែលមានភាពប្រៃ ក្នុងទីមានភាពប្រៃ ក៏ជាទីដែលមានទឹក ព្រោះហេតុនោះ ទើបហៅថា សមុទ្រ "

**ព្រះចៅមិលិន្ទ** ៖ " ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ " ៕

ចប់សមុទ្ទបញ្ហាទី ១២

## ពាក្យអធិប្បាយបញ្ហាទី ១២ ៖

បញ្ហាស្ដីអំពីសមុទ្រ ឈ្មោះថា **សមុទ្ទបញ្ហា** ។

ពាក្យថា **ព្រោះហេតុអ្វីទើបហៅទឹកថា សមុទ្រ** គឺ ព្រោះហេតុដូចម្ដេចទើបហៅទីដែលមានទឹកថា សមុទ្រ ។

បានសេចក្ដីថា គ្រាន់តែថាជាទីដែលមានទឹកប៉ុណ្ណោះ មិនអាចហៅថាសមុទ្រទេ ឬ គ្រាន់តែថា ជាទីដែលមានភាពប្រៃប៉ុណ្ណោះ ក៏មិនអាចហៅថា សមុទ្រ បានដែរ គឺហៅថា សមុទ្រ ក៏ព្រោះថា ជាទីដែលមានទាំងទឹកទាំងភាពប្រៃ ៕

ចប់ពាក្យអធិប្បាយបញ្ហាទី ១២

# បញ្ហាទី ១៣ - សមុទ្ទឯករសបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន ព្រោះហេតុដូចម្តេច ទើបសមុទ្រមានរសតែមួយ គឺ រសប្រៃ?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ មហាបពិត្រ សមុទ្រមានរសតែមួយ គឺ រសប្រៃ ព្រោះការដែលទឹកតាំងនៅជាយូរយារមកហើយ"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់សមុទ្ទឯករសបញ្ហាទី ១៣*

## ពាក្យអធិប្បាយបញ្ហាទី ១៣ ៖

*បញ្ហាពោលដល់ភាពមានរសតែមួយនៃសមុទ្រ ឈ្មោះថា **សមុទ្ទឯករសបញ្ហា** ។*

*ពាក្យថា **ព្រោះការដែលទឹកតាំងនៅជាយូរយារមកហើយ** គឺ ព្រោះការដែលទឹកក្នុងទីនោះតាំងនៅជាយូរយារ គឺ ដក់នៅជាយូរយារ មិនអាចដឹងបានថា ចាប់ផ្តើមដក់នៅតាំងពីពេលណា ការដក់នៅជាយូរយារដល់ថ្នាក់នោះ ជាហេតុឱ្យមានរសប្រៃ ដូចនេះ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៣*

# បញ្ហាទី ១៤ - សុខុមបញ្ហា

**ព្រះរាជា** មានបន្ទូលសួរថា " *ព្រះគុណម្ចាស់នាគសេន បុគ្គលអាចកាត់ផ្តាច់នូវអ្វី ដែលមានភាពសុខុមជាង(ប្រការផ្សេង)គ្រប់យ៉ាងបានឬទេ?"*

**ព្រះនាគសេន ៖** " *បាន មហាបពិត្រ បុគ្គលអាចកាត់ផ្តាច់នូវអ្វី ដែលមានភាពសុខុមជាង គ្រប់យ៉ាងបាន"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់ គឺអ្វីទៅឈ្មោះថា ជាអ្វី ដែលមានភាពសុខុមជាងគ្រប់យ៉ាង?"*

**ព្រះនាគសេន ៖** " *សូមថ្វាយព្រះពរ គឺ ធម៌ ឈ្មោះថា ជាអ្វីដែលមានភាពសុខុម ជាងគ្រប់យ៉ាង ។ សូមថ្វាយព្រះពរ ធម៌ទាំងឡាយគឺ មិនមែនមានភាពសុខុមទាំងអស់ គ្រប់យ៉ាងទេ ។ ពាក្យថា "សុខុម" ក្តី ពាក្យថា "គ្រើម" ក្តី ជាពាក្យពោលដល់ធម៌ទាំងឡាយ អ្វីណាមួយជាប្រការដែលអាចកាត់ផ្តាច់បាន បុគ្គលរមែងកាត់ផ្តាច់នូវអ្វីប្រការនោះទាំងអស់បាន ដោយបញ្ញា ពុំមានអ្វី ដែលត្រូវកាត់ផ្តាច់ដោយបញ្ញា ជាប្រការទី ២ ឡើយ"*

**ព្រះចៅមិលិន្ទ ៖** " *ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៕*

*ចប់សុខុមប្បញ្ហាទី ១៤*

## ពាក្យអធិប្បាយបញ្ហាទី ១៤ ៖

*បញ្ហាស្តីអំពីភាពសុខុម ឈ្មោះថា* ***សុខុមប្បញ្ហា*** *។*

*ពាក្យថា* ***ពុំមានអ្វី ដែលត្រូវកាត់ផ្តាច់ជាប្រការទី ២*** *គឺ ពុំមានអ្វីណាដែលបញ្ញាត្រូវកាត់ផ្តាច់ជាប្រការទី ២ គឺផ្សេងទៀត ក្រៅពីធម៌ទាំងពួង ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៤*

# បញ្ហាទី ១៥ - វិញ្ញាណនានត្ថប្បញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន របស់ដែលហៅថា "វិញ្ញាណ"ក្តី ថា"បញ្ញា"ក្តី ថា"ជីវៈក្នុងភូត"ក្តី ធម៌ទាំងនេះ មានអត្ថ-*

*ន័យផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ឬក៏ថាមានអត្ថន័យតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ មហាបពិត្រ វិញ្ញាណមានការដឹងផ្សេង ៗ ជាលក្ខណៈ បញ្ញាមានការដឹងដោយប្រការទាំងឡាយ ជាលក្ខណៈ ជីវៈក្នុងកូតពុំមានទេ"*

**ព្រះចៅមិលិន្ទ ៖** *" ប្រសិនបើជីវៈពុំមានទេ បើដូចនេះ អ្នកណាជាអ្នកឃើញរូបដោយភ្នែក បានឮសូរសំឡេងដោយត្រចៀក ហិតក្លិនដោយច្រមុះ ភ្លក់រសដោយអណ្តាត ពាល់ផោដ្ឋព្វៈដោយកាយ ដឹងធម៌ដោយចិត្ត?"*

**ព្រះថេរៈ** *ថ្វាយវិសជ្ជនាថា" សូមថ្វាយព្រះពរ ប្រសិនបើជីវៈឃើញរូបដោយភ្នែក ។ល។ ដឹងធម៌ដោយចិត្តនោះ នៅពេលភ្នែកទាំងពីរត្រូវខ្វេះចេញទៅ ជីវៈនោះក៏អើតមុខ ចេញទៅក្រៅខាងអាកាសដ៏ល្វឹងល្វើយ សម្លឹងមើលរូបបានច្បាស់ ។ នៅពេលត្រចៀកទាំង ២ ត្រូវទម្លុះ ពេលច្រមុះត្រូវទម្លុះ ពេលអណ្តាតត្រូវកន្ត្រាក់យកចេញ ពេលកាយត្រូវបំផ្លាញ នឹងអើតមុខទៅខាងអាកាសដ៏ល្វឹងល្វើយ ស្តាប់សំឡេង ហិតក្លិន ភ្លក់រស ពាល់ផោដ្ឋព្វៈបានច្បាស់ ឬយ៉ាងណា?"*

**ព្រះចៅមិលិន្ទ ៖** *" មិនមែនទេ ព្រះគុណម្ចាស់"*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ បើដូចនេះ ជីវៈក្នុងកូតក៏គ្មាន"*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន លោកម្ចាស់ឆ្លើយសមគួរហើយ" ៗ*

*ចប់វិញ្ញាណនានត្តបញ្ហាទី ១៤*

# ពាក្យអធិប្បាយបញ្ហាទី ១៥ ៖

*បញ្ហាស្តីអំពីភាពផ្សេងគ្នា នៃធម៌ទាំងឡាយ មានវិញ្ញាណ ជាដើម ឈ្មោះថា* ***វិញ្ញាណនានត្តបញ្ហា*** *។*

*ពាក្យថា* ***មានអត្ថន័យផ្សេងគ្នា*** *គឺ មានសភាវៈផ្សេងគ្នា ។*

*ពាក្យថា* ***ជីវៈក្នុងភូតពុំមានទេ*** *គឺ ជីវៈដែលមានឈ្មោះថា វេទគូ ក្នុងបញ្ហាមុនគឺ សត្វ ពុំមានក្នុងភូត គឺក្នុងខន្ធ បានសេចក្តីថា មានតែខន្ធសុទ្ធសាធប្រព្រឹត្តទៅ ខ្ទឹមសារចំណែកដែលនៅសល់ គួរជ្រាបពាក្យអធិប្បាយតាមន័យក្នុងបញ្ហាមុន ៗ ៕*

*ចប់ពាក្យអធិប្បាយបញ្ហាទី ១៥*

# បញ្ហាទី ១៦ - អរូបធម្មវវត្ថានទុក្ករប្បញ្ហា

**ព្រះរាជា** *មានបន្ទូលសួរថា " ព្រះគុណម្ចាស់នាគសេន ព្រះដ៏មានព្រះភាគទ្រង់បានធ្វើនូវប្រការដ៏ពិបាកធ្វើឬទេ ? "*

**ព្រះថេរៈ** *ថ្វាយព្រះពរវិសជ្ជនាថា " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះដ៏មានព្រះភាគ ទ្រង់បានធ្វើនូវប្រការដ៏ពិបាកធ្វើ "*

**ព្រះចៅមិលិន្ទ ៖** *" ព្រះគុណម្ចាស់នាគសេន ព្រះដ៏មានព្រះភាគទ្រង់បានធ្វើនូវប្រការដ៏ពិបាកធ្វើ គឺអ្វីទៅ ? "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់បានធ្វើនូវប្រការដ៏ពិបាកធ្វើ គឺការត្រាស់ញែកនាមធម៌ គឺ ចិត្តនិងចេតសិកទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយបានថា* ***"នេះផស្សៈ នេះវេទនា នេះសញ្ញា នេះចេតនា នេះចិត្ត"*** *ជាដើម "*

**ព្រះចៅមិលិន្ទ ៖** *" សូមព្រះគុណម្ចាស់ធ្វើការឧបមា "*

**ព្រះនាគសេន ៖** *" សូមថ្វាយព្រះពរ ប្រៀបដូចជា បុរសខ្លះទៅកាន់មហាសមុទ្រដោយនាវា ប្រើកម្ពុបង់ដៃដួសទឹក ឡើងមកភ្លក់ដោយអណ្តាត ។ សូមថ្វាយព្រះពរ បុរសនោះអាចដឹងបានឬទេថា នេះជាទឹកនៃទន្លេគង្គា នេះជាទឹកនៃទន្លេយមុនា នេះជាទឹកនៃទន្លេអចិរវតី នេះជាទឹកនៃទន្លេសរភូ*

*នេះជាទឹកនៃទន្លេមហី?"*

**ព្រះចៅមិលិន្ទ៖** *" ការដែលដឹង ជាប្រការដ៏ពិបាក ព្រះគុណម្ចាស់ "*

**ព្រះនាគសេន៖** *" សូមថ្វាយព្រះពរ ព្រះដ៏មានព្រះភាគទ្រង់បានធ្វើនូវប្រការដ៏ពិបាកធ្វើជាងនោះទៅទៀត គឺ ការត្រាស់ញែកនាមធម៌ គឺ ចិត្តនិងចេតសិកទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយបានថា "* ***នេះផស្សៈ នេះវេទនា នេះសញ្ញា នេះចេតនា នេះចិត្ត*** *" ជាដើម "*

**ព្រះរាជា** *ទ្រង់ធ្វើការអនុមោទនាជាខ្លាំងថា "ពិតជាប្រសើរមែន ព្រះគុណម្ចាស់នាគសេន " ៕*

*ចប់អរូបធម្មវវត្ថនទុក្ករប្បញ្ហាទី ១៦*

# ពាក្យអធិប្បាយបញ្ហាទី ១៦ ៖

*បញ្ហាស្តីអំពីការកំណត់ញែកនាមធម៌ទាំងឡាយ ដែលជាប្រការដ៏ពិបាកធ្វើ ឈ្មោះថា* ***អរូបធម្មវវត្ថានទុក្ករប្បញ្ហា*** *។*

*ពាក្យថា* ***ប្រការដ៏ពិបាកធ្វើ*** *បានសេចក្តីថា ជាការដែលអ្នកដទៃលើកលែងព្រះតថាគត នឹងគិតក្តី នឹងដឹងក្តី នឹងពោលក្តី នឹងបញ្ញត្តក្តី នឹងសម្តែងក្តី នឹងធ្វើក្តី ជាប្រការដែលពិបាកធ្វើ អធិប្បាយថា លើកលែងន័យដែលប្រទានឱ្យ គឺ មិនអាចធ្វើបានឡើយ ។*

*ទន្លេទាំងឡាយ មានទន្លេគង្គាជាដើម នាំគ្នាហូរឆ្ពោះតម្រង់ទៅរួមគ្នានៅមហាសមុទ្រ ទឹកក្នុងទន្លេនីមួយ ៗ ទាំងនោះ មានរសមិនដូចគ្នា នៅពេលហូរទៅរួមគ្នានៅមហាសមុទ្រ រសទាំងឡាយក៏រមែងដល់ភាពឡូកឡំគ្នា ។ នៅពេលបុគ្គលក្បង់ទឹកឡើងមកភ្លក់រស ទោះជាដឹងរស ប៉ុន្តែការនឹងកំណត់ញែក ដើម្បីឱ្យដឹងថា ទឹកដែលខ្លួនក្បង់ឡើងមកភ្លក់ជាទឹកនៃទន្លេអ្វី ជាប្រការដែលពិបាកនឹងធ្វើ ប្រការនេះយ៉ាងណា នៅពេលនាមធម៌ទាំងឡាយកើតឡើងដំណាលគ្នា ប្រព្រឹត្តទៅ ក្នុងអារម្មណ៍តែមួយ ដល់ភាព*

រួមគ្នាជាតែមួយ ព្រោះហេតុដូចពោលខាងលើ ការដែលនឹងកំណត់ញែកថា "**នេះផស្សៈ នេះវេទនា**" ជាដើម រមែងជាប្រការដ៏ពិបាកធ្វើ ដូចនេះ ។

ចប់ពាក្យអធិប្បាយបញ្ហាទី ១៦

# ចប់អរូបវវត្ថានវគ្គទី ៧

ក្នុងវគ្គនេះ មាន ១៦ បញ្ហា

**សម្គាល់ ៖** ចំពោះអរូបវវត្ថានវគ្គនេះ ក្នុងអដ្ឋកថាមានត្រឹមតែ ១៥ បញ្ហា ប៉ុណ្ណោះ ពុំមានពុទ្ធគុណសតិបដិលាភប្បញ្ហាទេ ។

ឆឆឆឆឆឆឆ 📖 ឈឈឈឈឈឈឈ

# មិលិន្ទប្បញ្ហាបុច្ឆាវិសជ្ជនា

**ព្រះថេរៈ** ថ្វាយព្រះពរថា " សូមថ្វាយព្រះពរ មហាបពិត្រ ព្រះអង្គទ្រង់ជ្រាបឬទេថា ពេលនេះជាវេលាណា ? "

**ព្រះចៅមិលិន្ទ** " ជ្រាប ព្រះគុណម្ចាស់ ថាពេលនេះ ហួសបឋមយាមទៅហើយ មជ្ឈិមយាមកំពុងតែប្រព្រឹត្តទៅ គប់ភ្លើងនៅជះពន្លឺនៅឡើយ ពួកភ្នាក់ងារនឹងនាំយកសំពត់ ៤ផ្ទាំង ដែលជារបស់ព្រះរាជទាន មកពីឃ្លាំង"

ពួកបម្រើរាជការយោនកទាំងឡាយ បានក្រាបទូលយ៉ាងនេះថា "ក្រាបទូល ព្រះមហារាជ ព្រះថេរៈជាបណ្ឌិតដ៏មានសមត្ថភាព ក្រាបទូល "

**ព្រះរាជា** " មែនហើយ ពួកនាយ ព្រះថេរៈជាបណ្ឌិត អ្នកជាគ្រូបាអាចារ្យ គួរតែដូចជាព្រះថេរៈនេះ ហើយអ្នកជាសិស្សក៏គួរតែដូចជារូបយើង អ្នកជាបណ្ឌិតនឹងដឹងសព្វនូវធម៌ ក្នុងកាលមិនយូរឡើយ "

**ព្រះរាជា** ទ្រង់រីករាយ ចំពោះពាក្យវិសជ្ជនា ដោះស្រាយបញ្ហារបស់ **ព្រះថេរៈ** ទ្រង់អារាធនាឱ្យព្រះនាគសេនត្រៀរគ្រងសំពត់កម្ពលដែលមានតម្លៃដល់ទៅ ១ សែនកហាបណៈ ហើយត្រាស់ថា " ព្រះគុណម្ចាស់នាគសេន ចាប់តាំងពីថ្ងៃនេះទៅ ខ្ញុំព្រះករុណានឹងត្រៀមកត្តាហារ ទុកសម្រាប់ព្រះភិក្ខុចំនួន ១០៨ អង្គ ចំពោះព្រះគុណម្ចាស់ នៅក្នុងនគរមានវត្ថុណាមួយ ដែលជាកប្បិយ ( សមគួរប្រើបានតាមពុទ្ធានុញ្ញាត ) ក្តី ខ្ញុំព្រះករុណាសូមបវារណាដោយវត្ថុនោះ " ដូចនេះ ។

**ព្រះថេរៈ** " កុំអី មហាបពិត្រ អាត្មាភាពល្មមរស់នៅបានហើយ "

**ព្រះរាជា** " ព្រះគុណម្ចាស់នាគសេន ខ្ញុំព្រះករុណាក៏បានជ្រាបដែរថា ល្មមអាចរស់នៅបាន ប៉ុន្តែ សូមព្រះគុណម្ចាស់រក្សាអង្គឯង និង សូមរក្សាខ្ញុំព្រះករុណាផងចុះ ។ យ៉ាងដូចម្តេច ហៅថា រក្សាអង្គឯង ? គឺ ពួកចូលចិត្តពោលពាក្យនិន្ទាអ្នកដទៃ អាចនឹងមកពោលយ៉ាងនេះថា " **ព្រះនាគសេន**

***បានធ្វើឱ្យព្រះចៅមិលិន្ទជ្រះថ្លា ក៏មិន (ឃើញថា) បានអ្វី ៗ សោះ "*** *បើដូចនេះ សូមព្រះគុណម្ចាស់រក្សាអត្តឯងផងចុះ ។ យ៉ាងដូចម្ដេច ឈ្មោះថា រក្សាខ្ញុំព្រះករុណា ? ពួកចូលចិត្តពោលពាក្យនិន្ទាអ្នកដទៃ អាចនឹងមកពោលយ៉ាងនេះថា "* ***ព្រះចៅមិលិន្ទទ្រង់ជ្រះថ្លាហើយ ក៏មិន (ឃើញថា) ទ្រង់ធ្វើអាការជ្រះថ្លាសោះ "*** *បើដូចនេះ ក៏សូមរក្សាខ្ញុំព្រះករុណាផងចុះ "*

**ព្រះថេរៈ** *" សូមថ្វាយព្រះពរ សូមឱ្យដូចតាមព្រះបំណងទៅចុះ "*

**ព្រះរាជា** *" ព្រះគុណម្ចាស់ ប្រៀបដូចជា រាជសីហ៍ជាស្ដេចនៃសត្វទាំងឡាយ ទោះជាត្រូវឃុំឃាំងនៅក្នុងចម្រឹងមាស ក៏នៅតែបែរមុខឆ្ពោះទៅខាងក្រៅតែម្យ៉ាងយ៉ាងណា ព្រះគុណម្ចាស់ ខ្ញុំព្រះករុណានៅគ្រប់គ្រងផ្ទះក៏ពិតមែន ប៉ុន្តែក៏ប៉ងបែរមុខឆ្ពោះទៅខាងក្រៅផ្ទះតែម្យ៉ាង ដូចនោះដែរ ។ ព្រះគុណម្ចាស់ ប្រសិនបើខ្ញុំព្រះករុណានឹងចាកចេញពីផ្ទះទៅបួស ដល់ភាពជាអ្នកពុំមានផ្ទះ ខ្ញុំព្រះករុណាក៏នឹងមានជីវិតរស់នៅមិនបានយូរ ខ្ញុំព្រះករុណាមានសត្រូវច្រើន " ដូចនេះ ។*

*គ្រានោះ ព្រះនាគសេន លុះដោះស្រាយបញ្ហារបស់ព្រះចៅមិលិន្ទរួចហើយ ក៏ក្រោកពីអាសនៈ ត្រឡប់ចូលទៅកាន់សង្ឃារាម ។ ព្រះចៅមិលិន្ទនៅពេលព្រះនាគសេនក្រោកចេញ ទៅមិនយូរប៉ុន្មាន ទ្រង់ក៏កើតសេចក្ដីតម្រិះយ៉ាងនេះថា "យើងសួរទៅថាយ៉ាងដូចម្ដេច ? ព្រះគុណម្ចាស់នាគសេន ឆ្លើយមកថាយ៉ាងដូចម្ដេច ? " ដូចនេះ បន្ទាប់មក ព្រះចៅមិលិន្ទទ្រង់ក៏មានព្រះតម្រិះគិតឃើញយ៉ាងនេះថា "* ***យើងសួរបានល្អគ្រប់ប្រការ ព្រះគុណម្ចាស់នាគសេន ក៏ឆ្លើយបានល្អគ្រប់ប្រការ "*** *ដូចនេះ ។*

*ទោះជាព្រះនាគសេនទៅដល់សង្ឃារាមហើយ ក៏មានគំនិតយ៉ាងនេះថា "ព្រះចៅមិលិន្ទ ត្រាស់សួរមកយ៉ាងដូចម្ដេច ? យើងថ្វាយព្រះពរឆ្លើយទៅថាយ៉ាងដូចម្ដេច ? " ដូចនេះ ។ បន្ទាប់មក ព្រះនាគសេនក៏មានគំនិតគិតឃើញយ៉ាងនេះថា "* ***ព្រះចៅមិលិន្ទត្រាស់សួរ បានល្អគ្រប់ប្រការ យើងក៏***

*ថ្វាយព្រះពរឆ្លើយ បានល្អគ្រប់ប្រការ ” ដូចនេះ ។*

*បន្ទាប់ពីនោះ នៅពេលរាត្រីបានកន្លងផុតទៅហើយ នៅពេលជិតភ្លឺ ព្រះនាគសេនក៏គ្រងសំពត់ កាន់បាត្រ និងចីពរ ចូលទៅកាន់ព្រះរាជនិវេសន៍ ដែលព្រះចៅមិលិន្ទប្រថាប់ ។ លុះចូលទៅហើយ ក៏គង់លើអាសនៈដែលគេបានចាត់ត្រៀមទុក ។ លំដាប់នោះ ព្រះចៅមិលិន្ទ ទ្រង់ក្រាបថ្វាយបង្គំព្រះនាគសេន ហើយទ្រង់ប្រថាប់នៅកន្លែងសមគួរមួយ ។*

*លុះ* **ព្រះចៅមិលិន្ទ** *ទ្រង់ប្រថាប់នៅកន្លែងសមគួរហើយ ក៏មានបន្ទូលសេចក្ដីនោះ ចំពោះព្រះនាគសេន “ **ព្រះគុណម្ចាស់ កុំមានគំនិតយ៉ាងនេះឱ្យសោះថា “ ព្រះចៅមិលិន្ទនោះ លុះទ្រង់គិតថា យើងបានសួរបញ្ហាជាមួយនឹងព្រះនាគសេនយ៉ាងនេះហើយ ទ្រង់គិតតែពីសោមនស្សរហូតដល់កន្លងផុតរាត្រីដែលនៅសល់នោះ ” សូមកុំយល់យ៉ាងនេះអី ។ ព្រះគុណម្ចាស់ ខ្ញុំព្រះករុណានោះ រហូតអស់រាត្រីដែលនៅសល់នោះ ក៏មានគំនិត(គិតសាឡើងវិញ)ប្រការនេះថា “ យើងសួរទៅថាយ៉ាងដូចម្ដេច ? ព្រះគុណម្ចាស់ឆ្លើយមកថា យ៉ាងដូចម្ដេច ? ” ថា “យើងសួរបានល្អគ្រប់ប្រការ ព្រះគុណម្ចាស់ក៏ឆ្លើយបានល្អគ្រប់ប្រការ ” ដូចនេះ ប៉ុណ្ណោះ ” ។**

*សូម្បី* **ព្រះថេរៈ** *ក៏ពោលយ៉ាងនេះថា “ សូមមហាបពិត្រ ទ្រង់កុំមានគំនិតយ៉ាងនេះឱ្យសោះថា “ ព្រះនាគសេននោះ លុះគិតថា យើងដោះស្រាយបញ្ហារបស់ព្រះចៅមិលិន្ទបាន ដូចនេះហើយ ក៏គិតតែពីសោមនស្សរហូតកន្លងផុតរាត្រីដែលនៅសល់នោះ ”* ***ព្រះអង្គទ្រង់កុំយល់ឃើញយ៉ាងនេះអី ។ មហាបពិត្រ អាត្មាភាពនោះ រហូតរាត្រីដែលនៅសល់នោះ បានមានគំនិត(គិតសាឡើងវិញ) ប្រការនេះថា “ ព្រះចៅមិលិន្ទត្រាស់សួរមកថាយ៉ាងដូចម្ដេច ? យើងថ្វាយព្រះពរសួរទៅថាយ៉ាងដូចម្ដេច ? ” ថា “ ព្រះចៅមិលិន្ទត្រាស់សួរបានល្អគ្រប់ប្រការ យើងក៏ថ្វាយព្រះពរឆ្លើយបានល្អគ្រប់ប្រការ ” ដូចនេះ ប៉ុណ្ណោះ ” ។***

កំពូលបណ្ឌិតដ៏អស្ចារ្យទាំង ២ បានសរសើរពាក្យពេចន៍ល្អរបស់គ្នាទៅវិញទៅមក យ៉ាងដូចនេះ ។

ចប់មិលិន្ទប្បញ្ហាបុច្ឆាវិសជ្ជនា

# ចប់មិលិន្ទប្បញ្ហាកណ្ឌទី ២

ក្នុងភាគ ១ នេះមាន ២ កណ្ឌ គឺ **បុព្វយោគកណ្ឌ** មានឈ្មោះថា ពាហិរកថា និង **មិលិន្ទប្បញ្ហាកណ្ឌ** គឺ វគ្គស្តីអំពីបញ្ហារបស់ព្រះចៅមិលិន្ទ ផ្ទាល់ដោយឡែកនេះ ប្រកបដោយ ៧ វគ្គ មានមហាវគ្គ ជាដើម សរុបបញ្ហា មាន ៨៦ បញ្ហា ។

# ចប់ ភាគ ១

សូមរង់ចាំអានជាបន្តទៀត

**ភាគ ២** - ស្តីអំពីលក្ខណៈរបស់បុគ្គល និង បញ្ហាពុទ្ធដីកាដែលមានន័យជា ២ យ៉ាងផ្សេងគ្នា មិនស្របគ្នា នៅក្នុងព្រះសូត្រ ( **កណ្ឌទី ៣** - លក្ខណប្បញ្ហាកណ្ឌ និង **កណ្ឌទី ៤** - មេណ្ឌកប្បញ្ហាកណ្ឌ ) ។

**ភាគ ៣** - ស្តីអំពីរឿងឲ្យអនុមាណថាប្រាកដជាយ៉ាងនេះឬយ៉ាងនោះ និង អំពីការឧបមាប្រៀបធៀបអង្គគុណខ្លះ របស់ព្រះអរហន្ត ជាមួយនឹងកិរិយាមួយចំនួនរបស់សត្វផ្សេង ៗ ( **កណ្ឌទី ៥** - អនុមាណប្បញ្ហាកណ្ឌ និង **កណ្ឌទី ៦** - ឧបមកថាបញ្ហាកណ្ឌ ) ។

# រាយនាមសប្បុរសជន

## ឧបត្ថម្ភការបោះពុម្ពសៀវភៅមិលិន្ទបញ្ហា ភាគ ១

## សប្បុរសជនបន្ទប់សន្ទនាព្រះធម៌តាមអ៊ិនធឺណេត

Paltalk Messenger

| | | |
|---|---|---|
| ភិក្ខុ អគ្គធីរោ **គង់ សុមិត្ត** | (វត្តនិគ្រោធវ័ន គល់ទទឹង) | ១.០០០.០០០៛ |
| ភិក្ខុ សទ្ធម្មប្បញ្ញោ **ឡូន ចាន់ថន** | (កាណាដា) | ១០០ $ |
| ភិក្ខុ អារម្ភវិរិយោ **កុំ គង់វណ្ណារ័ត្ន** | (កាណាដា) | ១០០ $ |
| ភិក្ខុ ឥទ្ធិសារោ **ស៊ុន សារិទ្ធ** | (កាណាដា) | ១០០ $ |
| ភិក្ខុ សីលរក្ខិតោ **អ៊ុន វ៉េន** | (អូស្ត្រាលី) | ១០០ $ |
| ភិក្ខុ មុនីរក្ខិតោ **ប៉ែន សុផេង** | (វត្តវេឡុវនារាម) | ៥០ $ |
| ព្រះគ្រូរតនវិសុទ្ធិ **ឆាត សុឆេត** | (វត្តបុទុមវតី) | ៤០ $ |
| ភិក្ខុ ធម្មបាលោ **ជិន សារិន** | (វត្តសំពៅមាស) | ៣៥ $ |
| ភិក្ខុ ព្រហ្មជោតោ **គង់ ផែង** | (វត្តសំពៅមាស) | ២០ $ |
| ភិក្ខុ មុនីរក្ខិតោ **ស៊ឹង ភារម្យ** | (ថៃ) | ២០ $ |
| ភិក្ខុ បញ្ញាវិរុឡ្ហោ **មហាយ៉ារី** | (វត្តបាត្លីវ័ន កំពង់ចាម) | ២០ $ |
| ភិក្ខុ អគ្គបញ្ញោ **ស៊ឹង ហ៊ុន** | (វត្តនិគ្រោធវ័ន គល់ទទឹង) | ១១ $ |
| ភិក្ខុ សមចិត្តោ **កុច បូណា** | (វត្តនិគ្រោធវ័ន គល់ទទឹង) | ១០ $ |
| ភិក្ខុ នន្ទញ្ញាណោ **រិន សំណាង** | (វត្តវេឡុវនារាម) | ១០ $ |
| ភិក្ខុ សុខិតត្ថេរោ **ហេង សុខុម** | (ថៃ) | ១០ $ |
| ភិក្ខុ អគ្គធរោ **អ៊ឹម ឧត្តម** | (ថៃ) | ១០ $ |
| ភិក្ខុ ទត្តត្ថេរោ **ថាន់ សុរិយា** | (ថៃ) | ១០ $ |
| ភិក្ខុ ចន្ទធម្មោ **ខៀវ ខន** | (វត្តបុទុមវតី) | ១០ $ |
| ភិក្ខុ សុជាតោ **វ៉ន ចន** | (វត្តបុទុមវតី) | ១០ $ |

| | | |
|---|---|---|
| ភិក្ខុ ធម្មថេរោ **មួង ចន្ថា** | (វត្តកៀនស្វាយក្រៅ) | ១០ $ |
| ភិក្ខុ សុភូតធម្មោ **រុន សុភ័ក្ត្រ** | (វត្តកៀនស្វាយក្រៅ) | ១០ $ |
| ភិក្ខុ បញ្ញាប្បជោតោ **ហៀង សុភ័ស្ត្រ** | (វត្តសន្សំកុសល) | ១០ $ |
| ភិក្ខុ យន្តករោ **ញ៉ៀប តាត** | (វត្តឧណ្ណាលោម) | ១០ $ |
| ភិក្ខុ មុនីជោតិត្ថេរោ **រុន សុវណ្ណា** | (វត្តសំសមី. ព្រៃវែង) | ១០ $ |
| ភិក្ខុ វិនយបាលោ **សុខ ធម្មភាសី** | (វត្តសំសមី. ព្រៃវែង) | ១០ $ |
| ភិក្ខុ ធម្មទីបោ **គញ្ញ សម្ផស្ស** | (វត្តបុទុមវតី) | ៥ $ |
| ភិក្ខុ សទ្ធាសោភណោ **គញ្ញ សំណាង** | (ថៃ) | ៥ $ |
| សាមណេរ **ស៊ឹម សុខលី** | (វត្តកំផែង បាត់ដំបង) | ១០ $ |
| សាមណេរ **ឆិម ម៉ុនឆា** | (វត្តសុភមង្គល បន្ទាយមានជ័យ) | ១០ $ |
| ឧបាសិកា **វណ្ណារី ទេពប្រណម្យ** | (ភ្នំពេញ) | ២០០ $ |
| ឧបាសិកា **ជា ឡេង** (ម្លិះលា) | ព្រមទាំងបុត្រ (អូស្ត្រាលី) | ២០០ $ |
| ឧបាសិកា **ចៅផ្កាយ៉ា ព្រីនសេស** | (អាមេរិក) | ៥០ $ |
| ឧ.សិ **រស់ រមនា** | ព្រមទាំងបុត្រ (ភ្នំពេញ) | ១០ $ |

# សប្បុរសជននៅភ្នំពេញ

| | | |
|---|---|---|
| ភិក្ខុ បញ្ញាបទីបោ **សៀវ តារ៉ា** | (វត្តឧណ្ណាលោម) | ១០ $ |
| ភិក្ខុ ចន្ទធម្មោ **តាត វបុល** | (វត្តឧណ្ណាលោម) | ១០ $ |
| ភិក្ខុ អគ្គប្បញ្ញោ **អាន ប៉េងថន** | (វត្តឧណ្ណាលោម) | ៧ $ |
| ភិក្ខុ កិច្ចសារោ **ជីន សុខហ៊ាង** | (វត្តឧណ្ណាលោម) | ៧ $ |
| ភិក្ខុ ឧត្តមបញ្ញោ **អយ សេងអ៊ន់** | (វត្តឧណ្ណាលោម) | ៧ $ |
| ភិក្ខុ បរិសុទ្ធោ **រី សារឹម** | (វត្តឧណ្ណាលោម) | ៧ $ |
| ភិក្ខុ មុនីបុត្តោ **ប៊ិន សុធា** | (វត្តឧណ្ណាលោម) | ៧ $ |
| ឧ.ស **ជា សារិន** | ឧ.សិ **ឡុង សោភ័ណ** | ៣៥ $ |

ឧ.ស **សែន វចិត្រ** ឧ.សិ **ម៉ែន ភាវ** ព្រមទាំងបុត្រ ៣៥ $

ឧ.ស **ម៉ែន សារ៉ាយ** ឧ.សិ **ឃ្លោក ស៊ីណា** ២១ $

ឧ.ស **ឃ្លោក វធូរ** ព្រមទាំងគ្រួសារ ២០ $

ឧ.ស **ឃ្លោក វ៉ា** ឧ.សិ **អ៊ី សុផល្លា** ព្រមទាំងបុត្រ ១០ $

ឧ.សិ **ឃ្លោក វន្នា** ឧ.សិ **ឃ្លោក ចន្ទី** ១០ $

ឧ.សិ **ស៊ីម កុសល** ១០ $

ឧ.ស **មួច មិន** ឧ.សិ **ភច យឺន** ១០ $

កុមារី **ទេពប្រណាម្យ រតនៈវណ្ណា** ៣២.០០០ ៛

ឧ.សិ **សាន** ១០.០០០ ៛

# សប្បុរសជន ខេត្តបន្ទាយមានជ័យ

ភិក្ខុ វជិរជោតោ **ទូ សុជាត** (វត្តប្រាសាទស្រះឈ្លូរ) ៣១៧.០០០ ៛

សាមណេរ **ឈាន វាសនា** (វត្តប្រាសាទស្រះឈ្លូរ) ៣០.០០០ ៛

សាមណេរ **ថាត សុភ័ក្ត្រ** (វត្តប្រាសាទស្រះឈ្លូរ) ៦០.០០០ ៛

សាមណេរ **ស៊ីន ដេត** (វត្តប្រាសាទស្រះឈ្លូរ) ៣០.០០០ ៛

សាមណេរ **វៀល សាវុធ** (វត្តប្រាសាទស្រះឈ្លូរ) ១៥.០០០ ៛

សាមណេរ **ឆាត វចិត្រ** (វត្តប្រាសាទស្រះឈ្លូរ) ១៩.០០០ ៛

ឧ.ស **ច្រុច តែន** និង ឧ.សិ **ឡឹង សុភា** ៧០.០០០ ៛

ឧ.ស **អ៊ូច មាស** និង ឧ.សិ **ឡើ ឡុន** ១៥.០០០ ៛

ឧ.សិ **ស្រីតូច ចក្រ** ១៥.០០០ ៛

ឧ.ស **អ៊ូច វួត** និង ឧ.សិ **តប សាឡេត** ១៥.០០០ ៛

ឧ.ស **ប៉េក ញូវ** និង ឧ.សិ **លឿន វួច** ១៥.០០០ ៛

ឧ.ស **ឡើ សាឃុត** និង ឧ.សិ **លិវ ផុស** ១៥.០០០ ៛

ឧ.ស **យោន សួម** និង ឧ.សិ **តប ទោត** ១៥.០០០ ៛

ឧ.ស **ថាប់ ស៊ឿន** និង ឧ.សិ **ហៀត ចាំ** ១៥.០០០ ៛

ឧ.ស **អឿម ហឹស** ១៥.០០០ ៛

ឧ.សិ **អ៊ូច ឆែម** ១៥.០០០ ៛

ឧ.សិ **រី មាល់** ១៥.០០០ ៛

ឧ.ស **ទេព ធុយ** និង ឧ.សិ **កោយ លាក** ១៥.០០០ ៛

ឧ.ស **ថាប់ ផែន** និង ឧ.សិ **គង់ ស៊ុក** ១៤.០០០ ៛

ឧ.ស **ឡាច ជួន** និង ឧ.សិ **គុយ ខៀវ** ១៤.០០០ ៛

ឧ.ស **ថាប់ ឈាវ** និង ឧ.សិ **ឡាច គយ** ១៤.០០០ ៛

ឧ.ស **ទន់ ជុំ** និង ឧ.សិ **អ៊ូត អោត** ១៤.០០០ ៛

ឧ.ស **ថាប់ ឈាវ** និង ឧ.សិ **ទន់ ឯក** ១៤.០០០ ៛

ឧ.ស **ឡាច គន់** និង ឧ.សិ **អ៊ូច ឈឿម** ១៤.០០០ ៛

ឧ.សិ **ប្លុង ទុំ** ១៤.០០០ ៛

ឧ.សិ **ប្លុង អោន** ១៤.០០០ ៛

ឧ.សិ **ហុក បូក** ១៤.០០០ ៛

ឧ.ស **ប្លុង ឆឹត** និង ឧ.សិ **ប្លុង សារិម** ១៤.០០០ ៛

ឧ.ស **គួន តឿន** និង ឧ.សិ **ទន់ សៀង** ១៤.០០០ ៛

ឧ.ស **លឿន មាន** និង ឧ.សិ **ជួន គន** ១៤.០០០ ៛

ឧ.ស **ហាន ឈួយ** និង ឧ.សិ **លឿន ឆឿម** ១៤.០០០ ៛

ឧ.ស **ឡិ រ៉ាត** និង ឧ.សិ **ច្រុច សារ៉ង** ១៤.០០០ ៛

ឧ.ស **ប៊ូ ច្បាន** និង ឧ.សិ **លឿន នឹក** ១៤.០០០ ៛

ឧ.ស **ហ៊ឹម ផេង** ១៤.០០០ ៛

ឧ.ស **នូ សែ** និង ឧ.សិ **ឃុន សំបូរ** ១៤.០០០ ៛

ឧ.សិ **ឌឿ ឈាម** ១៤.០០០ ៛

ឧ.ស **សួរ ឈួត** និង ឧ.សិ **ច្រុច ស្រីអូន** ១៤.០០០ ៛

| | | |
|---|---|---|
| ឧ.ស **ឆែប នៅ** និង ឧ.សិ **ច្រុច គួត** | | ១៥.០០០ ៛ |
| ឧ.ស **ធី ខុត** និង ឧ.សិ **យឹន ម៉ៅ** | | ១៥.០០០ ៛ |
| ឧ.សិ **ពេញ្ញ ឆុយ** | | ៧.០០០ ៛ |

# សប្បុរសជនចំណុះជើងវត្តទេវុន្សវនារាម

## ( ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ )

| | | |
|---|---|---|
| ឧ.សិ **សេង** | ព្រមទាំងកូនចៅ | ៥០.០០០ ៛ |
| ឧ.សិ **អ៊ុយ សាង** | | ៥០.០០០ ៛ |
| ឧ.សិ **សាវ លាប** | ព្រមទាំងកូនចៅ | ៣២.០០០ ៛ |
| ឧ.សិ **ទូច កែវ** និង ឧ.សិ **ឆៃ លីណា** | | ១៥.០០០ ៛ |
| ឧ.សិ **មាស ឈោង** | | ១៥.០០០ ៛ |
| ឧ.សិ **ខាត់** | | ១៥.០០០ ៛ |
| ឧ.ស **អ៊ិន សេស** | | ១៥.០០០ ៛ |
| ឧ.សិ **ហាម ហួន** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.ស **រឿន** និង ឧ.សិ **ម៉ាក់** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **ប៊ូ ម៉ាឡៃ** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **ឆួន យៀន** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **មឿន ចន្ថន** | ព្រមទាំងកូនចៅ | ១៥.០០០ ៛ |
| ឧ.សិ **គង់ ណារិន** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **អ៊ូច កុលិកា** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **ទូច យុំ** និង ឧ.សិ **សោភ័ណ** | | ១៥.០០០ ៛ |
| ឧ.សិ **ឥក សយ** និងចៅស្រី **ពៅ នីតា** | | ១៥.០០០ ៛ |
| ឧ.សិ **ហាម ហែម** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **យូ លន់** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |

| | | |
|---|---|---|
| ឧ.សិ **មឿន ភាក់** | ព្រមទាំងកូនចៅ | ១៥.០០០ ៛ |
| ឧ.សិ **ស្ងួន វ៉ន** | ព្រមទាំងបុត្រ | ១៥.០០០ ៛ |
| ឧ.សិ **មាស យ៉ាន** | ព្រមទាំងស្វាមី | ១៥.០០០ ៛ |
| ឧ.សិ **ជី នុត** | | ១៥.០០០ ៛ |
| ឧ.ស **មាស ប៉ម** | | ១០.០០០ ៛ |
| ឧ.សិ **ប៉ាល់ ចន្ថន** ឧ.សិ **ភញ្ញា** | ព្រមទាំងគ្រួសារ | ៧.០០០ ៛ |

# សប្បុរសជននាទីពន្លឺពុទ្ធឱវាទ នៃសហញ្ញាតព្រះធម៌

## ( **វត្តអង្គពោធិញ្ញាណ ស្ទឹងមានជ័យ ភ្នំពេញ** )

| | |
|---|---|
| ព្រះគ្រូ រតននាទោ **អ៊ួន សំណាង** | ១៥០.០០០ ៛ |
| ភិក្ខុ អគ្គវរោ **ញ៉ឹក អឿ** | ១០០.០០០ ៛ |
| ភិក្ខុ ធម្មចន្ទោ **សាន់ ណុប** | ៥០.០០០ ៛ |
| ភិក្ខុ មណិធម្មោ **អ៊ូ សាំគួយ** | ៥០.០០០ ៛ |
| ភិក្ខុ សង្ឃបណ្ឌិតោ **ឃៀង សុជាត** | ៥០.០០០ ៛ |
| ភិក្ខុ កល្យាណគុត្តោ **ឡុញ វណ្ណៈ** | ១០ $ |
| ភិក្ខុ បញ្ញាវិសារទោ **យឹម សុវណ្ណារ៉ា** | ១០ $ |
| ភិក្ខុ សុវណ្ណមុនីជោតោ **សុខ សារ៉ាត់** | ៣០.០០០ ៛ |
| ភិក្ខុ កល្យាណធម្មោ **ឡោ សុធារ៉ា** | ៣០.០០០ ៛ |
| ភិក្ខុ បិតធម្មោ **ឈឹន ចន្ថា** | ២០.០០០ ៛ |
| ភិក្ខុ ធម្មសារោ **ចៅ ប្រុសទូច** | ២០.០០០ ៛ |
| ភិក្ខុ កល្យាណសីលោ **យៀក ឈិន** | ១២.០០០ ៛ |
| ភិក្ខុ យសបាលោ **ឡេង យូ** | ១០.០០០ ៛ |
| សាមណេរ **មាស ឡឹម** | ១៥.០០០ ៛ |

ឧ.ស **ម៉ាន់ យ៉ាន** និងឧ.សិ **កែវ សុខហៃ** ព្រមទាំងបុត្រ ១០០ $

ឧ.ស **ឃុន ចែ័ត** និងឧ.សិ **គួយ ហ៊ីនអ៊ី** ព្រមទាំងបុត្រ ១៥ $

ឧ.សិ **គ សៀកហ៊ីន** ព្រមទាំងបុត្រ ១៥ $

ឧ.សិ **ប្រាក់ ស៊ីឡួន** ព្រមទាំងបុត្រ ១០ $

ឧ.ស **ប៊ុន ភួច** ឧ.សិ **ប៉ែន ឡឿន** ព្រមទាំងបុត្រ ១០ $

ឧ.សិ **អ៊ុច សារិន** ព្រមទាំងបុត្រ ៥
$

ឧ.សិ **ជា សារឹម** ព្រមទាំងបុត្រ ៥ $

ឧ.សិ **មាន សារឹម** ព្រមទាំងបុត្រ ១០០.០០០ ៛

ឧ.ស **ម៉ៅ ហ៊ិន** និង ឧ.សិ **ម៉ាន់ សារុន** ព្រមទាំងបុត្រ ៤០.០០០ ៛

ឧ.សិ **ម៉ោច សុំ** ព្រមទាំងបុត្រ ៤០.០០០ ៛

ឧ.សិ **អ៊ិន ឡុន** ព្រមទាំងបុត្រ ២៥.០០០ ៛

ឧ.សិ **យាយ កែ** ២៣.០០០ ៛

ឧ.សិ **ទែន ភន** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.សិ **សៀច អ៊ី** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.ស **មុំ សុផល** និង ឧ.សិ **សឿន ថេន** ព្រមទាំងបុត្រ
២០.០០០ ៛

ឧ.សិ **ជា សៀច លីម** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.សិ **អ៊ុយ រ៉េត** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.ស **ខ្វិ ភួច** និង ឧ.សិ **ទេស រឿច** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.ស **ព្រាប យឿន** និង ឧ.សិ **អ៊ូ គម** ព្រមទាំងបុត្រ ២០.០០០ ៛

ឧ.សិ **ឡុច សារ៉ាន់** ព្រមទាំងបុត្រនិងចៅ ២០.០០០ ៛

កញ្ញា **ញ៉េន ស្រីណៃ** ២០.០០០ ៛

ឧ.សិ **អ៊ូ សុន** ព្រមទាំងបុត្រ ១៥.០០០ ៛

ឧ.ស **រុន** និង ឧ.សិ **យ៉ុម** ១៥.០០០ ៛

ឧ.ស **សុខ** និង ឧ.សិ **ចាន់** ១៥.០០០ ៛

ឧ.ស **ឡឹក ចន** និង ឧ.សិ **ឌុក នឹម** ១៥.០០០ ៛

ឧ.ស **ប៉ែត** និង ឧ.សិ **ទូច** ព្រមទាំងបុត្រ ១៤.០០០ ៛

ឧ.សិ **ម៉ាន់ សំកុល** ព្រមទាំងបុត្រ ១៣.០០០ ៛

ឧ.សិ **ខឿន**

១៣.០០០ ៛

ឧ.ស **អួន** និង ឧ.សិ **ឡឿន** ១៣.០០០ ៛

ឧ.ស **ប៊ុន** និង ឧ.សិ **ទូច** ១៣.០០០ ៛

ឧ.ស **សាយ ប្រាក់** និង ឧ.សិ **សៅ ណាន់** ១៣.០០០ ៛

ឧ.ស **ញ៉ូក** និងឧ.សិ **ហ៊ុយ** ១៣.០០០ ៛

ឧ.សិ **ភាន** ព្រមទាំងបុត្រ ១២.០០០ ៛

ឧ.ស **ច្រឹង សេងហ៊ួន** ឧ.សិ **អុង គឹមសួ** ព្រមទាំងបុត្រ ១២.០០០ ៛

ឧ.សិ **គួយ អាំងគ** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.ស **ឡឿ ស៊ុន** និង ឧ.សិ **តុល ឡៀក** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.ស **វ៉ាត ហ៊ុន** និង ឧ.សិ **សឹម ចឹម** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.សិ **ប៉ុល ណាត់** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.សិ **ភួង សំអាត** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.សិ **យូ អេង លី** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.សិ **ឌិន សំ** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.សិ **ទឹម ឡៀង** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.ស **ថៃ** ព្រមទាំងបុត្រ ១០.០០០ ៛

ឧ.ស **ទេស ជួន** និង ឧ.សិ **យាយ សន** ១០.០០០ ៛

ឧ.សិ **ម៉ែន** ១០.០០០ ៛

ឧ.សិ **ថ្វាត់** ១០.០០០ ៛

ឧ.សិ **ប៊ិច** ១០.០០០ ៛

ឧ.ស **យ៉ិន** និង ឧ.សិ **យ៉េម** ១០.០០០ ៛

ឧ.ស **ប៊ូ** និង ឧ.សិ **សេម** ១០.០០០ ៛

ឧ.ស **ត្រ** និង ឧ.សិ **សាំ** ១០.០០០ ៛

ឧ.ស **ម៉ុម លន់** និង ឧ.សិ **អ៊ុម សឿន** ១០.០០០ ៛

ឧ.សិ **ម៉ុក យឿន** ១០.០០០ ៛

ឧ.សិ **ឆ្នួន សារី** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.សិ **តេខ ម៉ុស** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.សិ **ប៉ុល សន** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.សិ **សៀក មួយដូ** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.សិ **ឆ្នួន អ៊ុត** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.សិ **កែវ ម៉ៃ** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.ស **កេះ កេត** និង ឧ.សិ **អាខ សុវណ្ណា** ព្រមទាំងបុត្រ ៥.០០០ ៛

ឧ.ស **ឆាយ ប្រុស** និង ឧ.សិ **មាន សារិទ្ធ** ព្រមទាំងកូនចៅ ៥.០០០ ៛

ឧ.សិ **យ៉ាខ អាន**

៥.០០០ ៛

ឧ.សិ **ម៉ុល** ៥.០០០ ៛

ឧ.ស **ស្នួខ** និង ឧ.សិ **ទូច** ៥.០០០ ៛

ឧ.ស **មាស** និង ឧ.សិ **យ៉ាន** ៥.០០០ ៛

ឧ.ស **ឆាន** និង ឧ.សិ **ពៅ** ៥.០០០ ៛

ឧ.ស **លឹម ញៀន** ៣.០០០ ៛

ឧ.សិ **ខៀវ យ៉ន** ១.៥០០ ៛

ឧ.សិ **ម៉ុម គុំ** ១.០០០ ៛

ឧ.សិ **ឈាន** ១.០០០ ៛

ពុទ្ធបរិស័ទចំណោះជើង **វត្តបឹងខ្លារ** ខេត្តកំពង់ស្ពឺ ១៣៥.៨០០ ៛

# សប្បុរសជនក្រុមសាកច្ឆាធម៌ផ្សារដេប៉ូ

ឧ.សិ **អមរា ទេវ** ១០០ $

ឧ.ស **ជា ហួន** ៥០ $

ឧ.ស **គីម ហ៊ុច** ២៥ $

ឧ.ស **ថៃ៉ត សុភ័ណ** ២៥ $

ឧ.ស **សេន សំណាង** និង ភរិយា ២៥ $

ឧ.សិ **ជុំ ចាន់ធី** និងក្រុមញាតិព្រះធម៌ ២០ $

ឧ.សិ **សយ សុធា** ១០ $

ឧ.សិ **ស៊ីន សុវណ្ណនីតា** ១០ $

ឧ.សិ **គីម សុផាន** ៥ $

ឧ.សិ **សាន** ៥ $

ឧ.សិ **រ័ត្ន គីមឆុន** ៥ $

ឧ.សិ **សូ យឿន** ៥ $

ឧ.ស **អ៊ុល** ៥ $

ឧ.សិ **ស៊ីនួន ដេវត** ៥ $

៚៚៚៚៚ សាធុ ! សូមអនុមោទនា ៙៙៙៙៙


ពិភពលោកភ្លឺស្វាង
ដោយព្រះអាទិត្យ
ចិត្តភ្លឺស្វាងពិតដោយបញ្ញា
កំណត់ត្រៃលក្ខណ៍ក្នុងសង្ខារ
ចិត្តស្ងប់ទុក្ខាប្រាកដហោង ៗ